ឯកសារព័ត៌មាន

ផ្សាយនៅលើគេហទំព័រ និងបណ្តាញទំនាក់ទំនងសង្គម

របស់អាជ្ញាធរជាតិអប្សរា

ប្រចាំឆ្នាំ២០១៨



info@apsaraauthority.gov.kh

www.apsaraauthority.gov.kh

www.facebook.com/apsaraautorite

www.youtube.com/apsara authority

អារម្ភកថា

សកម្មភាពដែលបានធ្វើហើយ វាបានកន្លងទៅជាមួយនឹងពេលវេលា។ មានតែការកត់ត្រាទុកប៉ុណ្ណោះ ដែលអាចជួយឲ្យយើងនឹកឃើញសកម្មភាពទាំងនោះឡើងវិញ។ ឯកសារខ្លះមានតម្លៃត្រឹមជាឯកសារយោងសម្រាប់ការងារក្រោយៗទៀត ប៉ុន្តែឯកសារខ្លះ គឺមានតម្លៃជាប្រវត្តិសាស្ត្រ ដែលអាចជាមេរៀនសម្រាប់ក្មេងជំនាន់ក្រោយៗទៀត។

នាយកដ្ឋានផ្សព្វផ្សាយនៃអាជ្ញាធរជាតិអប្សរា បានកត់ត្រានិងផ្សព្វផ្សាយជាប្រចាំនូវរាល់សកម្មភាពរបស់ថ្នាក់ដឹកនាំ និងសកម្មភាពការងារនៃអាជ្ញាធរជាតិអប្សរា តាមរយៈបណ្តាញទំនាក់ទំនងសង្គម គេហទំព័រ និងចែកចាយទៅតាមបណ្តាញសារព័ត៌មានជាដៃគូជាច្រើនទៀត។ ឯកសារទាំងនេះ បានជ្រួតជ្រាបដល់មហាជនទាំងក្នុងឧទ្យានអង្គរ និងមហាជនទូទៅ និងបានបង្កើនការយល់ដឹងជំរុញឲ្យមានចូលរួមអភិរក្សបេតិកភណ្ឌទៀតផង។

ដើម្បីឲ្យឯកសារទាំងនេះកាន់តែមានប្រយោជន៍សម្រាប់ជាឯកសារយោង និងជាឯកសារស្រាវជ្រាវបន្តទៀតនោះ នាយកដ្ឋានផ្សព្វផ្សាយបានរៀបចំបោះពុម្ពនូវអត្ថបទផ្សព្វផ្សាយទាំងអស់ ជាសៀវភៅទុកជាឯកសារតម្កល់ប្រចាំឆ្នាំ។ ឯកសារទាំងនេះ ត្រូវបានដាក់រៀងតាមខែនីមួយៗ ហើយនៅខាងចុងនៃសៀវភៅមានឧបសម្ព័ន្ធ ដែលអាចជួយឲ្យអ្នកអានងាយស្វែងរកអត្ថបទដែលត្រូវការ។

អត្ថបទដែលមានក្នុងសៀវភៅនេះនិយាយអំពី សកម្មភាពថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា កិច្ចសហប្រតិបត្តិការអន្តរជាតិ ការអភិរក្ស និងជួសជុល ការគ្រប់គ្រងបរិស្ថាន ទឹក និងព្រៃឈើ ការបណ្តុះបណ្តាល ការសិក្សាស្រាវជ្រាវ ការអភិវឌ្ឍទេសចរណ៍ ការអភិវឌ្ឍសហគមន៍ ពិធីទំនៀមទម្លាប់អ្នកស្រុកអង្គរ និងអត្ថបទផ្សេងៗទៀតដែលទាក់ទងនឹងចំណេះដឹងអំពីបេតិកភណ្ឌពិភពលោកអង្គរ។

នាយកដ្ឋានផ្សព្វផ្សាយនៃអាជ្ញាធរជាតិអប្សរាសង្ឃឹមថា សៀវភៅនេះនឹងបានជាប្រយោជន៍ដល់អ្នកស្រាវជ្រាវ និងសាធារណជនទូទៅដែលចង់ដឹងអំពីសកម្មភាពរបស់អាជ្ញាធរជាតិអប្សរា ក៏ដូចជាប្រពៃណីទំនៀមទម្លាប់របស់អ្នកស្រុកអង្គរ។

ទោះជាក្រុមការងារបានធ្វើការងារនេះ ដោយសម្រិតសម្រាំង និងប្រុងប្រយ័ត្នខ្ពស់យ៉ាងណាក្តី កំហុសដោយអចេតនាផ្នែកអក្ខរាវិរុទ្ធ ឬកំហុសបច្ចេកទេសណាមួយច្បាស់ជាកើតមានឡើងជាក់ជាមិនខាន។ នាយកដ្ឋានផ្សព្វផ្សាយសូមខន្តីអភ័យទោសអំពីសំណាក់អ្នកអានទាំងអស់ចំពោះកំហុសឆ្គងទាំងនោះ ហើយរង់ចាំការរិះគន់ក្នុងន័យស្ថាបនាដោយសេចក្តីសប្បាយរីករាយ។

ថ្ងៃ ចន្ទ ១៤កើត ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
សៀមរាប ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១៩

ប្រធាននាយកដ្ឋានផ្សព្វផ្សាយ

ឡុច កុសល

មាតិកា

ចំណងជើងព័ត៌មាន **លេខទំព័រ**

អារម្ភកថា..... i

មាតិកា..... iii

ឧបសម្ពន្ធ..... ៣១៩

ផ្នែកទី ១

ប្រចាំខែមករា

- ឆ្នាំ២០១៧កន្លងទៅនេះអាជ្ញាធរជាតិអប្សរាបានឧបត្ថម្ភស្ត្រីទើបសម្រាលកូនរួចក្នុងតំបន់អង្គរ ១
- បានចំនួនជាង៦០០គ្រួសារ និងអនុញ្ញាតការសាងសង់ និងជួសជុលតូចៗបានចំនួនជិត៥០០ករណី ១
- ដំណើរវិវឌ្ឍនៃការងារជួសជុលស្ពានហាលខាងលិចប្រាសាទអង្គរវត្ត ២
- អបអរសាទរ! ប្រាសាទអង្គរវត្តរបស់ខ្មែរជាប់ចំណាត់ថ្នាក់លេខ១ជាសំណង់ប្រវត្តិសាស្ត្រដ៏អស្ចារ្យបំផុត និងចំណាត់ថ្នាក់លេខ៨ជាគោលដៅទេសចរណ៍លើពិភពលោកក្នុងឆ្នាំ២០១៧ .....៤
- ប្រជាពលរដ្ឋនៅភូមិធម្មជាតិរុនតាឯករីករាយចំពោះការរីកចម្រើនកម្រិតជីវភាពនាពេលបច្ចុប្បន្ន ៥
- ចម្លាក់ទ្វារបាលរកឃើញនៅប្រាសាទទន្លេស្ងួតកំពុងទទួលបានការជួសជុលពីអ្នកជំនាញអាជ្ញាធរជាតិអប្សរា ៧
- អ្នកស្រាវជ្រាវបុរាណវិទ្យាអន្តរជាតិចែករំលែកចំណេះដឹងទាក់ទងនឹងប្រវត្តិសាស្ត្រនិងបច្ចេកទេសសំយោគលោហៈដល់សាធារណជននៅអាជ្ញាធរជាតិអប្សរា ៨
- ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរាចូលរួមគោរពវិញ្ញាណក្ខន្ធ អតីតយុទ្ធជននៅក្នុងឱកាសរំឭកខួបលើកទី៣៩ នៃទិវាជ័យជម្នះ៧មករា (៧.០១.១៩៧៩-៧.១.២០១៨) ៩
- អាជ្ញាធរជាតិអប្សរា ៖ ស្វែងយល់ពីរបៀបជួសជុលបំណែកកុលាលភាជន៍ខ្មែរបុរាណ ១០
- គណៈកម្មការចម្រុះអាជ្ញាធរជាតិអប្សរានិងសាលាខេត្តសៀមរាប ចុះបោះបង្គោលកំណត់ព្រំដីកម្មសិទ្ធិរបស់រដ្ឋ ១២
- សម្រស់ដ៏ត្រកាលនៃទិដ្ឋភាពថ្ងៃរះពីលើប្រាសាទភ្នំបាខែង ១៣
- ម្រោងសុវុឌ្ឍិកម្មនៃការសម្អាតទឹក និងការគ្រប់គ្រងទឹកក្នុងតំបន់អង្គរបង្ហាញលទ្ធផលជាវិជ្ជមានជុំវិញគម្រោងសាកល្បងទីផ្សារអនាម័យនៅតំបន់អង្គរ ១៥
- ប្រតិភូរដ្ឋសភាសាធារណរដ្ឋកូរ៉េទស្សនៈកិច្ចនៅអាជ្ញាធរជាតិអប្សរាស្វែងយល់គម្រោងជួសជុលប្រាសាទព្រះពិធូរ ២០
- អាជ្ញាធរជាតិអប្សរាទទួលលទ្ធផលល្អប្រសើរពីការធ្វើសវនកម្មប្រព័ន្ធគ្រប់គ្រងបរិស្ថាន-អង្គរ ២៣
- អាជ្ញាធរជាតិអប្សរានិងសហភាពសហព័ន្ធយុវជនកម្ពុជាជួបពិភាក្សាអំពីការរៀបចំព្រឹត្តិការណ៍អង្គរសង្ក្រាន្តឆ្នាំថ្មីនៅរមណីយដ្ឋានអង្គរ ២៦
- ការសិក្សាផ្នែកបុរាណវិទ្យានិងវិទ្យាសាស្ត្រ បានយល់ស្របគ្នាថាការផលិតកុលាលភាជន៍ខ្មែរនៅតំបន់អង្គរចាប់ផ្តើមពីសតវត្សរ៍ទី៩ គ.ស. ២៧
- គណៈប្រតិភូអាជ្ញាធរជាតិអប្សរាបំពេញទស្សនកិច្ចនៅប្រទេសជប៉ុនដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការ

លើផ្នែកជួសជុលនិងអភិរក្សអង្គរ ២៩
- ប្រតិភូអាជ្ញាធរជាតិអប្សរាជួបពិភាក្សាបច្ចេកទេសលម្អិតពីគម្រោងជួសជុលស្ពានហាលអង្គរវត្ត
និងស្វែងយល់ពីការជួសជុលស្ពានបុរាណ និងវិមានបុរាណនៅប្រទេសជប៉ុន ៣២
- ក្រុមគណៈកម្មការចម្រុះរុះរើ និងបញ្ឈប់សកម្មភាពបំពានលើដីកម្មសិទ្ធិរបស់រដ្ឋ ៣៥

ផ្នែកទី ២

ប្រចាំខែកុម្ភៈ

- ខែមករាដើមឆ្នាំ២០១៨នេះអាជ្ញាធរជាតិអប្សរាអនុញ្ញាតការជួសជុលសំណង់តូចៗ
ជូនប្រជាពលរដ្ឋជាង៥០ករណី ៣៧
- រឿង ព្រះនាងកែវប្រាំពីរពណ៌ បានចេញផ្សាយហើយ! ៣៨
- គណៈកម្មការចម្រុះ ចុះបញ្ឈប់សកម្មភាពបំពាននិងរុះរើសំណង់ខុសច្បាប់លើកម្មសិទ្ធិដីរដ្ឋជាលើកទី២ ..... ៣៩
- ក្រុមបាល់ទាត់អាជ្ញាធរជាតិអប្សរាទទួលបានជើងឯករងក្នុងពានរង្វាន់រដ្ឋបាលខេត្តសៀមរាប
រដូវកាលទី៣ ..... ៤០
- អ្នកជំនាញមកពី១៧ប្រទេសជួបជុំគ្នានៅអង្គរ ដើម្បីពិភាក្សាគ្នាអំពីការគ្រប់គ្រងទេសចរណ៍
ក្នុងតំបន់បេតិកកណ្ឌពិភពលោក ៤១
- សំណង់តូចតាចចំនួន៤៧៥ករណីត្រូវបានអនុញ្ញាតឱ្យសាងសង់
និងជួសជុលនៅក្នុងឧទ្យានអង្គរនាឆ្នាំ២០១៧ ..... ៤៣
- កាសែត Le Monde ដ៏ល្បីរបស់បារាំងកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែងរបស់អាជ្ញាធរជាតិអប្សរា
ក្នុងតំបន់បេតិកកណ្ឌអង្គរ ៤៤
- សន្និបាតបូកសរុបលទ្ធផលការងារវប្បធម៌ និងវិចិត្រសិល្បៈ ៤៥
- បេតិកកណ្ឌអូរបីៈ រកត្រីត្រៀមឡើងមាយ ជាទំនៀមបុរាណរបស់អ្នកស្រុកអង្គរ! ៤៦
- មន្ត្រីជំនាញគ្រប់គ្រងទេសចរណ៍ក្នុងតំបន់បេតិកកណ្ឌបង្ហាញអារម្មណ៍ទាំងភ្ញាក់ផ្អើល
និងងឿងឆ្ងល់លើដំណើរការគ្រប់គ្រងរមណីយដ្ឋានអង្គរ ៤៧
- លោកជំទាវ ម៉ែន សំអន អំពាវនាវឱ្យពលរដ្ឋនិងវិស័យឯកជន «កុំឱ្យវិស័យទេសចរណ៍
បំពានលើវប្បធម៌ ត្រូវយកវប្បធម៌ ដើម្បីពង្រីកវិស័យទេសចរណ៍» ៤៩
- អ្នកជំនាញបុរាណវិទ្យា៤ស្ថាប័នបញ្ចប់វគ្គសិក្សាអំពីការរៀបចំផែនការរមេ
នៃសំណង់ប្រាសាទបុរាណក្នុងតំបន់អង្គរ ៥០
- ភ្នាក់ងារទេសចរក្នុងតំបន់អង្គរទទួលបានការបណ្តុះបណ្តាលវគ្គសង្គ្រោះបឋមពីអ្នកជំនាញជប៉ុន ៥២
- អាជ្ញាធរជាតិអប្សរាគ្រោងចាប់ដៃគូសហការជាមួយមជ្ឈមណ្ឌលស្រាវជ្រាវកសិកម្មធម្មជាតិមួយនៅប្រទេសកូរ៉េ
ដើម្បីពង្រឹងវិស័យកសិកម្មនៅភូមិធម្មជាតិរុនតាឯក ៥៤
- អាឡឺម៉ង់បន្តបំប៉នសមត្ថភាពការងារអភិរក្សថ្មដល់មន្ត្រីជំនាញអាជ្ញាធរជាតិអប្សរា ៥៥
- ទំនៀមលៀងមេមត់ ជាផ្នែកមួយនៃការរស់នៅរបស់ប្រជាជនក្នុងតំបន់អង្គរដោយមិនអាចខ្វះបាន! ៥៦
- សេចក្តីជូនដំណឹងស្តីពី ៖ ការកាត់សម្អាតដើមឈើ កាត់ក្រឹមែកឈើ និងអារច្រៀកដើមឈើ

នៅតាមបរិវេណប្រាសាទ និងតាមភូមិនានាក្នុងរមណីដ្ឋានអង្គរ ៥៩
- មូលនិធិបេតិកភណ្ឌវប្បធម៌កូរ៉េបើកសិក្ខាសាលាលើកទី២ស្តីអំពី «កិច្ចអភិរក្សប្រាសាទព្រះពិធូរ» ៦០
- សកម្មភាពដើមខែទី១ ឆ្នាំ២០១៨ របស់ភ្នាក់ងារទេសចរណ៍អាជ្ញាធរជាតិអប្សរាសង្គ្រោះភ្ញៀវ
និងប្រគល់របស់ជូនភ្ញៀវវិញ ៦១
- ពលរដ្ឋនៅភូមិព្រះដាក់យកភាជន៍បុរាណប្រគល់ឱ្យសារមន្ទីរព្រះនរោត្តម សីហនុ-អង្គរ ៦២

ផ្នែកទី ៣
ប្រចាំខែមីនា

- សេចក្តីជូនដំណឹងស្តីពីការសាងសង់កម្រាលក្តារនៅតាមផ្លូវរង់ទស្សនា និងជុំវិញដើមឈើ សម្រាប់ភ្ញៀវជាតិ-អន្តរជាតិ
ដើរទស្សនា ដើម្បីបញ្ឈប់ការដើរលើដីជាន់ឫស និងគល់ដើមឈើតទៅទៀតនៅក្នុងបរិវេណប្រាសាទតាព្រហ្ម..... ៦៥
- កីឡាការិនីជិត២០០នាក់ចូលរួមព្រឹត្តិការណ៍កីឡា RAID Amazones ជាលើកទី២នៅទឹកដីអង្គរ..... ៦៦
- សហគមន៍អ្នកប្រើប្រាស់ទឹកបារាយណ៍ទឹកថ្លាធ្វើការជ្រើសរើសប្រធានថ្មី
ក្រោមការសម្របសម្រួលអាជ្ញាធរជាតិអប្សរា ៦៨
- បុរាណវិទូ៦ប្រទេសបានទទួលការបណ្តុះបណ្តាលស្តីអំពីថ្មនិងកុលាលភាជន៍នៅអាជ្ញាធរជាតិអប្សរា ៧០
- ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរាយកបទពិសោធន៍គ្រប់គ្រងរមណីយដ្ឋានអង្គរ
ទៅបង្រៀននិស្សិតនៅប្រទេសជប៉ុន ៧៣
- អាជ្ញាធរជាតិអប្សរារៀបចំពិធីគោរពវិញ្ញាណក្ខន្ធសម្តេចវិបុលបញ្ញា សុខ អាន នៅស្នាក់ការកណ្តាល
ដើម្បីរំឭកខួប១ឆ្នាំនៃរមណភាព ៧៥
- តំណាងលោកជំទាវប្រធានអាជ្ញាធរជាតិអប្សរាទៅសួរសុខទុក្ខមន្ត្រីដែលជួបឧបទ្ទវហេតុគ្រោះថ្នាក់ចរាចរណ៍ ៧៦
- សេចក្តីជូនដំណឹង ស្តីពីព្រឹត្តិការណ៍សមរាត្រីនៅប្រាសាទអង្គរវត្ត ៧៧
- ប្រធានអាជ្ញាធរជាតិអប្សរាសម្តែងការសោកស្តាយចំពោះឧបទ្ទវហេតុអគ្គីភ័យនៃសាលមហោស្រពអង្គរ
និងសន្យាជ្រោមជ្រែងតាមលទ្ធភាពក្នុងការជួសជុលឡើងវិញ ៧៧
- រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈចុះត្រួតពិនិត្យការត្រៀមសម្ភោធសារមន្ទីរធម្មជាតិសកល
សម្តេចតេជោហ៊ុនសែនព្រះវិហារ ៧៨
- លោកជំទាវ ម៉ែន សំអន និងលោកជំទាវ ភឿងសកុណា ដឹកនាំមន្ត្រីរាជការ សប្បុរសជននិងអ្នកជំនាញ
ធ្វើពិធីប្រុងពលីបើកការដ្ឋានជួសជុលប្រាសាទចតុមុខនៃក្រុមប្រាសាទបាកាណ(ព្រះខ័ន្ធកំពង់ស្វាយ)
នៅខេត្តព្រះវិហារ ៧៩
- គណៈកម្មាធិការអាយស៊ីស៊ី-ព្រះវិហារ បើកកិច្ចប្រជុំពេញអង្គលើកទី៤ផ្តោតលើការជួសជុលប្រាសាទព្រះវិហារ ៨១
- លោកជំទាវប្រធានអាជ្ញាធរជាតិអប្សរាជួបពិភាក្សាជាមួយស្ថាប័នអន្តរជាតិដែលកំពុងបំពេញការងារ
នៅក្នុងរមណីយដ្ឋានអង្គរ ៨៣
- អាជ្ញាធរជាតិអប្សរាសម្រេចបង្កើត គណៈកម្មការដឹកនាំនិងសម្របសម្រួល
រៀបចំសណ្តាប់ធ្នាប់អ្នកលក់ដូរក្នុងរមណីយដ្ឋានអង្គរ ៨៥
- ជាងឈើ ជាងចម្លាក់ និងសិល្បៈករអន្តរជាតិជាង១០០ប្រទេស

ចូលរួមដាំដើមឈើនៅបរិវេណប្រាសាទប្រិយ៍ ៨៦
- អាជ្ញាធរជាតិអប្សរាកំពុងជួសជុលកំណាត់ផ្លូវវង់ធំដើម្បីសម្រួលចរាចរណ៍ឱ្យប្រសើរជាងមុន ៨៧
- ឆ្នាំ២០១៧ ក្រុមការងាររលេខាធិការដ្ឋានសហគមន៍អាជ្ញាធរជាតិអប្សរាបានអនុញ្ញាតឱ្យប្រជាពលរដ្ឋ
ក្នុងតំបន់អង្គរសោងសង់និងជួសជុលតូចតាចចំនួន៤៧៥ករណី ៨៩
- ជនសង្ស័យកាប់បំផ្លាញសិវលិង្គចំនួន៦នៅភ្នំគូលែនត្រូវបានចាប់មកផ្តន្ទាទោសហើយ! ៩០
- ចម្លាក់តោនៅប្រាសាទក្រវ៉ាន់ចំនួនមួយត្រូវបានតម្កល់ទុកនៅកន្លែងដើមវិញ
ក្រោយជួសជុលអស់ រយៈពេលមួយឆ្នាំ ៩២

ផ្នែកទី ៤

ប្រចាំខែមេសា

- សកម្មភាពរៀបចំព្រឹត្តិការណ៍អង្គរសង្ក្រាន្តឆ្នាំថ្មី ឆ្នាំច សំរឹទ្ធស័ក ព.ស. ២៥៦២ ..... ៩៥
- ព្រះពុទ្ធបដិមាទ្រង់អភ័យមុទ្រៈចំនួន២អង្គនៅប្រាសាទប្រែរូបកំពុងទទួលបានការជួសជុល ៩៦
- អាជ្ញាធរជាតិអប្សរា និងសារមន្ទីរសិល្បៈអាស៊ី ហ្គីមេ ចុះអនុស្សរណៈលើការបណ្តុះបណ្តាល
និងចងក្រងពាក្យសិល្បៈ និងបេតិកភណ្ឌ ៩៧
- អាជ្ញាធរជាតិអប្សរារៀបចំសមាហរណកម្មបុគ្គលិកអចិន្ត្រៃយ៍ជាមន្ត្រីរាជការ ១០០
- បុរាណវិទូបញ្ជាក់ពីមូលហេតុដែលហ៊ានសន្និដ្ឋានថា ការកំណាយឃើញបុរាណដ្ឋាននៅលើភ្នំគូលែន
អាចជាអតីតរាជវាំងឬរាជដំណាក់របស់ព្រះបាទជ័យវរ្ម័នទី២ក្នុងសតវត្សទី៩ ..... ១០៣
- ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរារៀបចំពិធីសូត្រមន្តលើកវាសីអបអរសាទរបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ១០៥
- សេចក្តីជូនដំណឹងស្តីពី៖ ការបើកឲ្យប្រើប្រាស់ស្ពានហាលប្រាសាទអង្គរវត្ត
ពីថ្ងៃទី១២ដល់ទី១៧ ខែមេសា ឆ្នាំ២០១៨ ..... ១០៦
- សេចក្តីជូនដំណឹងស្តីពីការពង្វាងការចូលទស្សនាប្រាសាទមួយចំនួនក្នុងព្រឹត្តិការណ៍អង្គរសង្ក្រានឆ្នាំ២០១៨ ..... ១០៧
- ភូមិខ្ញុំសង្ក្រាន្តឆ្នាំថ្មីបង្ហាញទិដ្ឋភាពពីរសម័យកាលនៃសង្គមខ្មែរ ១០៨
- លោកជំទាវរដ្ឋមន្ត្រី ភឿង សកុណា អញ្ជើញទៅពិនិត្យការក្រាលក្តារលើឫសឈើនៅប្រាសាទតាព្រហ្ម ១០៩
- តើដឹងទេថាស្ពានបុរាណតាមបណ្តោយផ្លូវជាតិលេខ៦ពីប្រាសាទបាគងដល់ទីប្រជុំជនកំពង់ក្តី
មានចំនួនប៉ុន្មាន? ១១០
- ប្រជាពលរដ្ឋ៥ភូមិក្នុងតំបន់អង្គរទទួលបានប្រឡាយថ្មីមួយខ្សែសម្រាប់ប្រើប្រាស់ក្នុងរដូវប្រាំង ១១៣
- សមត្ថកិច្ចចម្រុះចុះទប់ស្កាត់ការទន្ទ្រានព្រៃឈើក្នុងឧទ្យានអង្គរ ១១៤
- សេចក្តីជូនដំណឹងស្តីពីការកំណត់រយៈពេលនៃការបង់ថ្លៃសេវាសាធារណៈស្តីពីការគ្រប់គ្រងប្រាក់ចំណូល
ផ្សេងៗក្នុងតំបន់រមណីយដ្ឋានអង្គរតាមគណៈរបស់អាជ្ញាធរជាតិអប្សរានៅធនាគាជាតិនៃកម្ពុជា
សាខាខេត្តសៀមរាប ១១៦
- ក្រុមការងាររបស់អាជ្ញាធរជាតិអប្សរាកំពុងដំណើរការកំណាយស្រះនៅប្រាសាទអង្គរវត្ត ១១៦
- សេចក្តីជូនដំណឹងស្តីពីការកាត់ដកហូតដើមឈើ និងកាត់ក្រឹមែកឈើដែលមានហានិភ័យខ្ពស់
នៅតាមបរិវេណប្រាសាទ ក្នុងរមណីដ្ឋានអង្គរ ១១៨

– កុលាលភាជន៍ចំនួន៦៤វត្ថុ ផលិតក្នុងសម័យអង្គរមកពីខេត្តបុរីរម្យត្រូវបានប្រគល់ជូន
អាជ្ញាធរជាតិអប្សរារក្សាទុក! ១១៨

ផ្នែកទី ៥ 121

ប្រចាំខែឧសភា

– អាជ្ញាធរជាតិអប្សរានិងប្រជាមានិតចិនគ្រោងចុះអនុស្សារណៈ
ស្តីពីការចងសម្ពន្ធភាពតំបន់បេតិកភណ្ឌអង្គរនិងខេត្តសានស៊ី ១២១
– យុវជនស្ម័គ្រចិត្តបេតិកភណ្ឌបន្ទាយឆ្មារចែករំលែកបទពិសោធន៍ការងារ
ដល់សិស្សានុសិស្សវិទ្យាល័យស្រះស្រង់ ១២២
– សេចក្តីជូនដំណឹង ១២៥
– អាជ្ញាធរជាតិអប្សរាបើកវគ្គបណ្តុះបណ្តាល "កម្មវិធីអប់រំបេតិកភណ្ឌ"
ដល់កុមារនៅសាលាបឋមសិក្សាស្រះស្រង់ ១២៦
– សារមន្ទីរវាយនកណ្ឌបើកឱ្យទស្សនាដោយឥតគិតថ្លៃក្នុងថ្ងៃទិវាសារមន្ទីរអន្តរជាតិ ១២៧
– អាជ្ញាធរជាតិអប្សរា និងសារមន្ទីរវដ្ឋធានីរបស់ចិន ចុះអនុស្សរណៈយោគយល់គ្នាបង្កើត
ទំនាក់ទំនងគ្នាលើការងារសារមន្ទីរ ១២៨
– ភូមិធម្មជាតិរុនតាឯកទទួលបានការឧបត្ថម្ភអគារសិក្សាមួយខ្នង
ពីអង្គការ ARK Beautiful Earth for Children ១៣០
– ប្រជាជននៅភូមិត្រាច ស្រុកប្រាសាទបាគង ទទួលបានការបណ្តុះបណ្តាលស្តីពីសុវត្ថិភាព
នៃការប្រើប្រាស់ថ្នាំគីមីលើដំណាំកសិកម្ម ១៣១
– អង្គភាពគ្រប់គ្រងបរិស្ថានអង្គរនៃអាជ្ញាធរជាតិអប្សរា ទើបនឹងទទួលបានវិញ្ញាបនបត្រថ្មីពីស្តាប់ន JQA ១៣២
– ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា នាំយកអំណោយសង្គ្រោះបឋមជូនដល់ប្រជាពលរដ្ឋរងគ្រោះធម្មជាតិ
នៅឃុំបាគង ១៣៤
– សប្បុរសជនខ្មែរក្នុងស្រុកដំបូងៗចូលរួមបណ្តុះពូជអ្នកអភិរក្សបេតិកភណ្ឌអង្គរ ១៣៥
– ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចុះពិនិត្យសំណើរសាងសង់
និងនាំយកអំណោយជូនប្រជាជនរងគ្រោះដោយសារខ្យល់ព្យុះនៅក្នុងឧទ្យានអង្គរ ១៣៧
– អបអរសាទរ!ប្រាសាទអង្គរវត្តជាប់ចំណាត់ថ្នាក់លេខ១ជាសំណង់ប្រវត្តិសាស្ត្រដ៏អស្ចារ្យបំផុត
លើពិភពលោកក្នុងឆ្នាំ២០១៨ ..... ១៣៨
– អាជ្ញាធរជាតិអប្សរាបើកវគ្គបណ្តុះបណ្តាលស្តីអំពីលំនាំសំខាន់ៗនៃស្ថាបត្យកម្មខ្មែរ និងបដិមាសាស្ត្របុរាណ ១៤០
– អាជ្ញាធរជាតិអប្សរាបានដឹកនាំសប្បុរសជនចែកអំណោយជូនប្រជាពលរដ្ឋក្រីក្រ
នៅតំបន់អង្គរជិត២០០គ្រួសារ ១៤២
– អ្នកស្រុកអង្គរចំនួន១៣៨គ្រួសារទទួលបានការអនុញ្ញាតឱ្យសាងសង់
និងជួសជុលសំណង់ស្រាលក្នុងខែឧសភា ១៤៤

ផ្នែកទី ៦

ប្រចាំខែមិថុនា

- គណៈកម្មាធិការអាយស៊ីស៊ី-អង្គរនឹងបើកកិច្ចប្រជុំបច្ចេកទេសលើកទី៣០របស់ខ្លួន នៅថ្ងៃទី០៥-០៦ ខែមិថុនា ឆ្នាំ២០១៨ ..... ១៤៧
- កម្មវិធីបណ្តុះគំនិតកុមារថែរក្សាបរិស្ថានអង្គរជាផ្នែកមួយជំរុញអោយការគ្រប់គ្រងបរិស្ថាន ក្នុងឧទ្យានអង្គរមាននិរន្តរភាព ១៤៨
- អាយស៊ី-ស៊ីអង្គរ៖ ការងារថែរក្សានិងអភិវឌ្ឍន៍រមណីយដ្ឋានអង្គរកាន់តែទទួលបានជោគជ័យ ១៥០
- កិច្ចប្រជុំបច្ចេកទេសលើកទី៣០នៃគណៈកម្មការអាយស៊ីស៊ី-អង្គរបញ្ចប់ដោយលើកពីវឌ្ឍនភាពនៃការងារ និងធនធានមនុស្សរបស់អ្នកជំនាញខ្មែរលើកិច្ចការជួសជុលនិងអភិរក្សសម្បត្តិបេតិកភណ្ឌពិភពលោក ក្នុងតំបន់អង្គរ ១៥១
- អាជ្ញាធរជាតិអប្សរានឹងចាត់វិធានការយ៉ាងតឹងរឹងចំពោះការបង្ហោះ Drone នៅក្នុងតំបន់រមណីយដ្ឋានអង្គរ ១៥៤
- អាជ្ញាធរជាតិអប្សរាចុះ អនុស្សារណៈយោគយល់ជាមួយអាជ្ញាធរDASTAរបស់ប្រទេសថៃ ស្តីពីការអភិវឌ្ឍទេសចរណ៍ប្រកបដោយចីរភាព ១៥៧
- សារលិខិតថ្វាយព្រះពរសម្តេចព្រះមហាក្សត្រក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ១៥៨
- ដំឡូងដៃខ្លា ជាដំណាំប្រពៃណីដែលបានលើកកម្ពស់ជីវភាពរបស់អ្នកភូមិពាមបានយ៉ាងប្រសើរ ១៦០
- អាជ្ញាធរជាតិអប្សរាបើកវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រី និងបុគ្គលិកលើជំនាញផលិតវីដេអូ និងបទយកការណ៍ ១៦១
- ពិធីចុះហត្ថលេខានេះ ត្រូវបានអញ្ជើញជាអធិបតីដោយ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងលោកជំទាវ Gao Yan អនុរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មចិន ១៦៣
- អាជ្ញាធរជាតិអប្សរាបំភ្លឺទៅបណ្តាញសង្គមអំពីអក្សរបរទេសនៅលើឋប្រាសាទអង្គរវត្ត ១៦៨
- សេចក្តីជូនដំណឹង ការបង្ហោះ និងដាក់ដំណើរការទម្រង់ថ្មីនៃគេហទំព័រទេសចរណ៍ www.angkor.com.kh ១៦៥
- សេចក្តីជូនដំណឹងស្តីពី ការបង្វែរទិសចរាចរណ៍ នៅមុខអង្គរវត្ត ក្នុងពិធីលែងកូនត្រី នៃទិវាមច្ឆាជាតិនៅថ្ងៃទី ០១ ខែកក្តដា ឆ្នាំ២០១៨ ..... ១៦៧
- សេចក្តីជូនដំណឹងស្តីពី ការកាត់ដកហូតដើមឈើ និងកាត់ក្រឹមែកឈើដែលបង្កហានិភ័យខ្ពស់ ស្ថិតនៅក្នុងបរិវេណប្រាសាទបន្ទាយស្រី ១៦៨
- រមណីយដ្ឋានអង្គរនឹងបង្កើនបណ្តាញប្រព័ន្ធទូរសព្ទកាន់តែទូលំទូលាយ ១៦៩
- ពិធីបិទគម្រោងអប់រំបេតិកភណ្ឌសម្រាប់កុមារប្រចាំឆ្នាំ២០១៨នៅបន្ទាយឆ្មារ ១៧០
- ចាប់ពីឆ្នាំ២០០០មក ការងារជួសជុលប្រាសាទក្នុងតំបន់រលួសមានការវិវត្តអ្វីខ្លះ? ១៧៣

ផ្នែកទី ៧

ប្រចាំខែកក្កដា

- អាជ្ញាធរជាតិអប្សរាបើកវគ្គបណ្តុះបណ្តាលស្តីពី កិច្ចការពារ និងគ្រប់គ្រងរមណីយដ្ឋានអង្គរ បេតិកភណ្ឌពិភពលោកដល់មន្ត្រី-បុគ្គលិកចំនួន១០០នាក់ ១៧៧
- អ្នកឃុំជូនកែវនឹងទទួលបានស្ពានបេតុងថ្មីជាចំណងដៃពីអាជ្ញាធរជាតិអប្សរា ១៧៩
- សេចក្តីជូនដំណឹងស្តីពីការរៀបចំចរាចរឯកទិសនៅផ្លូវខាងក្រោយប្រាសាទអង្គរវត្ត ១៨១
- អាជ្ញាធរជាតិអប្សរានិងវិស័យឯកជនរួមគ្នាដាំកូនឈើជាង២០០០ដើមនៅបរិវេណ ខាងកើតខ្លោងទ្វារប្រាសាទតាព្រហ្ម ១៨២
- សេចក្តីជូនដំណឹងស្តីពីការកាត់ដកហូតដើមឈើ និងកាត់ក្រឹមែកឈើ ដែលមានហានិភ័យខ្ពស់ 184 នៅតាមបរិវេណប្រាសាទ ក្នុងរមណីយដ្ឋានអង្គរ ១៨៤
- អាជ្ញាធរជាតិអប្សរាអនុញ្ញាតច្បាប់ជួសជុលសំណង់ប្រភេទស្រាលចំនួន ១០៦១ ករណីក្នុងតំបន់រមណីយដ្ឋានអង្គរ ឆ្នាំ២០១៧ និងឆមាសទី១នៃឆ្នាំ២០១៨ ..... ១៨៥
- ឯកឧត្តម ហង់ ពៅ ចុះសួរសុខទុក្ខនិងក្រើនរំឭកមន្ត្រី-បុគ្គលិកក្រៅឧទ្យានអង្គរឱ្យ បំពេញកាតព្វកិច្ចជាពលរដ្ឋឱ្យបានគ្រប់គ្នានៅថ្ងៃបោះឆ្នោតខាងមុខ! ១៨៦
- សេចក្តីជូនដំណឹងស្តីពីការកាត់ដកហូតដើមឈើ និងកាត់ក្រឹមែកឈើ ដែលមានហានិភ័យខ្ពស់នៅតាមបរិវេណប្រាសាទ ក្នុងរមណីដ្ឋានអង្គរ ១៨៨
- អាជ្ញាធរជាតិអប្សរាសាងសង់ទ្វារទឹកសម្រាប់ផ្គត់ផ្គង់ស្រែជិត១០០ហិកតាជូនអ្នកភូមិនគរក្រៅ សង្កាត់គោកចក ក្រុងសៀមរាប ១៨៩
- អាជ្ញាធរជាតិអប្សរាសម្រេចជួសជុលផ្លូវភូមិមួយខ្សែជូនប្រជាពលរដ្ឋភូមិលលៃឃុំបាគង ១៩០
- អាជ្ញាធរជាតិអប្សរាកំពុងដំណើរការជួសជុលកំណាត់ផ្លូវមិត្តភាពកម្ពុជា-កូរ៉ែ ដែលមានប្រវែងជាង ៧០០ម៉ែត្រ ១៩១
- ឯកឧត្តម សុខ សង្វារ រំឭកភ្នាក់ងារប្រាសាទ និងបុគ្គលិកសាមន្តរទៅបោះឆ្នោតដើម្បី បំពេញកាតព្វកិច្ចជាពលរដ្ឋល្អ ១៩៣
- សាររំលែកទុក្ខរបស់លោកជំទាវ ភឿង សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាប្រធានអាជ្ញាធរជាតិអប្សរា ជូនចំពោះលោកស្រី Lablaude ព្រមទាំងក្រុមគ្រួសារ ១៩៤

ផ្នែកទី ៨
ប្រចាំខែសីហា

- អាជ្ញាធរជាតិអប្សរាកំពុងជួសជុលផ្លូវ៦០ម៉ែត្រដែលរងនូវការខូចខាត ១៩៧
- អាជ្ញាធរជាតិអប្សរាយកបាច់ផ្កាចូលរួមបុណ្យសពលោកសាស្ត្រាចារ្យ Lablaude នៅទីក្រុងបារីស ១៩៨
- ព្រះមហាក្សត្រកម្ពុជាផ្ញើសាររំលែកទុក្ខដល់គ្រួសារសពលោកសាស្ត្រាចារ្យ Pierre-André Lablaude ១៩៩
- កម្មវិធីអប់រំបេតិកភណ្ឌក្នុងតំបន់អង្គរបង្កើនការយល់ដឹងនិងក្តីស្រឡាញ់របស់យុវជន ចំពោះមរតកវប្បធម៌ជាតិកាន់តែខ្លាំង! ២០០
- សេចក្តីជូនដំណឹងស្តីពី ការកាត់សម្អាតដើមឈើងាប់ដែលបាក់ដួលរលំ និងកាត់ក្រឹមែកឈើ ដែលមានហានិភ័យខ្ពស់នៅតាមបរិវេណប្រាសាទ ក្នុងរមណីយដ្ឋានអង្គរ ២០៣

- សកម្មភាពជួសជុលប្រចាំថ្ងៃរបស់ក្រុមការងារអគ្គីសនីអាជ្ញាធរជាតិអប្សរាកំពុងជួសជុលភ្លើងបំភ្លឺ តាមដងផ្លូវមួយចំនួនទាំងនៅក្នុងនិងនៅខាងក្រៅរមណីយដ្ឋានអង្គរដូចជា ផ្លូវ៦០ម៉ែត្រ ផ្លូវកូម៉ែ ផ្លូវហ្សាលដីហ្គោលទៅចំបក់កំណប់ និងផ្លូវជុំវិញអង្គភាពនគរបាលការពារបេតិកភ័ណ្ឌ ២០៤
- អាជ្ញាធរជាតិអប្សរាបើកវគ្គអប់រំយុវជនស្ម័គ្រចិត្តការងារបេតិកកណ្ឌមកពី១០ប្រទេសផ្សេងគ្នា ២០៥
- តំណាង TripAdvisor ថាអង្គរវត្តពិតជាស័ក្តិសមចំពោះពានរង្វាន់សំណង់ប្រវត្តិសាស្ត្រ ដ៏អស្ចារ្យបំផុតក្នុងឆ្នាំ២០១៨ .....២០៦
- អាជ្ញាធរជាតិអប្សរាគ្រោងនឹងស្ថាបនាកំណាត់ផ្លូវអង្គរយ្យុងយូឱ្យរួចរាល់នៅក្នុងឆ្នាំ២០១៨ .....២០៧
- អាជ្ញាធរអប្សរាយកដើមគ្រញូងដែលចោរលួចកាប់ទៅរក្សាទុកនៅកន្លែងមានសុវត្ថិភាព ២០៩
- សហគមន៍ទេសចរណ៍បន្ទាយស្រី មានទាំងទេសភាពស្អាត និងការរក្សាបាននូវការអភិរក្សរមណីយដ្ឋានបុរាណ ២១០
- អ្នកជំនាញកសិកម្មចិនបង្រៀនប្រជាជនភូមិធម្មជាតិរុនតាឯកពីបច្ចេកទេសធ្វើស្រែ ឱ្យទទួលបានផលច្រើន ប្រើពូជតិច និងចំណេញពេលវេលា ២១១
- យុវជនស្ម័គ្រចិត្តបេតិកកណ្ឌពិភពលោក២៥រូប បានបញ្ចប់កម្មសិក្សារបស់ខ្លួនបានយ៉ាងជោគជ័យ ២១៣
- សេចក្តីជូនដំណឹងស្តីពីធ្វើការដាំកូនឈើបន្តវេនស្ថិតនៅតាមមាត់កសិណមុខប្រាសាទអង្គរខាងលិច និងដាំកូនរំដួល ២១៥
- ឯកសារបេតិកកណ្ឌប្រចាំតំបន់នឹងត្រូវចងក្រងនិងរក្សាទុកដោយក្រុមយុវជនបេតិកកណ្ឌស្ម័គ្រចិត្ត ក្នុងតំបន់អង្គរដោយខ្លួនឯង ២១៥
- ឥណ្ឌូនេស៊ីស្វែងរកកិច្ចសហការជាមួយអាជ្ញាធរជាតិអប្សរាដើម្បីចុះអនុស្សារណៈរវាងរមណីយដ្ឋានអង្គរ និងរមណីយដ្ឋាន Borobudur ២១៧
- សេចក្តីជូនដំណឹង ២១៨
- វិទ្យាស្ថានជាតិស្រាវជ្រាវណាវ៉ាប្រគល់វត្ថុបុរាណដែលបានពីកំណាយស្រាវជ្រាវ និងជួសជុលនៅតំបន់អង្គរជូនអាជ្ញាធរជាតិអប្សរា ២២០
- លោកជំទាវ ភឿង សកុណា ស្វាគមន៍ដំណើរទស្សនកិច្ចផ្លូវការរបស់រដ្ឋមន្ត្រីក្រសួងការបរទេសឥណ្ឌា ក្នុងខេត្តសៀមរាប ២២២
- លោកជំទាវ ភឿង សកុណា បើកកិច្ចប្រជុំពិភាក្សាត្រៀមរៀបចំកិច្ចប្រជុំគណៈកម្មាធិការអាយស៊ីស៊ី-អង្គរ និងខួប២៥ឆ្នាំនៃការបង្កើតគណៈកម្មាធិការអាយស៊ីស៊ី-អង្គរ ២២៣

ផ្នែកទី ៩

ប្រចាំខែកញ្ញា

- ការចូលរួមដាំដើមឈើក្នុងតំបន់អង្គរ ជាភារកិច្ចដែលអ្នកអាស្រ័យផលត្រូវចូលរួមទាំងអស់គ្នា ២២៥
- អាជ្ញាធរជាតិអប្សរាបញ្ចប់ការជួសជុលច្រាំងកសិន្នុអង្គរវត្តជ្រុងខាងលិចស្ពាបខាងជើងប្រវែង៤០ម៉ែត្រ និងបន្តធ្វើ២០ម៉ែត្រទៀត ២២៦
- អាជ្ញាធរជាតិអប្សរាអបអរសាទរជូនចំពោះលោកជំទាវ ភឿង សកុណា

ក្នុងតំណែងជា រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ នៃរាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៦ ..... ២២៨
- សកម្មភាពភ្នាក់ងារទេសចរណ៍នៃអាជ្ញាធរជាតិអប្សរាបានជួយសង្គ្រោះភ្ញៀវ និងប្រគល់របស់ជូនភ្ញៀវទេសចរ ២២៩
- អាជ្ញាធរជាតិអប្សរានិងមូលនិធិបេតិកភណ្ឌវប្បធម៌កូរ៉ែ
  នឹងបន្តកិច្ចសហការលើការអភិរក្សជួសជុលក្រុមប្រាសាទព្រះពិធូរ ២៣០
- សិក្ខាកាម១២នាក់នៃអាជ្ញាធរជាតិអប្សរាបញ្ចប់វគ្គសិក្សាការពិសោធបែបវិទ្យាសាស្ត្រសម្រាប់កិច្ចការអភិរក្ស ២៣១
- អាជ្ញាធរជាតិអប្សរាប្រជុំផ្ទៃក្នុងគណៈកម្មការប្រព័ន្ធគ្រប់គ្រងបរិស្ថាន-អង្គរ ISO 14001:2015 ..... ២៣៣
- ព្រឹត្តិការណ៍សមរាត្រីឆ្នាំ២០១៨មកដល់ទៀតហើយ ២៣៤
- កិច្ចប្រជុំបច្ចេកទេសលើកទី៤ បានបើកសម័យប្រជុំរបស់ខ្លួនហើយនៅព្រឹកថ្ងៃទី២០នេះ ២៣៥
- អាជ្ញាធរអប្សរាសូមជូនដំណឹងដល់បេក្ខជនទាំងអស់ដែលបានដាក់ពាក្យចូលបម្រើការងារជាភ្នាក់ងារទេសចរ
  បានជ្រាបថាអាជ្ញាធរអប្សរា នឹងធ្វើការប្រលងជ្រើសរើសនៅថ្ងៃព្រហស្បតិ៍ ទី២៧ ខែកញ្ញា ឆ្នាំ២០១៨ ..... ២៣៦
- អាជ្ញាធរជាតិអប្សរានិងភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉ែ KOICA នឹងចុះអនុស្សរណៈយោគយល់គ្នានៅចុងឆ្នាំ
  ២០១៨ដើម្បីបន្តជួសជុលក្រុមប្រាសាទព្រះពិធូរដំហ៊ានទី២ និងព្រះលានដល់ដំរី ២៣៧
- អាជ្ញាធរជាតិអប្សររៀបចំការប្រឡងជ្រើសរើសភ្នាក់ងារទេសចរណ៍លើកទី២ ..... ២៣៨

ផ្នែកទី ១០
ប្រចាំខែតុលា

- សេចក្តីជូនដំណឹងស្តីពី ការកាត់ដកហូតដើមឈើ និងកាត់ក្រឹមែកឈើដែលមានហានិភ័យខ្ពស់នៅតាមបរិវេណ
  ប្រាសាទ ក្នុងរមណីយដ្ឋានអង្គរ ២៣៩
- រមណីយដ្ឋានអង្គរចាប់ផ្តើមចងមិត្តភាពជាមួយឧទ្យានណាយហ្គាវ៉ានៃប្រទេសកាណា
  ដើម្បីពង្រឹងការងារគ្រប់គ្រង និងអភិវឌ្ឍន៍វិស័យទេសចរណ៍ ២៤០
- លោកបណ្ឌិត អ៊ា ដារិទ្ធ អ្នកជំនាញអាជ្ញាធរជាតិអប្សរា ត្រូវបានអញ្ជើញទៅបង្រៀននៅសាកលវិទ្យាល័យ
  CORNELL នៃសហរដ្ឋអាមេរិកអំពីកិច្ចការស្រាវជ្រាវកុលាលភាជន៍ខ្មែរ ២៤១
- អាជ្ញាធរជាតិអប្សរាចូលរួមគោរពព្រះបរមវិញ្ញាណក្ខន្ធព្រះករុណា ព្រះបរមរតនកោដ្ឋ ២៤៣
- ស្ពានឈើប្រវែង១៨៣ម៉ែត្រនៅក្នុងបរិវេណប្រាសាទបេងមាលាកំពុងសាងសង់ឡើងវិញ ២៤៤
- ក្រុមប្រឹក្សានិស្សិតអាស៊ានមកពីប្រទេសជប៉ុនជាង៣០០នាក់ បានដាំកូនឈើនៅមុខប្រាសាទបន្ទាយក្តី
  ក្រោមការសម្របសម្រួលពីអាជ្ញាធរជាតិអប្សរា និងក្រសួងបរិស្ថាន ២៤៦
- អាជ្ញាធរជាតិអប្សរាជួសជុលពង្រឹងទំនប់បារាយណ៍ទឹកថ្លាជ្រុងខាងលិច ផ្នែកខាងត្បូង
  ប្រវែង១,៦៤០ម៉ែត្រ ២៤៧
- ផ្លូវ៦០ ម៉ែត្រក្នុងក្រុងសៀមរាប ត្រូវបានប្រកាស់ប្រសិទ្ធិនាមជា «វិថីសម្តេចវិបុលបញ្ញា សុខ អាន» ២៤៩
- សេចក្តីជូនដំណឹងស្តីពី ការកាត់ដកហូតដើមឈើ និងកាត់ក្រឹមែកឈើដែលមានហានិភ័យខ្ពស់នៅតាមបរិវេណ
  ប្រាសាទ ក្នុងរមណីយដ្ឋានអង្គរ ២៥០
- លោកជំទាវ កឿង សកុណា ចូលរួមសិក្ខាសាលាស្តីពីលទ្ធផលគម្រោងអភិរក្ស
  និងជួសជុលប្រាសាទព្រះពិធូរនៅទីក្រុងសេអ៊ូល សាធារណរដ្ឋកូរ៉ែ ២៥១

– ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរាចូលរួមគោរពវិញ្ញាណក្ខន្ធសពឧត្តមសេនីយ៍ឯក ជា ម៉ន ២៥២

ផ្នែកទី ១១
ប្រចាំខែវិច្ឆិកា

– សេចក្តីជូនដំណឹងស្តីពី ការបើកឲ្យចូលទស្សនាសារមន្ទីរព្រះនរោត្តមសីហនុអង្គរ
ដោយមិនគិតថ្លៃចំនួន០៣ថ្ងៃ ២៥៣
– បុគ្គលិកទើបចូលបម្រើការងារថ្មីប្រមាណ១០០នាក់ទទួលបានការបណ្តុះបណ្តាល
លើកិច្ចការពារ និងគ្រប់គ្រងរមណីដ្ឋានអង្គរ ២៥៤
– ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរាចូលរួមគោរពវិញ្ញាណក្ខន្ធសពឯកឧត្តមឧត្តមសេនីយ៍ឯក ព្រហ្ម ពុធ ២៥៥
– ផ្លូវថ្នល់ដែលស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា
នឹងចាប់ផ្តើមជួសជុលឡើងវិញទាំងអស់នៅចុងឆ្នាំ២០១៨នេះតទៅ ២៥៦
– អាជ្ញាធរជាតិអប្សរាចុះអនុស្សរណៈជាមួយវិទ្យាស្ថាន KICT
ដើម្បីសិក្សាលើការរៀបចំលំហូរចរាចរក្នុងរមណីយដ្ឋានអង្គរ ២៥៧
– អ្នកភូមិនគរក្រៅអរគុណដល់អាជ្ញាធរជាតិអប្សរាចំពោះទ្វារទឹកថ្មីដែលជួយឱ្យផលកសិកម្ម
ពួកគាត់បានផលល្អឡើងវិញ ២៥៨
– តំណាងផ្នែកវប្បធម៌ និងសារមន្ទីរប្រទេសអាស៊ានចុះសិក្សាស្វែងយល់ពីការងារ
គ្រប់គ្រងរមណីយដ្ឋានអង្គររបស់អាជ្ញាធរជាតិអប្សរា ២៦០
– អាជ្ញាធរជាតិអប្សរាចាប់ផ្តើមអ៊ុតកៅស៊ូលើផ្លូវសម្តេចវិបុលបញ្ញា សុខ អាន
ដែលជាផ្លូវសំខាន់មួយក្នុងក្រុងសៀមរាប ២៦១
– សិក្ខាកាម៤០នាក់ នឹងក្លាយជាអ្នកជំនាញនិងពេញសិទ្ធិក្នុងការបម្រើការងារនៅអាជ្ញាធរជាតិអប្សរា
ក្រោយបញ្ចប់វគ្គបណ្តុះបណ្តាលស្តីអំពីកិច្ចការពារ និងគ្រប់គ្រងរមណីយដ្ឋានអង្គរបេតិកភណ្ឌពិភពលោក ២៦២
– សេចក្តីជូនដំណឹងស្តីពី ការកាត់ដកហូតដើមឈើ និងកាត់ក្រឹមែកឈើដែលមានហានិភ័យខ្ពស់នៅតាមបរិវេណ
ប្រាសាទ ក្នុងរមណីយដ្ឋានអង្គរ ២៦៤
– អាជ្ញាធរជាតិអប្សរាលើកកម្ពស់តម្លៃបេតិកភណ្ឌនិងជំរុញការអានដល់កុមារ ២៦៥
– សេចក្តីជូនណឹងស្តីពី ការរៀបចំទិវាជំងឺទឹកនោមផ្អែមពិភពលោកឆ្នាំ២០១៨
នៅបរិវេណទីលាន Parvis ប្រាសាទបន្ទាយស្រី ២៦៦
– អាជ្ញាធរជាតិអប្សរាដាំកូនឈើជំនួសដើមចាស់ដើម្បីរក្សាទេសភាពវប្បធម៌ក្នុងរមណីយដ្ឋានអង្គរ ២៦៧
– អាជ្ញាធរជាតិអប្សរាបើកវគ្គបណ្តុះបណ្តាលពីការប្រើប្រាស់គេហទំព័រអាយស៊ីស៊ី-អង្គរ ២៦៨
– ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរាចូលរួមគោរពវិញ្ញាណក្ខន្ធវីរៈយុទ្ធជន
និងរំលឹកខួបលើកទី៦៥ ទិវាបុណ្យឯករាជ្យជាតិ ២៦៩
– អាជ្ញាធរជាតិអប្សរាបណ្តុះគំនិតឱ្យកុមារស្វែងយល់ពីប្រវត្តិនិងការអភិរក្សបុរាណដ្ឋាន
ដើម្បីឱ្យពួកគេចេះស្រឡាញ់និងចូលរួមការពារ ២៧០
– អាជ្ញាធរជាតិអប្សរាបើកកិច្ចប្រជុំសវនកម្មផ្ទៃក្នុងប្រព័ន្ធគ្រប់គ្រងបរិស្ថាន-អង្គរ ISO-14001:2015 ..... ២៧២

- លោកជំទាវ កឿង សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងជាប្រធានអាជ្ញាធរជាតិអប្សរា អញ្ជើញទស្សនកិច្ចផ្លាស់ប្តូរបទពិសោធន៍ការគ្រប់គ្រងរមណីយដ្ឋាន Paestum នៅប្រទេសអ៊ីតាលី ២៧៣
- លោកជំទាវ កឿង សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងជាប្រធានអាជ្ញាធរជាតិអប្សរា ចូលរួមជាភ្ញៀវកិត្តិយសក្នុងកិច្ចប្រជុំផ្លាស់ប្តូរបទពិសោធន៍អំពីបេតិកភណ្ឌ និងទេសចរណ៍ នៃតំបន់មេឌីទែរ៉ាណេនិងអឺរ៉ុប ២៧៤
- លោកជំទាវ កឿង សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងជាប្រធានអាជ្ញាធរជាតិអប្សរា ទទួលពានរង្វាន់បុរាណវិទ្យាប៉ាស្តូមឆ្នាំ២០១៨ (PAESTUM ARCHEOLOGIA) នៅប្រទេសអីតាលី ២៧៦
- គណៈកម្មការចម្រុះដឹកនាំដោយអាជ្ញាធរជាតិអប្សរាប្រជុំពិភាក្សា រកដំណោះស្រាយ នៃការរៀបចំសណ្តាប់ធ្នាប់តូបលក់ដូរនៅមុខក្រុមប្រាសាទព្រះពិធូរ ២៧៧
- កុមារសាលាបឋមសិក្សាប្រាសាទចារ្យចាប់អារម្មណ៍ការផ្សព្វផ្សាយការអប់រំបេតិកភណ្ឌក្នុងតំបន់អង្គរ ២៧៨
- សេចក្តីជូនដំណឹងស្តីពី ការកាត់ដកហូតដើមឈើ និងកាត់ក្រឹមែកឈើ ដែលមានហានិភ័យខ្ពស់នៅតាមបរិវេណប្រាសាទ ក្នុងរមណីយដ្ឋានអង្គរ ២៨០
- សេចក្តីប្រកាសព័ត៌មានស្តីពីការប្រារព្ធពិធីខួប២៥ឆ្នាំនៃការបង្កើតគណៈកម្មាធិការអន្តរជាតិដើម្បី សម្របសម្រួលកិច្ចគាំពារ និងអភិវឌ្ឍន៍តំបន់រមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ(អាយស៊ីស៊ី-អង្គរ) ២៨១
- អាជ្ញាធរជាតិអប្សរាតាំងបង្ហាញជាសាធារណៈដើម្បីត្រៀមសម្ពោធការតាំងពិព័រណ៍ផ្លូវការអំពីសកម្មភាព និងសមិទ្ធផល២៥ឆ្នាំរបស់គណៈកម្មាធិការអាយស៊ីស៊ី-អង្គរ ២៨២
- ភូមិធម្មជាតិរុនតាឯកបានទទួលពានរង្វាន់សហគមន៍ទេសចរណ៍គំរូ ២៨៣
- អ្នកជំនាញអាជ្ញាធរជាតិអប្សរាបង្រៀនអំពីការអភិរក្សចម្លាក់ថ្មប្រាសាទដល់សិស្សានុសិស្ស នៃសាលាបឋមសិក្សាប្រាសាទបន្ទាយសំរ៉ែ ២៨៤
- សេចក្តីជូនដំណឹងស្តីពី ការបិទបរិវេណលានដល់ដំរី ២៨៦

ផ្នែកទី ១២
ប្រចាំខែឆ្នូ

- អភិបាលក្រុង Fontainebleau នៃប្រទេសបារាំងស្វែងរកកិច្ចសហការជាមួយអាជ្ញាធរជាតិអប្សរា ដើម្បីចងសម្ពន្ធមេត្រីភាពរវាងរមណីយដ្ឋានអង្គរ និងរមណីយដ្ឋាន Fontainebleau ២៨៧
- សៅម៉ាគ្រុបផ្តល់កង់៩២គ្រឿង និងសម្ភារសិក្សាជាច្រើនដល់សិស្សានុសិស្សនៅភូមិធម្មជាតិរុនតាឯក ២៨៨
- អ្នកជំនាញអាដហុកចុះពិនិត្យការដ្ឋាននៅរមណីយដ្ឋានអង្គរមុនកិច្ចប្រជុំអាយស៊ីស៊ី-អង្គរ ២៨៩
- លោកជំទាវ កឿង សកុណា ចូលរួមក្នុងពិធីខួប១០ឆ្នាំរបស់សារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ និងពិធីពុទ្ធាភិសេកព្រះពុទ្ធអង្គធំ ២៩០
- អ្នកជំនាញការអាដហុកចុះពិនិត្យការដ្ឋានសាងសង់ផ្លូវលើភ្នំគូលែនមុននឹងបើកកិច្ចប្រជុំអាយស៊ីស៊ី-អង្គរ ២៩២
- កម្មវិធីអបអរខួប ២៥ឆ្នាំ នៃការបង្កើតអាយស៊ីស៊ី-អង្គរ ប្រារព្ធធ្វើក្រោមវត្តមាន សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ២៩៣

- សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន អំពាវនាវដល់បណ្តាប្រទេសជាមិត្ត
  និងដៃគូសហប្រតិបត្តិការអន្តរជាតិបន្តជួយរមណីយដ្ឋានអង្គរ ២៩៥
- ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា និង អាយស៊ីស៊ី-អង្គរ អញ្ជើញគោរពវិញ្ញាណក្ខន្ធលោកសាស្ត្រាចារ្យ
  Pierre Andre Lablaude អតីតអ្នកជំនាញ Adhoc របស់អាយស៊ីស៊ី-អង្គរ ២៩៦
- សេចក្តីជូនដំណឹងស្តីពី ការរៀបចំកម្មវិធីសម្តែងសិល្បៈស្បែកធំ និងរបាំកូរ៉េនៅទីតាំងប្រាសាទព្រះពិធូរ
  និងនៅដីបុរីទេសចរណ៍-វប្បធម៌ខាងត្បូងសាលាខេត្តសៀមរាប ២៩៧
- រមណីយដ្ឋានអង្គរលែងប្រឈមនឹងបញ្ហាអសន្តិសុខ ប្រាសាទដួលរលំ និងការលួចវត្ថុបុរាណទៀតហើយ! ២៩៨
- អគ្គនាយិកាអង្គការយូណេស្កូ អញ្ជើញទស្សនកិច្ចរមណីយដ្ឋានអង្គរ ២៩៩
- អាជ្ញាធរជាតិអប្សរានិងភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA) ចុះអនុស្សារណៈយោគយល់គ្នា
  បន្តជួសជុលក្រុមប្រាសាទព្រះពិធូរ និងលានដល់ដំរី ៣០០
- សេចក្តីប្រកាសព័ត៌មានលទ្ធផលកិច្ចប្រជុំបច្ចេកទេសលើកទី៣១ និងពេញអង្គលើកទី២៥
  នៃគណៈកម្មាធិការអន្តរជាតិសម្របសម្រួលកិច្ចគាំពារនិងអភិវឌ្ឍន៍រមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ ៣០២
- កិច្ចប្រជុំ អាយស៊ីស៊ី-អង្គរ រយៈពេល២ថ្ងៃទទួលបានលទ្ធផលគួរឱ្យមោទនភាព ៣០៤
- ថ្នាក់ដឹកនាំនៃអាជ្ញាធរជាតិអប្សរាចូលរួមថ្វាយយាងនិវត្តរបស់ព្រះមហាក្សត្រ និងព្រះមហាក្សត្រី ៣០៦
- ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី សព្វព្រះរាជហឫទ័យស្តេច
  យាងជាព្រះរាជាធិបតីដ៏ខ្ពង់ខ្ពស់បំផុត ក្នុងព្រះរាជពិធីបិទអបអរសាទរខួប២៥ឆ្នាំ អាយស៊ីស៊ី-អង្គរ
  និងព្រះរាជពិធីលៀងសាយភោជន៍ នាព្រះលានដល់ដំរី ៣០៧
- អាជ្ញាធរជាតិអប្សរានិងភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េសម្តែងសិល្បៈវប្បធម៌
  អបអរការបញ្ចប់គម្រោងជួសជុលប្រាសាទព្រះពិធូរជំហានទី១ .....៣០៩
- ការអប់រំបេតិកភណ្ឌដល់កុមារជុំវិញការយល់ដឹងផ្នែកវប្បធម៌
  ដែលទាមទារឱ្យមានការជួយពីអ្នកជំនាញបន្ថែមលើម៉ោងសិក្សា ៣១០
- សេចក្តីជូនដំណឹងស្តីពីការជីកប្រឡាយតាមព្រំផ្ទៃដីព្រៃឈើ
  ដើម្បីការពារ និងរក្សាព្រៃឈើក្នុងឧទ្យានអង្គរ ៣១២
- សេចក្តីជូនដំណឹងស្តីពី ការកាត់ដកហូតដើមឈើ និងកាត់ក្រឹមែកឈើដែលមានហានិភ័យខ្ពស់នៅតាមបរិវេណ
  ប្រាសាទ ក្នុងរមណីយដ្ឋានអង្គរ ៣១៣
- សិប្បកម្មបុរាណផ្នែកសិល្បៈតាំងលម្អនិងភ្លេងខ្មែរនៅសហគមន៍កុដិសូរ
  ទទួលបានការគាំទ្រច្រើនពីសំណាក់ភ្ញៀវទេសចរ ៣១៤
- សិស្សថ្នាក់ទី៤,៥ និងទី៦ ទទួលការអប់រំឱ្យចេះកាត់បន្ថយសំរាម ៣១៥
- សិស្សថ្នាក់បឋមសិក្សាក្នុងរមណីយដ្ឋានអង្គរជាង ៣០០នាក់ ទទួលបានការអប់រំឱ្យចេះកាត់បន្ថយសំរាម ៣១៧

ព្រឹត្តិការណ៍ព័ត៌មានប្រចាំខែមករា

ផ្នែកទី ១
ប្រចាំខែមករា

ឆ្នាំ២០១៧កន្លងទៅនេះអាជ្ញាធរជាតិអប្សរាបានឧបត្ថម្ភស្ត្រើផើបសម្រាលកូនរួចក្នុងតំបន់អង្គរ ចានចំនួន២០០គ្រួសារ និងអនុញ្ញាតការសាងសង់ និងជួសជុលតូចៗចានចំនួន៤០០ករណី

ផ្សាយនៅថ្ងៃទី ០៣ ខែ មករា ឆ្នាំ២០១៨

ក្រៅពីការងារអភិរក្ស និងអភិវឌ្ឍន៍ អាជ្ញាធរជាតិអប្សរាបានយកចិត្តទុកដាក់លើសុខុមាលភាពរបស់ប្រជាពលរដ្ឋក្នុងរមណីយដ្ឋានអង្គរជាប្រចាំ ក្នុងគម្រោងលើកស្ទួយកម្រិតជីវភាពប្រជាពលរដ្ឋ តាមរយៈក្រុមការងារសហគមន៍ ដែលតែងចុះដល់លំនៅឋានរបស់ប្រជាពលរដ្ឋគ្រប់តំបន់ទាំងអស់។

ជាក់ស្តែង រយៈពេលមួយឆ្នាំ២០១៧កន្លងទៅនេះ អាជ្ញាធរជាតិអប្សរាបានឧបត្ថម្ភកញ្ចប់ទ្រទ្រង់សុខុមាលភាពម្តាយនិងទារកក្នុងតំបន់អង្គរបានចំនួន៦០៥គ្រួសារ ដែលក្នុងកញ្ចប់នេះមានដូចជា កូនមុងសម្រាប់ទារក សម្លៀកបំពាក់ទារក និងបំពង់ទឹកក្តៅជាដើម រួមទាំងថវិកាមួយចំនួនផង។

តាមរយៈក្រុមការងារសហគមន៍នេះដែរ អាជ្ញាធរជាតិអប្សរាក៏បានចុះពិនិត្យ និងដោះស្រាយសំណើសាងសង់ និងជួសជុលតូចៗបានចំនួន៤៧៥ករណី របស់ប្រជាពលរដ្ឋដែលមានសេចក្តីត្រូវការចាំបាច់ ក្នុងការកែលម្អលំនៅដ្ឋានរបស់ពួកគាត់ឲ្យមានលក្ខណៈងាយស្រួលក្នុងជីវភាពរស់នៅសមរម្យ។

ក្រៅពីករណីខាងលើ អាជ្ញាធរជាតិអប្សរាក៏បានឧបត្ថម្ភសង្កសី ថវិកា និងសម្ភារៈមនុស្សធម៌ជាច្រើនទៀត ដល់ប្រជាពលរដ្ឋដែលរងគ្រោះដោយភ្លើងឆេះផ្ទះ និងចូលរួមឧបត្ថម្ភជាស៊ីម៉ង់ត៍ សម្ភារៈសាងសង់ផ្សេងៗ ដល់វត្តអារាម និងអាគារសាធារណៈក្នុងតំបន់អង្គរជាដើម៕









ដំណើរវិវឌ្ឍនៃការចាប់ជួសជុលស្ពានហាលខាងលិចប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី ០៣ ខែ មករា ឆ្នាំ២០១៨

គម្រោងជួសជុលស្ពានហាលខាងលិចនៃប្រាសាទអង្គរវត្ត បានបើកការដ្ឋានជាផ្លូវការកាលពីថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៦ ដោយគ្រោងនឹងចំណាយពេល៤ឆ្នាំដើម្បីឲ្យរួចរាល់។ នេះជាគម្រោងសហការជំហានទី២រវាងអាជ្ញាធរជាតិអប្សរា និងសាកលវិទ្យាល័យសូហ្វីយ៉ានៃប្រទេសជប៉ុន បន្ទាប់ពីដំណាក់កាលទី១នៃគម្រោងសហការដែលបានជួសជុលស្ពានហាលនេះប្រវែង១០០ម៉ែត្ររួចរាល់ជាស្ពារ(១៩៩៦-២០០៧)។

គម្រោងជួសជុលដំណាក់កាលទី២នេះ ភាគីជប៉ុនបានផ្តល់អ្នកជំនាញការបច្ចេកទេស ព្រមទាំងសម្ភារៈបច្ចេកទេសទំនើប។ ដើម្បីងាយស្រួលក្នុងកិច្ចការជួសជុល។ ចំណែកអាជ្ញាធរជាតិអប្សរាទទួលបន្ទុក ទាំងថវិកានិងកម្លាំងពលកម្ម ដោយក្នុងនោះ អ្នកជំនាញខ្មែរចំនួន៤នាក់ដែលជាស្ថាបត្យករ បុរាណវិទូ និងពលករជំនាញចំនួន ៥៤នាក់ កំពុងធ្វើការរួមគ្នាជាមួយអ្នកបច្ចេកទេសជប៉ុនមកពីសាកលវិទ្យាល័យសូហ្វីយ៉ា។

លោក អន សុភាព មន្ត្រីជំនាញនៃនាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរ និងបុរាណវិទ្យាបង្ការដែលទទួលបន្ទុកលើការគ្រប់គ្រងរួមនិងសម្របសម្រួលទូទៅក្នុងគម្រោង បានបង្ហាញនូវដំណើរវិវឌ្ឍនៃការជួសជុលនេះថា កិច្ចការបឋមៗដែលក្រុមការងារបាននិងកំពុងអនុវត្តសព្វថ្ងៃគឺ ការសិក្សានិងប្រមូលទិន្នន័យទាំងឡាយ ដែលជាប្រយោជន៍សម្រាប់ឯកសារបច្ចេកទេសនៃការជួសជុល រួមមាន៖ កិច្ចការសម្រង់និងគូរប្លង់ ការវិនិច្ឆ័យនិងរកដំណោះស្រាយលើវិធីសាស្ត្រនៃការជួសជុលការងារស្រាវជ្រាវតាមរយៈការបើករណ្តៅកំណាយ និងរៀបចំសង់ទំនប់ទប់ទឹកប្រវែង ១៣៣.៥ម៉ែត្រ តាមបណ្តោយជញ្ជាំងខាងជើងនៃស្ពានហាល។

បំណងនិងទស្សនៈរួមផ្នែកបច្ចេកទេសជួសជុលរចនាសម្ព័ន្ធស្ពានហាលនេះ គឺ រក្សាទម្រង់ដើមរបស់សំណង់ រួមទាំងរក្សាប្រវត្តិនៃការជួសជុល បច្ចេកទេសនិងស្នាដៃស្ថាបត្យកម្ម។ ម្យ៉ាងទៀតរាល់ដំណើរការអនុវត្តកិច្ចការជួសជុលនីមួយៗ បានទទួលនូវអនុសាសន៍ណែនាំបន្ថែមពីអ្នកជំនាញ អាជ ហុក នៃគណកម្មាធិការ ICC-Angkor។ ហេតុនេះហើយ ដើម្បីឆ្លើយតបនឹងអនុសាសន៍ទាំងនោះគម្រោងបានបើករណ្តៅកំណាយស្រាវជ្រាវចំនួន៥កន្លែង ដែលស្ថិតតាមបណ្តោយនៃកម្រាលស្ពានហាល ក្នុងបំណងសិក្សា និងប្រៀបធៀបរចនាសម្ព័ន្ធខាងស្ថាបត្យកម្ម ស្វែងយល់ពីប្រវត្តិនិងវាយតម្លៃនូវកម្រិតនៃភាពខូចខាតរបស់ស្ពានហាល។ល។ លទ្ធផលដែលបានពីកំណាយស្រាវជ្រាវ បង្ហាញនូវភាពខុសគ្នាច្រើនដូចជា៖ ប្រវត្តិនៃការ

ជួសជុលកែលំអស្ពានហាលក្នុងសម័យក្រោយអង្គរ (សវទី១៦-១៧) បច្ចេកទេសនៃការបង្ហាប់គ្រឹះ ភាពខ្សោយនិងភាពរឹងមាំនៃរចនាសម្ព័ន្ធដញ្ជាំងនិងយល់ដឹងអំពីបច្ចេកទេសបុរាណដែលបានសង់ស្ពានហាល។

ក្រុមអ្នកជំនាញខ្មែរនិងអ្នកជំនាញជប៉ុនបានធ្វើការរួមគ្នាលើផ្នែកបច្ចេកទេស ក្នុងនោះលទ្ធផលដែលបានពីការសិក្សាស្រាវជ្រាវគឺជាទិន្នន័យគោលដែលមានប្រយោជន៍ខ្លាំងសម្រាប់យកទៅវិភាគលម្អិត និងកំណត់នូវវិធីសាស្ត្រនៃការជួសជុលពង្រឹងរចនាសម្ព័ន្ធស្ពានហាល។ ចំពោះបច្ចេកទេសនៃការងារជួសជុល គណៈកម្មាធិការ ICC-Angkor ក្នុងកិច្ចប្រជុំចុងក្រោយកាលពីពាក់កណ្តាលខែធ្នូកន្លងទៅនេះ បានកំណត់ឲ្យធ្វើការជួសជុលដោយមិនឲ្យរុះរើជញ្ជាំង ដើម្បីទុកជាស្លាកស្នាមប្រវត្តិសាស្ត្រ។

ឆ្លងកាត់ការជជែកពិភាក្សាជាមួយអ្នកជំនាញការជាន់ខ្ពស់ជាច្រើនរួចមក គណៈកម្មាធិការនេះសម្រេចឲ្យក្រុមការងារធ្វើការជួសជុលសាកល្បងទៅលើចំណុចលំបាកខ្លាំងប្រវែង៤ទៅ៥ម៉ែត្រ ដោយប្រើបច្ចេកទេសមិនរុះរើជញ្ជាំង ដើម្បីដឹងថា តើអ្វីខ្លះជាភាពប្រឈមខ្លាំង និងបន្តរិះរកមធ្យោបាយបន្ថែមទៀត ដើម្បីដោះស្រាយ។ ដូច្នេះ ក្រុមការងារនឹងអនុវត្តគម្រោងសាកល្បងនេះក្នុងរយៈពេលធាប់ៗខាងមុខ៕









អបអរសាទរ! ប្រាសាទអង្គរវត្តរបស់ខ្មែរជាប់ចំណាត់ថ្នាក់លេខ១ជាសំណង់ប្រវត្តិសាស្ត្រដ៏អស្ចារ្យបំផុត និងចំណាត់ថ្នាក់លេខ៨ជាគោលដៅទេសចរណ៍លើពិភពលោកក្នុងឆ្នាំ២០១៧

ផ្សាយនៅថ្ងៃទី ០៤ ខែ មករា ឆ្នាំ២០១៨

ក្រោយការចូលរួមបោះឆ្នោតពីភ្ញៀវទេសចរជាប់លាននាក់ជុំវិញពិភពលោក គេហទំព័រដ៏ល្បីល្បាញ TripAdvisor បានផ្តល់ចំណាត់ថ្នាក់លេខ១ដល់ប្រាសាទអង្គរវត្តរបស់កម្ពុជា ជាសំណង់ដ៏មានសារៈសំខាន់ផ្នែកប្រវត្តិសាស្ត្រអស្ចារ្យបំផុតនិងចំណាត់ថ្នាក់លេខ៨ជាគោលដៅទេសចរណ៍របស់ពិភពលោកសម្រាប់ឆ្នាំ២០១៧នេះ។

នេះគឺជាឆ្នាំទី៤ហើយ ដែលអង្គរត្រូវបានភ្ញៀវទេសចរលើពិភពលោកបោះឆ្នោតគាំទ្រ ហើយទទួលបានចំណាត់លេខ១ជាប់ៗគ្នាតាមរយៈគេហទំព័រដ៏ល្បីល្បាញផ្សេងៗគ្នា គឺ កាលពីឆ្នាំ២០១៤ អង្គរបានជាប់ចំណាត់ថ្នាក់លេខ១ នៅលើគេហទំព័រមួយដែលតែងតែយកតំបន់បុរាណវិទ្យា និងប្រវត្តិសាស្ត្រទាំងអស់លើពិភពលោកមកប្រៀបធៀបគ្នា នោះគឺគេហទំព័រ ArchaeoMadness។ បន្ទាប់មកទៀត នៅដើមឆ្នាំ២០១៥ អង្គរទទួលបានចំណាត់ថ្នាក់លេខ១ម្តងទៀត នៅលើគេហទំព័រអន្តរជាតិមួយ ដែលជាគេហទំព័រផ្សព្វផ្សាយតំបន់ទេសចរណ៍ល្បីៗលើពិភពលោក នោះគឺគេហទំព័រ TripAdvisor។ នៅឆ្នាំ២០១៦កន្លងទៅ អង្គរបានបន្តជាប់លេខ១បន្ថែមទៀត នៅលើគេហទំព័ររបស់ក្រុមហ៊ុន Lonely Planet ដែលជាគេហទំព័រផ្សព្វផ្សាយ និងជាប្រភពព័ត៌មានទេសចរណ៍ដ៏ល្បីមួយលើពិភពលោក មានទាំងព័ត៌មានតាមរយៈវីដេសាយ ទស្សនាវដ្តីនិងសៀវភៅជាដើម។

នេះជាមោទនភាពមួយរបស់ជាតិខ្មែរយើងទាំងមូល ដែលអង្គរវត្តរបស់កម្ពុជាទទួលបានការគាំទ្រពីបណ្តាប្រជាជនជុំវិញពិភពលោក។ ក្នុងនាមស្ថាប័នគ្រប់គ្រងរមណីយដ្ឋានអង្គរ អាជ្ញាធរជាតិអប្សរា សូមចូលរួមអបអរសាទរ និងសូមអំពាវនាវដល់សាធារណជនទាំងអស់បន្តចូលរួមថែរក្សា ការពារនូវបេតិកភណ្ឌរបស់ដូនតាយើងឲ្យបានខ្លាំងក្លាដើម្បីភាពគង់វង្សយូរអង្វែងតទៅ៕









ប្រជាពលរដ្ឋនៅភូមិធម្មជាតិរុនតាឯកអរគុណចំពោះការកែចម្រើនកម្រិតជីវភាពនាពេលបច្ចុប្បន្ន

ផ្សាយនៅថ្ងៃទី ០៥ ខែ មករា ឆ្នាំ២០១៨

ភាពរីកចម្រើនគួរឱ្យកត់សម្គាល់នៅភូមិធម្មជាតិរុនតាឯក ធ្វើឱ្យប្រជាពលរដ្ឋដែលកំពុងរស់នៅ និងប្រកបរបរនៅទីនោះ មានការសោទរ និងកំពុងរស់នៅដោយភាពសប្បាយរីករាយ ជាមួយសមិទ្ធផលដែលពួកគេកំពុងទទួលបាន។ កម្រិតជីវភាពនៅទីនោះ មានភាពល្អប្រសើរ ប្រជាពលរដ្ឋមានការងារធ្វើគ្រប់គ្នា ពិសេសគឺអាចរកចំណូលចូលគ្រួសារបានគ្រប់គ្រាន់ ធ្វើឱ្យកម្រិតជីវភាពរបស់ពួកគេមានភាពធូរធារជាលំដាប់។

ដើម្បីឱ្យកម្រិតជីវភាពរបស់ប្រជាពលរដ្ឋរីកចម្រើនទៅបាន អាជ្ញាធរជាតិអប្សរាមានគោលដៅចំនួន២ ក្នុងនោះរួមមាន ការអភិវឌ្ឍវិស័យទេសចរណ៍ និងកសិកម្ម។សម្រាប់ការងារកសិកម្មនាពេលបច្ចុប្បន្ន អាចនិយាយបានថា ភូមិធម្មជាតិរុនតាឯកកំពុងជោគជ័យលើវិស័យមួយនេះ ហើយប្រជាពលរដ្ឋជាច្រើនគ្រួសារបាននឹងកំពុងទទួលផលពីវិស័យមួយនេះផងដែរ។ បើក្រឡេកមើលវិស័យកសិកម្ម បច្ចុប្បន្នអ្នកភូមិធម្មជាតិរុនតាឯកកំពុងទាញចំណូលបានច្រើនគួរសមពីដំណាំម្រុំ។ មានប្រជាពលរដ្ឋប្រមាណ ៣០គ្រួសារ កំពុងដាំម្រុំ ដែលមានក្រុមហ៊ុនមួយជាអ្នកទទួលទិញ និងផ្តល់បច្ចេកទេស។

ម្ចាស់ក្រុមហ៊ុន អេស គី អិល អ៊ី (S.P.L.E) **លោក អ៊ឹង តុងអៀង** មានប្រសាសន៍ថា កាលពីពេលថ្មីៗនេះ ក្រុមហ៊ុនរបស់លោកបានចុះកិច្ចព្រមព្រៀងជាមួយក្រុមហ៊ុនជប៉ុន ដើម្បីទទួលទិញផលិតផលម្រុំពីប្រជាពលរដ្ឋក្នុងភូមិធម្មជាតិរុនតាឯក។ លោកបញ្ជាក់ថា ខាងភាគីជប៉ុន មុននឹងសម្រេចទទួលទិញផលិតផលម្រុំនេះ ពួកគេបានយកដីពីភូមិទៅពិសោធន៍ ដោយពិនិត្យរកសារធាតុគីមីចំនួនប្រមាណ ២៤០មុខ និងចុងក្រោយបានបង្ហាញថា ដីនៅទីនេះ គ្មានសារធាតុគ្រោះថ្នាក់ណាមួយដែលប៉ះពាល់ដល់សុខភាពឡើយទើបពួកគេសម្រេចទទួលផលិតផលពីយើង។

លោកបន្ថែមថា ក្រុមហ៊ុន MWSO របស់ជប៉ុន បានទទួលទិញផលិតផលម្រុំពីអ្នកភូមិក្នុងមួយខែចំនួន ១០តោនម្រុំស្រស់ ដែលស្មើនឹង ១តោនក្រោយពេលសម្ងួត។ លោកបន្ថែមទៀតថា គោលបំណងសំខាន់ ដែលក្រុមហ៊ុនរបស់លោក មកវិនិយោគនៅភូមិធម្មជាតិរុនតាឯកនេះ ព្រោះថា ដើម្បីរួមចំណែកអភិវឌ្ឍកម្រិតជីវភាពរបស់ប្រជាពលរដ្ឋ ហើយមួយទៀតដីនៅតំបន់នេះមានភាពអំណោយផលច្រើនសម្រាប់ដំណាំរុក្ខជាតិម្រុំ។ ក្រៅពីនេះ ក្រុមហ៊ុនក៏បានផ្តល់បច្ចេកទេសដាំដុះរួមនឹងដើមទុនកម្រិតទាបគ្មានការប្រាក់ សម្រាប់ប្រជាពលរដ្ឋ ផងដែរ។ ហើយបច្ចុប្បន្ននេះទៀត ក្រុមហ៊ុន អិស គី អិល អ៊ី កំពុងសាកល្បងដាំដំណាំសណ្តែកផ្កាយ ជាមួយពលរដ្ឋ ១៨គ្រួសារ ដែលមានសហគមន៍កសិកម្មកម្ពុជាជាអ្នកបង្រៀនបច្ចេកទេសនិងទទួលទិញផ្តាច់មុខ។

កសិករ **អ្នកស្រី ទិត្យ អ៊ុច** ដែលបាននិងកំពុងទទួលផលពីដំណាំម្រុំ បានឱ្យដឹងថា អ្នកស្រីមានភាពរីករាយ ទៅនឹងអ្វីដែលគ្រួសារអ្នកស្រីកំពុងទទួលបាន។ អ្នកស្រីបន្តថា អ្នកស្រីដាំម្រុំបានមួយឆ្នាំហើយ ហើយក្នុងមួយខែអាចរកចំណូលបានប្រមាណ៣០០ដុល្លារ។ **អ្នកស្រី ទិត្យ អ៊ុច** បានរម្លឹកពីការមករស់នៅក្នុងភូមិធម្មជាតិរុនតាឯកកាលពី៧ឆ្នាំមុន ដែលអ្នកស្រីថា មានភាពលំបាកបន្តិច តែសព្វថ្ងៃអ្នកស្រីមិនចង់ទៅណាទេ ព្រោះមុខរបរនៅទីនេះ អាចឱ្យគ្រួសារអ្នកស្រីដែលមានកូន ៣នាក់ក្នុងបន្ទុក រស់នៅបានស្រួល និងមានការមើលខុសត្រូវពីអ្នកជំនាញកសិកម្មដែលបានបណ្តុះបណ្តាលរបស់អាជ្ញាធរជាតិអប្សរានិងមានការផ្តល់ទុនសម្រាប់ការងារកសិកម្មផ្សេងៗផងដែរ។

ចំណែក **អ្នកស្រី ស៊ត់ សាលី** ជាស្ត្រីមេម៉ាយ មានកូន៣នាក់ ក៏កំពុងរីករាយចំពោះសមិទ្ធផលដំណាំម្រុំនេះផងដែរ។ អ្នកស្រីថា ខ្លួនបានតស៊ូប្រឹងប្រែងចិញ្ចឹមកូនតែម្នាក់ឯង និងបានក្រុមការងារក្នុងគម្រោងភូមិធម្មជាតិរុនតាឯក ខ្នះខ្នែងជួយសព្វបែបគ្រប់យ៉ាង ទើបបានមកដល់សព្វថ្ងៃនេះ ហើយអ្នកស្រីក៏មិនចង់ទៅណាទៀតដែរ ព្រោះស្រឡាញ់ការរស់នៅនៅទីនេះ។ អ្នកស្រីបន្ថែមថា៖ «ខ្ញុំស្រឡាញ់ទីនេះ ពីមុនខ្ញុំមានប្តី រហូតដល់អត់ប្តី ខ្ញុំនៅតែតស៊ូដែរ ខ្ញុំអត់ចង់ទៅណាទៀតទេ ខ្ញុំស្រឡាញ់ដីខ្ញុំ សូម្បីតែដីចម្ការខ្ញុំរាល់ថ្ងៃអត់បានទៅតែមួយថ្ងៃ ក៏ខ្ញុំនឹកដែរ នឹករបស់របរបស់យើង តែដាំហើយគឺចង់ថែទាំឱ្យល្អ»។

ឯកឧត្តម ម៉ី ម៉ារ៉ាឌី ទីប្រឹក្សាអាជ្ញាធរជាតិអប្សរា និងជាប្រធានគម្រោងអភិវឌ្ឍន៍ភូមិធម្មជាតិ រុនតាឯក មានប្រសាសន៍ថា ទាក់ទងនឹងដំណាំម្រុំ សព្វថ្ងៃមានគ្រួសារប្រមាណ ៣០ កំពុងចូលរួមដាំដុះ នៅលើផ្ទៃដីជិត ១០ហិកតា។ រាល់គ្រួសារនីមួយៗ អាចរកចំណូលបានពី ១០០ដុល្លារ ទៅ៣០០ដុល្លារក្នុងមួយខែ ទៅតាមផ្ទៃដីដែលពួកគេដាំដុះ។ ឯកឧត្តមបន្ថែមថា បច្ចុប្បន្នគម្រោងនេះ មានប្រជាជនជាង ១០០គ្រួសារកំពុងរស់នៅ ដោយខ្លះដាំដំណាំម្រុំ សណ្តែកផ្កាយ ចិញ្ចឹមមាន់ ទា និងដាំបន្លែធម្មជាតិ។ល។

តាមការបញ្ជាក់របស់ឯកឧត្តមប្រធានគម្រោង គោលដៅទៅខាងមុខរបស់អាជ្ញាធរជាតិអប្សរា គឺរៀបចំប្រព័ន្ធធារាសាស្ត្រ និងហេដ្ឋារចនាសម្ព័ន្ធនានា ដើម្បីធានាកម្រិតជីវភាពរបស់ប្រជាពលរដ្ឋកំពុងរស់នៅ និងគ្រួសារបន្ថែមទៀត ដែលគ្រោងនឹងមករស់នៅទីនេះ។ ឯកឧត្តម បញ្ជាក់ថា គោលការណ៍របស់អាជ្ញាធរជាតិអប្សរា គឺរៀងរាល់ឆ្នាំយកប្រជាពលរដ្ឋប្រមាណ១០០គ្រួសារចូលមករស់នៅ ដើម្បីបំពេញនៅក្នុងគម្រោងទីមួយរបស់ខ្លួន ដែលត្រូវការប្រមាណ ៨០០គ្រួសារ។

គួររំឭកថា ភូមិធម្មជាតិរុនតាឯក ត្រូវបានបង្កើតឡើងដោយមានការជ្រើសរើសប្រជាជនក្នុងតំបន់អង្គរឲ្យមករស់នៅដោយសារកំណើនយ៉ាងឆាប់រហ័សក្នុងតំបន់បេតិកភណ្ឌមួយនេះ។ បច្ចុប្បន្នមានគ្រួសារចំនួន ១០៣ហើយ ដែលត្រូវបានជ្រើសរើសឲ្យមកស្នាក់នៅ ដោយមានការផ្តល់ផ្ទះមួយខ្នង និងដីសម្រាប់ធ្វើកសិកម្ម។ ផ្ទៃដីសរុបនៃភូមិនេះមានចំនួន ១០១២ហិកតា ហើយគ្រោងនឹងពង្រីកបន្ថែមទៀតនាពេលអនាគត។ ហេដ្ឋារចនាសម្ព័ន្ធក្នុងភូមិនេះរួមមាន សាលារៀន មណ្ឌលសុខភាព វត្តអារាម ហើយភូមិនេះមានបឹងធម្មជាតិដ៏ធំមួយ គឺបឹងជាលា ដែលអាចស្តុកទឹកបានគ្រប់គ្រាន់សម្រាប់ប្រើប្រាស់លើវិស័យកសិកម្មជាដើម៕









ចម្លាក់ទ្វារចាលរកឃើញនៅប្រាសាទទន្លេស្ងួតកំពុងទទួលបានការជួសជុល ពីអ្នកជំនាញអាជ្ញាធរជាតិអប្សរា

ផ្សាយនៅថ្ងៃទី ០៥ ខែ មករា ឆ្នាំ២០១៨

កាលពីថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៧ កន្លងមក ក្នុងគម្រោងស្រាវជ្រាវរវាងអាជ្ញាធរជាតិអប្សរា វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា (ITC) និងវិទ្យាស្ថានស្រាវជ្រាវអាស៊ីអាគ្នេយ៍នៃប្រទេសសិង្ហបុរី (ISEAS) បានរួមគ្នាធ្វើកំណាយស្រាវជ្រាវនៅក្នុងបរិវេណប្រាសាទទន្លេស្ងួត រកឃើញបដិមាទ្វារបាលដែលមានចំនួន០៦បំណែក មានព្រះកេស ដងខ្លួន បំណែកដៃ ជើង និងក្រវិលដែលបច្ចុប្បន្នកំពុងជួសជុលនិងអភិរក្សដោយក្រុមការងារអភិរក្សនិងជួសជុលវត្ថុសិល្បៈ ហៅកាត់ថា I.T.A.L.I.A នៃអាជ្ញាធរជាតិអប្សរា។

លោក ឮ ចាន់ណា៉ បុគ្គលិកជំនាញផ្នែកជួសជុលនិងអភិរក្សថ្ម មកពីនាយកដ្ឋានអភិរក្សប្រាសាទក្រៅឧទ្យានអង្គរ និងជាសមាជិកនៃក្រុមអ៊ីតាលីយ៉ាប្រចាំការនៅមន្ទីរពិសោធន៍ក្នុងអភិរក្សដ្ឋានអង្គរ បានឱ្យដឹងថាៈ មុនពេលទទួលបានរូបចម្លាក់ទ្វារបាលពីសារមន្ទីរព្រះសីហនុ-អង្គរ ក្រុមការងារបានធ្វើការសិក្សាទាក់ទងនឹងប្រវត្តិរបស់វត្ថុសិល្បៈ បានគូររូបទាក់ទងនឹងក្បាច់លម្អ និងការខូចខាតរបស់បដិមា។ បន្ទាប់មកប្រើម៉ាស៊ីនម៉ាយក្រូស្កុប (Microscope) ដើម្បីដឹងពីការខូចខាតលើផ្នែកការពុកផុយផ្នែកខាងក្នុង និងវត្ថុធាតុដែលជាប់លើផ្នែបដិមា។ បន្ថែមពីនោះក្រុមការងារក៏ធ្វើការវិភាគលម្អិតលើវត្ថុផ្សេងៗដែលជាប់នឹងបដិមាត្រង់ផ្នែខាងលើ កម្រិតការខូចខាតនៃថ្មផ្នែកខាងក្នុង វាស់សីតុណ្ហភាពនិងសំណើមរបស់ថ្ម និងបរិស្ថានជុំវិញបដិមារួមនឹងបំណែកវត្ថុសិល្បៈនីមួយៗផងដែរ។ការជួសជុសត្រូវបានបែងចែកជា២ផ្នែក គឺការសម្អាត (Cleaning Treatment) និងការជួសជុល (Intervention)។ មុនសម្អាត ចាំបាច់ធ្វើការសាកល្បងលើវត្ថុធាតុមួយចំនួនមានដូចជាក្រដាសជប៉ុន (Japanese paper) Compress (ម្សៅក្រដាសលាយម្សៅដីឥដ្ឋ) និង Algar Algar gel ដើម្បីពិនិត្យមើលលទ្ធភាព ប្រសិទ្ធភាពនៃការសម្អាត និងបង្ការផលប៉ះពាល់ដល់សាច់ថ្មដែលកំពុងពុកផុយ។ ផ្នែកតាមលទ្ធផលសម្អាតសាកល្បងទាំងធូលី និងអំបិលក្នុងរន្ធថ្មត្រូវបានសម្អាតនៅត្រង់ចំណុចបែកដើម្បី រក្សាគុណភាពថ្មបានយូរនៅពេលតភ្ជាប់រួចរាល់។ រីឯផ្នែខាងក្រៅគឺសម្អាតតែធូលីនិងស្នាមប្រឡាក់ដែលជិតជាប់ប៉ុណ្ណោះ ព្រោះដើម្បីរក្សាភាពដើមនិងតម្លៃបុរាណវិទ្យានៃបដិមា។ ម្យ៉ាងទៀតក៏ដើម្បីបង្ហាញថាបដិមានេះត្រូវបានរកឃើញដោយកំណាយបុរាណវិទ្យា។

បច្ចុប្បន្នការសម្អាតបានប្រហែល៥០% លុះសម្អាតរួចរាល់អ្នកជំនាញនឹងធ្វើការសម្លាប់ប្រភេទពួកស្លែដីវសាស្ត្រដោយប្រើ Biocide ពង្រឹងផ្នែកពុកផុយ និងផ្នែកត្រូវតភ្ជាប់។ ឯការតភ្ជាប់ឡើងវិញ ត្រូវបិទបាយអបំពេញស្នាមប្រេះ និងផាត់ពណ៌បន្សុំ។ **លោក ណា៉** បញ្ជាក់ថា យើងមិនអាចកំណត់កាលបរិច្ឆេទនៃការរួចរាល់បាននោះទេពេលនេះ ព្រោះការងារទាំងនេះត្រូវការពេលវេលាយូរដើម្បីធ្វើការសិក្សានិងជួសជុលដោយប្រុងប្រយ័ត្នបំផុត៕









អ្នកស្រាវជ្រាវបុរាណវិទ្យាអន្តរជាតិចែករំលែកចំណេះដឹងជាក់ចេញនឹងប្រវត្តិសាស្ត្រនិងបច្ចេកទេសសំយោគលោហៈដល់សារធារណជននៅអាជ្ញាធរជាតិអប្សរា

ផ្សាយនៅថ្ងៃទី ០៥ខែ មករា ឆ្នាំ២០១៨

នាថ្ងៃទី១១ ខែមករា ឆ្នាំ២០១៨ខាងមុខនេះ នៅមជ្ឈមណ្ឌលបណ្តុះបណ្តាលអង្គរនៃអាជ្ញាធរជាតិអប្សរា នឹងមានការធ្វើបទបង្ហាញអំពីប្រវត្តិសាស្ត្រនិងបច្ចេកទេសសំយោគលោហៈ (Copper Alloy Sculpture Techniques and History: an International Interdisciplinary Group) ពីសំណាក់អ្នកស្រាវជ្រាវជាន់ខ្ពស់អន្តរជាតិផ្នែកបុរាណវិទ្យាមកពីច្រើនប្រទេសដូចជា៖ បារាំង អង់គ្លេស សហរដ្ឋអាមេរិក បែលហ្សិក និងលុច្សសំបួរ ដើម្បីធ្វើបទបង្ហាញពីការសិក្សាស្រាវជ្រាវការដ្ឋានស្លសំរឹទ្ធនិងលទ្ធផលដែលបានរកឃើញកន្លងមក។

គួរបញ្ជាក់ផងដែរថា នៅស្រុកខ្មែរត្រូវបានគេរកឃើញការដ្ឋានស្លសំរឹទ្ធធំជាងគេបង្អស់នៅក្នុងរាជវាំងអង្គរធំ និងសិក្សាបានលទ្ធផលច្រើនជាងគេផងដែរនៅក្នុងតំបន់អាស៊ីអាគ្នេយ៍។

អាស្រ័យហេតុនេះ អាជ្ញាធរជាតិអប្សរាសូមគោរពអញ្ជើញដល់សាធារណជនទូទៅ សិស្ស និស្សិត មន្ត្រីរាជការ មគ្គុទ្ទេសក៍ទេសចរ អ្នកសិក្សាស្រាវជ្រាវជាតិ-អន្តរជាតិ ដែលមានបំណងចង់ស្វែងយល់ចំណេះដឹងបន្ថែមពីបច្ចេកទេសសំយោគលោហៈ សូមចូលរួមស្តាប់ដោយមេត្រី នាព្រឹកថ្ងៃទី១១ ខែមករា ឆ្នាំ២០១៨ វេលាម៉ោង៨.០០នាទីព្រឹក ដល់ម៉ោង១១.៣០នាទីថ្ងៃត្រង់ នៅមជ្ឈមណ្ឌលបណ្តុះបណ្តាលអង្គរនៃអាជ្ញាធរជាតិអប្សរា៕



ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរាចូលរួមគោរពវិញ្ញាណក្ខន្ធ អតីតយុទ្ធជននៅក្នុងឱកាស រំឲ្យកឧបលើកទី៣៩ នៃទិវាជ័យជម្នះ៧មករា (៧.០១.១៩៧៩-៧.១.២០១៨)

ផ្សាយនៅថ្ងៃទី ០៧ ខែ មករា ឆ្នាំ២០១៨

នាព្រឹកថ្ងៃទី៧ មករា ឆ្នាំ២០១៨នេះ ថ្នាក់ដឹកនាំនៃអាជ្ញាធរជាតិអប្សរាដឹកនាំដោយ **ឯកឧត្តម ហង់ ពៅ** អគ្គនាយករងតំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមបណ្ឌិត ស៊ុ ម៉ាប់** អគ្គនាយកអាជ្ញាធរជាតិអប្សរា បានចូលរួមគោរពវិញ្ញាណក្ខន្ធអតីតវីរយុទ្ធជនយុទ្ធនារី នៅវិមានរំឲ្យកគុណអតីតវីរយុទ្ធជនខេត្តសៀមរាប ដែលប្រារព្ធឡើងក្រោមអធិបតីភាព **សម្តេចពិជ័យសេនា ទៀ ឌាញ់** ឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងការពារជាតិ។

ពិធីគោរពវិញ្ញាណក្ខន្ធនេះ ត្រូវបានរៀបចំឡើងស្របពេលដែលរាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាប្រជាពលរដ្ឋទូទាំងប្រទេសរៀបចំខួបទី៣៩ នៃទិវាជ័យជម្នះ៧មករា១៩៧៩។ ទិវាជ័យជម្នះ៧មករា ជាទិវាប្រវត្តិសាស្ត្រមិនអាចបំភ្លេចបានដែលរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាបានសង្គ្រោះ ជីវិតប្រជាជនខ្មែររាប់លានអ្នក និងរំដោះប្រទេសជាតិពីរបបប្រល័យពូជសាសន៍។

តាមរយៈជ័យជម្នះដ៏មានន័យនេះហើយ ដែលបាននាំមកនូវសន្តិភាព និងការអភិវឌ្ឍលើគ្រប់វិស័យក្នុងប្រទេសកម្ពុជា ដោយរួមបញ្ចូលទាំងការងារអភិរក្ស ជួសជុល និងស្តារឡើងវិញនូវបេតិកភណ្ឌជាតិ និងបេតិកភណ្ឌពិភពលោកអង្គររបស់កម្ពុជា។









អាជ្ញាធរជាតិអប្សរា៖ ស្វែងយល់ពីរបៀបជួសជុលបំណែកកុលាលភាជន៍ខ្មែរបុរាណ

ផ្សាយនៅថ្ងៃទី ០៩ ខែ មករា ឆ្នាំ២០១៨

សម្ភារៈប្រើប្រាស់បុរាណដែលបុព្វបុរសបានផលិតឡើងពីដីដុតដូចជា ក្អម ខួច ចាន ពែង ជាដើម ត្រូវបានអ្នកស្រាវជ្រាវកំណត់ឈ្មោះជារួមថា កុលាលភាជន៍ (Ceramic)។ រយៈពេលជាង២០ឆ្នាំនៃការធ្វើកំណាយ អ្នកស្រាវជ្រាវនៃអាជ្ញាធរជាតិអប្សរា និងដៃគូបរទេសបានរកឃើញនិងប្រមូលបំណែកកុលាលភាជន៍បានជាង៩ម៉ឺនបំណែក យកមករក្សាទុកក្នុងអង្គភាពកុលាលភាជន៍អង្គរនៃអាជ្ញាធរជាតិអប្សរា។

បច្ចុប្បន្ន ក្រុមការងារនៃអង្គភាពកុលាលភាជន៍អង្គរកំពុងធ្វើការចុះបញ្ជី និងជួសជុលនូវបំណែកធំៗ ដើម្បីឲ្យលេចចេញជារូបរាងដើមនៃកុលាលភាជន៍បុរាណឡើងវិញ។ រហូតមកទល់ពេលនេះ អ្នកជំនាញសម្រេចការជួសជុលបានចំនួន១៩កុលាលភាជន៍និងកំពុងបន្តជួសជុលនូវបំណែកផ្សេងៗទៀត។

លោក ធី សេរីឌ្ឍ មន្ត្រីជំនាញផ្នែកបុរាណវិទ្យា និងទទួលបានការបណ្តុះបណ្តាលបន្ថែមលើការជួសជុលកុលាលភាជន៍បុរាណ ដែលកំពុងបំពេញការងារផ្នែកជួសជុលនៅក្នុងអង្គភាពនេះបានបញ្ជាក់ថា ការងារជួសជុលកុលាលភាជន៍បុរាណត្រូវធ្វើឡើងជា៥ដំណាក់កាល គឺ ការសម្អាត ការតភ្ជាប់ ការបំពេញចន្លោះដោយម្នាងសិលា ការលាបថ្នាំ និងការចុះលេខបញ្ជី។

លោក សេរីឌ្ឍ ពន្យល់បន្តថា ដំណាក់កាលទី១ ជាដំណាក់កាលសម្អាតកម្ចាត់សារធាតុអំបិលដែលតោងស្អិតនៅជាប់កុលាភាជន៍ចេញ ដោយយកកុលាលភាជន៍ទៅត្រាំទឹកស្អាត។ ដំណាក់កាលទី២ គឺពង្រឹងមុខកាត់ដែលបែក រួចយកបំណែកកុលាភាជន៍ទាំងនោះមកផ្គុំបញ្ចូលគ្នាដើម្បីរកបំណែកដែលបាត់ ឬខូចខាត។ ដំណាក់កាលទី៣ គឺ ត្រូវប្រើប្រាស់ម្នាងសិលាយកមកបិទបំពេញចន្លោះ ក្នុងករណីដែលបំណែកកុលាភាជន៍មានការបាត់បង់ត្រង់ចំណុចរឹងមាំ។ ដំណាក់កាលទី៤ គឺលាបពណ៌លើម្នាងសិលាដើម្បីអោយពណ៌ស៊ីគ្នានឹងកុលាលភាជន៍។ ដំណាក់កាលទី៥ ដែលជាដំណាក់កាលចុងក្រោយ គឺ អ្នកអភិរក្សត្រូវចុះបញ្ជីសារពើភណ្ឌទៅក្នុងប្រព័ន្ធទិន្នន័យ ស្តីពីប្រវត្តិនៃការជួសជុលកុលាលភាជន៍នីមួយៗ ដើម្បីទុកជាឯកសារ។

កុលាលភាជន៍ដែលបានជួសជុលហើយ នឹងត្រូវយកទៅដាក់តាំងបង្ហាញជូនសាធារណជនចូលទស្សនា នៅសារមន្ទីរព្រះនរោត្តម សីហនុ-អង្គរ។ តាមរយៈពិព័រណ៌នេះ នឹងជួយឲ្យសាធារណជនបានយល់ដឹងអំពីតម្លៃបេតិកភណ្ឌ បណ្តុះចិត្តគំនិតស្រឡាញ់ និងចូលរួមថែរក្សាការពារទាំងអស់គ្នា៕






ក្រុមការងារចម្រុះកំពុងចុះហោះបង្គោលព្រំដីរដ្ឋដែលបុក្កលឯកជនបំពានយក

ផ្សាយនៅថ្ងៃទី ១០ ខែ មករា ឆ្នាំ២០១៨

នាព្រឹកថ្ងៃទី១០ ខែមករា ឆ្នាំ២០១៨ កម្លាំងចម្រុះនៃអាជ្ញាធរអប្សរានិងសាលាខេត្តសៀមរាប ដែលមានការចូលរួមពីអាជ្ញាធរក្រុងសៀមរាប មន្ត្រីជំនាញអាជ្ញាធរជាតិអប្សរា មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់និងសុរិយោដី អាជ្ញាធរក្រុងសៀមរាប មេធាវីប្រចាំអាជ្ញាធរអប្សរា រួមនឹងមន្ត្រីពាក់ព័ន្ធផ្សេងទៀត កំពុងចុះអនុវត្តការបោះបង្គោលកំណត់ព្រំដីរដ្ឋ ដែលគ្រប់គ្រងដោយអាជ្ញាធរជាតិអប្សរាស្ថិតនៅតំបន់ផ្លូវ៦០ម៉ែត្រ។

ការចុះអនុវត្តការងារនេះ ក្នុងបំណងទប់ស្កាត់ការរំលោភបំពានយកដីរបស់រដ្ឋទៅគ្រប់គ្រងធ្វើជាកម្មសិទ្ធិឯកជនពីសំណាក់បុគ្គលមួយចំនួន៕








គណៈកម្មការចម្រុះអាជ្ញាធរជាតិអប្សរានិងសាលាខេត្តសៀមរាប ចុះចោះបង្គោលកំណត់ព្រំដីកម្មសិទ្ធិរបស់រដ្ឋ

ផ្សាយនៅថ្ងៃទី ១១ ខែ មករា ឆ្នាំ២០១៨

នាព្រឹកថ្ងៃទី១០ ខែមករា ឆ្នាំ២០១៨ គណៈកម្មការចម្រុះនៃអាជ្ញាធរជាតិអប្សរានិងសាលាខេត្តសៀមរាប រួមមាន មន្ត្រីជំនាញអាជ្ញាធរជាតិអប្សរា សាលាក្រុងសៀមរាប មន្ត្រីជំនាញមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី មេធាវីប្រចាំអាជ្ញាធរជាតិអប្សរា រួមនឹងមន្ត្រីពាក់ព័ន្ធផ្សេងទៀត បានចុះអនុវត្តការបោះបង្គោលកំណត់ព្រំដីជាកម្មសិទ្ធិរបស់រដ្ឋ ដែលគ្រប់គ្រងដោយអាជ្ញាធរជាតិអប្សរាស្ថិតនៅភូមិធ្លកអណ្តូង(ចុងកៅស៊ូ) សង្កាត់ស្លក្រាម ក្រុងសៀមរាប (តំបន់ផ្លូវ១០ម៉ែត្រ)។

តាមការបញ្ជាក់ពី **ឯកឧត្តម ភុំ ប៊ុនឆាន់** មេធាវីរបស់អាជ្ញាធរជាតិអប្សរាឱ្យដឹងថា ការចុះបោះបង្គោលព្រំដី គឺដើម្បីកំណត់ព្រំដីរវាងដីរដ្ឋគ្រប់គ្រងដោយអាជ្ញាធរជាតិអប្សរា និងដីឯកជនរបស់ បុគ្គល លី អ៊ុំអេង ដែលបុគ្គលរូបនេះបានចាក់ដីបំពានរំលោភយកដីកម្មសិទ្ធិរបស់រដ្ឋធ្វើជាកម្មសិទ្ធិឯកជនរបស់ខ្លួន និងយកទៅពុះជាដីឡូត៍សម្រាប់លក់។ ការកំណត់ព្រំដីឱ្យច្បាស់លាស់នៅថ្ងៃនេះ គឺដើម្បីចៀសវាងទំនាស់នៅថ្ងៃក្រោយ និងដើម្បីឱ្យ បុគ្គល លី អ៊ុំអេង បញ្ឈប់សកម្មភាពបំពានយកដីកម្មសិទ្ធិរបស់រដ្ឋធ្វើជាកម្មសិទ្ធរបស់ខ្លួនតាមអំពើចិត្តទៅទៀត។

ដីកម្មសិទ្ធិរបស់រដ្ឋដែលរំលោភបំពានយកធ្វើជាកម្មសិទ្ធិឯកជនដោយ បុគ្គល លី អ៊ុំអេង មានចំនួន៣ទីតាំង ដែលទីតាំងនីមួយៗស្ថិតនៅជាប់ព្រំដីកម្មសិទ្ធិ ឯកជនរបស់បុគ្គលនេះ។ បច្ចុប្បន្នដីកម្មសិទ្ធិរបស់រដ្ឋទាំង៣ ទីតាំងនេះត្រូវបាន បុគ្គល លី អ៊ុំអេង យកទៅពុះជាដីឡូត៍សម្រាប់លក់ជាសាធារណៈ។

មានវត្តមានក្នុងការកំណត់ព្រំដីកម្មសិទ្ធិរបស់រដ្ឋនាពេលនោះ **លោក សូរ ប្ផាគុង** អភិបាលក្រុងសៀមរាប បានសម្តែងនូវការគាំទ្រចំពោះចំណាត់ការរបស់គណៈកម្មការចម្រុះ ជាពិសេសបញ្ជាក់ពីការគាំទ្រយ៉ាងពេញទំហឹងរបស់អភិបាលនៃគណៈអភិបាលខេត្តសៀមរាបលើការងារនេះ។ **លោក សូរ ប្ផាគុង** បានបញ្ជាក់បន្ថែមទៀតថា មានឯកសារគតិយុត្តិជាច្រើនត្រូវបានផ្សព្វផ្សាយជាសាធារណៈប៉ុន្តែ បុគ្គល លី អ៊ុំអេង នៅតែរំលោភចាក់ដីបំពានទៅលើដីកម្មសិទ្ធិរបស់រដ្ឋដែលគ្រប់គ្រងដោយអាជ្ញាធរជាតិអប្សរា ដែលទង្វើនេះត្រូវតែទប់ស្កាត់ឱ្យបាន។លោកក៏បានសំណូមពរ ប្រជាពលរដ្ឋជាម្ចាស់ដីទាំងអស់ធ្វើយ៉ាងណាចូលរួមសហការជាមួយគណៈកម្មការចម្រុះ និងបញ្ឈប់នូវសកម្មភាពទាំងអស់ដែលប៉ុនប៉ងរំលោភយកដីរដ្ឋធ្វើជាកម្មសិទ្ធិឯកជនរបស់ខ្លួន៕






សម្រស់ដ៏ត្រកាលនៃទិដ្ឋភាពថ្ងៃរះពីលើប្រាសាទភ្នំបាខែង

ផ្សាយនៅថ្ងៃទី ១២ ខែ មករា ឆ្នាំ២០១៨

ប្រាសាទភ្នំបាខែង ក្រៅពីមានសំណង់ស្ថាបត្យកម្មដ៏ល្អវិសេសវិសាលហើយ ទីតាំងប្រាសាទនេះ ក៏ជាកន្លែងមើលទេសភាពប្រាសាទអង្គរវត្ត បារាយណ៍ទឹកថ្លា ជួរភ្នំគូលែន សម្រស់ព្រៃឈើនៅក្នុងឧទ្យានអង្គរ ជាពិសេសអ្វីដែលភ្ញៀវទេសចរជាតិអន្តរជាតិតែងតែចង់មើលបំផុតគឺទិដ្ឋភាពថ្ងៃរះនិងថ្ងៃលិចដ៏ស្រស់ត្រកាលពីលើប្រាសាទនេះ។

ចង់ដឹងថាសម្រស់ដ៏ស្រស់ស្អាតនាពេលអរុណោទ័យ និងពេលព្រះអាទិត្យរះមើលពីប្រាសាទភ្នំបាខែងគួរឱ្យចង់គយគន់ប៉ុណ្ណានោះសូមអញ្ជើញទស្សនាកម្រងរូបភាពដែលផ្តិតរូបភាពដោយភ្នាក់ងារទេសចរណ៍នៃអាជ្ញាធរជាតិអប្សរាដូចតទៅ៖








អបអរសាទរប្រាសាទភិមានអាកាសនឹងឧទ្ធូលចានការជួសជុលឡើងវិញឆាប់ៗខាងមុខនេះ

ផ្សាយនៅថ្ងៃទី ១២ ខែ មករា ឆ្នាំ២០១៨

ប្រាសាទភិមានអាកាសអតីតព្រះបរមរាជវាំងនៃក្រុងអង្គរធំ នឹងត្រូវជួសជុលឡើងវិញក្នុងពេលឆាប់ៗខាងមុខនេះ ដោយក្រុមរដ្ឋាភិបាលចិនសម្រាប់ការអភិរក្សអង្គរ ហៅកាត់ថា CSA (Chinese government team for Safegaurding Angkor) នៃសាធារណរដ្ឋប្រជាមានិតចិន។

តាមកិច្ចពិភាក្សាដែលធ្លាប់មានកន្លងមករវាងថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា និង បណ្ឌិតសភាចិនផ្នែកបេតិកភណ្ឌវប្បធម៌ កិច្ចសហប្រតិបត្តិការដើម្បីការជួសជុលព្រះបរមរាជវាំងទីងក្រុងអង្គរធំអាចនឹងប្រព្រឹត្តទៅនៅពាក់កណ្តាលឆ្នាំ២០១៨ខាងមុខនេះ។

តាមសេចក្តីប្រកាសរួមនៃដំណើរទស្សនកិច្ចផ្លូវការរបស់ **ឯកឧត្តម លី ខឺឈាង** នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាមានិតចិន មកកាន់កម្ពុជា ពីថ្ងៃទី១០-១១ ខែមករា ឆ្នាំ២០១៨ កន្លងទៅនេះ ថ្នាក់ដឹកនាំនៃប្រទេសទាំងពីរក៏បានធ្វើជាអធិបតីនៃការចុះអនុស្សារណៈនៃការយោគយល់គ្នាលើឯកសារចំនួន១៩ ដែលក្នុងនោះក៏មានឯកសារស្តីពី លិខិតប្តូរសារនៃពីការជួសជុលនៅរាជវាំងក្រុងអង្គរធំដែរ។

សូមជម្រាបថា CSA នៃសាធារណរដ្ឋមានិតចិនបានចូលរួមជួសជុលប្រាសាទចៅសាយទេវតាក្នុងឆ្នាំ១៩៩៨ និងរួចរាល់នៅឆ្នាំ២០០៨ ហើយចាប់ជួសជុលប្រាសាតាកែវចាប់ពីឆ្នាំ២០០៧ បញ្ចប់នៅចុងឆ្នាំ២០១៧។ បច្ចុប្បន្ន CSA កំពុងរៀបចំគម្រោងដើម្បីធ្វើការជួសជុលអតីតរាជវាំងក្រុងអង្គរធំជាបន្តទៀត។





ម្រោងសុកុឌ្ឍិកម្មនៃការសម្អាតទឹក និងការគ្រប់គ្រងទឹកក្នុងតំបន់អង្គរបន្ថាញលទ្ធផលជាវិជ្ជមាន ជុំវិញគម្រោងសាកល្បងទីផ្សារអនាម័យនៅតំបន់អង្គរ

ផ្សាយនៅថ្ងៃទី ១៦ ខែ មករា ឆ្នាំ២០១៨

នៅព្រឹកថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៨ គម្រោងសុវុឌ្ឍិកម្មនៃការសម្អាតទឹក និងការគ្រប់គ្រងទឹកក្នុងតំបន់អង្គរ (PAAGERA) បានរៀបចំបទបង្ហាញស្តីពីលទ្ធផលគម្រោងសាកល្បងទីផ្សារអនាម័យ ដើម្បីចែករំលែកបទពិសោធន៍ ដល់មន្ត្រីបុគ្គលិក៣៥រូបនៃអាជ្ញាធរជាតិអប្សរាដែលធ្វើការងារពាក់ព័ន្ធនឹងការអប់រំប្រជាពលរដ្ឋ។

ការធ្វើបទបង្ហាញនៅពេលនេះ គឺធ្វើឡើងក្រោយពីគម្រោងបានអនុវត្តកម្មវិធីទីផ្សារអនាម័យទៅលើឃុំចំនួន២ ក្នុងស្រុកបន្ទាយស្រី គឺឃុំរុនតាឯក និងឃុំរំចេក ពីខែមករា ដល់ឧសភា ឆ្នាំ២០១៧កន្លងទៅ។ តាមរយៈបទបង្ហាញដោយ **លោក សេង គុយស្រ៊ាន់** ទីប្រឹក្សាគម្រោង PAAGERA បង្ហាញថា គម្រោងទីផ្សារអនាម័យធ្វើឡើងដោយអនុវត្តជាមួយភ្នាក់ងារលក់បង្គន់ ដោយការបណ្តុះបណ្តាលភ្នាក់ងារលក់ និងការអប់រំផ្សព្វផ្សាយផ្ទាល់ជាមួយសហគ្រាសផលិតបង្គន់។ ជាមួយគ្នានេះ ក្រុមការងារក៏សហការជាមួយអជ្ញាធរមូលដ្ឋានដោយជំរុញ និងលើកទឹកចិត្តប្រជាជនចូលរួមសហការនិងសាងសង់បង្គន់ តាមដាននិងសហការជាមួយភាគីពាក់ព័ន្ធផ្សេងៗទៀត។

លោក គុយស្រ៊ាន់ ក៏បានបង្ហាញលទ្ធផលដែលមានការរីកចម្រើនគួរឲ្យកត់សម្គាល់នៃការអនុវត្តគម្រោងដូចជា ក្រោយអនុវត្តគម្រោង បង្គន់លក់បានចំនួន៣៣១ ក្នុងនោះឃុំគោលដៅបានចំនួន១១៦បង្គន់។ ដោយគិតជារួម ឃុំរំចេកមានគ្រួសារដែលមានបង្គន់ប្រើប្រាស់កើនឡើង៥% ស្មើនឹង៥៧% (មុនអនុវត្តគម្រោងមានត្រឹមតែ៥២%) ចំណែកឃុំរុនតាឯកកើនឡើងចំនួន៨%ស្មើនឹង៣៣%(មុនគម្រោងមានត្រឹមតែ២៥%)។

លោកជូ វ៉ាឌីណា អ្នកសម្របសម្រួលគម្រោងមានប្រសាសន៍ថា គម្រោងសាកល្បងទីផ្សារអនាម័យក្នុងតំបន់អង្គរមានគោលដៅបញ្ឈប់ការបន្ទោបង់ពាសវាលពាសកាល ស្របតាមយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជាដែលបានដាក់ចេញបញ្ហាអនាម័យគឺធ្វើយ៉ាងណាឱ្យប្រជាពលរដ្ឋមានបង្គន់អនាម័យសមស្របនៅឆ្នាំ២០២៥។

លោកបញ្ជាក់ថាបន្ទាប់ពីបញ្ចប់គម្រោងនេះជោគជ័យ នឹងមានការអនុវត្តនៅភូមិ ឃុំផ្សេងៗទៀតក្នុងតំបន់អង្គរ។ ជាចុងក្រោយលោក **ជូ វ៉ាឌីណា** ក៏បានស្នើដល់ប្រជាពលរដ្ឋឱ្យចូលរួមសហការជាមួយក្រុមការងារអាជ្ញាធរអប្សរា ដែលចុះផ្សព្វផ្សាយក្នុងការប្រើប្រាស់បង្គន់ និងឱ្យពួកគាត់ចូលរួមឱ្យបានច្រើនពិសេសអ្នកដែលមិនទាន់មានបង្គន់សម្រាប់ប្រើប្រាស់ហើយផ្លាស់ប្តូរទម្លាប់ពីការបន្ទោបង់ពាសវាលពាសកាលមកប្រើប្រាស់បង្គន់អនាម័យវិញ៕









ប្រាសាទអង្គរវត្ត ៖ ពាងទងកូរសមុទ្រទឹកដោះនឹងមានការបំពាក់ពិតានឡើងវិញ

ផ្សាយនៅថ្ងៃទី ១៦ ខែ មករា ឆ្នាំ២០១៨

រោងទងកូរសមុទ្រទឹកដោះនៃប្រាសាទអង្គរវត្តដែលស្ថិតនៅផ្នែក អាគ្នេយ៍ នឹងត្រូវធ្វើការបំពាក់ពិតានឡើងវិញ។ ការបំពាក់ពិតានឈើនៅលើរោងទងកូរសមុទ្រទឹកដោះនៅប្រាសាទអង្គរវត្ត ជាគម្រោងសហការនៃអាជ្ញាធរជាតិអប្សរា និងអង្គការមូលនិធិប្រាសាទបុរាណពិភពលោក (World Monument Fund-WMF) របស់សហរដ្ឋអាមេរិក។

អ្នកសម្របសម្រួលអង្គការមូលនិធិប្រាសាទបុរាណពិភពលោកនិងជាអ្នកអនុវត្តគម្រោង **លោកស្រី ជាម ផល្លី** បានឲ្យដឹងថាគម្រោងនេះអាចនឹងបញ្ចប់នៅពេលណាបានទេ ព្រោះពិតានឈើថ្មីទាំងនេះឆ្លាក់តែជាងចម្លាក់ម្នាក់គត់។ តាមការរៀបរាប់របស់លោកស្រី ពិតានឈើទាំងអស់ត្រូវឆ្លាក់តាមទម្រង់ដើម ដែលមានបន្សល់ទុកតាំងបុរាណកាលមក។ ម្យ៉ាងទៀតទាំងសមត្ថភាពឆ្លាក់និងគុណភាពរូបចម្លាក់ក៏ត្រូវទទួលស្គាល់ដោយគណៈកម្មការអាយស៊ីស៊ី-អង្គរដែរ។

ឈើដែលត្រូវយកមកឆ្លាក់ធ្វើជាពិតានគឺប្រភេទឈើគគីរ។ ហេតុផលដែលជ្រើសរើសឈើគគីរ ព្រោះថាឈើពិតានដែលបន្សល់ពីបុរាណនិងរក្សាទុកនៅសារមន្ទីរជាតិភ្នំពេញ និងសារមន្ទីរនៅប្រទេសបារាំង ក៏ជាប្រភេទឈើគគីរដែរ។ **លោកស្រី ជាម ផល្លី** ពន្យល់ថា សាច់ឈើគគីរធន់នឹងទឹកហើយគម្រោងនេះត្រូវការឈើគគីរប្រមាណជាង ១០ម៉ែត្រគីប។ ប៉ុន្តែអ្វីដែលជាបញ្ហានៅពេលនេះគឺកង្វះឈើដែលធ្វើឱ្យគម្រោងមានភាពយឺតយ៉ាវ។

គម្រោងបំពាក់ពិតានឈើថ្មីលើរោងទងកូរសមុទ្រទឹកដោះនេះ ទទួលបានការគាំទ្រពីគណៈកម្មាធិការអាយស៊ីស៊ីអង្គរ តាំងសម័យកិច្ចប្រជុំបច្ចេកទេសលើកទី២៥ នៅថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៥កន្លងមក។ **លោក លី វណ្ណា** ប្រធាននាយកដ្ឋានអភិរក្សក្នុងឧទ្យានអង្គរ និងបុរាណវិទ្យាបង្ការនៃអាជ្ញាធរជាតិអប្សរា ធ្លាប់លើកឡើងថា ពិតានឈើថ្មីដែលនឹងត្រូវយកទៅបំពាក់លើថែវកូរសមុទ្រទឹកដោះនេះ គឺមានឆ្លាក់ចម្លាក់ក្បាច់ ធ្វើតាមសំណល់បុរាណដោយមានក្បាច់ចំនួន១០ប្រភេទ គឺ ក្បាច់ផ្កាចាន់ ក្បាច់ផ្កាពងត្រី ក្បាច់ត្រឡាចបំបែក ក្បាច់ពេជ្រក្តារ ក្បាច់ចែងអង្គរ ក្បាច់ស្នឹងព័ទ្ធ ក្បាច់សន្លឹកឈូកបំបែក ក្បាច់ពងត្រីរង្វង់ក្បាច់កេសរនិងក្បាច់ផ្លែឈូក។

គួរបញ្ជាក់ថានៅឆ្នាំ២០០៨រហូតដល់ឆ្នាំ២០១២ អាជ្ញាធរជាតិអប្សរានិងអង្គការមូលនិធិប្រាសាទបុរាណពិភពលោក បានជួសជុលដំបូលរោងទងកូរសមុទ្រទឹកដោះដើម្បីរក្សាឲ្យបាននូវផ្ទាំងចម្លាក់ដែលរៀបរាប់ពីការកូរសមុទ្រទឹកដោះតាមរយៈការទាញព្រ័តយកឈ្នះចាញ់រវាងពួកទេពនិងពួកអសុរ។ ឯការជួសជុល ចាំបាច់ត្រូវប្រើប្រាស់បន្ទះសំណ ពី២ទៅ៣មីលីម៉ែត្រធ្វើយ៉ាងណាកុំឱ្យទឹកលិចដំបូលដែលនឹងអាចប៉ះពាល់ដល់ចម្លាក់។









ស្ថាប័នជានាគុណភាពជប៉ុនធ្វើសវនកម្មលើប្រព័ន្ធគ្រប់គ្រងបរិស្ថានអង្គរនៃអាជ្ញាធរជាតិអប្សរា-

ផ្សាយនៅថ្ងៃទី ១៦ ខែ មករា ឆ្នាំ២០១៨

ស្ថាប័នជានាគុណភាពជប៉ុន (Japanese Quality Assurance) បានបើកសវនកម្មប្រចាំឆ្នាំលើការងារគ្រប់គ្រងបរិស្ថាននៃអាជ្ញាធរជាតិអប្សរា រយៈពេល៣ថ្ងៃ ចាប់ពីថ្ងៃទី១៦ដល់ទី១៨ ខែមករា ឆ្នាំ២០១៨។ ពិធីបើកដំណើរការសវនកម្ម បានធ្វើឡើងនៅព្រឹកថ្ងៃទី១៦ ខែមករា ក្រោមអធិបតីភាព **ឯកឧត្តម សុខ លក្ខិណា** ប្រធានអង្គភាពគ្រប់គ្រងប្រព័ន្ធបរិស្ថាននៃអាជ្ញាធរជាតិអប្សរា និងជាតំណាងអគ្គនាយកអាជ្ញាធរជាតិអប្សរា និងសវនករនៃស្ថាប័ន JQA ចំនួន២រូប គឺ **លោក Kozo Sakurada** និង **លោកYamadaMamoru**។

សវនករនៃស្ថាប័ន JQA **លោក Kozo Sakurada** លើកឡើងថា សវនកម្មលើកនេះជាការអនុវត្តស្តង់ដារថ្មី ISO14001-2015 ដោយក្នុងពេលសវនកម្មត្រូវផ្តោតលើ៥ចំណុច ដូចជា ភាពមិនអនុលោកម្រិតធ្ងន់ធ្ងរ ភាពមិនអនុលោមកម្រិតស្រាល ឱកាសសម្រាប់កែលម្អ (ចំណុចតាមសង្កេត) ចំណុចល្អ និងចំណុចខ្លាំងរបស់នាយកដ្ឋានឬអង្គភាពទាំង១៦នៃអាជ្ញាធរជាតិអប្សរា។ ជាមួយគ្នានេះដែរ សវនកម្មក៏នឹងវាយតម្លៃផងដែរ តើស្ថាប័នអាជ្ញាធរជាតិអប្សរាដែលបានទទួលវិញ្ញាបនបត្រ ISO14001ដល់ទៅ៤លើកមកហើយនោះ បានពិនិត្យឡើងវិញនូវប្រព័ន្ធគ្រប់គ្រងរបស់ខ្លួនឱ្យអនុលោមទៅនឹងស្តង់ដារថ្មី ISO14001-2015 ហើយឬនៅ? និងបានបំពេញចំណុចកំណត់ដោស្តង់ដារថ្មីនេះហើយឬនៅ? តាមរយៈសវនកម្មនេះ ក្រុមការងារគ្រប់គ្រងប្រព័ន្ធបរិស្ថាន និងក្រុមជំរុញការងារបរិស្ថាននៃអាជ្ញាធរជាតិអប្សរា កាន់តែយកចិត្តទុកដាក់និងមានស្មារតីបន្ថែមទៀតលើបញ្ហានេះ។

មានប្រសាសន៍ក្នុងពិធីបើកនេះ **ឯកឧត្តម សុខ លក្ខិណា** លើកឡើងថា អាជ្ញាធរជាតិអប្សរាពិតជាមានមោទនភាពណាស់ ដែលអង្គរទទួលបានវិញ្ញាបនបត្រ ISO14001 ពីស្ថាប័នធានាគុណភាពរបស់ជប៉ុនជាបន្តបន្ទាប់ ហើយរមណីយដ្ឋានអង្គរគឺជារមណីយដ្ឋានបេតិកភណ្ឌពិភពលោកតែមួយគត់ ដែលបានទទួលវិញ្ញាបនបត្រគ្រប់គ្រងប្រព័ន្ធបរិស្ថាន។ តាមរយៈវិញ្ញាបនបត្រនេះ អង្គរបានជាប់ចំណាត់ថ្នាក់ជាគោលដៅទេសចរណ៍លេខ១លើពិភពលោកដែរ។ យើងនឹងខិតខំបន្តទៀត ដើម្បីទទួលបានវិញ្ញាបនបត្រក្នុងដំណាក់កាលបន្ទាប់និងដើម្បីភាពស្រស់ស្អាតនៃបរិស្ថានអង្គររបស់យើង។

ឯកឧត្តមក៏បានជំរុញឲ្យនាយកដ្ឋានឬអង្គភាពទាំងអស់ ត្រៀមលក្ខណៈ និងទទួលស្វាគមន៍សវនករ JQA ក្នុងដំណើរការធ្វើសវនកម្មលើស្តង់ដារថ្មីនៅពេលនេះ។ ឯកឧត្តមបញ្ជាក់ថា លទ្ធផលដែលយើងទទួលបានកន្លងមក ក៏មិនមែនដើម្បីសម្រាប់តែអាជ្ញាធរជាតិអប្សរាប៉ុណ្ណោះទេតែសម្រាប់ប្រជាជនកម្ពុជានិងជាតិរបស់យើងទាំងមូល៕






សេចក្តីប្រកាសព័ត៌មាន

ផ្សាយនៅថ្ងៃទី ១៦ ខែ មករា ឆ្នាំ២០១៨

អាជ្ញាធរជាតិអប្សរាសូមប្រកាសជូនសាធារណជនដែលបានទិញដីឡូត៍ពីក្រុមហ៊ុនហ្គោលឌែន អ៊ីហ្គល រៀលអ៊ិស្ទេត ខូអិលធីឌី ដែលមានទីតាំងនៅភូមិធ្លកអណ្តូង សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប (ចំណុចផ្លូវ៦០ម៉ែត្រឬអង្គរយ្យុងយូ) មកធ្វើការពិនិត្យផ្ទៀងផ្ទាត់ក្បាលដីជាមួយក្រុមការងារអន្តរក្រសួងដោះស្រាយគោលនយោបាយដីធ្លីបុរីវប្បធម៌ទេសចរណ៍ នៅមជ្ឈមណ្ឌលអាជ្ញាធរជាតិអប្សរា ដើម្បីជៀសវាងការខូចខាតផលប្រយោជន៍ជាយថាហេតុ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA
លេខ ៦ពាណ្ឌ្យ.សហ

សេចក្តីប្រកាសព័ត៌មាន

អាជ្ញាធរជាតិអប្សរា មានកិត្តិយសសូមជម្រាបជូនសាធារណជនមេត្តាជ្រាបថា កាលពីថ្ងៃពុធ ៩រោច ខែបុស្ស ឆ្នាំរកា នព្វស័ក ពស ២៥៦១ ត្រូវនឹងថ្ងៃទី១០ ខែមករា ឆ្នាំ ២០១៨ ក្រុមការងារចម្រុះដែលមានសមាសភាពចូលរួមពី សាលាខេត្តសៀមរាប សាលាក្រុងសៀមរាប មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តសៀមរាប និង អាជ្ញាធរជាតិអប្សរា បានចុះកំណត់ព្រំដី និងបោះបង្គោលព្រំដី រវាងក្បាលដីរបស់រដ្ឋ ដែលគ្រប់គ្រងដោយអាជ្ញាធរជាតិអប្សរាជាមួយនឹងក្បាលដីលេខ ៤៩៨៩ របស់ឈ្មោះ លី អ៊ុំអេង ស្ថិតនៅភូមិធ្លកអណ្តូង សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប នៅចំណុចផ្លូវ ៦០ម៉ែត្រ ឬអង្គរយ្យុងយូ។

នៅពេលអនុវត្តការងារកំណត់ព្រំដី និងបោះបង្គោលព្រំដីនេះ ក្រុមការងារចម្រុះ បានសង្កេតឃើញថា មានការចាក់បំពេញអាចម៍ដី និងរៀបចំពុះជាដីឡូត៍សម្រាប់លក់ ទាំងនៅលើក្បាលដីរបស់ឈ្មោះ លី អ៊ុំអេង និងក្បាលដីរបស់រដ្ឋ ក្រោមគម្រោងពុះដីឡូត៍ ផ្ទះល្វែង វីឡា ផ្សាររាត្រី របស់ ក្រុមហ៊ុន ហ្គោលឌែន អ៊ីហ្គល រៀលអ៊ិស្ទេត ខូអិលធីឌី។ ដូច្នេះ ដើម្បីជៀសវាងការខូចខាតផលប្រយោជន៍ ជាយថាហេតុ ដោយសារការទិញដី ពីគម្រោងខាងលើប៉ះចំដីរបស់រដ្ឋនោះ សាធារណជនទាំងអស់ដែលបានទិញដីឡូត៍ក្នុងតំបន់នេះ អាចមកធ្វើការពិនិត្យផ្ទៀងផ្ទាត់ជាមួយក្រុមការងារអន្តរក្រសួងដោះស្រាយគោលនយោបាយដីធ្លីបុរីវប្បធម៌ទេសចរណ៍ មានទីតាំងនៅអាជ្ញាធរជាតិអប្សរា រៀងរាល់ម៉ោងធ្វើការពីម៉ោង៨:០០ព្រឹកដល់ម៉ោង៤:០០រសៀល ចាប់ពីពេលនេះរហូតដល់ថ្ងៃពុធ ១៤កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស២៥៦១ ត្រូវនឹងថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៨។

អាជ្ញាធរជាតិអប្សរា មិនទទួលខុសត្រូវ ចំពោះការខូចខាតផលប្រយោជន៍របស់សាធារណ-ជន ដែលបានទិញដីប៉ះចំដីរបស់រដ្ឋ ពីគម្រោងខាងលើនេះឡើយ។

ថ្ងៃសុក្រ ១១រោច ខែបុស្ស ឆ្នាំរកា នព្វស័ក ពស ២៥៦១
សៀមរាប ថ្ងៃទី១២ ខែមករា ឆ្នាំ២០១៨
អាជ្ញាធរជាតិអប្សរា

ភ្នំពេញ:
មហាវិថីសហព័ន្ធរុស្សី លេខ៤១ សង្កាត់មិត្តភាព ខណ្ឌ៧មករា
ទូរសព្ទ/ទូរសារ៖ ០២៣ ២១៥ ៣៣១/០២៣ ២១៥ ៣៣៦
អាជ្ញាធរនីម្មឹការពារអមណ៊ីយម្ពានទិងម្បីបចំតំបន់អង្គរ
Email: info@apsaraauthority.gov.kh
Website: http//www.apsaraauthority.gov.kh
សៀមរាប:
ភូមិបង្កោង ឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប
ទូរសព្ទ/ទូរសារ៖ ០៦៣ ៣៦៥ ៥៣៣/០៦៣ ៣៦៥ ៥៣៦









ប្រតិភូរដ្ឋសភាសាធារណរដ្ឋកូរ៉េទស្សនៈកិច្ចនៅអាជ្ញាធរជាតិអប្សរាស្វែងយល់កម្រោងជួសជុលប្រាសាទព្រះពិធូរ

ផ្សាយនៅថ្ងៃទី ១៨ ខែ មករា ឆ្នាំ២០១៨

នៅព្រឹកថ្ងៃព្រហស្បតិ៍ ២កើត ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស២៥៦១ ត្រូវនឹងថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៨ គណៈកម្មាធិការជំនាញនៃរដ្ឋសភាសាធារណរដ្ឋកូរ៉េទទួលបន្ទុកការងារអប់រំ កីឡា វប្បធម៌ និងទេសចរណ៍ បានសម្តែងការគួរសមជាមួយ **ឯកឧត្តមបណ្ឌិត ស៊ុំ ម៉ាប់** អគ្គនាយកអាជ្ញាធរជាតិអប្សរា និងស្វែងយល់ពីគម្រោងជួសជុលប្រាសាទពិធូរ។ គម្រោងជួសជុលប្រាសាទព្រះពិធូរ គឺជាកិច្ចសហប្រតិបត្តិការរវាងអាជ្ញាធរជាតិអប្សរា និង មូលនិធិបេតិកភណ្ឌវប្បធម៌កូរ៉េ (KOCHEF) និងភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA)។

ជាកិច្ចស្វាគមន៍ **ឯកឧត្តមបណ្ឌិត ស៊ុំ ម៉ាប់** អគ្គនាយកអាជ្ញាធរជាតិអប្សរា បានថ្លែងអំណរគុណដល់គណៈប្រតិភូទាំងអស់ និងបានជម្រាបជូនពីវឌ្ឍនភាពដ៏ប្រសើរនៃគម្រោងជួសជុលប្រាសាទព្រះពិធូរ។ នាពេលនោះដែរ ប្រតិភូគណៈកម្មាធិការជំនាញនៃរដ្ឋសភាសាធារណរដ្ឋកូរ៉េ បានសម្តែងនូវសេចក្តីសប្បាយរីករាយចំពោះលទ្ធផលប្រកបដោយផ្លែផ្កានៃគម្រោងជួសជុលប្រាសាទព្រះពិធូរនេះ និងសន្យាពិនិត្យលទ្ធភាពបន្ថែមដើម្បីជំរុញគម្រោងជួសជុលនេះឲ្យដំណើរការជាបន្តទៀត។ បន្ថែមលើសនោះ ប្រតិភូក៏បានបញ្ជាក់ថានឹងនាំអំពីជោគជ័យទាំងឡាយទៅជូនរដ្ឋសភាសាធារណរដ្ឋកូរ៉េ និងប្រជាជនកូរ៉េដើម្បីបន្តនូវកិច្ចសហប្រតិបត្តិការផ្សេងៗជាច្រើនទៀតជួយដល់ប្រជាជនកម្ពុជា។

គម្រោងកិច្ចសហប្រតិបត្តិការជួសជុលប្រាសាទព្រះពិធូរ គឺដើម្បីជួសជុលស្តារឡើងវិញនូវក្រុមប្រាសាទព្រះពិធូរ មានទីតាំងនៅទល់មុខព្រះលានជល់ដំរី។ គម្រោងនេះចាប់ផ្តើមពីឆ្នាំ២០១៥ និងគ្រោងបញ្ចប់ជំហានដំបូងក្នុងឆ្នាំ២០១៨។ គម្រោងអភិរក្សជួសជុលប្រាសាទព្រះពិធូរមានការងារ៣ធំដែលត្រូវធ្វើគឺ ការងារបណ្តុះបណ្តាលធនធានមនុស្ស ការងារស្រាវជ្រាវចងក្រងឯកសារ និងការងារអភិរក្សជួសជុលស្តារឡើងវិញ។









មេណីយដ្ឋានអង្គរ៖ ទោចម្ពុជកូរជី៣ត្រូវបានព្រលែងក្នុងព្រៃឧទ្យានអង្គរ

ផ្សាយនៅថ្ងៃទី ១៩ ខែ មករា ឆ្នាំ២០១៨

សត្វទោចម្ពុជគូទី៣ ត្រូវបានអាជ្ញាធរជអប្សរា និងអង្គការដៃគូ ធ្វើការព្រលែងនៅក្នុងព្រៃនៃឧទ្យានអង្គរ។ ការព្រលែងនេះធ្វើឡើងនៅព្រឹកថ្ងៃទី១៧ខែមករាឆ្នាំ២០១៨នៅខ្លោងទ្វារតាការវនៃទីក្រុងអង្គរធំ។

លោក យិន សូវ៉ាត អនុប្រធាននាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាននៃអាជ្ញាធរអប្សរា បានឱ្យដឹងថា បច្ចុប្បន្នព្រៃឧទ្យានអង្គរមានសត្វទោចចំនួន១០ក្បាលហើយ។ ទោចម្ពុជដែលព្រលែងនៅពេលនេះ មានចំនួន៣ គឺមេមួយ ឈ្មោលមេ និងកូនមួយ ដែលកូនបានកើតក្នុងទ្រុង ហើយក្រុមការងារបធនផ្សុំក្នុងទ្រុងអស់រយៈពេលប្រមាណមួយឆ្នាំ មុនធ្វើការព្រលែង។

លោក និក ម៉ាក នាយកសង្ត្រោះ និងថែរក្សាសត្វព្រៃ របស់អង្គការសម្ព័ន្ធមិត្តសត្វព្រៃ (Wildlife Alliance) បានឱ្យដឹងដែរថា សត្វទោចម្ពុជដែលយកមកព្រលែងនៅពេលនេះ គឺនាំយកពីសួនសត្វតាម៉ៅ។ លោកបន្ថែមថា ការព្រលែងនេះធ្វើឡើងបន្ទាប់ពីយើងជោគជ័យក្នុងការព្រលែងសត្វទោចក្នុងព្រៃឧទ្យានអង្គរនាពេលកន្លងមក។

តាមការសិក្សាស្រាវជ្រាវកន្លងមក ឃើញថា តំបន់អង្គរធ្លាប់មានប្រភេទសត្វទោចរស់នៅ ប៉ុន្តែវាត្រូវបានផុតពូជទៅវិញនៅអំឡុងពេលមានសង្គ្រាមស៊ីវិល។ ដូច្នេះអាជ្ញាធរជាតិអប្សរា សហការជាមួយរដ្ឋបាលព្រៃឈើ អង្គការសម្ព័ន្ធមិត្តសត្វព្រៃ បានចាប់ផ្តើមគម្រោងស្តារសត្វព្រៃឡើងវិញក្នុងតំបន់អង្គរ ហើយបាននាំប្រភេទសត្វព្រៃដែលធ្លាប់មាននៅតំបន់អង្គរមកវិញដូចជាសត្វទោចជាដើម។

សត្វទោចជាប្រភេទសត្វព្រៃចូលចិត្តរស់នៅដាច់ឆ្ងាយពីគេឯង ឬអាចនិយាយបានថា ចន្លោះព្រៃ២០ហិកតា រស់នៅបានមួយគូ។ ចំណីរបស់វា រួមមានស្លឹកឈើ ផ្លែឈើ និងប្រភេទសត្វល្អិតផ្សេងៗ។ សត្វទោចចាប់ផ្តើមមានកូននៅអាយុ ៥ឆ្នាំ ហើយចន្លោះពេលនោះវានឹងមានកូនម្តងទៀតក្រោយកូនរបស់វាមានអាយុពី៣ឆ្នាំឡើងទៅ។

គួរម្លឹកថា អាជ្ញាធរជាតិអប្សរា បានព្រលែងទោចម្តុជគូដំបូងនៅតំបន់ប្រាសាទតានៃ នាខែមិថុនា ឆ្នាំ២០១៣ និងមួយគូទៀត នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៥ នៅខ្លោងទ្វារខ្មោចខាងកើតប្រាសាទបាយ័ន។ ចំណែកទោចម្តុជមួយគូនៅម្តុំប្រាសាទតានៃ បានបង្កើតកូនចំនួនពីរលើក គឺកូនទីមួយជាកូនញី នៅអំឡុងខែកញ្ញា ឆ្នាំ២០១៥ និងកូនទី២ កើតនៅថ្ងៃទី ០៧ ខែកក្កដា ឆ្នាំ២០១៧។ ចំណែកគូទី២ នៅខ្លោងទ្វាប្រាសាទ ក៏បានបង្កើតកូនមួយក្បាលផងដែរ។ សរុបទាំងអស់ សព្វថ្ងៃនៅក្នុងព្រៃឧទ្យានអង្គរមានសត្វទោចចំនួន១០ក្បាលរាប់ទាំងការព្រលែងជាលើកទី៣នេះ៕









អាជ្ញាធរជាតិអប្សរាឧទ្ទេសលទ្ធផលល្អប្រសើរពីការដើរសវនកម្មប្រព័ន្ធគ្រប់គ្រងបរិស្ថានអង្គរ-

ផ្សាយនៅថ្ងៃទី ២២ ខែ មករា ឆ្នាំ២០១៨

សវនកម្មលើប្រព័ន្ធគ្រប់គ្រងបរិស្ថាន-អង្គរដោយស្ថាប័នជានាគុណភាពជប៉ុន Japan Quality Assurance (JQA) មកលើអាជ្ញាធរជាតិអប្សរា បានបញ្ចប់នៅសៀលថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៨ ដោយលទ្ធផលយ៉ាង ល្អប្រសើរបំផុត។ យោងលទ្ធផលសវនកម្ម **លោក Kozo Sakurada** និង **លោក Yamada Mamoru** សវនករមកពីស្ថាប័ន JQA បានវាយតម្លៃខ្ពស់ចំពោះការអនុវត្តរបស់អាជ្ញាធរជាតិអប្សរាលើការគ្រប់គ្រងប្រព័ន្ធបរិស្ថានក្នុងតំបន់អង្គរស្តង់ដារថ្មី ISO 14001-2015 ។ បើទោះបីជា ស្តង់ដារថ្មី ISO 14001-2015 អាជ្ញាធរជាតិអប្សរាទើបអនុវត្តជាលើកដំបូង តែអាជ្ញាធរជាតិអប្សរាបានបំពេញការងារនេះយ៉ាងល្អ និងមិនមានភាពមិនអនុលោម ហើយមានចំណុចសង្កេតតែ៧ចំណុចប៉ុណ្ណោះ។

ឯកឧត្តម សុខ លក្ខិណា ជាប្រធាននៃអង្គភាពគ្រប់គ្រងប្រព័ន្ធបរិស្ថានអង្គរ និងជាតំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម បណ្ឌិត ស៊ុំ ម៉ាប់** អគ្គនាយកអាជ្ញាធរជាតិអប្សរា ក្នុងពិធីបិទសវនកម្មផ្ទៃក្រៅ បានឱ្យដឹងថា ការធ្វើសវនកម្មទទួលបានលទ្ធផលល្អប្រសើរ។ យើងមានចំណុចតាមសង្កេតចំនួន៧ ហើយសវនករបានផ្តល់ជាអនុសាសន៍មួយដើម្បីកែលំអរ។

ឯកឧត្តមក៏បានរំពឹងទុកថា រមណីយដ្ឋានអង្គរនឹងទទួលបានវិញ្ញាបនបត្រ ISO 14001 ជាថ្មីបន្តទៀត។ វិញ្ញាបនបត្រ ISO 14001 សំដៅលើផ្នែកបរិស្ថាននេះ មានសារៈសំខាន់ណាស់ចំពោះរមណីយដ្ឋានអង្គរ ព្រោះរមណីយដ្ឋានអង្គរបានក្លាយជាគោលដៅទេសចរណ៍លេខ១លើពិភពលោក គឺតាមរយៈការបោះឆ្នោតវាយតម្លៃពីភ្ញៀវលើពិភពលោក ដែលនេះមិនអាចកាត់ផ្តាច់ពីការប្រឹងប្រែងរបស់អាជ្ញាធរជាតិអប្សរាមកលើកិច្ចការគ្រប់គ្រងប្រព័ន្ធបរិស្ថានបានឡើយ។ ពោលគឺអាជ្ញាធរជាតិអប្សរាជានាបាននូវបរិស្ថានល្អ ទេសភាពស្អាត មិនប៉ះពាល់ដល់ប្រាសាទបុរាណជាដើម។

គួររំឭកដែរថារមណីយដ្ឋានអង្គរបានធ្វើកម្មវិធីសវនកម្មនេះតាំងពីឆ្នាំ២០១៤ និងទទួលវិញ្ញាបនបត្រចំនួន៤លើកមក ហើយពីស្ថាប័ន JQA។ វិញ្ញាបនបត្រម្តង មានសុពលភាពចំនួន៣ឆ្នាំ ហើយសវនកស្ថាប័ន JQA តែងតែចុះមកពិនិត្យ១ឆ្នាំម្តងនឹងវាយតម្លៃអំពីលទ្ធផលដែលអនុលោមនិងមិនអនុលោមតាមអនុសាសន៍នៃស្តង់ដារដែលបានកំណត់៕









ថ្ងៃ៣កើត ខែមាឃជំ អ្នកស្រុកតំបន់អង្គរប្រារព្ធទំនៀមទ្រឿងអ្នកតា

ផ្សាយនៅថ្ងៃទី ២២ ខែ មករា ឆ្នាំ២០១៨

ជារៀងរាល់ឆ្នាំនៅថ្ងៃ៣កើត ខែមាឃជំ អ្នកស្រុកក្នុងតំបន់អង្គរ តែងតែប្រជុំគ្នាតាមស្រុកភូមិរបស់ខ្លួនរៀបចំទំនៀមឡើងអ្នកតាឬហៅថាឡើងមាឃ។ ទោះបីសម័យកាលមានការរីកចម្រើនទៅហើយក្តី តែអ្នកស្រុកអង្គរ នៅតែថែរក្សាទំនៀមបែបបុរាណនេះបានយ៉ាងល្អ ហើយគេតែងបានឃើញការរៀបចំពិធីឡើងអ្នកតានេះ ពេញដោយភាពអ៊ូអរ និងសប្បាយរីករាយបំផុត។

ពីតំបន់មួយទៅតំបន់មួយនៅក្នុងឧទ្យានអង្គរឬខេត្តសៀមរាប មានការរៀបចំពិធីនេះមិនខុសគ្នាប៉ុន្មាននោះទេ។ អ្នកស្រុក អ្នកភូមិ តែងមកជុំគ្នារៀបចំពិធីនេះនៅតាមសាលាឆទាន វត្តអារាម ឬនៅទីសក្ការបូជាផ្សេងៗដែលមានអ្នកតាតាំងនៅ។ អ្នកខ្លះយកបាយសម្លរ បង្អែមចម្អាប គ្រឿងសំណែនផ្សេងៗ ពិសេសគឺនំបញ្ចុកតែម្តងពីផ្ទះរៀងៗខ្លួន ដើម្បីយកសែនអ្នកតាសុំសេចក្តីសុខចម្រើនក្នុងគ្រួសារផងក្នុងភូមិស្រុកខ្លួនផង។

គ្រឿងរណ្តាប់សំខាន់ៗបន្ថែមពីលើចំណីអាហារ យើងសង្កេតឃើញមាន៖ ស្លាធម៌ បាយសី ទៀន ធូប ភ្ញីផ្កា គ្រឿងក្រអូប អំបោះចងដៃ ផ្លែឈើ កេសជ្ជៈ ពិសេសស្រាស មាន់លុងស្ងោរ ក្បាលជ្រូកទៅតាមលទ្ធភាពរបស់អ្នកភូមិ។ លើសពីនោះ តួអង្គសំខាន់នៅក្នុងពិធី គឺអ្នកស្នងរូបអ្នកតានិងអ្នកភ្លេង ដើម្បីញ៉ាំងបរិយាកាសកម្មវិធីឱ្យកាន់តែសប្បាយរីករាយផង ដើម្បីឱ្យមនុស្សមានទំនាក់ទំនងជាមួយអមនុស្សផង ដោយសួរនាំពីតម្រូវការរបស់អ្នកតាថែរក្សាភូមិស្រុក រួមទាំងសុំពរសុំជ័យពីគាត់។

ភាគច្រើននៃការប្រារព្ធពិធីឡើងអ្នកតា គឺគេតែងធ្វើឡើងចាប់ពីម៉ោង២រសៀល រហូតដល់ម៉ោង៧យប់តាមតំបន់ ព្រោះកន្លែងខ្លះមានការបញ្ជាន់រូប ហើយកន្លែងខ្លះទៀតត្រឹមសែនព្រេនធម្មតា ។ នៅពេល(ករណីគ្មានអ្នកបញ្ជាន់រូបចូលរួម) ដល់ម៉ោងកំណត់ហើយ អ្នកស្រុក អ្នកភូមិ បានយកចំណីអាហារ គ្រឿងសំណែនពីផ្ទះរៀងៗខ្លួន មកជុំគ្នានៅខ្នមអ្នកតាវត្តអារាម សាលាឆទាន និងកន្លែងសក្ការបូជាដែលអ្នកភូមិគោរព ដោយតម្រៀបម្ហូបអាហារយ៉ាងច្រើននៅពីមុខខ្នម ហើយចាប់ផ្តើមសែនព្រេន តែបើកន្លែងខ្លះដែលបញ្ជាន់រូប គឺគេមានការប្រគំភ្លេងជាច្រើនបទ ដែលសុទ្ធតែជាបទចំណូលចិត្តរបស់អ្នកតាឬអមនុស្សផ្សេងៗឱ្យរាំលេងសប្បាយរីករាយ ហើយមានអ្នកស្រុក អ្នកភូមិសួរឆ្លងឆ្លើយនឹងរូបនោះ។

ឯរូបនោះក៏និយាយ រាំវែក ហូបចុកតាមចំណង់ចិត្ត ឯអ្នកស្រុកខ្លះក៏សុំពរសុំជ័យ សុំចងអំបោះដៃ សុំទឹកមន្តមកប្រោះព្រំជាដើម។ ពេលសែនព្រេនរួចរាល់ឬរាំវែកអស់ចិត្ត អស់ចង់ហើយ គេក៏យកសំណែននោះទៅចាក់គរគ្នានៅមុខខ្នមអ្នកតា ទុកជាកិច្ចបង្ហើយនៃកម្មវិធី។ ពេលចប់ហើយ អ្នកស្រុកតំបន់ខ្លះ ក៏ត្រឡប់ទៅផ្ទះជាធម្មតា តែអ្នកស្រុកនៅតំបន់ខ្លះ គេនៅបន្តសប្បាយរីករាយដោយការជះទឹកប៉ាតម្សៅគ្នារាំវែកស្គរដៃយ៉ាងគគ្រឹកគគ្រេង។

លោកយាយ ព្រឿង ចាស់ព្រឹទ្ធាចារ្យ ដែលបានចូលរួមក្នុងពិធីឡើងអ្នកតានៅភូមិសំរោង សង្កាត់នគរធំ បានឱ្យដឹងថា លោកយាយតែងចូលរួមក្នុងពិធីឡើងអ្នកតាជារៀងរាល់ឆ្នាំ មិនដែលខកខានទេ។ លោកយាយបន្ថែមថា ពិធីនេះធ្វើឡើងដើម្បីគោរពដល់អ្នកតាម្ចាស់ស្រុក បំណងឱ្យលោកថែរក្សាភូមិករ និងឱ្យអ្នកភូមិបានសុខសប្បាយ ចៀសផុតរោគរាតត្បាត ធ្វើស្រែធ្វើស្រូវឱ្យបានភោគផលច្រើនរកស៊ីទទួលទានមានបាននៅក្នុងឆ្នាំថ្មី។

តាមការឱ្យដឹងពី **លោកយាយ ព្រឿង** អ្នកតាម្ចាស់ស្រុកនៅភូមិសំរោង **ឈ្មោះតា រឹទ្ធិមានជ័យ** ដែលជាអ្នកតាថ្មី ក្រោយអ្នកតាចាស់ **ឈ្មោះ តាគង់** បានបាត់នៅសម័យសង្គ្រាម។ យ៉ាងណា លោកយាយថា លោកតា រឹទ្ធិមានជ័យ តែងជួយថែរក្សាអ្នកភូមិឱ្យមានសេចក្តីសុខជារហូតមក។

រីឯ **លោកយាយ នុក គិក** ក៏បង្ហាញអារម្មណ៍រីករាយក្នុងការចូលរួមពិធីឡើងអ្នកតានេះដែរ។ លោកយាយថា នៅឆ្នាំថ្មីនេះ លោកយាយបន់អ្នកតាសុំឱ្យស្រុកទេសសុខសប្បាយ មានអាយុវែង និងឱ្យមានភ្លៀងធ្លាច្រើន ដើម្បីស្រោចស្រពផលដំណាំបានផលល្អ។









អាជ្ញាធរជាតិអប្សរានិងសហភាពសហព័ន្ធយុវជនកម្ពុជាជួបពិភាក្សាអំពីការរៀបចំព្រឹត្តិការណ៍អង្គរសង្ក្រាន្តឆ្នាំថ្មីឆ្នាំ ច សំរឹទ្ធិស័ក ព.ស ២៥៦២ នៅអគ្គនាយកដ្ឋាននៃអាជ្ញាធរជាតិអប្សរា។

ផ្សាយនៅថ្ងៃទី ២៣ ខែ មករា ឆ្នាំ២០១៨

ព្រឹកថ្ងៃទី២២ ខែមករា ឆ្នាំ២០១៨នេះ អាជ្ញាធរជាតិអប្សរា និងសហភាពសហព័ន្ធយុវជនកម្ពុជាបានជួបពិភាក្សាគ្នាអំពីដំណើរការរៀបចំព្រឹត្តិការណ៍អង្គរសង្ក្រាន្តឆ្នាំថ្មីឆ្នាំ ច សំរឹទ្ធិស័ក ព.ស ២៥៦២ នៅអគ្គនាយកដ្ឋាននៃអាជ្ញាធរជាតិអប្សរា។ កិច្ចពិភាក្សានេះធ្វើឡើងក្រោមអធិបតីភាព **ឯកឧត្តម សុខ សន្ធារ** អគ្គនាយករងនៃអាជ្ញាធរជាតិអប្សរា និង **ឯកឧត្តម សុខ សប្បាយណា** ប្រធានផ្នែកប្រតិបត្តិនៃព្រឹត្តការណ៍អង្គរសង្ក្រាន្ត តំណាង **ឯកឧត្តម ហ៊ុន ម៉ានី** ប្រធានសហភាពសហព័ន្ធកម្ពុជា(ស.ស.យ.ក)ដោយមានការចូលរួមពីថ្នាក់ដឹកនាំនិងក្រុមការងារជាច្រើនរូបទៀត។

មានប្រសាសន៍ក្នុងជំនួបពិភាក្សានេះ **ឯកឧត្តម សុខ សប្បាយណា** បានរៀបរាប់អំពីភាពជោគជ័យជាបន្តបន្ទាប់នៃព្រឹត្តការណ៍អង្គរសង្ក្រាន្តរយៈពេល៥ឆ្នាំកន្លងមក ជាពិសេសកំណើនភ្ញៀវមកទស្សនាកម្សាន្តតាំងពីចំនួនប្រមាណជាង៧ម៉ឺននាក់នៅឆ្នាំ២០១៣ កើនរហូតដល់ជាង១លាន៦សែននាក់នៅឆ្នាំ២០១៧កន្លងទៅ។

តាមគម្រោងសម្រាប់ឆ្នាំទី៦នេះព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រនេះ អង្គរសង្ក្រាន្តនឹងកែសម្រួល និងបន្ថែមនូវកម្មវិធីថ្មីៗមួយចំនួនទៀត ដើម្បីឲ្យមានទាក់ទាញកាន់តែខ្លាំង ដូចជាកម្មវិធីបំបួសនាគ កម្មវិធីសមាធិនៅក្បែរប្រាសាទអង្គរវត្ត កម្មវិធីព្រៃប្រសិទ្ធីដើម្បីបណ្តុះការស្រឡាញ់ព្រៃឈើនិងសត្វព្រៃនិងកម្មវិធីបាញ់ព្រួញជាដើម។

ជាមួយគ្នានេះ **ឯកឧត្តម សុខ សប្បាយណា** ក៏បានលើកឡើងនូវសំណើចំនួន១០៤ចំណុច ពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់អាជ្ញាធរជាតិអប្សរាក្នុងការជំរុញឲ្យ ព្រឹត្តិការប្រព្រឹត្តទៅដោយរលូនដូចជា ការកាត់ក្រីមែកឈើបញ្ជៀសគ្រោះថ្នាក់ ការថែទាំទីធ្លាសៅបៃតងរហូតដល់កម្មវិធីនិងទីតាំងរៀបចំកម្មវិធីជាដើម។

ជាការឆ្លើយតប **ឯកឧត្តមសុខ សន្ធារ** បានបង្ហាញពីជំហរគាំទ្រទាំងស្រុងរបស់អាជ្ញាធរជាតិអប្សរាចំពោះការប្រារព្ធនូវព្រឹត្តការណ៍អង្គរសង្ក្រាន្តឆ្នាំ២០១៨ខាងមុខនេះ។ ជាក់ស្តែង អាជ្ញាធរជាតិអប្សរាបានរៀបចំក្រុមការងារអង្គរសង្ក្រាន្ត និងបានដំណើរការបណ្តើរៗខ្លះទៅហើយ។ ចំពោះសំណើដែលបានលើកឡើងមកនេះ អាជ្ញាធរជាតិអប្សរា នឹងបើកអង្គប្រជុំផ្ទៃក្នុងដើម្បីពិនិត្យសំណូមពរនីមួយៗ ដើម្បីប្រគល់ជូនមន្ត្រីជំនាញដោះស្រាយ និងឆ្លើយតបឲ្យបានទាន់ពេលវេលា។ ជាចុងក្រោយឯកឧត្តមក៏បានបង្ហាញការប្តេជ្ញាចិត្តសហការ ដើម្បីជំរុញឲ្យព្រឹត្តិការណ៍អង្គរសង្ក្រាន្តឆ្នាំថ្មីដំណើរការដោយរលូន និងកាន់តែជោគជ័យជាងឆ្នាំមុនៗថែមទៀត។






ការសិក្សាផ្នែកបុរាណវិទ្យានិងវិទ្យាសាស្ត្រ ចាយយល់ស្របភ្ជាប់ការផលិតកុលាលភាជន៍ខ្មែរ នៅតំបន់អង្គរចាប់ផ្តើមពីសតវត្សរ៍ទី៩ ក.ស.

ផ្សាយនៅថ្ងៃទី ២៣ ខែ មករា ឆ្នាំ២០១៨

ក្រោយចំណាយពេលជាង២០ឆ្នាំលើការសិក្សាស្រាវជ្រាវកុលាលភាជន៍ខ្មែរទាំងផ្នែកបុរាណវិទ្យា និងការវិភាគបែបវិទ្យាសាស្ត្រ អ្នកស្រាវជ្រាវបានសន្និដ្ឋានដូចគ្នាថា ការផលិតកុលាលភាជន៍ក្នុងតំបន់អង្គរ បានចាប់ផ្តើមពីដើមសតវត្សទី៩ គ.ស.។ ការសន្និដ្ឋានដូច្នេះ គឺក្រោយពីអ្នកស្រាវជ្រាវបានធ្វើកំណាយទៅលើស្ថានីយឡដុតកុលាលភាជន៍ចំនួន១០ ក្នុងតំបន់រមណីយដ្ឋានអង្គរ ព្រមទាំងបានយកបំណែកកុលាលភាជន៍ទៅវិភាគនៅមន្ទីរពិសោធន៍បរទេសដូចជាប្រទេសជប៉ុន និងសហរដ្ឋអាមេរិកជាដើម។

លោកបណ្ឌិត អ៊ា ជាវិទ្ធ អនុប្រធាន មជ្ឈមណ្ឌលអន្តរជាតិស្រាវជ្រាវនិងតម្កល់ឯកសារអង្គរនៃអាជ្ញាធរជាតិអប្សរា បានមានប្រសាសន៍ថាការស្រាវជ្រាវឡដុតកុលាលភាជន៍ខ្មែរត្រូវបានបែងចែកជាពីរដំណាក់កាល៖

ឡនៅដំណាក់កាលទី១ ផលិតឡើងប្រហែលជានៅក្នុងសតវត្សរ៍ទី៩ដល់ទី១០នៃគ.ស.។ នេះជាការស្រាវជ្រាវតាមបែបបុរាណវិទ្យាដែលប្រៀបធៀបឡ ជាមួយនឹងបំណែកកុលាលភាជន៍ ដែលបានមកពីកន្លែងប្រើប្រាស់ដែលរកឃើញនៅស្ថានីយផ្សេងៗទៀតនៅតំបន់អង្គរ។ ក្នុងដំណាក់កាលទី១ ឡមានរូបរាងច្បាស់លាស់ ចែកជាបីផ្នែកគឺ ប្រអប់ភ្លើងសម្រាប់ដាក់ឧស កន្លែងសម្រាប់ដាក់កុលាលភាជន៍ និងបំពង់ផ្សែងនៅខាងលើ។ ឡក្នុងដំណាក់កាលទី១នេះមានទំហំតូច ទទឹងប្រមាណ១,៥០ម៉ែត្រដល់៣,៦ម៉ែត្រ បណ្តោយប្រវែង៥ម៉ែត្រ ដល់៩ម៉ែត្រប៉ុណ្ណោះ។ នៅចំកណ្តាលនៃឡមានសសរ៥សម្រាប់ទ្រដំបូលឡ។ ឡប្រភេទនេះផលិតវត្ថុតូចៗពណ៌បៃតងដូចជា ខួច ដន្លាប់ កោដ្ឋ ចាន និងកូនក្រឡជាដើម និងសម្ភារៈធំជាងនេះបន្តិចប៉ុន្តែគ្មានស្រទាប់រលោងដូចជាក្រឡក្អមនិងពងជាក់ទឹកជាដើម។

ចំណែកកុលាលភាជន៍ដែលផលិតក្នុងដំណាក់កាលទី២គឺប្រភេទកុលាលភាជន៍ពណ៌ខ្មៅតមានក្រឡ ពាង ក្អម ក្បឿង និងភាជន៍រូបសត្វជាដើម។ រចនាសម្ព័ន្ធឡនៅដំណាក់កាលទី២ មានទំហំធំវែងជាងដំណាក់កាលទី១។ ដំណាក់កាលទី២នេះបានចាប់ផ្តើមពីសតវត្សរ៍ទី១១ដល់១៥ នៃគ.ស. (ចុងសម័យអង្គរ)។ ឡមានការវិវត្តដែលមានប្រវែងរហូតដល់បណ្តោយ ២១ម៉ែត្រ ទទឹងមានប្រវែង៣,២ម៉ែត្រ។ កន្លែងដាក់កុលាលភាជន៍(Ceramic)មាន៤បន្ទប់ ខណ្ឌដោយរណ្តៅ៣កន្លែង សម្រាប់ដាក់ឧសបញ្ចូលដើម្បីឲ្យភ្លើងឆេះខ្លាំងក្តៅសព្វ ធ្វើឲ្យកុលាលភាជន៍មានកម្រឹតរឹងខ្លាំងហើយមានស្រទាប់រលោងស្អិតជាប់គ្នាល្អ។ ដំណាក់កាលទី២នេះខ្មែរបុរាណនិយមផលិតកុលាលភាជន៍ពណ៌ខ្មៅត ហើយគុណភាពរឹងមាំល្អ។

លោកឆាយ រចនា ប្រធានការិយាល័យសិក្សាកុលាលភាជន៍នៃមជ្ឈមណ្ឌលអន្តរជាតិស្រាវជ្រាវ និងតម្កល់ឯកសារអង្គរបានឲ្យដឹងថា ដើម្បីឲ្យដឹងអំពីអាយុកាល និងសមាសធាតុផ្សំ យើងត្រូវយកធ្យូង និងបំណែកកុលាលភាជន៍ដែលបានមកពីធ្វើកំណាយក្នុងឡទៅពិសោធនៅបរទេស ដូចជាប្រទេសជប៉ុន អាមេរិក និងប្រទេសសិង្ហបុរីជាដើម។ ថ្មីៗនេះអាជ្ញាធរអប្សរាបានសហការជាមួយសកលវិទ្យាល័យ New England ប្រទេសអូស្ត្រាលីដើម្បីសិក្សាអំពីអាយុកាល សមាសធាតុផ្សំនៅក្នុងកុលាលភសាជន៍។

យោងតាមការសិក្សារស្រាវជ្រាវកុលាលភាជន៍ខ្មែរតាមបែបវិទ្យាសាស្ត្រ គេអាចបែងចែកការផលិតកុលាលភាជន៍ជា ២ដំណាក់កាល គឺកុលាលភាជន៍ពណ៌បៃតងចាប់ផ្តើមផលិតនៅចុងសតវត្សរ៍ទី៨ គ.ស. ឬដើមសតវត្សរ៍ទី៩ គ.ស. រហូតមកដល់ចុងសតវត្សរ៍១៣ គ.ស។ រីឯកុលាលភាជន៍មានពណ៌ខ្មៅតចាប់ផ្តើមផលិតនៅចុងសតវត្សរ៍ទី១១ដល់សតវត្សរ៍ទី១៥ គ.ស.។ លោក រចនា បញ្ជាក់ថារបកគំហើញតាមរយៈការសិក្សាតាមបែបបុរាណវិទ្យា និងវិទ្យាសាស្ត្រពុំមានគម្លាតខុសគ្នាខ្លាំងនោះឡើយ។ វិទ្យាសាស្ត្រផ្តល់ព័ត៌មានឲ្យអ្នកស្រាវជ្រាវដឹងអំពីការចាប់ផ្តើម ផលិត និងបញ្ចប់ទៅវិញ និងលក្ខណៈខុសគ្នាពីឡមួយទៅឡមួយទៀត។ ទិន្នន័យនៃការស្រាវជ្រាវតាមរបៀបទាំង២យ៉ាងកាន់តែធ្វើអោយយើងដឹងច្បាស់ថា នៅសម័យអង្គរ ខ្មែរបុរាណបានផលិតកុលាលភាជន៍ប៉ុន្មានប្រភេទ ព្រោះកុលាលភាជន៍ជាវត្ថុសំខាន់សម្រាប់បង្ហាញជីវភាពប្រចាំថ្ងៃដែលប្រើប្រាស់នៅសម័យនោះ។

បច្ចុប្បន្ន ការស្រាវជ្រាវកុលាលភាជន៍ខ្មែរនៅតែបន្តដោយអ្នកជំនាញខ្មែរសហការជាមួយប្រទេសជប៉ុន ធ្វើកំណាយស្រាវជ្រាវឡ បែបបុរាណវិទ្យានៅតំបន់ខាងកើតអង្គរ ដែលផលិតកុលាលភាជន៍ពណ៌ខ្មៅត។ ជាមួយគ្នានេះ ក្រុមការងារក៏ធ្វើសហប្រតិបត្តិការណ៍ជាមួយស្ថាប័នអន្តរជាតិ រួមមានស្ថាប័នមកពីសហរដ្ឋអាមេរិក និងអូស្ត្រាលី ដើម្បីធ្វើវិភាគវិទ្យាសាស្ត្រទៅលើកុលាលភាជន៍ដើម្បីដឹងពីអាយុកាល ដឹងអំពីធាតុផ្សំ និងដឹងពីកន្លែងប្រើប្រាស់ ដែលនឹងអាចធ្វើឲ្យយើងដឹងពីអាណាចក្រខ្មែរកាចម្រើនដល់កន្លែងណាខ្លះតាមរយៈការរកឃើញកុលាលភាជន៍ខ្មែរនៅកន្លែងទាំងអស់នោះ៕









កណៈប្រតិភូអាជ្ញាធរជាតិអប្សរាបំពេញទស្សនកិច្ចនៅប្រទេសជប៉ុនដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការលើផ្នែកជួសជុលនិងអភិរក្សអង្គរ

ផ្សាយនៅថ្ងៃទី ២៦ ខែ មករា ឆ្នាំ២០១៨

គណៈប្រតិភូអាជ្ញាធរជាតិអប្សរា ដឹកនាំដោយ **ឯកឧត្តម ហង់ ពៅ** អគ្គនាយករង ទទួលបន្ទុកនាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរនិងបុរាណវិទ្យាបង្គារ បានទៅបំពេញទស្សនកិច្ចផ្លូវការនៅប្រទេសជប៉ុនរយៈពេល៧ថ្ងៃ ចាប់ពីថ្ងៃទី២១ដល់ថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៨ ដើម្បីពង្រីកកិច្ចសហប្រតិបត្តិការលើផ្នែកជួសជុលនិងអភិរក្សបេតិកភណ្ឌក្នុងតំបន់អង្គរ។

ក្នុងដំណើរទស្សនកិច្ចផ្លូវការនេះ ឯកឧត្តមនិងក្រុមការងារបានចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារជាមួយថ្នាក់ដឹកនាំជាច្រើនរូបតាមស្ថាប័ននានាដូចជា **លោក តូស៊ីអាគី កូសូ** សកលវិទ្យាធិការនៃសកលវិទ្យាល័យសូហ្វីយ៉ាជប៉ុន **លោកសាស្ត្រាចារ្យបណ្ឌិត យូស៊ីអាគី អ៊ីហ្ស៊ីសាវ៉ា** ប្រធានមជ្ឈមណ្ឌលអាស៊ីសិក្សាស្រាវជ្រាវនិងបណ្តុះបណ្តាលធនធានមនុស្សនៃសាកលវិទ្យាល័យសូហ្វីយ៉ា **លោក តូម៉ូយូគី សាគូរ៉ៃ** អនុប្រធានមូលនិធិជប៉ុន និង **លោក ហាម៉ាដា យ៉ាស** នាយករងទីភ្នាក់ងារវប្បធម៌ជប៉ុន។

គួរបញ្ជាក់ដែរថា សាកលវិទ្យាល័យសូហ្វីយ៉ា និងមូលនិធិជប៉ុនទាំងអស់នេះ សុទ្ធតែបានចូលរួមចំណែកដ៏ធំក្នុងការបណ្តុះបណ្តាលធនធានមនុស្សរបស់កម្ពុជាយ៉ាងច្រើនគ្រប់វិស័យ ពិសេសលើវិស័យបេតិកភណ្ឌ ហើយក៏មានកិច្ចសហប្រតិបត្តិការជួសជុលបុរាណដ្ឋានជាច្រើននៅក្នុងឧទ្យានអង្គរផងដែរ។

បន្ថែមពីនោះទៀត គណៈប្រតិភូនៃអាជ្ញាធរជាតិអប្សរាក៏បានចូលរួមពិធីបើកពិរព័ណ៌រូបថតស្តីពីសកម្មភាពជួសជុលនិងអភិរក្សប្រាសាទនៅកម្ពុជាដែលរៀបចំឡើងនៅសកលវិទ្យាល័យសូហ្វីយ៉ា ដោយមានវត្តមានរបស់ **លោកជំទាវ ជា គីមថា** ឯកអគ្គរាជទូតព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសជប៉ុនជាអធិបតីក្នុងកម្មវិធី៕









អាជ្ញាធរជាតិអប្សរា ទទួលកុលាលភាជន៍ពីតំណាងសមាគមមិត្តភក្តីទេសភ៍កាសាចិន

ផ្សាយនៅថ្ងៃទី ២៩ ខែ មករា ឆ្នាំ២០១៨

នៅរសៀលថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៨ តំណាងសមាគមមិត្តទេសភាសាចិន-កម្ពុជា **លោក ធៀម ធឿន** ដែលមានទីលំនៅរស់នៅភូមិវាល ឃុំគោកចក បានយកកុលាលភាជន៍ ដែលមានដូចជាថូ និងបំណែកក្រឡមួយចំនួន យកមកប្រគល់ជូនអាជ្ញាធរជាតិអប្សរា។ តាមការលើកឡើងរបស់ **លោក ធៀម ធឿន** កុលាលភាជន៍នេះ ត្រូវបានអ្នកជិតខាងរបស់លោក រើសបានដោយចៃដន្យនៅពេលគាត់ជីកដីគាស់ដើមចេកលើដីរបស់ខ្លួនអំឡុងខែកក្កដាឆ្នាំ២០១៧។

ពិធីប្រគល់កុលាលភាជន៍នេះ ត្រូវបានធ្វើឡើងនៅសារមន្ទីរព្រះនរោត្តម សីហនុ-អង្គរ ក្រោមវត្តមាន **ឯកឧត្តម សុខ សង្ហារ** អគ្គនាយករងនៃអាជ្ញាធរជាតិអប្សរា តំណាង **ឯកឧត្តមបណ្ឌិត ស៊ុំ ម៉ាប់** អគ្គនាយកអាជ្ញាធរជាតិអប្សរា។

លោក ធៀម ធឿន បានឱ្យដឹងថា កុលាលភាជន៍ដែលយកមកប្រគល់នៅពេលនេះ គឺជារបស់អ្នកជិតលោក ដែលបានជីកដីឃើញកាលពីកន្លងមក។ លោកបន្ថែមថា ក្រោយរក្សាទុកជាច្រើនមក អ្នកភូមិម្នាក់នោះបានប្រគល់ឱ្យលោកអំឡុងសប្តាហ៍មុនដើម្បីរក្សាទុក តែចុងក្រោយលោកសម្រេចប្រគល់វត្ថុបុរាណទាំងនេះដល់អាជ្ញាធរជាតិអប្សរា ដែលមានសមត្ថកិច្ច ថែរក្សាវត្ថុទាំងនេះ។ លោកបញ្ជាក់ទៀតថា លោកស្រឡាញ់វប្បធម៌ដូនតា និងចង់ថែរក្សាឱ្យនៅគង់វង្ស និងបានសម្រេចចិត្តយកមកប្រគល់ជូនដល់សារមន្ទីរសីហនុ-អង្គរដើម្បីជួសជុលនិងថែរក្សា។

លោក ឆាយ រចនា ប្រធានការិយាល័យសិក្សាកុលាលភាជន៍នៃមជ្ឈមណ្ឌលអន្តរជាតិ ស្រាវជ្រាវ និងតម្កល់ឯកសារអង្គរ បានបង្ហាញថា បំណែកកុលាលភាជន៍ទាំងនេះស្ថិតក្នុងពីរសម័យកាលផ្សេងគ្នា គឺសម័យអង្គរ និងក្រោយអង្គរ។ ចំណែកកុលាលភាជន៍ដែលទទួលបាននេះ គឺកុលាលភាជន៍ខ្មែរ និងមួយចំណែកជាកុលាលភាជន៍ចិន។ លោកបានបញ្ជាក់ថានេះជាកស្តុតាងមួយបង្ហាញថាខ្មែរសម័យបុរាណក្រៅពីផលិតកុលាលភាជន៍សម្រាប់ប្រើប្រាស់ក្នុងស្រុក ថែមទាំងបាននាំចូលពីចិនទៀតផងតាមរយៈឈ្មួញចិន។ លោកបន្ថែមថាតួនាទីសំខាន់នៃកុលាលភាជន៍គឺប្រើប្រាស់សម្រាប់សាសនា និងសម្រាប់ជីវភាពប្រចាំថ្ងៃ។

ឯកឧត្តម សុខ សង្ហារ អគ្គនាយករងនៃអាជ្ញាធរអប្សរា បានថ្លែងអំណរគុណ និងកោតសរសើរដល់ **លោក ធៀម ធឿង** ដែលមានចិត្តចង់ថែរក្សាទុកកេរមរតកវប្បធម៌ខ្មែរ តាមរយៈការប្រគល់ជូន កុលាលភាជន៍ដល់អាជ្ញាធរជាតិអប្សរា។ ឯកឧត្តមបញ្ជាក់ថាដើម្បីដឹងឱ្យកាន់តែច្បាស់លាស់ ក្រុមអ្នកជំនាញបុរាណវិទ្យានឹងសិក្សាបន្ថែមអំពីសម័យកាល និងតួនាទី របស់កុលាលភាជន៍ទាំងនេះ។

ឯកឧត្តមក៏បានសំណូមពរដល់ប្រជាជនទាំងអស់សូមចូលរួម ក្នុងរណីរកឃើញវត្ថុបុរាណនានា ត្រូវផ្តល់ព័ត៌មានដល់អាជ្ញាធរមូលដ្ឋាន ឬតាមរយៈអាជ្ញាធរជាតិអប្សរាដើម្បីអោយអ្នកជំនាញសិក្សាស្រាវជ្រាវ និងយកមករក្សាទុកនៅសារមន្ទីរ ដើម្បីទុកជាសម្បត្តិវប្បធម៌ឱ្យកូនចៅបានដឹងក៏ដូចជាបង្ហាញដល់អន្តរជាតិបានដឹងឮផង៕









ប្រតិភូអាជ្ញាធរជាតិអប្សរាជួបពិភាក្សាបច្ចេកទេសលម្អិតពីគម្រោងជួសជុលស្ពានហាលអង្គរវត្ត និងស្វែងយល់ពីការជួសជុលស្ពានបុរាណ និងវិមានបុរាណនៅប្រទេសជប៉ុន

ផ្សាយនៅថ្ងៃទី ២៩ ខែ មករា ឆ្នាំ២០១៨

នៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៨ គណៈប្រតិភូនៃអាជ្ញាធរជាតិអប្សរា ដឹកនាំដោយ **ឯកឧត្តម ហង់ ពៅ** អគ្គនាយករង និង **សាស្ត្រាចារ្យ** Azedine Beschaouch លេខាវិទ្យាសាស្ត្រអចិន្ត្រៃយ៍នៃគណៈកម្មាធិការអាយស៊ីស៊ីអង្គរ និងជាទីប្រឹក្សាអាជ្ញាធរជាតិអប្សរា បានចូលរួមកិច្ចប្រជុំបច្ចេកទេសស្តីពីការជួសជុលស្ពានហាលប្រាសាទអង្គរវត្ត នៅសាកលវិទ្យាល័យសូហ្វីយ៉ា-ជប៉ុនក្នុងទីក្រុងតូក្យូ។

កិច្ចប្រជុំនេះធ្វើឡើងក្រោមការសម្របសម្រួលដោយ **លោក ស្សេនគីជិ ហ៊ីរ៉ាយ៉ាម៉ា** សាស្ត្រាចារ្យកិត្តិយសនៃសាកលវិទ្យាល័យនីហុននិងជាប្រធានគណៈកម្មការបច្ចេកទេសនៃគម្រោងជួសជុលស្ពានហាលប្រាសាទអង្គរវត្ត។

ប្រធានបទនៃកិច្ចប្រជុំដែលមានរយៈពេលជាង៦ម៉ោងនេះ បានផ្តោតសំខាន់លើ ការគ្រប់គ្រងទឹកនៅកសិន្ទុអង្គរវត្ត ស្ថានភាពទ្រេតនិងប៉ោងនៃស្ពានហាល ការប្រើប្រាស់បេតុងដើម្បីពង្រឹងជញ្ជាំង ការបំពេញដីខាងក្នុងឡើងវិញ ការទល់ទ្រជញ្ជាំង សុវត្ថិភាពនៃការរើ ឬមិនរើជញ្ជាំង ការផ្លាស់ប្តូរដុំថ្មបាយក្រៀមដែលពុកផុយនៅជាប់ទឹក ការអនុវត្តគម្រោងជួសជុលស្ពានហាលសាកល្បង ការប្រើប្រាស់បច្ចេកទេសថត3Dសម្រាប់គម្រោងអភិរក្សជួសជុលនិងការប្រើប្រាស់ Drone និងរបៀបវារៈផ្សេងៗជាច្រើនទៀត។

ក្រៅពីកិច្ចប្រជុំដ៏សំខាន់នេះ គណៈប្រតិភូនៃអាជ្ញាធរជាតិអប្សរាក៏បានទៅសិក្សាស្វែងយល់អំពីការងារជួសជុលបេតិកភណ្ឌវប្បធម៌នៅខេត្តគូម៉ាម៉ូតូ ដែលមានលក្ខណៈប្រហាក់ប្រហែលគ្នានឹងស្ពានហាលប្រាសាទអង្គរវត្តដែរ គឺការជួសជុលស្ពានបុរាណចំនួន៣កន្លែង និងវិមានបុរាណដែលរងការខូចខាតដោយសារគ្រោះរញ្ជួយផែនដី បាក់រលំជញ្ជាំងនិងស្រុតដីខាងក្នុង។

តាមរយៈការចុះសិក្សាផ្ទាល់ដល់ការដ្ឋានទាំងនេះ គណៈប្រតិភូអាជ្ញាធរជាតិអប្សរាទទួលបានបទពិសោធន៍ ចំណេះដឹងល្អៗមួយចំនួនសម្រាប់អនុវត្តគម្រោងជួសជុលស្ពានហាលឲ្យកាន់តែល្អប្រសើរថែមទៀត។

នេះជាលទ្ធផលវិជ្ជមានមួយនៃដំណើរទស្សនកិច្ចផ្លូវការនៃគណៈប្រតិភូអាជ្ញាធរជាតិអប្សរា ដឹកនាំដោយ **ឯកឧត្តម ហង់ ពៅ** អគ្គនាយករង ទទួលបន្ទុកនាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរ និងបុរាណវិទ្យាបង្ការទៅកាន់ប្រទេសជប៉ុនរយៈពេល៧ថ្ងៃ ចាប់ពីថ្ងៃទី២១ដល់ថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៨ ដើម្បីពង្រីកកិច្ចសហប្រតិបត្តិការលើផ្នែកជួសជុលនិងអភិរក្សបេតិកភណ្ឌក្នុងតំបន់អង្គរ៕






អាជ្ញាធរជាតិអប្សរាប្រជុំពិភាក្សាបណ្តុះបណ្តាលស្តីពីការរៀបចំផែនការមេរបស់សំណង់ប្រាសាទបុរាណ

ផ្សាយនៅថ្ងៃទី ២៩ ខែ មករា ឆ្នាំ២០១៨

នៅមជ្ឈមណ្ឌលបណ្តុះបណ្តាលអង្គរ នៃអាជ្ញាធរជាតិអប្សរា នៅព្រឹកថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៨ មានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី «ការរៀបចំផែនការមេរបស់សំណង់ប្រាសាទបុរាណ»។ វគ្គបណ្តុះបណ្តាលនេះ មានការចូលរួមពីមន្ត្រីជំនាញនៃបណ្តានាយកដ្ឋានក្នុងអាជ្ញាធរជាតិអប្សរា ក្រសួងវប្បធម៌ អាជ្ញាធរជាតិព្រះវិហារ និងអាជ្ញាធរជាតិសំបូរព្រៃគុកជាដើម។

ថ្លែងក្នុងពិធីបើកវគ្គបណ្តុះបណ្តាលនេះ **ឯកឧត្តម សុខ សង្ហារ** អគ្គនាយករងអាជ្ញាធរជាតិអប្សរា បានឱ្យដឹងថា វគ្គបណ្តុះបណ្តាលនេះនឹងធ្វើរយៈពេល២សប្តាហ៍ គឺចាប់ពីថ្ងៃទី២៩ ខែមករា ដល់ថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១៨។ ឯកឧត្តមបន្ថែមថា វគ្គបណ្តុះបណ្តាលនេះ នឹងផ្តោតការយល់ដឹងពីការគ្រប់គ្រងប្រាសាទដោយចីរភាព។ តាមឯកឧត្តម ដើម្បីធ្វើការទាំងនេះបាន យើងត្រូវយល់ដឹងពីគុណតម្លៃនៃប្រាសាទ ជាពិសេសយល់ដឹងពីការងារអភិរក្ស ហើយយើងត្រូវតែមានការអភិវឌ្ឍដោយសមស្របឬដោយចីរភាព។

ឯកឧត្តម សុខ សង្ហារ បន្ថែមទៀតថា៖« ការអភិរក្ស និងការអភិវឌ្ឍ មិនអាចដាច់ពីគ្នាបានទេ តែគោលដំហររបស់យើង (អាជ្ញាធរជាតិអប្សរា) គឺអភិរក្សដើម្បីអភិវឌ្ឍន៍និងអភិវឌ្ឍន៍ដើម្បីអភិរក្ស»។

វគ្គបណ្តុះបណ្តាលស្តីពីការរៀបចំផែនការមេរបស់សំណង់ប្រាសាទបុរាណ នៅឆ្នាំនេះ គឺមានការចូលរួមពីបណ្តាអង្គភាពច្រើនជាងឆ្នាំទៅ។ ឆ្នាំទៅ មានតែនាយកដ្ឋាន៣ប៉ុណ្ណោះចូលរួម មាននាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យាន និងបុរាណវិទ្យាបង្គារ នាយកដ្ឋានអភិរក្សប្រាសាទក្រៅឧទ្យានអង្គរ និងបុរាណវិទ្យាបង្គារ និងនាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍អង្គរ តែឆ្នាំនេះមាននាយកដ្ឋានទ្រទ្រង់បច្ចេកទេសនិងគម្រោងអន្តរវិស័យ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ អាជ្ញាធរជាតិព្រះវិហារ និងអាជ្ញាធរជាតិសំបូរព្រៃគុក។

ឯកឧត្តម សុខ សង្ហារ រំពឹងថា វគ្គបណ្តុះបណ្តាលរយៈពេល២សប្តាហ៍នេះ នឹងធ្វើឱ្យសិក្ខាកាមទាំងអស់យល់ពីចំណុចសំខាន់ៗ ដែលជាសារប្រយោជន៍ដល់ការងារអភិរក្ស និងការងារអភិវឌ្ឍនៃរមណីយដ្ឋានអង្គរ ក៏ដូចជាសំណង់ប្រាសាទបុរាណដទៃក្នុងប្រទេសកម្ពុជា។

គួរបញ្ជាក់ថា វាគ្មិនសម្រាប់វគ្គបណ្តុះបណ្តាលលើកនេះ គឺ **លោក** Jean-Christophe Simon អគ្គនាយកផ្នែកអធិការកិច្ចនៃសំណង់បុរាណនៃក្រសួងវប្បធម៌បារាំង៕









ក្រុមគណៈកម្មការចម្រុះរុះពី និងបញ្ឈប់សកម្មភាពបំពានលើដីកម្មសិទ្ធិរបស់រដ្ឋ

ផ្សាយនៅថ្ងៃទី ៣០ ខែ មករា ឆ្នាំ២០១៩

នាព្រឹកថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៨ ក្រុមគណៈកម្មការចម្រុះ រួមមាន មន្ត្រីអាជ្ញាធរជាតិអប្សរា សាលាក្រុងសៀមរាប មេធាវីប្រចាំអាជ្ញាធរជាតិអប្សរា និងមន្ត្រីពាក់ព័ន្ធផ្សេងទៀត ក្រោមការសម្របសម្រួលរបស់ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តសៀមរាប បានចុះរុះរើរបងថ្មព័ទ្ធលួសបន្លា រោងចាំដីរបស់ ឈ្មោះ ហួន សីហា និងបក្ខពួកខ្លួនស្ថិតនៅភូមិអញ្ជាញ សង្កាត់នគរធំក្រុងសៀមរាបខេត្តសៀមរាបត្រង់ចំណុចខាងត្បូងក្រោលសេះ។

មូលហេតុនៃការចុះរុះរើ ព្រោះ ឈ្មោះ ហួន សីហា បានរំលោភយកជាកម្មសិទ្ធិ និងបានធ្វើរបងថ្មព័ទ្ធលួស រោងចាំដី ដាំដើមស្វាយថ្មីធំស្រាប់ ដាក់លូ ចាក់បំពេញអាចមន៍ដី។ល។ លើដីកម្មសិទ្ធិរបស់រដ្ឋ តាំងពីថ្ងៃទី៥ ខែមករា ឆ្នាំ២០១៨ ហើយអាជ្ញាធរជាតិអប្សរាក៏ធ្លាប់ បានជូនដំណឹងនិងទុកពេលឱ្យមួយសប្តាហ៍ដើម្បី ឱ្យម្ចាស់ដីរុះរើដោយខ្លួនឯងតាំងពីថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៨មកម្លេះ។ ម្យ៉ាងវិញទៀត ទីតាំងដីកម្មសិទ្ធិរបស់រដ្ឋដែល ឈ្មោះហួន សីហា រំលោភយកជាកម្មសិទ្ធិត្រូវបានរដ្ឋបាលខេត្តសៀមរាបធ្វើការបិទផ្សាយជាសាធារណៈនូវឯកសារនៃការរឹនិច្ឆ័យ រួមមានប្លង់សុរិយោដី និងបញ្ជីឈ្មោះអ្នកកាន់កាប់ដីរួចមកហើយនៅថ្ងៃទី២៧ខែកុម្ភៈឆ្នាំ២០១៧។

ឯកឧត្តម ខូយ គីមឆ ទីប្រឹក្សាអាជ្ញាធរជាតិអប្សរា បានឱ្យដឹងថា ទីតាំងដែលបានមកអនុវត្តន៍រុះរើនេះ គឺជាក្បាលដីដែលអាជ្ញាធរជាតិអប្សរាបានដោះស្រាយគោលនយោបាយរួចហើយ និងមានឯកសារបញ្ជាក់ច្បាស់លាស់ទទួលស្គាល់ដោយក្រុមការងារអន្តរក្រសួងដោះស្រាយគោលនយោបាយដីធ្លីបុរីទេសចរណ៍វប្បធម៌។ ឯកឧត្តមបន្ថែមថា ក្នុងពេលថ្មីៗកន្លងមកនេះ ស្រាប់តែ ឈ្មោះ ហួន សីហា មកចូលរំលោភយកជាកម្មសិទ្ធិដោយធ្វើរបងថ្មព័ទ្ធលួសបន្លា ធ្វើរោងចាំដី ដាំដើមស្វាយធំៗស្រាប់ ដាក់លូនិងចាក់ដី ហើយអាជ្ញាធរជាតិអប្សរាក៏បានអញ្ជើញ ឈ្មោះ ហួន សីហា មកជួបជើម្បីដោះស្រាយ និងបានធ្វើលិខិតទៅ ឈ្មោះ ហួន សីហា ដើម្បីឲ្យធ្វើការរុះរើចេញដោយខ្លួនឯងក្នុងរយៈ១សប្តាហ៍។ ប៉ុន្តែបុគ្គលនេះ មិនត្រឹមតែពុំទទួលយកនូវសំណូមពររបស់អាជ្ញាធរជាតិអប្សរាទេ តែថែមទាំងបានប្រើប្រាស់អាកប្បកិរិយាមិនសមរម្យ និងបង្កការលំបាកក្នុងការចុះអនុវត្តការងារដល់មន្ត្រីសាធារណៈ។

អភិបាលក្រុងសៀមរាប **លោក សួរ ច្លាតុង** បានសំណូមពរដល់ប្រជាពលរដ្ឋទាំងអស់ ពិសេសអ្នកចំណូលថ្មី មុននឹងទិញដីនៅតំបន់ណាមួយ ត្រូវសួរប្រវត្តិដីទីនោះឱ្យច្បាស់លាស់សិន ជៀសវាងកុំឱ្យមានបញ្ហាផ្លូវច្បាប់ផ្សេងៗ។ ក្រៅពីនេះ លោកអភិបាលក្រុងក៏ស្នើសុំដល់ប្រជាពលរដ្ឋទាំងអស់ ចូលរួមថែរក្សាសណ្តាប់ធ្នាប់ ពិសេសកុំរំលោភដីចំណីផ្លូវ ត្រូវទុកដើម្បីឱ្យអាជ្ញាធរមានលទ្ធភាពរៀបចំក្រុងឱ្យបានល្អប្រយោជន៍ដើម្បីប្រជាពលរដ្ឋនិងសម្រាប់ភ្ញៀវទេសចរ៕






www.apsaraauthority.gov.kh


នាយកដ្ឋានផ្សព្វផ្សាយ
www.apsaraauthority.gov.kh

ព្រឹត្តិការណ៍ព័ត៌មាន
ប្រចាំខែកុម្ភៈ

ផ្នែកទី ២
ប្រចាំខែកុម្ភៈ

ខែមករាដើមឆ្នាំ២០១៨នេះអាជ្ញាធរជាតិអប្សរាអនុញ្ញាតការជួសជុលសំណង់តូចៗ ជូនប្រជាពលរដ្ឋជាង៥០ករណី

ផ្សាយនៅថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ២០១៨

គិតចាប់ពីថ្ងៃទី១ ដល់ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៨ កន្លងទៅ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរា បានសម្រេចការងារក្នុងការចុះពិនិត្យ សំណើសុំជួសជុលតូចៗ ដោយបានអនុញ្ញាតជូនប្រជាពលរដ្ឋចំនួន៥៤ ករណី។

ការងារអនុញ្ញាតនេះធ្វើឡើងតាមតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋដែលជាអ្នកស្រុកចាស់ ស្ថិតនៅក្នុងតំបន់រមណីយដ្ឋានអង្គរ។ ជាក់ស្តែង ស្រុកប្រាសាទបាគង បានអនុញ្ញាតបានចំនួន១០ករណី ស្រុកអង្គរធំ អនុញ្ញាតបានចំនួន៦ករណី ស្រុកពួកអនុញ្ញាតបានចំនួន១០ ករណី ក្រុងសៀមរាប អនុញ្ញាតបានចំនួន១៨ករណី និងនៅស្រុកបន្ទាយស្រី អនុញ្ញាតបានចំនួន១០ករណី។

ចំពោះការចុះពិនិត្យនេះ និងការសម្រេចសាងសង់ និងជួសជុលនេះធ្វើឡើងដោយ ក្រុមការងារបានចុះជួបប្រជាពលរដ្ឋដោយផ្ទាល់ដើម្បីផ្តល់ភាពងាយស្រួល និងសម្រួលដល់ពួកគាត់ដោយពុំចាំបាច់ឡើងមកដល់ទីស្នាក់ការកណ្តាលនៃអាជ្ញាធរជាតិអប្សរានោះឡើយ ដោយផ្តល់សេវាដល់ទីកន្លែង។

គួរឲ្យកត់ផងដែរថា ឆ្នាំ២០១៧ កន្លងមក អាជ្ញាធរជាតិអប្សរាបានអនុញ្ញាតការសាងសង់ និងជួសជុលតូចៗចំនួន៥០០ករណី និងឧបត្ថម្ភស្ត្រីទើបសម្រាលកូនរួចក្នុងតំបន់អង្គរចំនួនជាង៦០០គ្រួសារ។ ក្រៅពីនេះអាជ្ញាធរជាតិអប្សរាក៏បានជួយឧត្តម្ភដល់ប្រជាជនដែលរងគ្រោះថ្នាក់ដោយសារភ្លើងឆេះផ្ទះ ទឹកជំនន់ ជាសម្ភារៈផ្សេងៗជូនដល់វត្តអារាម អាគារសាធារណៈក្នុងតំបន់អង្គរជាដើម៕









រឿង ព្រះនាងកែវប្រាំពីរពណ៌ ចានចេញផ្សាយហើយ!

ផ្សាយនៅថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១៨

រឿង «ព្រះនាងកែវប្រាំពីរពណ៌» ជារឿងព្រេងខ្មែរទាក់ទងនឹងប្រវត្តិសាស្ត្រ បូជនីយដ្ឋាន និងជីវភាពរស់នៅរបស់ប្រជាជនក្នុងខេត្តសៀមរាប បានចេញផ្សាយហើយ និងតម្កល់ទុកនៅបណ្ណាល័យអាជ្ញាធរជាតិអប្សរា។

ប្រភពនៃរឿងព្រេងនេះដកស្រង់ចេញពីប្រសាសន៍របស់លោកតា ឈ្នាង នៅវត្តស្វាយរមៀត នាឆ្នាំ១៩៩៩ ហើយសហការរៀបរៀងដោយក្រុមអ្នកស្រាវជ្រាវនៃអាជ្ញាធរជាតិអប្សរាជាមួយនឹងសាកលវិទ្យាល័យសូហ្វីយ៉ា បោះពុម្ពដោយអង្គការព្រះពុទ្ធសាសនា ស៊ីនញូ-អិន។ ការចងក្រងរឿងព្រេងនេះឡើង ក្នុងបំណងរក្សារឿងទាំងឡាយដែលមានមនុស្សចាស់ទុំតិចតួចនៅចេះចាំ ឱ្យមានស្នាដៃជាសំណេរ រក្សាទុកដល់អ្នកជំនាន់ក្រោយ។

តាមរយៈសាច់រឿង «ព្រះនាងកែវប្រាំពីរពណ៌» ជាបុត្រីរបស់ព្រះមហាក្សត្រមួយអង្គសោយរាជ្យនៅរាជធានីអង្គរព្រះនាមកងចក្រ។ ព្រះនាងមានរូបសម្បត្តិល្អឥតខ្ចោះ ហើយសម្រស់អាចប្រែប្រួលបានប្រាំពីរដងក្នុងមួយថ្ងៃ។ ភាពល្បីល្បាញនៃរូបឆោមរបស់ព្រះនាងល្បីរន្ទឺដល់ព្រះរាជបុត្រានៃស្តេចចិត្តឱ្យចាប់ចិត្តមកដណ្តឹង ជាហេតុធ្វើឱ្យព្រះនាងត្រូវឃ្លាតឆ្ងាយពីស្រុកទេសនិងក្រពើសំណព្វរបស់ខ្លួនទាំងមិនដាច់ចិត្ត។ ពេលដឹងថា ម្ចាស់ខ្លួនត្រូវចាកចេញ អាធន ជាក្រពើក៏បាននាំម្ចាស់ស្រីខ្លួនដិះលម្ហែក្នុងបារាយណ៍ទឹកថ្លា ហើយក៏លេបព្រះនាងចូលក្នុងពោះ ធ្វើឱ្យមានការភ្ញាក់ផ្អើលដល់ព្រះបិតា រាស្ត្រពេញនគរ បង្កើតការតាមចាប់ក្រពើជាបន្ទាន់ដោយប្រកាសរកអ្នកល្បីខាងចាប់ក្រពើមកជួយ។ ទីតាំងទាំងអស់នោះ រួមនឹងមនុស្សមួយចំនួន បានក្លាយជាទីតាំងប្រវត្តិសាស្ត្រនិងមានឈ្មោះរហូតដល់សព្វថ្ងៃនេះនៅក្នុងខេត្តសៀមរាប។

ចង់ដឹងថាសាច់រឿងមានខ្លឹមសារលម្អិតយ៉ាងណា មានទីតាំងប្រវត្តិសាស្ត្រនៅកន្លែងណាខ្លះ សូមប្រិយមិត្តរកអានសៀវភៅរឿង «ព្រះនាងកែវប្រាំពីរពណ៌» នៅបណ្ណាល័យអាជ្ញាធរជាតិអប្សរា៕









គណៈកម្មការចម្រុះ ចុះបញ្ឈប់សកម្មភាពបំពាននិងរុះពីសំណង់ខុសច្បាប់លើកម្មសិទ្ធិជីវជ្ជជាលើកទី២

ផ្សាយនៅថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ២០១៨

នាព្រឹកថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៨ ក្រុមការងារចម្រុះរួមមាន មន្ត្រីអាជ្ញាធរជាតិអប្សរា មន្ត្រីសាលាក្រុងសៀមរាប មេធាវីប្រចាំអាជ្ញាធរជាតិអប្សរា រួមនឹងមន្ត្រីមានសមត្ថកិច្ចពាក់ព័ន្ធផ្សេងទៀត ក្រោមការសម្របស្រួលពី **លោក សំរិទ្ធ សុខុន** ព្រះរាជអាជ្ញារងតំណាងអយ្យការអមសាលាដំបូងខេត្តសៀមរាប បានចុះប្រតិបត្តិការរុះរើបង្គោលរបងព័ទ្ធលួសបន្លាខុសច្បាប់របស់ ឈ្មោះ ហួន សីហា នៅលើទីតាំងចំនួន២ក្បាលដី ស្ថិតក្នុងភូមិអញ្ចាញ សង្កាត់នគរធំ ក្រុង/ខេត្តសៀមរាប ជាកម្មសិទ្ធិឯកជនរបស់រដ្ឋគ្រប់គ្រងដោយអាជ្ញាធរជាតិអប្សរា ដែលលោក ហួន សីហា និងបក្ខពួកបានសាងសង់ឡើងវិញ កាលពីថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៨ បន្ទាប់ពីក្រុមគណៈកម្មការចម្រុះរុះរើរួចកាលពីព្រឹកថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៨។ ការចុះអនុវត្តការងារជាថ្មីនេះ ដោយសារ ឈ្មោះ ហួន សីហា និងបក្ខពួកមិនខ្លាចញញើត នៅតែបំពាន ផ្តើនចំពោះច្បាប់ ហាមឃាត់ដោយបាននាំគ្នាសង់របងលួសជាថ្មីហើយដកបង្គោលដែលក្រុមគណៈកម្មការចម្រុះបានបោះជាសម្គាល់ចោល។ អ្វីដែលគួរឱ្យកត់សម្គាល់នោះ ពេលកំពុងអនុវត្តការងាររុះរើ ពុំបានឃើញវត្តមាន ឈ្មោះ ហួន សីហា នៅក្នុងទីតាំងឡើយ មានតែបក្ខពួកពីរនាក់ដែលនៅចាំដី ហើយក្រុមសមត្ថកិច្ចបានឃាត់ខ្លួនបុគ្គលពីររូបនោះ ដើម្បីយកទៅសាកសួរ។

គួរបញ្ជាក់ផងដែរថា សំណង់រោងចាំដី របងថ្មដែលឈ្មោះ ហួន សីហា និងបក្ខពួកបានសាងសង់នោះ ត្រូវបានគណៈកម្មការចម្រុះចុះបញ្ឈប់សកម្មភាពនិងរុះរើម្តងរួចមកហើយកាលពីថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៨កន្លងមក។









ក្រុមបាល់ទាត់អាជ្ញាធរជាតិអប្សរាឧឡូបានជើងឯករងក្នុងពានរង្វាន់រដ្ឋបាលខេត្តសៀមរាប ជុំទីកាលទី៣

ផ្សាយនៅថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ២០១៨

ពានរង្វាន់បាល់ទាត់ខេត្តសៀមរាប ដែលប្រមូលផ្តុំដោយក្រុមកីឡាករមកពីបណ្តាមន្ទីរនិងស្ថាប័នជុំវិញខេត្តសៀមរាបលើកទី៣បានបិទបញ្ចប់ហើយ ដោយក្រុមបាល់ទាត់អាជ្ញាធរជាតិអប្សរាទទួលបានជើងឯករង ក្រោយបរាជ័យក្រោមថ្វីជើងរបស់ក្រុមកីឡាបាល់ទាត់ក្រុងសៀមរាប ក្នុងលទ្ធផល១-១ ក្នុងម៉ោងធម្មតា និង០-២ ដោយបាល់១១ម៉ែត្រកាត់សេចក្តី ក្នុងវគ្គផ្តាច់ព្រ័ត្រនាព្រលប់ថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១៨នេះ។ បរាជ័យតែ១លើកនៃក្រុមបាល់ទាត់របស់អាជ្ញាធរជាតិអប្សរាក្នុងរដូវកាលនេះ បានន័យថា ក្រុមបាល់ទាត់អាជ្ញាធរជាតិអប្សរាពុំអាចការពារតំណែងជើងឯករបស់ខ្លួនបានឡើយ ក្រោយគ្រងជើងឯកពានរង្វាន់មួយនេះអស់២រដូវកាលកន្លងមក។

ទោះជាយ៉ាងណា នេះជាមោទនភាពមួយនៃក្រុមបាល់ទាត់របស់អាជ្ញាធរជាតិអប្សរា ដែលបានប្រឹងប្រែងអស់ពីសមត្ថភាពរបស់ខ្លួន ដើម្បីរួមចំណែកលើកកម្ពស់វិស័យកីឡាបាល់ទាត់នៅកម្ពុជា។ ក្នុងតំណែងជើងឯករងក្នុងរដូវកាលនេះ ក្រុមបាល់ទាត់អាជ្ញាធរជាតិអប្សរាទទួលបានពានមួយអមដោយទឹកប្រាក់ចំនួន៨០ម៉ឺនរៀល៕









អ្នកជំនាញមកពី១៧ប្រទេសជួបជុំគ្នានៅអង្គរ ដើម្បីពិភាក្សាអំពីការគ្រប់គ្រងទេសចរណ៍ក្នុងតំបន់បេតិកភណ្ឌពិភពលោក

ផ្សាយនៅថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ២០១៨

អ្នកស្រាវជ្រាវ និងមន្ត្រីជំនាញមកបណ្តាប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍ ជប៉ុន និងអឺរ៉ុបជាដើម បានមកជួបជុំគ្នានៅសាលសន្និសីទអង្គរ នៃអាជ្ញាធរជាតិអប្សរា តាមរយៈសិក្ខាសាលាអន្តរជាតិស្តីពី និរន្តរភាព និងការគ្រប់គ្រងទេសចរណ៍ក្នុងតំបន់បេតិកភណ្ឌពិភពលោក ដែលសហការរៀបចំដោយអាជ្ញាធរជាតិអប្សរា និងមជ្ឈមណ្ឌល SEAMEO SPAFA។

កិច្ចប្រជុំពិភាក្សានេះនឹងធ្វើឡើងរយៈពេល៤ថ្ងៃ ដោយដំណើរការពីថ្ងៃទី៥ ដល់ទី៨ ខែកុម្ភៈ ឆ្នាំ២០១៨។ នេះជាសិក្ខាសាលាដែលប្រមូលផ្តុំដោយវាគ្មិនដែលភាគច្រើនជាអ្នកស្រាវជ្រាវ អ្នកទេសចរណ៍ និងមន្ត្រីគ្រប់គ្រងនៅតំបន់ទេសចរណ៍ក្នុងតំបន់បេតិកភណ្ឌផ្សេងៗនៃពិភពលោក។

បណ្ឌិត Rujaya Abhakhorn នាយកមជ្ឈមណ្ឌល SEAMEO SPAFA បានលើកឡើងថា យើងបានអញ្ជើញវាគ្មិនដែលមានជំនាញលើការគ្រប់គ្រងទេសចរណ៍ក្នុងតំបន់បេតិកភណ្ឌ មកជួបជុំគ្នានៅអង្គរ ដើម្បីឲ្យពួកគេបានឃើញនូវការគ្រប់គ្រងទេសចរណ៍នៅទីនេះ ព្រោះអាជ្ញាធរជាតិអប្សរាមិនត្រឹមតែធ្វើការលើការអភិរក្សប៉ុណ្ណោះទេ តែបានធ្វើការយ៉ាងច្រើនលើការរៀបចំទេសចរណ៍យ៉ាងមានប្រសិទ្ធភាពទៀតផង។

អគ្គនាយករង ទទួលបន្ទុកនាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍អង្គរ **ឯកឧត្តម សុខ សង្ហារ** បញ្ជាក់ថា តាមរយៈប្រធានដែលប្រមូលផ្តុំដោយអ្នកជំនាញ និងអ្នកគ្រប់គ្រងតំបន់ទេសចរណ៍ក្នុងតំបន់បេតិកភណ្ឌជាច្រើននេះនឹងបង្ហាញថា យើងធ្វើការក្នុងគោលដៅមួយដូចគ្នា។ រមណីយដ្ឋានអង្គរ ជាទីតាំងដ៏សំខាន់សម្រាប់ជាមេរៀននៃការងារអភិរក្ស និងអភិវឌ្ឍន៍ប្រកបដោយចីរភាព ដែលអាជ្ញាធរជាតិអប្សរាកំពុងបន្តអនុវត្តសព្វថ្ងៃ។

ឯកឧត្តមបន្ថែមថា អង្គរកំពុងតែក្លាយជាទិសដៅទេសចណ៍ដ៏សំខាន់ ដែលទាមទារឲ្យយើងត្រូវយកចិត្តទុកដាក់ខ្ពស់លើបញ្ហាប៉ះពាល់ផ្សេងៗ ដែលតែងកើតមានឡើងពីវិស័យទេសចរណ៍។ យើងសង្ឃឹមថា កិច្ចពិភាក្សានេះនឹងផ្តល់នូវចំណុចល្អៗជាច្រើនទៀត ដើម្បីជំរុញឲ្យការគ្រប់គ្រងទេសចរណ៍នៅអង្គរ ក៏ដូចជាតំបន់បេតិកភណ្ឌផ្សេងៗទទួលនូវប្រសិទ្ធភាពល្អបំផុតនាពេលអនាគត។

ឯកឧត្តម ជុច ភឿន រដ្ឋលេខាធិការ និងជាតំណាង **លោកជំទាវ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈបានបញ្ជាក់ថា នេះជាសិក្ខាសាលាដ៏មានតម្លៃដែលនឹងអនុញ្ញាតឲ្យអ្នកគ្រប់គ្រងទេសចរណ៍ក្នុងតំបន់បេតិកភណ្ឌមានគំនិតបន្ថែមលើការរៀបចំផែនការបានល្អ និងអនុវត្តការគ្រប់គ្រងទេសចរណ៍ឲ្យកាន់តែមានប្រសិទ្ធភាព។ ដោយឡែកយើងជឿជាក់ថា បទពិសោធន៍ជាង២៥ឆ្នាំនៃការងារគ្រប់គ្រងអង្គរប្រកបដោយភាពជោគជ័យកន្លងមក អាចជាមេរៀនដ៏ល្អដែលអាចរៀនសូត្របានជាសាកល ពោលគឺ កិច្ចការពីរដែលអាជ្ញាធរជាតិអប្សរាបានអនុវត្តជាប្រចាំគឺ ការអភិរក្ស និងអភិវឌ្ឍន៍ប្រកបដោយចីរភាព៕









សំណង់តូចតាចចំនួន៤៧៤ករណីត្រូវបានអនុញ្ញាតឱ្យសាងសង់ និងជួសជុលនៅក្នុងឧទ្យានអង្គរនាឆ្នាំ២០១៧

ផ្សាយនៅថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ២០១៨

យោងតាមរបាយការណ៍បូកសរុបការងារប្រចាំឆ្នាំរបស់លេខាធិការដ្ឋានសហគមន៍នៃអាជ្ញាធរជាតិអប្សរា ចេញផ្សាយនានៅចុងឆ្នាំ២០១៧ កន្លងមក បានឱ្យដឹងថា គិតចាប់ពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ក្រុមការងារសហគមន៍ បានចុះទៅពិនិត្យ អនុញ្ញាតសាងសង់ និងជួសជុលសំណង់តូចតាចក្នុងឧទ្យានអង្គរបានចំនួន៤៧៥ករណី។

ការងារអនុញ្ញាតនេះធ្វើឡើងតាមតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋដែលជាអ្នកស្រុកចាស់ ស្ថិតនៅក្នុងតំបន់រមណីយដ្ឋានអង្គរ។ ជាក់ស្តែង ស្រុកប្រាសាទបាគង បានអនុញ្ញាតបានចំនួន៦៨ ករណី ស្រុកអង្គរធំ អនុញ្ញាតបានចំនួន៧ ករណី ស្រុកពួកអនុញ្ញាតបានចំនួន១០១ ករណី ក្រុងសៀមរាប អនុញ្ញាតបានចំនួន២២០ ករណី និងនៅស្រុកបន្ទាយស្រីអនុញ្ញាតបានចំនួន៧៩ ករណី។ ចំពោះការចុះពិនិត្យ និងការសម្រេចសាងសង់ និងជួសជុលនេះ ក្រុមការងារបានចុះជួបប្រជាពលរដ្ឋដោយផ្ទាល់ និងផ្តល់សេវាកម្មដល់ទីកន្លែងតែម្តង ដើម្បីផ្តល់ភាពងាយស្រួល និងសម្រួលដល់ពួកគាត់ដោយពុំតម្រូវឲ្យអ្នកស្រុកឡើងមកដល់ទីស្នាក់ការកណ្តាលនៃអាជ្ញាធរជាតិអប្សរានោះឡើយ។

ក្នុងនោះផងដែរ នៅឆ្នាំ២០១៧កន្លងទៅនេះ ក្រុមការងារសហគមន៍ក៏បានចុះផ្សព្វផ្សាយបេតិកភណ្ឌ សាកសួរសុខទុក្ខនិងនាំយកកញ្ចប់អំណោយគាំពារសុខុមាលភាពមាតានិងទារកទៅ ឧបត្ថម្ភស្ត្រីទើបសម្រាលកូនរួចក្នុងតំបន់ឧទ្យានអង្គរបានចំនួនជាង៦០៥កញ្ចប់ នៅស្រុកគោលដៅដូចជា ស្រុកប្រាសាទបាគង៩៦កញ្ចប់ ស្រុកអង្គរធំបាន៦៩កញ្ចប់ ស្រុកពួកបានចំនួន២០៩កញ្ចប់ ក្រុងសៀមរាបបានចំនួន៩១កញ្ចប់ និងស្រុកបន្ទាយស្រីបាន១៤០កញ្ចប់។ ក្រៅពីនេះ អាជ្ញាធរជាតិអប្សរាក៏បានជួយឧត្តម្ភមនុស្សធម៌ដល់ប្រជាជនដែលមានជីវភាពក្រីក្រ គ្រោះថ្នាក់ដោយភ្លើងឆេះផ្ទះ ទឹកជំនន់ និងជូនជាសម្ភារៈផ្សេងៗដល់វត្តអារាម អាគារសាធារណៈក្នុងតំបន់អង្គរជាដើម៕









កាសែត Le Monde ជ័ល្លីរបស់ចារាំងកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែងរបស់អាជ្ញាធរជាតិអប្សរា ក្នុងតំបន់បេតិកភណ្ឌអង្គរ

ផ្សាយនៅថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ២០១៨

តាមការចុះផ្សាយនៃបទយកការណ៍ពិសេសរបស់កាសែតបារាំង Le Monde កាសែតដ៏ល្បីមួយក្នុងពិភពលោក ថែមទាំងមានសុក្រិត្យភាពបំផុត ចេញផ្សាយកាលពីថ្ងៃអាទិត្យ ទី០៤ ខែមករា ឆ្នាំ២០១៨ ក្រោមចំណងជើងថា «អង្គរ ការប្រឈមនៃការកើនឡើងយ៉ាងគំហុកនៃវិស័យទេសចរណ៍» បានបង្ហាញពីបញ្ហាជាច្រើននៅក្នុងតំបន់អង្គរ មានទាំងការអភិរក្ស ជួសជុលសំណង់ប្រាសាទ បរិស្ថាន ការគ្រប់គ្រងទេសចរ ចំណូលអង្គរ ការរីករាលដាលនៃសំណង់ក្នុងឧទ្យានអង្គរ ជីវភាពរស់នៅរបស់ប្រជាជន ការបង្កើតគណៈកម្មាធិការគ្រប់គ្រងតំបន់អង្គរ កសិកម្ម និងការវិនិយោគទុនផ្សេងៗ។ល។

កាសែតនេះ បានកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ស្ថាប័នអាជ្ញាធរជាតិអប្សរាលើតំបន់ឧទ្យានអង្គរក្នុងផ្ទៃក្រឡាជាង៤០១គីឡូម៉ែត្រក្រឡា ដូចជាការទប់ស្កាត់នូវការរីករាលដាលនៃសំណង់ខុសច្បាប់ក្នុងតំបន់អង្គរបានរាប់រយករណី ការយកចិត្តទុកដាក់លើការថែរក្សា ការពារ ជួសជុល អភិរក្សប្រាង្គប្រាសាទនានាជាមួយអ្នកជំនាញបរទេសនិងកិច្ចសហប្រតិបត្តិការអន្តរជាតិថែមទៀត ក្នុងនោះក៏មានបារាំងផងដែរ។ ពិសេសគឺការបង្កើតឱ្យមានគណគណៈកម្មាធិការអន្តរជាតិដើម្បីសម្របសម្រួលកិច្ចគាំពារ និងអភិវឌ្ឍន៍រមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរហៅកាត់ថា អាយស៊ីស៊ី-អង្គរ (ICC-Angkor) ដែលជាគំរូដ៏ល្អសម្រាប់តំបន់បេតិកភណ្ឌដទៃទៀតលើពិភពលោកយកគំរូតាម។

ក្រៅពីការងារគ្រប់គ្រង អភិរក្សនិងអភិវឌ្ឍន៍ប្រកបដោយចីរភាពរមណីយដ្ឋានអង្គរ អាជ្ញាធរជាតិអប្សរាក៏បានយកចិត្តទុកដាក់យ៉ាងខ្លាំងអំពីការរស់នៅរបស់ប្រជាជនក្នុងតំបន់អង្គរដោយខ្លួនឯងផង និងមានការសហការពីដៃគូអភិវឌ្ឍន៍ផងទាំងលើផ្នែកសិក្សាអប់រំ ការថែរក្សាបេតិកភណ្ឌ ការបណ្តុះបណ្តាលលើជំនាញចិញ្ចឹមសត្វនិងការដាំដុះផ្សេងៗ អប់រំអំពីបរិស្ថានល្អនិងអនាម័យ ការរស់នៅនិងហូបស្អាត ការប្រើប្រាស់និងសាងសង់បង្គន់ជាដើម។

ដើម្បីទទួលបានព័ត៌មានផ្សេងៗអំពីសកម្មភាពការងារនិងសមិទ្ធផលដែលអាជ្ញាធរជាតិអប្សរាសម្រេចបាន សូមអញ្ជើញទស្សនាគេហទំព័រ www.apsaraauthority.gov.khនិងហ្វេសប៊ុកផ្លូវការអាជ្ញាធរជាតិអប្សរាដែលឈ្មោះ អាជ្ញាធរជាតិអប្សរា៕









សន្និបាតបូកសរុបលទ្ធផលការងារវប្បធម៌ និងវិចិត្រសិល្បៈ

ផ្សាយនៅថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ២០១៨

សន្និបាតបូកសរុបលទ្ធផលការងារវប្បធម៌ និងវិចិត្រសិល្បៈ ឆ្នាំ២០១៧ និងលើកទិសដៅការងារវប្បធម៌ និងវិចិត្រសិល្បៈ ឆ្នាំ២០១៨ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **លោកជំទាវ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។ ថ្ងៃពុធ ០៧រោច និងថ្ងៃព្រហស្បតិ៍ ០៨រោច ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស២៥៦១ ត្រូវនឹងថ្ងៃទី០៧ និងទី០៨ ខែកុម្ភៈ ឆ្នាំ ២០១៨ នៅសាលចតុម្មុខ។ អត្ថបទ៖ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។









បេតិកភណ្ឌអរូបីៈ រកត្រីត្រៀមឡើងមាយ ជាជំនៀមបុរាណរបស់អ្នកស្រុកអង្គរ!

ផ្សាយនៅថ្ងៃទី ០៨ ខែ កុម្ភ: ឆ្នាំ២០១៨

តំបន់រមណីយដ្ឋានអង្គរ ជាតំបន់បេតិកភណ្ឌរស់ដែល សម្បូរទៅដោយមរតកអរូបីជាច្រើន ហើយត្រូវបានអ្នកស្រុកអង្គរបន្ត ប្រតិបត្តិយ៉ាងខ្ជាប់ខ្ជួនរហូតមកដល់បច្ចុប្បន្ន។ ពិធីបុណ្យឡើងមាយឬបុណ្យឡើងអ្នកតា ក៏ជាទំនៀមទម្លាប់ប្រពៃណីមួយ ក្នុងចំណោមបេតិកភណ្ឌអរូបីជាច្រើនប្រតិបត្តិដោយអ្នកស្រុកអង្គរ។

ជារៀងរាល់ឆ្នាំ រាប់រយឆ្នាំ រាប់ជំនាន់មនុស្សមកហើយ ឱ្យតែដល់ខែមាយ (ពិសេសពាកើតខែមាយឬកំឡុងពេលណាមួយ ក្នុងខែមាយ) អ្នកស្រុកភូមិបង្កោង ឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប មិនដែលខកខាននិងតែងតែនាំគ្នាប្រារព្ធ ពិធីចាប់ត្រីរួមជាលក្ខណៈសហគមន៍ដើម្បីត្រៀមរៀបចំពិធីឡើងមាយតាមទំនៀមទម្លាប់ពីបុរាណ។

ការចាប់ត្រីរួមធ្វើឡើងនៅត្រពាំងបឹងដែលជាត្រពាំងបុរាណ មានទឹកខួបប្រាំងខួបវស្សា អ្នកស្រុកបានអភិរក្សទុក ការពារ មិនអនុញ្ញាតឱ្យនរណាម្នាក់ចូលមកនេសាទផ្តេសផ្តាស់ខុសពីខែមាយនេះឡើយ លុះត្រាតែមានការណាត់គ្នាពីមេភូមិជាមុន ហើយកំណត់ថ្ងៃនេសាទរួម ទើបអ្នកស្រុកអាចទៅរកចាប់បាន។

លោកមេភូមិបង្កោងមានប្រសាសន៍ថា ជារៀងរាល់ឆ្នាំឱ្យតែខែមាយមកដល់ គាត់តែងតែប្រកូកប្រកាស និងកំណត់ពេល វេលាសមស្របណាមួយដល់អ្នកស្រុកក្នុងភូមិ ដើម្បីឱ្យពួកគាត់នាំគ្នាទៅចាប់ត្រីទាំងអស់គ្នា ហើយត្រីដែលចាប់បាននោះ សម្រាប់ធ្វើទឹកនំបញ្ចុកនិងធ្វើម្ហូបអាហាររួម សម្រាប់ពិធីឡើងមាយ ឬបុណ្យឡើងអ្នកតានៅក្នុងខែនេះតាមទំនៀមបុរាណ។ ទោះបីពិធីនេះមិនបានប្រារព្ធក្នុងថ្ងៃណាមួយច្បាស់លាស់ តែមិនឱ្យហួសពីខែមាយនេះឡើយ។

លោកមេភូមិបញ្ជាក់ថា ក្នុងការនេសាទត្រី គឺយើងប្រកូកប្រកាសឱ្យអ្នកស្រុកមកជុំគ្នា ហើយក៏ចាប់ផ្តើមដុតកាំជ្រួច ទើបអ្នក ស្រុកអាចចុះរកបាន។ ភាគច្រើនតែងចាប់ផ្តើមពីព្រឹកព្រាងៗប្រហែលម៉ោងជិត៥ភ្លឺ តែដោយសារឆ្នាំនេះរងាពេក ទើបយើង ចាប់ផ្តើមរកនៅម៉ោង៦ព្រឹក។ ត្រពាំងបឹងនេះត្រូវបានថែរក្សា ការពារបានយ៉ាងល្អ មិនឱ្យអ្នកក្រៅមកនេសាទឡើយ និង ហាមដាច់ខាតការនេសាទដោយប្រើម៉ាស៊ីនធក់ និងអូសមង។ ចំពោះទិន្នន័យត្រីឆ្នាំនេះដែរ គឺទទួលបានច្រើនជាងឆ្នាំមុន។ ចំណែកការរកត្រីដើម្បីយកទៅធ្វើពិធីនេះ គឺបានអនុញ្ញាតប្រជាជនប្រើប្រាស់តែឧបករណ៍បុរាណទាំងអស់ មានដូចជា ឈ្នាង អង្រុត និងសំណាញ់ជាដើម។

ការប្រារព្ធពិធីបុណ្យឡើងមាឃឬឡើងអ្នកតានេះ ជាផ្នែកមួយនៃបេតិកភណ្ឌអរូបី ក្រៅពីបង្ហាញឱ្យឃើញតម្លៃប្បពម៌ ការថែរក្សាមរតកវប្បធម៌ ក៏បានឆ្លុះបញ្ចាំងពីសាមគ្គីភាពនិងភាពរស់រវើកនៅតាមសហគមន៍ និងដើម្បីអបអរដល់ទិន្នផលទទួលបាន ក្រោយពីបានប្រមូលផលស្រូវរួចរាល់ហើយ។ ចំពោះពិធីនេះ ក៏មានការប្រារព្ធប្រហាក់ប្រហែលគ្នានៅតាមស្រុកនិងខេត្តមួយចំនួនទៀតទូទាំងប្រទេសកម្ពុជាផងដែរ។






មន្ត្រីជំនាញក្រប់ក្រងទេសចរណ៍ក្នុងតំបន់បេតិកភណ្ឌបង្ហាញអារម្មណ៍ចាំងភ្លាក់ផ្អើល និងចឿងឆ្ងល់លើដំណើរការក្រប់ក្រងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ២០១៨

ថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០១៨ ដែលជាថ្ងៃទី៣នៃសិក្ខាសាលា មន្ត្រីជំនាញបានចំណាយពេលពេញមួយថ្ងៃ ដើម្បីចុះធ្វើកម្មសិក្សានៅទីតាំងសំខាន់ៗក្នុងតំបន់អង្គរដូចជា បញ្ជរលក់សំបុត្រទស្សនាអង្គរ ការរៀបចំលំហូរភ្ញៀវនៅរួតបាកាណ ការរៀបចំមណ្ឌលបដិសណ្ឋារកិច្ចនៅប្រាសាទបន្ទាយស្រី ការរៀបចំភូមិធម្មជាតិរុនតាឯក និងការរៀបចំលំហូរទេសចរណ៍នៅលើប្រាសាទភ្នំបាខែង។

ក្រោយបញ្ចប់កម្មសិក្សានេះ **លោក Aufa Syahrizal Sarkomi** ដែលជាមន្ត្រីរៀបគ្រប់គ្រងតំបន់ទេសចរណ៍ គុហា Harimauនៃប្រទេសឥណ្ឌូណេស៊ី បញ្ជាក់ថា លោកពិតជាកោតសរសើរនូវការរៀបចំលំហូរទេសចរណ៍នៅអង្គរ ជាពិសេសគឺការអាចកំណត់ចំនួនភ្ញៀវឡើង-ចុះ ក្នុងការទស្សនារួតបាកាណ និងភ្នំបាខែង។ លោកបន្ថែមថា ក្រុមការងាររលោកនឹងយកគំនិតនេះជូនថ្នាក់ដឹកនាំ ដើម្បីរៀបចំនូវតំបន់មួយចំនួនក្នុងប្រទេសរបស់លោក។

ប្រតិភូមកពីប្រទេសថៃពីរូបក៏បានបង្ហាញអារម្មណ៍ភ្ញាក់ផ្អើល ចំពោះគម្រោងរៀបចំភូមិធម្មជាតិរុនតាឯក ដើម្បីកាត់បន្ថយកំណើនគ្រួសារនៅក្នុងតំបន់បេតិកភណ្ឌពិភពលោក។ លោកបញ្ជាក់ថា គម្រោងនេះ បង្ហាញពីទំនួលខុសត្រូវរបស់

រាជរដ្ឋាភិបាលកម្ពុជាចំពោះសហគមន៍ក្នុងតំបន់បេតិកភណ្ឌ តាមរយៈការទិញដី សង់ផ្ទះជូនប្រជាពលរដ្ឋ និងបង្កើតក្រុមការងារទទួលខុសត្រូវលើជីវភាពរបស់ពួកគេ នៅខាងក្រៅតំបន់បេតិកភណ្ឌជំនួសវិញ។

លោកបន្តថា ច្រើនឆ្នាំមកហើយ ប្រទេសថៃក៏ធ្លាប់មានគម្រោងរៀបចំរបៀបនេះនៅតំបន់មួយដែរ ប៉ុន្តែ គម្រោងនោះនៅលើអាកាសប៉ុណ្ណោះ ដោយមិនលេចចេញជារូបរាងឡើយ ក្រោយអ្នកសិក្សារកឃើញថា វាជាការចំណាយដ៏ធំធេងមួយ។ "ក្រោយឃើញគម្រោងនេះ ខ្ញុំពិតជាភ្ញាក់ផ្អើល មិននឹកថាលើលោកនេះគេអាធ្វើចឹងបានទេ។ ខ្ញុំគិតថា បើគេធ្វើកើត យើងក៏អាចធ្វើកើតដែរ។យើងនឹងយកគំនិតនេះទៅគិតឡើងវិញ ដើម្បីរៀបចំនៅកន្លែងរបស់យើងនាពេលអនាគត"។

ក្នុងពិធីបិទវគ្គសិក្ខាសាលានារសៀលថ្ងៃទី៨ ខែកុម្ភៈនេះ **សាស្ត្រាចារ្យ** Azedine Baschaouch ទីប្រឹក្សាអាជ្ញាធរជាតិអប្សរា និងលេខាធិការវិទ្យាសាស្ត្រអចិន្ត្រៃយ៍នៃគណៈកម្មាធិការអាយស៊ីស៊ី-អង្គរ បានកោតសរសើរដល់ស្មារតីរួបរួមគ្នានៃអ្នកជំនាញគ្រប់គ្រងទេសចរណ៍ក្នុងតំបន់បេតិកភណ្ឌគ្រប់តំបន់ ដែលសហការគ្នារៀបចំកម្មវិធីនេះឡើង។ លោកសាស្ត្រាចារ្យកត់សម្គាល់ថា ទេសចរណ៍ក្នុងតំបន់បេតិកភណ្ឌ គឺជាទេសចរណ៍ដែលត្រូវយកចិត្តទុកដាក់ខ្ពស់បំផុត ដោយហេតុថា ទេសចរណ៍នៅតំបន់នេះអាចជះឥទ្ធិពលមិនល្អច្រើន បើអ្នកគ្រប់គ្រងមានការធ្វេសប្រហែស។ ជាមួយគ្នានេះ លោកសាស្ត្រាចារ្យក៏សំណូមពរឲ្យក្រុមការងារបន្តសហការគ្នា និងបង្កើតបណ្តាញទំនាក់ទំនងគ្នាជិតស្និទ្ធថែមទៀត ដើម្បីរៀនសូត្រពីគ្នាទៅវិញទៅមក។

នេះជាសិក្ខាសាលាចែករំលែកបទពិសោធន៍ដ៏មានខ្លឹមសារ ដែលនឹងជួយឲ្យអ្នកគ្រប់គ្រងទេសចរណ៍នៅអង្គរ ក៏ដូចជាប្រទេសផ្សេងៗទៀត ទទួលបានដំណោះស្រាយល្អៗសម្រាប់អនុវត្តនៅប្រទេសរៀងៗខ្លួន។ សិក្ខាសាលានេះក៏ស្របនឹងយុទ្ធសាស្ត្រជាតិដែលជំរុញឲ្យមានទំនាក់ទំនងល្អ និងជិតស្និទ្ធជាមួយនឹងបណ្តាប្រទេសជាដៃគូ ដើម្បីបន្តកិច្ចសហការលើការងារគ្រប់គ្រងរមណីយដ្ឋានបេតិកភណ្ឌឲ្យមានតុល្យភាពរវាងការងារអភិរក្ស និងអភិវឌ្ឍន៍ប្រកបដោយចីរភាព៕









លោកជំទាវ ម៉ែន សំអន អំពាវនាវឱ្យពលរដ្ឋនិងទិស័យឯកជន «កុំឱ្យទិស័យទេសចរណ៍ បំពានលើវប្បធម៌ ត្រូវយកវប្បធម៌ ដើម្បីពង្រីកទិស័យទេសចរណ៍™

ផ្សាយនៅថ្ងៃទី ១២ ខែ កុម្ភ: ឆ្នាំ២០១៨

ក្នុងពិធីបិទសន្និបាតបូកសរុបការងារឆ្នាំ២០១៧ និងលើកទិសដៅការងារសម្រាប់ឆ្នាំ២០១៨ របស់ក្រសួងវប្បធម៌ និងវិចិត្រសិល្ប: នារសៀលថ្ងៃទី៨ ខែកុម្ភ: ឆ្នាំ២០១៨ នៅសាលសន្និសីទចតុមុខ **លោកជំទាវ ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច បានថ្លែងអំពាវនាវដល់ប្រជាពលរដ្ឋនិងវិស័យឯកជន «កុំឱ្យវិស័យទេសចរណ៍ បំពានលើវប្បធម៌ ផ្ទុយទៅវិញត្រូវយកវប្បធម៌ ដើម្បីពង្រីកវិស័យទេសចរណ៍» ទើបធ្វើឱ្យ វិស័យទេសចរណ៍មាននិរន្តរភាព «ធានាយ៉ាងណា កុំឱ្យវិស័យទេសចរណ៍បំពាន ទៅលើវប្បធម៌ ចំណុចនេះដែលយើងតែងតែរំឲកដាស់តឿនថា បេតិកភណ្ឌពិភពលោកដូចជា ប្រាសាទអង្គរ ប្រាសាទព្រះវិហារ និងសំបូរព្រៃគុក មិនត្រូវបានបំពានណាមួយនោះទេ»។ ជាពិសេស តាមរយ:ទេសចរណ៍បេតិកភណ្ឌ និងវប្បធម៌ដែលជាវិស័យកំពុងមានសន្ទុះយ៉ាងខ្លាំងក្លា ដោយបាននាំមកនូវចំណូលរាប់ពាន់លានដុល្លារទៅក្នុងចរន្តសេដ្ឋកិច្ចជាតិ។

លោកជំទាវ ម៉ែន សំអន បានបញ្ជាក់ថា រាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** បានយកចិត្តទុកដាក់ខ្ពស់លើវិស័យវប្បធម៌ និងគិតគូរយ៉ាងច្បាស់លាស់ក្នុងការការពារ អភិរក្ស និងអភិវឌ្ឍបេតិកភណ្ឌវប្បធម៌ជាតិ ប្រកបដោយចីរភាព ដោយឈរលើគោលការណ៍ «អភិរក្សដើម្បីអភិវឌ្ឍ និងអភិវឌ្ឍលើមូលដ្ឋានអភិរក្ស» សំដៅទាញយកប្រយោជន៍សមស្របសម្រាប់ការអភិវឌ្ឍប្រទេសជាតិ និងផ្ទេរមរតកដ៏មានតម្លៃនេះដល់យុវជនជំនាន់ក្រោយៗទៀត។

ជាក់ស្តែងចេញតាមរយ:កិច្ចខិតខំប្រឹងប្រែងជាប់មិនដាច់ និងការដាក់ចេញនូវគោលនយោបាយផ្សេងៗ រាជរដ្ឋាភិបាលកម្ពុជាទទួលបានសមិទ្ធផលយ៉ាងច្រើន ជាបន្តបន្ទាប់នាពេលកន្លងមក និងបានប្រែក្លាយកម្ពុជាដែលគេធ្លាប់ស្គាល់ថា ជាវាលពិឃាតមកជាព្រះរាជាណាចក្រនៃវប្បធម៌ ជាតួអង្គមួយដ៏លេចធ្លោនៅលើវេទិកាបេតិកភណ្ឌពិភពលោក និងធ្លាប់ទទួលបានជោគជ័យជាច្រើនលើករួចមកហើយ ក្នុងការស្នើសុំដាក់បញ្ចូលបេតិកភណ្ឌវប្បធម៌ជាតិទាំងរូបី និងអរូបីទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក របស់អង្គការយូណេស្កូមានដូចជា៖ រមណីយដ្ឋានអង្គរ របាំព្រះរាជទ្រព្យ ឬរបាំក្បាច់បុរាណខ្មែរ ល្ខោនស្រមោលស្បែកធំ ប្រាសាទព្រះវិហារ ល្បែងទាញព្រ័ត្រ ចាប៊ីដងវែង និងថ្មីៗនេះតំបន់ប្រាសាទសំបូរព្រៃគុក។

អាជ្ញាធរជាតិអប្សរាដែលមានតួនាទីថែរក្សា ការពារអភិរក្សតំបន់អង្គរ បានប្រែក្លាយមរតកបេតិកភណ្ឌពិភពលោកប្រឈមនឹងគ្រោះថ្នាក់មួយនេះ ទៅជារមណីយដ្ឋានបេតិកភណ្ឌពេញលេញនិងធ្វើឱ្យអង្គរក្លាយជាចំណុចស្នូលក្នុងការទាក់ទាញភ្ញៀវទេចរឱ្យចូលមកកម្សាន្តទស្សនាជាច្រើនម៉ឺននាក់ក្នុងមួយឆ្នាំៗ ។

ម្យ៉ាងទៀត តម្លៃជាសាកលរបស់តំបន់បេតិកភណ្ឌអង្គរក្តី ព្រះវិហារ សម្បូរព្រៃគុកក្តី គឺជាល្បាយបញ្ចូលគ្នារវាងស្នាដៃឯករបស់បុព្វបុរសខ្មែរ ជាសំណង់ប្រាសាទដ៏វិសេសវិសាល រួមទាំងប្រពៃណីរបស់អ្នកស្រុក ជាមួយនឹងបរិស្ថានជុំវិញប្រាសាទជាចំណុចធ្វើឱ្យតំបន់បេតិកភណ្ឌទាំងនេះមានការទាក់ទាញបំផុតសម្រាប់ទេសចរ និងធ្វើឱ្យអង្គរបានក្លាយជាគោលដៅទេសចរណ៍ទី១ដល់ទៅ៣ឆ្នាំជាប់គ្នាតាមការបោះឆ្នោតជាសាកលពីសំណាក់ភ្ញៀវទេសចរណ៍លើពិភពលោក។ ភាពរីកចម្រើននិងការអភិវឌ្ឍនៅក្នុងតំបន់បុរាណដ្ឋានដ៏ល្បីល្បាញនេះ ឱ្យក្លាយជាប្រភពសេដ្ឋកិច្ចចូលជាតិដ៏សំខាន់៕






អ្នកជំនាញបុរាណវិទ្យា៨ស្ថាប័នបញ្ចប់វគ្គសិក្សាអំពីការរៀបចំផែនការមេនៃសំណង់ប្រាសាទបុរាណក្នុងតំបន់អង្គរ

ផ្សាយនៅថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ២០១៨

សិក្ខាកាម២២រូប នៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ជាមន្ត្រីជំនាញមកពីអាជ្ញាធរជាតិអប្សរា នាយកដ្ឋានគាំពារនិងអភិរក្សសំណង់បុរាណ អាជ្ញាធរជាតិព្រះវិហារ និងអាជ្ញាធរជាតិសំបូរព្រៃគុក បានបញ្ចប់វគ្គសិក្សាអំពី ការរៀបចំផែនការមេនៃសំណង់ប្រាសាទបុរាណក្នុងតំបន់អង្គរ កាលពីថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១៨។

វគ្គសិក្សានេះបានចាប់ផ្តើមកាលពីថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៨ បង្រៀនដោយ **លោកសាស្ត្រាចារ្យ ជនជាតិបារាំង** Jean-Christophe SIMON អ្នកជំនាញផ្នែកស្ថាបត្យកម្មបេតិកភណ្ឌ។

ថ្លែងក្នុងពិធីបិទវគ្គនៅមជ្ឈមណ្ឌលបណ្តុះបណ្តាលអង្គរ **លោកសាស្ត្រាចារ្យ** Jean-Christophe SIMON បានឱ្យដឹងថា វគ្គសិក្សានេះធ្វើឡើងក្នុងបំណងពង្រឹងការធ្វើការងារជាក្រុម និងការចែករំលែកព័ត៌មាន ដើម្បីរៀបចំឯកសារផែនការមេដែលជារឿងដ៏មានសារៈសំខាន់សម្រាប់ការរៀបចំផែនការអភិរក្សប្រាសាទនិងអភិវឌ្ឍន៍រមណីយដ្ឋាន។ លើសពីនោះទៀត វគ្គបណ្តុះបណ្តាលនេះនឹងធ្វើឱ្យកាន់តែប្រសើរនូវការអភិរក្សប្រាសាទតាមរយៈការវិភាគពីផលប៉ះពាល់លើសម្ភារៈសំណង់ រៀបចំគោលនយោបាយសម្រាប់ទេសចរណ៍ ដើម្បីអាចទទួលបានសេវាចាំបាច់មួយចំនួន និងចូលរួមអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ប្រជាពលរដ្ឋមូលដ្ឋានដែលរស់នៅក្នុងតំបន់នោះ។ លោកសាស្ត្រាចារ្យបន្តទៀតថា ក្នុងការសិក្សាគឺផ្តោតសំខាន់លើទ្រឹស្តីផងនិងការអនុវត្តតាមទីតាំងជាក់ស្តែងផង ទៅលើគោលដៅ២កន្លែង គឺប្រាសាទបាគងនិងប្រាសាទព្រះគោ ដោយបែងចែកសិក្ខាកាមជា៣ក្រុម គឺក្រុមទី១ សិក្សាអំពីការខូចខាតរបស់ប្រាសាទ ក្រុមទី២ សិក្សាអំពីជីវភាពសហគមន៍នៅជុំវិញប្រាសាទ និងក្រុមទី៣ សិក្សាអំពីទេសភាពវប្បធម៌ក្នុងតំបន់។

លោក សយ សុការិន្ទ បុគ្គលិកបច្ចេកទេសនៃនាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរ និងបុរាណវិទ្យាបង្គារ បានលើកឡើងថា ក្រុមលោកបានសិក្សាអំពីរចនាសម្ព័ន្ធប្រាសាទព្រះគោ ដោយសង្កេតរកមូលហេតុនៃការពុកផុយ ការបាក់ស្រុត និងការបំផ្លាញដោយកត្តាផ្សេងៗមកលើថ្មភក់ ថ្មបាយក្រៀម និងឥដ្ឋ។ សិក្សាលើកត្តាទឹកដែលនៅជុំវិញប្រាសាទ ឬទឹកដក់នៅតាមប្រាសាទ និងសិក្សាការប៉ះពាល់បណ្តាលមកពីរុក្ខជាតិដែលដុះតាមប្រាសាទ និងរិះរកវិធីសាស្ត្រដើម្បីកាត់បន្ថយការបំផ្លាញ ហើយរកដំណោះស្រាយជាបន្ទាន់ដើម្បីស្រោចស្រង់ និងរៀបចំផែនការមេសម្រាប់ជួសជុល។

លោក រ៉ែត សុផល បុគ្គលិកនាយកដ្ឋានអភិវឌ្ឍន៍ វប្បធម៌ សារមន្ទីរ និងបទដ្ឋានបេតិកភណ្ឌ តំណាងឱ្យក្រុមទី២ បានឱ្យដឹងថាក្រុមលោកបានបែងចែកជា២សំខាន់ គឺសកម្មភាពសហគមន៍បម្រើផលប្រយោជន៍ឱ្យសហគមន៍ និងសកម្មភាពសហគមន៍បម្រើផលប្រយោជន៍ឱ្យវិស័យទេសចរណ៍។ ក្រុមនេះសិក្សាអំពីមុខរបរ ការដាំដុះសម្រាប់គ្រួសារ និងលក់ទៅលើទីផ្សារ រួមទាំងសកម្មភាពមួយចំនួនទៀតដូចជាតម្បាញ ចម្លាក់ អាហារដ្ឋានសម្រាប់បម្រើភ្ញៀវទេសចរ ដើម្បីរកចំណូលបន្ថែម។

លោក សុខ សូសិលា បុគ្គលិកបច្ចេកទេស នាយកដ្ឋានទ្រទ្រង់បច្ចេកទេស និងគម្រោងអន្តរវិស័យ ក៏បានលើកឡើងដែរក្រុមលោកសិក្សាអំពីទេសភាពវប្បធម៌ ផ្តោតសំខាន់ទៅលើតំបន់ជុំវិញទាំងមូល មានប្រភេទដើមឈើ សំណង់ផ្ទះប្រជាជនផ្ទះបុរាណ សម្ភារៈសំណង់ និងរបងដែលសង់អំពីបង្គោលឈើឬថ្មជាដើម ដើម្បីធ្វើយ៉ាងណាជៀសវាងការប៉ះពាល់តម្លៃលេចធ្លោរបស់ប្រាសាទ។

គួរឲ្យកត់ដែរថា នេះជាលើកទី២ហើយដែលអាជ្ញាធរជាតិអប្សរាបានរៀបចំវគ្គបណ្តុះបណ្តាលរបៀបនេះឡើងដល់អ្នកជំនាញខ្មែរ ឱ្យកាន់តែមានភាពប្រសើរឡើងក្នុងជំនាញរបស់ខ្លួនលើវិស័យបេតិកភណ្ឌ។ សិក្ខាកាមក៏សំណូមពរដល់ថ្នាក់ដឹកឱ្យរៀបចំវគ្គបណ្តុះបណ្តាលនេះជាបន្តទៅទៀត ដោយមានគ្រូបង្គោលទាំងខ្មែរនិងបរទេស មកបង្ហាត់បង្ហាញធ្វើឱ្យពួកគាត់ទទួលចំណេះដឹងថ្មីៗ ដើម្បីពង្រឹងប្រសិទ្ធភាពការងារគ្រប់គ្រងប្រាសាទ និងការគ្រប់គ្រងរមណីយដ្ឋានទាំងមូល៕






ភ្នាក់ងារទេសចរក្នុងតំបន់អន្តរទន្លេបានការបណ្តុះបណ្តាលវគ្គសង្គ្រោះបឋមពីអ្នកជំនាញជប៉ុន

ផ្សាយនៅថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ២០១៨

ភ្នាក់ងារទេសចរដែលបំពេញការងារនៅតាមប្រាសាទក្នុងរមណីយដ្ឋានអង្គរចំនួន៤០នាក់ បានទទួលការបណ្តុះបណ្តាលវគ្គសង្គ្រោះបឋមពីអង្គការ NPO Srolanh Project បង្រៀនដោយអ្នកជំនាញជប៉ុន៩រូប។

វគ្គសិក្សានេះមានរយៈពេល១ព្រឹក នាថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៨ នៅសាលសន្និសិទអង្គរនៃមជ្ឈមណ្ឌលអាជ្ញាធរជាតិអប្សរា ដោយផ្តោតសំខាន់លើការធ្វើចលនាដង្ហើម ការរំលួស ការជួយសង្គ្រោះដោយសារបាក់ឬគ្រិចជាដើម។គួរបញ្ជាក់ផងដែរថា មកដល់បច្ចុប្បន្ននេះ អង្គការ NPO Srolanh Project បានចុះមកបង្រៀនដល់ភ្នាក់ងារទេសចរចំនួន០៣លើក ហើយ ដែលមានភ្នាក់ងារចូលរួមសរុបចំនួន១២០នាក់ ដោយក្នុងមួយវគ្គមានភ្នាក់ងារទេសចរចំនួន៤០នាក់។

ការរៀបចំវគ្គបណ្តុះបណ្តាលសង្គ្រោះបឋមខាងលើនេះ គេតែងតែធ្វើឡើងជារៀងរាល់៦ខែម្តង គឺនៅក្នុងខែកុម្ភៈ និងខែកក្កដា៕


នាយកដ្ឋានផ្សព្វផ្សាយ
www.apsaraauthority.gov.kh


នាយកដ្ឋានផ្សព្វផ្សាយ
www.apsaraauthority.gov.kh


Workshop on Sustainability
and Tourism Management
នាយកដ្ឋានផ្សព្វផ្សាយ
www.apsaraauthority.gov.kh


WFD Srolanh Project
Sites
នាយកដ្ឋានផ្សព្វផ្សាយ
www.apsaraauthority.gov.kh

អាជ្ញាធរជាតិអប្សរាក្រោកចាប់ដៃភូសហការជាមួយមជ្ឈមណ្ឌលស្រាវជ្រាវកសិកម្មធម្មជាតិមួយនៅប្រទេសភូវ៉ែ ដើម្បីពង្រឹងវិស័យកសិកម្មនៅភូមិធម្មជាតិរុនតាឯក

ផ្សាយនៅថ្ងៃទី ខែ១៤ កុម្ភៈ ឆ្នាំ២០១៨

គម្រោងអភិវឌ្ឍន៍ភូមិធម្មជាតិរុនតាឯក បានផ្តោតសំខាន់លើការអភិវឌ្ឍកសិកម្មដោយធម្មជាតិ មិនប្រើប្រាស់សារធាតុគីមី។ ដើម្បីជំរុញគម្រោងនេះឲ្យដំណើរការទៅដោយរលូន អាជ្ញាធរជាតិអប្សរាបានសហការជាមួយស្ថាប័នបរទេសមួយចំនួន ដែលមានជំនាញលើការងារកសិកម្មធម្មជាតិ។

ជាក់ស្តែង នៅព្រឹកថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៨នេះ **ឯកឧត្តមបណ្ឌិត ស៊ុំ ម៉ាប់** អគ្គនាយកអាជ្ញាធរជាតិអប្សរាបានអនុញ្ញាតឲ្យប្រតិភូនៃមជ្ឈមណ្ឌលស្រាវជ្រាវ DURE នៅប្រទេសភូវ៉ែតាមរយៈក្រុមហ៊ុន S&MDC Co.,Ltd. ដែលធ្វើការលើវិស័យកសិកម្មធម្មជាតិចូលជួប ពិភាក្សាការងារដោយផ្តោតសំខាន់លើការអភិវឌ្ឍ កសិកម្មធម្មជាតិនៅភូមិធម្មជាតិរុនតាឯក។

ឯកឧត្តម ម៊ុំ ម៉ារ៉ាឌី ទីប្រឹក្សានិងជាប្រធានគម្រោងអភិវឌ្ឍន៍ភូមិធម្មជាតិរុនតាឯកបានបញ្ជាក់ថា ជំនួបពិភាក្សានេះ ធ្វើឡើងដើម្បីដឹងពីលទ្ធភាពដែលស្ថាប័នទាំងពីរអាចនឹងបង្កើតកិច្ចសហការគ្នា នាពេលខាងមុខលើការរៀបចំកសិកម្មធម្មជាតិនៅភូមិធម្មជាតិរុនតាឯក។

ឯកឧត្តមបន្ថែមថា "យើងមានគម្រោងកសិកម្មធម្មជាតិ ដែលស្របគ្នានឹងមជ្ឈមណ្ឌលស្រាវជ្រាវរបស់ពួកគាត់ដែលកំពុងធ្វើការផ្នែកកសិកម្មធម្មជាតិនៅប្រទេសភូវ៉ែ លើផ្ទៃដីជាង១៥០០ហិកតាដែរ។ ពួកគាត់មានជំនាញពិសេសក្នុងការធ្វើឲ្យដីបង្កើនគុណភាពដោយខ្លួន តាមរយៈការធ្វើដីឲ្យធូរជ្រៅទៅខាងក្រោម ដែលជាជំនួយដល់ការលូតលាស់ដំណាំកសិកម្ម ទទួលបានផលច្រើន ដោយមិនចាំបាច់ប្រើប្រាស់សារធាតុគីមី"។

គួររំឭកថា ភូមិធម្មជាតិរុនតាឯក ត្រូវបានបង្កើតឡើងដោយមានការជ្រើសរើសប្រជាជនក្នុងតំបន់អង្គរឲ្យមករស់នៅដោយសារកំណើនយ៉ាងឆាប់រហ័សក្នុងតំបន់បេតិកភណ្ឌមួយនេះ។ បច្ចុប្បន្នមានគ្រួសារចំនួន ១០៣ហើយ ដែលត្រូវបានជ្រើសរើសឲ្យមកស្នាក់នៅ ដោយមានការផ្តល់ផ្ទះមួយខ្នង និងដីសម្រាប់ធ្វើកសិកម្ម១ហិកតា។ ផ្ទៃដីសរុបនៃភូមិនេះមានចំនួន ១០១២ហិកតា ហើយគ្រោងនឹងពង្រីកបន្ថែមទៀតនាពេលអនាគត។ ដើម្បីលើកស្ទួយជីវភាពប្រជាពលរដ្ឋនៅទីនេះ ក្រៅពីហេដ្ឋារចនាសម្ព័ន្ធ ក្រុមគម្រោងបានផ្តោតការយកចិត្តទុកដាក់ខ្លាំងលើវិស័យកសិកម្មដោយមិនប្រើប្រាស់សារធាតុគីមី។

គម្រោងនេះបានដំណើរការជាបណ្តើរៗដោយទទួលបានទាំងលទ្ធផលកសិកម្ម និងទីផ្សារនាំទៅក្រៅប្រទេសទៀតផង។ ទោះជាយ៉ាងនេះក្តី ក្រុមគម្រោងក៏នៅតែរង់ចាំស្វាគមន៍រាល់គម្រោងសហប្រតិបត្តិការជាតិ និងអន្តរជាតិដើម្បីពង្រីកវិសាលភាពទីផ្សារឲ្យទូលំទូលាយ៕






អាឡឺម៉ង់បន្តបំប៉ន សម្ថភាពការងារអភិរក្សថ្មដល់មន្ត្រីជំនាញអាជ្ញាធរជាតិអប្សរា

ផ្សាយនៅថ្ងៃទី ១៤ ខែ កុម្ភ: ឆ្នាំ២០១៨

ប្រទេសអាឡឺម៉ង់តាមរយៈស្ថាប័នGIZ បានបន្តជួយបណ្តុះបណ្តាលមន្ត្រីជំនាញរបស់អាជ្ញាធរជាតិអប្សរាលើការងារអភិរក្សថ្មថែមទៀតក្នុងឆ្នាំនេះ។ វគ្គបណ្តុះបណ្តាលថ្មី ដែលទើបបើកកម្មវិធីនៅព្រឹកថ្ងៃទី១៤ ខែកុម្ភ: ឆ្នាំ២០១៨នេះ គឺវគ្គបណ្តុះបណ្តាល ស្តីអំពី Laboratory and Science in Applied Conservation។

វគ្គនេះ រៀបចំឡើងដោយអញ្ជើញមន្ត្រីជំនាញ១១រូប ដែលធ្លាប់ទទួលបានការបណ្តុះបណ្តាលជាច្រើនឆ្នាំមកហើយ ដើម្បីបំប៉នការយល់ដឹងថែមទៀត កាន់តែស៊ីជម្រៅអំពីរចនាសម្ពន្ធថ្ម ការតាមដានពីបម្រែបម្រួលរបស់ថ្ម របៀបប្រើប្រាស់ថ្ម របៀបប្រើប្រាស់ថ្នាំ និងសម្ភារៈផ្សេងៗទៅតាមបទដ្ឋានការអភិរក្ស និងការសិក្សារូបវន្តរបស់ថ្មតាមបែបពិសោធន៍ វិទ្យាសាស្ត្រ ដោយមានការអនុវត្តទ្រឹស្តីនៅក្នុងមន្ទីរពិសោធន៍ផ្ទាល់តែម្តង។

អ្នកស្រីបណ្ឌិត Grifi Federica ដែលជាគ្រូឧទ្ទេសនៃវគ្គបណ្តុះបណ្តាលនេះ លើកឡើងថាប្រធានបទសំខាន់នៃវគ្គបណ្តុះបណ្តាលនេះគឺនៅត្រង់ថា "វាមានគម្លាតគ្នារវាងទ្រឹស្តីវិទ្យាសាស្ត្រ និងការអនុវត្តជាក់ស្តែងលើការងារអភិរក្សថ្ម។ ខ្ញុំចង់ឱ្យអ្នកអភិរក្សយើងបំពេញនូវគម្លាតនេះ ដោយផ្សារភ្ជាប់នូវទ្រឹស្តីវិទ្យាសាស្ត្រជាមួយនឹងការអនុវត្តជាក់ស្តែង។ យើងនឹងបកស្រាយទ្រឹស្តីវិភាគបែបវិទ្យាសាស្ត្រចូលទៅក្នុងការងារជាក់ស្តែងនៅការដ្ឋាន។ ម្យ៉ាងទៀត យើងឃើញថា ទ្រឹស្តីភាគច្រើនមានលក្ខណៈជាវិទ្យាសាស្ត្រ ដែលធ្វើឱ្យអ្នកអភិរក្សពិបាកយល់។ ខ្ញុំនឹងយកទ្រឹស្តីនេះមកបកស្រាយដោយភាសាសាមញ្ញសម្រាប់ក្រុមអ្នកអភិរក្សយើងងាយយល់ ងាយស្តាប់បាន"។

ឯកឧត្តម ហង់ ពៅ អគ្គនាយករងនិងជាតំណាង **ឯកឧត្តមបណ្ឌិត ស៊ុំ ម៉ាប់** អគ្គនាយកអាជ្ញាធរជាតិអប្សរាមានប្រសាសន៍ ក្នុងពិធីបើកវគ្គបណ្តុះបណ្តាលថា នេះមិនមែនជាលើកទីមួយទេដែល GIZ បានបើកវគ្គបណ្តុះបណ្តាលដល់អ្នកជំនាញខ្មែរ ប៉ុន្តែក្នុងករណីនេះមានរយៈពេលវែង និងសិក្សានៅមន្ទីរពិសោធន៍ផ្ទាល់ ដោយវិភាគលម្អិតលើសមាសធាតុថ្ម តាមបែបវិទ្យាសាស្ត្រ។ ឯកឧត្តមបន្ថែមថា នេះជាវគ្គបណ្តុះបណ្តាលកម្រិតខ្ពស់មួយ ដែលអ្នកចូលរួមភាគច្រើនគឺសុទ្ធតែធ្លាប់ឆ្លងកាត់វគ្គបណ្តុះបណ្តាល និងមានជំនាញក្នុងការដ្ឋានស្រាប់ហើយ។ តែវគ្គនេះ នឹងជួយលម្អិតដល់ពួកគាត់រវាងទ្រឹស្តីវិទ្យាសាស្ត្រនិងការដែលគាត់អនុវត្តជាក់ស្តែងនៅការដ្ឋាន។

គួររំឭកផងដែរថាតាំងពីឆ្នាំ២០០៦ ស្ថាប័ន GIZ បានសហប្រតិបត្តិការជាមួយអាជ្ញាធរជាតិអប្សរាលើការបណ្តុះបណ្តាលអ្នកជំនាញលើការជួសជុលថ្ម។ នៅឆ្នាំ២០០៧ អាជ្ញាធរជាតិអប្សរាក៏បានបង្កើតអង្គភាពអភិរក្សថ្មឡើង (Stone Conservation Unit - SCU) ដើម្បីជួសជុលថ្មនៅតាមប្រាសាទ និងរចនាសម្ព័ន្ធផ្សេងៗ។ បច្ចុប្បន្នក្រុមការងារនេះបានទទួលបន្ទុកជួសជុលចម្លាក់ប្រាសាទ និងព្យាបាលថ្មនៅតាមប្រាសាទមួយចំនួនដូចជា ចម្លាក់តោនៅប្រាសាទក្រវ៉ាន់ ចម្លាក់តោនិងពុទ្ធបដិមានៅប្រាសាទប្រែរូប និងចម្លាក់មួយចំនួនទៀតនៅប្រាសាទបន្ទាយសំរ៉ែជាដើម៕









ទំនៀមលៀងមេមត់ ជាផ្នែកមួយនៃការរស់នៅរបស់ប្រជាជនក្នុងតំបន់អង្គរដោយមិនអាចខ្វះបាន!

ផ្សាយនៅថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ២០១៨

ជារៀងរាល់ឆ្នាំ តាំងពីបរមបុរាណមកហើយ ឱ្យតែដល់ខែមាឃ អ្នកស្រុកអង្គរដែលមានជំនឿនិងរក្សាបានខ្ជាប់ខ្ជួននូវមរតកទាក់ទងនឹងពិធីលៀងមេមត់ តែងប្រារព្ធពិធីនេះមិនដែលខកខានតាមភូមិស្រុករបស់ខ្លួនយ៉ាងអធិកអធម។ ជាក់ស្តែង

ពិធីនេះ ត្រូវបានរៀបចំយ៉ាងគគ្រឹកគគ្រេង កាលពីថ្ងៃ៣រោច ខែមាឃ ឆ្នាំរកា ត្រូវនឹងថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៨ កន្លងមក នៅផ្ទះ **អ្នកស្រី គង់** ជាគ្រូធំមួយមានគេគោរពច្រើន ស្ថិតក្នុងភូមិនគរក្រៅ សង្កាត់គោកចក ខេត្ត/ក្រុងសៀមរាប។

តាមប្រសាសន៍របស់ **អ្នកស្រី គង់** ឱ្យដឹងថា ឆ្នាំនេះមានមេមត់ក្មេងចាស់ ប្រុសស្រីជាង៣០នាក់ដែលមកលៀង។ ឯអ្នកខ្លះគេខ្មាសអៀនក្នុងការរាំវែក គេបានយកគ្រឿងណ្តាប់មកឱ្យយើង (**អ្នកស្រី គង់**) ចូលជំនួសឬក៏បងប្អូនគេដែលមានរូបស្នងត្រូវមកលៀងមេមត់ដែរក៏មាន។ អ្នកស្រីបន្តទៀតថា ការរៀបចំលៀងមេមត់ គឺដើម្បីសុំសេចក្តីសុខ សេចក្តីចម្រើន ឱ្យព្រលឹងដូចតាជាគ្រូកំណើត ជាឈ្នួរបានរាំវែកឱ្យសប្បាយមួយឆ្នាំម្តង និងឱ្យអ្នកស្នងរូបជារូបជាអង្គពីជំងឺឈឺក្បាលវិលមុខផ្សេងៗ។

សម្រាប់អ្នកស្រី ដែលមានគ្រូធំជាស្តេចស្វា ហៅថា «ព្រះរាជគ្រូ» ចូលសណ្ឋិតជាង១០ឆ្នាំមកហើយនោះ ដំបូងមិនបានជឿលើជំនឿនេះទេ រហូតឈឺត្រដាបត្រដួសស្ទើរស្លាប់ស្ទើររស់ រកពេទ្យបីបួនមើលមិនជា ដាក់ថ្នាំមិនត្រូវ ដល់ថ្នាក់ឈឺទាំងកូនទាំងប្តី ទើបចាប់ផ្តើមរៀបចំអាសនៈ គ្រឿងណ្តាប់សម្រាប់គ្រូដែលចង់នៅជាមួយ ហើយប្រតិបត្តិតាមដោយកាន់សីល កាន់ធម៌សច្ចៈ ក៏បានជាសះស្បើយ គ្រួសារក៏សុខសប្បាយ ជីវភាពក៏ធូរធារជាងមុន។

អ្នកស្រីត្រូវបានអ្នកភូមិនិងក្រៅភូមិស្រុកផងចូលមកឱ្យជួយព្យាបាលជំងឺ ដោះអំពើផ្លូវងងឹត ទស្សន៍ទាយ ស្រោចទឹក លើករាសីក្នុងការរកស៊ី កាត់គ្រោះជាហូរហែ។ លើសពីនោះទៀត គាត់ក៏ជាអ្នកប្រោះព្រំ បង្កក់រាសីដល់មេមត់ផ្សេងៗទៀតនៅក្នុងស្រុក ក្រៅស្រុក តាមដែលគេជឿជាក់និងគោរពរាប់អាន រហូតដល់គេហៅថាជា «គ្រូធំ»។ ដូច្នេះហើយ រៀងរាល់ឆ្នាំ គេតែងរៀបចំលៀងមេមត់នៅផ្ទះរបស់គាត់ ព្រោះគេជឿថាមានតែគ្រូធំទេ ដែលអាចការពារយិតយោងមេមត់ផ្សេងៗនិងការផ្ទាញ់ផ្ទាលពីសភាវៈអាក្រក់មកយាយីបៀតបៀនបាន។

ក្នុងនាមជាគ្រូធំម្នាក់ អ្នកស្រីមានតួនាទីមើលថែ ការពារ និងយឹតយោងមេមត់ផ្សេងៗដែលមកលៀងពីពួកសភាវៈអាក្រក់កុំឱ្យបៀតបៀនតាមផ្លូវងងឹត រួមទាំងសម្របសម្រួលដល់មេមត់ខ្លះទៀតដែលទើបមកថ្មី ហើយក៏ជាអ្នកសួរនាំពីបំណងឬតម្រូវការរបស់ព្រលឹងនៃរូបនោះផងដែរពេលរូបនោះនិយាយអ្វីប្រាប់។

ចំពោះអ្នកស្រី «មេមត់» គ្រាន់តែជាព្រលឹងដូនតាដែលបានស្លាប់ទៅក្លាយជាខ្មោចដែលមានឫទ្ធិអំណាចព្រោះធ្លាប់ជាអ្នករៀនមន្តវិជ្ជាការផ្សេងៗកាលនៅរស់ ដែលខ្លះកាច ខ្លះស្លូត ក្រមិចក្រមើម របិលរប៉ូចតាមនិស្ស័យជាមនុស្សកាលនៅរស់ តែមិនមែនវិញ្ញាណអាក្រក់ ស្មោកគ្រោក ដើរធ្វើបាបកូនចៅឬអ្នកណាផ្សេងនោះទេ។ ព្រលឹងទាំងនេះតែងតែនៅជាមួយកូនចៅណាម្នាក់ក្នុងគ្រួសារដែលមាននិស្ស័យជាមួយ ហើយទាមទារឱ្យយើងជាអ្នកកាន់ អ្នកស្នងរូបគោរព រំឭកនឹកគុណ មិនឱ្យធ្វើអ្វីដែលអាក្រក់ និងរៀបគ្រឿងណ្តាប់តាមអ្វីដែលត្រូវការ ហើយចង់រាំវែកឱ្យសប្បាយរីករាយតែប៉ុណ្ណោះ។ បើយើងធ្វើតាមបាន យើងក៏សុខសប្បាយ តែបើយើងល្មើស ធ្វើអាក្រក់ ខុសប្រពៃណី មិនអើពើ នឹងធ្វើឱ្យអ្នកនោះឬកូនចៅមានជំងឺតម្កាត់ ឬរកស៊ីមិនសូវធូរធារ តែបើយើងដឹង ហើយកែខៃវិញ នោះនឹងបានល្អប្រសើរ។

បន្ថែមពីនោះ អ្នកស្រីក៏រៀបរាប់ដោយអឹមអៀននិងអស់សំណើចថា ពេលចូលរូបអត់ខ្មាសទេ ឮតែភ្លេងពិណពាទ្យ គឺចង់តែរាំទ្រាំមិនបាន ទាំងតាមធម្មតាអ្នកស្រីជាមនុស្សអៀនច្រើន សុភាព មិនចេះរាំវែកសូម្បីបន្តិច។ អ្នកស្រីនឹងបន្តជំនឿនេះរហូត ព្រោះជំនឿនេះធ្វើឱ្យអ្នកស្រី គ្រួសារ និងស្រុកភូមិមានក្តីសុខ ហើយក៏មិនជឿដៃរថា ជំនឿនេះនឹងបាត់បង់ពីទឹកដីអង្គរ ព្រោះមានកូនចៅច្រើនណាស់ចាំគោរពប្រតិបត្តិនិងជឿជាក់ ហើយវាជាផ្នែកមួយដ៏សំខាន់ដែលមិនអាចបោះបង់ចោលបានក្នុងការរស់នៅ។

ចំពោះ **បងស្រី ប្រាក់** ដែលមានឈ្នួរកាន់យូរឆ្នាំហើយ ហើយក៏មកលៀងរាល់ឆ្នាំដែរ។ បងស្រីឱ្យដឹងថា មុននឹងដឹងថា យើងមានឈ្នួរឬគ្រូកំណើតកាន់ គឺយើងចេះតែឈឺនេះ ឈឺនោះ ទៅពេទ្យក៏មិនជា លេបថ្នាំក៏មិនត្រូវ ក៏ទៅឱ្យគ្រូដែលចេះទស្សន៍ទាយទើបដឹងថាយើងទាស់អី ខ្វះអី។ លុះពេលដឹងថាជាគ្រូកំណើតឬឈ្នួរហើយ គេត្រូវការបែបម៉េច ត្រូវការអ្វីខ្លះ ក៏រៀបទៅតាមគេតម្រូវ មិនចេះតែធ្វើតាមចិត្តនោះទេ។ ការរៀបជមនិងគ្រឿងរណ្តាប់សម្រាប់គ្រូកំណើតនិងឈ្នួរ គឺខុសគ្នា។ បើយើងរៀបត្រូវ ពេលរូបចូលមកក៏រាំរែកសប្បាយរីករាយ បង្ហូតបង្ហាញគេ ហើយលើកមកថើបដោយក្តីស្រឡាញ់ ហើយរូបកាយអ្នកស្នងក៏ស្រឡះខ្លួន ជាសះស្បើយពីជំងឺ។ ផ្ទុយទៅវិញ បើរៀបចំគ្រឿងរណ្តាប់មិនត្រូវ ពិសេសជមគឺមេមត់មិនចូលរូបឡើយ ឬចូលតែយំ មិនរាំលេង បោកប្រាស់ ក្រញ៉ៀក្រញូវ ដែលគេថា «មេមត់ង៉ក់» ហើយធ្វើឱ្យរូបកាយអ្នកស្នងមិនជាស្រួលខ្លួនដែរ។

អ្នកស្រី ទិត្យ ហៀម មានទាំងឈ្នួរយាយតាកាន់ផង គ្រូកំណើតកាន់ផងជាង២០ឆ្នាំមកហើយ។ គាត់មិនដែលខកខានទេក្នុងការមកលៀងមេមត់ ដើម្បីឱ្យគ្រូកំណើតនិងឈ្នួរបានរាំរែកសប្បាយពេលដល់ខែដល់រដូវ។ អ្នកស្រី បញ្ជាក់ថា ឈ្នួរ គឺតមកពីម៉ែពីឪ យាយតា ហើយត្រូវរាំរែកជាប់រាល់ឆ្នាំ ឯគ្រូកំណើត គឺជាគ្រូដែលយើងបានទៅរៀនសូត្រធម៌មន្តវិជ្ជាការជាមួយ ឬទៅឱ្យកាត់មើលជំងឺឱ្យ លុះពេលគាត់ស្លាប់ទៅ គ្រូគាត់ក៏នឹងមកទំ (នៅជាមួយ) យើង តែវាមិនទាំងអស់ទេអាស្រ័យលើនិស្ស័យ ហើយគ្រូកំណើត គឺរាំ៣ឆ្នាំម្តង។

បើទោះបីមានវ័យជាង៥០ឆ្នាំទៅហើយក៏ដោយ ក៏អ្នកស្រីប្រកាន់ជំហរយ៉ាងមុតមាំមិនបោះបង់ចោលការចូលរូប មិនបោះបង់ចោលព្រលឹងដូនតា ឬចងឈ្នួរចោលដែរ ព្រោះវាបាប វាធ្វើឱ្យយើងឈឺ វាដូចជាយើងបង្គត់បាយបង្គត់ទឹកដូនតាម៉ែឪយើងឱ្យក្តៅក្រហាយ ណាមួយវាក៏មិនលំបាកអីផង មួយឆ្នាំរៀបចំពិធីតែម្តង ហើយកូនចៅក៏គាំទ្រនិងជួយជ្រោមជ្រែងក្នុងការមករៀបចំពិធីលៀងមេមត់នេះទៀត! បើយើងគោរពតាម យើងក៏ស្រឡះរូបស្រឡះអង្គ កូនចៅសុខសប្បាយ និងជាទំនៀមទម្លាប់ពីបរមបុរាណផង»។

ពិធីលៀងមេមត់ គឺពិតជាសំខាន់ខ្លាំងណាស់សម្រាប់ប្រជាជនក្នុងតំបន់អង្គរ ព្រោះវាជាផ្នែកមួយនៃការរស់នៅរបស់ពួកគាត់ទាក់ទងនឹងជំនឿដែលផ្តាច់មិនបាន បើទោះបីវិទ្យាសាស្ត្រនិងផ្នែកសុខាភិបាលមានការរីកចម្រើនខ្លាំងក្តី។ លើសពីនោះទៀត ក៏បង្ហាញពីការដឹងគុណចំពោះបុព្វបុរសជាគ្រូបាចារ្យ ជាឪពុកម្តាយដែលបានចែកឋានទៅហើយផងដែរ មិនថាគាត់ទៅជាអ្វី ក៏នៅតែកូនចៅរាប់រកជានិច្ច។ ការចូលរួម ភាពជឿជាក់ និងការយើញរឿងហេតុអស្ចារ្យនៅក្នុងពិធី ជាអ្វីដែលធ្វើឱ្យពួកគាត់យល់ថា វត្ថុស័ក្តិសិទ្ធិនិងបារមីនៅតែមានជីវិតរស់នៅលើដែនដីអង្គរ មិនសាបសូន្យទៅណា។

ការប្រតិបត្តិទាំងនេះ ជាការរួមចំណែកមួយក្នុងការថែរក្សាមរតកជំនឿឱ្យនៅតែមានជីវិតគ្រប់ជំនាន់ និងបញ្ជាក់ពីកំណើតអត្តសញ្ញាណរបស់ជាតិខ្មែរ ដែលមិនគួរឱ្យបាត់បង់តាមពេលវេលា៕









សេចក្តីជូនដំណឹងស្តីពី៖ ការកាត់សម្អាតដើមឈើ កាត់ក្រឹមកឈើ និងអារច្រៀកដើមឈើនៅតាមបរិវេណប្រាសាទ និងតាមកូមិនានាក្នុងរមណីដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ២០១៨



ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA

ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

អាជ្ញាធរអប្សរា
APSARA
ន.អ.អ/រប.សណ.៣
០៧

សេចក្តីជូនដំណឹង
ស្តីពី
ការកាត់សម្អាតដើមឈើ កាត់ក្រឹមកឈើ និងអារច្រៀកដើមឈើ
នៅតាមបរិវេណប្រាសាទ និងតាមកូមិនានាក្នុងរមណីយដ្ឋានអង្គរ

អាជ្ញាធរអប្សរា សូមជូនដំណឹងដល់ស្ថាប័ន សមត្ថកិច្ចពាក់ព័ន្ធ ភ្ញៀវជាតិ-អន្តរជាតិ មគ្គុទ្ទេសក៍ទេសចរណ៍ ព្រមទាំងសាធារណជនទាំងអស់មេត្តាជ្រាបថា ដើម្បីធានាដល់សុវត្ថិភាពភ្ញៀវទេសចរ សាធារណជន ក៏ដូចជាដើម្បីលើកតម្កស់សោភ័ណភាពនៅតាមដងផ្លូវ និងកូមិនានាក្នុងតំបន់រមណីយដ្ឋានអង្គរ និងតំបន់ដែលគ្រប់គ្រងដោយអាជ្ញាធរអប្សរា នាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាន នៃអាជ្ញាធរអប្សរានឹងធ្វើការកាត់សម្អាតដើមឈើ កាត់ក្រឹមកឈើ និងអារច្រៀកដើមឈើ តាមទីតាំងដូចខាងក្រោម៖

-កាត់សម្អាតដើមឈើចំនួន ១១ដើម ដែលដួលរលំដោយសារភ្លៀង និងខ្យល់ក្នុងបរិវេណប្រាសាទព្រះខ័ន បរិវេណខ្លោងទ្វារជីឆ្នាំង និងបរិវេណប្រាសាទអង្គរវត្ត។

-កាប់សម្អាតដើមឈើដែលមានកំពស់ចាប់ពី ១ម៉ែត្រឡើង និងកាត់ក្រឹមកឈើដែលបំរះពាល់ទេសភាពប្រាសាទ ក្នុងបរិវេណប្រាសាទអង្គរវត្ត។

-អារច្រៀកឈើចំនួន ១៨ដើម ដែលបានរលំដួលដោយសារភ្លៀង និងខ្យល់នៅក្នុងតំបន់ឧទ្យានអង្គរ។

-កាត់ក្រឹមកឈើជុះគ្របតាមដងផ្លូវវង់តូច វង់ធំ និងក្នុងតំបន់ឧទ្យានអង្គរ។

-កាត់ដកហូតដើមឈើ និងកាត់ក្រឹមកឈើនៅភូមិត្រកាំងសេះ សង្កាត់គោកចក ក្រុងសៀមរាប។

ការងារនេះ នឹងចាប់ផ្តើមអនុវត្តចាប់ពីថ្ងៃទី ០៧ ខែកុម្ភៈ ឆ្នាំ២០១៨ រហូតដល់បញ្ចប់ការងារ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមស្ថាប័ន សមត្ថកិច្ចពាក់ព័ន្ធ ភ្ញៀវជាតិ-អន្តរជាតិ មគ្គុទ្ទេសក៍ទេសចរណ៍ ព្រមទាំងសាធារណជនទាំងអស់ មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃ អង្គារ ១៣រោច ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
ត្រចៀកកែ ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ២០១៨
អគ្គនាយក

ស៊ុំ ម៉ាប់

ជម្លូតជូន៖
-សាលាខេត្តសៀមរាប
-មន្ទីរបរិស្ថានខេត្តសៀមរាប
-មន្ទីរកសិកម្ម ព្រៃឈើ និងនេសាទខេត្តសៀមរាប
-អង្គភាពនគរបាលការពារបេតិកភណ្ឌប្រចាំខេត្តសៀមរាប
-ស្នាក់ការតំបន់ការពារទេសភាពអង្គរ
-សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ទាំងអស់ប្រចាំខេត្តសៀមរាប
ដើម្បីជូនជ្រាប និងសហការ-
-ប៉ូលីសទេសចរណ៍
-ប្រចាំនាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធរបស់អាជ្ញាធរអប្សរា
ដើម្បីចុះការ និងសហការ-
-ឯកសារ-កាលប្បវត្តិ

លេខទូរស័ព្ទទំនាក់ទំនង៖លោក ឧត សុវណ្ណារិទ្ធ 012-354-630, លោក ម៉ៀន សុធី 010-304-069,086-9522-5056,កញ្ញា ងាន ច័ន្ទលា 095-947-860

PHNOM PENH :
អាជ្ញាធរដែនដីសម្រាប់ការពារ អភិរក្ស និងគ្រប់គ្រងតំបន់អង្គរ
AUTHORITY FOR THE PROTECTION AND MANAGEMENT OF ANGKOR AND THE REGION OF SIEMREAP
Website : http://www.apsaraauthority.gov.kh
SIEM REAP :

មូលនិធិបេតិកភណ្ឌវប្បធម៌កូរ៉េបើកសិក្ខាសាលាលើកទី២ស្តីអំពី «កិច្ចអភិរក្សប្រាសាទព្រះពិធូរ»

ផ្សាយនៅថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ២០១៨

ក្រុមអ្នកជំនាញបុរាណវិទ្យាខ្មែរនិងកូរ៉េជាច្រើនរូប បានធ្វើបទបង្ហាញទាក់ទងនឹងកិច្ចការអភិរក្សប្រាសាទក្នុងតំបន់អង្គរ នៅក្នុងសិក្ខាសាលាស្តីអំពី «កិច្ចអភិរក្សប្រាសាទព្រះពិធូរ» ជាលើកទី២រៀបចំដោយគម្រោងជួសជុលប្រាសាទព្រះពិធូរ ដែលមានកិច្ចសហប្រតិបត្តិការរវាងអាជ្ញាធរជាតិអប្សរានិងមូលនិធិបេតិកភណ្ឌវប្បធម៌កូរ៉េ (KCHEF) និងភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA) នាថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៨។

សិក្ខាសាលារយៈពេលមួយថ្ងៃពេញនេះ អញ្ជើញបើកកម្មវិធីដោយ **ឯកឧត្តមបណ្ឌិត ស៊ុំ ម៉ាប់** អគ្គនាយកអាជ្ញាធរជាតិអប្សរា និងមានអ្នកជំនាញខ្មែរ អ្នកជំនាញអន្តរជាតិជាច្រើនស្ថាប័នពាក់ព័ន្ធនឹងវិស័យជួសជុលអភិរក្សបេតិកភណ្ឌក្នុងតំបន់អង្គរចូលរួមជាច្រើននាក់ផងដែរ។

សិក្ខាសាលានេះ ធ្វើឡើងក្នុងគោលបំណងចែករំលែកចំណេះដឹងអំពីការស្រាវជ្រាវទាក់ទងការជួសជុល ការអភិរក្សប្រាសាទក្នុងតំបន់អង្គរ ពិសេសគឺក្រុមប្រាសាទព្រះពិធូរ ដែលទទួលខុសត្រូវការងារដោយអ្នកជំនាញកូរ៉េ។ ក្នុងសិក្ខាសាលានេះ ក៏មានបទបង្ហាញជាច្រើននិយាយអំពីការស្រាវជ្រាវអំពីវប្បធម៌ អរិយធម៌ខ្មែរ ការកំណាយស្រាវជ្រាវពីរចនាសម្ពន្ធសំណង់ប្រាសាទព្រះពិធូរ ស្ថាបត្យកម្មសំណង់ ចម្លាក់តាមប្រាសាទផ្សេងៗផងដែរ។

គួរបញ្ជាក់ដែរថា គម្រោងកិច្ចសហប្រតិបត្តិការជួសជុលប្រាសាទព្រះពិធូរ គឺដើម្បីជួសជុលស្តារឡើងវិញនូវក្រុមប្រាសាទព្រះពិធូរ មានទីតាំងនៅទល់មុខព្រះលានជល់ដំរី។ គម្រោងនេះចាប់ផ្តើមពីឆ្នាំ២០១៥ និងគ្រោងបញ្ចប់ជំហានដំបូងក្នុងឆ្នាំ២០១៨។ គម្រោងអភិរក្សជួសជុលប្រាសាទព្រះពិធូរមានការងារ៣ធំដែលត្រូវធ្វើគឺ ការងារបណ្តុះបណ្តាលធនធានមនុស្ស ការងារស្រាវជ្រាវចងក្រងឯកសារ និងការងារអភិរក្សជួសជុលស្តារឡើងវិញ៕









សកម្មភាពដើមខែទី១ ឆ្នាំ២០១៨ របស់ភ្នាក់ងារទេសចរណ៍អាជ្ញាធរជាតិអប្សរាសង្គ្រោះភ្ញៀវ និងប្រគល់របស់ជូនភ្ញៀវទិញ

ផ្សាយនៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ២០១៨

ភ្នាក់ងារទេសចរណ៍ មានតួនាទីសំខាន់ក្នុងការផ្តល់នូវព័ត៌មានអំពីសេវាកម្មទេសចរណ៍ដល់ភ្ញៀវ មើលសកម្មភាពនានា ពន្យល់ណែនាំឱ្យភ្ញៀវគោរពតាមក្រមប្រតិបត្តិអង្គរ ជួយសង្គ្រោះភ្ញៀវ ប្រគល់របស់ជូនភ្ញៀវ ជាពិសេសជួយដោះស្រាយបញ្ហាផ្សេងៗដែលបានកើតឡើងចំពោះភ្ញៀវដោយថាហេតុក្នុងដំណើរទស្សនានៅតំបន់អង្គរ។

យោងតាមរបាយការណ៍សកម្មភាពការងាររបស់នាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍អង្គរ នៃអាជ្ញាធរជាតិអប្សរាប្រចាំខែមករា ឆ្នាំ២០១៨ បានឱ្យដឹងថា ក្រុមការងារជួយសង្គ្រោះភ្ញៀវបានចំនួន៤០ករណីដែលរងរបួសដោយរអិលឬជំពប់ជើងដួលគ្រិច ថ្លោះដៃ ជើង ខ្យល់គរ រលាមុខ ចុកពោះ សត្វស្វាខាំ និងពស់ចឹកជាដើម។ បញ្ហាទាំងនេះកើតឡើងដោយសារភ្ញៀវខ្លះមានការធ្វេសប្រហែស និងមិនគោរពតាមការណែនាំ ឬផ្លាកសញ្ញាហាមឃាត់ និងបញ្ហាសុខភាពផ្ទាល់ខ្លួន។

បញ្ហាទាំងនេះត្រូវបានភ្នាក់ងារទេសចរណ៍ដែលមានជំនាញសង្គ្រោះបឋម និងមានបរិក្ខារសង្គ្រោះបឋមនៅជាប់ខ្លួនជួយសង្គ្រោះបឋមទាន់ពេលវេលានៅកន្លែងកើតហេតុក្នុងករណីស្រាលៗនិងសហការជាមួយនគរបាលទេសចរ និងនគរបាលការពារបេតិកភណ្ឌ បញ្ជូនទៅមន្ទីរពេទ្យក្នុងរកណីរបួសធ្ងន់ធ្ងរ។

បន្ថែមពីនោះ ក្រុមភ្នាក់ងារទេសចរណ៍ក៏បានរើសរបស់របរភ្ញៀវដែលភ្លេចឬជ្រុះនៅតាមប្រាសាទចំនួន២៨ករណីមានៈទូរសព្ទដៃ អាយផេត កាបូបស្ពាយ កាបូបលុយ និងម៉ាស៊ីនថតជាដើម ហើយបានរកឃើញនិងប្រគល់ជូនម្ចាស់វិញបាន ២៥ករណី។ ឯរបស់ខ្លះទៀត ដែលភ្ញៀវមិនបានមករកភ្លាមៗ ក្រុមការងារបានប្រគល់ឱ្យនគរបាលទេសចរណ៍រក្សាទុករងចាំម្ចាស់ដើមមកទាក់ទង។ រាល់សកម្មភាពទាំងអស់នេះ តែងទទួលបានការអរគុណនិងការកោតសរសើរយ៉ាងកក់ក្តៅពីសំណាក់ភ្ញៀវទេសចរជាតិនិងអន្តរជាតិ ព្រមទាំងបានបង្ហាញនូវក្តីស្រលាញ់និងទំនុកចិត្តខ្ពស់មកលើភ្នាក់ងារទេសចរណ៍នៃអាជ្ញាធរជាតិអប្សរាទៀតផង។

ក្រៅពីការសង្គ្រោះ ការរើសរបស់ភ្ញៀវ ក្រុមភ្នាក់ងារទេសចរណ៍ក៏បានហាមឃាត់ភ្ញៀវដែលប្រព្រឹត្តិមិនសមរម្យបានចំនួន១០០ករណីរួមមានៈ ការបង្ហោះត្រួន (Drone) ជនបរទេសថតរូប អាពាហ៍ពិពាហ៍ដោយគ្មានការអនុញ្ញាត ការថតរូបបញ្ចេញកាយវិការមិនសមរម្យ ឡើងកន្លែងហាមឃាត់និងគ្រោះថ្នាក់ លួចដុំថ្មប្រាសាទ ស្លៀកពាក់សុិចស៊ី ប្រើប្រាស់ម៉ាស៊ីនថតខ្នាតធំ ថតរូបម៉ូដែល លួចថតវីដេអូដើម្បីផ្សព្វផ្សាយធ្វើអាជីវកម្មជាដើម។ ក្រោយពីហាមឃាត់ ក្រុមការងារក៏បានណែនាំតាមគោលការណ៍ដែលមានជាធរមាន និងដាក់សំណើសុំច្បាប់អនុញ្ញាតពីអាជ្ញាធរជាតិអប្សរាជាមុនសិន ក្នុងករណីណាមួយដែលត្រូវឆ្លងកាត់អាជ្ញាធរជាតិអប្សរា៕






ពលរដ្ឋនៅភូមិព្រះដាក់យកភាជន៍បុរាណប្រគល់ឱ្យសារមន្ទីរព្រះនរោត្តម សីហនុ-អង្គរ

ផ្សាយនៅថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ២០១៨

ប្រជាពលរដ្ឋរស់នៅភូមិថ្នល់ទទឹង ឃុំព្រះដាក់ ស្រុកបន្ទាយស្រី បានយកភាជន៍បុរាណ ដែលប្រទះឃើញក្នុងច្បារដំលូងខ្លួនក្បែរភូមិមកប្រគល់ជូនសារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ ដើម្បីថែរក្សាទុក។ ភាជន៍នេះ មានស្រទាប់រលោងពណ៌ត្នោត ត្រូវបានដឹងថាផលិតឡើងក្នុងស.វទី១១ដល់ទី១៣នៃគ.ស។ សភាពភាជន៍នេះពេលជីកបាន គឺបែកមាត់លើស្រាប់ និងបែកខ្លួនបន្តិចដោយសារការជីកដីប៉ះដោយអចេតនា។

ការប្រគល់ភាជន៍នេះមិនមែនជាលើកដំបូងឡើយ គឺកន្លងមកធ្លាប់មានប្រជាពលរដ្ឋច្រើននាក់ហើយ ដែលស្គាល់ពីតម្លៃបេតិកភណ្ឌនិងប្រគល់វត្ថុបុរាណមួយចំនួនដល់សារមន្ទីររបស់អាជ្ញាធរជាតិអប្សរា ក្នុងន័យរួមគ្នាថែរក្សាវត្ថុសិល្បៈខ្មែរ។

យុវជន ប៊ឹម ជាតិ ដែលមានទីលំនៅភូមិថ្នល់ទទឹង នៅរសៀលថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៨ បានយកក្រឡភាជន៍បុរាណដែលខ្លួនប្រទះឃើញកាលពីដើមខែមករា មកប្រគល់ជូនសារមន្ទីរព្រះនរោត្តម សីហនុ-អង្គរ។ តាមការរៀបចំរបស់ ជាតិ ខ្លួនបានប្រទះឃើញភាជន៍នេះនៅដីចម្ការដំលូង ពេលទៅកាប់ដីបានជម្រៅដីប្រហែលមួយតឹក ដែលនៅឆ្ងាយពីភូមិប្រមាណមួយគីឡូម៉ែត្រ។

យុវជនខាងលើបន្ថែមថា ភ្លាមៗក្រោយប្រទះឃើញនៅថ្ងៃទី៣ ខែមករា ខ្លួនបានយកភាជន៍ទៅរក្សាទុកនៅផ្ទះ តែក្រោយមកដោយសារមានគំនិតថែរក្សានិងការបារម្ភពីសុវត្ថិភាពផង ខ្លួនក៏សម្រេចយកភាជន៍ដែលឃើញនេះមកប្រគល់ឱ្យសារមន្ទីរ តាមការណែនាំពីមគ្គុទ្ទេសក៍ភាសាបារាំងម្នាក់ ព្រោះគិតថាក្នុងសារមន្ទីរមានសុវត្ថិភាពខ្ពស់។ ជាងនេះទៅទៀតនោះ ក្នុងសារមន្ទីរជាទីដែលសាធារណជនគ្រប់ជាតិសាសន៍ចូលមកទស្សនា ហើយវាស្របតាមគំនិតរបស់យុវជន ជាតិ ដែលចង់បង្ហាញវត្ថុបុរាណដែលរកឃើញឱ្យក្មេងៗជំនាន់ក្រោយបានស្គាល់។

អគ្គនាយិកាសារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ **កញ្ញា ឆោម គន្ធា** បានឱ្យដឹងថា នេះជាលើកទី៥ហើយ ដែលប្រជាពលរដ្ឋរស់នៅក្នុងរមណីយដ្ឋានអង្គរ បានយកវត្ថុបុរាណដែលប្រទះឃើញ យកមកប្រគល់ជូនសារមន្ទីរដើម្បីធ្វើការអភិរក្ស ក៏ដូចជាតាំងបង្ហាញក្នុងសារមន្ទីរ។ កញ្ញាក៏បានកោតសរសើរដល់ស្មារតីប្រជាពលរដ្ឋ ដែលបានយល់ពីតម្លៃនៃសម្បត្តិបេតិកភណ្ឌជាតិ បំណងថែរក្សាវត្ថុទាំងនោះ ជាប្រយោជន៍សម្រាប់កូនចៅតទៅជំនាន់ក្រោយៗ ឱ្យបានសិក្សានិងស្វែងយល់៕









ព្រឹត្តិការណ៍ព័ត៌មាន
ប្រចាំខែមីនា

ផ្នែកទី ៣
ប្រចាំខែមីនា

សេចក្តីជូនដំណឹងស្តីពីការសាងសង់កម្រាលក្តារនៅតាមផ្លូវទស្សនា និងជុំវិញដើមឈើ សម្រាប់ភ្ញៀវជាតិ-អន្តរជាតិ ដើរទស្សនា ដើម្បីបញ្ឈប់ការដើរលើជីជាស់ឫស និងកល់ដើមឈើតទៅទៀតនៅក្នុងបរិវេណប្រាសាទតាព្រហ្ម

ផ្សាយនៅថ្ងៃទី ០២ ខែ មីនា ឆ្នាំ២០១៨



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA

លេខ:២៨៨.អប.សវណ
១៨

សេចក្តីជូនដំណឹង
ស្តីពី
ការសាងសង់កម្រាលក្តារនៅតាមផ្លូវទស្សនា និងជុំវិញដើមឈើ សម្រាប់ភ្ញៀវជាតិ-អន្តរជាតិ ដើរទស្សនា ដើម្បីបញ្ឈប់ការដើរលើជីជាស់ឫស និងកល់ដើមឈើតទៅទៀតនៅក្នុងបរិវេណប្រាសាទតាព្រហ្ម

អាជ្ញាធរជាតិអប្សរា សូមជូនដំណឹងដល់ស្ថាប័ន សមត្ថកិច្ចពាក់ព័ន្ធ ភ្ញៀវជាតិ-អន្តរជាតិ មគ្គុទ្ទេសក៍ទេសចរណ៍ ព្រមទាំងសាធារណៈជនទាំងអស់មេត្តាជ្រាបថា ដើម្បីបញ្ចៀសផលប៉ះពាល់ដោយសកម្មភាពរបស់មនុស្ស ដើរជាន់ឫស និងគល់ដើមឈើដែលធ្វើឲ្យស្ថានភាពលូតលាស់នៃដើមឈើទាំងអស់នោះមិនលូតលាស់ទៅតាមប្រក្រតី និងដើម្បីលើកកម្ពស់សោភ័ណភាពបរិវេណប្រាសាទនិងតាមទីតាំងក្នុងវង់ទស្សនាប្រាសាទតាព្រហ្ម នាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពប្បធម៌ និងបរិស្ថាន នៃអាជ្ញាធរអប្សរានឹងធ្វើការសាងសង់កម្រាលក្តារនៅតាមផ្លូវវង់ទស្សនា និងជុំវិញដើមឈើ សម្រាប់ភ្ញៀវជាតិ-អន្តរជាតិ ដើរទស្សនាតាមគល់ដើមឈើមួយចំនួននៅក្នុងបរិវេណប្រាសាទតាព្រហ្ម។

ការងារនេះ នឹងចាប់ផ្តើមអនុវត្តចាប់ពីថ្ងៃពុធ ១៨កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស២៥៦១ ត្រូវនឹងថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៨ រហូតដល់បញ្ចប់ការងារ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមស្ថាប័ន សមត្ថកិច្ចពាក់ព័ន្ធ ភ្ញៀវជាតិ-អន្តរជាតិ មគ្គុទ្ទេសក៍ទេសចរណ៍ ព្រមទាំងសាធារណៈជនទាំងអស់ មេត្តាជ្រាបជាពត៌មាន។

ថ្ងៃព្រហស្បតិ៍ ៧កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស២៥៦១
សៀមរាប, ថ្ងៃទី ០១ ខែ មីនា ឆ្នាំ២០១៨
អគ្គនាយក

APSARA

ជុំ ម៉ាប់

ចម្លងជូន៖
-សាលាខេត្តសៀមរាប
-មន្ទីរបរិស្ថានខេត្តសៀមរាប
-មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តសៀមរាប
-អង្គភាពនគរបាលការពារបរិក្ខភណ្ឌប្រចាំខេត្តសៀមរាប
-ស្នាក់ការគ្រប់គ្រងការពារទេសភាពអង្គរ
-សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ទាំងអស់ប្រចាំខេត្តសៀមរាប
។ដើម្បីជូនជ្រាប និងសហការ៖
-គ្រប់នាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធរបស់អាជ្ញាធរអប្សរា
។ដើម្បីជូនជ្រាប និងមូលការ៖
-ឯកសារ-កាលប្បវត្តិ

ភ្ជាប់ទៅ:
អាជ្ញាធរជាតិអប្សរា
Email: info@apsaraauthority.gov.kh
Website: http://www.apsaraauthority.gov.kh
ចម្លាយ:
ភូមិបណ្តូក ឃុំស្វាយដង្គំ ស្រុកប្រាសាទបាគង ខេត្តសៀមរាប

កីឡាការពារជីវិត២០០នាក់ចូលរួមព្រឹត្តិការណ៍កីឡា RAID Amazones ជាលើកដំ២នៅជីកដីអង្គរ

ផ្សាយនៅថ្ងៃទី ០៧ ខែ មីនា ឆ្នាំ២០១៨

ព្រឹត្តិការណ៍កីឡាRAID Amazones ដែលប្រមូលផ្តុំដោយអ្នកចូលរួមសុទ្ធតែជាស្ត្រីបានចាប់ផ្តើមហើយនៅព្រឹកព្រលឹមថ្ងៃទី៧ ខែមីនា ឆ្នាំ២០១៨ នៅលើទឹកដីអង្គរខេត្តសៀមរាប។ ព្រឹត្តិការណ៍នេះមានអ្នកចូលរួមប្រមាណ១៧៤នាក់ ចម្រុះជាតិសាសន៍មកពីជុំវិញពិភពលោក។

ក្នុងពិធីបើកព្រឹត្តិការណ៍ជាផ្លូវការព្រឹកមិញនេះ មានការអញ្ជើញចូលរួមពីសំណាក់ **លោកជំទាវ** Eva Nguyen Bin ឯកអគ្គរដ្ឋទូតបារាំងប្រចាំកម្ពុជា **ឯកឧត្តម ថាន់ តិរុណ** អភិបាលរងខេត្តសៀមរាប **ឯកឧត្តម សុខ សង្ហារ** អគ្គនាយករង និងជាតំណាង **ឯកឧត្តមបណ្ឌិត ស៊ុ ម៉ាប់** អគ្គនាយកអាជ្ញាធរជាតិអប្សរា។

មានប្រសាសន៍ក្នុងពិធីបើកព្រឹត្តិការណ៍នេះ **ឯកឧត្តម ថាន់ តិរុណ** បានសម្តែងការស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមានរបស់គណៈអធិបតី និងក្រុមកីឡាិនីទាំងអស់ ដែលបានចូលរួមក្នុងព្រឹត្តិការណ៍ដ៏ធំនេះនៅលើទឹកដីខេត្តសៀមរាបនៃប្រទេសកម្ពុជា។ ឯកឧត្តមក៏បានជូនពរកីឡាិនីបានទទួលបទពិសោធន៍ល្អៗពីការមកកាន់កម្ពុជានៅពេលនេះ៕

ឯកឧត្តម សុខ សង្ហារ បានថ្លែងអំណរគុណគណៈអធិបតី សមត្ថកិច្ចពាក់ព័ន្ធ និងដៃគូសហការទាំងអស់ដែលបានផ្តួចផ្តើមឲ្យមានព្រឹត្តិការណ៍នេះឡើង។ ជាមួយគ្នានេះ ឯកឧត្តមក៏បានរំឭកផងដែរអំពីសុខសន្តិភាពដ៏ពេញលេញនៅកម្ពុជាបច្ចុប្បន្ន ដែលកត្តានេះធ្វើឲ្យកម្ពុជាអាចទទួលរៀបចំនូវព្រឹត្តិការណ៍លំដាប់អន្តរជាតិផ្សេងៗ ដូចជាព្រឹត្តិការណ៍ RAID Amazones នៅពេលនេះជាដើម។ ឯកឧត្តមសង្ឃឹមថា តាមរយៈការផ្សព្វផ្សាយលើឆាកអន្តរជាតិនូវព្រឹត្តិការណ៍ដ៏ធំនេះ ប្រជាពលរដ្ឋរាប់លាននាក់ជុំវិញពិភពលោក នឹងស្គាល់កម្ពុជាកាន់តែច្បាស់ ជាពិសេស គឺអង្គរដែលជាសម្បត្តិបេតិកភណ្ឌពិភពលោកដ៏អស្ចារ្យរបស់កម្ពុជា។

ជាមួយគ្នានេះដែរ **លោកជំទាវ** Eva Nguyen Bin ឯកអគ្គរដ្ឋទូតបារាំងប្រចាំកម្ពុជាក៏បានថ្លែងកីឡាិនីទាំងអស់ ដែលបានធ្វើដំណើរយ៉ាងវែងឆ្ងាយមកចូលរួមព្រឹត្តិការណ៍ដ៏សំខាន់នេះនៅទឹកដីអង្គររបស់កម្ពុជា។ លោកជំទាវក៏បានជូនពរកីឡាិនីទាំងអស់ភ្ជាប់នឹងថ្ងៃ៨មីនាដែលជាទិវាសិទ្ធិនារីដ៏សំខាន់លើពិភពលោកផងដែរ៕

ព្រឹត្តិការណ៍កីឡា RAID Amazones លើកទី៣នេះប្រព្រឹត្តទៅរយៈ៥ថ្ងៃ ដោយថ្ងៃដំបូងនេះ គឺរត់ប្រណាំងក្នុងតំបន់អង្គរក្នុងចម្ងាយ១៧,៥គម ចេញពីកន្លែងលក់សំបុត្រទៅដល់ខ្លោងទ្វារចូលខាងលិចនៃប្រាសាទបាយ័ន។ ក្រៅពីនេះ RAID Amazones នឹងមានសកម្មភាពកីឡាផ្សេងទៀតដូចជា ការជិះកង់ និងការជិះទូកជាដើម ព្រមទាំងការទស្សនាស្វែងយល់ពីវប្បធម៌ទំនៀមទម្លាប់របស់ប្រជាពលរដ្ឋខ្មែរ។

គួរឭកថា RAID Amazones ជាព្រឹត្តិការណ៍កីឡាអន្តរជាតិមួយដ៏មានប្រជាប្រិយភាពបំផុតនៅលើពិភពលោក មានសុទ្ធតែនារីជាអ្នកចូលរួម។ កីឡានេះ បង្កើតឡើងដោយអតីតពិធីករទូរទស្សន៍ជនជាតិបារាំងឈ្មោះ ALEXANDER DEBANNE មានរយៈពេល១៥ឆ្នាំមកហើយនិងបានធ្វើនៅតាមបណ្តាប្រទេសជាច្រើន។

នេះជាលើកទី២សម្រាប់កម្ពុជាជាម្ចាស់ផ្ទះ ដែលរៀបចំឡើងនៅលើទឹកដីអង្គរ។ លើកទី១ គឺកាលពីខែធ្នូឆ្នាំ២០១៤ និងលើកទី២ចែកជា២ដំណាក់កាលដោយកត្តាអ្នកចូលរួមច្រើនលើសលុបគឺកាលពីខែធ្នូ ឆ្នាំ២០១៧មួយដំណាក់កាល និងខែមីនានេះមួយដំណាក់កាល។ ព្រឹត្តិការណ៍នេះ សហការរៀបចំដោយអាជ្ញាធរជាតិអប្សរា គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា ក្រសួងទេសចរណ៍ ក្រសួងកិច្ចការនារី និងក្រុមហ៊ុនបារាំងឈ្មោះ ZBO រួមទាំងបណ្តាញផ្សព្វផ្សាយព័ត៌មានបារាំង។

ការរៀបចំព្រឹត្តិការណ៍ RAID Amazones នៅលើទឹកដីអង្គរ គឺជាឧទាហរណ៍ជាក់ស្តែងមួយ ដែលបង្ហាញអំពីសមត្ថកិច្ចរបស់អាជ្ញាធរជាតិអប្សរាលើការគ្រប់គ្រងរមណីយដ្ឋានអង្គរ ដែលមិនត្រឹមគិតគូរលើការងារអភិរក្សប៉ុណ្ណោះទេ តែក៏ផ្តោតសំខាន់លើការអភិវឌ្ឍប្រកបដោយចីរភាព តាមរយៈការរៀបចំកម្មវិធីអន្តរជាតិល្បីៗ ដើម្បីទាក់ទាញទេសចរមកកាន់កម្ពុជាកាន់តែច្រើន ឡើងៗជារៀងរាល់ឆ្នាំ៕









អាជ្ញាធរជាតិអប្សរាកំពុងដំណើរការកម្រោងរៀបចំក្រាលក្តារលើឫសឈើនៅប្រាសាទតាព្រហ្ម

ផ្សាយនៅថ្ងៃទី ១២ ខែ មីនា ឆ្នាំ២០១៨

អាជ្ញាធរជាតិអប្សរា នៅថ្ងៃទី៦ ខែមីនា បានដំណើរការគម្រោងរៀបចំក្រាលក្តារឈើ តាមឫសឈើធំៗ និងនៅតាមវង់ទស្សនារបស់ភ្ញៀវទេសចរ នៅប្រាសាទតាព្រហ្ម។ តាមការប៉ាន់ស្មានគម្រោងនេះអាចនឹងបញ្ចប់នៅមុនរដូវវស្សាមកដល់។ ក្រុមការងារនៃនាយកដ្ឋានគ្រប់គ្រងព្រៃឈើ បរិស្ថាន និងទេសភាពវប្បធម៌ នៃអាជ្ញាធរជាតិអប្សរា កំពុងញាប់ដៃញាប់ជើងរៀបចំក្រាលក្តារនៅជុំវិញឫសឈើនៅប្រាសាទតាព្រហ្ម។ គេដឹងហើយថា ដើមឈើធំៗ និងឫសធំៗ ដែលមានវ័យចំណាស់នៅប្រាសាទតាព្រហ្ម គឺជាផ្នែកមួយដ៏ទាក់ទាញសម្រាប់ភ្ញៀវទេសចរជាតិ និងអន្តរជាតិ។ ពួកគេតែងផ្តិតយកទិដ្ឋភាពទាំងនោះ នៅពេលបានមកដល់ប្រាសាទម្តងៗ។

ជាមួយនឹងកំណើនទេសចរជាច្រើនមកដល់ប្រាសាទតាព្រហ្ម វាក៏បានបង្កហានិភ័យផងដែរ។ ហានិភ័យត្រង់ភ្ញៀវទេសចរបានដើរជាន់ឫសឈើនៅក្រោមដីដោយមិនដឹងខ្លួន ដែលវានឹងបង្អាក់ដំណើរលូតលាស់របស់ ដើមឈើទាំងនោះ។ **លោក យិន សូវ៉ាត** អនុប្រធាននាយកដ្ឋានគ្រប់គ្រងព្រៃឈើ បរិស្ថាន និងទេសភាពវប្បធម៌ ដែលកំពុងដឹកនាំក្រុមការងាររៀបចំកម្រាលក្តារនៅប្រាសាទតាព្រហ្ម បានថ្លែងថា គោលបំណងនៃការរៀបចំនេះ គឺដើម្បីបង្កើនការលូតលាស់របស់ដើមឈើ និងថែរក្សាបរិស្ថានជុំវិញឱ្យបានល្អប្រសើរឡើងវិញ។ តាមការបញ្ជាក់របស់មន្ត្រីព្រៃឈើ ទីតាំងឫសឈើចំនួន៦កន្លែង ដែលគ្រោងក្រាលក្តារនិងនៅតាមវង់ទស្សនាប្រវែងជាង៤០០ម៉ែត្របន្ថែមទៀត។

តាមការបញ្ជាក់របស់ **លោក យិន សូវ៉ាត** ឈើដែលយកមកប្រើប្រាស់នេះជាប្រភេទឈើគគីរ ដែលតាមការប៉ាន់ស្មានសរុបប្រហែលជាង ៧០ម៉ែត្រគីប ដែលវាអាចរក្សាគុណភាពបានពី៦ ទៅ៧ឆ្នាំ។ ក្រុមការងារកំពុងមមាញឹករៀបចំគម្រោងនេះ ដោយរំពឹងថាវានឹងរួចរាល់នៅមុនរដូវវស្សាឬមុនកិច្ចប្រជុំអាយស៊ីស៊ី-អង្គរនៅក្នុងខែមិថុនាខាងមុខ៕









សហគមន៍អ្នកប្រើប្រាស់ទឹកចាយណ៍ទឹកថ្នាំជ្រើសរើសប្រធានថ្មី ក្រោមការសម្របសម្រួលអាជ្ញាធរជាតិអប្សរា

ផ្សាយនៅថ្ងៃទី ១២ ខែ មីនា ឆ្នាំ២០១៨

នៅព្រឹកថ្ងៃទី៩ ខែមីនា ឆ្នាំ២០១៨ អាជ្ញាធរជាតិអប្សរា បានសម្របសម្រួលរៀបចំបោះឆ្នោតប្រធានសហគមន៍អ្នកប្រើប្រាស់ទឹកបាយណ៍ទឹកថ្លាអណត្តិទី២ បន្ទាប់ពីអណត្តិចាស់ដែលបានជ្រើសរើសកាលពីឆ្នាំ២០១៤ ត្រូវបានបញ្ចប់។ ការបោះឆ្នោតនេះក្នុងអណត្តិថ្មីនេះ **លោក សុខ ម៉ក់** ត្រូវជាប់ជាអ្នកដឹកនាំនៅអណត្តិទី២នេះ។

ក្រោយរាជរដ្ឋាភិបាលប្រគល់សិទ្ធិឱ្យ អាជ្ញាធរជាតិអប្សរាគ្រប់គ្រង ទឹកបារាយណ៍ទឹកថ្លានៅឆ្នាំ២០១៤មកអាជ្ញាធរជាតិអប្សរា បានសម្របសម្រួលរៀបចំឱ្យមានសហគមន៍ប្រើប្រាស់ទឹកឲ្យបានត្រឹមត្រូវ សម្រាប់ទាញយកទឹកបារាយណ៍ទឹកថ្លាយកទៅប្រើប្រាស់ជាប្រយោជន៍ដល់ការងារកសិកម្ម។ នៅឆ្នាំ២០១៤ តាមរយៈការបោះឆ្នោតជ្រើសរើសប្រធានសហគមន៍នេះ **លោក ហួត ហាយ** បានជាប់ជាប្រធាន និងបានដឹកនាំសហគមន៍អ្នកប្រើប្រាស់ ទឹកបារាយណ៍ទឹកថ្លារយៈពេល៣ឆ្នាំ។

លោក សុខ ម៉ក់ ដែលទើបជាប់ជាប្រធាន និងមានទីលំនៅក្នុងសង្កាត់ទឹកវិល បានឱ្យដឹងនឹងខិតខំប្រឹងប្រែងធ្វើយ៉ាងណាឱ្យស័ក្តិសមចំពោះការបោះឆ្នោតគាំទ្រពីប្រជាពលរដ្ឋ។ លោកបន្ថែមថា នឹងស្វែងរកគ្រប់មធ្យោបាយ រិះរកដើម្បីឱ្យពលរដ្ឋមានទឹកប្រើប្រាស់គ្រប់គ្រាន់។

លោក ជូវ៉ា ឌីណា អនុប្រធាននាយកដ្ឋានគ្រប់គ្រងទឹក នៃអាជ្ញាធរជាតិអប្សរា ដែលបានដឹកនាំក្រុមការងាររៀបចំកម្មវិធីបោះឆ្នោតនៅសហគមន៍អ្នកប្រើប្រាស់ទឹកបារាយណ៍ទឹកថ្លា បានឱ្យដឹងថា ជាគោលការណ៍របស់អាជ្ញាធរជាតិអប្សរា គឺរៀបចំឱ្យមានអាណត្តិបោះឆ្នោត៣ឆ្នាំម្តង។ លោកបញ្ជាក់ថា កាលពីអាណត្តិមុន ក្រោមការដឹកនាំរបស់ **លោក ហួត ហាយ** គឺធ្វើឱ្យប្រជាពលរដ្ឋសប្បាយរីករាយពេលដែលពួកគេមានទឹកប្រើប្រាស់បានគ្រប់គ្រាន់។

តាមការលើកឡើងរបស់មន្ត្រីជំនាញទឹក ដើម្បីឱ្យការប្រើប្រាស់ទឹកនៅបារាយណ៍ទឹកថ្លាមាននិរន្តរភាព គឺអាជ្ញាធរជាតិអប្សរា ចង់ឱ្យពលរដ្ឋទាំងអស់ ផ្លាស់ប្តូរពីការធ្វើស្រែមកដាំដំណាំវិញ។ **លោក ជូវ៉ា ឌីណា** ពន្យល់ថា ការដាំដំណាំប្រើប្រាស់ទឹកអស់តិច ហើយគេអាចបង្វែរទាំងក្នុងបារាយណ៍ទៅធ្វើទឹកស្អាតវិញ ព្រោះតម្រូវការក្នុងទីក្រុងសៀមរាបបច្ចុប្បន្នមានការកើនឡើងខ្ពស់។ លោកបន្ថែមទៀតថា ការដាំដំណាំ ក្រៅពីប្រើទឹកអស់តិចហើយនោះ ក៏អាចលក់បានថ្លៃជាងទៀត ដូច្នេះលើកទឹកចិត្តឱ្យពលរដ្ឋគួរងៀកទៅដាំដំណាំនិងបន្លែជំនួសវិញ។

សូមបញ្ជាក់ថា កាលពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៤ រាជរដ្ឋាភិបាលបានប្រគល់ការងារគ្រប់គ្រងទឹក និងទ្វារទឹកនៅបារាយណ៍ទឹកថ្លា (បារាយណ៍ខាងលិច) ជូនអាជ្ញាធរជាតិអប្សរា ដោយត្រូវទទួលខុសត្រូវទាំងស្រុងលើតម្រូវការទឹកសម្រាប់ស្រូវចំនួន១២០០០ហិកតា (ស្រូវរដូវ៨០០០ហិកតា ស្រូវប្រាំង៤០០០ហិកតា) និងដំណាំរួមផ្សំផ្សេងទៀតចំនួន១០០០ហិកតា និងធានាដោះស្រាយរាល់បញ្ហាគ្រោះទឹកជំនន់ និងភាពរាំងស្ងួត ដែលអាចកើតមានឡើងជាយថាហេតុ។ បន្ទាប់ពីបានទទួលគោលការណ៍នេះហើយ អាជ្ញាធរជាតិអប្សរាបានជួសជុល ស្តារឡើងវិញជាបន្ទាន់នូវទ្វារទឹក និងប្រព័ន្ធប្រឡាយនៃបារាយណ៍ខាងលិច ដែលការងារនេះ ធ្វើឲ្យប្រជាពលរដ្ឋមានទឹកគ្រប់គ្រាន់សម្រាប់ការបង្កបង្កើនផលបានគ្រប់រដូវ៕









បុរាណវិទូ៦ប្រទេសចានទទួលការបណ្តុះបណ្តាលស្តីអំពីឬនិទកុលាលកាជន៍នៅអាជ្ញាធរជាតិអប្សរា

ផ្សាយនៅថ្ងៃទី ១២ ខែ មីនា ឆ្នាំ២០១៨

អាជ្ញាធរជាតិអប្សរាបានក្លាយជាម្ចាស់ផ្ទះ ក្នុងការបើកវគ្គបណ្តុះបណ្តាលស្តីអំពីរចនាសម្ព័ន្ធថ្ម និងបច្ចេកទេសធ្វើកុលាលភាជន៍ ដល់អ្នកស្រាវជ្រាវបុរាណវិទ្យា៦ប្រទេសនៅអាស៊ីអាគ្នេយ៍ រយៈពេល៥ថ្ងៃ ចាប់ពីថ្ងៃទី៥ ដល់ថ្ងៃទី៩ ខែមីនា ឆ្នាំ២០១៨។ វគ្គសិក្សានេះមានសិក្ខាកាមចំនួន១៧នាក់ គឺខ្មែរ៩នាក់ មកពីអាជ្ញាធរជាតិអប្សរា សម្ស្យរព្រៃគុក ព្រះវិហារ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងនិស្សិតបុរាណវិទ្យានៃសាកលវិទ្យាភូមិន្ទវិចិត្រសិល្បៈ និងបរទេស៨នាក់ មកពីសិង្ហបុរី តៃវ៉ាន់ ថៃ ភូមា និងវៀតណាម។

លោកបណ្ឌិត អ៊ា ជារិទ្ធ អនុប្រធានមជ្ឈមណ្ឌលអន្តរជាតិស្រាវជ្រាវ និងតម្កល់ឯកសារអង្គរនៃអាជ្ញាធរជាតិអប្សរា និងជាអ្នកសម្របសម្រួលកម្មវិធីបានឱ្យដឹងថា សិក្ខាសាលានេះជាកិច្ចសហប្រតិបត្តិការរវាងអាជ្ញាធរជាតិអប្សរានិងវិទ្យាស្ថាន Smithsonian សហរដ្ឋអាមេរិក។ សិក្ខាសាលានេះបង្រៀនដោយ **គ្រូជំនាញ Petrography** មកពីសាកល វិទ្យាល័យ ArizonaនិងDelaware។

លោក ជារិទ្ធ បញ្ជាក់ថា វាមានសារៈសំខាន់ខ្លាំងណាស់សម្រាប់បុរាណវិទូ ព្រោះធ្វើឱ្យយើងដឹងពីបច្ចេកទេសធ្វើកុលាលភាជន៍សម័យបុរាណ ដឹងពីធាតុផ្សំដែលយកមកធ្វើកុលាលភាជន៍ ធាតុផ្សំនៃថ្មនៅក្នុងតំបន់អង្គរ រួមទាំងថ្មផ្សេងៗនៅក្នុងពិភពលោកតាមរយៈការពិនិត្យដោយម៉ាស៊ីនមីក្រូទស្សន៍ដ៏ទំនើប។ លោកក៏បានថ្លែងអំណរគុណដល់វិទ្យាស្ថាន Smithsonian ដែលបានសហការជាមួយអាជ្ញាធរជាតិអប្សរាក្នុងការបណ្តុះបណ្តាលធនធានមនុស្សដល់ទៅ៣លើក គឺលើកទី១ នៅឆ្នាំ២០១៣៖ បានបណ្តុះបណ្តាលអំពីការស្រាវជ្រាវឡបុរាណសម័យអង្គរ។ ទី២នៅឆ្នាំ២០១៤៖ កម្មវិធីថែរក្សានិងទុកដាក់វត្ថុបុរាណឱ្យបានត្រឹមត្រូវតាមស្តង់ដារអន្តរជាតិ។ ទី៣នៅឆ្នាំ២០១៨នេះ៖ សិក្សាអំពីរចនាសម្ព័ន្ធថ្មនិងបច្ចេកទេសធ្វើកុលាលភាជន៍ខ្មែរនិងពិភពលោក។

លើសពីនោះ អង្គការ Friends of Khmer Culture (FOKCI) តាមរយៈស្ថាប័ន Smithsonian បានប្រគល់ជូនម៉ាស៊ីនមីក្រូ ទស្សន៍មួយគ្រឿង ឯកសារ សៀវភៅ និងសម្ភារៈមន្ទីរពិសោធន៍ដល់អាជ្ញាធរជាតិអប្សរាសម្រាប់ប្រើប្រាស់ក្នុងការស្រាវជ្រាវទៅថ្ងៃក្រោយ។

អ្នកស្រីសាស្ត្រាចារ្យ Louise Cort អ្នកអភិរក្សកុលាលភាជន៍នៅសារមន្ទីរ Freer Gallery of Art និង Arthur M.Sackler នៃសាកលវិទ្យាស្ថាន Smithsonian ក្នុងរដ្ឋ Washington DC បានបញ្ជាក់ពីគោលបំណងនៃវគ្គសិក្សា គឺដើម្បីកសាងសមត្ថភាពរបស់អង្គភាពកុលាលភាជន៍អង្គរ និងបណ្តុះ បណ្តាលអ្នកស្រាវជ្រាវនៅតំបន់អាស៊ីអាគ្នេយ៍។ សិក្ខាកាមត្រូវបានចែកចេញជាពីរក្រុម ហើយប្តូរ វេនគ្នាសិក្សា។ ក្រុមទី១ បង្រៀនដោយសាស្ត្រាចារ្យ Pamela Vandiver សិក្សាអំពីទំហំកម្ទេចដី ការដុតកំដៅកុលាលភាជន៍សីតុណ្ហភាពទាប ភាពរឹងនៃភាជន៍ (Mohs hardness collection) ការហាលដីឥដ្ឋ ដើម្បីមើលពីការបាត់បង់ជាតិទឹកក្នុងដីឥដ្ឋ រចនាសម្ព័ន្ធដី ធាតុផ្សំដីឥដ្ឋ ការដុតកំដៅ ការកកើតកញ្ចក់ និងស្រទាប់រលោង។ ក្រុមទី២ បង្រៀនដោយសាស្ត្រាចារ្យ Chandra Reedy អំពីរបៀប មើលធាតុផ្សំរ៉ែផ្សេងៗក្នុងថ្ម និងភាជន៍តាមរយៈមីក្រូទស្សន៍ និងរបៀបវិភាគធាតុផ្សំក្នុងភាជន៍ផុយ និងភាជន៍រឹង។ លើសពីនោះ គាត់បានបង្ហាញអំពីធាតុផ្សំក្នុងថ្មដែលធ្វើប្រាសាទបន្ទាយស្រី តាកែវ ភ្នំក្រោម បាភួន អង្គរវត្ត និងបាយ័ន និងធាតុផ្សំធ្វើភាជន៍មកពីឡសម័យអង្គរ។ សរុបមក វគ្គសិក្សានេះ បង្រៀនសិក្ខាកាមឱ្យយល់ដឹងអំពីការប្រែប្រួលរបស់ដីឥដ្ឋពេលមើលតាមមីក្រូទស្សន៍ ហើយវាក៏ធ្វើឱ្យអ្នកបុរាណវិទូឬអ្នកវិទ្យាសាស្ត្រអាចមើលឆ្លុះដល់ផ្នែកខាងក្នុងនៃភាជន៍ ឱ្យដឹងថាវាមានផ្ទុកសារធាតុរ៉ែអ្វីខ្លះ ដើម្បីយើងអាចប្រៀបធៀបទៅនឹងភាជន៍ផ្សេងៗថាប្រើធាតុផ្សំដូចគ្នាឬខុសគ្នា។ បន្ទាប់មក យើងអាចដឹងថាតើភាជន៍ទាំងនោះផលិតនៅកន្លែងតែមួយឬផ្សេងគ្នា ហើយក៏ដឹងពីសីតុណ្ហភាពដែលគេប្រើដុតភាជន៍ទាំងនោះដែរ ដែលធ្វើឱ្យយើងយល់ដឹងកាន់តែច្រើនអំពីការផលិតកុលាលភាជន៍របស់ឡបុរាណខ្មែរសម័យមុន។

លោកស្រីសាស្ត្រាចារ្យ Louise Cort ក៍បានចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះអាជ្ញាធរជាតិអប្សរាដែលបានបង្កើតឱ្យមានអង្គភាពកុលាលភាជន៍អង្គរ ដែលបានគាំទ្រសកម្មភាពអ្នកស្រាវជ្រាវភាជន៍នៅតំបន់អង្គរ ជាពិសេសបានថែរក្សាភាជន៍ដែលបានរកឃើញពីការកំណាយគឺមិនមែនសម្រាប់តែបច្ចុប្បន្នតែសម្រាប់អនាគតផង។

បុគ្គលិកនៃមជ្ឈមណ្ឌលអន្តរជាតិស្រាវជ្រាវនិងតម្កល់ឯកសារអង្គរ ផ្នែកក្រុមអភិរក្សកុលាល ភាជន៍ខ្មែរ **អ្នកស្រី ស៊ឹង ស្រីទូច** បានឱ្យដឹងថា វគ្គសិក្សានេះគឺបង្រៀនយ៉ាងច្រើនអំពីការវិភាគនិងធាតុផ្សំនៃថ្មនិងកុលាលភាជន៍តាមមីក្រូទស្សន៍ ដោយការអនុវត្តផ្ទាល់ ការបង្រៀនតាមការបញ្ចាំងស្លាយ និងតាមឯកសារពាក់ព័ន្ធផ្សេងៗ។ វាជាការលំបាកបន្តិចសម្រាប់អ្នកស្រីព្រោះពាក្យបច្ចេកទេសថ្មីៗ និងប្រើភាសាអង់គ្លេស តែវាពិតជាល្អសម្រាប់ការងារសព្វថ្ងៃនេះក្នុងនាមជាអ្នក អភិរក្សកុលាលភាជន៍មួយរូប។ **លោក AARON Kao** មន្ត្រីស្រាវជ្រាវមកពីមជ្ឈមណ្ឌល Nalanda srivijaya ប្រទេសសិង្ហបុរី បានសម្តែងនូវការរីករាយដែលលោកត្រូវបានជ្រើសរើសឱ្យចូលរួមក្នុងវគ្គសិក្សាដ៏មានសារៈសំខាន់មួយនេះ ដោយបានរៀនពីទម្រង់របស់ថ្ម រៀនកំណត់សម្គាល់ធាតុផ្សំនៃការផលិតភាជន៍ និងបច្ចេកទេសនៃការផលិតរបស់វា។ នៅក្នុងការសិក្សា៥ថ្ងៃវាមានការលំបាកខ្លះ តែដោយសារលោកធ្លាប់រៀនពីមុនមក ទើបធ្វើឱ្យលោកយល់កាន់តែច្រើនក្នុងពេលសិក្សា ពិសេសបន្ថែមចំណេះដឹងក្នុងការស្រាវជ្រាវរបស់លោកកាន់តែស៊ីជម្រៅជាងមុន។

បន្ទាប់ពីបញ្ចប់វគ្គសិក្សា **ឯកឧត្តម ហង់ ពៅ** អគ្គនាយករងអាជ្ញាធរជាតិអប្សរាបានចូលរួមថ្លែង សុន្ទរកថាបិទវគ្គសិក្ខាសាលា ដោយបានថ្លែងអំណរគុណដល់សាស្ត្រាចារ្យនិងជំនួយការដែលបានខិតខំបង្ហាត់បង្រៀនដល់សិក្ខាកាម និងបានផ្តែផ្តាំ អោយសិក្ខាកាមយកចំណេះដឹងនេះទៅអនុវត្តក្នុងជំនាញរបស់ខ្លួនបន្ថែមទៀត។ **សាស្ត្រាចារ្យ Louise Cort** ក៍បានស្នើអោយសិក្ខាកាមទាំងអស់នៅបន្តទំនាក់ទំនងគ្នា និងចែករំលែកចំណេះដឹងគ្នាត ទៅមុខទៀតតាមរយៈប្រព័ន្ធអ៊ីនធើណិត ហើយសង្ឃឹមថានឹងមានវគ្គបណ្តុះបណ្តាលក្រោយៗទៀត។

ចុងបញ្ចប់ **ឯកឧត្តម ហង់ ពៅ អ្នកស្រី ម៉ម វណ្ណរតន៍** និង**សាស្ត្រាចារ្យ Louise Cort** បាន ប្រគល់វិញ្ញាបនបត្រដល់សិក្ខាកាមទាំង១៧រូបព្រមទាំងសាស្ត្រាចារ្យនិងជំនួយការចំនួន៦រូប៕









អាជ្ញាធរជាតិអប្សរាត្រៀមខ្លួនចូលរួមសហការក្នុងការរៀបចំព្រឹត្តិការណ៍សង្ក្រាន្តឆ្នាំ២០១៨

ផ្សាយនៅថ្ងៃទី១៤ ខែ មីនា ឆ្នាំ២០១៨

ដើម្បីអបអរសាទរពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ ឆ្នាំវកសំរឹទ្ធិស័ក ព.ស ២៥៦១ឈានចូល២៥៦២ខាងមុខនេះ ព្រឹត្តិការណ៍អង្គរសង្ក្រាន្តដែល នឹងត្រូវរៀបចំឡើងនៅរមណីយដ្ឋានអង្គរ នឹងមានទម្រង់កាន់តែធំជាងឆ្នាំមុនៗ។

មានប្រសាសន៍ក្នុងពិធីជួបពិភាក្សាការងាររវាងសហភាពសហព័ន្ធយុវជនកម្ពុជា និងថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរាស្តីពីដំណើរឆ្ពោះទៅកាន់ព្រឹត្តិការណ៍អង្គរសង្ក្រាន្តឆ្នាំ២០១៨ នារសៀលថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៨ **ឯកឧត្តម ហ៊ុន ម៉ានី** បានបញ្ជាក់ថា ព្រឹត្តិការណ៍អង្គរសង្ក្រាន្តឆ្នាំថ្មីនេះនឹងបង្កើនកម្មវិធីរហូតដល់៣២កម្មវិធី ដែលបង្ហាញអំពីប្រពៃណី ទំនៀមទម្លាប់និងវប្បធម៌របស់ខ្មែរដើសំបូរបែបជាមួយការជួយរួមពីយុវជនស្ម័គ្រចិត្តដល់ទៅជាង៤ពាន់នាក់។

យោងតាមបទបង្ហាញដោយ **ឯកឧត្តម សុខ សុប្បាយណា** ប្រធានផ្នែកប្រតិបត្តិនៃព្រឹត្តការណ៍អង្គរសង្ក្រាន្ត បញ្ជាក់ថា អង្គរសង្ក្រាន្តឆ្នាំនេះនឹងកែសម្រួល និងបន្ថែមនូវកម្មវិធីថ្មីៗមួយចំនួនទៀត ដើម្បីឲ្យមានទាក់ទាញកាន់តែខ្លាំង ដូចជា សហស្សវិចិត្រវាយនា ដែលជាការកម្មវិធីបង្ហាញក្រមាខ្មែរដ៏វិចិត្រប្រវែង១០០០ម៉ែត្រ កម្មវិធីព្រៃប្រសិទ្ធិដើម្បីបណ្តុះការស្រឡាញ់ព្រៃឈើនិងសត្វព្រៃនិងកម្មវិធីបាញ់ព្រួញជាដើម។ល។

ឯកឧត្តមបណ្ឌិត ស៊ុំ ម៉ាប់ អគ្គនាយកអាជ្ញាធរជាតិអប្សរា មានប្រសាសន៍ក្នុងកិច្ចប្រជុំពិភាក្សានេះថា អាជ្ញាធរជាតិអប្សរាបានត្រៀមខ្លួនរួចរាល់ ដើម្បីសហការរៀបចំព្រឹត្តិការណ៍ដ៏សំខាន់នេះហើយ។ ជាក់ស្តែង ក្រុមការងារនៃអាជ្ញាធរជាតិអប្សរា

បានដោះស្រាយជូននូវសំណូមពរ១០១ចំណុច ក្នុងចំណោយម១០៤សំណូមពរ ដែលក្រុមការងាររៀបចំព្រឹត្តិការណ៍បានស្នើមកអាជ្ញាធរជាតិអប្សរា។ ចំណុចដែលនៅសេសសល់តិចតួច ក្រុមការងារកំពុងបន្តដោះស្រាយជូនក្រុមការងាររៀបចំព្រឹត្តិការណ៍បន្ថែមទៀត។

គួរឲ្យកថា ព្រឹត្តិការណ៍អង្គរសង្ក្រាន្តត្រូវបានរៀបចំឡើងដោយសហការពសហព័ន្ធយុវជនកម្ពុជា ក្រោមកិច្ចសហការពីក្រសួង និងស្ថាប័នពាក់ព័ន្ធជាច្រើន។ ព្រឹត្តិការណ៍នេះបានទាក់ទាញនូវភ្ញៀវទេសចរជាតិ និងអន្តរជាតិមកកាន់តំបន់រមណីយដ្ឋានអង្គរកាន់តែច្រើនឡើងៗដាក់ស្តែងនៅឆ្នាំ២០១៧កន្លងទៅ ភ្ញៀវទេសចរមានចំនួនជាង១លាន៦សែន ដែលមានកំណើនដល់ទៅ៣២៥%ធៀបនឹងឆ្នាំ២០១៣ដែលជាឆ្នាំដំបូងនៃការរៀបចំព្រឹត្តិការណ៍៕






ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរាយកបទពិសោធន៍ក្រប់ក្រងរមណីយដ្ឋានអង្គរ ទៅបង្រៀនសិស្សិកនៅប្រទេសជប៉ុន

ផ្សាយនៅថ្ងៃទី ១៤ ខែ មីនា ឆ្នាំ២០១៨

ថ្នាក់ដឹកនាំនៃអាជ្ញាធរជាតិអប្សរា **ឯកឧត្តម ហង់ ពៅ** អគ្គនាយករង បាននាំយកបទពិសោធន៍ និងការរកឃើញថ្មីៗ នៃការងារគ្រប់គ្រងរមណីយដ្ឋានអង្គរ ទៅបង្រៀនដល់និស្សិតពីថ្នាក់នៃសាកលវិទ្យាល័យ Kanazawa នៃប្រទេសជប៉ុន។ ការបង្រៀននេះធ្វើឡើងតាមរយៈ កិច្ចសហប្រតិបត្តិការរវាងអាជ្ញាធរជាតិអប្សរា និងសាកលវិទ្យាល័យរដ្ឋរបស់ជប៉ុន Kanazawa ដែលបានធ្វើការសិក្សាស្រាវជ្រាវរួមគ្នាលើបញ្ហាទឹក បរិស្ថាន ជីវភាពរបស់ប្រជាពលរដ្ឋ និងវប្បធម៌របស់ប្រទេសកម្ពុជា និងជប៉ុន។ កិច្ចសហប្រតិបត្តិការនេះធ្វើឡើងតាំងពីឆ្នាំ២០០៥ និងបន្តរហូតដល់មកដល់បច្ចុប្បន្ន។

ក្រោយបញ្ចប់ការធ្វើបទបង្ហាញចុងក្រោយ នាពេលថ្មីកន្លងទៅនេះ **ឯកឧត្តម ហង់ ពៅ** បានលើកឡើងថា តាមរយៈកិច្ចសហប្រតិបត្តិការនេះ ចាប់ពីឆ្នាំ២០០៧មក នៅកំឡុងខែមករា និងខែកុម្ភៈ ថ្នាក់ដឹកនាំនៃសាកលវិទ្យាល័យ Kanazawa តែងអញ្ជើញរូបគាត់មកបង្រៀន ឬធ្វើបទបង្ហាញដល់និស្សិតជារៀងរាល់ឆ្នាំ។ ចាប់ពីឆ្នាំ២០១៤មក ដោយសាកលវិទ្យាល័យ Kanazawa យល់ឃើញថា ការបង្រៀន និងការធ្វើបទបង្ហាញនេះមានសារៈសំខាន់ ទើបបានតែងតាំងឯកឧត្តមជាសាស្ត្រាចារ្យ Visiting Professor ដើម្បីធ្វើបទបង្ហាញអំពីបទពិសោធន៍នៃការងារគ្រប់គ្រងរមណីយដ្ឋានអង្គរ ដោយផ្តោតសំខាន់លើការគ្រប់គ្រងទឹកបរិស្ថាននិងជីវភាពរបស់ប្រជាពលរដ្ឋជាដើម។

យោងតាមបទពិសោធន៍នៃការបង្រៀន និងបទបង្ហាញដ៏មានសារៈសំខាន់នេះ សាកលវិទ្យាល័យក៏បានបញ្ជូននិស្សិតឲ្យមកធ្វើកម្មសិក្សា ស្វែងយល់អំពីវប្បធម៌ខ្មែរ និងសិក្សាអំពីការគ្រប់គ្រងរមណីយដ្ឋានអង្គរនៅអាជ្ញាធរជាតិអប្សរាយៈពេល២សប្តាហ៍សម្រាប់និស្សិតពី៨ទៅ១០នាក់ជារៀងរាល់ឆ្នាំ។

ក្រៅពីធ្វើបទបង្ហាញនៅសាកលវិទ្យាល័យ **ឯកឧត្តម ហង់ ពៅ** ក៏បានឆ្លៀតពេលដ៏មានតម្លៃទៅបំពេញទស្សនកិច្ចសិក្សានៅទីក្រុងKomatsu និងសាកលវិទ្យាល័យKomatsu និងបានជួបពិភាក្សាជាមួយថ្នាក់ដឹកនាំក្រុង និងសាកលវិទ្យាល័យដើម្បីរឹតចំណងសហប្រតិបត្តិការបន្ថែមទៀតរវាងខេត្ត Komatsu និងរមណីយដ្ឋានអង្គរ ក៏ដូចជាខេត្តសៀមរាបទាំងមូល។

នេះជាមោទនភាពមួយ ដែលថ្នាក់ដឹកនាំនៃអាជ្ញាធរជាតិអប្សរាមានសមត្ថភាព ហើយត្រូវបានទទួលស្គាល់ដោយសាកលវិទ្យាល័យរដ្ឋរបស់ប្រទេសជប៉ុនលើឆាកអន្តរជាតិ ពីការងារស្រាវជ្រាវ និងការគ្រប់គ្រងរមណីយដ្ឋានអង្គរ ក៏ដូចជាការចែករំលែកចំណេះដឹងល្អៗនេះដល់និស្សិតបរទេស នៃប្រទេសដ៏ជឿនលឿនទៀតផង៕

រូបភាពពី៖ឯកឧត្តមហង់ពៅ






អាជ្ញាធរជាតិអប្សរាធ្វើបច់ពិធីគោរពវិញ្ញាណក្ខន្ធសម្តេចវិបុលបញ្ញា សុខ អាន នៅស្ពាក់ការកណ្តាល ដើម្បីរំឭកខួបឆ្នាំនៃមរណភាព

ផ្សាយនៅថ្ងៃទី ១៥ ខែ មីនា ឆ្នាំ២០១៨

ក្នុងឱកាសខួបមួយឆ្នាំនៃមរណភាពរបស់ **សម្តេចវិបុលបញ្ញា សុខ អាន** អតីតឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាអតីតប្រធានអាជ្ញាធរជាតិអប្សរា នៅថ្ងៃទី១៣ និង១៤ ខែមីនា ឆ្នាំ២០១៨ ថ្នាក់ដឹកនាំ និងមន្ត្រីបុគ្គលិកមួយចំនួន ក្រោមការដឹកនាំរបស់លោកជំទាវប្រធានអាជ្ញាធរជាតិអប្សរា បានទៅគោរពវិញ្ញាណក្ខន្ធ ដើម្បីរំឭកខួប១ឆ្នាំ នៅគេហដ្ឋានរបស់សម្តេចនារាជធានីភ្នំពេញ។ ដោយឡែក ថ្នាក់ដឹកនាំ និងមន្ត្រីបុគ្គលិករបស់អាជ្ញាធរជាតិអប្សរាជាច្រើនរូប ដែលជាប់ការកិច្ចមិនបានទៅចូលរួមពិធីនៅរាជធានីភ្នំពេញ ក៏បានចូលរួមគោរពវិញ្ញាណក្ខន្ធនៅទីស្នាក់ការកណ្តាលនៃអាជ្ញាធរជាតិអប្សរា។

ការចូលរួមគោរពវិញ្ញាណក្ខន្ធនៅពេលនេះ ត្រូវបានរៀបចំឡើងដើម្បីសម្តែងនូវការដឹងគុណចំពោះសម្តេចវិបុលបញ្ញា ដែលសម្តេចធ្លាប់បានដឹកនាំការងារគ្រប់គ្រងរមណីយដ្ឋានអង្គរក្នុងឋានៈជាប្រធានអាជ្ញាធរជាតិអប្សរា សម្រេចបានលទ្ធផលយ៉ាងត្រចះត្រចង់ ធ្វើឲ្យអង្គរក្សាបាននូវតម្លៃលេចធ្លោជាសាកល និងកាន់តែមានភាពល្បីល្បាញ ទូទាំងសកលលោក។ ឆ្លៀតក្នុងឱកាសដ៏ថ្លៃថ្លានេះ ថ្នាក់ដឹកនាំ មន្ត្រីបុគ្គលិក ធ្មាំ កម្មករទាំងអស់ដែលធ្លាប់រស់ក្រោមឱវាទរបស់**សម្តេចវិបុលបញ្ញា** សូមលើកឡើងនូវកងការមហាកុសលគ្រប់យ៉ាងឧទ្ទិសជូនចំពោះសម្តេច សូមសម្តេចបានទៅកាន់សុគតិភពកុំបីខាន។ ជាមួយគ្នានេះ ថ្នាក់ដឹកនាំនិងមន្ត្រីបុគ្គលិកទាំងអស់ប្តេជ្ញាថែរក្សានូវកេរដំណែលដ៏ថ្លៃថ្លារបស់ដូនតា ក៏ដូចជាស្នាដៃការពារមរតកដូនជាបន្តបន្ទាប់របស់ថ្នាក់ដឹកនាំជាតិឲ្យបានគង់វង្សយូរអង្វែងតទៅ។

សម្តេចវិបុលបញ្ញា សុខ អាន បានទទួលមរណភាពកាលពីថ្ងៃ៣រោជ ខែផល្គុន ឆ្នាំវក អដ្ឋស័ក ពុទ្ធសករាជ២៥៦០ ត្រូវនឹងថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៧វេលាម៉ោង១៨:៣២នាទីដោយរោគាពាធក្នុងជន្មាយុ៦៦ឆ្នាំ៕









តំណាងលោកជំទាវប្រធានអាជ្ញាធរជាតិអប្សរាចៅសួរសុខទុក្ខមន្ត្រី ដែលជួបឧបទ្ទវហេតុគ្រោះថ្នាក់ចរាចរណ៍

ផ្សាយនៅថ្ងៃទី១៦ ខែ មីនា ឆ្នាំ២០១៨

នៅល្ងាចថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៨ **លោក ហេង សុផាឌី** អគ្គនាយករងនៃអគ្គនាយកដ្ឋានបេតិកភណ្ឌវប្បធម៌ ជាតំណាងដ៏ខ្ពង់ខ្ពស់របស់ **លោកជំទាវ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាប្រធានអាជ្ញាធរជាតិអប្សរា បានទៅសួរសុខទុក្ខ **លោក ទេព តូនី** អនុប្រធាននាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាន នៃអាជ្ញាធរជាតិអប្សរា ដែលកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យកាល់ម៉ែត្រាជធានីភ្នំពេញ ក្រោយជួបឧបទ្ទវហេតុគ្រោះថ្នាក់ចរាចរណ៍នៅស្រុកសន្ទុក ខេត្តកំពង់ធំ នារសៀលថ្ងៃទី១៤ ខែមីនា ពេលចុះបំពេញការងារ។ក្នុងឱកាសទៅសួរសុខទុក្ខនោះ **លោក ហេង សុផាឌី** ក៏បានពាំនាំនូវការផ្តាំផ្ញើសួរសុខទុក្ខ និងជូនពរសូមឱ្យ **លោក ទេព តូនី** បានឆាប់ជាសះស្បើយ និងបានយកថវិកាចំនួន២លានរៀល ឧបត្ថម្ភជូនដល់លោកដើម្បីព្យាបាលជំងឺ ផងដែរ។ សកម្មភាពនេះ បញ្ជាក់ឱ្យឃើញពីការយកចិត្តទុកដាក់របស់ប្រធានអាជ្ញាធរជាតិអប្សរា ពីសុខទុក្ខរបស់មន្ត្រី និងបុគ្គលិកក្រោមបង្គាប់គ្រប់ជាន់ថ្នាក់ដែលជួបប្រទះនូវបញ្ហាលំបាកនិងមានទុក្ខធុរៈនានាក្នុងជីវិត។

លោក ទេព តូនី ក៏បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោកជំទាវប្រធានអាជ្ញាធរជាតិអប្សរាដែលបានយកចិត្តទុកដាក់ពីសុខទុក្ខរបស់លោកក្នុងពេលជួបគ្រោះអាសន្ន។ ទឹកចិត្តនិងទង្វើទាំងនេះ ជាភាពកក់ក្តៅខ្លាំងណាស់សម្រាប់លោកនិងក្រុមគ្រួសារ៕





សេចក្តីជូនដំណឹង ស្តីពីព្រឹត្តិការណ៍សមរាត្រីនៅប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី ១៦ ខែ មីនា ឆ្នាំ២០១៨



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរ APSARA

សេចក្តីជូនដំណឹង
ស្តីពី
ព្រឹត្តិការណ៍សមរាត្រីនៅប្រាសាទអង្គរវត្ត

អាជ្ញាធរជាតិអប្សរាមានកិត្តិយសសូមជម្រាបជូនសាធារណជនជាតិ និងអន្តរជាតិទាំងអស់ មេត្តាជ្រាបថា ព្រឹត្តិការណ៍សមរាត្រី (Angkor Equinox) គឺថ្ងៃដែលព្រះអាទិត្យនឹងរះពីលំអុំចូលប្រាង្គកណ្តាលប្រាសាទអង្គរវត្ត នាថ្ងៃព្រាំងឆ្នាំនេះគឺចំថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៨ ដែលរៀបរៀងសេចក្តីទាំង អស់អាចទស្សនាបានចន្លោះពីម៉ោង៥ ដល់ម៉ោង៧ព្រឹក។

អាជ្ញាធរជាតិអប្សរាសូមបញ្ជាក់ថា ព្រឹត្តិការណ៍ចំអស្តាប្រនេះ ពុំមែនជាអច្ឆរិយហេតុ ឬជាបាតុភូតដែលកើតមើលដោយចៃដន្យនោះឡើយ។ ប៉ុន្តែនេះជាព្រឹត្តិការណ៍ដែលបុព្វបុរសរបស់ខ្មែរបានគិតគូរសិក្សាយ៉ាងច្បាស់លាស់អំពីវិទ្យាតារាសាស្ត្រ រួមផ្សំជាមួយក្បួនស្តាបត្យកម្ម ក្នុងការស្ថាបនាប្រាសាទអង្គរវត្ត។

តាមការប្រើប្រាស់ខ្លាតង្វាស់ដែលបុព្វបុរសសាងសង់អង្គរវត្ត អ្នកស្រាវជ្រាវរកឃើញថា តាមក្បួនតារាសាស្ត្រឥណ្ឌា គេបែងចែកគេលវេលាជាយុគតិតទៅតាមដំណើរព្រះច័ន្ទនិងព្រះអាទិត្យ ទើបកើតមានជាចន្ទគតិនិងសុរិយគតិ។ ក្នុងដំណើរមួយគោចរបស់ព្រះអាទិត្យនេះ មួយឆ្នាំត្រូវបែងចែកជា២ដំណើរគឺចំនួន១៨៩ថ្ងៃ និងចំនួន១៨៦ថ្ងៃ។ ដោយគិតទៅលើចន្ទាសម្លឹងនៅពាក់ពាក្យណ ដែលមានចែវខ្សែងស្មាន មានប្រាង្គប្រាំសាងឡើងកាត់កែងគ្នា ដែលមានប្រវែងលិច-កើតចំនួន១៨៩ ហត្ថ និងខើង-ត្បូងប្រវែង១៧៦,៣៧ហត្ថ។ បើយកចំនួនទាំងពីរ គឺសរុបបានចំនួន៣៦៥,៣៧ហត្ថ។

បើយើងសើកសែងការឃ្លៀងឃ្លាតខ្លះដោយទេវតា ដែលជាទំនៀមបស់ជាងចេញ និងការបំពេញបង្ក្រប់ព្រមទាំងកាត់ចំនួនសេសសល់ចេញ តម្រូវឲ្យចំនួនតគ្នាមកវិញ នោះយើងនឹងឃើញថា ប្រវែងចែវខ្សែងស្មាននៅពាក់ពាក្យណដែលអាចសំណាត់កាត់កែងគ្នា សរុបគឺ៣៦៥ហត្ថ ដែលគេចចែងកាត់កែងលិច-កើតមាន១៨៩ហត្ថ និងគេចចែងខើង-ត្បូង មាន១៧៦ហត្ថ នោះត្រូវនឹងដំណើរគោចរបស់ព្រះអាទិត្យក្នុងរយៈពេល៣៦៥ថ្ងៃក្នុងមួយឆ្នាំ ដែលសិស្សតារាសាស្ត្រចែកជាពីរដំណើរគឺ១៨៩ថ្ងៃនិង១៧៦ថ្ងៃ។



ក្នុងមួយឆ្នាំ១ មានខែខ្លះថ្ងៃវែងជាងយប់ ហើយខែខ្លះទៀតយប់វែងជាងថ្ងៃ ប៉ុន្តែក្នុងនោះមានខែពីរ ដែលពេលយប់និងថ្ងៃមានរយៈពេលស្មើគ្នានោះគឺ នៅពេលដែលព្រះអាទិត្យគោចរបាន១៨៩ថ្ងៃម្តង ដែលត្រូវនឹងថ្ងៃទី២០ឬ២១ ខែមីនា ឬឆ្នាំខ្លះអាចមាននៅថ្ងៃទី២៣ និងពេលដែលព្រះអាទិត្យគោចរបាន១៧៦ថ្ងៃម្តងទៀត ដែលត្រូវនឹងថ្ងៃទី២១ឬ២២ ឬក៏ទី២៣ ខែកញ្ញា។

ដោយតនិត្តភាពមិត្តភាពសាស្ត្រ និងលោកជាគុរុវិទ្យានេះហើយ ដែលស្តាបត្យកម្មបុរាណកសាងអង្គរវត្ត ឲ្យខ្លះប្រែប្រួលទៅតាមបរិបទសង្គមក្រាឡង និងវប្បធម៌ដែលមានការប្រែប្រួលតាមបរិបទសង្គមក្រាឡង ដោយយកប្រាង្គកណ្តាលនៃអង្គរវត្តជាគោលកណ្តាល និងជាចំណុចសង្កេតសម្គាល់គោចរបស់ព្រះអាទិត្យ។ ក្នុងរវាង ១៨៩ថ្ងៃនិងបន្តទៀត១៧៦ថ្ងៃ ព្រះអាទិត្យនឹងមករះលំអុំចំណុចនេះម្តង។ តាមការស្រាវជ្រាវនេះហើយ ទើបក្នុងមួយឆ្នាំព្រះអាទិត្យតែងតែលេចឡើងត្រង់ តាមបង្អួចកណ្តាលនៃអង្គរវត្តនេះដែរ ដែលធ្វើឲ្យក្នុងមួយឆ្នាំជាមួយនឹងការសិក្សាស្រាវជ្រាវ ដើម្បីទទួលបានខ្លឹមសារលម្អិត ដែលពន្យល់ពីព្រឹត្តិការណ៍នេះ សាធារណជនអាចចូលទៅកាន់គេហទំព័រផ្លូវការរបស់អាជ្ញាធរជាតិអប្សរា www.apsaraauthority.gov.kh ដែលធ្លាប់បានចេញផ្សាយពីមុនមក ដោយស្វែងរកក្នុងពាក្យគន្លឹះ សមរាត្រី ឬ Angkor Equinox ។

ដូចបានជម្រាបជូនខាងលើនេះ អាជ្ញាធរជាតិអប្សរាសូមគោរពអញ្ជើញរៀបរាប់ទេសចរជាតិ និងអន្តរជាតិឲ្យមកទស្សនាឮព្រឹត្តិការណ៍នេះឲ្យបានច្រើនកុះករ ដើម្បីបង្ហាញឲ្យពិភពលោកឃើញនូវអច្ឆរិយភាពនៃប្រាសាទអង្គរវត្ត ដែលជាស្នាដៃដ៏ល្អឯកបស់បុព្វបុរសខ្មែរយើង។

ធ្វើនៅថ្ងៃសុក្រ ១៥កេីត ខែផល្គុន ឆ្នាំរកា ឧទ្ទិសក ព.ស ២៥៦១
សៀមរាប, ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៨
អាជ្ញាធរជាតិអប្សរា

ប្រធានអាជ្ញាធរជាតិអប្សរាសម្តែងការសោកស្តាយចំពោះឧបទ្ទវហេតុអគ្គីភ័យឆេះសាលមហោស្រពអង្គរ និងសន្យាជ្រោមជ្រែងតាមលទ្ធភាពក្នុងការជួសជុលឡើងវិញ

ផ្សាយនៅថ្ងៃទី ១៧ ខែ មីនា ឆ្នាំ២០១៨

រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងជាប្រធានអាជ្ញាធរជាតិអប្សរា **លោកជំទាវ ភឿង សកុណា** ផ្លៀតក្នុងឱកាសមកបំពេញភារកិច្ចនៅខេត្តសៀមរាប បានអញ្ជើញទៅពិនិត្យសាលមហោស្រពអង្គរ នាព្រឹកថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៨ នេះ។

ការអញ្ជើញទៅពិនិត្យសាលមហោស្រពអង្គរនេះ ធ្វើឡើងបន្ទាប់ពីសាលមហោស្រពដ៏ធំ ដែលបានបង្ហាញទស្សនីយភាពដ៏អស្ចារ្យនៃអារ្យធម៌ដ៏រុងរឿងរបស់ខ្មែរមួយនេះ ទើបតែត្រូវអគ្គីសនីឆាបឆេះកាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៨ ម្សិលមិញ។ ជាមួយគ្នានឹងការចុះពិនិត្យ លោកជំទាវរដ្ឋមន្ត្រីក៏បានសម្តែងនូវការសោកស្តាយយ៉ាងខ្លាំង ព្រមទាំងសន្យាជួយជ្រោមជ្រែងតាមលទ្ធភាពគ្រប់យ៉ាង ដែលពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដើម្បីឲ្យសាលមហោស្រពនេះអាចមានលទ្ធភាពសម្តែងឡើងវិញនូវផ្ទាំងទស្សនីយភាពដ៏អស្ចារ្យទាំងនោះ។

សាលមហោស្រពអង្គរ ត្រូវបានសាងសង់ដោយគម្រោងវិនិយោគរួមគ្នារវាងអ្នកវិនិយោគចិន និងវិនិយោគក្នុងស្រុក ដែលមានទីតាំងនៅជាប់បុរីប្រិមប្រិយខេត្តសៀមរាប។ សាលមហោស្រពនេះទើបតែដាក់សម្ពោធប្រើប្រាស់ជាផ្លូវការកាលពីខែតុលា ឆ្នាំ២០១៧កន្លងទៅ និងត្រូវបានឆាបឆេះដោយគ្រោះអគ្គីភ័យនៅព្រឹកព្រលឹមថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៨នេះ៕









រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈចុះត្រួតពិនិត្យការត្រៀមសម្ពោធសារមន្ទីរជម្នាតិសកល សម្តេចតេជោហ៊ុនសែនព្រះវិហារ

ផ្សាយនៅថ្ងៃទី ១៩ ខែ មីនា ឆ្នាំ២០១៨

សារមន្ទីរជម្នាជាតិសកលសម្តេចតេជោហ៊ុនសែនព្រះវិហារ នឹងត្រូវសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃអង្គារ ០៤កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស២៥៦១ ត្រូវនឹងថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៨។

ដើម្បីត្រៀមខ្លួនឲ្យរួចរាល់សម្រាប់ការសម្ពោធប្រកបដោយភាពល្អប្រសើរ នាថ្ងៃអាទិត្យ ០២កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស២៥៦១ ត្រូវនឹងថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៨ **លោកជំទាវ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈនិងជាប្រធានអាជ្ញាធរជាតិអប្សរាបាន ដឹកនាំក្រុមការងារជំនាញមកពីក្រសួងវប្បធម៌និងវិចិត្រសិល្បៈអាជ្ញាធរជាតិអប្សរា អាជ្ញាធរជាតិព្រះវិហារ ចុះពិនិត្យដោយផ្ទាល់នូវការរៀបចំ និងដាក់តាំងបង្ហាញសមុច្ចយនានាក្នុងសារមន្ទីរ។

សូមបញ្ជាក់ថា សារមន្ទីរធម្មជាតិសកលសម្តេចតេជោហ៊ុនសែនព្រះវិហារ មានទីតាំងនៅភូមិធម្មជាតិ ឃុំស្រអែម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ប្រម៉ាណ២៣គីឡូម៉ែត្រពីរមណីយដ្ឋានប្រាសាទព្រះវិហារដែលជាបេតិកភណ្ឌពិភពលោក។









លោកជំទាវ ម៉ែន សំអន និងលោកជំទាវ ភឿង សកុណា ដឹកនាំមន្ត្រីរាជការ សប្បុរសជន និងអ្នកជំនាញធ្វើពិធីប្រុងពលីបើកការដ្ឋានជួសជុលប្រាសាទចតុមុខនៃក្រុមប្រាសាទបាកាណ(ព្រះខ័ន្ធកំពង់ស្វាយ) នៅខេត្តព្រះវិហារ

ផ្សាយនៅថ្ងៃទី ២០ខែ មីនា ឆ្នាំ២០១៨

លោកជំទាវ ម៉ែន សំអន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច និង **លោកជំទាវ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ដោយមានការចូលរួមពីអភិបាលនៃគណៈអភិបាលខេត្តព្រះវិហារ បានដឹកនាំមន្ត្រីរាជការ អ្នកជំនាញផ្នែកអភិរក្សជួសជុលប្រាសាទ ឆ្មាំការពារប្រាសាទ ធ្វើពិធី ប្រុងពលីបើកការដ្ឋានជួសជុលប្រាសាទចតុមុខនៃក្រុមប្រាសាទបាកាណ(ព្រះខ័ន្ធកំពង់ស្វាយ) នៅថ្ងៃចន្ទ ០៣កើត ឆ្នាំ រកា នព្វស័ក ព.ស២៥៦១ ត្រូវនឹងថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៨។

ថ្លែងនាពេលនេះ លោកជំទាវ ឧបនាយករដ្ឋមន្ត្រី បានលើកឡើងថា ដោយប្រាសាទរបស់យើងត្រូវបានខូចខាត បែកបាក់ដោយសារសង្គ្រាម តែពេលនេះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រមុខនៃរាជរដ្ឋាភិបាលកម្ពុជា បានធ្វើឲ្យប្រទេសយើងមានសុខសន្តិភាព សុវត្ថិភាពពេញលេញ និងការរីកចម្រើនគ្រប់វិស័យ និងម្យ៉ាងទៀតដោយ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈមានលទ្ធភាពជំនាញគ្រប់គ្រាន់ក្នុងការជួសជុលទើបយើងចាំបាច់ត្រូវតែជួសជុល អភិរក្សសម្បត្តិបេតិកភណ្ឌជាតិឡើងវិញសំដៅលើកកម្ពើងដួងព្រលឹងជាតិ។ បន្ថែមលើសនេះ លោកជំទាវក៏បានស្នើឲ្យប្រជាពលរដ្ឋខ្មែរចូលរួមថែរក្សាទ្រព្យសម្បត្តិដែលជាមរតកដូនតា និងជាដួងព្រលឹងជាតិឲ្យបានគង់វង្សទាំងនៅជំនាន់នេះ ជំនាន់កូនចៅយើងក្រោយៗទៀត។

ឋវិកាសម្រាប់ការជួសជុលប្រាសាទចតុមុខគឺបានមកពីសកម្មភាពសប្បុរសធម៌ និងពិធីបុណ្យផ្តាំប្រាក់ដែលលោកជំទាវ ឧបនាយករដ្ឋមន្ត្រី បានខិតខំផ្តួចផ្តើមនាពេលកន្លងមក។ គួរបញ្ជាក់ថា ប្រាសាទចតុមុខមានទីតាំងនៅភូមិរណសិរ្ស ស្រុកសង្គមថ្មី ខេត្តព្រះវិហារ និងស្ថិតក្នុងក្រុមប្រាសាទបាកាណ(ព្រះខ័ន្ធកំពង់ស្វាយ) ដែលជាទីតាំងប្រវត្តិសាស្ត្រក្នុងបង្កើតនិងហ្វឹកហាត់កងទ័ពមុនពេលព្រះបាទជ័យវរ្ម័នទី៧ធ្វើការដេញដោលយកឈ្នះពួកចាម។









ពិធីប្រុងពលីសម្ពោធសាមគ្គីរដ្ឋមន្ត្រីជម្ចាតិសកលសម្តេចតេជោហ៊ុនសែនព្រះវិហារប្រកាន់ភ្ជាប់ក្រោមអធិបតីភាពលោកជំទាវ ភឿង សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

ផ្សាយនៅថ្ងៃទី ២០ ខែ មីនា ឆ្នាំ២០១៨

លោកជំទាវ ភឿង សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងជាប្រធានអាជ្ញាធរជាតិអប្សរា បានអញ្ជើញជាអធិបតីក្នុងពិធីប្រុងពលីការដាក់ឲ្យ ដំណើរដាក់ផ្លូវការសាមគ្គីរដ្ឋមន្ត្រីធម្មជាតិសកល សម្តេចតេជោហ៊ុនសែនព្រះវិហារនៅថ្ងៃចន្ទ

០៣កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស២៥៦១ ត្រូវនឹងថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៨ ដោយមានការចូលរួមពី **ឯកឧត្តម សួស យ៉ារ៉ា** អ្នកតំណាងរាស្ត្រមណ្ឌលព្រះវិហារ មន្ត្រីរាជការ និងអាជ្ញាធរមូលដ្ឋាន។ សារមន្ទីរធម្មជាតិសកលសម្តេចតេជោហ៊ុនសែនព្រះវិហារ មានទីតាំងនៅភូមិធម្មជាតិ ឃុំស្រអែម ស្រុកជាំក្សាន្តខេត្តព្រះវិហារ នឹងសម្ពោធដាក់ឲ្យដំណើរការជាផ្លូវការនៅថ្ងៃអង្គារ ០៤កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស២៥៦១ ត្រូវនឹងថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៨។






កណៈកម្មាធិការអាយស៊ីស៊ី-ព្រះវិហារ បើកកិច្ចប្រជុំពេញអង្គលើកទី៤ ផ្តោតលើការជួសជុលប្រាសាទព្រះវិហារ

ផ្សាយនៅថ្ងៃទី ២១ ខែ មីនា ឆ្នាំ២០១៨

នៅព្រឹកថ្ងៃពុធ ០៥កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស២៥៦១ ត្រូវនឹងថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៨ គណៈកម្មាធិការសម្របសម្រួលអន្តរជាតិសម្រាប់ការអភិរក្ស និងលើកតម្លៃមណ្ឌលប្រាសាទព្រះវិហារ បានបើកកិច្ចប្រជុំពេញអង្គលើកទី៤របស់ខ្លួននៅស្នាក់ការអាជ្ញាធរជាតិអប្សរានាខេត្តសៀមរាប។ កិច្ចប្រជុំបានផ្តោតលើប្រធានបទសំខាន់ៗមួយចំនួនដូចជាការងារអភិរក្សនិងអភិវឌ្ឍនៅប្រាសាទព្រះវិហារនិងប្រាសាទកោះកេរ។

អង្គប្រជុំមានការអញ្ជើញចូលរួមដ៏ខ្ពង់ខ្ពស់ **លោកជំទាវ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាប្រធានអាជ្ញាធរជាតិអប្សរា សហប្រធានកិច្ចប្រជុំអាយស៊ីស៊ី-ព្រះវិហារ មានប្រទេសចិន និងប្រទេសឥណ្ឌា តំណាងទូត ស្ថាប័នដៃគូអភិវឌ្ឍន៍មន្ត្រីរាជការព្រមទាំងអ្នកជំនាញជាតិនិងអន្តរជាតិជាច្រើន។

មានប្រសាសន៍ក្នុងពិធីបើកកិច្ចប្រជុំពេញអង្គលើកទី៤ **លោកជំទាវ ភឿង សកុណា** បានសម្តែងអារម្មណ៍សប្បាយរីករាយដែលបានចូលរួមក្នុងកិច្ចប្រជុំនិងបង្ហាញនូវការវិវត្តនៃការងារសំខាន់ៗដែលភាគីពាក់ព័ន្ធ បានបំពេញនាពេលកន្លងមក លើការងារជួសជុល និងអភិរក្សទាំងនៅប្រាសាទព្រះវិហារ និងនៅប្រាសាទកោះកេរ។ រីឯកិច្ចប្រជុំនាពេលនេះក៏កំពុងបង្ហាញនូវដំណើរការដ៏ត្រឹមត្រូវ ហើយលោកជំទាវសង្ឃឹមថា សកម្មភាពការងារជួសជុលក្នុងប្រាសាទព្រះវិហារ និងតំបន់កោះកេរ នឹងត្រូវបានពង្រីកនាពេលខាងមុខ។

ក្នុងនាមអាជ្ញាធរជាតិព្រះវិហារ **លោកបណ្ឌិត គឹម សេតារា** ប្រធានអាជ្ញាធរជាតិព្រះវិហារ បានប្រសាសន៍ថា អង្គប្រជុំនេះមានរបៀបវារៈសំខាន់ ផ្តោតលើការសហប្រតិបត្តិការ ពិសេសសហប្រធានប្រទេសចិន និងឥណ្ឌា រួមជាមួយដៃគូសហប្រតិបត្តិការផ្សេងៗទៀត ដែលបានបង្ហាញឆន្ទៈនៃការចូលរួមជួសជុលប្រាសាទព្រះវិហារ និងមួយផ្នែកទៀតនៅប្រាសាទកោះកេរ។ បន្ថែមលើសនេះ អង្គប្រជុំក៏នឹងពិភាក្សាផងដែរអំពីបញ្ហាបរិស្ថានផងដែរព្រោះថា ដោយសារទីនោះជាតំបន់ភ្នំ ហើយនៅខែវស្សាមានបញ្ហាទឹកហូរច្រោះនិងខែប្រាំងមានភ្លើងឆេះព្រៃ។

គួរបញ្ជាក់ថា នៅប្រាសាទព្រះវិហារមានខ្លោងទ្វារ (Gupura) ចំនួន៥ ដែលនីមួយៗមានភាពទ្រុឌទ្រោម។ នាពេលកន្លងមកភាគីចិន ធ្លាប់បានសន្យាជួសជុលប្រាង្គនិងខ្លោងទ្វារទី១ ទី២ និងទី៣ ចំណែកឯភាគីឥណ្ឌា សន្យាជួយជួសជុលខ្លោងទ្វារទី៥និងជណ្តើរខាងជើង។រីឯប្រទេសរុស្ស៊ីក៏បានសន្យាជួសជុលខ្លោងទ្វារទី៤ផងដែរ៕









លោកជំទាវប្រធានអាជ្ញាធរជាតិអប្សរាជួបពិភាក្សាជាមួយស្ថាប័នអន្តរជាតិដែលកំពុងបំពេញការងារនៅក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី ២២ ខែ មីនា ឆ្នាំ២០១៨

ចាប់តាំងពីអង្គរបានចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោកនៅឆ្នាំ១៩៩២ មានស្ថាប័នអន្តរជាតិជាច្រើនបានចូលរួមក្នុងការជួយស្រោចស្រង់អង្គរ ដែលមានទាំងគម្រោងអភិរក្ស ជួសជុលប្រាសាទ ស្រាវជ្រាវ បណ្តុះបណ្តាលធនធានមនុស្ស និងអភិវឌ្ឍន៍សហគមន៍ជាដើម។

ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការឲ្យកាន់តែល្អប្រសើររវាងស្ថាប័នអន្តរជាតិទាំងនេះ នាព្រឹកថ្ងៃព្រហស្បតិ៍ ០៥កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស២៥៦១ ត្រូវនឹងថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៨ **លោកជំទាវ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាប្រធានអាជ្ញាធរជាតិអប្សរា បានជួបពិភាក្សាជាមួយតំណាងស្ថាប័នអន្តរជាតិគ្រប់ការដ្ឋានទាំងអស់ដែលកំពុងបំពេញការងារនៅក្នុងរមណីយដ្ឋានអង្គរ។

គោលបំណងសំខាន់នៃជំនួបពិភាក្សានាពេលនេះ គឺសំដៅជំរុញកិច្ចសហប្រតិបត្តិការឲ្យកាន់តែមានការជិតស្និទ្ធតាមរយៈការស្វែងយល់នូវបញ្ហាប្រឈមនានាដែលការដ្ឋានអន្តរជាតិជួបប្រទះក្នុងការអនុវត្តការងារគម្រោងនីមួយៗ និងចូលរួមចំណែកដោះស្រាយនូវបញ្ហាប្រឈមផ្សេងៗក្នុងន័យជំរុញឲ្យដំណើរការអភិរក្ស ជួសជុលប្រាសាទក្នុងរមណីយដ្ឋានអង្គរ ដំណើរការទៅដោយរលូននិងរក្សាបាននូវតម្លៃលេចធ្លោជាសាកលនៃអង្គរ។

មានប្រសាសន៍ក្នុងជំនួបពិភាក្សានេះ លោកជំទាវរដ្ឋមន្ត្រីក៏បានថ្លែងរំលឹកអំពីលទ្ធផលដ៏ល្អប្រសើរដែលសម្រេចបាននាពេលកន្លងមក និងសម្តែងការអរគុណដល់ស្ថាប័នអន្តរជាតិទាំងអស់ ដែលបានរួមចំណែកយ៉ាងសំខាន់ក្នុងកិច្ចការអភិរក្ស និងអភិវឌ្ឍន៍រមណីយដ្ឋានអង្គរ ព្រោះបើគ្មានការជួយជ្រោមជ្រែងពីបណ្តាប្រទេសជាដៃគូតាំងពីដើមមកទេ អង្គរមិនអាចគេចផុតពីភាពប្រឈមនឹងគ្រោះថ្នាក់បានឡើយ៕









ប្រធានអាជ្ញាធរជាតិអប្សរាជួបពិភាក្សាការងារជាមួយតំណាងវិស័យឯកជនដើម្បីបង្កើនគុណភាពវិស័យទេសចរណ៍ក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី ២២ ខែ មីនា ឆ្នាំ២០១៨

នៅរសៀលថ្ងៃព្រហស្បតិ៍ ០៦កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១ ត្រូវនឹងថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៨ **លោក ជំទាវ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងជាប្រធានអាជ្ញាធរជាតិអប្សរា បានជួបពិភាក្សាការងារជាមួយតំណាងវិស័យឯកជន ដើម្បីលើកកម្ពស់គុណភាពសេវាកម្មទេសចរណ៍ក្នុងរមណីយដ្ឋានអង្គរ។ កិច្ចប្រជុំនេះមានអ្នកតំណាងមកពីក្រុមហ៊ុនឯកជន សណ្ឋាគារ វិស័យទេសចរណ៍ មគ្គុទេសក៍ទេសចរណ៍ជាដើម ដែលសរុបទាំងអស់ប្រមាណ៣០នាក់។

គោលបំណងនៃកិច្ចប្រជុំនេះ គឺដើម្បីពិភាក្សាផ្លាស់ប្តូរយោបល់ដោយចំហរ លើកិច្ចសហប្រតិបត្តិការនានាជាមួយវិស័យឯកជនដើម្បីស្វែងយល់ និងរកដំណោះស្រាយ សំដៅអភិវឌ្ឍន៍វិស័យទេសចរណ៍ក្នុងរមណីយដ្ឋានអង្គរឱ្យមានការអភិវឌ្ឍប្រកបដោយចេរីភាព។ ក្នុងនោះដែរ កិច្ចប្រជុំនេះក៏ដើម្បីស្វែងរកដំណោះស្រាយរួមមួយរវាងស្ថាប័នរដ្ឋ និងវិស័យឯកជនធ្វើយ៉ាងណាឱ្យភ្ញៀវទេសចរមកទស្សនារមណីយដ្ឋានអង្គរ ទទួលបានបទពិសោធន៍ល្អៗក្នុងដំណើរកម្សាន្តរបស់ខ្លួន។

ថ្លែងក្នុងពិធីនោះ **លោកជំទាវ ភឿង សកុណា** បានសម្តែងអារម្មណ៍សប្បាយរីករាយ និងអរគុណដល់វិស័យឯកជនដែលបានចូលរួមក្នុងការអភិវឌ្ឍវិស័យទេសចរណ៍ក្នុងរមណីយដ្ឋានអង្គរ ដូចជាការផ្សព្វផ្សាយពីសម្បត្តិវប្បធម៌ខ្មែរដល់ទេសចរណ៍នៅលើសាកលលោកបានដឹងពីភាពអស្ចារ្យរបស់កម្ពុជា។ លើសពីនេះទៀត លោកជំទាវជឿជាក់ថាកិច្ចសហប្រតិបត្តិការនេះនឹងបន្តទៅមុខជានិរន្ត ហើយស្នើឱ្យមានការពិភាក្សាឬមានទំនាក់ទំនងដោយផ្ទាល់មកអាជ្ញាធរជាតិអប្សរា៕





អាជ្ញាធរជាតិអប្សរាសម្រេចបង្កើត គណៈកម្មការដឹកនាំនិងសម្របសម្រួល ព្រមទាំងសណ្តាប់ធ្នាប់អ្នកលក់ដូរក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី ២៦ ខែ មីនា ឆ្នាំ២០១៨

ដើម្បីរៀបចំសណ្តាប់ធ្នាប់អ្នកលក់ដូរក្នុងរមណីយដ្ឋានអង្គរ ឲ្យសក្តិសមនឹងតម្លៃរបស់អង្គរ ដែលជាសម្បត្តិបេតិកភណ្ឌពិភពលោក អាជ្ញាធរជាតិអប្សរាបានសម្រេចបង្កើតគណៈកម្មការ ចម្រុះមួយដែលមានសមាសភាពពីអាជ្ញាធរជាតិអប្សរា អាជ្ញាធរខេត្តសៀមរាប កម្លាំងសមត្ថកិច្ច និងអាជ្ញាធរមូលដ្ឋានដែលស្ថិតនៅក្នុងរមណីយដ្ឋានអង្គរ។

គណៈកម្មការនេះបង្កើតឡើងតាមសេចក្តីសម្រេចលេខ១១សសរ របស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៨។ តាមសេចក្តីសម្រេចនេះ គណៈកម្មការចម្រុះមានសភាពពីអាជ្ញាធរជាតិអប្សរាជាប្រធាន សមាសភាពពីរដ្ឋបាលខេត្តសៀមរាបជាអនុប្រធាន និងមានអាជ្ញាធរមូលដ្ឋានដែលស្ថិតនៅក្នុងរមណីយដ្ឋានអង្គរជាសមាជិក។

នារសៀលថ្ងៃសុក្រ ៧រោច ខែផល្គុន ឆ្នាំរកា នព្វស័ក ពស២៥៦១ ត្រូវនឹងថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៨នេះ **ឯកឧត្តម សុខ សង្ហារ** អគ្គនាយករងនៃអាជ្ញាធរជាតិអប្សរា ក្នុងនាមប្រធាននៃគណៈកម្មការនេះបានដឹកនាំកិច្ចប្រជុំជាលើកដំបូងជាមួយសមាជិកសមាជិកា ដើម្បីផ្លាស់ប្តូរយោបល់គ្នាស្តីពីការអនុវត្តសេចក្តីសម្រេចខាងលើឲ្យសម្រេចបានលទ្ធផលល្អប្រសើរ។

មានប្រសាសន៍ក្នុងកិច្ចប្រជុំនេះ **ឯកឧត្តម សុខ សង្ហារ** បានរៀបរាប់ពីដើមហេតុដែលជំរុញឲ្យមានការបង្កើតគណៈកម្មការនេះឡើង។ ឯកឧត្តមបញ្ជាក់ថា បេសកកម្មដ៏សំខាន់បំផុតនៃគណៈកម្មការនេះគឺធ្វើយ៉ាងណារក្សា សណ្តាប់ធ្នាប់ឲ្យបានល្អប្រសើរ ក្នុងន័យទាក់ទាញភ្ញៀវទេសចរមកកាន់អង្គរកាន់តែច្រើន ជាពិសេសនោះគឺ រក្សានូវភាពថ្លៃថ្នូររបស់រមណីយដ្ឋានអង្គរយើង។

ឯកឧត្តមបន្ថែមថា "អាជ្ញាធរជាតិអប្សរាមិនហាមឃាត់ទេការលក់ដូរក្នុងរមណីយដ្ឋានអង្គរ យើងមានតែជំរុញឲ្យអ្នកស្រុកអង្គរមានឱកាសបានលក់ដូរ ដើម្បីបង្កើនកម្រិតជីវភាពរបស់ពួកគាត់។ តែយើងក៏ត្រូវគិតគូរពីភាពថ្លៃថ្នូររបស់អង្គរ តាមរយៈការរៀបចំពួកគាត់ឲ្យលក់ដូរតាមទីតាំងសមរម្យ មានសណ្តាប់ធ្នាប់ មានសុចរិតភាពក្នុងអាជីវកម្មរបស់គាត់ជាមួយភ្ញៀវដែលមកទស្សនាអង្គរ"។

លោក សុខ ចុល នាយករងរដ្ឋបាលសាលាខេត្តសៀមរាប ក្នុងនាមអនុប្រធាននៃគណៈកម្មការនេះ បានលើកឡើងថា សាលាខេត្តសៀមរាប រួមទាំងអាជ្ញាធរដែនដីគាំទ្រទាំងស្រុងនូវការបង្កើតគណៈកម្មការនេះឡើង។ លោកបញ្ជាក់ថា រដ្ឋបាលខេត្តសៀមរាបក៏ដូចជាអាជ្ញាធរជាតិអប្សរាដែរ គឺផ្តោតលើសណ្តាប់ធ្នាប់របៀបរៀបរយ ធ្វើយ៉ាងណាឲ្យខេត្តសៀមរាបក៏ដូចជាតំបន់អង្គរសក្តិសមជាតំបន់បេតិកភណ្ឌ ដែលកំពុងតែទទួលបានការចាប់អារម្មណ៍ពីសំណាក់ភ្ញៀវទេសចរកាន់តែច្រើនឡើងៗ។

ឆ្លងតាមការពិភាក្សាគ្នាក្នុងកិច្ចប្រជុំនេះ អង្គប្រជុំទាំងអស់បានបង្ហាញការគាំទ្រនិងសន្យាចូលរួមសកម្មភាពរៀបចំសណ្តាប់ធ្នាប់អ្នកលក់ដូរនៅរមណីយដ្ឋានអង្គរឲ្យកាន់តែល្អប្រសើរឡើងជាលំដាប់៕






ជាងឈើ ជាងចម្លាក់ និងសិល្បៈករអន្តរជាតិជាង១០០ប្រទេស ចូលរួមដាំដើមឈើនៅបរិវេណប្រាសាទប្រិយ៍

ផ្សាយនៅថ្ងៃទី ២៧ ខែ មីនា ឆ្នាំ២០១៨

នាព្រឹកថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៨ ជាងឈើ ជាងចម្លាក់ សិល្បករ មកពីប្រមាណជា១០០ប្រទេស សរុបប្រមាណ៣០០នាក់នៅជុំវិញពិភពលោកបានមកជួបជុំគ្នា ចូលរួមដាំដើមក្រញូងចំនួន២០០ដើមជាមិត្តភាពនៅខាងកើតឆៀងខាងជើងក្នុងបរិវេណប្រាសាទប្រិយ៍នៃតំបន់ឧទ្យានអង្គរ។

ពិធីនេះដឹកនាំដោយ **ឯកឧត្តម ស៊ុំ ឈុំឃុន** អនុប្រធានរាជបណ្ឌិត្យសភាកម្ពុជា ដើម្បីអបអរសាទរទិវាវប្បធម៌ឈើ ពិភពលោកឆ្នាំ២០១៨ ក្រោមប្រធានបទ ព្រៃឈើ និង ជីវិត ដែលធ្វើឡើងនៅខេត្តសៀមរាប។ នេះជាលើកទី៦នៃការប្រារព្ធពិធីទិវាវប្បធម៌ឈើលើពិភពលោក ហើយជាលើកទី១របស់ប្រទេកម្ពុជាដែលបានធ្វើជាម្ចាស់ផ្ទះ។

ព្រឹត្តិការណ៍អន្តរជាតិនេះ ជាទិវាដ៏មានអត្ថន័យសម្រាប់ការបណ្តុះគំនិតឱ្យពិភពលោកស្រលាញ់ព្រៃឈើ។ ម្យ៉ាងទៀតព្រៃឈើគឺមានសារៈសំខាន់ណាស់សម្រាប់ភាពគង់វង្សរបស់ប្រាសាទក្នុងតំបន់អង្គរ ព្រោះវាជារបាំងការពារខ្យល់យ៉ាងរឹងមាំ រក្សាសំណើមដល់ថ្មប្រាសាទមិនងាយធ្វើឱ្យថ្មរបេះឬសឹករិចរិល ទប់ទល់ការហូរច្រោះដី រក្សាទឹកក្រោមដីមិនឱ្យប្រាសាទស្រុត និងជាគម្របបៃតងលម្អជុំវិញប្រាសាទ ឱ្យមានទេសភាពស្រស់ត្រកាលគួរជាទីគយគន់៕






អាជ្ញាធរជាតិអប្សរាកំពុងជួសជុលកំណាត់ផ្លូវចង់ដើម្បីសម្រួលចរាចរណ៍ឱ្យប្រសើរជាងមុន

ផ្សាយនៅថ្ងៃទី ២៧ ខែ មីនា ឆ្នាំ២០១៨

កំណាត់ផ្លូវក្រាលកៅស៊ូនៅវង់ធំក្នុងតំបន់ឧទ្យានអង្គរដែលមានប្រវែងជាង២០គីឡូម៉ែត្រ ជាផ្នែកមួយដ៏សំខាន់សម្រាប់ការធ្វើដំណើររបស់អ្នកស្រុកផងនិងបម្រើឱ្យវិស័យទេសចរណ៍ផងប៉ុន្តែផ្លូវនេះបានរងនូវការខូចខាតដោយអន្លើៗ។

បច្ចុប្បន្នកំណាត់ផ្លូវក្រាលកៅស៊ូចាប់ពីក្លោងទ្វារជើឆ្នាំង រហូតដល់ទ្វារទឹកប្រាសាទព្រះខ័ន កំពុងជួសជុលកែលម្អឡើងវិញទាំងស្រុងតាមបច្ចេកទេសដោយអាជ្ញាធរជាតិអប្សរា ទទួលបន្ទុកដោយនាយកដ្ឋាន ទ្រទ្រង់បច្ចេកទេសនិងគម្រោងអន្តរវិស័យ។ គម្រោងជួសជុលផ្លូវវង់ធំនេះបានសិក្សាបច្ចេកទេសចាប់តាំងពីឆ្នាំ២០១៦ ហើយកន្លងមកក្រុមអ្នកជំនាញការលើផ្នែកអភិរក្សបុរាណវិទ្យានៃគណៈកម្មការអាយស៊ីស៊ី-អង្គរ បានចុះពិនិត្យនិងផ្តល់យោបល់នៅនឹងកន្លែង ព្រមទាំងផ្តល់ការការអនុម័តឱ្យធ្វើការជួសជុលក្នុងកិច្ចប្រជុំអាយស៊ីស៊ី-អង្គរ កាលពីខែធ្នូ ឆ្នាំ២០១៧។

លោក ហេង គីមឡេង ប្រធាននាយកដ្ឋានទ្រទ្រង់បច្ចេកទេសនិងគម្រោងអន្តរវិស័យនៃអគ្គនាយកដ្ឋានអាជ្ញាធរជាតិអប្សរា បានឱ្យដឹងថា៖ ក្រុមការងារបានអនុវត្តការងារកាលពីខែមីនា ឆ្នាំ២០១៨ ហើយការអនុវត្តគម្រោងនេះមានរយៈពេល៤ខែទើបបញ្ចប់។ រីឯការជួសជុលកែលម្អផ្លូវវង់ធំវិញ ក៏មិនបានធ្វើឡើងទាំង២០គីឡូម៉ែត្រតែម្តងនោះទេ ព្រោះធ្វើទៅតាមលទ្ធភាពថវិកាប្រចាំឆ្នាំ។ ជាក់ស្តែងគម្រោងមូលនិធិឆ្នាំ២០១៧ អាចធ្វើបានប្រវែង៤០៦០ម៉ែត្រ និងសម្រាប់ឆ្នាំ២០១៨ អាចជួសជុលបន្ថែមបានប្រវែង៥០០០ម៉ែត្រទៀត។

លោកបន្តទៀតថា៖ ដំបូងឡើយ ការជួសជុលគ្រោងពង្រីកទទឹងរហូតដល់៩ម៉ែត្រ គឺ៦ម៉ែត្រសម្រាប់យានយន្តធ្វើចរាចរណ៍ និង១ម៉ែត្រសងខាងសម្រាប់អ្នកជិះកង់។ ប៉ុន្តែក្រោយកិច្ចប្រជុំជាមួយនាយកដ្ឋានពាក់ព័ន្ធ បានឱ្យដឹងពីចរាចរណ៍ផ្លូវនេះថាមិនសូវមានអ្នកជិះកង់ច្រើន ទើបសម្រេចពង្រីកទទឹងផ្លូវត្រឹម៦ម៉ែត្រ លើទទឹងផ្លូវចាស់៥ម៉ែត្រ សម្រាប់ប្រើប្រាស់រួមរវាងអ្នកជិះកង់និងយានយន្ត។ ក្រៅពីការកែលម្អផ្លូវនេះ ក្រុមការងារក៏បានកែសម្រួលប្រព័ន្ធរំដោះទឹកអមសងខាងផ្លូវដោយប្រើបច្ចេកទេសបើកមុខលូជារាងត្រីកោណដើម្បីឱ្យទឹកជ្រាបចូលក្នុងដីបានលឿន និងបង្ការការបាក់ស្រុតដីលុបប្រព័ន្ធបង្ហូរទឹកផងដែរ។

ជាការកត់សម្គាល់កំឡុងពេលនៃការជួសជុលនេះក៏បានបង្ករការហុយដី ការរំខានក្នុងការធ្វើដំណើរខ្លះៗដល់ប្រជាពលរដ្ឋ ក៏ដូចជាភ្ញៀវទេសចរដែលទស្សនាតំបន់វង់ធំ ពេលក្រុមការងារកំពុងឈូសឆាយ ចាក់កៅស៊ូ និងរោយកម្ទេចថ្មតាមលក្ខណៈបច្ចេកទេស។ ដូច្នេះរាល់ពេលធ្វើដំណើរឆ្លងកាត់ត្រូវមានការប្រុងប្រយ័ត្នខ្ពស់ បង្ការកុំឱ្យមានគ្រោះថ្នាក់ដោយយថាហេតុ និងត្រូវពាក់ម៉ាស មួក ឬកន្សែងការពារធូលីដីហុយពេលធ្វើដំណើរដោយកង់ឬម៉ូតូ។ ក្នុងនាមស្ថាប័នជំនាញអាជ្ញាធរជាតិអប្សរាសូមការអធ្យាស្រ័យ និងការយោគយល់ពីសំណាក់បងប្អូនប្រជាពលរដ្ឋ ក៏ដូចជាភ្ញៀវទេសចរទាំងអស់ចំពោះផលលំបាកតិចតួច ដែលបង្ករឡើងពីការស្ថាបនាផ្លូវនេះ។ ក្នុងពេលឆាប់ៗបន្ទាប់ពីចាក់កៅស៊ូរួចរាល់ទាំងស្រុងផ្លូវនេះនឹងបាត់ហុយ ហើយក្លាយជាផ្លូវមួយដ៏ល្អសម្រាប់ការធ្វើដំណើរ ងាយស្រួលក្នុងការទស្សនាប្រាង្គប្រាសាទប្រកបដោយផាសុខភាព៕









ឆ្នាំ២០១៧ ក្រុមការងារលេខាធិការដ្ឋានសហគមន៍អាជ្ញាធរជាតិអប្សរាចានអនុញ្ញាតឱ្យប្រជាពលរដ្ឋ ក្នុងតំបន់អង្គរសាងសង់និងជួសជុលតូចតាចចំនួន៤៧៥ករណី

ផ្សាយនៅថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៨

នាព្រឹកថ្ងៃពុធ ១២កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស២៥៦១ ត្រូវនឹងថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៨ **ឯកឧត្តមបណ្ឌិត ស៊ុំ ម៉ាប់** អគ្គនាយកអាជ្ញាធរជាតិអប្សរា បានដឹកនាំប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៧ និងលើកទិសដៅការងារឆ្នាំ២០១៨នៃក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរា។

កិច្ចប្រជុំនេះធ្វើឡើងដើម្បីពិនិត្យជាក់ស្តែងលើលទ្ធផលការងារនាឆ្នាំ២០១៧ និងធ្វើការកែសម្រួលសមាសភាពក្រុមការងារ ការអនុវត្តការងារ ការដោះស្រាយសំណើរ និងសំណូមពរផ្សេងៗ បញ្ហាប្រឈម ព្រមទាំងលើកទិសដៅថ្មី។

ឯកឧត្តមបណ្ឌិត ស៊ុំ ម៉ាប់ បានឱ្យដឹងថា ភារកិច្ចសំខាន់របស់ក្រុមការងារសហគមន៍ត្រូវផ្តោតសំខាន់លើការយកចិត្តទុកខ្ពស់ចំពោះសហគមន៍ប្រជាពលរដ្ឋ ក្នុងតំបន់អង្គរតាមរយៈការចុះសួរសុខទុក្ខ ការផ្សព្វផ្សាយអំពីគុណតម្លៃអង្គរ សិទ្ធិអាទិភាពរបស់ប្រជាពលរដ្ឋក្នុងតំបន់ សកម្មភាពមនុស្សធម៌ ការលើកស្ទួយជីវភាពប្រចាំថ្ងៃរបស់ប្រជាជន និងការអប់រំចំណេះដឹងទូទៅ អនាម័យ បរិស្ថានជាដើម ពិសេសគឺដោះស្រាយសំណើរផ្សេងៗ ទាក់ទងនឹងការសុំសាងសង់ឬជួសជុលតូចធំដែលកំពុងប្រឈមខ្លាំងក្នុងតំបន់អង្គរ។

ឯកឧត្តមបណ្ឌិត ស៊ុំ ម៉ាប់ ក៏បានកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ក្រុមការងារទាំងអស់ដើម្បីតម្លៃនៃអង្គរ និងជំរុញឲ្យក្រុមការងារបន្តយកចិត្តទុកដាក់និងអនុវត្តការងារឱ្យ មានប្រសិទ្ធភាពខ្ពស់ធ្វើយ៉ាងណាបំពេញបាននូវតម្រូវការរបស់បងប្អូនប្រជាពលរដ្ឋ។ ជាពិសេសក្រុមការងារត្រូវពន្លឿនការចុះពិនិត្យសំណើរបស់ប្រជាពលរដ្ឋដល់មូលដ្ឋាន និងត្រូវអនុញ្ញាតនៅនឹងកន្លែងក្នុងករណីចាំបាច់។

ទាក់ទងនឹងកិច្ចការនេះ តាមរបាយការណ៍លេខាធិការដ្ឋានក្រុមការងារសហគមន៍បានឱ្យដឹងពីការចុះពិនិត្យសំណង់នាឆ្នាំ២០១៧នេះថាបានអនុញ្ញាតឱ្យសាងសង់ និងជួសជុលតូចតាចបានចំនួន៤៧៥ករណី លើគោលដៅចំនួន៥គឺ ស្រុកប្រាសាទបាគង អនុញ្ញាត៦៨ករណី ស្រុកអង្គរធំ៧ករណី ស្រុកពួក១០១ករណី ក្រុងសៀមរាប២២០ករណី និងស្រុកបន្ទាយស្រី៧៩ករណី។ បើគិតពីស្ថិតិការអនុញ្ញាតនិងសាងសង់តូចតាចរយៈពេល៥ឆ្នាំ ពីឆ្នាំ២០១៣ ដល់២០១៧ គឺក្រុមការងារសហគមន៍បានអនុញ្ញាតដល់ប្រជាពលរដ្ឋបាន១២០៤ករណីហើយ។









ជនសង្ស័យកាប់បំផ្លាញសិវលិង្គចំនួន៦នៅភ្នំគូលែនត្រូវបានចាប់មកផ្តន្ទាទោសហើយ!

ផ្សាយនៅថ្ងៃទី ៣០ ខែ មីនា ឆ្នាំ២០១៨

ជនសង្ស័យចំនួនពីររូបក្នុងចំណោមគ្នាបីនាក់ ត្រូវបានមន្ត្រីប៉ូលិសជំនាញព្រហ្មទណ្ឌ កម្រិតស្រាលខេត្តសៀមរាប ស៊ើបអង្កេតដឹងតាមចម្លើយសារភាពថា ជាអ្នកបានវាយបំផ្លាញចម្លាក់សិវលិង្គនៅ បាតស្នឹងលិង្គមួយពាន់នៃរមណីយដ្ឋានភ្នំគូលែនកាលពីថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៨។

ជនសង្ស័យទាំងពីររូបនេះត្រូវបានបញ្ជូនទៅកាន់សាលាដំបូងខេត្តសៀមរាប ដើម្បីចាត់ការតាមនីតិវិធីច្បាប់កាលពីរសៀលថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៨។ ជនសង្ស័យទី១មាន **ឈ្មោះ សារឿន យ៉ុត** ភេទប្រុស អាយុ២១ឆ្នាំ មុខរបរមិនពិតប្រាកដ រស់នៅភូមិអន្លង់ធំ ឃុំខ្នងភ្នំ ស្រុកស្វាយលើ ខេត្តសៀមរាប។ ជនសង្ស័យទី២ **ឈ្មោះ ព្រឹង ម៉ៅ** ភេទប្រុស អាយុ១៨ឆ្នាំ មុខរបរព្រឹនរូបថត រស់នៅភូមិព្រះអង្គធំ ឃុំខ្នងភ្នំ ស្រុកស្វាយលើ ខេត្តសៀមរាប។ រីឯជនសង្ស័យទី៣ **ឈ្មោះ រុន** រស់នៅស្រុកជាមួយគ្នា បានរត់គេចខ្លួន ហើយសមត្ថកិច្ចកំពុងស្រាវជ្រាវដើម្បីនឹងចាប់យកមកផ្តន្ទាទោសដូចគ្នាចំពោះទង្វើបំផ្លាញបេតិកភណ្ឌឥតស្គាល់ពីតម្លៃនៃសម្បត្តិវប្បធម៌ដូនតា។ បើតាមចម្លើយសារភាពពីជនសង្ស័យឥតស្រឡាញ់សម្បត្តិជាតិទាំងនេះ ពួកគេបានប្រើដាវសាម៉ូរ៉ៃដាប់បំផ្លាញសិវលង្គទាំង៦ពិតប្រាកដមែន។ ក្នុងនោះដែរ សមត្ថកិច្ចដកហូតដាវបានចំនួន៣ដើមដើម្បីរក្សាទុកធ្វើជាភស្តុតាង។

តាមការបញ្ជាក់ពី **លោកបណ្ឌិត ឈាន រដ្ឋា** ប្រធានស្តីទីនាយកដ្ឋានអភិរក្ស ប្រាសាទក្រៅឧទ្យានអង្គរ នារសៀលថ្ងៃទី២៩ មីនា ឆ្នាំ២០១៨បានឱ្យដឹងថា ក្រុមការងារបានឃើញភាពខុសប្រក្រតី នៃសិវលិង្គពេលដើរល្បាតនៅព្រឹកថ្ងៃទី១៨ មីនា ឆ្នាំ២០១៨ ហើយក៏បានរៀបចំដាក់ពាក្យបណ្តឹងទៅតាមនីតិវិធី ដើម្បីស្វែងរកអ្នកប្រព្រឹត្តយកមកផ្តន្ទាទោសទៅតាមច្បាប់។ ពេលនេះជនសង្ស័យទាំងនោះត្រូវបានចាប់ខ្លួនបាន២នាក់ហើយ រង់ចាំការសាកសួរទៅតាមនីតិវិធីច្បាប់បន្តទៀត ហើយម្នាក់ទៀតសមត្ថកិច្ចកំពុងតាមចាប់ខ្លួន។

លោកបញ្ជាក់ទៀតថា សិវលិង្គដែលជនសង្ស័យបានលួចដាប់បំផ្លាញនៅបាតស្នឹងលិង្គមួយពាន់លើភ្នំគូលែន មានចំនួន៦។ ក្នុងនោះសិវលិង្គចំនួន៣ត្រូវបានជនល្មើសដាប់យកចេញ និងបានកាប់សិវលិង្គចំនួន៣ទៀត តែមិនទាន់ដាច់ចេញពីដើងទម្រនៅឡើយ។

អាជ្ញាធរជាតិអប្សរានឹងពង្រឹងសមត្ថកិច្ចការពាររបស់ខ្លួន ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធផ្សេងៗឱ្យបានល្អជាងមុន ព្រមទាំងបង្ហាបចំណេះដឹងស្តីពីតម្លៃនៃបេតិកភណ្ឌដល់ប្រជាជនក្នុងតំបន់ ពិសេសគឺយុវជនជំនាន់ក្រោយដែលជាសរសៃទ្រូងដ៏សំខាន់សម្រាប់ការពារថែរក្សា អភិរក្សមរតកវប្បធម៌បន្តពីអ្នកជំនាន់មុន។ ប្រជាជនទាំងអស់ក៏ជ្រួតជ្រាប ហើយសន្យាចូលរួម និងអប់រំកូនចៅខ្លួនឱ្យយកចិត្តទុកដាក់ ថែរក្សាសម្បត្តិដូនតាឱ្យបានគង់វង្ស។

អាជ្ញាធរជាតិអប្សរាសូមម្តែងនូវការសោកស្តាយជាខ្លាំងចំពោះការបាត់បង់នូវសម្បត្តិ បេតិកភណ្ឌវប្បធម៌ដ៏មានតម្លៃនៅលើភ្នំគូលែន។ មិនតែប៉ុណ្ណោះ ទីតាំងសិវលិង្គនេះ ក៏ជាទីសក្ការៈដ៏សក្តិសិទ្ធិក្នុងជំនឿសុំទឹកមន្តរបស់ប្រជាជនខ្មែរផងដែរ។ យើងសូមថ្កោលទោសយ៉ាងដាច់ខាត ចំពោះជនឥតស្គាល់អត្តសញ្ញាណជាតិដែលដាច់ចិត្តលើកដៃបំផ្លាញសម្បត្តិពាន់ឆ្នាំទាំងនេះឱ្យខូចខាតនិងបាត់បងរូបភាពដើម។

នេះជាការសោកស្តាយណាស់ ក្នុងនាមជាកូនខ្មែរគ្រប់រូប ត្រូវចូលរួមលើកតម្លៃ សិក្សាស្រាវជ្រាវ និងថែរក្សាសម្បត្តិជាតិទាំងអស់ឱ្យបានល្អប្រសើរ ជាជាងការបំផ្លាញ រហូតបាត់បង់ ទើបស្តាយក្រោយ៕









ចម្លាក់តោនៅប្រាសាទក្រ៉ាន់ចំនួនមួយត្រូវបានតម្កល់ទុកនៅកន្លែងដើមវិញ ក្រោយជួសជុលអស់ រយៈពេលមួយឆ្នាំ

ផ្សាយនៅថ្ងៃទី ៣០ ខែ មីនា ឆ្នាំ២០១៨

ក្រុមអ្នកជំនាញអភិរក្សថ្ម នៃនាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរនិងបុរាណវិទ្យា បង្ការបស់អាជ្ញាធរជាតិអប្សរា បានធ្វើការជួសជុលចម្លាក់តោ ចំនួនមួយនៅប្រាសាទក្រ៉ាន់ ស្ថិតក្នុងភូមិក្រ៉ាន់ សង្កាត់នគរធំ ក្រុងសៀមរាប រួចរាល់ជាស្ថាពរហើយ។

លោក រីក រ៉ែត អ្នកជំនាញអភិរក្សថ្មនៃអាជ្ញាធរជាតិអប្សរាបានលើកឡើងថា ចម្លាក់តោថ្មនេះ មុនការជួសជុលមានសភាពទ្រុឌទ្រោម បែកបាក់រូបរាងជាកំណាត់តូចធំនៅលើដីមុខប្រាសាទ។ កាលពីសម័យបារាំង ចម្លាក់តោនេះត្រូវបានអ្នកជំនាញបារាំងជួសជុលម្តងរួចហើយ តែការជួសជុលនោះ គ្រាន់តែយកស៊ីម៉ង់ត៍និងដែកមកប្រើបិទភ្ជាប់ឱ្យមានលំនឹងអាចឈរបានប៉ុណ្ណោះ ប៉ុន្តែក្រោយមកវាក៏បានបែកបាក់ជាបន្តបន្ទាប់តាមអាយុកាលស៊ីម៉ងត៍។

លោក រ៉ែត បន្តទៀតថា ដូច្នេះដើម្បីលើកតម្លៃមរតកអង្គរនិងចម្លាក់តោដែលរងនូវការខូចនេះ ក្រុមអ្នកជំនាញអភិរក្សថ្មបានជ្រើសរើសចម្លាក់តោមួយក្នុងចំណោមតោទាំង៥នៃប្រាសាទក្រ៉ាន់ដើម្បីជួសជុលសាកល្បង មុននឹងឈានទៅដល់ការជួសជុលចម្លាក់តោដទៃទៀតនៅប្រាសាទនេះ។

ក្នុងការជួសជុល ក្រុមការងារក៏បានប្រើបច្ចេកទេសជួសជុលសមស្របទៅតាមបទដ្ឋានដែលអាចធានាបាននូវលក្ខណៈដើម និងសុវត្ថិភាពយូរអង្វែងនៃចម្លាក់។ រីឯបច្ចេកទេសនិងការជួសជុលក៏ ត្រូវបានទទួលស្គាល់ដោយអ្នកជំនាញការអាដហុករបស់គណៈកម្មការអាយស៊ីស៊ី-អង្គរផងដែរ។

សម្រាប់ពេលវេលាក្នុងការជួសជុល ក្រុមការងារបានចំណាយពេលអស់១ឆ្នាំ គឺចាប់ពីខែឧសភាឆ្នាំ២០១៧ ដល់ខែមីនា ឆ្នាំ២០១៨ ដើម្បីរក្សាបាននូវតម្លៃ លក្ខណៈដើម និងភាពល្អប្រសើរនៃចម្លាក់ ដោយសិក្សាលម្អិតពីរចនាបថជើងចម្លាក់តោដទៃៗនៅតាមបណ្តាប្រាសាទមួយចំនួនដែលបានកសាងក្នុងរជ្ជកាលតែមួយគ្នាមកធ្វើការប្រៀបធៀបគ្នា ថាតើត្រូវរើសយករចនាបថជើងតោណាមួយមកធ្វើជាគំរូក្នុងការឆ្លាក់ ដើម្បីតភ្ជាប់នឹងខ្លួនចម្លាក់សត្វតោនៅប្រាសាទក្រ៉ាន់។

បច្ចុប្បន្នចម្លាក់តោត្រូវបានអ្នកជំនាញជួសជុលរួចរាល់ហើយ ហើយក៏បានយកមកតម្កល់ទុកនៅទីតាំងដើមខាងមុខប្រាសាទវិញ ក្នុងន័យអភិរក្សថែរក្សាមរតកដូនតាដែលជាសម្បត្តិបេតិកភណ្ឌជាតិ និងដាក់បង្ហាញជូនភ្ញៀវទេសចរជាតិ និងអន្តរជាតិទស្សនាឡើងវិញ។






នាយកដ្ឋានផ្សព្វផ្សាយ
www.apsaraauthority.gov.kh


នាយកដ្ឋានផ្សព្វផ្សាយ
www.apsaraauthority.gov.kh

ព្រឹត្តិការណ៍ព័ត៌មាន
ប្រចាំខែមេសា

ផ្នែកទី ៤
ប្រចាំខែមេសា

សកម្មភាពរៀបចំព្រឹត្តិការណ៍អង្គរសង្ក្រាន្តឆ្នាំថ្មី ឆ្នាំច សំរឹទ្ធស័ក ព.ស. ២៥៦២

ផ្សាយនៅថ្ងៃទី ០២ ខែ មេសា ឆ្នាំ២០១៨

នាឱកាសឆ្នាំចាស់ ផ្លាស់ចូលឆ្នាំថ្មីប្រពៃណីខ្មែរជិតឈានចូលមកដល់ ក្រុមការងារផ្សេងនៃសហភាពសហព័ន្ធយុវជនកម្ពុជា ដែលដឹកនាំដោយ **ឯកឧត្តម ហ៊ុន ម៉ានី** កំពុងតែប្រញាប់ដៃប្រញាប់ជើងអនុវត្តការងាររបស់ខ្លួនយ៉ាងសស្រាក់សស្រាំ ដើម្បីចូលរួមអបអរសាទរទទួលទេវតាឆ្នាំថ្មី ឆ្នាំច សំរឹទ្ធស័ក ព.ស.២៥៦២ នៅលើទឹកដីអង្គរដ៏ពិសិដ្ឋ។ អាជ្ញាធរជាតិអប្សរាក្នុងនាមជាដៃគូសហការមួយក្នុងចំណោមដៃគូសហការជាច្រើនទៀតនៃសហភាពសហព័ន្ធយុវជនកម្ពុជា ក៏បានបំពេញការងាររបស់ខ្លួនយ៉ាងមមាញឹកផងដែរ។

រូបភាពសកម្មភាពក្រុមការងារកំពុងរៀបចំនូវកម្មវិធីជាច្រើននៃព្រឹត្តិការណ៍អង្គរសង្ក្រាន្តតាមទីតាំងនីមួយៗ ទាំងនៅមុខប្រាសាទអង្គរវត្តនិងប្រាសាទបាយ័នមានដូចខាងក្រោម៖









ព្រះពុទ្ធបដិមាទ្រង់អភ័យមុទ្រៈចំនួន២អង្គនៅប្រាសាទប្រែរូបកំពុងទទួលបានការជួសជុល

ផ្សាយនៅថ្ងៃទី ០២ ខែ មេសា ឆ្នាំ២០១៨

អ្នកជំនាញខ្មែរខាងអភិរក្សថ្ម នៃនាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរ និងបុរាណវិទ្យាបង្ការរបស់អាជ្ញាធរជាតិអប្សរា សហការជាមួយស្ថាប័ន GIZ កំពុងដំណើរការជួសជុលចម្លាក់ ព្រះពុទ្ធបដិមាចំនួនពីរអង្គ ស្ថិតនៅប្រាង្គកណ្តាលនៃប្រាសាទប្រែរូប។

សភាពនៃព្រះពុទ្ធបដិមាពីរអង្គ គឺបានបាត់បង់ព្រះកេស ព្រះហស្តទាំងស្រុង និងជាច់ត្រឹមកជើង។ បដិមាព្រះពុទ្ធទាំងនេះធ្វើអំពីថ្មកក់ ក្នុងរចនាបទបាយ័ន ទ្រង់ឈរក្នុងកាយវិការអភ័យមុទ្រៈលម្អដោយខ្នុកនិងម្រ័ក្សណ៍ និងមានក្បាច់បិទលម្អដោយគ្រឿងសិប្បីសត្វថែមទៀត។

តាមលក្ខណៈសម្គាល់ខាងផ្នែកក្បាច់លម្អនិងរចនាបថ បង្ហាញថាព្រះពុទ្ធរូបទាំងពីរអង្គនេះប្រហែលជាធ្វើឡើងក្នុងសម័យកណ្តាល (ស.វទី១៥-១៦) ជាសម័យដែលខ្មែរងាកមកគោរពព្រះពុទ្ធសាសនាថេរវាទវិញ ត្បិតប្រាសាទនេះដើមឡើយគឺសាងឧទ្ទិសដល់ព្រហ្មញ្ញសាសនា។ បច្ចុប្បន្នមានប្រជាជននៅជុំវិញទីនេះ តែងតែមកបន់ស្រន់សុំទឹកភ្លៀង និងបានហៅឈ្មោះពុទ្ធបដិមាទាំងពីរអង្គនេះថាលោកតាសៅ។

លោក ឡុង ណារី ប្រធានគម្រោងជួសជុលបញ្ជាក់ថា គេពុំបានដឹងច្បាស់លាស់ពីពេលវេលា និងមូលហេតុដែលព្រះពុទ្ធបដិមាទាំងពីរអង្គនេះមានការខូចខាតដោយសារអ្វីឡើយ។ ផ្នែកតាមស្លាកស្នាមជាក់ស្តែង ចម្លាក់ពុទ្ធបដិមាទាំងពីរអង្គនេះគឺត្រូវបានជួសជុលម្តងរួចទៅហើយ ប្រហែលជានៅសតវត្សរ៍ទី១៦ ដែលគេប្រើដែកស្នូលមានរាងជ្រុងសម្រាប់តភ្ជាប់ ខុសពីការជួសជុលនៅសម័យបារាំងដែលប្រើស្ពាន់និងដែកសសៃមូល។ ម្យ៉ាងទៀតការជួសជុលសម័យនោះ គេប្រើថ្មថ្មីជំនួសកន្លែងដែលបាត់បង់ និងផ្នែកខ្លះបានប្រើប្រាស់ឈើតភ្ជាប់ជាមួយថ្មបន្ទាប់មកលាបម្រ័ក្សណ៍ពីលើដើម្បីលម្អ។

លោកបានបន្ថែមថា ក្រុមការងារនឹងយកសារធាតុម្រ័ក្សណ៍នេះទៅពិសោធនៅមន្ទីរពិសោធន៍របស់ប្រទេសកូរ៉ែ ដើម្បីឱ្យដឹងពីសមាសធាតុផ្សំថាមានអ្វីខ្លះ។ ចំពោះបច្ចេកទេសនៃការជួសជុលទៀតសោត ក្រុមការងារនឹងរៀបចំតបំណែកបាក់បែករបស់ ព្រះពុទ្ធរូប អភិរក្សក្បាច់ និងគ្រឿងលម្អដទៃដោយប្រើបច្ចេកទេសបុរាណ គួបផ្សំនឹងការប្រើសម្ភារៈថ្មីៗមួយចំនួនដូចជាការបិទ បាយអរ ថ្មកក់ ដើម្បីពង្រឹងមុខតំណារ ពង្រឹងស្នាមប្រេះ និងលាងសម្អាតធូលីដី មុនឈានដល់ការផ្គុំឡើងវិញហើយជួសជុល។ ក្នុងករណីដែលស្រាវជ្រាវរកព្រះកេសនិងព្រះហស្តនៃពុទ្ធបដិមាទាំងពីរអង្គមិនឃើញ ក្រុមការងារនឹងនៅតែបន្តឱ្យពុទ្ធបដិមា ទ្រង់គង់ឈរឡើងវិញដើម្បីឱ្យប្រជាជនបានគោរពបូជាជាប្រក្រតីនៅពេលខ្លីខាងមុខ។

លោក Sebastian Kerridge អ្នកសម្របសម្រួលកិច្ចការបច្ចេកទេសនៃស្ថាប័ន GIZ បញ្ជាក់ថា ពួកយើងជាអ្នកគាំទ្រគម្រោង អភិរក្សថ្ម តាមរយៈការជួយបណ្តុះបណ្តាលធនធានមនុស្សរបស់ អាជ្ញាធរជាតិអប្សរាអស់រយៈពេលជាច្រើនឆ្នាំមកហើយ។ គម្រោងនេះ យើងបានបណ្តុះបណ្តាលអ្នកជំនាញខ្មែរបានជាច្រើនរូបលើការងារជួសជុលនិងអភិរក្សថ្ម ហើយបច្ចុប្បន្នអ្នកជំនាញទាំងនេះកំពុងបំពេញការងារដោយផ្ទាល់ខ្លួនរបស់ពួកគេក្នុងអង្គភាពអាជ្ញាធរជាតិអប្សរា។ នេះលទ្ធផលល្អប្រសើរដែលយើងចង់ឃើញប្រជាជនខ្មែរបំពេញការងារអភិរក្សជួសជុលប្រាសាទខ្មែរ ដោយស្មាដៃរបស់ពួកគេផ្ទាល់។ យើងសង្ឃឹមថា ចំណេះដឹងនេះនឹងបន្តផ្ទេរដល់អ្នកជំនាញក្មេងៗជំនាន់ក្រោយដែលនឹងបន្តវេននាពេលអនាគត។

ជាចុងក្រោយ **លោក ឡុង ណារី** ក៏បានសំណូមពរដល់ប្រជាជនទាំងអស់ដែលមានជំនឿ និងស្រលាញ់មរតកដូនតា គួរតែលើកតម្លៃព្រះពុទ្ធសាសនា ពេលមកអុជធូប ទៀន ស្រោចទឹក ឬបាញ់ទឹកអប់ជាដើម សូមមេត្តាកុំឱ្យប៉ះពាល់ដល់រាល់បុរាណវត្ថុ ព្រោះគ្រឿងក្រអូបផ្សែងកម្តៅទាំងអស់នេះមានផ្ទុកសារជាតិបង្កឱ្យមានបញ្ហាដល់បដិមា៕









អាជ្ញាធរជាតិអប្សរា និងសាមគ្គីសិល្បៈអាស៊ី ហ្គឺមេ ចុះអនុស្សរណៈលើការបណ្តុះបណ្តាលនិងចងក្រងពាក្យសិល្បៈ និងបេតិកភណ្ឌ

ផ្សាយនៅថ្ងៃទី ០៣ ខែ មេសា ឆ្នាំ២០១៨

នៅព្រឹកថ្ងៃចន្ទ ២រោច ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស២៥៦១ ត្រូវនឹងថ្ងៃទី២ ខែមេសា ឆ្នាំ២០១៨ នាស្នាក់ការអាជ្ញាធរជាតិអប្សរា មានរៀបចំពិធីចុះអនុស្សរណៈ យោគយល់គ្នារវាងអាជ្ញាធរជាតិអប្សរា និងសាមគ្គីសិល្បៈអាស៊ីហ្គឺមេប្រទេសបារាំង។ អនុស្សរណៈនេះ ធ្វើឡើងក្នុងបំណងដើម្បីបណ្តុះបណ្តាលអ្នកជំនាញខ្មែរ និងរៀបចំចងក្រងវាក្យសព្ទបេតិកភណ្ឌ ដែលទាក់ទងក្នុងសិល្បៈវប្បធម៌ខ្មែរ។

ពិធីចុះអនុស្សរណៈធ្វើឡើងរវាងតំណាងអាជ្ញាធរជាតិអប្សរា **ឯកឧត្តម ហង់ ពៅ** អគ្គនាយករង និង**លោកស្រី** Sophie Makariou ប្រធានសាមគ្គីសិល្បៈអាស៊ី ហ្គឺមេ ដែលជាសាមគ្គីដែលតម្កល់វត្ថុសិល្បៈខ្មែរច្រើនជាងគេលើពិភពលោក។ គោលបំណងសំខាន់ៗនៃអនុស្សរណៈនេះគឺ ដើម្បីបណ្តុះបណ្តាលអ្នកជំនាញរបស់អាជ្ញាធរជាតិអប្សរាបន្ថែមលើការស្វែងយល់អំពីអត្តសញ្ញាណនៃរចនាបទសិល្បៈខ្មែរ និង ចងក្រងវាក្យសព្ទនៃសិល្បៈនិងបេតិកភណ្ឌខ្មែរ ដែលឯកសារនេះនឹងរៀបរៀងជា៣ភាសាមានខ្មែរ បារាំង និងអង់គ្លេស។

តាមផែនការ សារមន្ទីរហ្គីមេនឹងបញ្ជូនអ្នកជំនាញរបស់ខ្លួនមកបណ្តុះបណ្តាលមន្ត្រីអាជ្ញាធរជាតិអប្សរាអំពីជំនាញខាងលើចាប់ពីខែ មិថុនាតទៅ។ ទោះជាយ៉ាងនេះក្តី នេះមិនមែនជាកិច្ចសហប្រតិបត្តិការលើកដំបូងរវាងស្ថាប័នទាំងពីរឡើយពោលសារមន្ទីហ្គីមេធ្លាប់បានបណ្តុះបណ្តាល មន្ត្រីជាន់ខ្ពស់អាជ្ញាធរជាតិអប្សរាចំនួន០២រូបអំពីការគ្រប់គ្រងទូទៅនៃសារមន្ទីរការអភិរក្សវាយនភណ្ឌនិងចំណេះដឹងបែបវិទ្យាសាស្ត្រស្តីពីការដាក់តាំងបង្ហាញសមុច្ចយ។






អាជ្ញាធរជាតិអប្សរានិងអង្គការមូលនិធិបុរាណវិទ្យានិងអភិវឌ្ឍន៍ (ADF) ធ្វើកំណាយសង្ត្រោះលើធីតាំងបុរាណមួយកន្លែងនៅលើខ្លងភ្នំគូលែន

ផ្សាយនៅថ្ងៃទី ០៣ ខែ មេសា ឆ្នាំ២០១៨

អាជ្ញាធរជាតិអប្សរាបានសហការជាមួយស្ថាប័ន ADF ធ្វើកំណាយសង្ត្រោះមួយកន្លែងនៅបុរាណដ្ឋានលើភ្នំគូលែន ដែលគ្រោងនឹងធ្វើផ្លូវឆ្លងកាត់លើកន្លែងនោះ។ គម្រោងកំណាយនេះបានចាប់ផ្តើមកាលពីថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៨ ដើម្បីឱ្យដឹងថាកន្លែងបុរាណដ្ឋាននោះជាកន្លែងអ្វីតាមការពើបប្រទះឃើញថ្មបាយក្រៀមដែលផុសឡើង ហើយចងក្រងទិន្នន័យពីបុរាណដ្ឋាននោះ រក្សាទុកជាឯកសារសម្រាប់សិក្សាទៅថ្ងៃក្រោយ មុននឹងចាប់ផ្តើមសាងសង់ផ្លូវ។ **លោកបណ្ឌិត ឈាន រដ្ឋា** ប្រធានស្តីទីនាយកដ្ឋានអភិរក្សប្រាសាទក្រៅឧទ្យានបានឱ្យដឹងថា ៖ គម្រោងសាងសង់ផ្លូវនេះត្រូវបានអ្នកជំនាញសិក្សាតាំងពីឆ្នាំ២០១៦ ហើយទើបនឹងចាប់ផ្តើមសាងសង់នៅដើមឆ្នាំ ២០១៨នេះ។ ចំពោះផ្លូវដែលកំពុងស្ថាបនានេះមានទទឹងប្រវែង៦ម៉ែត្រ និង៣២គីឡូម៉ែត្រ ដោយគិតចាប់ពីជើងភ្នំស្រុកបន្ទាយស្រី មកដល់ទីប្រជុំស្រុកស្វាយដោយប្រើប្រាស់ថវិកាមូលនិធិអភិរក្សនិងអភិវឌ្ឍតំបន់អង្គរ។

ចំពោះការសាងសង់ផ្លូវទៀតសោត គឺសាងសង់នៅលើផ្លូវចាស់មានស្រាប់ ពោលគឺផ្លូវដែលប្រជាពលរដ្ឋរស់នៅលើខ្នងភ្នំគូលែន ប្រើប្រាស់តាំងពីយូរយារណាស់មកហើយ។ នៅមុនគម្រោងត្រូវបានអនុវត្តអ្នកបុរាណវិទ្យាបានចុះសិក្សាអំពីផលប៉ះពាល់ដល់ផ្នែកវប្បធម៌ប្រវត្តិសាស្ត្រឃើញមានចំនួន៤កន្លែង។ ក្នុងនោះ៣ទីតាំង យើងសាងសង់ផ្លូវរាងបាន លើកលែងតែចំណុចដែលកំពុងធ្វើកំណាយសង្គ្រោះនេះ ជាទីតាំងដែលយើងមិនអាចធ្វើផ្លូវរាងបាន។ ដូច្នេះហើយតាមការចុះទៅពិនិត្យផ្ទាល់ពីអ្នកជំនាញការអាជ្ញាធរជាតិអប្សរានិងអនុសាសន៍នៃគណៈកម្មការអាយស៊ីស៊ី-អង្គរឆ្នាំ២០១៧ បានសម្រេចឱ្យធ្វើកំណាយសង្គ្រោះសិន មុននឹងធ្វើការសាងសង់ផ្លូវថ្មីនេះ ដើម្បីធ្វើយ៉ាងណាបញ្ចៀសនូវផលប៉ះពាល់ឱ្យបានជាអតិបរមា។

ជាចុងក្រោយ **លោកបណ្ឌិត ឈាន រដ្ឋា** ក៏បានសំណូមពរដល់ប្រជាពលរដ្ឋទាំងអស់ កុំឱ្យមានមន្ទិល ភ្ញាក់ផ្អើលចំពោះការធ្វើកំណាយសង្គ្រោះបែបបុរាណវិទ្យាដោយស្ថាប័នទាំងពីរ។ លើសពីនេះទៀត អាជ្ញាធរជាតិអប្សរានឹងខិតខំអភិរក្ស សម្បត្តិបេតិកភណ្ឌជាតិនៅលើខ្នងភ្នំគូលែន ដើម្បីឱ្យបេតិកភណ្ឌទាំងនោះទទួលបាននូវការគាំពារ និងអភិរក្សពិតប្រាកដ រួមទាំងចូលរួមលើកតម្លៃសេដ្ឋកិច្ចប្រជាពលរដ្ឋ តាមរយៈវិស័យទេសចរណ៍។ ជាពិសេសទៀតនោះ លោកបណ្ឌិត បានបញ្ជាក់បន្ថែមថា ភ្នំគូលែនគឺជារមណីយដ្ឋានវប្បធម៌ ប្រវត្តិសាស្ត្រនិងធម្មជាតិ ហើយនឹងអាចក្លាយជាសម្បត្តិបេតិកភណ្ឌពិភពលោកនាពេលអនាគតដ៏ឆាប់ខាងមុខ។ ដូច្នេះ ដើម្បីឱ្យរមណីយដ្ឋាន អាចបញ្ចូលជាសម្បត្តិបេតិកភណ្ឌពិភពលោកបាន សូមប្រជាពលរដ្ឋគ្រប់រូបចូលរួមថែរក្សា អភិរក្សបេតិកភណ្ឌនិងធម្មជាតិទាំងអស់គ្នាឱ្យរក្សាបាននូវតម្លៃជាសាកលដែលជាភាពអស្ចារ្យនៃភ្នំគូលែន៕









អាជ្ញាធរជាតិអប្សរារៀបចំសមាហរណកម្មបុគ្គលិកអចិន្ត្រៃយ៍ជាមន្ត្រីរាជការ

ផ្សាយនៅថ្ងៃទី ០៣ ខែ មេសា ឆ្នាំ២០១៨

ក្រុមការងារនៃគណៈកម្មការសមាហរណកម្មបុគ្គលិកអចិន្ត្រៃយ៍ជា មន្ត្រីរាជការកំពុងរៀបចំលក្ខណៈវិនិច្ឆ័យសម្រាប់ធ្វើការពិនិត្យ និងវាយតម្លៃកម្រិតជំនាញ សមត្ថភាព បទពិសោធន៍ និងអតីតភាពការងាររបស់ បុគ្គលិកអចិន្ត្រៃយ៍របស់អាជ្ញាធរជាតិអប្សរា។

ជាក់ស្តែងនៅថ្ងៃចន្ទ-អង្គារ៍ ២-៣រោច ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស២៥៦១ ត្រូវនឹងថ្ងៃទី២-៣ ខែមេសា ឆ្នាំ២០១៨ **ឯកឧត្តម ជុក មុន្នី** អនុរដ្ឋលេខាធិការ ប្រតិភូក្រសួងមុខងារសាធារណៈបានដឹកនាំក្រុមការងារចុះត្រួតពិនិត្យផ្ទាល់ និងផ្ទៀងផ្ទាត់ឯកសារពាក់ព័ន្ធនានា ព្រមទាំងជួបសម្ភាសន៍ដោយផ្ទាល់ជាមួយបុគ្គលិកអចិន្ត្រៃយ៍ទាំងនោះ។ តាមការបញ្ជាក់ពី **ឯកឧត្តម ជុក មុន្នី** ការជួបប្រាស្រ័យផ្ទាល់ជាមួយបុគ្គលិកអចិន្ត្រៃយ៍ពាក់ព័ន្ធទាំងអស់គឺមានសារៈសំខាន់ណាស់ ព្រោះចាំបាច់ត្រូវតែអនុវត្តការងារប្រកបដោយតម្លាភាព ទទួលយកបានគ្រប់ភាគីពាក់ព័ន្ធ ហើយអ្នកត្រូវចូលជាមន្ត្រីរាជការស៊ីវិល អ្នកនោះត្រូវតែបំពេញនូវគ្រប់លក្ខណៈទាំងអស់ដែលមានចែងក្នុងសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា។

សូមបញ្ជាក់ថា គណៈកម្មការនេះមានសមាសភាពចម្រុះមកពីក្រសួងស្ថាប័នពាក់ព័ន្ធមួយចំនួន ហើយបានបង្កើតឡើងតាំងពីថ្ងៃចន្ទ ៦កើត ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស២៥៦១ ត្រូវនឹងថ្ងៃទី២២ ខែមករា ឆ្នាំ២០១៨ មកម្ល៉េះ៕






អាជ្ញាធរជាតិអប្សរា៖ ពុំមានប្រាសាទថ្មីដែលត្រូវបានរកឃើញនៅស្រុកខាទិន ខេត្តសៀមរាបទេ!

ផ្សាយនៅថ្ងៃទី ០៤ ខែ មេសា ឆ្នាំ២០១៨

កាលពីថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៨ កន្លងមក មានការសែតមួយចំនួនបានចុះផ្សាយថា «អ្នកជំនាញបុរាណវិទ្យាបង្ហាញស្នាមញញឹម ខណៈដែលកាលពីពេលថ្មីៗនេះ បានរកឃើញវត្តមានប្រាសាទថ្មីឈ្មោះ "ចន្ទគីរី"» ស្ថិតក្នុងភូមិគោកចាន់ ឃុំល្វាក្រាំងស្រុកវ៉ារិនខេត្តសៀមរាប។

លោកបណ្ឌិត ឈាន រដ្ឋា ប្រធានស្តីនាយកដ្ឋានអភិរក្សប្រាសាទក្រៅឧទ្យានអង្គរនៃអាជ្ញាធរជាតិបានបញ្ជាក់ថា៖ ការលើកឡើងនោះជារឿងមិនពិតឡើយ។ តាមពិតទៅ ប្រាសាទនោះមានឈ្មោះថា «ប្រាសាទ តាឡី» បានចុះក្នុងបញ្ជីសារពើភណ្ឌប្រាសាទអស់ទៅហើយ។ ប្រាសាទនេះធ្លាប់បានស្រាវជ្រាវនិងចងក្រងជាឯកសារអំពីឈ្មោះ ប្រវត្តិ និងទីតាំង ដោយជនជាតិបារាំង **លោក LUNET DE LA JONQUIÈRE** នៅឆ្នាំ១៩១១។

ក្រោយមក ក្រសួងវប្បធម៌និងវិចិត្រសិល្បៈបានសហការជាមួយសាលាបារាំងចុងបូព៌ា បានចុះធ្វើបញ្ជីសារពើភណ្ឌបុរាណវិទ្យាប្រទេសកម្ពុជា ខេត្តសៀមរាប បោះពុម្ពនៅខែធ្នូ ឆ្នាំ២០១១ ក៏បានបញ្ជាក់យ៉ាងច្បាស់ថា៖ ប្រាសាទតាឡីស្ថិតក្នុងភូមិគោកចន្ទ ឃុំល្វាក្រាំង ស្រុកវ៉ារិន ខេត្តសៀមរាប ស្ថិតនៅចម្ងាយ១៥គីឡូម៉ែត្រពីប្រាសាទភូមិប្រាសាទ។ ប្រាសាទនេះមានកំពែងពីរ។ ក្នុងនោះលក្ខណៈសំខាន់ៗនៃប្រាសាទរួមមាន៖ ប៉មមួយមានរាងបួនជ្រុងស្មើធ្វើពីថ្មបាយក្រៀមបែរមុខទៅកើត មានយ៉ាធ្វើពីឥដ្ឋអមដោយបង្អួចពីរធ្វើពីថ្មបាយក្រៀម។ ប៉មនេះមានទ្វារបញ្ឆោតនៅមុខបីផ្សេងទៀត។ ហោត្រ័យមួយធ្វើពីថ្មបាយក្រៀម ដំបូលពីឥដ្ឋបែរមុខទៅលិច មានយ៉និងស៊ុមទ្វារធ្វើអំពីថ្មកក់ ស្ថិតនៅជ្រុងអាគ្នេយ៍។ ថែវមួយធ្វើពីថ្មបាយក្រៀមមានសសរធ្វើពីថ្មកក់ខាងក្នុង។ ខ្លោងទ្វារកំពែងពីរមានច្រកចូលមួយ ស្ថិតនៅខាងលិចនិងខាងកើត។ ខ្លោងទ្វារកំពែងបញ្ឆោតពីរធ្វើពីថ្មបាយក្រៀមស្ថិតនៅខាងជើងនិងខាងត្បូង។ ខ្លោងទ្វារនេះមានដំបូលធ្វើពីឥដ្ឋដែរ។ ហោបន្ទាត់ទ្រូងមួយមានទ្វារចំហៀងនិងខ្លោងទ្វារកំពែងមួយធ្វើពីឥដ្ឋ។ កំពែងទីពីរនិងខ្លោងទ្វារកំពែងមួយធ្វើពីថ្មបាយក្រៀមមានច្រកបី។ ខ្លោងទ្វារនេះមានបន្ទប់កណ្តាលមួយនិងបន្ទប់អមពីរបែរទៅកើតនិងទៅលិច។ ស្រះតូចមួយមានគែមលម្អរពីថ្មបាយក្រៀមស្ថិតនៅឦសាន។ នៅខាងកើតប្រាសាទមានបារាយពីរ។ ស្រះពីរស្ថិតនៅបន្តបន្ទាប់គ្នាខាងកើត។

លោក រដ្ឋា បន្តទៀតថា ចំពោះការហៅឈ្មោះប្រាសាទចន្ទគិរីនោះ គឺប្រហែលអ្នកស្រុកហៅដោយផ្អែកលើឈ្មោះវត្តនិងអាស្រមដែលទើបសាងសង់នាពេលថ្មីៗប៉ុណ្ណោះ ព្រោះមិនមានឈ្មោះនេះឡើយនៅលើទីតាំងដូចគ្នាក្នុងបញ្ជីសារពើភណ្ឌប្រាសាទ។ លើសពីនោះ ការសែតនេះ ក៏មិនបានបញ្ជាក់ពីឈ្មោះនិងតួនាទីរបស់អ្នកបុរាណវិទ្យាណាម្នាក់មកអះអាងដែរ។ ដូច្នេះ សូមស្ថាប័នការសែតនីមួយៗមុននឹងធ្វើការចុះផ្សាយព័ត៌មាន សូមចុះផ្សាយឱ្យបានត្រឹមត្រូវ ដោយសិក្សាឱ្យបានច្បាស់លាស់ចៀសវាងការសរសេរដោយគ្មានមូលដ្ឋានគ្រឹះផ្លូវការនាំឱ្យមានការយល់ច្រឡំ។

បច្ចុប្បន្នក៏ដូចជាកន្លងមក អាជ្ញាធរជាតិអប្សរាក៏បានទៅពិនិត្យមើលស្ថានភាពប្រាសាទនេះតែយើងមិនទាន់មានគម្រោងក្នុងការអភិរក្ស ជួសជុលនៅឡើយដោយសារកត្តាជាច្រើន ហើយក៏មិនបានបោះបង់ប្រាសាទនេះចោលឱ្យនៅឯកាដែរ។ ម្យ៉ាងវិញទៀត ប្រាសាទតាឡី ក៏មិនមានការលួចបំផ្លាញបន្តទៀតដែរ ក្រៅពីភាពទ្រុឌទ្រោមនៃអាយុកាល និងសង្គ្រាម ហើយក៏សង្កេតឃើញថាមានភូមិបានរៀបចំពិធីឡើងគ្រូ បញ្ជាន់អារក្ស សុំទឹកភ្លៀងនៅប្រាសាទតាឡីទៀតផង៕









អាជ្ញាធរជាតិអប្សរាក្រោកធ្វើកំណាយដើម្បីពិនិត្យមើលរចនាសម្ព័ន្ធស្រះអង្គរ ឥតុមុនធ្វើការជួសជុល

ផ្សាយនៅថ្ងៃទី ១០ ខែ មេសា ឆ្នាំ២០១៨

អាជ្ញាធរជាតិអប្សរា នឹងរៀបចំធ្វើកំណាយនៅផ្នែកណាមួយនៃស្រះទឹកខាងជើង និងខាងត្បូងក្នុងប្រាសាទអង្គរវត្ត មុនធ្វើការជួសជុល។ កំណាយនេះគឺដើម្បីពិនិត្យមើលរចនាសម្ព័ន្ធ និងទ្រង់ទ្រាយរបស់ស្រះ មុនអ្នកជំនាញធ្វើការជួសជុលឱ្យស្របតាមលំនាំចាស់និងជៀសវាងផលប៉ះពាល់ណាមួយ។

លោក លី វណ្ណា ប្រធាននាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរ និងបុរាណវិទ្យាបង្ការនៃអាជ្ញាធរជាតិអប្សរា បានថ្លែងឱ្យដឹងថា កំណាយស្រាវជ្រាវបុរាណវិទ្យានេះ ធ្វើឡើងតាមយោបល់អ្នកជំនាញការអាដហុក របស់គណៈកម្មការអាយស៊ីស៊ី-អង្គរ ដែលសុំឱ្យអ្នកជំនាញធ្វើកំណាយមុននឹងជួសជុលនិងកែលំអស្រះទាំងពីររបស់ប្រាសាទអង្គរវត្ត។

តាម **លោក លី វណ្ណា** គម្រោងជួសជុល និងស្តារឡើងវិញនៃស្រះខាងលើ គឺក្នុងបំណងលើកតម្លៃ កែលំអស្រះ ដើម្បីឱ្យទឹកនៅបានយូរ និងរៀបចំច្រាំងស្រះជុំវិញ ដែលកន្លងមកស្រះទាំងនេះបានទាក់ទាញភ្ញៀវទេសចរជាច្រើន ដែលចូលចិត្តផ្តិតទិដ្ឋភាពរបស់ពួកគេជាមួយកំពូលប្រាសាទអង្គរ ដែលឆ្លុះជាមួយទឹកស្រះដ៏ស្រស់ស្អាត។ **លោក លី** វណ្ណាបញ្ជាក់ថា កំណាយនេះនឹងអាចឱ្យអ្នកជំនាញដឹងកាន់តែច្បាស់ពីរចនាសម្ព័ន្ធរបស់ស្រះ ក៏ដូចជាគុណភាពរបស់ថ្ម ថាតើវាត្រូវកែលំអបែបណាបន្ថែមទៀតផងដែរ។

គម្រោងកំណាយស្រាវជ្រាវនៅស្រះអង្គរ គ្រោងធ្វើនៅក្រោយពិធីបុណ្យចូលឆ្នាំប្រពៃណីជាតិ និងប្រើពេលចន្លោះ ពី១ខែកន្លះ ទៅ២ខែ។ អាជ្ញាធរជាតិអប្សរា តាមរយៈនាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរ និងបុរាណវិទ្យាបង្ការ ស្នើឱ្យភ្ញៀវទេសចរជាតិ និងអន្តរជាតិ ព្រមទាំងសាធារណជនទាំងអស់ យោគយល់ និងជ្រាបពីព័ត៌មាននេះ។





បុរាណវិទូបញ្ជាក់ពីមូលហេតុដែលប៉ាន សន្និដ្ឋានថា ការកំណាយឃើញបុរាណដ្ឋាននៅលើភ្នំគូលែន អាចជាអតីតរាជវាំងឬរាជដំណាក់របស់ព្រះចាទជ័យវ្មន់ទី២ក្នុងសតវត្សទី៩

ផ្សាយនៅ ថ្ងៃទី ១២ ខែ មេសា ឆ្នាំ២០១៨

ក្រុមបុរាណវិទូនៃអាជ្ញាធរជាតិអប្សរានិងបុរាណវិទូនៃអង្គការមូលនិធិបុរាណវិទ្យានិងអភិវឌ្ឍន៍ (ADF) បានសហការជាមួយ ក្រសួងបរិស្ថានធ្វើកំណាយលើទីតាំងមួយឈ្មោះ បន្ទាយ ឬហៅថា «ផ្ទះគូចារ្យ» បានរកឃើញរចនាសម្ពន្ធសំណង់បុរាណមួយ ធ្វើពីឥដ្ឋនិងថ្មបាយក្រៀម។ ទីតាំងនេះស្ថិតនៅសហគមន៍តំបន់ការពារធម្មជាតិព្រៃធំអន្លង់ធំ ភូមិអន្លង់ធំ ឃុំខ្នងភ្នំ ស្រុកស្វាយលើ ខេត្តសៀមរាប នៃឧទ្យានជាតិព្រះជ័យវ្មន៍នរោត្តមភ្នំគូលែននិយាមការ 48P 406579 1498122។

ទាក់ទងនឹងការអះអាងថា ទីនេះអាចជាអតីតរាជវាំងឬរាជដំណាក់របស់ព្រះបាទជ័យវ្មន៍ទី២នោះ **លោកបណ្ឌិត JB Chevance** ប្រធានអង្គការមូលនិធិបុរាណវិទ្យានិងអភិវឌ្ឍន៍ (ADF) បកប្រែដោយ **លោក សាយៀន សក្តា** បុរាណវិទូនៃអង្គការ ADF ឱ្យដឹងថា៖

១. យោងទៅលើឯកសារស្រាវជ្រាវរបស់បារាំងនិងខ្មែរពីមុនៗដែលសន្និដ្ឋានថានេះជារាជវាំងរបស់ព្រះអង្គដែលទ្រង់ បានមកតាំងរាជធានីនៅលើខ្នងភ្នំគូលែន។ តាមការសន្និដ្ឋានរបស់អ្នកជំនាញ ទីនេះប្រហែលជាអតីត «រាជដំណាក់ឬរាជវាំង» របស់ព្រះបាទជ័យវ្មន៍ទី២ កសាងនៅដើមសតវត្សរ៍ទី៩ មានទំហំផ្ទៃដី៤០០ម៉ែត្រx៦០០ម៉ែត្រ។

២. បើយោងតាមសិលាចារឹកស្តុកកក់ធំ (K.235) ប្រមាណជាងពីរយឆ្នាំបន្ទាប់ពីការចូលទីវង្គត់របស់ព្រះបាទជ័យវ្មន៍ទី២ បានរៀបរាប់យ៉ាងក្បោះក្បាយពីការផ្លាស់ប្តូររាជធានីរបស់ព្រះអង្គពីតំបន់មួយទៅតំបន់មួយ ប៉ុន្តែមានការសន្និដ្ឋានច្រើនដូចគ្នាថាមហេន្ទ្របព៌ត គឺជាភ្នំគូលែនបច្ចុប្បន្ន ព្រោះមានប្រាសាទដែលព្រះអង្គប្រកាសរាជបន្ទាប់ពីព្រះអង្គបានធ្វើការបង្រួបបង្រួមជាតិរួច សំណង់សាធារណៈ ទំនប់ទឹក ប្រាសាទសម្រាប់សាសនា និងរាជវាំងក៏បានរកឃើញជាបន្តបន្ទាប់។

៣. ទីតាំងនេះក៏ធ្លាប់មានការសន្និដ្ឋានពីអ្នកស្រាវជ្រាវជាតិ-អន្តរជាតិថាប្រហែលជារាជវាំង ក៏ប៉ុន្តែនៅតែមិនទាន់មានភស្តុតាងបែបវិទ្យាសាស្ត្រណាមួយមកបញ្ជាក់នោះទេ ទើបក្នុងឆ្នាំ២០០៩ បុរាណវិទូនៃអាជ្ញាធរជាតិអប្សរា បានសហការជាមួយបុរាណវិទូនៃអង្គការ ADF ចាប់ផ្តើមធ្វើកំណាយ។ ជាលទ្ធផលនាពេលនោះ តាមរយៈការយកធ្សូងទៅពិសោធឃើញថា ទីតាំងនេះគឺស្ថិតក្នុងសតវត្សទី៩នៃរាជរបស់ព្រះបាទជ័យវ្មន៍ទី២។

៤. ផ្អែកតាមទិន្នន័យ LiDAR ឆ្នាំ២០១២ និង ២០១៥ និងលទ្ធផលបឋមបានពីការធ្វើកំណាយក្នុងឆ្នាំ២០១៨នេះ បានបង្ហាញកាន់តែច្បាស់ពីរចនាសម្ពន្ធរៀបចំក្រុង មានទំនប់បុរាណ ប្រាសាទបុរាណ សំណង់សាធារណៈ ប្រព័ន្ធធារាសាស្ត្រ បារាយណ៍ជាដើម គឺចាប់ផ្តើមចេញពីទីតាំងមួយនេះ។

តាមសណ្ឋានដីទូទាំងភ្នំគូលែន អត់មានសណ្ឋានដីណាដូចកន្លែងនេះទេ ដែលមានទំនប់ព័ទ្ធនិងផ្លូវខ្ទាត់ខ្នែងជុំវិញ។ យោងតាមលទ្ធផលដែលសន្និដ្ឋានបឋមមាន៖ -យើងបានរកឃើញកាំជណ្តើរសង់ពីឥដ្ឋដែលជាច្រកចូលពីទិសខាងកើត។ -ចំពោះសំណង់កណ្តាលនៃអគារអាចបែងចែកជា៣ដំណាក់កាល។ ដំណាក់កាលទី១៖ ប្រហែលជាស្ថិតក្នុងរាជព្រះបាទជ័យវរ្ម័នទី២ ក្នុងសតវត្សទី៩ បច្ចេកទេសសំណង់មានការបង្ហាប់គ្រឹះដោយប្រើដីលាយជាមួយកម្ទេចថ្មបាយក្រៀម គ្រួស បន្ទាប់មករៀបក្រវ៉ាត់ពីឥដ្ឋ មុននឹងធ្វើសំណង់ខាងលើ។ ដំណាក់កាលទី២៖ គឺចាក់ដីកម្រាស់៣០សង់ទីម៉ែត្រនៅលើកម្រាលឥដ្ឋដំណាក់កាលទី១ បន្ទាប់មកក៏រៀបកម្រាលឥដ្ឋនៅពីលើ។ ក្នុងដំណាក់កាលនេះ យើងមិនទាន់អាចធ្វើការសន្និដ្ឋានថាធ្វើពេលណានៅឡើយនោះទេ ដោយសារយើងមិនទាន់មានកស្តុតាងគ្រប់គ្រាន់។ ដំណាក់កាលទី៣៖ ស្ថិតក្នុងអំឡុងទសវត្សទី៦០ រហូតដល់បច្ចុប្បន្នតាមរយៈការសាកសួរពីចាស់ទុំនៅតំបន់នេះ ទៅទស្សវត្សទី៦០ គឺមានលោកតាអាចារ្យម្នាក់បានមកសង់ផ្ទះនេះដើម្បីតាំងធម៌លុះដល់ប្រទេសមានសង្គ្រាមក៏បាត់ដំណឹងគាត់ចាប់ពីពេលនោះមក។

ក្នុងនាមជាអ្នកចូលរួមកំណាយផ្ទាល់ **លោក ងិន សារុន** បុរាណវិទូនិងជាបុគ្គលិកបច្ចេកទេសនៃនាយកដ្ឋានអភិរក្សប្រាសាទក្រៅឧទ្យានបានឱ្យដឹងថា ការរកឃើញរចនាសម្ពន្ធសំណង់នេះពិតជាអស្ចារ្យខ្លាំងណាស់ វាជាទិន្នន័យថ្មីឱ្យដឹងកាន់តែច្បាស់ថាសំណង់នេះជាអ្វី សម្ភារៈធ្វើសំណង់ ដំណាក់កាលសាងសង់ តួនាទីសំណង់ ឆ្នាំកសាង និងចងក្រងជាឯកសារទុកសម្រាប់អ្នកជំនាន់ក្រោយសិក្សាស្រាវជ្រាវ។ លោកបន្តទៀតថា លោកបានជួយលើការងារបច្ចេកទេស ការគូរប្លង់ ការមើលស្រទាប់ដី ធ្វើឱ្យលោកបានផ្លាស់ប្តូរបទពិសោធន៍គ្នាទៅវិញទៅមក ពិសេសអភិវឌ្ឍន៍សមត្ថភាពចំណេះដឹងផ្នែកបុរាណវិទ្យាកាន់តែល្អប្រសើរ។

លោកបណ្ឌិត ឈាន រដ្ឋា ប្រធានស្តីទីនាយកដ្ឋានអភិរក្សប្រាសាទក្រៅឧទ្យានអង្គរនៃអាជ្ញាធរជាតិអប្សរា បានអបអរសាទចំពោះលទ្ធផលដ៏ធំធេងនៃការរកឃើញកស្តុតាងថ្មីៗបន្ថែមទៀតនេះតាមរយៈកិច្ចសហការគ្នាជាមួយអង្គការADF ដែលបានចុះអនុស្សារណៈយោគយល់គ្នាតាំងពីឆ្នាំ២០០៨ លើកិច្ចការអភិរក្សការស្រាវជ្រាវផ្នែកបុរាណវិទ្យានិងកិច្ចការបណ្តុះបណ្តាលធនធានមនុស្ស។ ការងារកំណាយនេះ ក្រុមការងារនឹងប្រើរយៈពេលមួយខែក្នុងការបើកកំណាយស្រាវជ្រាវ ដោយចាប់ផ្តើមពីថ្ងៃទី១២ មីនា គ្រោងបញ្ចប់នៅថ្ងៃទី១៣ មេសា ឆ្នាំ២០១៨ខាងមុននេះ។ ក្រៅពីកិច្ចការកំណាយស្រាយជ្រាវនេះ អាជ្ញាធរជាតិអប្សរានិងអង្គការ ADF បាននឹងកំពុងចងក្រងសៀវភៅស្តីអំពីបញ្ហីសារពើភណ្ឌបុរាណវត្ថុនិងបុរាណដ្ឋាននៅលើខ្នងភ្នំគូលែនដែលជាលទ្ធផលដ៏ធំធេងបានមកពីការងារ ស្រាវជ្រាវនិងចុះផ្ទៀងផ្ទាត់ដល់ទីតាំងផ្ទាល់ដោយប្រៀបធៀប ជាមួយទិន្នន័យដែលបានពីបច្ចេកវិទ្យា LiDAR ឆ្នាំ២០១២និង២០១៥។ លទ្ធផលទាំងនេះ នឹងក្លាយជាចំណែកបំពេញលក្ខខណ្ឌក្នុងការដាក់បញ្ចូលភ្នំគូលែនទៅជាសម្បត្តិបេតិកភណ្ឌពិភពលោកនាអនាគត៕









ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរារៀបចំពិធីសូត្រមន្តលើកកាសីអបអរសាទរបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ

ផ្សាយនៅថ្ងៃទី ១២ ខែ មេសា ឆ្នាំ២០១៨

នាព្រឹកថ្ងៃព្រហស្បតិ៍ ១២រោច ខែចែត្រ ឆ្នាំរកា នព្វស័ក ព.ស២៥៦១ ត្រូវនឹងថ្ងៃទី១៤ ខែមេសា ឆ្នាំ២០១៨ **លោកជំទាវ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងជាប្រធានអាជ្ញាធរជាតិអប្សរា រួមទាំងថ្នាក់ដឹកនាំគ្រប់នាយកដ្ឋាន មន្ត្រី-បុគ្គលិក ទាំងអស់ បានរៀបចំពិធីនិមន្តព្រះសង្ឃចំនួន៧អង្គចម្រើនព្រះបរិត្ត និងថ្វាយទេយ្យទានតាមទំនៀមទម្លាប់ព្រះពុទ្ធសាសនា ដើម្បីសុំសុខសិរីសួស្តី អបអរសាទរឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ដែលនឹងចូលមកដល់នៅថ្ងៃ១៤រោច ខែចែត្រ ឆ្នាំច នព្វស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី១៤ ខែមេសា ឆ្នាំ២០១៨ខាងមុខនេះ។

មានមតិសំណេះសំណាលជាមួយថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិកក្រោមបង្គាប់ទាំងអស់ លោកជំទាវរដ្ឋមន្ត្រី ដែលកាន់តំណែងជាប្រធានអាជ្ញាធរជាតិអប្សរាមួយឆ្នាំមកនេះ បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំគ្រប់នាយកដ្ឋាន រួមទាំងមន្ត្រី-បុគ្គលិកគ្រប់រូបនៃអាជ្ញាធរជាតិអប្សរា ដែលបានលះបង់កម្លាំងកាយចិត្តបំពេញការងារអភិរក្ស ជួសជុលសម្បត្តិវប្បធម៌ខ្មែរបានយ៉ាងល្អ ប្រកបដោយស្មារីទទួលខុសត្រូវខ្ពស់ ក្នុងការលើកតម្លៃមរតកជូនតាដោយមិនគិតពីការនឿយហត់និងបញ្ហាប្រឈមនានាដែលកើតឡើងក្នុងការបំពេញការងារនៅតំបន់អង្គរ។

លោកជំទាវសូមគោរពជូនពរដល់ថ្នាក់ដឹកនាំ មន្ត្រី និងបុគ្គលិកគ្រប់រូប សូមទទួលបាននូវសេចក្តីសុខចម្រើននាឱកាសឆ្នាំថ្មី សូមឱ្យការជួបជុំនេះប្រកបដោយភាពសប្បាយរីករាយ សុខដុមរមនាក្នុងគ្រួសារ និងសុខសុវត្ថិភាពគ្រប់ពេលវេលា៕









សេចក្តីជូនដំណឹងស្តីពី៖ ការបើកឲ្យប្រើប្រាស់ស្ពានហាលប្រាសាទអង្គរវត្ត ពីថ្ងៃទី១២ដល់ទី១៧ ខែមេសា ឆ្នាំ២០១៨

ផ្សាយនៅថ្ងៃទី១២ ខែ មេសា ឆ្នាំ២០១៨

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA
លេខ ២៨៤/អប.សជសា

សេចក្តីជូនដំណឹង
ស្តីពី
ការបើកឲ្យប្រើប្រាស់ស្ពានហាលប្រាសាទអង្គរវត្ត ពីថ្ងៃទី១២ដល់ទី១៧ ខែមេសា ឆ្នាំ២០១៨

អាជ្ញាធរជាតិអប្សរា មានកិត្តិយសសូមជម្រាបជូនដំណឹងដល់គ្រប់ក្រសួង មន្ទីរ ស្ថាប័នជាតិ-អន្តរជាតិ សមាគមទីភ្នាក់ងារទេសចរណ៍ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ មគ្គុទ្ទេសក៍ទេសចរណ៍ ក្រុមហ៊ុនទេសចរណ៍ សមាគមដឹកជញ្ជូនភ្ញៀវទេសចរ អ្នកដឹកជញ្ជូនភ្ញៀវទេសចរ ភ្ញៀវទេសចរជាតិ-អន្តរជាតិ និងសាធារណជនទាំងអស់ឲ្យបានជ្រាបថា៖ ដើម្បីជានាសុវត្ថិភាពភ្ញៀវទេសចរ រក្សាសណ្តាប់ធ្នាប់ និងសម្រួលដល់ការចូលទស្សនាប្រាសាទអង្គរវត្ត ក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦១-២៥៦២ គ.ស ២០១៨ អាជ្ញាធរជាតិអប្សរានឹងបើកស្ពានហាលមុខប្រាសាទអង្គរវត្ត សម្រាប់ភ្ញៀវទេសចរជាតិ-អន្តរជាតិប្រើប្រាស់ជាច្រកចូលប្រាសាទពីថ្ងៃព្រហស្បតិ៍ ទី១២ ដល់ថ្ងៃអង្គារទី១៧ ខែមេសា ឆ្នាំ២០១៨។ ចំពោះច្រកចេញពីប្រាសាទ សូមប្រើប្រាស់ស្ពានបណ្តែតទឹកដែលស្ថិតនៅខាងត្បូងស្ពានហាល ឬច្រកខាងកើតប្រាសាទ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម ឯកឧត្តម លោកជំទាវ លោក លោកស្រី គ្រប់ក្រសួង មន្ទីរ ស្ថាប័នជាតិ-អន្តរជាតិ សមាគមទីភ្នាក់ងារទេសចរណ៍ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ មគ្គុទ្ទេសក៍ទេសចរណ៍ ក្រុមហ៊ុនទេសចរណ៍ សមាគមដឹកជញ្ជូនភ្ញៀវទេសចរ អ្នកដឹកជញ្ជូនភ្ញៀវទេសចរ ភ្ញៀវទេសចរជាតិ-អន្តរជាតិ និងសាធារណជនទាំងអស់ មេត្តាជ្រាប និងចូលរួមសហការអនុវត្តឲ្យមានប្រសិទ្ធភាពខ្ពស់។

ធ្វើនៅថ្ងៃ ៩ ខែចេត្រ ឆ្នាំកោ នព្វស័ក ព.ស២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែមេសា ឆ្នាំ២០១៨

ហត់ ពៅ

ចម្លងជូន
- សាលាខេត្តសៀមរាប
- ក្រសួងព័ត៌មាន
- ក្រសួងទេសចរណ៍
- អគ្គភាពនគរបាលការពារសន្តិសុខក្នុងតំបន់ខេត្តសៀមរាប
- អគ្គភាពនគរបាលទេសចរណ៍ក្នុងតំបន់ខេត្តសៀមរាប
- ប្រឹក្សាខេត្ត
- សមាគមទីភ្នាក់ងារទេសចរណ៍
- សមាគមមគ្គុទ្ទេសក៍
- សមាគមមគ្គុទ្ទេសក៍ទេសចរណ៍
- សមាគមអ្នកបើកបរដឹកជញ្ជូនភ្ញៀវទេសចរ
- ឯកសារ-កាលប្បវត្តិ

ភ្ជាប់ជូន:
មហាវិទ្យាល័យកម្ពុជ ឆ្នាំ២០១ សន្តានចិត្តភាព ទណ្ឌវត្តអគ្គ
ទូរស័ព្ទ/ទូរសារ៖ ០៦៣ ២៦៤ ៨៨១/០៦៣ ២៦៤ ៨៨៦

អាជ្ញាធរជាតិអប្សរាសម្រាប់ការទទួលស្គាល់ពិភពលោក
Email: info@apsaraauthority.gov.kh
Website: http://www.apsaraauthority.gov.kh

សៀមរាប:
ភូមិបន្ទាយ ឃុំស្វាយដង ស្រុកប្រាសាទបាគង ខេត្តសៀមរាប
ទូរស័ព្ទ/ទូរសារ៖ ០៦៣ ៨៦៤ ៤៨៣/០៦៣ ៨៦៤ ៤៨៦

សេចក្តីជូនដំណឹងស្តីពីការពង្វាងការចូលទស្សនាប្រាសាទមួយចំនួនក្នុងព្រឹត្តិការណ៍អង្គរសង្ក្រាន ឆ្នាំ២០១៨

ផ្សាយនៅថ្ងៃទី ១២ ខែ មេសា ឆ្នាំ២០១៨



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA

លេខ.៣០៣/២៤ រប.ស.ជ.ណ

សេចក្តីជូនដំណឹង
ស្តីពី

ការពង្វាងការចូលទស្សនាប្រាសាទមួយចំនួនក្នុងព្រឹត្តិការណ៍អង្គរសង្ក្រាន្ត ឆ្នាំ២០១៨

អាជ្ញាធរជាតិអប្សរា មានកិត្តិយសសូមជម្រាបជូនដំណឹងដល់គ្រប់ក្រសួង មន្ទីរស្ថាប័នជាតិ-អន្តរជាតិ សមាគមទីភ្នាក់ងារទេសចរណ៍ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ ក្រុមហ៊ុនទេសចរណ៍ សមាគមអ្នកបើកបររថយន្តដឹកជញ្ជូនភ្ជៀវទេសចរ អ្នកបើកបរដឹកជញ្ជូនភ្ជៀវទេសចរ ម្ចាស់សណ្ឋាគារ ទីភ្នាក់ងារទេសចរណ៍ ភ្ជៀវទេសចរជាតិ-អន្តរជាតិ ព្រមទាំងសាធារណជនទាំងអស់ជ្រាបថា សហភាពសហព័ន្ធយុវជនកម្ពុជា នឹងរៀបចំព្រឹត្តិការណ៍អង្គរសង្ក្រាន្តឆ្នាំ២០១៨ ដើម្បីអបអរសាទរពិធីបុណ្យចូលឆ្នាំប្រពៃណីជាតិខ្មែរ ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២ គ.ស២០១៨ នាពេលខាងមុខនេះ។

ទន្ទឹមនឹងនោះ ដើម្បីធានាឱ្យការរៀបចំព្រឹត្តិការណ៍អង្គរសង្ក្រាន្តឆ្នាំ២០១៨ ប្រព្រឹត្តិទៅបានរលូន អាជ្ញាធរជាតិអប្សរា នឹងធ្វើការបង្វែរផ្លូវចូលប្រាសាទមួយចំនួនតាមកម្មវិធីដូចជម្រាបជូនខាងក្រោម៖

១-ថ្ងៃសុក្រ ១៣រោច ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១ ត្រូវនឹងថ្ងៃទី១៣ ខែមេសា ឆ្នាំ២០១៨ ចាប់ពីម៉ោង៧៖០០នាទីព្រឹក រហូតដល់ ម៉ោង១២៖០០នាទីរសៀល ពង្វាងការចូលបរិវេណអង្គរធំ ដើម្បីរៀបចំកម្មវិធីបើកព្រឹត្តិការណ៍អង្គរសង្ក្រាន្ត។

២-ថ្ងៃសៅរ៍១៤រោច ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១ ត្រូវនឹងថ្ងៃទី១៤ ខែមេសា ឆ្នាំ២០១៨ ៖

- ពីម៉ោង៧៖០០នាទីដល់ម៉ោង១០៖០០នាទីព្រឹក ការឆ្លងកាត់ទៅវិញទៅមកតាមច្រកអង្គរធំ ត្រូវបង្វែរឱ្យឆ្លងកាត់តាមច្រកផ្លូវខាងឆ្វេងប្រាសាទបាយ័នតែមួយផ្លូវ។ ផ្អាកការធ្វើដំណើរទៅខាងស្តាំប្រាសាទបាយ័ន និងការចូលទស្សនាប្រាសាទបាយ័ន ដើម្បីរៀបចំកម្មវិធីទទួលទេវតាឆ្នាំថ្មី។
- ពីម៉ោង១៤៖០០នាទីរសៀលដល់ម៉ោង១៩៖០០ល្ងាច ផ្អាកការឆ្លងកាត់ស្តានហាល ដោយប្រើប្រាស់ស្តានបណ្តែតទឹកទាំងទៅទាំងមកដើម្បីរៀបចំកម្មវិធីទាញព្រ័ត្ត និងបណ្តែតប្រទីប

៣-ថ្ងៃអាទិត្យ ១កើត ខែពិសាខ ឆ្នាំច សំរឹទ្ធស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី១៥ ខែមេសា ឆ្នាំ២០១៨ ចាប់ពីម៉ោង១២៖០០ ថ្ងៃត្រង់រហូតដល់ម៉ោង១៦៖០០នាទីល្ងាច ផ្អាកការឆ្លងកាត់តាមច្រកក្លោងទ្វារដៃឆ្នាំង ដើម្បីរៀបចំកម្មវិធីហែក្សួនព្រឹត្តិការណ៍អង្គរសង្ក្រាន្តឆ្នាំ២០១៨។

អាជ្ញាធរជាតិអប្សរាសង្ឃឹមយ៉ាងមុតមាំថា គ្រប់ក្រសួង មន្ទីរស្ថាប័នជាតិ-អន្តរជាតិ សមាគមទីភ្នាក់ងារទេសចរណ៍ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ ក្រុមហ៊ុនទេសចរណ៍ សមាគមអ្នកបើកបររថយន្តដឹកជញ្ជូនភ្ជៀវទេសចរ អ្នកបើកបរដឹកជញ្ជូនភ្ជៀវទេសចរ ម្ចាស់សណ្ឋាគារ ទីភ្នាក់ងារទេសចរណ៍ ភ្ជៀវទេសចរជាតិ-អន្តរជាតិ ព្រមទាំងសាធារណជនទាំងអស់ នឹងចូលរួមអនុវត្ត និងជួយផ្សព្វផ្សាយឱ្យបានទូលំទូលាយ។

ថ្ងៃ ក្រាបគាទិ ១២ រោច ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១
សៀមរាប ថ្ងៃទី ១២ ខែមេសា ឆ្នាំ២០១៨
អគ្គនាយក

ចម្លងជូន
- សាលាខេត្តសៀមរាប
- ស្នងការដ្ឋាននគរបាលខេត្តសៀមរាប
- បញ្ជាការដ្ឋានកងអាវុធហត្ថខេត្តសៀមរាប
- សាលាក្រុង/ស្រុកទាំង១២
- គ្រប់នាយកដ្ឋាន/អង្គភាពចំណុះអាជ្ញាធរជាតិអប្សរា
- អង្គភាពនគរបាលការពារបេតិកភណ្ឌប្រចាំខេត្តសៀមរាប
- អង្គភាពនគរបាលទេសចរណ៍ប្រចាំខេត្តសៀមរាប
- គ្រឹះស្ថានអង្គរ
"ដើម្បីជួយផ្សព្វផ្សាយឱ្យបានទូលំទូលាយ"
- ឯកសារ-កាលប្បវត្តិ

ស៊ុំ ម៉ាប់

ភ្ជុំពេញ:
អបាវិទីសហព័ន្ធរុស្ស៊ី លេខ៤១ សង្កាត់ទឹត្តភាព ខណ្ឌៃឆមការ
ទូរសព្ទ/ទូរសារ៖ ០២៣ ២៦៥ ៥៥១/០២៣ ២៦៥ ៥៥៦

អាជ្ញាធរជើម្បីការពារមណ៍យន្ធាទនិងដៀបចំតំបន់អង្គរ
Email: info@apsaraauthority.gov.kh
Website: http//www.apsaraauthority.gov.kh

សៀមរាប:
ភូមិបង្កោង ឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប
ទូរសព្ទ/ទូរសារ៖ ០៦៣ ៥៦៥ ៥៥៧/០៦៣ ៥៦៥ ៥៥៦

ភូមិខ្ញុំសង្ក្រាន្តឆ្លាំថ្មីបង្ហាញនិដ្ឋភាពពីរសម័យកាលនៃសង្គមខ្មែរ

ផ្សាយនៅថ្ងៃទី ១៨ ខែ មេសា ឆ្នាំ២០១៨

មានទីតាំងនៅខាងជើងប្រាសាទបាយ័ន្ត ភូមិខ្ញុំឆ្នាំនេះបានបង្ហាញនូវភាពស្រស់ស្អាតដ៏គួរឱ្យចាប់អារម្មណ៍ក្រោមការរៀបចំរបស់អាជ្ញាធរជាតិអប្សរា។

តាមប្រសាសន៍របស់ **ឯកឧត្តម សុខ សង្ហារ** អគ្គនាយករងទទួលបន្ទុកនាយកដ្ឋាន អភិវឌ្ឍន៍ទេសចរណ៍នៃអាជ្ញាធរជាតិអប្សរាបានឱ្យដឹងថា៖ សម្រាប់ឆ្នាំច សំរឹទ្ធស័ក ព.ស២៥៦២ នេះ ក្រុមការងារភូមិខ្ញុំបានបង្ហាញសម័យកាលពីរដ៏សំខាន់ គឺសម័យឧដុង្គ និងសម័យឯករាជ្យ ដែលរាប់បញ្ចូលទាំងម៉ូដផ្ទះ សម្លៀកបំពាក់ ការតុបតែងខ្លួន និងការរស់នៅជាដើម។

ឯកឧត្តមបន្តទៀតថា ក្រៅពីនោះ ក៏មានបង្ហាញពីសកម្មភាពអង្គរសង្ក្រាន្តតាំងពីឆ្នាំទី២០១៣ រហូតដល់ឆ្នាំ២០១៨ ផ្ទះអក្សរសិល្ប៍ ផ្ទះចារស្លឹករឹត កន្លែងតន្ត្រី កន្លែងរបាំប្រពៃណី និងសាលាធម៌ ដែលជាកន្លែងបង្ហាញនូវទំនៀមទម្លាប់របស់ខ្មែរលើផ្នែកជំនឿ។ អ្វីដែលកាន់តែពិសេស គឺខ្មុកយក្ស រូបហនុមាន ក៏បានតាំងបង្ហាញ ដើម្បីជាការលើកកម្ពស់ពីស្នាដៃសិល្បៈខ្មែរ ក្នុងទម្រង់ល្ខោនខោលផងដែរ។

ចង់ដឹងថាទេសភាពនោះស្រស់ស្អាតយ៉ាងណាសូមទស្សនាកម្រងរូបភាពខាងក្រោមដូចតទៅ៖









លោកជំទាវរដ្ឋមន្ត្រី ភឿង សកុណា អញ្ជើញទៅពិនិត្យការក្រាលក្តារលើឫសឈើនៅប្រាសាទតាព្រហ្ម

ផ្សាយនៅថ្ងៃទី ១៨ ខែ មេសា ឆ្នាំ២០១៨

ឆ្លៀតក្នុងឱកាសព្រឹត្តិការណ៍អង្គរសង្ក្រាន្តដ៏មមាញឹក **លោកជំទាវ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាប្រធានអាជ្ញាធរជាតិអប្សរា បានអញ្ជើញចុះទៅពិនិត្យតាមដាននិងវឌ្ឍនភាពនៃការក្រាលកម្រាលក្តារនៅលើឫសឈើនាប្រាសាទតាព្រហ្ម។

គោលបំណងនៃការចុះទៅពិនិត្យការក្រាលកម្រាលក្តារនេះ គឺដើម្បីមើលភាពរៀបរយនៃការក្រាលកម្រាលនិងស្វែងយល់បន្ថែមពីគុណភាពនៃកម្រាលថាអាចសង្គ្រោះដើមឈើបានកម្រិតណា។ លើសពីនោះទៀត ការក្រាលកម្រាលក្តារលើឫសឈើនៅប្រាសាទតាព្រហ្ម ក៏ស្របទៅតាមអនុសាសន៍របស់កិច្ចប្រជុំអាយស៊ីស៊ី-អង្គរ (ICC-Angkor) ផងដែរ។

គួរបញ្ជាក់ផងដែរថា ដើមឈើធំៗភាគច្រើននៅក្នុងប្រាសាទតាព្រហ្ម គឺកំពុងរង គ្រោះថ្នាក់ដោយសារកំណើនភ្ញៀវទេសចរជាច្រើនចូលទៅទស្សនាប្រាសាទហើយជាន់លើឫស ឬលើដីក្បែរឫស ជាហេតុធ្វើឱ្យឫសឈើមានដំបៅ ក្រិន មានជំងឺ ហើយហាប់ដីមិនអាចដកដង្ហើមបាន។ ដោយហេតុដូច្នេះ ដើម្បីបញ្ចៀសនូវហានិភ័យដល់ដើមឈើទាំងឡាយអាជ្ញាធរជាតិអប្សរាក៏រៀបចំក្រាលកម្រាលក្តារលើឫសឈើដើម្បីសង្គ្រោះដើមឈើឱ្យមានសុវត្ថិភាពល្អប្រសើរឡើងវិញ៕









តើដីទទេជាស្ពានបុរាណតាមបណ្តោយផ្លូវជាតិលេខ៦ពីប្រាសាទចាកទជល់ទីប្រជុំជនកំពង់ក្តី មានចំនួនប៉ុន្មាន?

ផ្សាយនៅថ្ងៃទី ២០ ខែ មេសា ឆ្នាំ២០១៨

ផ្លូវជាតិលេខ៦ ពីបាគងទៅទីប្រជុំជនកំពង់ក្តី គឺរត់លើកំណាត់ផ្លូវបុរាណពីសម័យអង្គរ ហើយតាមការស្រាវជ្រាវរបស់អ្នកបុរាណវិទ្យាបានរកឃើញថា កំណាត់ផ្លូវនេះមានស្ពានបុរាណចំនួន២១ ក៏ប៉ុន្តែបច្ចុប្បន្នស្ពានបុរាណចំនួន១០ បានខូចបាត់រូបរាង ហើយមាននៅសល់តែស្ពានចំនួន១១ប៉ុណ្ណោះដែលអាចរក្សាបាន។

ការខូចខាតបាត់បង់ក៏ព្រោះតែកត្តាពេលវេលា ការខ្វះខាតកិច្ចការគាំពារនាពេលប្រទេសស្ថិតក្នុងស្ថានប្រទាញប្រទង់ដោយសារសង្ត្រាមស៊ីវិល ហើយស្ពានដែលមាននៅសល់ទាំង១១ នោះមានដូចជា ស្ពានអូរចិញ្ជៀន ស្ពានតូច ស្ពានថ្មបាយក្រៀម ស្ពានថ្មស្ពានតាមាស ស្ពានភូមិអូរ ស្ពានថ្នាល់ដាច់ ស្ពានស្វាយ ស្ពានបឹងអំពិល ស្ពានខ្ពស់ និងស្ពានព្រះទិស។

កន្លងមកស្ពានបុរាណទាំង១១នេះ មានការទ្រុឌទ្រោមខ្លាំង ទើបនៅឆ្នាំ២០១៣ នៅពេលធ្វើការជួសជុលផ្លូវជាតិលេខ៦ឡើងវិញ ទើបអាជ្ញាធរជាតិអប្សរាបានស្នើសុំក្រសួងសាធារណការនិងដឹកជញ្ជូន និងក្រុមហ៊ុនចិនដែលទទួលម៉ៅការធ្វើផ្លូវវាងស្ពានបុរាណទាំងនោះ ដើម្បីថែរក្សា អភិរក្សស្ពានទាំងនោះឱ្យបានគង់វង្សតកូនចៅ និងសម្រាប់បម្រើវិស័យទេសចរណ៍ផង។

ក្នុងន័យថែរក្សានិងលើកតម្លៃស្ពានបុរាណទាំងនោះ នាយកដ្ឋានអភិរក្សប្រាសាទក្រៅឧទ្យានអង្គរនៃអាជ្ញាធរជាតិអប្សរា បានយកចិត្តដាក់ថែទាំនិងលើកតម្លៃស្ពានបុរាណ ដូចជា ស្ពានព្រះទិស ដោយដាក់ឱ្យមានភ្នាក់អភិរក្សចំនួន៤នាក់ បំពេញការងារជាអចិន្ត្រៃយ៍ បានកសាងរោងឆ្មាំ១ខ្នង បង្គន់អនាម័យ១ខ្នង មាន៤បន្ទប់ សម្រាប់បម្រើទេសចរ។ ដោយឡែកស្ពានបុរាណចំនួន១០ទៀត យើងបានដាក់ស្លាកឈ្មោះស្ពានបុរាណតាមស្ពាននីមួយៗ ដើម្បីឱ្យភ្ញៀវទេសចរបានស្គាល់ ព្រមទាំងធ្វើការសម្អាតជារៀងរាល់ខែរួមមាន៖ ការកាប់ឆ្ការរុក្ខជាតិតូចធំ រើសសំរាមជុំវិញស្ពាន និងមើលស្ថានភាពស្ពានជាដើម។









ក្រុមមក្ខុទ្ទេសក៍សាទរចំពោះកម្រោងក្រាលក្តារឈើនៅតាមឫសឈើបុរាណក្នុងបរិវេណប្រាសាទតាព្រហ្ម ហើយថាកម្រោងនេះចានជួយដល់ដើមឈើ និងការពារសុខភាពដល់ភ្ញៀវទេសចរជាដែរ

ផ្សាយនៅថ្ងៃទី ២៣ ខែ មេសា ឆ្នាំ២០១៨

ក្រុមការងាររបស់អាជ្ញាធរជាតិអប្សរា បាននិងកំពុងរៀបចំដួសជុល និងក្រាលក្តារឈើតាមឫសឈើធំៗក្នុងបរិវេណប្រាសាទតាព្រហ្ម។ គម្រោងនេះត្រូវបានគាំទ្រ និងសាទរដោយក្រុមមគ្គុទ្ទេសក៍ទេសចរណ៍ ដោយពួកគេយល់ថា នេះជាការយកចិត្តទុកដាក់ដល់ដើមឈើដែលមានវ័យចំណាស់ៗ លើកសោភ័ណភាពប្រាសាទ ក៏ដូចជាការការពារគ្រោះថ្នាក់ដល់ភ្ញៀវដោយថាហេតុផងដែរ។

ចាប់ពីថ្ងៃទី៦ ខែមីនា ឆ្នាំ២០១៨មក ក្រុមការងារនៃនាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាននៃអាជ្ញាធរជាតិអប្សរា បានដំណើរការគម្រោងរៀបចំក្រាលក្តារឈើ តាមឫសឈើធំៗ និងនៅតាមរង់ទស្សនារបស់ភ្ញៀវទេសចរ នៅប្រាសាទតាព្រហ្ម។ តាមការប៉ាន់ស្មាន គម្រោងនេះអាចនឹងបញ្ចប់នៅមុនរដូវវស្សាមកដល់។

គម្រោងនេះមានការសាទរ និងគាំទ្រដោយមគ្គុទ្ទេសក៍ទេសចរណ៍ជាទូទៅ។ តួយ៉ាង មគ្គុទ្ទេសក៍ទេសចរណ៍កសាអង់គ្លេស **លោក តឹក តែម** បានសម្តែងអារម្មណ៍រីករាយ និងគាំទ្រយ៉ាងពេញទំហឹងលើ គម្រោងរៀបចំក្រាលក្តារនៅប្រាសាទតាព្រហ្មនេះ។ លោកយល់ថា គម្រោងនេះអាចការពារឫសឈើដែលមានវ័យចំណាស់ៗ និងមួយទៀតជួយការពារគ្រោះថ្នាក់ដល់ភ្ញៀវដោយថាហេតុផងដែរ។

ដោយឡែក **លោក ទៀ គីយូ** ប្រធានសមាគមមគ្គុទ្ទេសក៍ទេសចរណ៍ភាសាចិន-កម្ពុជានោះវិញ ក៏បានសម្តែងការគាំទ្រអស់ពីចិត្តទៅលើគម្រោងខាងនេះផងដែរ។ **លោក គីយូ** បានឱ្យដឹងថា ឫសឈើទាំងនោះអាចបង្កគ្រោះថ្នាក់ដល់ភ្ញៀវដែលមានវ័យចំណាស់ គឺអាចឱ្យពួកគាត់ជំពប់ជើងជាដើមប្រសិនបើខ្វះការប្រុងប្រយ័ត្ន ហើយគម្រោងនេះ នឹងជួយការពារដល់ដើមឈើដែលមានវ័យចំណាស់នៅក្នុងប្រាសាទតាព្រហ្មផងដែរ។ ដើមឈើទាំងនោះអាចនឹងស្លាប់បាន តាមរយៈការដើរជាន់ពីសំណាក់ភ្ញៀវទេសចរដែលមានចំនួនច្រើនរយនាក់ក្នុងមួយថ្ងៃៗ។

គេដឹងហើយថា ដើមឈើធំៗ និងឫសធំៗ ដែលមានវ័យចំណាស់នៅប្រាសាទតាព្រហ្ម គឺជាផ្នែកមួយដ៏ទាក់ទាញសម្រាប់ភ្ញៀវទេសចរជាតិ និងអន្តរជាតិ។ ពួកគេតែងផ្តិតយកទិដ្ឋភាពទាំងនោះ នៅពេលបានមកដល់ប្រាសាទម្តងៗ។ ជាមួយនឹង

កំណើនទេសចរជាច្រើនមកដល់ប្រាសាទតាព្រហ្ម វាក៏បានបង្កហានិភ័យផងដែរ។ ហានិភ័យត្រង់ភ្ញៀវទេសចរបានដើរជាន់ឫសឈើនៅក្រោមដីដោយមិនដឹងខ្លួន ដែលវានឹងបង្អាក់ដំណើរលូតលាស់របស់ដើមឈើទាំងនោះ។

លោក យិន សូវ៉ាត អ្នកគ្រប់គ្រងការដ្ឋានគម្រោងក្រាលក្តារនៅប្រាសាទតាព្រហ្ម បានឱ្យដឹងថា រហូតមកដល់ពេលនេះ យើងបានក្រាលក្តារបានប្រមាណ ៥០ម៉ែត្ររួចហើយគិតទាំងជណ្តើរ។ លោកបន្ថែមថា នឹងបន្តគម្រោងនេះជាដំណាក់កាលៗរហូតដល់បញ្ចប់។

លោក យិន សូវ៉ាត អនុប្រធាននាយកដ្ឋានគ្រប់គ្រងព្រៃឈើ បរិស្ថាន និងទេសភាពវប្បធម៌ ដែលកំពុងដឹកនាំក្រុមការងារ រៀបចំកម្រាលក្តារនៅប្រាសាទតាព្រហ្ម បានថ្លែងនាពេលកន្លងទៅថា គោលបំណងនៃការរៀបចំនេះ គឺដើម្បីបង្កើនការលូតលាស់របស់ដើមឈើ និងថែរក្សាបរិស្ថានជុំវិញឱ្យបានល្អប្រសើរឡើងវិញ។ តាមការបញ្ជាក់របស់មន្ត្រីព្រៃឈើ ទីតាំងឫសឈើចំនួន៦កន្លែង ដែលគ្រោងក្រាលក្តារ និងនៅតាមវង់ទស្សនាប្រវែងជាង៤០០ម៉ែត្របន្ថែមទៀត ហើយឈើដែលយកមកក្រាលនេះជាប្រភេទឈើគគីរ ដែលតាមការប៉ាន់ស្មានអាចមានប្រហែល៧០ម៉ែត្រគីប ដែលវាអាចរក្សាគុណភាពបានពី៦ ទៅ៧ឆ្នាំ។ ឈើនេះជាជំនួយឧបត្ថម្ភដោយភាគីឥណ្ឌា ដែលកំពុងដំណើរការជួសជុលប្រាសាទតាព្រហ្ម ចំណែកអាជ្ញាធរជាតិអប្សរា ចេញផ្នែកកម្លាំងពលកម្ម ដែលប្រើប្រាស់កម្មករចំនួន ១២នាក់៕









ប្រជាពលរដ្ឋ៤ភូមិក្នុងតំបន់អន្តរាគមន៍លចានប្រឡាយថ្មីមួយខ្សែសម្រាប់ប្រើប្រាស់ក្នុងរដូវប្រាំង

ផ្សាយនៅថ្ងៃទី ២៤ ខែ មេសា ឆ្នាំ២០១៨

ដើម្បីសម្រួលដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ អាជ្ញាធរជាតិអប្សរា សហការជាមួយ អាជ្ញាធរមូលដ្ឋាន និងក្រុមហ៊ុនយុវពាណិជ្ជបានស្តារប្រឡាយបុរាណមួយខ្សែ ដែលមានប្រវែង ១៣០០ម៉ែត្រ ទទឹង៤ម៉ែត្រ និងជម្រៅ២ម៉ែត្រ ជូនដល់ប្រជាពលរដ្ឋក្នុងភូមិគិរីមានន្ទ និងភូមិបង្គោង ដើម្បីទប់ទឹកប្រើប្រាស់ក្នុងរដូវប្រាំង។

ក្នុងពិធីបើកការដ្ឋានស្តារប្រឡាយនាព្រឹកថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៨នេះ លោក ព្រៀន ប្រម មេឃុំអំពិលបានបញ្ជាក់ថា ប្រឡាយមួយខ្សែនេះជាប្រឡាយបុរាណ ដែលមានជាយូរយារ មកហើយ។ កាលពីមុនប្រជាពលរដ្ឋនៅទីនេះ តែងមានទឹកប្រើប្រាស់គ្រប់ប្រាំងរដូវ ដោយ អាស្រ័យទឹកប្រឡាយនេះ។ ប៉ុន្តែដោយសារប៉ុន្មានឆ្នាំចុងក្រោយនេះ អាកាសធាតុប្រែប្រួល ហើយស្ថានភាពបាតប្រឡាយក៏កាន់តែរាក់ទៅៗ ដែលធ្វើឲ្យប្រឡាយដ៏ចំណាស់នេះ លែងមាន ទឹកហូរ និងប្រើប្រាស់បានទៀតនៅរដូវប្រាំង។ ក្នុងនាមអាជ្ញាធរមូលដ្ឋានលោកពិតជារីករាយ និងថ្លែងអំណរគុណចំពោះអាជ្ញាធរជាតិអប្សរា និងក្រុមហ៊ុនយុវពាណិជ្ជដែលបានជួយស្តារប្រឡា យនេះឡើងវិញ។

លោក ភូ ភក្តី តំណាងក្រុមហ៊ុនយុវពាណិជ្ជបានលើកឡើងថា ការសម្រេចស្តារប្រឡាយបុរាណនេះឡើង គឺធ្វើតាមសំណូមពររបស់អាជ្ញាធរមូលដ្ឋាន និងមានការអនុញ្ញាតព្រមទាំងការចុះពិនិត្យមើលបច្ចេកទេសការងារពីមន្ត្រីជំនាញនៃអាជ្ញាធរជាតិអប្សរា។ លោកបញ្ជាក់ថា ក្រុមហ៊ុនរបស់លោកនឹងបញ្ចប់ការងារនេះក្នុងរយៈពេល១ខែយ៉ាងយូរ។

លោក ម៉ក់ សំការ អភិបាលនៃគណៈអភិបាលស្រុកប្រាសាទបាគងក៏បានបង្ហាញនូវភាពសប្បាយរីករាយដែលប្រជាពលរដ្ឋនឹងទទួលបាននូវប្រឡាយ សម្រាប់តម្កល់ទឹកប្រើប្រាស់តាមតម្រូវការជាក់ស្តែង។ លោកបញ្ជាក់ថា នេះជាសមិទ្ធផលមួយក្នុងចំណោមសមិទ្ធផលដ៏លើសលុបដែលកើតឡើងក្នុងសម័យកាលនៃ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជាប្រមុខរាជរដ្ឋាភិបាលកម្ពុជា។

ឯកឧត្តម សុខ សង្ហារ អគ្គនាយករងនៃអាជ្ញាធរជាតិអប្សរា ដែលបានអញ្ជើញជាអធិបតីក្នុងពិធីបើកការដ្ឋាននេះបានបញ្ជាក់ថា អាជ្ញាធរជាតិតែងគោរពនិងដើរតាមគោលនយោបាយអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាលកម្ពុជា។ ដូច្នេះហើយក្នុងកិច្ចអភិរក្សរមណីយដ្ឋានអង្គរ អាជ្ញាធរជាតិអប្សរាក៏មិនភ្លេចការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ដែលបម្រើដល់វិស័យទេសចរណ៍ និងតម្រូវការរបស់ប្រជាពលរដ្ឋក្នុងតំបន់រមណីយដ្ឋានអង្គរ។ ឯកឧត្តមបញ្ជាក់ថា នេះសបញ្ជាក់អំពីការយកចិត្តទុកដាក់របស់ថ្នាក់ដឹកនាំប្រទេស ចំពោះសុខទុក្ខរបស់ប្រជាពលរដ្ឋ ជាពិសេស គឺសម្តេចតេជោនាយករដ្ឋមន្ត្រី ដែលសម្តេចតែងតែគិតគូរដល់សុខសន្តិភាពជាតិ និងការអភិវឌ្ឍគ្រប់វិស័យផ្សារភ្ជាប់នឹងការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងកិច្ចការពារសម្បត្តិបេតិកភណ្ឌជាតិសម្រាប់កូនចៅគ្រប់ជំនាន់។

ជាចុងក្រោយ ឯកឧត្តមក៏បានសំណូមពរចំពោះក្រុមហ៊ុនក្នុងករណីប្រទះឃើញ ដោយចៃដន្យនូវវត្ថុបុរាណណាមួយក្នុងការដីកស្តារប្រឡាយឡើងវិញ ត្រូវប្រគល់ជូនសមត្ថកិច្ចដើម្បីរក្សាទុកក្នុងទីសុវត្ថិភាព។ ជាមួយគ្នានេះ ឯកឧត្តមក៏បានសំណូមពរប្រជាពលរដ្ឋសូមចូលរួមថែរក្សាសមិទ្ធផលដែលសម្រេចបានឲ្យបានគង់វង្ស៕









សមត្ថកិច្ចចម្រុះចុះទប់ស្កាត់ការឆក្រាន់ព្រៃឈើក្នុងឧទ្យានអង្គរ

ផ្សាយនៅថ្ងៃទី ២៤ ខែ មេសា ឆ្នាំ២០១៨

ក្រុមការងារចម្រុះ រួមមានមន្ត្រីជំនាញនៃអាជ្ញាធរជាតិអប្សរា ប៉ូលិសបេតិកភណ្ឌ អាជ្ញាធរមូលដ្ឋានជាច្រើនរូប បានចុះពិនិត្យមើលការកាប់ទន្ទ្រានព្រៃនៅក្នុងឧទ្យានអង្គរ នារសៀលថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៨ ស្ថិតក្នុងភូមិក្រវ៉ាន់ សង្កាត់នគរធំ ក្រុងសៀមរាប ខេត្តសៀមរាប ខាងកើតកន្លែងត្រួតពិនិត្យសំបុត្រចំណុចអក្សរតេផ្លូវ៦០ម៉ែត្រ។

លោក បេង ប៊ិន មន្ត្រីទទួលបន្ទុកព្រៃឈើនៃនាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាន បានឱ្យដឹងថា សកម្មភាពលួចកាប់ទន្ទ្រានព្រៃឈើ នៅខាងកើតប៉ុស្តិ៍ត្រួតពិនិត្យសំបុត្រ៦០ម៉ែត្រ បានចាប់ផ្តើមតាំងពីឆ្នាំ២០១៧មកម្ល៉េះ តែក្រោយការទប់ស្កាត់ឃើញថាសកម្មភាពទាំងនោះបានបញ្ឈប់ហើយ។ ដោយឡែកក្នុងកំឡុងពេលបុណ្យចូលឆ្នាំថ្មីកន្លងមកនេះ សកម្មភាពកាប់ទន្ទ្រានដុតព្រៃបាន កើតឡើងម្តងទៀត។ ជនដែលសកម្មក្នុងការកាប់ព្រៃនេះ មាន **ឈ្មោះ ថៃ ធឿង** ដែលមានទំហំប្រមាណជាកន្លះហិចតានៅខាងក្រោយផ្ទះរបស់ខ្លួន រួមនឹងកន្លែងផ្សេងៗទៀតជាច្រើនកន្លែង។ មួយចំណុចទៀតនៅឆៀងមុខផ្ទះ **ថៃ ធឿង** មានទំហំប្រមាណ៣០ម៉x៤០ម៉ ដែលបង្កដោយជនមិនស្គាល់ឈ្មោះ។

លោក បេង ប៊ិន បញ្ជាក់ទៀតថា៖ ការលួចកាប់នេះ ធ្វើឡើងពេលក្រុមការងារព្រៃឈើរបស់អាជ្ញាធរជាតិអប្សរាអវត្តមានដូចជាពេលបុណ្យចូលឆ្នាំ ថ្ងៃសម្រាកបុណ្យជាតិ ថ្ងៃសៅរ៍-អាទិត្យ និងចន្លោះមុននិងក្រោយពេលចូលនិងចេញធ្វើការរបស់ក្រុមការងារ។ ពួកគេតែងលួចកាប់បន្តិចម្តងៗជារៀងរាល់ថ្ងៃ លុះពេលហាមឃាត់ ហើយសួរនាំ ក៏ឆ្លើយថា គ្រាន់តែដើរកាប់ដើម្បីហាត់ប្រាណឬក៏ប្រើពាក្យដេរប្រទេចតបមកក្រុមការងារ ហើយអះអាងថាព្រៃទាំងអស់នេះ ជាកម្មសិទ្ធិរបស់ខ្លួន ទាំងដែលខ្លួនត្រឹមជាអ្នកចំណូលស្រុកប៉ុណ្ណោះ ហើយអ្នកខ្លះទៀតត្រូវចៅសង្កាត់អះអាងថាមិនមានឈ្មោះជាប្រជាជនស្ថិតក្នុងភូមិស្រុករបស់ខ្លួនឡើយ។

ដោយមូលហេតុអាជ្ញាធរជាតិអប្សរា មិនមានសមត្ថកិច្ចក្នុងការដាក់ទោសទណ្ឌចំពោះជនបង្កបទល្មើស ក៏តែងតែសហការជាមួយអាជ្ញាធរមូលដ្ឋាននិងមន្ត្រីពាក់ព័ន្ធផ្សេងៗដើម្បីទប់ស្កាត់។ ជាក់ស្តែង **លោក ង៉ា ចុង** ចៅសង្កាត់នគរធំ ក៏បានរំឭកថា ច្រើនដងណាស់ដែលលោកហៅ **ថៃ ធឿង** ទៅជួបដើម្បីនិយាយគ្នា តែជននេះមិនសូវទៅ ហើយក៏ធ្លាប់ធ្វើកិច្ចសន្យានឹងបុគ្គលនេះច្រើនដងដែរកន្លងមក តែធ្វើរួច ជននោះនៅតែមិនបញ្ឈប់សកម្មភាពរបស់ខ្លួន។ លោកក៏បានលើកឡើងថា ដើម្បីទប់ស្កាត់ឱ្យបាន ក្រុមការងារទាំងអស់ ពិសេសមន្ត្រីប៉ូលិសបេតិកភណ្ឌត្រូវដាក់កម្លាំងតាមគ្រប់ជំហាននិងបង្ក្រាបលើបទល្មើសដាក់ស្តែង ហើយដាក់ទោសឱ្យសមនឹងកម្រិតទោស ទើបរាងចាល ដោយមិនអាចយោគយល់បានឡើយ ព្រោះកន្លងមកការយោគយល់គឺគ្មានប្រសិទ្ធិភាពចំពោះជននេះ។

ដោយឡែក សម្រាប់មន្ត្រីប៉ូលិសបេតិកភណ្ឌ បានអះអាងថា ចំពោះករណីដុតព្រៃនិងកាប់ព្រៃទន្ទ្រានយកដីនេះ គឺមិនបានដឹងព័ត៌មានឡើយ តែពីពេលនេះទៅ ក្រុមការងារនឹងចុះល្បាត ហើយសហការយ៉ាងជិតស្និទ្ធជាមួយក្រុមការងារអាជ្ញាធរជាតិអប្សរា អាជ្ញាធរមូលដ្ឋាន ដោយការចុះល្បាតឱ្យបានញឹកញាប់ ពិសេសបន្ថែមលើម៉ោងការងារដែលក្រុមអាជ្ញាធរជាតិអប្សរាផុតម៉ោងធ្វើការ។

គួរបញ្ជាក់ជូនថា សម្រាប់ការចុះពិនិត្យនៅរសៀលថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៨នេះ ក្រុមការងារចម្រុះមិនបានឃើញមានអ្នកបង្កហេតុឡើយ ព្រោះពួកគេបានគេចខ្លួនអស់ ហើយនឹងសម្ងំក្នុងផ្ទះ។ លើសពីនោះ ក៏បានឃើញការកាប់បន្ថែមទៀតដែលតាមការស្មានគឺធ្វើឡើងមួយថ្ងៃពីរថ្ងៃមុននេះពេលក្រុមការងារផុតម៉ោងការងារ៕









សេចក្តីជូនដំណឹងស្តីពីការកំណត់រយៈពេលនៃការបង់ថ្លៃសេវាសាធារណៈស្តីពីការគ្រប់គ្រងប្រមូលចំណូលផ្សេងៗក្នុងតំបន់រមណីយដ្ឋានអង្គរតាមកណ្តាលរបស់អាជ្ញាធរជាតិអប្សរានៅជនាគារជាតិនៃកម្ពុជា សាខាខេត្តសៀមរាប

ផ្សាយនៅថ្ងៃទី ២៦ ខែ មេសា ឆ្នាំ២០១៨



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លេខ ...../ប.ស/ណ
ស្តីពី

សេចក្តីជូនដំណឹង
ការកំណត់រយៈពេលនៃការបង់ថ្លៃសេវាសាធារណៈស្តីពីការគ្រប់គ្រងការប្រមូលចំណូល
ផ្សេងៗក្នុងតំបន់រមណីយដ្ឋានអង្គរតាមគណនីរបស់អាជ្ញាធរជាតិអប្សរា
នៅជនាគារជាតិនៃកម្ពុជា សាខាខេត្តសៀមរាប

អាជ្ញាធរជាតិអប្សរា មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ក្រប់ក្រសួង មន្ទីរស្ថាប័នជាតិ-អន្តរជាតិ សមាគមទីភ្នាក់ងារទេសចរណ៍ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ ក្រុមហ៊ុនទេសចរណ៍ សមាគមអ្នកបើកបរបង់បន្ថែមជំរាបជូនភ្ញៀវទេសចរ អ្នកបើកបរដើរជំរាបជូនភ្ញៀវទេសចរ ម្ចាស់សណ្ឋាគារ ទីភ្នាក់ងារទេសចរណ៍ ភ្ញៀវទេសចរជាតិ-អន្តរជាតិ ព្រមទាំងសាធារណៈជនទាំងអស់ជ្រាបថា បន្ទាប់ពីអាជ្ញាធរជាតិអប្សរា បានដាក់ឱ្យអនុវត្តការបង់ថ្លៃសេវាសាធារណៈតាមគណនីរបស់អាជ្ញាធរជាតិអប្សរានៅជនាគារជាតិនៃកម្ពុជាសាខាខេត្តសៀមរាបបាប់ថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៧ មកឃើញថា ការផ្តល់សេវាមានភាពស្មុគស្មាញ និងសណ្ឋានយ៉ាងខ្លាំង។ ទន្ទឹមនឹងនោះ ក្នុងគោលបំណងកែលម្អការផ្តល់សេវាសាធារណៈឱ្យកាន់តែប្រសើរឡើងមួយកម្រិតទៀត អាជ្ញាធរជាតិអប្សរា សូមកំណត់នីតិវិធី និងរយៈពេលនៃការបង់ថ្លៃសេវាសាធារណៈរបស់អាជ្ញាធរជាតិអប្សរា ដោយចាប់អនុវត្តពីថ្ងៃអង្គារ ៣រោច ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១៨ តទៅ៖

I-ការរៀបចំពិធីទទួលទានអាហារ និងសម្តែងសិល្បៈក្នុងឧទ្យានអង្គរ និងតំបន់ពាក់ព័ន្ធ

១-ការបង់ថ្លៃសេវាកំណត់រយៈពេលយ៉ាងបំផុត១០ថ្ងៃ (ថ្ងៃធ្វើការ) បន្ទាប់ពីការជូនដំណឹងពីមជ្ឈមណ្ឌលសេវាកម្មនៃអាជ្ញាធរជាតិអប្សរា។ ផុតកំណត់ខាងលើការស្នើសុំនឹងត្រូវទុកជាមោឃៈ។

២-ការដាក់ពាក្យស្នើសុំត្រូវបញ្ចូលគ្រប់កម្មវិធីដែលក្រុមហ៊ុនមានបំណងរៀបចំជូនភ្ញៀវទេសចរឱ្យបានលម្អិត និងច្បាស់លាស់ ក្រប់មកជាមួយនឹងសំណើសុំតែមួយដងគត់ ដើម្បីជូនអាជ្ញាធរជាតិអប្សរា ពិនិត្យនិងសម្រេច ដោយមិនអនុញ្ញាតឱ្យមានការស្នើសុំបន្ថែមផ្សេង។ទៀតឡើយ លើកលែងតែករណីបន្ថែមចំនួនភ្ញៀវតែប៉ុណ្ណោះ។

៣-កំណត់រយៈពេល០៥ថ្ងៃ (ថ្ងៃធ្វើការ) ក្នុងការទទួលពាក្យស្នើសុំ។ ការស្នើសុំមានរយៈពេលតិចជាង០៥ថ្ងៃ (ថ្ងៃធ្វើការ) ត្រូវពិន័យ២០%។ ក្នុងករណីតិចជាង០៣ថ្ងៃ (ថ្ងៃធ្វើការ) មុនថ្ងៃរៀបចំពិធីអាជ្ញាធរជាតិអប្សរាមិនទទួលពិនិត្យឡើយ លើកលែងតែករណីបន្ថែមភ្ញៀវដោយត្រូវបង់ថ្លៃសេវាតាមគោលការណ៍កំណត់។

៤-ត្រូវចូលរួមផ្សព្វផ្សាយពីក្រមប្រតិបត្តិអង្គជូនភ្ញៀវទេសចរចូលមកមុខដើ។

៥-ត្រូវគោរពតាមការណែនាំ និងសហការឱ្យបានដឹងស្និទ្ធជាមួយក្រុមការងារអាជ្ញាធរជាតិអប្សរាដែលចុះត្រួតពិនិត្យនិងតាមដានការរៀបចំកម្មវិធីពេលយប់ឱ្យបានល្អ។



៦-ត្រូវគោរព និងអនុវត្តតាមកិច្ចសន្យា និងខ្លឹមសារនៃលិខិតអនុញ្ញាត។ ក្នុងករណីអនុវត្តមិនបានត្រឹមត្រូវ អាជ្ញាធរជាតិអប្សរានឹងចាត់វិធានការដូចខាងក្រោម៖

- ប្រព្រឹត្តិខុសលើកទី១ នឹងទទួលបានលិខិតព្រមានជាលាយលក្ខណ៍អក្សរពីអាជ្ញាធរជាតិអប្សរា
- ប្រព្រឹត្តិខុសលើកទី២ បញ្ឈប់ការផ្តល់ការអនុញ្ញាតរយៈពេល ៦ខែ
- ប្រព្រឹត្តិខុសលើកទី៣ បញ្ឈប់ការផ្តល់ការអនុញ្ញាតរយៈពេល ៣ឆ្នាំ ឬរហូតតទៅ។

៧-អាជ្ញាធរជាតិអប្សរា និងបិទផ្សាយការកត់ត្រាមានស្នើសុំកម្មវិធីទទួលទានអាហារពេលល្ងាច និងសម្តែងសិល្បៈ នៅមជ្ឈមណ្ឌលសេវាកម្មនិងនៅតាមគេហទំព័រ http://apsaraauthority.gov.kh។

II-ការចំតែងអ្នក និងប្រភាពសន្លឹកក្នុងឧទ្យានអង្គរ និងតំបន់ពាក់ព័ន្ធ

១-ការបង់ថ្លៃសេវាកំណត់រយៈពេលយ៉ាងបំផុតត្រឹមថ្ងៃថត បន្ទាប់ពីការជូនដំណឹងពីមជ្ឈមណ្ឌលសេវាកម្មនៃអាជ្ញាធរជាតិអប្សរា។ ផុតកំណត់ខាងលើលិខិតអនុញ្ញាតត្រូវទុកជាមោឃៈ។

២-កំណត់រយៈពេល១០ថ្ងៃ (ថ្ងៃធ្វើការ) មុនថ្ងៃថត ក្នុងការទទួលពាក្យស្នើសុំ ចំតខ្សែភាពយន្តខ្នាតតូច/ខ្នាតធំ និងការចំតខ្សែភាពយន្តភាគឬភាពយន្តខ្នុទូរទស្សន៍ខ្នាតតូច/ខ្នាតធំ។

៣-កំណត់រយៈពេល០៥ថ្ងៃ (ថ្ងៃធ្វើការ) មុនថ្ងៃថត ក្នុងការទទួលពាក្យស្នើសុំចំតផ្សេង។ទៀត (ជុំចមានចែងក្នុងតារាង ឧបសម្ព័ន្ធ ស្តីពីការគ្រប់គ្រងការប្រមូលចំណូលពីសេវាផ្សេង។ក្នុងតំបន់រមណីយដ្ឋានអង្គរ)។

៤-ការដាក់ពាក្យស្នើសុំត្រូវផ្តល់ឯកសារឱ្បានគ្រប់គ្រាន់មើបអាជ្ញាធរជាតិអប្សរាពិនិត្យនិងសម្រេច។

៥-ការដាក់ពាក្យតិចជាង០៣ថ្ងៃ(ថ្ងៃធ្វើការ)មុនថ្ងៃថត អាជ្ញាធរជាតិអប្សរាមិនទទួលពិនិត្យឡើយ លើកលែងតែមានការសម្រេចពីឯកឧត្តមអគ្គនាយកអាជ្ញាធរជាតិអប្សរា។

រាល់ការបង់ថ្លៃសេវាសាធារណៈរបស់អាជ្ញាធរជាតិអប្សរា ត្រូវបានកំណត់នៅក្នុងកិច្ចសន្យានិងត្រូវបង់ចូលគណនីអាជ្ញាធរជាតិអប្សរានៅជនាគារជាតិនៃកម្ពុជាសាខាខេត្តសៀមរាប *ដោយពុំមានការបង់ថ្លៃសេវាបន្ថែមណាមួយផ្សេងទៀតឡើយ*។

អាជ្ញាធរជាតិអប្សរាសង្ឃឹមយ៉ាងមុតមាំថា ក្រប់ក្រសួង មន្ទីរស្ថាប័នជាតិ-អន្តរជាតិ សមាគមទីភ្នាក់ងារទេសចរណ៍ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ ក្រុមហ៊ុនទេសចរណ៍ សមាគមអ្នកបើកបរបង់បន្ថែមជំរាបជូនភ្ញៀវទេសចរ អ្នកបើកបរដើរជំរាបជូនភ្ញៀវទេសចរ ម្ចាស់សណ្ឋាគារ ទីភ្នាក់ងារទេសចរណ៍ ភ្ញៀវទេសចរជាតិ-អន្តរជាតិ ព្រមទាំងសាធារណៈជនទាំងអស់ នឹងចូលរួមអនុវត្ត និងជួយផ្សព្វផ្សាយឱ្យបានទូលំទូលាយ។

ថ្ងៃ...ខែចេត្រ ឆ្នាំកោ ឆស័ក ព.ស ២៥៦១
សៀមរាប ថ្ងៃទី...ខែមេសា ឆ្នាំ២០១៨

អគ្គនាយក

ស៊ុំ ម៉ាច់

ក្រុមការងាររបស់អាជ្ញាធរជាតិអប្សរាកំពុងជំរុញការកំណាយស្រះនៅប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី ២៦ ខែ មេសា ឆ្នាំ២០១៨

ក្រុមការងាររបស់នាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរ និងបុរាណវិទ្យាបង្ការនៃអាជ្ញាធរជាតិអប្សរា កំពុងដំណើរការកំណាយស្រះខាងជើងនៃប្រាសាទអង្គរវត្ត។ កំណាយទើបនឹងចាប់ផ្តើម ហើយអ្នកជំនាញពុំទាន់ប្រមូលទិន្នន័យបានច្រើនពីកំណាយនៅឡើយ។

ក្រុមអ្នកជំនាញបានចាប់ផ្តើមកំណាយ នៅស្រះខាងជើងប្រាសាទអង្គរវត្តចាប់ពីថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៨មក។ ក្នុងរយៈពេល៣ថ្ងៃ ចាប់ពីថ្ងៃទី២៣ ដល់ថ្ងៃទី២៥ អ្នកជំនាញមិនទាន់រកលទ្ធផលបានពីរចនាសម្ព័ន្ធស្រះនៅឡើយ។

អ្នកស្រី នេត ស៊ីមន បុគ្គលិកបច្ចេកទេស នៃនាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យាន និងបុរាណវិទ្យាបង្ការ ដែលកំពុងធ្វើកំណាយនៅស្រះអង្គរវត្តបានឱ្យដឹងថា ភ្លាមៗនេះក្រុមការងារមិនទាន់បានប្រទះឃើញរចនាសម្ព័ន្ធស្រះនៅឡើយ។ អ្នកស្រីបន្ថែមថា តាមគម្រោងក្រុមការងាររបស់អ្នកស្រី នឹងបើករណ្តៅនៅស្រះខាងជើងចំនួន២ទីតាំង គឺនៅផ្នែកខាងលិច និងខាងត្បូង។

អ្នកស្រីបន្ថែមថា៖« មូលហេតុដែលយើងធ្វើកំណាយនេះ គឺយើងចង់ដឹងពីការបង្កើនៅទីនេះ ថាតើវាទើបនឹងមាន ឬមានយូរហើយ មួយទៀតគឺយើងចង់ដឹងពីរចនាសម្ព័ន្ធស្រះទាំងមូល វាខូចខាតអ្វីខ្លះ ដើម្បីពេលយើងជួសជុលទៅឱ្យស្របតាមទម្រង់ដើម»។

ក្រុមអ្នកបច្ចេកទេសរបស់អាជ្ញាធរជាតិអប្សរាដែលកំពុងដឹកនាំធ្វើកំណាយនៅស្រះអង្គរវត្តមានចំនួន៤រូប ហើយតាមគម្រោង ពួកគេនឹងប្រើពេលចំនួន២ខែសម្រាប់គម្រោងមួយនេះ។ យ៉ាងណា **អ្នកស្រី នេត សុីមន** បញ្ជាក់ថា គម្រោងនេះអាចលើសពីរយៈពេលដែលបានកំណត់ ឬអាចរួចមុន ទៅតាមភាពជាក់ស្តែងដែលអ្នកស្រាវជ្រាវបានប្រទះរាល់រចនាសម្ព័ន្ធរបស់ស្រះ។

ដោយសារទីតាំងកំណាយស្ថិតនៅទីតាំងដែលភ្ញៀវទេសចរតែងឈរផ្តិតរូបរបស់ពួកគេ ទៅនឹងកំពូលប្រាង្គកណ្តាលនៃប្រាសាទអង្គរវត្ត ដូច្នេះវាបានទាញចំណាប់អារម្មណ៍ច្រើនដល់ពួកគេ ហើយអ្នកស្រាវជ្រាវនៅទីនោះតែងទទួលបានសំណួរពីភ្ញៀវទេសចរទាំងនោះផងដែរ។ ដូច្នេះហើយ ទើបមន្ត្រីបច្ចេកទេសនៃការដ្ឋានកំណាយ បានស្នើសុំដល់ភ្ញៀវទាំងអស់យោគយល់និងយល់ពីការងារដែលពួកគេកំពុងធ្វើ៕









សេចក្តីជូនដំណឹងស្តីពីការកាត់ដកហូតដើមឈើ និងកាត់ក្រឹមែកឈើដែលមានហានិភ័យខ្ពស់នៅតាមបរិវេណប្រាសាទ ក្នុងរមណីដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី ៣០ ខែ មេសា ឆ្នាំ២០១៨



ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA

ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

អាជ្ញាធរអប្សរា
APSARA

សេចក្តីជូនដំណឹង
ស្តីពី
ការកាត់ដកហូតដើមឈើ និងកាត់ក្រឹមែកឈើ
ដែលមានហានិភ័យខ្ពស់នៅតាមបរិវេណប្រាសាទ ក្នុងរមណីយដ្ឋានអង្គរ

អាជ្ញាធរអប្សរា សូមជូនដំណឹងដល់ស្ថាប័ន សមត្ថកិច្ចពាក់ព័ន្ធ ភ្ញៀវជាតិ-អន្តរជាតិ មគ្គុទ្ទេសក៍ទេសចរណ៍ ព្រមទាំងសាធារណជនទាំងអស់មេត្តាជ្រាបថា ដើម្បីធានាដល់សុវត្ថិភាពភ្ញៀវទេសចរ សាធារណជន កំដុចជាដើម្បីលើកកម្ពស់សោភ័ណភាពនៅតាមដងផ្លូវ និងនៅតាមបរិវេណប្រាសាទ ក្នុងតំបន់រមណីយដ្ឋានអង្គរ និងតំបន់ដែលគ្រប់គ្រងដោយអាជ្ញាធរអប្សរា នាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាន នៃអាជ្ញាធរអប្សរា នឹងធ្វើការកាត់ដកហូតដើមឈើ និងកាត់ក្រឹមែកឈើ តាមទីតាំងដូចខាងក្រោម៖

-កាត់ដកហូតដើមឈើងាប់ទាំងស្រុងចំនួន ០៥ដើម នៅក្នុងបរិវេណប្រាសាទកីមានអាកាស។

-កាត់ដកហូតដើមឈើងាប់ទាំងស្រុងចំនួន ០៣ដើម និងកាត់ក្រឹមែកចំនួន ០៥ដើម នៅក្នុងបរិវេណប្រាសាទព្រះប៉ាលិលេយ្យ។

-កាត់ដកហូតដើមឈើងាប់ចំនួន ០២ដើម នៅតាមផ្លូវចូលប្រាសាទតានែ និងជុះនៅក្បែរប៉ុស្តិ៍នគរបាលការពារបេតិកភ័ណ្ឌទី៨។

-កាត់ដកហូត និងកាត់ក្រឹមែកឈើចំនួន ០៨ដើម ដែលមានហានិភ័យខ្ពស់ស្ថិតនៅក្នុងបរិវេណប្រាសាទតាព្រហ្ម។

ការងារនេះ នឹងចាប់ផ្តើមអនុវត្តចាប់ពីថ្ងៃទី ១៨ ខែមេសា ឆ្នាំ២០១៨ រហូតដល់បញ្ចប់ការងារ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមស្ថាប័ន សមត្ថកិច្ចពាក់ព័ន្ធ ភ្ញៀវជាតិ-អន្តរជាតិ មគ្គុទ្ទេសក៍ទេសចរណ៍ ព្រមទាំងសាធារណជនទាំងអស់ មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃសុក្រ ១៣ ស៊ីរីទ្ធសក ស.ស ២៥៦១
ត្រូវនឹងថ្ងៃទី ២៧ ខែ ៧ ឆ្នាំ ២០១៨

ទីស្នាក់ការ

ធម្មនុជន៖
-សាលាខេត្តសៀមរាប
-មន្ទីរបរិស្ថានខេត្តសៀមរាប
-មន្ទីរកសិកម្ម ព្រៃឈើ និងនេសាទខេត្តសៀមរាប
-អង្គភាពនគរបាលការពារបេតិកភណ្ឌប្រចាំខេត្តសៀមរាប
-ស្នាក់ការគ្រប់គ្រងការពារទេសភាពអង្គរ
-សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ទាំងអស់ប្រចាំខេត្តសៀមរាប
-ដើម្បីជូនជ្រាប និងសហការ-
-ប៉ូលីសទេសចរណ៍
-ត្រប់ឆាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធរបស់អាជ្ញាធរអប្សរា
-ដើម្បីមេត្តា និងសហការ-
-ឯកសារ-កាលប្បវត្តិ

លេខទូរស័ព្ទទំនាក់ទំនង៖លោក គង់ សុវណ្ណារិទ្ធ 012-354-630, លោក ម៉ៀន សុធី 010-304-089,088-9522-5059,កញ្ញា ឆេង វុចនា 095-947-860

PHNOM PENH :
AUTHORITY FOR THE PROTECTION AND MANAGEMENT OF ANGKOR AND THE REGION OF SIEMREAP
Website : http://www.apsaraauthority.gov.kh
SIEM REAP :

កុលាលភាជន៍ចំនួន៦៤ឆ្នុ ផលិតក្នុងសម័យអង្គរមកពីខេត្តបុរីរម្យត្រូវបានប្រគល់ជូនអាជ្ញាធរជាតិអប្សរាក្សាទុក!

ផ្សាយនៅថ្ងៃទី ៣០ ខែ មេសា ឆ្នាំ២០១៨

កុលាលភាជន៍ចំនួនប្រាំកេស ស្មើចំនួន៦៤វត្ថុ មានដូចជាចាន ក្រឡ ដន្លាប់ ខួច មានស្រទាប់រលោងពណ៌បៃតងនិងពណ៌ត្នោត ត្រូវបានប្រគល់ជូនអាជ្ញាធរជាតិអប្សរាដោយវិទ្យាស្ថាន Smitsonian តាមរយៈស្ថានទូតសហរដ្ឋអាមេរិក ដើម្បីរក្សាទុក អភិរក្ស និងសិក្សា។ កុលាលភាជន៍ទាំងនេះផលិតនៅសម័យអង្គរ មានប្រភពមកពីខេត្តបុរីរម្យប្រទេសថៃនាពេលបច្ចុប្បន្ន។

លោកបណ្ឌិត អ៊ា ជាវិទ្ធ អនុប្រធានមជ្ឈមណ្ឌលអន្តរជាតិស្រាវជ្រាវនិងតម្កល់ឯកសារអង្គរ អ្នកតំណាងអាជ្ញាធរជាតិអប្សរា ក្នុងការទទួលកុលាលភាជន៍ទាំងនេះ បានឱ្យដឹងថា ប្រវត្តិនៃវត្ថុខាងលើ ត្រូវបានអ្នកស្រឡាញ់វត្ថុបុរាណជនជាតិជប៉ុននិងអាមេរិកប្រមូលទិញពីខេត្តបុរីរម្យ យកទៅសហរដ្ឋអាមេរិកក្នុងទសវត្សឆ្នាំ១៩៧០ ហើយបន្ទាប់មកបានប្រគល់ជូនវិទ្យាស្ថាន Smithsonian។ ដោយមានកិច្ចសហការល្អជាមួយអាជ្ញាធរជាតិអប្សរា វិទ្យាស្ថាន Smithsonian ក៏បានប្រគល់កុលាលភាជន៍ទាំងនេះឱ្យអង្គភាពកុលាលភាជន៍អង្គរជាអ្នកមើលការខុសត្រូវ។

ទាក់ទងនឹងភាជន៍ទាំងអស់ ចំពោះភាជន៍មួយចំនួនដែលល្អៗ អាជ្ញាធរជាតិអប្សរានឹងយកទៅតាំងពិព័រណ៌បង្ហាញជាសាធារណៈ ព្រោះអាជ្ញាធរជាតិអប្សរាមានគម្រោងតាំងពិព័រណ៌វត្ថុបុរាណដែលស្រាវជ្រាវបានជាង២០ឆ្នាំពីតំបន់អង្គរ។ លើសពីនោះ វត្ថុទាំងនោះនឹងត្រូវរក្សាទុកដើម្បីសិក្សាប្រៀបធៀបពីសម័យកាល បច្ចេកទេស និងគុណភាព រវាងកុលាលភាជន៍ដែលមានប្រភពពីបុរីរម្យ និងតំបន់អង្គរព្រោះកុលាលភាជន៍អាចឆ្លុះបញ្ចាំង ពីសម័យកាលមួយនៃប្រវត្តិសាស្ត្រខ្មែរ និងបង្ហាញពីជីវភាពរស់នៅរបស់ប្រជាជនសម័យអង្គរ ថាតើខ្មែរយើងមានលទ្ធភាពផលិតភាជន៍បានល្អកម្រិតណា។ នាសម័យបុរាណ ភាជន៍ត្រូវបានគេប្រើប្រាស់ប្រចាំថ្ងៃ ធ្វើជាគ្រឿងតាំងលម្អក្នុងផ្ទះ និងសម្រាប់ប្រើក្នុងពិធីសាសនាផ្សេងៗ ដូចជាពិធីសែនព្រេននិងបួងសួងជាដើម។

ពិធីប្រគល់កុលាលភាជន៍នេះប្រព្រឹត្តទៅស្ថានទូតសហរដ្ឋអាមេរិក កាលពីថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៨ រវាង **លោកបណ្ឌិត អ៊ា ជាវិទ្ធ** និង **លោក ជី សេរ៉ីឡា** (តំណាងអាជ្ញាធរជាតិអប្សរា) និង **លោកស្រី** Monica Davis (តំណាងស្ថានទូតអាមេរិក)។ នេះជាលើកទី១ហើយដែលកុលាលភាជន៍ដ៏ច្រើនបែបនេះត្រូវបានប្រគល់ជូនអាជ្ញាធរជាតិអប្សរា។ អាជ្ញាធរជាតិអប្សរាសំណូមពរដល់ប្រជាពលរដ្ឋដែលរើសបានវត្ថុបុរាណ សូមកុំរក្សាទុកឬលក់ដូរខុសច្បាប់ សូមយកវត្ថុបុរាណនោះមកប្រគល់ជូនអាជ្ញាធរជាតិអប្សរា ដើម្បីរក្សាទុក អភិរក្ស និងសិក្សាពីប្រវត្តិនៃវត្ថុសិល្បៈទាំងនោះ ដើម្បីចងក្រងជាឯកសារសម្រាប់ឱ្យអ្នកជំនាន់ក្រោយបានយល់ដឹងអំពីបុរាណវត្ថុខ្មែរ។

សូមបញ្ជាក់ថា ដោយមានកិច្ចសហការល្អជាមួយអាជ្ញាធរជាតិអប្សរា វិទ្យាស្ថាន Smithsonian ក៏ធ្លាប់បានរៀបចំសិក្ខាសាលាមួយស្តីអំពីថ្មនិងកុលាលភាជន៍ (Petrography workshop) ចាប់ពីថ្ងៃទី៥ ដល់ថ្ងៃទី៩ ខែមីនា ឆ្នាំ២០១៨កន្លងទៅ នៅអាជ្ញាធរជាតិអប្សរា មានអ្នកចូលរួម១៦នាក់មកពីប្រទេសអាស៊ីអាគ្នេយ៍ ដែលក្នុងនោះអ្នកជំនាញជនជាតិខ្មែរមានចំនួន០៨នាក់។ ក្រៅតែពីបានប្រគល់កុលាលភាជន៍ដ៏ច្រើន វិទ្យាស្ថាន Smithsonian ក៏បានផ្តល់ជូននូវសម្ភារៈមួយចំនួនដូចជា ម៉ាស៊ីនមីក្រូទស្សន៍ សម្ភារៈមន្ទីរពិសោធន៍ និងសៀវភៅស្តីពីការវិភាគថ្មនិងកុលាលភាជន៍ផងដែរ៕





ព្រឹត្តិការណ៍ព័ត៌មាន
ប្រចាំខែឧសភា

ផ្នែកទី ៤
ប្រចាំខែឧសភា

អាជ្ញាធរជាតិអប្សរានិងប្រជាមានិតចិនក្រោចចុះអនុស្សារណៈស្តីពីការចងសម្ពន្ធភាពតំបន់បេតិកភណ្ឌអន្តរនិងខេត្តសានស៊ី

ផ្សាយនៅថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ២០១៨

ឯកឧត្តម ហង់ ពៅ អគ្គនាយករងតំណាង **ឯកឧត្តម ស៊ុំ ម៉ាច** អគ្គនាយកអាជ្ញាធរជាតិអប្សរា កាលពីព្រឹកថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១៨ បានអនុញ្ញាតឱ្យប្រតិភូក្រុង Datong ខេត្តសានស៊ី នៃសាធារណរដ្ឋប្រជាមានិតចិន ដឹកនាំដោយ **លោក Feng Sujing** អភិបាលរងក្រុង Datong ចូលជួបសំណេះសំណាលការងារ មុននឹងឈានដល់កិច្ចព្រមព្រៀងចុះអនុស្សារណៈយោគយល់គ្នា ស្តីអំពីការចងសម្ពន្ធមេត្រីភាពរវាងតំបន់បេតិកភណ្ឌពិភពលោកនៃប្រទេសទាំងពីរគឺខេត្តសានស៊ី និងខេត្តសៀមរាប។

លោក Feng Sujing មានប្រសាសន៍ថា នៅក្រុង Datong មានប្រាសាទអ៊ីងកាង កសាងនៅសតវត្សរ៍ទី៤ ជាប្រាសាទពុទ្ធសាសនាធំជាងគេនៅលើពិភពលោក ឯខេត្តសៀមរាបក៏មានប្រាសាទអង្គរវត្តជាមជ្ឈមណ្ឌលសាសនាដ៏ធំនៅអាស៊ីអាគ្នេយ៍ ហើយជាសម្បត្តិបេតិកភណ្ឌពិភពលោកដូចគ្នា។ ដូច្នេះនេះគឺជាឆន្ទៈនិងគោលបំណងក្នុងការចងសម្ពន្ធភាពរវាងភាគីតាំងពីរ។ បច្ចុប្បន្នទីក្រុង Datong និងក្រុងសៀមរាប បានចុះហត្ថលេខាចងសម្ពន្ធមេត្រីភាពនៅប្រទេសចិនរួចមកហើយ។

លោកបានបន្តថា ប្រសិនជាមានការចងសម្ពន្ធមេត្រីភាពរវាងប្រាសាទទាំងពីរជាមួយគ្នា យើងអាចជំរុញនិងពង្រឹងកិច្ចប្រតិបត្តិការបន្ថែមទៀតលើវិស័យទេសចរណ៍ ការជួសជុល និងការអភិរក្សប្រាសាទ។ លោកនឹងស្វាគមន៍ដល់អ្នកជំនាញខ្មែរធ្វើទស្សនកិច្ចនៅខេត្តសានស៊ីនៅប្រទេសចិននាពេលអនាគតផងដែរ។

ថ្លែងក្នុងជំនួបនោះ **ឯកឧត្តម ហង់ ពៅ** បានសម្តែងនូវអំណរសាទរយ៉ាងជ្រាលជ្រៅចំពោះគណៈប្រតិភូចិនថាអាជ្ញាធរជាតិអប្សរាពេញចិត្តនឹងស្វាគមន៍រាល់កិច្ចសហប្រតិបត្តិការដែលបម្រើដល់ប្រយោជន៍បេតិកភណ្ឌទាំងមូល។ ដោយមើលឃើញចំណុចពិសេស សម្រាប់ការផ្លាស់ប្តូរបទពិសោធន៍រវាងខ្មែរ និងចិនក្នុងការអភិរក្សប្រាសាទ ការអភិវឌ្ឍវិស័យទេសចរណ៍ និងការគ្រប់គ្រងបេតិកភណ្ឌពិភពលោកឱ្យកាន់តែប្រសើរឡើង។ ម្យ៉ាងទៀតទស្សនវិស័យក្នុងការអភិរក្សនិងការអភិវឌ្ឍបេតិកភណ្ឌពិភពលោករវាងប្រទេសនៅអាស៊ី គឺមានទស្សនវិស័យប្រហាក់ប្រហែលគ្នា និងងាយសហការគ្នា។

ជាមួយគ្នានេះ ឯកឧត្តមក៏បានរំឭកនូវប្រត្តិសាស្ត្រដ៏យូរអង្វែងនៃទំនាក់ទំនងប្រទេសទាំងពីរ ទាំងផ្នែកសាសនា និងជំនួញ រួមទាំងការជួសជុលប្រាសាទកន្លងមកផងដែរ។ ឯកឧត្តម ក៏សង្ឃឹមថាទំនាក់ទំនងនេះកាន់តែល្អប្រសើរ តាមរយៈកិច្ចសហប្រតិបត្តិការនានាក្នុងតំបន់អង្គរនិងទំនាក់ទំនងផ្សេងៗ។






យុវជនស្ម័គ្រចិត្តបេតិកភណ្ឌបន្ទាយឆ្មារចែករំលែកបទពិសោធន៍ការចារ ដល់សិស្សានុសិស្សវិទ្យាល័យស្រះស្រង់

ផ្សាយនៅថ្ងៃទី ០៨ខែ ឧសភា ឆ្នាំ២០១៨

មានរយៈពេល៣ថ្ងៃនៅលើទឹកដីអង្គរ នាថ្ងៃទី៤ ទី៥ ទី៦ ខែឧសភា ឆ្នាំ២០១៨ យុវជនស្ម័គ្រចិត្តបេតិកភណ្ឌបន្ទាយឆ្មារ ជាសិស្សថ្នាក់ទី១០ ១១ និង១២ ចំនួន១៨នាក់ បានមកចែករំលែកបទពិសោធន៍ទាក់ទងនឹងការការពារ ថែរក្សា និងស្រាវជ្រាវបេតិកភណ្ឌក្នុងតំបន់ខ្លួនដល់សិស្សានុស្សវិទ្យាល័យស្រះស្រង់ និងស្វែងយល់បន្ថែមពីប្រវត្តិសាស្ត្រតំបន់អង្គរ ពីសំណាក់អ្នកជំនាញអាជ្ញាធរជាតិអប្សរាផង។

លោកនាយករងវិទ្យាល័យបន្ទាយឆ្មារ **យុត សារឿន** ជាអ្នកដឹកនាំយុវសិស្សទាំង១៨រូប បានឱ្យដឹងថាកម្មវិធីអប់រំ បេតិកភណ្ឌនៅបន្ទាយឆ្មារមានរយៈពេល៤ឆ្នាំហើយ គឺចាប់ផ្តើមពីឆ្នាំ២០១៤ ហើយទទួលបានជោគជ័យគួរឱ្យសប្បាយចិត្ត។ កម្មវិធីនេះមានការជួយផ្នែកបច្ចេកទេសពីអាជ្ញាធរជាតិអប្សរា អង្គការគាំពារកេរមរតក និងថវិកាពីភាគីថៃ។

ការបង្កើតឱ្យមានគម្រោងនេះ គឺដើម្បីឱ្យយុវជននៅក្នុងតំបន់បានស្គាល់អ្វីជាបុរាណដ្ឋាន មរតកវប្បធម៌ផ្សេងៗដែលមានក្នុងស្រុក ចេះការពារ ថែរក្សា អភិរក្ស ដើម្បីឱ្យភ្ញៀវទេសចរទៅមើល បង្កើនចំណូលដល់អ្នកស្រុក។

លោកគ្រូក៏បានលើកឡើងពីបញ្ហាដែលប្រឈមនៅក្នុងតំបន់បន្ទាយឆ្មារ គឺការដើរឆក់ កោស រូសលើថ្មប្រាសាទ ការជីកកកាយវត្ថុបុរាណ និងជួញដូរ តែក្រោយមានយុវជនស្ម័គ្រចិត្តបេតិកភណ្ឌ បញ្ហាទាំងនោះក៏លែងសូវកើតមាន ព្រោះពួកគេយល់និងចេះស្រឡាញ់សម្បត្តិដូនតា។ ចំពោះកិច្ចការនេះ នឹងធ្វើឱ្យសិស្សទទួលបានគំនិតចេះសរសេរស្រាវជ្រាវនិងយកបទពិសោធន៍ទៅសិក្សានៅមហាវិទ្យាល័យ។

យុវសិស្ស ពឿត ឆាលី ជាសិស្សថ្នាក់ទី១២ បានលើកឡើងថា នេះជាឱកាសល្អដែលបានមកធ្វើបទបង្ហាញដល់មិត្តនៅវិទ្យាល័យស្រះស្រង់ទាក់ទងនឹងការងារអប់រំបេតិកភណ្ឌ។ វាជាការងារដ៏រីករាយ ថ្វីត្បិតតែជួបបញ្ហាលំបាកខ្លះៗពេលចុះទៅស្រាវជ្រាវនៅកន្លែងឆ្ងាយ ដោយសារមធ្យោបាយធ្វើដំណើរ ការរុករកក្នុងព្រៃ តែវាមិនប៉ះពាល់ដល់ការសិក្សាទេ ព្រោះយើងធ្វើការស្រាវជ្រាវតែពេលទំនេរ។ ក្នុងនាមជាអ្នកបន្ទាយឆ្មារ ខ្ញុំត្រូវតែស្គាល់ថានៅតំបន់ខ្ញុំមានសក្តានុពលទេសចរណ៍រូបីនិងអរូបីអ្វីខ្លះ ទាន់មានឱកាសក្នុងការសិក្សា ហើយវាផ្តល់ចំណេះដឹងនិងបទពិសោធន៍ត្រៀមនៅសាកលវិទ្យាល័យ លើផ្នែកស្រាវជ្រាវនិងការប្រើប្រាស់កុំព្យូទ័ររបស់ខ្ញុំ។

យុវសិស្ស ជិន ប៉ូលី ថ្នាក់ទី១០អា បានសម្រេចចិត្តចូលកម្មវិធីនេះ ព្រោះការស្រឡាញ់វិស័យនេះនិងចង់ដឹងពីប្រវត្តិសាស្ត្រនិងភូមិសាស្ត្រដែលខ្លួនរស់នៅ។ ការងារនេះបង្រៀនប្អូនឱ្យចេះដឹងច្រើនទាក់ទងនឹងការស្រាវជ្រាវ កុំព្យូទ័រ និងចែករំលែកចំណេះដឹងទាំងនេះដល់ប្អូនៗនៅសាលាបឋមនៅបន្ទាយឆ្មារ។ ប្អូនក៏សំណូមពរឱ្យយុវជនទាំងអស់ចូលរួមចំណែកក្នុងការថែរក្សាស្រឡាញ់សម្បត្តិដូនតាឱ្យបានគង់វង្ស។

អ្នកគ្រូ មាំង សេរីវ័ត្ន គ្រូបង្រៀនពលរដ្ឋវិជ្ជានៃវិទ្យាល័យស្រះស្រង់ ពេញចិត្តជាខ្លាំងចំពោះគម្រោងសិក្សានេះ ព្រោះអ្នកគ្រូផ្ទាល់ក៏ស្រឡាញ់ការស្រាវជ្រាវចំពោះវត្ថុបុរាណនិងប្រាសាទនានា។ កម្មវិធីនេះ នឹងធ្វើឱ្យក្មេងៗស្គាល់ពីមូលដ្ឋានគ្រឹះមួយចំនួនពីការស្រាវជ្រាវ ហើយអាចដកស្រង់បទពិសោធន៍ផ្ទាល់ ពិសេសពួកគេស្ថិតក្នុងខេត្តសៀមរាបដែលសម្បូរដោយប្រាសាទស្រាប់ហើយបើអនាគតពួកគេចង់ក្លាយជាបុរាណវិទូឬមគ្គុទ្ទេសក៍វាកាន់តែងាយស្រួល។

យុវសិស្ស គឹម នឹង នៃវិទ្យាល័យស្រះស្រង់ ក៏សម្តែងនូវការសប្បាយចិត្តដែលបានចូលរៀនក្នុងគម្រោងនេះ ព្រោះប្អូនមានគោលបំណងចង់ស្រាវជ្រាវសម្បត្តិមរតកនៅក្នុងស្រុកប្អូន ហើយវាក៏ជាតួនាទីរបស់កូនខ្មែរគ្រប់រូបដែលត្រូវចូលរួមថែរក្សាសម្បត្តិបេតិកភណ្ឌជាតិដ៏មានតម្លៃឱ្យបានគង់វង្សផងដែរ៕









អាជ្ញាធរជាតិអប្សរាពង្រឹងសមត្ថភាពមន្ត្រីលើជំនាញសរសេរព័ត៌មាន

ផ្សាយនៅថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ២០១៨

នៅព្រឹកថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៨ នាស្នាក់ការអាជ្ញាធរជាតិអប្សរា បានបើកវគ្គបណ្តុះបណ្តាលស្តីពីជំនាញសរសេរព័ត៌មានដល់មន្ត្រីនិងបុគ្គលិកតាមនាយកដ្ឋានចំណុះ ក្នុងបំណងពង្រឹងការសរសេរព័ត៌មានបម្រើដល់ស្ថាប័នរបស់ខ្លួន។ សិក្ខាកាមដែលចូលរួមវគ្គបណ្តុះបណ្តាលនេះ គឺជាមន្ត្រីនិងបុគ្គលិកនៅនាយកដ្ឋាននានារបស់អាជ្ញាធរជាតិអប្សរា ដែលសរុបមានចំនួន២៩រូប។

វគ្គបណ្តុះបណ្តាលដែលមានរយៈពេល៣ថ្ងៃនេះ គឺចាប់ពីថ្ងៃទី៩ ដល់ទី១១ ខែឧសភា ធ្វើឡើងដើម្បីផ្តល់ឱកាសដល់មន្ត្រីនិងបុគ្គលិកទទួលបន្ទុកផ្នែកព័ត៌មានប្រចាំនាយកដ្ឋាននីមួយៗ ឱ្យទទួលបានការបណ្តុះបណ្តាលជំនាញសរសេរព័ត៌មាននិងពង្រឹងបន្ថែមនូវសមត្ថភាពក្នុងការសរសេរព័ត៌មានឱ្យបានល្អប្រសើរ ស្របទៅតាមគោលការណ៍នៃសារព័ត៌មាន។

លោក ឆាយ សុផល គ្រូបង្គោលនៃវគ្គបណ្តុះបណ្តាលជាសាស្ត្រាចារ្យសារព័ត៌មានដែលមានជំនាញ និងវិជ្ជាជីវៈ និងជាអ្នកសារព័ត៌មានអាជីពជាច្រើនឆ្នាំមកហើយ។ លោកបញ្ជាក់ថា វគ្គបណ្តុះបណ្តាលនេះសំខាន់ផ្តល់នូវចំណេះដឹងអំពីវិជ្ជាជីវៈមូលដ្ឋានគ្រឹះនៃការសរសេរសារព័ត៌មានព្រមទាំងក្រមសីលធម៌សារព័ត៌មាន។

លោក ឡុង កុសល ប្រធាននាយកដ្ឋានផ្សព្វផ្សាយ បានថ្លែងថាវគ្គបណ្តុះបណ្តាលនេះ គឺជាចំណេះដឹងបន្ថែមសម្រាប់មន្ត្រីនិងបុគ្គលិកនៅតាមនាយកដ្ឋានមួយចំនួន ដើម្បីមានគំនិតចេះផលិតព័ត៌មាននានាសម្រាប់យកមកផ្សព្វផ្សាយបម្រើដល់ស្ថាប័នអាជ្ញាធរជាតិអប្សរាទាំងមូល។

បន្ថែមពីនេះ លោកវាំពឹងថា វានឹងជួយឱ្យមន្ត្រី និងបុគ្គលិកដែលទទួលបន្ទុកផ្នែកព័ត៌មាន កាន់តែមានលទ្ធភាពអាចផលិតព័ត៌មានគ្រប់ទម្រង់ សំដៅធ្វើយ៉ាងណាពាំនាំព័ត៌មាន ព្រឹត្តិការណ៍សំខាន់ៗរបស់អាជ្ញាធរជាតិអប្សរាផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់សាធារណជន៕









សេចក្តីជូនដំណឹង

ផ្សាយនៅថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ២០១៨



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរអប្សរា
APSARA

លេខ.៣៤៨/ប្រ: សវ/ណ
១៨

សេចក្តីជូនដំណឹង

ថ្នី។ មានបុគ្គលមួយចំនួនប្រកាសលក់-ដឹក្តី ដោយបានផ្សព្វផ្សាយព័ត៌មានក្លែងក្លាយលើបណ្តាញព័ត៌មានសង្គម ដែលអះអាងថាមានការកាត់ដីមួយចំនួនចេញពីតំបន់រមណីយដ្ឋានអង្គរ និងអាចសាងសង់សំណង់ស្រាលជាប្រភេទលំនៅដ្ឋានបាន ស្ថិតក្នុងភូមិអណ្តូង សង្កាត់នគរដំ ក្រុងសៀមរាប ខេត្តសៀមរាប។

ដើម្បីជៀសវាងការខូចខាតផលប្រយោជន៍ក្នុងការទិញ-លក់ កាន់កាប់ដី អាជ្ញាធរជាតិអប្សរា សូមជម្រាបជូនសាធារណជនមេត្តាជ្រាបថា ៖

១. រាល់ការសាងសង់ទាំងអស់ក្នុងតំបន់រមណីយដ្ឋានអង្គរ ត្រូវមានការអនុញ្ញាតពីអាជ្ញាធរជាតិអប្សរា។

២. ស្របតាមដំពូកមួយ មាត្រា៨នៃព្រះរាជក្រឹត្យលេខ ០០១ន.ស ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៨ ស្តីពីការកំណត់ និងការចាត់ចែងគ្រប់គ្រងតំបន់សៀមរាបអង្គរ និងប្រការ១ និងប្រការ២ នៃសេចក្តីសម្រេចលេខ៣០សសរ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០៤ ស្តីពីការកំណត់បទដ្ឋានគតិយុត្តប្រើប្រាស់ដីនៅតំបន់១ និងតំបន់២ក្នុងតំបន់រមណីយដ្ឋានសៀមរាបអង្គរ ហាមឃាត់លើសកម្មភាពទិញ-លក់ដីរបស់ឈ្មួញក្នុងគោលដៅធ្វើអាជីវកម្មយកចំណេញសម្រាប់ក្រុមហ៊ុន ឬបុគ្គល ឬការទិញ-លក់សម្រាប់យកទៅសាងសង់សណ្ឋាគារ គោជនីយដ្ឋាន ខាងអូរទេ ជាដើម។ល។

៣. អាជ្ញាធរជាតិអប្សរានឹងចាត់វិធានការតាមផ្លូវច្បាប់ ចំពោះបុគ្គលណាដែលនៅតែបន្តក្នុងកុហកសាធារណជនក្នុងគោលបំណងកេងចំណេញដីធ្លីក្នុងតំបន់រមណីយដ្ឋានអង្គរ។

៤. អាជ្ញាធរជាតិអប្សរា សូមអំពាវនាវដល់សាធារណជនទាំងអស់ សូមកុំជាប់កលល្បិចបោកប្រាស់របស់បុគ្គលមួយក្តាប់តូច។

៥. សូមធ្វើការទំនាក់ទំនងមកកាន់អាជ្ញាធរជាតិអប្សរា នៅគ្រប់ទីតាំងទូទាំងឡាយណាពាក់ព័ន្ធនឹងការគ្រប់គ្រងដីធ្លីក្នុងតំបន់រមណីយដ្ឋានអង្គរតាមលេខទូរស័ព្ទ ០៩២ ៨៩ ៩៩ ៦៦ ឬតាមលេខទូរស័ព្ទថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា ដែលបានប្រកាសតាមគេហទំព័រផ្លូវការរបស់អាជ្ញាធរជាតិអប្សរា www.apsaraauthority.gov.kh ។

អាជ្ញាធរជាតិអប្សរា មិនទទួលខុសត្រូវ ចំពោះការខូចខាតផលប្រយោជន៍សាធារណជន ដែលបានទិញដីក្នុងតំបន់រមណីយដ្ឋានអង្គរនេះឡើយ។

ថ្ងៃ សុក្រ ១២ កើត ខែ ពិសាខ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស.២៥៦២
សៀមរាប ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ២០១៨

អគ្គនាយកអប្សរា

អាជ្ញាធរជាតិអប្សរាបើកវគ្គបណ្តុះបណ្តាល "កម្មវិធីអប់រំបេតិកភណ្ឌ" ដល់កុមារនៅសាលាបឋមសិក្សាស្រះស្រែ

ផ្សាយនៅថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ២០១៨

«កម្មវិធីអប់រំបេតិកភណ្ឌ» ជាកម្មវិធីថ្មីមួយដែលអាជ្ញាធរជាតិអប្សរាបង្កើតឡើងដើម្បីអប់រំ ដល់សិស្សបឋមសិក្សាឱ្យស្គាល់អំពីបេតិកភណ្ឌអង្គរដែលខ្លួនកំពុងរស់នៅជាមួយ បណ្តុះគំនិតស្រឡាញ់ និងការពារបេតិកភណ្ឌក្នុងតំបន់ខ្លួនឱ្យបានល្អប្រសើរ។ កម្មវិធីនេះ មានការចូលរួមសហការពីមជ្ឈមណ្ឌលយុវជនកម្ពុជា អង្គការគាំពារមរតក វិស័យឯកជន និងលោកគ្រូអ្នកគ្រូនៃសាលាគោលដៅក្នុងតំបន់។

លោក អ៊ឹម សុខវិទ្ធី អនុប្រធានមជ្ឈមណ្ឌលអន្តរជាតិស្រាវជ្រាវនិងតម្កល់ឯកសារអង្គរ បានឱ្យដឹងថា «កម្មវិធីអប់រំបេតិកភណ្ឌ» មានរយៈពេលមួយឆមាស គឺចាប់ផ្តើមដំណើរការនៅថ្ងៃទី១០ ខែឧសភា រហូតដល់ខែសីហា ឆ្នាំ២០១៨ ដោយការបង្រៀនដំបូង គឺយកថ្នាក់ទី៥និងទី៦ នៃសាលាបឋមសិក្សាស្រះស្រង់ ព្រោះជាពួកគេរស់នៅក្នុងតំបន់ដ៏មានអាទិភាពទាំងបុរាណដ្ឋាននិងទំនៀមទម្លាប់ប្រពៃណី ហើយសាលានេះ ក៏មានការសហការយ៉ាងល្អជាមួយក្រុមការងារផងដែរ។

លោក វិទ្ធី បន្តទៀតថា ក្នុង៦ខែនេះនឹងបង្រៀនឱ្យសិស្សដឹងថា អ្វីទៅដែលហៅថាបេតិកភណ្ឌ? ប្រភេទនៃបេតិកភណ្ឌ? អ្វីទៅជាបេតិកភណ្ឌជាតិ? អ្វីទៅជាបេតិកភណ្ឌពិភពលោក? ផលប្រយោជន៍និងតម្លៃរបស់បេតិកភណ្ឌចំពោះសហគមន៍? និងចំពោះជាតិ? តើត្រូវការពារបេតិកភណ្ឌអង្គរយ៉ាងណា? បញ្ហាបរិស្ថានចំពោះបេតិកភណ្ឌ?

ក្នុងនាមជាអ្នករៀបចំកម្មវិធី លោកអនុប្រធានមជ្ឈមណ្ឌលអន្តរជាតិស្រាវជ្រាវនិងតម្កល់ឯកសារអង្គរ ក៏រំពឹងទុកខ្ពស់ពីការទទួលបានអ្នកស្ម័គ្រចិត្តអភិរក្សបេតិកភណ្ឌវ័យក្មេងច្រើន ដែលមានចិត្តស្រឡាញ់ ចង់ថែរក្សា ការពារសម្បត្តិដូនតាដោយបេះដូងពិតៗ។ ពួកគេក៏នឹងក្លាយជាអ្នកនាំសារដ៏មានប្រសិទ្ធិភាពបំផុត ទៅកាន់សហគមន៍ដែលពួកគេរស់នៅ។ ពិសេសពួកគេនឹងមានទុនសម្រាប់ការសិក្សាស្រាវមេរៀននៅថ្នាក់ខ្ពស់ យល់ដឹងច្រើនពីសម្បត្តិវប្បធម៌ជាតិ ជាកត្តាជំរុញឱ្យពួកគេមានការចូលរួមចំណែកយ៉ាងសកម្មក្នុងកិច្ចការអភិរក្សបេតកភណ្ឌជាមួយអ្នកជំនាញបានកាន់តែល្អផងដែរ។





សារមន្ទីរវាយនកណ្តាលបើកឱ្យទស្សនាដោយឥតគិតថ្លៃក្នុងថ្ងៃទិវាសារមន្ទីរអន្តរជាតិ

ផ្សាយនៅថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ២០១៨

អាជ្ញាធរជាតិអប្សរា សហការជាមួយសារមន្ទីរវាយនកណ្តាប្រពៃណីអាស៊ី អិល ជី ស៊ី នឹងបង្កើតឱ្យមានការចូលទស្សនាដោយឥតគិតថ្លៃ នៅសារមន្ទីរវាយនកណ្តាប្រពៃណីអាស៊ី ដើម្បីចូលរួមអបអរទិវា សារមន្ទីរអន្តរជាតិ ១៨ ឧសភា។

កម្មវិធីអបអរសាទរ បើកទស្សនាដោយសេរីនៅក្នុងសារមន្ទីរវាយនកណ្តាប្រពៃណីអាស៊ី នឹងធ្វើឡើងនៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៨នេះ ចាប់ពីម៉ោង៨កន្លះព្រឹកតទៅ ត្រូវបានរៀបចំឡើងដោយក្រុមប្រឹក្សាសារមន្ទីរអន្តរជាតិ និងក្រុមប្រឹក្សាសារមន្ទីរជាតិ។

សូមសាធារណជនទាំងអស់ មកចូលរួមទស្សនាការដាក់បង្ហាញនូវ ផលិតផលប្រពៃណីដ៏សម្បូរបែបនៅក្នុងសារមន្ទីរវាយនកណ្តាប្រពៃណីអាស៊ី ដែលមានទីតាំងនៅផ្លូវ៦០ម៉ែត្រ ខាងត្បូងរង្វង់មូល ក្នុងភូមិបឹងដូនប៉ា សង្កាត់ស្លក្រាម ក្រុងសៀមរាប។

គួរឲ្យកត់ថា សារមន្ទីរវាយនកណ្តាប្រពៃណីអាស៊ី ជាសមិទ្ធផលនៃកិច្ចសហប្រតិបត្តិការរវាងរដ្ឋាភិបាលឥណ្ឌាជាមួយបណ្តាប្រទេសតំបន់ទន្លេមេគង្គរួមមានរដ្ឋាភិបាលកម្ពុជា វៀតណាម ថៃ មីយ៉ាន់ម៉ា និងឡាវ៕









អាជ្ញាធរជាតិអប្សរា និងសារមន្ទីរដ្ឋធានីរបស់ចិន ចុះអនុស្សរណៈយោគយល់ក្លាបឡើក ជំនាក់ជំនងក្លាលើការចារសារមន្ទីរ

ផ្សាយនៅថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ២០១៨

នៅរសៀលថ្ងៃទី១៨ ឧសភា ឆ្នាំ២០១៨ នៅស្នាក់ការអាជ្ញាធរជាតិអប្សរា បានរៀបចំពិធីចុះអនុស្សរណៈយោគយល់គ្នារវាងអាជ្ញាធរជាតិអប្សរា និងសារមន្ទីរដ្ឋធានីរបស់ចិន ដើម្បីធ្វើការរួមគ្នាលើវិស័យសារមន្ទីរ។ គោលបំណងនៃអនុស្ស រណៈនេះក៏មានបំណងដើម្បីផ្លាស់ប្តូរការតាំងពិព័រណ៍ ការស្រាវជ្រាវ និងផ្លាស់ប្តូរបទពិសោធន៍ ព្រមទាងបណ្តុះបណ្តាលអ្នកជំនាញផ្នែកសារមន្ទីរផងដែរ។

ពិធីចុះអនុស្សរណៈយោគយល់ត្រូវបានធ្វើឡើងដោយអគ្គនាយកអាជ្ញាធរជាតិអប្សរា **ឯកឧត្តមបណ្ឌិត ស៊ុ ម៉ាប់** និងប្រធានសារមន្ទីរដ្ឋធានី **លោក HAN Zhanming**។ ខ្លឹមសារពិស្តារពីបំណងនៃពិធីចុះអនុស្សរណៈយោគយល់រវាងស្ថាប័នទាំងពីរ រួមមាន បង្កើតការផ្លាស់ប្តូរការសិក្សាស្រាវជ្រាវផ្តោតលើសមុច្ច័យរបស់សារមន្ទីរទាំងពីរ បង្កើតការផ្លាស់ប្តូរស្តពីការតាំងពិព័រណ៍ និងសហការអភិរក្សរួមគ្នារវាងភាគីទាំងពីរ បង្កើតការផ្លាស់ប្តូរបុគ្គលិកនិងអ្នកជំនាញសារមន្ទី និងអញ្ជើញបុគ្គលិកសារមន្ទីរចូលរួមក្នុងសន្និសីទនិងសកម្មភាពផ្សេងៗទៀត។

មានមតិស្វាគមន៍ក្នុងពិធីចុះអន្សរសណៈយោគយល់នេះដែរ **ឯកឧត្តមបណ្ឌិត ស៊ុ ម៉ាប់** អគ្គនាយកអាជ្ញាធរជាតិអប្សរា បានរម្លឹកឡើងវិញនូវទំនាក់ទំនង គ្នាយ៉ាងល្អប្រសើររវាងភាគីចិន និងកម្ពុជា ហើយស្ថាប័នមួយ របស់ចិនក៏បាននិងកំពុងជួយការងារជួសជុលប្រាសាទបុរាណខ្មែរផងដែរ។ ម្យ៉ាងទៀត នេះជាលើកទី២ហើយ ដែលអាជ្ញាធរជាតិអប្សរា បានចុះអនុស្សរណៈយោគយល់ជាមួយភាគីចិន ទាក់ទងនឹងវិស័យសារមន្ទីរ។ បន្ថែមពីនេះ ឯកឧត្តមអគ្គនាយកក៏បានរៀបរាប់ពីសារមន្ទីរដែលស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា រួមមាន សារមន្ទីរព្រះនរោត្តម សីហនុ-អង្គរ សារមន្ទីរវាយនភណ្ឌអាស៊ីនិងសារមន្ទីរកុលាលភាជន៍ភូមិតានី។

គួរបញ្ជាក់ថា អនុស្សរណៈនេះរៀបចំឡើងស្របពេលដែលពិភពលោកកំពុងអបអរទិវាសារមន្ទីរអន្តរជាតិ ១៨ ឧសភា ក្រោមប្រធានបទ «សារមន្ទីរដែលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធ វិធីសាស្ត្រថ្មី សាធារណជនថ្មី (Hyperconnected Museums New approaches, new publics)»។









សារមន្ទីរតាយនកណ្តាអាស៊ី អិម ជី ស៊ី ចូលរួមអបអរទិវាសារមន្ទីរអន្តរជាតិក្រោមប្រធានបទ «សារមន្ទីរដែលមានចំណាក់ចំនងយ៉ាងជិតស្និទ្ធ វិធីសាស្ត្រថ្មី សាធារណជនថ្មី»

ផ្សាយនៅថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ២០១៨

ជារៀងរាល់ឆ្នាំនៅថ្ងៃទី១៨ ឧសភា ពិភពលោកបានប្រារព្ធទិវាសារមន្ទីរអន្តរជាតិ។ ប្រធានបទសម្រាប់អបអរទិវាសារមន្ទីរជាតិនៅឆ្នាំនេះ គឺ «សារមន្ទីរដែលមានចំនាក់ចំនងយ៉ាងជិតស្និទ្ធ វិធីសាស្ត្រថ្មី សាធារណជនថ្មី»។ សារមន្ទីរតាយនកណ្តាអាស៊ី អិម ជី ស៊ី ក៏បានចូលរួមអបអរសាទរក្នុងទិវាដ៏មានសារប្រយោជន៍នេះដែរ។

ដើម្បីជាការអបអរទិវាសារមន្ទីរអន្តរជាតិ (International Museum Day) សារមន្ទីរតាយនកណ្តាអាស៊ី បានបើកឱ្យសាធារណជនទាំងអស់ ចូលទស្សនាក្នុងសារមន្ទីរដោយឥតគិតថ្លៃរយៈពេលពេញមួយថ្ងៃទី១៨ ឧសភា ចាប់ពីម៉ោង៨ព្រឹកតទៅ។ ជាមួយគ្នានេះ សារមន្ទីរជាតិក៏បានចូលរួមអបអរសាទរចំពោះទិវានេះដែរ។ នេះបើតាមការលើកឡើងរបស់ **លោកជំទាវ ចៅ ស៊ុនកិរិយា** ។

សមាជិកអគ្គលេខាធិការនៃក្រុមប្រឹក្សាអន្តរជាតិនៃសារមន្ទីរកម្ពុជា (International council of museums Cambodia) **លោកជំទាវ ចៅ ស៊ុនកិរិយា** បានលើកឡើងថា ថ្ងៃទី១៨ ឧសភា ជាថ្ងៃដែលប្រជាជនគ្រប់រូបត្រូវចងចាំ។ លោកជំទាវបន្ថែមថា កម្ពុជាបានក្លាយជាបេក្ខភាពក្នុងក្រុមប្រឹក្សាអន្តរជាតិនៃសារមន្ទីរ (International council of museums =ICOM) ចាប់ពីឆ្នាំ១៩៩៧មកម្លេះ ហើយសារមន្ទីរទាំងអស់ជាសមាជិកភាពនៃស្ថាប័នដ៏មានសារសំខាន់មួយនេះ។

គួរម្លឹកថា ក្រុមប្រឹក្សាសារមន្ទីរអន្តរជាតិ ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៤៦ ដែលមានស្នាក់នៅទីក្រុងប៉ារីស ប្រទេសបារាំង។ ក្រុមប្រឹក្សានេះបង្កើតឡើងក្នុងបំណងដើម្បីលើកកម្ពស់ និងការពារបេតិកភណ្ឌធម្មជាតិ និងបេតិកភណ្ឌវប្បធម៌ នាពេលបច្ចុប្បន្ន និងអនាគត ទាំងផ្នែករូបី និងអរូបី។ បច្ចុប្បន្ន សមាជិកភាពនៃក្រុមប្រឹក្សាអន្តរជាតិសារមន្ទីរ មានចំនួនជាង ៣៧០០០ នៅក្នុងប្រទេសចំនួន ១៤១៕

ភូមិធម្មជាតិរុនតាឯកទទួលបានការឧបត្ថម្ភអគារសិក្សាមួយខ្នង

ពីអង្គការ ARK Beautiful Earth for Children

ផ្សាយនៅថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ២០១៨

ភូមិធម្មជាតិរុនតាឯក ដែលមានទីតាំងនៅឃុំរុនតាឯក ស្រុកបន្ទាយស្រី ខេត្តសៀមរាប នឹងទទួលបានការឧបត្ថម្ភអាគារសិក្សាមួយខ្នងស្មើ៥បន្ទប់ពីអង្គការ ARK BeaBeautiful Earth for Children។ ជាក់ស្តែង នៅព្រឹកថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៨ ពិធីបញ្ចុះបឋមសិលាបានប្រព្រឹត្តទៅក្រោមវត្តមាន **ឯកឧត្តម ហាច ពៅ** អគ្គនាយករងតំណាង **ឯកឧត្តម បណ្ឌិត ស៊ុំ ម៉ាប់** អគ្គនាយកអាជ្ញាធរជាតិអប្សរា និង **លោកស្រី សាន ណារី** តំណាងអង្គការ ARK Beautiful Earth for Children របស់ប្រទេសជប៉ុន។

លោក ភ័ន ផល្លា ប្រធាននាយកដ្ឋានរដ្ឋបាល បុគ្គលិក និងសម្ភារៈ ទទួលបន្ទុកជាអនុប្រធានគម្រោងអភិវឌ្ឍន៍ភូមិធម្មជាតិរុនតាឯកបានឱ្យដឹងថា អគារសិក្សាមួយខ្នងនេះជាសមិទ្ធផលថ្មីមួយរបស់គម្រោងភូមិធម្មជាតិរុនតាឯក ដែលបានទទួលការឧបត្ថម្ភពីអង្គការ ARK Beautiful Earth for Children របស់ប្រទេសជប៉ុន។ គម្រោងនេះនឹងចាប់ផ្តើមសាងសង់ពីថ្ងៃទី២២ ខែឧសភា រហូតដល់ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៨ មាន៥បន្ទប់ ចែកជាទីចាត់ការ១បន្ទប់ ថ្នាក់រៀន៤បន្ទប់ បំពាក់ដោយគ្រឿងបរិក្ខាសិក្សានិងការិយាល័យគ្រប់បន្ទប់។

លោក ផល្លា បានបញ្ជាក់ថា បច្ចុប្បន្នសាលារៀននៅភូមិធម្មជាតិរុនតាឯកមានត្រឹមដល់ថ្នាក់ទី៥ប៉ុណ្ណោះ តែនៅពេលមានអគារសិក្សាថ្មីនោះសិស្សនឹងអាចសិក្សាពីថ្នាក់ទី៦ដល់ទី៨ នៅទីនេះបាន ដោយមិនបាច់ធ្វើដំណើរឆ្ងាយទៅក្រៅភូមិ ដើម្បីសម្រួលដល់ការធ្វើដំណើរ សុវត្ថិភាព និងការសិក្សារបស់កុមារនៅតំបន់នេះ។

ក្នុងនាមតំណាងម្ចាស់ជំនួយ **លោកស្រី សាន ណារី** មានប្រសាសន៍ថា អង្គការ ARK Beautiful Earth for Children មានមូលនិធិសម្រាប់ជួយសាងសង់សាលារៀនទូទាំងពិភពលោក។ ចំណែកនៅប្រទេសកម្ពុជា អង្គការនេះបានជួយសាងសង់សាលាបានប្រមាណជាង២០ខ្នងរួចមកហើយនៅតាមតំបន់ឆ្ងាយៗពីការអភិវឌ្ឍ រួមមាននៅខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តតាកែវ និងចុងក្រោយនៅខេត្តសៀមរាបគឺភូមិធម្មជាតិរុនតាឯក។

លោកស្រីបានបន្តថា មានតែការអប់រំទេ ដែលធ្វើឱ្យមនុស្សមានការចេះដឹង ប្រទេសជាតិរីកចម្រើន ទើបអង្គការ ARK Beautiful Earth for Children ចូលរួមចំណែកជាមួយរដ្ឋាភិបាលកម្ពុជា ដោយប្រមូលថវិកាពីសម្បុរជនជប៉ុនជួយសាងសង់សាលារៀនឱ្យបានច្រើនតាមលទ្ធភាព ព្រោះប្រទេសយើងនៅខ្វះសាលាច្រើន។ ដោយឡែក គម្រោងសាងសង់អាគារសិក្សានៅភូមិធម្មជាតិរុនតាឯកជាគម្រោងចុងក្រោយសំរាប់អង្គការ ARK Beautiful Earth for Children តែមិនមានន័យថាអង្គការនឹងបញ្ឈប់ការជួយនៅកម្ពុជាទេ គឺយើងកំពុងពិចារណាថា តើនឹងមានគម្រោងអ្វីបន្ថែមសម្រាប់ជួយអភិវឌ្ឍន៍ភូមិធម្មជាតិរុនតាឯកនិងតំបន់ដទៃទៀតឱ្យកាន់តែប្រសើរឡើង៕






ប្រជាជនភៅភូមិត្រាច ស្រុកប្រាសាទបាគង ទទួលបានការបណ្តុះបណ្តាលស្តីពីសុវត្ថិភាព និងការប្រើប្រាស់ថ្នាំគីមីលើដំណាំកសិកម្ម

ផ្សាយនៅថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ២០១៨

ដើម្បីរួមចំណែកលើកស្ទួយជីវភាពប្រជាជនក្នុងតំបន់អង្គរគម្រោង ACHA នៃអាជ្ញាធរជាតិអប្សរាផ្នែកកសិកម្មសហការជាមួយអង្គរ IDE (In Partnership Promoting Agribusiness) បើកវគ្គបណ្តុះបណ្តាលដល់ប្រជាជន៣០នាក់នៅភូមិត្រាច ឃុំបល្ល័ង្ក ស្រុកប្រាសាទបាគង ខេត្តសៀមរាប ស្តីអំពី «សុវត្ថិភាពនិងប្រសិទ្ធភាពនៃការប្រើប្រាស់ថ្នាំគីមីលើដំណាំកសិកម្ម» កាលពីថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៨។

វគ្គបណ្តុះបណ្តាលនេះបង្រៀនទាំងទ្រឹស្តីនិងការអនុវត្ត ឱ្យប្រជាកសិករដែលដាំដំណាំចេះពីរបៀបបាញ់ថ្នាំគីមីលើដំណាំឱ្យបានត្រឹមត្រូវ មានសុវត្ថិភាព និងប្រសិទ្ធិភាព (ការប្រើប្រាស់សម្លៀកបំពាក់ ម៉ាស់សុវត្ថិភាព ស្រោមដៃ វ៉ែនតា) ឱ្យស្គាល់ពីសត្វបំផ្លាញដំណាំនិងសត្វដែលមានប្រយោជន៍ រួមទាំងវិធីទប់ស្កាត់ពីការបំផ្លាញរបស់សត្វល្អិត និងជំងឺផ្សេងៗផងដែរ។

អ្នកគ្រូ ចាន់ សុមនា អ្នកសម្របសម្រួលផ្នែកគីមីកសិកម្មរបស់អង្គការIDE បានលើកឡើងថា ភាគច្រើនកសិកប្រើប្រាស់ថ្នាំគីមីទៅតាមទម្លាប់ មិនយកចិត្តទុកដាក់ពីសុវត្ថិភាពអាយុជីវិតពួកគាត់ទេ។ ដូច្នេះ វគ្គបណ្តុះបណ្តាលនេះធ្វើឡើងដើម្បីឱ្យពួកគាត់ស្វែងយល់បានច្បាស់ពីការប្រើប្រាស់ថ្នាំនិងការការពារខ្លួនពីសារធាតុគីមី ដែលទាមទារឱ្យគាត់យកចិត្តទុកដាក់ខ្ពស់ក្នុងការស្លៀកពាក់ឱ្យបានត្រឹមត្រូវ មើលបរិស្ថានជុំវិញពាក់ព័ន្ធកន្លែងទុកដាក់ថ្នាំ កន្លែងដែលត្រូវបាញ់ថ្នាំ ស្គាល់សត្វល្អិតចង្រៃឬក៏សត្វល្អិតមានប្រយោជន៍មុននឹងបាញ់ថ្នាំ។ ចុងក្រោយ គឺផ្តោតទៅលើអ្នកបរិភោគ ត្រូវមើលសេចក្តីណែនាំឱ្យបានច្បាស់លាស់ពីការបាញ់ថ្នាំ តើប៉ុន្មានថ្ងៃបន្ទាប់ពីការបាញ់អាចប្រមូលផលទៅបរិភោគបាន ដែលមិនធ្វើឱ្យមានផលប៉ះពាល់ដល់សុខភាព។

អ្នកស្រី ឈិ រិ ជាកសិករគំរូប្រចាំភូមិត្រាច បានលើកឡើងថា នេះជាលើកទី១ហើយទទួលបានវគ្គបណ្តុះបណ្តាលស្តីពីការប្រើប្រាស់ថ្នាំកសិកម្ម។ អំស្រីអរគុណដល់អាជ្ញាធរជាតិដែលបានផ្តល់ពូជ ការទំនុកបម្រុងផ្សេងៗទាក់ទងនឹងការដាំដំណាំ រួមទាំងក្រុមការងារអង្គការ IDE ដែលតែងយកចិត្តទុកដាក់ណែនាំ តាមដាន និងបង្រៀនឱ្យស្គាល់ពីសត្វល្អមានប្រយោជន៍ និងសត្វចង្រៃពិសេសជួយដោះស្រាយភ្លាមៗពេលដំណាំមានបញ្ហា។

ទាក់ទងនឹងការអភិវឌ្ឍជីវភាពប្រជាជនក្នុងតំបន់អង្គរតាមរយៈកសិកម្មនេះ **លោក ឡាច វីយ៉ា** បុគ្គលិកបច្ចេកទេសនៃគម្រោង ACHA ឱ្យដឹងថា ក្រុមការងារបានចុះជួយប្រជាកសិករក្នុងតំបន់រមណីយដ្ឋានអង្គរជាប្រចាំថ្ងៃនៅតាមភូមិឃុំគោលដៅ ដូចជា ឃុំដូនកែវ ឃុំសំរោងយារ ក្របីរៀល ព្រះដាក់ ភូមិសាលាក្រាំន (ភ្នំបូក) និងភូមិត្រាច (ចៅស្រីវិបុល)។ អាជ្ញាធរជាតិអប្សរាបានផ្តល់ពូជបន្លែ ពូជសត្វ ព្រមទាំងរកទីផ្សារខ្លះៗដើម្បីលើកស្ទួយជីវភាពអ្នកស្រុកឱ្យប្រសើរជាងមុន។ ពិសេសគឺសហការជាមួយអង្គការ IDE ដើម្បីបង្រៀនប្រជាជនឱ្យបានយល់ដឹងពីការដាំដុះ ដើម្បីទទួលបានទិន្នផលល្អ៕






អង្គភាពប្រព័ន្ធគ្រប់គ្រងបរិស្ថានអង្គរនៃអាជ្ញាធរជាតិអប្សរា ទើបនឹងទទួលបានវិញ្ញាបនបត្រថ្មីពីស្ថាប័ន JQA

ផ្សាយនៅថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ២០១៨

អង្គភាពប្រព័ន្ធគ្រប់គ្រងបរិស្ថានអង្គរ (EMS) ទើបនឹងទទួលបានវិញ្ញាបនបត្រថ្មីពីស្ថាប័ន JQA (Japan Quality Assurance) ដែលជាស្ថាប័នវាយតម្លៃកម្រិតស្តង់ដា ISO ផ្នែកបរិស្ថាន។ វិញ្ញាបនបត្រថ្មីនេះ ជាកម្រិតស្តង់ដា ដែល EMS ទើបនឹងទទួលបាននៅថ្ងៃទី២០ ឧសភា ឆ្នាំ២០១៨ ជាប្រភេទស្តង់ដា ISO 14001 ឆ្នាំ2015។

នៅព្រឹកថ្ងៃទី២២ ឧសភា នៅស្នាក់ការអាជ្ញាធរជាតិអប្សរា បានរៀបចំសិក្ខាសាលាផ្ទៃក្នុងស្តីពី «ការអនុវត្តប្រព័ន្ធគ្រប់គ្រងបរិស្ថាន-អង្គរ អនុលោមតាមស្តង់ដាអន្តរជាតិ ISO 14001:2015»។ សិក្ខាសាលានេះមានគោលបំណងដើម្បីផ្សព្វផ្សាយសៀវភៅប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងបរិស្ថាន-អង្គរ ផ្សព្វផ្សាយផែនការ និងការអនុវត្តការងារបរិស្ថាននាយកដ្ឋាននីមួយៗ និងស្វែងយល់ពីដំណោះស្រាយរួម ប្រសិទ្ធិភាពការងារ និងការកែលម្អប្រព័ន្ធ។

មានមតិសំណេះសំណាល និងបើកសិក្ខាសាលាខាងលើ **ឯកឧត្តម សុខ លក្ខិណា** ប្រធានអង្គភាពប្រព័ន្ធគ្រប់គ្រងបរិស្ថានអង្គរ បានឱ្យដឹង កាលពីថ្ងៃទី២០ ឧសភា ស្ថាប័ន JQA ទើបនឹងផ្តល់នូវវិញ្ញាបនបត្រថ្មីដល់អង្គភាព EMS។ ឯកឧត្តមបន្ថែមថា វិញ្ញាបនបត្រនេះ គឺជាកម្រិតស្តង់ដាវាយតម្លៃផ្នែកបរិស្ថាន ISO 14001:2015 ដែលខុសពីរាល់ដង ដែលជាកម្រិតស្តង់ ISO 14001:2004 ។ ឯកឧត្តមពន្យល់ថា៖« វិញ្ញាបនបត្រថ្មីនេះ គឺដូចគ្នាទេ។ នៅចុងខែមួយ ដើមខែពីរកន្លងទៅ ក្រុមសវនករបានចុះមកធ្វើសវនកម្មដើម្បីយកខ្លឹមសារទៅស្ថាប័ន JQA ហើយគេទើបនឹងសម្រេចផ្តល់ស្តង់ដាថ្មីមកយើងកាលពី២ថ្ងៃមុននេះ។

ខ្ញុំគិតថា ប្រហែលនេះជាកម្រិតស្តង់ដាថ្មីដែលអង្គភាពយើងបានប្រើប្រាស់មុនគេក៏ថាបាន ព្រោះមិនធ្លាប់ឃើញក្រុមហ៊ុនអង្គភាពណាប្រើប្រាស់វានៅឡើយ ឃើញតែត្រឹមស្តង់ដា ISO 14001:2004 ដែលជាកម្រិតស្តង់ដាចាស់»។

ក្រៅពីមានមោទនភាពចំពោះលទ្ធផលខាងលើនេះហើយ **ឯកឧត្តម សុខ លក្ខិណា** ក៏បានក្រើនរម្លឹកដល់មន្ត្រី និងបុគ្គលិកតាមនាយកដ្ឋានពាក់ព័ន្ធដែលបានចូលរួមក្នុងសិក្ខសាលាខាងលើ ត្រូវយកចិត្តទុកដាក់បន្ថែម និងប្រឹងប្រែងរក្សានិរន្តរភាពចំពោះអ្វីដែលស្ថាប័នអន្តរជាតិ JQA បានផ្តល់ឱ្យនេះ។

គួរបញ្ជាក់ថា នេះជាលើកទី៥ហើយ ដែលអាជ្ញាធរជាតិអប្សរាទទួលវិញ្ញាបនបត្រស្តង់ដា ISO។ ក្នុងនោះ លើកទី១ ឆ្នាំ២០០៦ វិញ្ញាបនបត្រ ISO 14001 ដោយមានស្ថាប័នជប៉ុនទាំង៤ មាន JQA, Sophia, ISRI, JQAI នៅបន្តជួយជាបច្ចេកទេសដើម្បីជំរុញការងារប្រព័ន្ធគ្រប់គ្រងបរិស្ថាននេះឱ្យដំណើរការជាប្រក្រតី។ លើកទី២ ឆ្នាំ២០០៩ លើកទី៣ ឆ្នាំ២០១២ ទី៤ ឆ្នាំ២០១៥ ទទួលបានវិញ្ញាបនបត្រ ISO 14001 តាមរយៈការវាយតម្លៃ និងផ្តល់វិញ្ញាបនបត្រនេះដោយស្ថាប័ន JQA និងទី៥ ឆ្នាំ២០១៨ វិញ្ញាបនបត្រ ISO 14001:2015 តាមរយៈការវាយតម្លៃ និងផ្តល់វិញ្ញាបនបត្រនេះដោយស្ថាប័នJQA៕









ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា នាំយកអំណោយសង្គ្រោះបឋមជូនដល់ប្រជាពលរដ្ឋរងគ្រោះធម្មជាតិ នៅឃុំចាកង

ផ្សាយនៅថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ២០១៨

ថ្ងៃទី២២ខែ ឧសភា ឆ្នាំ២០១៨ **ឯកឧត្តម សុខ សង្ហារ** អគ្គនាយករង នៃអាជ្ញាធរជាតិអប្សរា **ឯកឧត្តម សុខ លក្ខិណា** ទីប្រឹក្សា និងជាប្រធានក្រុមការងារសហគមន៍ប្រចាំស្រុកប្រាសាទបាគង រួមនឹងក្រុមការងារ បានចុះជួបប្រជាពលរដ្ឋនៅភូមិឌីឡោក និងភូមិថ្នល់ត្រង់ ឃុំបាគង ស្រុកប្រាសាទបាគង ខេត្តសៀមរាប ដែលជួបគ្រោះធម្មជាតិដោយផ្ទះ និងរោងរបស់ពួកគាត់ដួលរាបដល់ដី ដោយសារភ្លៀងមួយមេធំលាយដោយខ្យល់ព្យុះ កាលពីថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៨ កន្លងទៅនេះ។

ឯកឧត្តម សុខ សង្ហារ បានសម្តែងការចូលរួមសោកស្តាយចំពោះប្រជាពលរដ្ឋដែលជួបគ្រោះធម្មជាតិនេះ និងផ្តាំផ្ញើប្រជាពលរដ្ឋឲ្យមានការប្រុងប្រយ័ត្នខ្ពស់ ពីគ្រោះធម្មជាតិ ដោយសារតែរដូវវស្សាបានឈានចូលមកដល់ ដែលអាចនឹងមានភ្លៀងនិងខ្យល់បក់បោកខ្លាំងៗ បង្កគ្រោះថ្នាក់ដល់ទ្រព្យសម្បត្តិ និងអាយុជីវិត។ ជាមួយគ្នានឹងការចុះសួរសុខទុក្ខនេះ ឯកឧត្តមនិងក្រុមការងារក៏បាន ផ្តល់ជំនួយសង្គ្រោះបឋមដល់ក្រុមគ្រួសាររងគ្រោះ ដូចជា ទឹកបរិសុទ្ធ ទឹកត្រី ទឹកស៊ីអ៊ីវ និងអង្ករជាដើម។

ជាមួយគ្នានេះ ឯកឧត្តមក៏បានសហការជាមួយអាជ្ញាធរមូលដ្ឋានដើម្បីសាងសង់ផ្ទះថ្មីជូនគ្រួសាររងគ្រោះមួយគ្រួសារ ដែលរលំដួលផ្ទះទាំងស្រុង ដោយឯកឧត្តមនិងក្រុមការងារជា អ្នកធានាលើការចំណាយ និងប្រជាពលរដ្ឋក្នុងភូមិជាអ្នកចូលរួមសាងសង់។ ដោយឡែក ក្រុមការងារបានអនុញ្ញាតឱ្យគ្រួសារពីរផ្សេងទៀតដែលរងគ្រោះដោយដួលរោងគោ និងផ្ទះបាយ ដើម្បីជួសជុលឡើងវិញ បន្ទាប់ពីពិនិត្យឃើញថា សំណង់ទាំងពីរនេះជាសំណង់ចាស់ ត្រឹមត្រូវតាមច្បាប់។

លោក យន់ រ៉ន មេឃុំបាគងបានឱ្យដឹងថា ភ្លៀងធំលាយនឹងខ្យល់ព្យុះកាលពីថ្ងៃអាទិត្យ ទី២០ ខែឧសភា ឆ្នាំ២០១៨ កន្លងទៅនេះ បានប៉ះពាល់ដល់ប្រជាពលរដ្ឋ៣គ្រួសារក្នុងឃុំបាគង ក្នុងនោះផ្ទះមួយខ្នង រោងគោមួយ និងផ្ទះបាយ ដែលរលំដួលរាបដល់ដី។

លោកយាយ ភៀម ហឿន ជាម្ចាស់ផ្ទះរង់គ្រោះបានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់រាជរដ្ឋាបាលកម្ពុជា ក្រោមការដឹកនាំរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ដែលតែងតែយកចិត្តទុកដាក់ចំពោះសុខទុក្ខរបស់ប្រជាពលរដ្ឋគ្រប់ពេលវេលា៕






សប្បុរសជនខ្មែរក្នុងស្រុកជំរុញៗចូលរួមបណ្តុះពូជអ្នកអភិរក្សបេតិកភណ្ឌអង្គរ

ផ្សាយនៅថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ២០១៨

អាជ្ញាធរជាតិអប្សរា សហការជាមួយអង្គការគាំពារកេរមរតក និងមជ្ឈមណ្ឌលជាតិយុវជនកម្ពុជា បង្កើតកម្មវិធីអប់រំថ្មីមួយហៅថា «អប់រំបេតិកភណ្ឌ» ក្នុងគោលបំណងលើកកម្ពស់ការយល់ដឹងនិងបញ្ជាបតម្លៃបេតិកភណ្ឌ ដល់សិក្សានុសិស្សនៃសាលាបឋមសិក្សានៅក្នុងតំបន់អង្គរ តាមរយៈការបើកវគ្គបណ្តុះបណ្តាល អប់រំខ្លីៗចំនួនមួយឆមាសម្តង។ កម្មវិធីក្នុងដំហានដំបូងបានចាប់ដំណើរការពីខែឧសភា ដល់ខែសីហា ឆ្នាំ២០១៨ នៅសាលាបឋមសិក្សាស្រះស្រង់។

ដើម្បីដំណើរការកម្មវិធីអប់រំបេតិកភណ្ឌកាន់តែទទួលបានភាពជោគជ័យ អាជ្ញាធរជាតិអប្សរាបានបញ្ជូនបុគ្គលិកជំនាញផ្នែកបេតិកភណ្ឌវប្បធម៌ អ្នកស្រាវជ្រាវបុរាណវិទ្យា ចុះអប់រំផ្ទាល់ក្នុងសាលាគោលដៅក្នុងតំបន់ រួមមានសាលាបឋមសិក្សាស្រះស្រង់និងវិទ្យាល័យនគរធំ ដោយមានការសហការជាមួយអង្គការគាំពារមរតក លោកនាយកសាលា លោកគ្រូអ្នកគ្រូ មជ្ឈមណ្ឌលជាតិយុវជនកម្ពុជា។

កម្មវិធីនេះអាចដំណើរការបានក៏ដោយសារការឧបត្ថម្ភគាំទ្រពីមជ្ឈមណ្ឌលស្រាវជ្រាវទំនាក់ទំនងវប្បធម៌ នៅអាស៊ីជឺគោក និងជាពិសេសពីសប្បុរសជនអ្នកសៀមរាបតែម្តង។

ជំនួយឧបត្ថម្ភពីសប្បុរសជនអ្នកសៀមរាបក្នុងកម្មវិធីរបៀបនេះ ក៏បានអនុវត្តកន្លងមកនៅសាលារៀនក្នុងតំបន់រមណីយដ្ឋានបន្ទាយឆ្មារ ខេត្តបន្ទាយមានជ័យដែរ មាន **លោក អ៊ឹម ផាន់មូលីវណ្ណ** និងគ្រួសារ **លោក ហ្វីលីព កៅ** និងគ្រួសារ ។ល។ សម្រាប់ឱកាសបើកកម្មវិធីអប់រំបេតិកភណ្ឌនៅអង្គរ ដោយមានក្តីស្រឡាញ់វិស័យបេតិកភណ្ឌនិងបុរាណវិទ្យា តែមិនមានឱកាសបានរៀនសូត្រ ឬក៏ធ្វើការដិតដល់នឹងផ្នែកនេះ **លោកស្រី ម៉ម សុម៉ាលី សេរី** និងស្វាមី ព្រមទាំងបុត្រ មានកំណើតកើតជានៅសៀមរាបផ្ទាល់ បាននាំយកអំណោយ មានសៀវភៅ២០០ក្បាល បិច៣០០ដើម កូល័រផាត់ពណ៌១៨០ប្រអប់ ខ្មៅដៃ និងជំរុលុបជាច្រើនដើម ដែលជាតម្រូវការចាំបាច់សម្រាប់ការសិក្សា ឧបត្ថម្ភដល់សិស្សានុសិស្សសាលាបឋមសិក្សាស្រះស្រង់ ដើម្បីជាការលើកចិត្តនិងរួមចំណែកអភិវឌ្ឍន៍ធនធានមនុស្សលើវិស័យបេតិកភណ្ឌជាមួយអាជ្ញាធរជាតិអប្សរា។

លោកស្រី សេរី បាននិយាយថា នេះជាសន្តានចិត្តបន្តិចបន្តួច បរិច្ចាគសម្ភារៈសិក្សាទៅតាមលទ្ធភាព ព្រោះខ្ញុំពីក្មេងស្រលាញ់ការសិក្សាណាស់ និងចង់ឱ្យក្មេងៗមានការសិក្សាបានខ្ពស់ យល់ដឹងពីតម្លៃនៃបេតិកភណ្ឌដែលយើងមាននិងមើលឃើញសព្វថ្ងៃ ជាពិសេសការចូលរួមថែរក្សាតែម្តង។ អ្នកស្រីក៏បានសំណូមពរឱ្យកុមារា កុមារីទាំងអស់យកចិត្តទុកដាក់រៀនសូត្រឱ្យបានច្រើន ជាជាងយកពេលវេលាទៅលេងឥតប្រយោជន៍ ព្រោះវ័យនេះត្រូវខំបណ្តុះខ្លួនក្នុងការសិក្សាដើម្បីទទួលបានអនាគតល្អនៅថ្ងៃមុខ។

លោក អ៊ឹម សុខវិទ្ធី អនុប្រធាននៃគម្រោងអប់រំបេតិកភណ្ឌនេះ បានចាប់អារម្មណ៍ថា នេះជាសកម្មភាពចូលរួមយ៉ាងប្រពៃរបស់សប្បុរសជនក្នុងស្រុករបស់ខ្លួន។ ជាសញ្ញាណនៃក្តីសង្ឃឹមសម្រាប់បណ្តុះពូជ អ្នកអភិរក្សបេតិកភណ្ឌជាតិ។ មុនៗយើងសង្កេតឃើញមានតែជំនួយមកពីបរទេស។ ថ្មីៗនេះ ការជួយជ្រោមជ្រែងគ្នាមានកំណើតហើយ និងជាទីសង្ឃឹមសម្រាប់អភិវឌ្ឍន៍ស្រុក។ ប្រៀបដូចនឹងពាក្យបុរាណពោលថា « អ្នកមានរក្សាខ្សត់ ដូចសំពត់ពាត់ពីក្រៅ អ្នកប្រាជ្ញរក្សាខ្លៅដូចសំពៅនៅសំប៉ាន »។









ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចុះពិនិត្យសំណើរសាងសង់ និងនាំយកអំណោយជូនប្រជាជនរងគ្រោះដោយសារខ្យល់ព្យុះនៅក្នុងឧទ្យានអង្គរ

ផ្សាយនៅថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០១៨

ក្នុងរយៈពេល២ថ្ងៃ ចាប់ពីថ្ងៃទី២២-២៣ ខែឧសភា ឆ្នាំ២០១៨ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរា បានចុះពិនិត្យការស្នើសុំជួសជុលសំណង់និងសស្រាក់សស្រាំក្នុងការជួយសង្គ្រោះប្រជាជនក្នុងតំបន់អង្គរ ដែលទទួលរងគ្រោះដោយសារខ្យល់ព្យុះ បង្កផលប៉ះពាល់ដល់ទីជម្រកនិងការរស់នៅយ៉ាងខ្លាំង។

ក្រុមការងារសហគមន៍ បានចុះទៅតាមគោលដៅ ដូចជាស្រុកអង្គរធំ ស្រុកពួក និងស្រុកប្រាសាទបាគង។ តាមការចុះពិនិត្យជាក់ស្តែងនៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៨ ក្រុមការងារប្រចាំស្រុកអង្គរធំ បានឧបត្ថម្ភជនរងគ្រោះដោយខ្យល់ព្យុះ ចំនួន០២គ្រួសារនៅភូមិភ្លង់ និងភូមិសំរោង ស្រុកអង្គរធំដោយមួយគ្រួសារទទួលបានអង្ករ២៥គីឡូ មីម៉ាម៉ា១កេស ទឹកស៊ីអ៊ីវ៣ដប ទឹកត្រី៣ដប ទឹកដោះគោ១កំប៉ុង ប្រេងឆា១ដប ស្ករស១គីឡូ និងប៊ីចេង១កញ្ចប់។ លើសពីនេះទៀត ក្រុមការងារក៏បានសម្រេចអនុញ្ញាតឱ្យ ជួសជុលនៅនឹងទីតាំងមាន០១ករណី ដែលស្ថិតនៅភូមិភ្លង់ ឃុំលាងដៃ ស្រុកអង្គរធំ ។ ដោយឡែកក្រុមការងារសហគមន៍ប្រចាំស្រុកពួក បានចុះពិនិត្យនិងអនុញ្ញាតឱ្យប្រជាពលរដ្ឋសាង់សង់និងជួសជុលឡើងវិញនូវករណីផ្ទះដួលរលំទាំងស្រុង១០ករណីនិងខូចខាតដំបូល៥ករណី ដោយសារគ្រោះធម្មជាតិបណ្តាលពីខ្យល់ខ្លាំងនៅភូមិប្រឡាយ ឃុំខ្នាត។

រីឯស្រុកប្រាសាទបាគង ក្រុមការងារបានចុះពិនិត្យការស្នើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋនៅភូមិស្ទឹង ឃុំបាគង ដោយសម្រេចអនុញ្ញាតឲ្យជួសជុលផ្ទះតូចតាចនៅទីតាំងផ្ទាល់ចំនួន១៤ករណី ចំណែកឯ០៤ករណីទៀត ម្ចាស់ពុំទាន់មានលទ្ធភាពធ្វើនិងម្ចាស់ផ្ទះមិននៅ។ ក្រុមការងារក៏បានទៅពិនិត្យនិងអនុញ្ញាតឱ្យសាងសង់ផ្ទះបាយឡើងវិញដែលបានដួលរលំដោយសារមានខ្យល់ នៅភូមិរលួសខាងលិច ចំនួន០២ករណីថែមទៀត។

នេះជាទឹកចិត្តនៃការចែករំលែក និងជួយសង្គ្រោះដល់ប្រជាជនក្នុងតំបន់អង្គរ ដែលជួបគ្រោះអាសន្នដោយមិនប្រកាន់និន្នាការនយោបាយ មានក្រ ឬជាតិសាសន៍អ្វីនោះឡើយ។ អាជ្ញាធរជាតិអប្សរាតែងយកចិត្តទុកដាក់ពីការរស់នៅ សុខទុក្ខ និងការរៀបសាងសង់ផ្សេងៗដល់អ្នកស្រុកក្នុងតំបន់ឱ្យស្របទៅតាមគោលការណ៍ និងលើកកម្ពស់ផ្នែកអប់រំ រួមទាំងសុខុមាលភាពរបស់ប្រជាជនផងដែរ៕






អបអរសាទរ!ប្រាសាទអង្គរវត្តជាប់ចំណាត់ថ្នាក់លេខ១ជាសំណង់ប្រកប្តីសាស្ត្រដ៏អស្ចារ្យបំផុត លើពិភពលោកក្នុងឆ្នាំ២០១៨

ផ្សាយនៅថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០១៨

ក្រោយការចូលរួមបោះឆ្នោតពីភ្ញៀវទេសចរជាប់លាននាក់ជុំវិញពិភពលោក គេហទំព័រដ៏ល្បីល្បាញ TripAdvisor បានផ្តល់ចំណាត់ថ្នាក់លេខ១ដល់ប្រាសាទអង្គរវត្តរបស់កម្ពុជា ជាសំណង់ដ៏មានសារៈសំខាន់ផ្នែកប្រវត្តិសាស្ត្រអស្ចារ្យបំផុតនិងចំណាត់ថ្នាក់លេខ១៣ជាគោលដៅទេសចរណ៍របស់ពិភពលោកសម្រាប់ឆ្នាំ២០១៨នេះ។

នេះគឺជាឆ្នាំទី៥ហើយ ដែលអង្គរត្រូវបានភ្ញៀវទេសចរលើពិភពលោកបោះឆ្នោតគាំទ្រ ហើយទទួលបានចំណាត់លេខ១ជាប់ៗគ្នាតាមរយៈគេហទំព័រដ៏ល្បីល្បាញផ្សេងៗគ្នា គឺកាលពីឆ្នាំ២០១៤ អង្គរបានជាប់ចំណាត់ថ្នាក់លេខ១ នៅលើគេហទំព័រមួយដែលតែងតែយកតំបន់បុរាណវិទ្យា និងប្រវត្តិសាស្ត្រទាំងអស់លើពិភពលោកមកប្រៀបធៀបគ្នា នោះគឺគេហទំព័រ ArchaeoMadness។

បន្ទាប់មកទៀត នៅដើមឆ្នាំ២០១៥ អង្គរទទួលបានចំណាត់ថ្នាក់លេខ១ម្តងទៀត នៅលើគេហទំព័រអន្តរជាតិមួយ ដែលជាគេហទំព័រផ្សព្វផ្សាយតំបន់ទេសចរណ៍ល្បីៗលើពិភពលោក នោះគឺគេហទំព័រ TripAdvisor។ នៅឆ្នាំ២០១៦ អង្គរបានបន្តជាប់លេខ១បន្ថែមទៀត នៅលើគេហទំព័ររបស់ក្រុមហ៊ុន Lonely Planet ដែលជាគេហទំព័រផ្សព្វផ្សាយ និងជាប្រភពព័ត៌មានទេសចរណ៍ដ៏ល្បីមួយលើពិភពលោក មានទាំងព័ត៌មានតាមរយៈវីដេសាយ ទស្សនាវដ្តី និងសៀវភៅ ជាដើម។ នៅឆ្នាំ២០១៧ និងឆ្នាំ២០១៨នេះ TripAdvisor ក៏បានបន្តផ្តល់ចំណាត់ថ្នាក់លេខ១ដល់ប្រាសាទអង្គរវត្តរបស់កម្ពុជាក្នុងឋានៈជាសំណង់ដ៏មានសារៈសំខាន់ផ្នែកប្រវត្តិសាស្ត្រអស្ចារ្យបំផុតក្នុងលោក។

នេះជាមោទនភាពមួយរបស់ជាតិខ្មែរយើងទាំងមូល ដែលអង្គរវត្តរបស់កម្ពុជាទទួលបានការគាំទ្រពីបណ្តាប្រជាជនជុំវិញពិភពលោក។ ក្នុងនាមស្ថាប័នគ្រប់គ្រងរមណីយដ្ឋានអង្គរ អាជ្ញាធរជាតិអប្សរា សូមចូលរួមអបអរសាទរ និងសូមអំពាវនាវដល់សាធារណជនទាំងអស់បន្តចូលរួមថែរក្សា ការពារនូវបេតិកភណ្ឌរបស់ជូនតាយើងឲ្យបានខ្លាំងក្លាដើម្បីភាពគង់វង្សយូរអង្វែងតទៅ៕









ប្រជាកសិករក្នុងតំបន់អង្គរទទួលបានទក្ខបណ្តុះបណ្តាលស្តីពីទីផ្សារកសិផល

ផ្សាយនៅថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ២០១៨

កាលពីថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៨ អាជ្ញាធរជាតិអប្សរាតាមរយៈគម្រោង ACHA សហការជាមួយអង្គការ IDE (In Partnership Promoting Agribusiness) បានបើកវគ្គបណ្តុះបណ្តាលស្តីពីទីផ្សារកសិផលដល់ប្រជាកសិករ ជាកសិករគំរូនិងអ្នកធ្វើតាមចំនួន២០គ្រួសារ ដែលស្ថិតនៅភូមិអូរ ឃុំព្រះដាក់ ស្រុកបន្ទាយស្រី ខេត្តសៀមរាប ដើម្បីជាការលើកទឹកចិត្តក៏ដូចជាផ្តល់ក្តីសង្ឃឹមដល់ប្រជាកសិករក្នុងការដាំដុះកសិកម្មបន្ថែមទៀត។

លោក ឡាច វីយ៉ា បុគ្គលិកបច្ចេកទេសរបស់គម្រោង ACHA បានលើកឡើងថា វគ្គបណ្តុះបណ្តាលនេះ បានផ្តល់ចំណេះដឹងដល់ពួកគាត់ពាក់ព័ន្ធនឹងទីផ្សារក្នុងភូមិស្រុកនិងក្រៅតំបន់ដែលខ្លួនរស់នៅ ចេះវិភាគថ្លៃដើម យល់ពីតម្រូវការរបស់ទីផ្សារ និងឱ្យពួកគាត់ចេះសហការគ្នាក្នុងនាមជាប្រជាកសិកររនិងប្រជាកសិករ ដើម្បីនាំចេញកសិផលខ្លួនទៅលក់បានតម្លៃខ្ពស់នៅលើទីផ្សារ។

លោក វីយ៉ា បន្ថែមថា លទ្ធផលដែលទទួលបានពីវគ្គបណ្តុះបណ្តាលនេះកន្លងមក ធ្វើឱ្យប្រជាកសិករដាំដំណាំត្រូវនឹងតម្រូវការទីផ្សារ ថាខែណាគួរដាំដំណាំអ្វី ដើម្បីបានតម្លៃខ្ពស់ ចេះរកមើលទីផ្សារក្នុងភូមិ និងចេះស៊ើបរកទីផ្សារខ្លួនឯងលក់ផលិតផលបានថ្លៃទៀតផង។

សូមបញ្ជាក់ថា វគ្គបណ្តុះបណ្តាលស្តីពីផ្សារកសិផលនេះ ធ្លាប់បង្រៀនដល់ប្រជាកសិករគំរូនិងកសិករគ្រាប់តាមបានចំនួន២០វគ្គរួចហើយនៅក្នុងតំបន់អង្គរ ហើយវគ្គនេះ ជាវគ្គចុងក្រោយនៃម្រោង ACHA ដែលបានសហការជាមួយអង្គការ IDE។ កន្លងមក អាជ្ញាធរជាតិអប្សរានិងដៃគូក៏បានសហការរកទីផ្សារជូនប្រជាជនឱ្យលក់ផលិតផលបានតម្លៃសមរម្យ ហើយក៏បានផ្តល់ពូជ បច្ចេកទេស និងជំរុញលើកទឹកចិត្តក្នុងការដាំដុះផងដែរ។ ពិសេស ផលិតផលដែលប្រជាជនក្នុងគម្រោងដាំបាន ក៏បានយកទៅលក់នៅក្នុងពិព័រណ៌ផលិតផលបន្លែ ផ្លែឈើកម្ពុជាលើកទី១០ កាលពីថ្ងៃទី០១ ដល់ថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៧កន្លងមកនេះ ដែលបានធ្វើឱ្យអ្នកដាំ អ្នកទិញ និងឈ្មួញបានជួបគ្នាក្នុងការបង្កើតទំនាក់ទំនងលើផ្នែកពូជ របៀបដាំដុះតម្រូវការទីផ្សារនិងដៃគូពាណិជកម្មបានយ៉ាងល្អប្រសើរ៕









អាជ្ញាធរជាតិអប្សរាបើកវគ្គបណ្តុះបណ្តាលស្តីអំពី លំនាំសំខាន់ៗនៃស្ថាបត្យកម្មខ្មែរ និងបដិមាសាស្ត្របុរាណ

ផ្សាយនៅថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ២០១៨

អ្នកជំនាញអាជ្ញាធរជាតិអប្សរាទទួលការបណ្តុះបណ្តាលស្តីពី "លក្ខណៈពិសេសនៃបេតិកភណ្ឌខ្មែរ៖ លំនាំសំខាន់ៗនៃស្ថាបត្យកម្មខ្មែរ និងបដិមាសាស្ត្របុរាណ" បង្រៀនដោយ**លោកសាស្ត្រាចារ្យ** Pierre Baptiste អ្នកជំនាញអភិរក្សនិងស្រាវជ្រាវនៃសារមន្ទីរGUIMET នៃប្រទេសបារាំង។

វគ្គបណ្តុះបណ្តាលនេះ មានរយៈពេល២ថ្ងៃ ចាប់ពីថ្ងៃទី២៨ ដល់ ២៩ ខែឧសភា ឆ្នាំ២០១៨ ក្នុងគោលបំណងដើម្បីស្វែងយល់ពីទិដ្ឋភាពទូទៅនៃប្រវត្តិសាស្ត្រ បច្ចេកទេស សោភ័ណភាពនៃបេតិកភណ្ឌរបស់អារ្យធម៌ខ្មែរសម័យបុរាណ កំណត់កាលបរិច្ឆេទបដិមានិងប្រាសាទខ្មែរតាមបែបវិទ្យាសាស្ត្រ។

អ្នកជំនាញដែលចូលរួមក្នុងវគ្គសិក្សានេះ គឺជាមន្ត្រីនិងបុគ្គលិកបច្ចេកទេសនៃក្រុម I.T.A.L.I.A នាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរ និងបុរាណវិទ្យាបង្ការ នាយកដ្ឋានអភិវឌ្ឍន៍វប្បធម៌ សារមន្ទីរ និងបទដ្ឋានបេតិកភណ្ឌ មជ្ឈមណ្ឌលអន្តរជាតិ និងតម្កល់ឯកសារអង្គរ នាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍អង្គរ និងក្រុមការងារអនុវត្តផែនការគ្រប់គ្រងទេសចរណ៍ នាយកដ្ឋានទ្រទ្រង់បច្ចេកទេស និងគម្រោងអន្តរវិស័យ ចំណុះឱ្យអាជ្ញាធរជាតិអប្សរាសរុបចំនួន៤៥រូប។

អាជ្ញាធរជាតិអប្សរា តែងតែយកចិត្តទុកដាក់ចំពោះការបណ្តុះបណ្តាលធនធានមនុស្សជាច្រើនជំនាញដល់មន្ត្រីបុគ្គលិកដើម្បីអភិវឌ្ឍន៍សមត្ថភាពនិងចំណេះដឹងក្នុងកិច្ចការអភិរក្ស ជួសជុលបុរាណដ្ឋានក្នុងតំបន់អង្គរឱ្យកាន់តែប្រសើរឡើង ដោយមានទាំងគ្រូជំនាញជាតិនិងអន្តរជាតិមកបង្រៀន។ លើសពីនោះទៀត ក្រៅពីយកចិត្តទុកដាក់លើការអភិរក្សនិងជួសជុល ក៏មានបង្រៀនជំនាញសង្គ្រោះបឋមដល់ភ្នាក់ងារទេសចរ ដើម្បីជួយសង្គ្រោះដល់ភ្ញៀវទេសចរដែលមកទស្សនានៅក្នុងតំបន់អង្គរឱ្យមានភាពកក់ក្តៅនិងសុវត្ថិភាពពេលពួកគេមានបញ្ហាផងដែរ៕









អាជ្ញាធរជាតិអប្សរាចាត់ដឹកនាំសប្បុរសជនចែកអំណោយជូនប្រជាពលរដ្ឋក្រីក្រ នៅតំបន់អង្គរដើម២០០គ្រួសារ

ផ្សាយនៅថ្ងៃទី ២៩ខែ ឧសភា ឆ្នាំ២០១៨

ប្រជាពលរដ្ឋក្រីក្រក្នុងឃុំបាគង ស្រុកប្រាសាទបាគងនៃរមណីយដ្ឋានអង្គរ បានទទួលអំណោយពីសប្បុរសជនមកពីប្រទេសម៉ាឡេស៊ី តាមរយៈការសម្របសម្រួលរបស់អាជ្ញាធរជាតិអប្សរា។ ពិធីប្រគល់អំណោយជូនប្រជាពលរដ្ឋប្រមាណ ១៧៩គ្រួសារនេះ ត្រូវបានរៀបចំឡើងនារសៀលថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៨ នៅវត្តលលៃ ឃុំបាគង ស្រុកប្រាសាទបាគង ខេត្តសៀមរាប។

លោកស្រី TEOH តំណាងមូលនិធិ TEOH &GOH បានបង្ហាញនូវភាពសប្បាយរីករាយដែលបានរួមចំណែកជួយដល់ប្រជាពលរដ្ឋខ្វះខាតនៅទីនេះ។ លោកស្រីបញ្ជាក់ថា មូលនិធិរបស់លោកស្រីបានដំណើរការជួយជនក្រខ្សត់ជាច្រើនឆ្នាំមកហើយ ទាំងប្រទេសផ្សេងៗរួមទាំងកម្ពុជាផង។ លោកស្រីក៏បានថ្លែងងអំណរគុណដល់ក្រុមការងារដែលបានជួយជ្រោមជ្រែងរៀបចំឲ្យមានកម្មវិធីមនុស្សធម៌នេះឡើង។

លោក ម៉ក់ សំការ អភិបាលស្រុកប្រាសាទបាគងបានបញ្ជាក់ថា ប្រជាពលរដ្ឋដែលអញ្ជើញមកទទួលអំណោយសប្បុរសធម៌នៅពេលនេះ ជាគ្រួសារដែលមានក្នុងបញ្ជីពលរដ្ឋក្រីក្រសរុប១៧៩គ្រួសារ។ លោកក៏បានថ្លែងអំណរគុណដល់ម្ចាស់ជំនួយ និងអាជ្ញាធរជាតិអប្សរាតាមរយៈ **ឯកឧត្តម សុខ សង្ហារ** ដែលបានគិតគូរដល់សេចក្តីទុក្ខលំបាករបស់ប្រពលរដ្ឋក្នុងមូលដ្ឋានរបស់លោក។

មានប្រសាសន៍សំណេះសំណាលជាមួយម្ចាស់ជំនួយ និងប្រជាពលរដ្ឋក្នុងឱកាសនេះ **ឯកឧត្តម សុខ សង្ហារ** អគ្គនាយករងនៃអាជ្ញាធរជាតិអប្សរាបានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះមូលនិធិ TEOH &GOH ដែលបានលះបង់ទ្រព្យធនឧបត្ថម្ភដល់ប្រជាពលរដ្ឋដែលមានជីវភាពខ្វះខាតនៅតាមបណ្តាខេត្តមួយចំនួននៅប្រទេសកម្ពុជា ក៏ដូចជាក្នុងតំបន់រមណីយដ្ឋានអង្គរនៅពេលនេះដែរ។

ឯកឧត្តមបញ្ជាក់ថា មិនថានៅក្នុងប្រទេសណាទេ មនុស្សក្នុងសង្គមមិនមានជីវភាពដូចៗគ្នានោះទេ។ ដោយសារកម្រិតជីវភាពមិនដូចគ្នានេះហើយ ទើបសង្គមយើងត្រូវការជួយសង្គ្រោះគ្នា។ ការជួយគ្នាមិនត្រឹមតែធ្វើឲ្យអ្នកខ្វះខាតបានប្រសើរឡើងនោះទេ តែជាការបង្កើតនូវសម្ព័ន្ធភាព ការស្រឡាញ់រាប់អាន និងភាពស្មោះត្រង់ ដែលធ្វើឲ្យសង្គមយើងមានសន្តិភាពពិតប្រាកដ។

ជាមួយគ្នានេះ ឯកឧត្តមក៏បានគូសបញ្ជាក់អំពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលកម្ពុជា ចំពោះសុខទុក្ខរបស់ប្រជាពលរដ្ឋគ្រប់រូប។ ជាក់ស្តែងគឺ គោលនយោបាយកាត់បន្ថយភាពក្រីក្រ តាមរយៈការអភិវឌ្ឍជាតិលើគ្រប់វិស័យ និងការប្តេជ្ញាយ៉ាងមុឺងម៉ាត់របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ក្នុងការរក្សានូវសន្តិភាព និងស្ថិរភាពនយោបាយជូនមាតុភូមិកម្ពុជាគ្រប់កាលៈទេសៈ។

សូមបញ្ជាក់ថា អំណោយសប្បុរសធម៌នៅពេលនេះគឺពលរដ្ឋមួយគ្រួសារទទួលបានអង្ករ៣០គីឡូក្រាម មី១កេស ត្រីខ១យួរ ទឹកត្រី ទឹកស៊ីអ៊ីវ ប្រេងឆា និងអំបិល១កញ្ចប់៕






ដំណឹងជ្រើសរើសភ្នាក់ងារទេសចរ

ផ្សាយនៅថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ២០១៨

អាជ្ញាធរអប្សរា អាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងតំបន់អង្គរ (www.apsaraauthority.gov.kh) ជូនដំណឹងដល់សិស្ស និស្សិត និងសាធារណៈជនទាំងអស់ឲ្យបានជ្រាបថា អាជ្ញាធរអប្សរា នឹងធ្វើការជ្រើរើស ភ្នាក់ងារទេសចរ កម្រិតសញ្ញាបត្រទុតិយភូមិ ចំនួន ១៤រូប ឲ្យបម្រើការងារនៅនាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍អង្គរ។



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ថ្ងៃ ... ខែ ... ឆ្នាំ ... ស័ក ព.ស ...
សៀមរាប ថ្ងៃទី ... ខែ ... ឆ្នាំ ...

ដំណឹងជ្រើសរើសបុគ្គលិក

អាជ្ញាធរអប្សរា "អាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងតំបន់អង្គរ" (www.apsaraauthority.gov.kh) សូមជូនដំណឹងដល់សិស្ស និស្សិត និងសាធារណជនទាំងអស់ឲ្យបានជ្រាបថា អាជ្ញាធរអប្សរា នឹងធ្វើការជ្រើសរើសភ្នាក់ងារទេសចរ កម្រិតសញ្ញាបត្រទុតិយភូមិ ចំនួន ១៤រូប ឲ្យបម្រើការងារនៅនាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍អង្គរ។ លក្ខខណ្ឌនៃការជ្រើសរើសមានដូចខាងក្រោម៖

១- កម្រិតសិក្សា
- ត្រូវមានសញ្ញាបត្រទុតិយភូមិ

២- លក្ខខណ្ឌនៃការជ្រើសរើស មានដូចតទៅ
- បេក្ខជនត្រូវមានសញ្ជាតិខ្មែរ
- មានអាយុចាប់ពី ១៨-៣៥ឆ្នាំ
- ធ្លាប់មានបទពិសោធន៍ការងារចាប់ពី ១ឆ្នាំឡើងទៅ (បើមានការតែប្រសើរ)
- មានចំណេះដឹងថ្នែកភាសាបរទេស (អាទិភាព ភាសាអង់គ្លេស)
- មានសុខភាពល្អ
- មិនត្រូវសាលក្រមសិទ្ធិពាងផ្លូវច្បាប់ណា និងសិទ្ធិជាពលរដ្ឋ
- បេក្ខជនដែលមានលំនៅដ្ឋានក្នុងខេត្តឬអង្គរត្រូវបានផ្តល់អាទិភាព

៣- សំណុំឯកសារដែលត្រូវមាន
- ពីរច្បាប់ពុម្ពរូបមានទំហំ (៤×៦) ០១ច្បាប់
- អត្តសញ្ញាណប័ណ្ណ និងសៀវភៅស្នាក់នៅ ច្បាប់ថតចម្លង ០១ច្បាប់
- សំបុត្រកំណើត ច្បាប់ថតចម្លង ០១ច្បាប់
- ថតចម្លង និងបញ្ជាក់សញ្ញាបត្រ ដោយមានការទទួលស្គាល់ជាផ្លូវការពីក្រសួងចេញ-ប្តូរបើតមួយ

៤- ទីកន្លែងទទួលពាក្យ៖ ទីស្នាក់ការអាជ្ញាធរអប្សរាថ្មី "អជ្ឈមណ្ឌលអាជ្ញាធរជាតិអប្សរា" នៅនាយកដ្ឋានវប្បធម៌ បុគ្គលិក និងសិល្បៈ ចាប់ពីថ្ងៃជូនដំណឹងនេះ រហូតដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៨។

៥- ការសម្ភាសបេក្ខជន៖ បន្ទាប់ក្រោយពីបេក្ខជនដែលត្រូវឆ្លងកាត់ការប្រលង និងសម្ភាសជ្រើសរើសនឹងត្រូវបិទផ្សាយនៅស្នាក់ការអាជ្ញាធរអប្សរាខេត្តសៀមរាប ឬជូនដំណឹងតាមទូរស័ព្ទផ្ទាល់ទៅបេក្ខជន។

៦- ព័ត៌មានលំអិត៖ សូមទំនាក់ទំនងមកលេខទូរស័ព្ទ ០១២/០៩៣ ៩៨៦ ៩១៨

អ្នកស្រុកអន្តរចំនួន១៣៨ក្រួសារទទួលបានការអនុញ្ញាតឱ្យសាងសង់ និងជួសជុលសំណង់ស្រាលក្នុងខែឧសភា

ផ្សាយនៅថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០១៨

ក្នុងអំឡុងពេលខែឧសភានេះ ក្រុមការងាររលេខាធិការដ្ឋានសហគមន៍ទាំង៥ក្រុមនៃអាជ្ញាធរជាតិអប្សរា បានបន្តការងារចុះពិនិត្យ អនុញ្ញាតការសាងសង់ផ្ទះថ្មីជំនួសផ្ទះចាស់ និងជួសជុលសំណង់តូចតាចបានចំនួន១៣៨ករណី រួមមានស្រុកប្រាសាទបាគង អនុញ្ញាតបានចំនួន១៦ករណី ស្រុកអង្គរធំ អនុញ្ញាតបានចំនួន១៣ករណី ស្រុកពួក អនុញ្ញាតបានចំនួន៤៧ករណី ក្រុងសៀមរាប អនុញ្ញាតបានចំនួន៥៣ករណី និងស្រុកបន្ទាយស្រី អនុញ្ញាតបានចំនួន០៩ករណី។

ការអនុញ្ញាតនេះ ធ្វើឡើងបន្ទាប់ពីក្រុមការងារសហគមន៍ បានចុះពិនិត្យទៅដល់ខ្នងផ្ទះជាក់ស្តែងនិងឯកសារពាក់ព័ន្ធមួយចំនួនទៀត ដើម្បីជាមូលដ្ឋានបច្ចេកទេសក្នុងការវាយតម្លៃថា ពួកគាត់គឺជាប្រជាពលដ្ឋចាស់រស់នៅក្នុងតំបន់អង្គរពិតប្រាកដនិងមានការបញ្ជាក់យ៉ាងច្បាស់លាស់ពីអាជ្ញាធរមូលដ្ឋានភូមិ-ឃុំ-សង្កាត់ ហើយមានតម្រូវការជាក់ស្តែងក្នុងការកែលម្អការរស់នៅឱ្យបានល្អប្រសើរ។

ទន្ទឹមនឹងនេះដែរ អាជ្ញាធរជាតិអប្សរា ក៏បានឧបត្ថម្ភថវិកានិងផ្តល់សង្កសីសម្រាប់ប្រក់ដំបូលដល់ក្មេងកំព្រាបីនាក់បងប្អូននៅភូមិគោកស្នួល ឃុំខ្នាត ស្រុកពួក និងបានឧបត្ថម្ភគ្រឿងឧបភោគបរិភោគដល់ប្រជាពលរដ្ឋចំនួនបីគ្រួសារដែលរងគ្រោះដោយខ្យល់កន្ត្រាក់រលំផ្ទះនៅភូមិភ្លង់ និងភូមិសំរោង ឃុំលាងដៃ ស្រុកអង្គរធំ និងមួយគ្រួសារទៀតស្ថិតនៅភូមិថ្នល់ត្រង់ ឃុំបាគងស្រុកប្រាសាទបាគង។

គួរបញ្ជាក់ដែរថា អាជ្ញាធរជាតិអប្សរាបានបង្កើតក្រុមការងារសហគមន៍នេះឡើង គឺដើម្បីសម្រួលដល់ការរស់នៅរបស់ប្រជាពលរដ្ឋក្នុងតំបន់អង្គរដែលគ្របដណ្តប់លើផ្ទៃដី ៤០១គីឡូម៉ែត្រការ៉េ ស្ថិតនៅក្នុងក្រុង/ស្រុកចំនួន៥ ឃុំចំនួន២១ និងភូមិចំនួន១១២ លើការសាងសង់ផ្ទះថ្មីជំនួសផ្ទះចាស់និងជួសជុលសំណង់តូចតាច ការដោះស្រាយបញ្ហាប្រឈមនានា ការលើកកម្ពស់សុខុមាលភាពមាតានិងទារក ការជួយសង្គ្រោះពេលប្រជាជនមានទុក្ខលំបាក រួមទាំងផ្សព្វផ្សាយការយល់ដឹងអំពីបេតិកភណ្ឌដល់ប្រជាជនគ្រប់ៗគ្នា៕









អាជ្ញាធរជាតិអប្សរានិងការបណ្តុះបណ្តាលអ្នកជំនាន់ក្រោយ

ផ្សាយនៅថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០១៨

ក្រុមប្រឹក្សាកុមារនិងយុវជនចំនួន៤០០នាក់ ជាបន្តបន្ទាប់បានមកទស្សនាស្វែងយល់អំពីអង្គរនៅក្នុងខែឧសភា ឆ្នាំ២០១៨ ដើម្បីទទួលបានការអប់រំបណ្តុះបណ្តាល និងស្វែងយល់អំពីប្រវត្តិសាស្ត្រ វប្បធម៌ និងបេតិកភណ្ឌអង្គរ។ ដំណើរទស្សនកិច្ចសិក្សានេះបានរៀបចំដោយនាយកដ្ឋានយុវជននៃក្រសួងអប់រំ យុវជននិងកីឡា ដោយសហការជាមួយអាជ្ញាធរជាតិអប្សរា ដើម្បីបង្ហាត់បង្ហាញដល់កុមារនិងយុវជន ទាំងនៅមជ្ឈមណ្ឌលជាតិយុវជនខេត្តសៀមរាបនិងនៅតាមប្រាសាទនានាក្នុងរមណីយដ្ឋានអង្គរ។

ការបណ្តុះបណ្តាលនេះ សំដៅឱ្យសិស្សនិងយុវជនបានយល់ដឹងអំពីប្រវត្តិសាស្ត្រនៃទឹកដីមួយដែលជាអតីតរាជធានីនៃចក្រភពខ្មែរ ដែលមានអារ្យធម៌ចម្រុងចម្រើន ហើយដែលបច្ចុប្បន្នក្លាយជារមណីយដ្ឋានបេតិកភណ្ឌពិភពលោកដ៏មានតម្លៃខ្ពស់បំផុតរបស់ជាតិ។

លោក អ៊ឹម សុខវិទ្ធី អនុប្រធានមជ្ឈមណ្ឌលស្រាវជ្រាវអន្តរជាតិនិងតម្កល់ឯកសារអង្គរ បានលើកឡើងក្នុងកម្មវិធីបណ្តុះបណ្តាលថា អង្គរមិនត្រឹមតែជារាជធានីនៃចក្រភពមួយទេ តែអង្គរបានក្លាយជាអារ្យធម៌មួយដោយខ្លួនឯង និងបានរីកសន្ធឹងទៅសម្គាល់ដល់តំបន់ភូមិសាស្ត្រទាំងមូលទៀតផង ដែលនេះអាចសម្គាល់បានដោយការត្បាញបញ្ចូលគ្នារវាងស្ថានភាពភូមិសាស្ត្រលាយឡំជាមួយសំណល់បុរាណវិទ្យា។ ក្រុងពិសិដ្ឋ ព្រះនគរ ដែលផ្សំឡើងដោយប្រាសាទរាប់រយអាងរក្សាទឹកបារាយណ៍ ប្រព័ន្ធធារាសាស្ត្រ និងសំណល់បុរាណវិទ្យាដទៃទៀត តាំងនៅក្នុងលម្ហទេសភាពធំទូលាយមួយដែលលេចឡើងដោយក្រុងតូចៗទីប្រជុំជនជាច្រើននៅផ្តុំគ្នា។

លោកបន្តថា អង្គរមិនបានបាត់ខ្លួនទៅតាមសម័យកាលដែលកន្លងផុតទៅទេ គឺសំណល់បុរាណវិទ្យា សំណង់ស្ថាបត្យកម្ម ស្លាកស្នាមនៃរាជធានីនៃចក្រភពខ្មែរ ដែលបានស្ថាបនាឡើងរវាងដើមសតវត្សទី៩ដល់ទី១៥ ភាគច្រើននៅគង់វង្សដល់សព្វថ្ងៃ។ ប្រវត្តិសាស្ត្រនៃអារ្យធម៌សម័យអង្គរពិតជាបានជះឥទ្ធិពលដល់ការអភិវឌ្ឍប្រទេសកម្ពុជាយ៉ាងជ្រាលជ្រៅទាំងក្នុងទម្រង់សង្គមនិងវប្បធម៌ជាបន្តបន្ទាប់ ដោយផ្សារភ្ជាប់ទៅបុព្វបុរសអង្គររបស់ខ្លួន។ លើសពីនេះ អង្គរជានិមិត្តរូបជាតិដ៏ធំសម្បើមក្នុងសតវត្សទី២១ ហើយរមណីយដ្ឋាននេះក៏បានក្លាយជាគោលដៅទេសចរណ៍វប្បធម៌ដ៏ល្បីល្បាញពេញនិយមបំផុតមួយនៅអាស៊ីនិងនៅលើពិភពលោកដោយមានភ្ញៀវទេសចរចម្រុះជាតិសាសន៍បានមកទស្សនា និងទទួលចំណាត់ថ្នាក់ខ្ពស់បំផុតជាគោលដៅទេសចរណ៍របស់ពិភពលោកក្នុងរយៈពេល៥ឆ្នាំជាប់គ្នា។

សូមបញ្ជាក់ថា នាឆ្នាំ១៩៩១ អតីតព្រះមហាក្សត្រកម្ពុជាព្រះនរោត្តមសីហនុ ព្រះបរមរតនកោដ្ឋ បានអំពាវនាវដល់អង្គការយូណេស្កូដើម្បីឱ្យជួយស្រោចស្រង់អង្គរ។ ជាការឆ្លើយតបទៅនឹងសំណើនេះ អគ្គនាយកអង្គការយូណេស្កូបានចាប់ផ្តើមធ្វើយុទ្ធនាការអន្តរជាតិមួយជាផ្លូវការដើម្បី "ស្រោចស្រង់អង្គរ"។ នៅឆ្នាំ១៩៩២ ប្រាសាទអង្គរត្រូវបានអង្គការយូណេស្កូបញ្ចូលជាបេតិកភណ្ឌពិភពលោក។ ការចុះបញ្ជីនេះបាននាំមកនូវកិច្ចសហប្រតិបត្តិការអន្តរជាតិដើម្បីការពារនិងអភិវឌ្ឍន៍តំបន់ប្រវត្តិសាស្ត្រអង្គរ។

មកដល់បច្ចុប្បន្ន កិច្ចសហប្រតិបត្តិការអន្តរជាតិនេះបាននិងអនុវត្តនូវគម្រោងជាច្រើនក្នុងការអភិរក្សនិងការគ្រប់គ្រងឧទ្យានអង្គរអស់រយៈពេល២៥ឆ្នាំមកហើយ។ រីឯគម្រោងអភិរក្សថ្មីៗក៏នៅតែបន្តក្រោមឆត្រអង្គការយូណេស្កូ ដែលនេះបានឆ្លុះបញ្ចាំងពីចំណងមិត្តភាពដ៏យូរអង្វែងដែលមានតាំង ពីមុនប្រវត្តិសាស្ត្ររវាងតំបន់អង្គរនិងតំបន់អាស៊ី ព្រមទាំងពិភពលោកទាំងមូល៕






ព្រឹត្តិការណ៍ព័ត៌មាន
ប្រចាំខែមិថុនា

ផ្នែកទី ៦
ប្រចាំខែមិថុនា

កណៈកម្មាធិការអាយស៊ីស៊ី-អង្គរនឹងបើកកិច្ចប្រជុំបច្ចេកទេសលើកទី៣០របស់ខ្លួន នៅថ្ងៃទី០៤-០៦ ខែមិថុនា ឆ្នាំ២០១៨

ផ្សាយនៅថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ២០១៨

គណៈកម្មាធិការអន្តរជាតិដើម្បីសម្របសម្រួលកិច្ចគាំពារនិងអភិវឌ្ឍន៍រមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរហៅកាត់ថា អាយស៊ីស៊ី-អង្គរ (International Coordination Committee for the Safeguarding and Development of Historic Site of Angkor : ICC-Angkor) នឹងបើកកិច្ចប្រជុំបច្ចេកទេសលើកទី៣០របស់ខ្លួន នៅថ្ងៃទី០៥និងទី០៦ ខែមិថុនា ឆ្នាំ២០១៨ នាសាលសន្និសីទអង្គរនៅមជ្ឈមណ្ឌលអាជ្ញាធរជាតិអប្សរា។

កិច្ចប្រជុំអាយស៊ីស៊ី-អង្គរ នឹងប្រារព្ធឡើងក្រោមអធិបតីភាព **លោកជំទាវ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងជាប្រធានអាជ្ញាធរជាតិអប្សរា រួមជាមួយសហប្រធានទាំងពីរ គឺ**លោក Guillaume NARJOLLET** ទីប្រឹក្សាផ្នែកសហប្រតិបត្តិការនិងកិច្ចការវប្បធម៌ នៃស្ថានទូតបារាំងប្រចាំកម្ពុជា និង **លោក Kenichi BESSHO** អនុប្រធានបេសកម្មនៃស្ថានទូតជប៉ុនប្រចាំប្រទេសកម្ពុជា។

របៀបវារៈនៃកិច្ចប្រជុំពេលនេះ នឹងផ្តោតទៅលើចំណុចសំខាន់ៗមួយចំនួនដូចជា តាមដានរបាយការណ៍នៃការងារអភិរក្សជួសជុល និងការងារស្រាវជ្រាវ ការអភិវឌ្ឍដោយចីរភាព ក្នុងតំបន់រមណីយដ្ឋានអង្គរ ដែលបានពីការផ្តល់អនុសាសន៍នៅក្នុងកិច្ចប្រជុំពេញអង្គពីឆ្នាំ២០១៧និងឆ្នាំកន្លងមក។

គណៈកម្មាធិការអាយស៊ីស៊ី-អង្គរ(ICC-Angkor) បានបង្កើតឡើងនៅឆ្នាំ១៩៩៣ ក្រោយសន្និសីទអន្តរជាតិលើកទី១ស្តីពីអង្គរនៅទីក្រុងតូក្យូ ប្រទេសជប៉ុន តាមសំណូមពររបស់គណៈកម្មាធិការបេតិកភណ្ឌពិភពលោក ពេលទទួលចុះអង្គរទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក។ ការបង្កើតយន្តការអន្តរជាតិ ICC សម្រាប់អង្គរ ជាលក្ខខណ្ឌមួយក្នុងចំណោមលក្ខខណ្ឌទាំង៥ ដែលតម្រូវឱ្យអាជ្ញាធរកម្ពុជាបំពេញក្នុងរយៈពេល៣ឆ្នាំ (១៩៩៣-១៩៩៦)។ សមាជិកនៃអាយស៊ីស៊ី (ICC) មានចំនួន៣៧ប្រទេស មកពីទ្វីប៥ និងមានអង្គការអន្តរជាតិចំនួន១៣ទៀតចូលរួមជាសមាជិកដែរ៕









កម្មវិធីបណ្តុះគំនិតកុមារថែរក្សាបរិស្ថានអង្គរជាផ្នែកមួយជំរុញអោយការគ្រប់គ្រងបរិស្ថានក្នុងឧទ្យានអង្គរមានភាពនិរន្តរភាព

ផ្សាយនៅថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ២០១៨

កម្មវិធីបណ្តុះគំនិតកុមារថែរក្សាបរិស្ថានអង្គរ ជាកម្មវិធីសម្រាប់អប់រំកុមារតូចឱ្យយល់ ដឹងពីការថែរក្សាបរិស្ថានក្នុងរមណីយដ្ឋានអង្គរ។ កម្មវិធីនេះត្រូវបានបង្កើតឡើងដោយស្ថាប័នជានាគុណភាពជប៉ុន (Japan Quality Assurance Organization= JQA) សហការជាមួយអាជ្ញាធរជាតិអប្សរា និងមន្ទីរអប់រំ យុវជន និងកីឡា ខេត្តសៀមរាប។ គោលបំណងនៃកម្មវិធីអប់រំនេះ គឺដើម្បីបណ្តុះគំនិតកុមារទៅលើការថែរក្សាបរិស្ថាន ជំរុញឱ្យការគ្រប់គ្រងបរិស្ថានអង្គរមាននិរន្តរភាពជានិរន្តន៍។

លោក SATORU KISHINO មន្ត្រីទទួលបន្ទុកអប់រំបរិស្ថានចំពោះកុមារ នៃស្ថាប័ន JQA បានឱ្យដឹងថា ស្ថាប័នជប៉ុន JQA បានចូលមកធ្វើការជាមួយអាជ្ញាធរជាតិអប្សរាទៅលើការងារអប់រំកុមារ ចាប់ពីឆ្នាំ២០១១មក។ លោកថា ការអប់រំបរិស្ថានពិតជាមានសារសំខាន់ណាស់ លើការងារគ្រប់គ្រងបរិស្ថានក្នុងរមណីយដ្ឋានអង្គរ។ លោកពន្យល់ថា គេត្រូវបណ្តុះគំនិតឱ្យកុមារយល់ដឹងពីការថែរក្សាបរិស្ថាន ការគ្រប់គ្រងបរិស្ថានចាប់ពីពួកគេនៅតូចៗទៅ ដើម្បីឱ្យគំនិតនេះរីកដុះដាលនៅពេលពួកគេធំដឹងក្តី។ លោកបន្ថែមថា គោលបំណងរបស់កម្មវិធីអប់រំនេះ គឺធ្វើយ៉ាងណា រក្សារមណីយដ្ឋានអង្គរឱ្យនៅបន្តជារមណីយដ្ឋានដែលមានបរិស្ថាន វប្បធម៌ និងសហគមន៍ ដើម្បីជានាំបាននូវការអភិវឌ្ឍប្រកបដោយនិរន្តរភាពសម្រាប់អ្នកជំនាន់ក្រោយ។

នៅក្នុងការអនុវត្តកម្មវិធីបណ្តុះគំនិតកុមារថែរក្សាបរិស្ថាននេះ ស្ថាប័ន JQA បានជ្រើសយកវិធីមួយដែលជាគោលគំនិតនៃស្តង់ដាអន្តរជាតិ ISO14001 ដាក់ជាស្នូលនៃការអប់រំ ពោលគឺគោរពទៅតាមក្បួន PDCA =Plan,Do,Check,Act មានន័យថា គិត ធ្វើតាមដាន និងពិនិត្យឡើងវិញ ដោយចាប់ផ្តើមពីការដាក់គោលដៅ រួចហើយចាប់អនុវត្ត បន្តដោយធ្វើការតាមដាន និងពិចារណាសារជាថ្មី ហើយសកម្មក្នុងការកែតម្រូវ កែលម្អជាបន្តបន្ទាប់។ **លោក SATORU KISHINO** ថា ក្បួននេះ ជាជំនួយឱ្យកុមារចេះគិតដោយខ្លួនឯង ក្លាក់រឭកអំពីបញ្ហាបរិស្ថាន ថាជាបញ្ហាផ្ទាល់ខ្លួន របស់ផ្ទះខ្លួន សាលាខ្លួន ភូមិខ្លួន តំបន់ខ្លួន ហើយត្រិះរិះរកវិធីដោះស្រាយដោយខ្លួនឯងនិងចេះរួបរួមគ្នាធ្វើសកម្មភាពទៅតាមឆន្ទៈរបស់ខ្លួន។

ជារៀងរាល់ឆ្នាំ ស្ថាប័ន JQA បានជួយឧបត្ថម្ភដល់អាជ្ញាធរជាតិអប្សរា ដោយបញ្ជូនអ្នកជំនាញការរបស់ខ្លួន បើកសិក្ខាសាលាទាក់ទងនឹងការថែរក្សាបរិស្ថានជូនមន្ត្រីរដ្ឋបាលស្រុក-ខេត្ត និងក្រុមហ៊ុនពាណិជ្ជកម្មទេសចរណ៍ មានសណ្ឋាគារ និង ភោជនីយដ្ឋានជាដើម ដើម្បីឱ្យពួកគេចូលរួមចំពោះការងារថែរក្សាបរិស្ថានអង្គរនេះ។ ចាប់ពីឆ្នាំ២០១១មក ស្ថាប័ន JQA បានធ្វើសកម្មភាពអប់រំកុមារនៅតាមសាលាក្នុងរមណីយដ្ឋានអង្គរ ដែលរៀននៅថ្នាក់ទី៥ និងទី៦ ឱ្យពួកគេយល់ដឹងបន្ថែមពីបញ្ហាបរិស្ថាន និងសង្ឃឹមថា ការចូលរួមរបស់កុមារនឹងធ្វើឱ្យចលនានេះរីកសាយភាយទៅដល់គ្រួសារ ដល់ភូមិ-ឃុំ រហូតដល់សហគមន៍ក្នុងតំបន់ទាំងមូលក្លាយជាគំរូល្អមួយសម្រាប់ប្រទេសកម្ពុជាទៅអនាគតជាពុំខាន។

ទោះជាស្ថាប័ន JQA មានកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរជាតិអប្សរា ទាំងទៅលើការងារផ្តល់វិញ្ញាបនបត្រស្តង់ដា ISO 14001 និងការងារអប់រំបរិស្ថានកុមារបែបណាក្តី ក៏ស្ថាប័ននេះមានបំណង ចង់ឱ្យអាជ្ញាធរជាតិអប្សរា ដែលជាស្ថាប័នជាតិ អាចបន្តការងារនេះបានដោយខ្លួនឯង និយាយឱ្យខ្លីគឺដើរតួជាតួឯកជំនួសស្ថាប័ន JQA ដោយស្ថាប័ននេះសុំធ្វើជាតួរង ឬតួរាយវិញ។ នេះជាការលើកឡើងរបស់លោក SATORU KISHINO អំពីបំណងក្នុងរយៈពេល៣ឆ្នាំទៅមុខ។ លោកពន្យល់ថា ទាំងអាជ្ញាធរជាតិអប្សរា និងមន្ទីរអប់រំ យុវជន និងកីឡា ដែលសហការរៀបចំកម្មវិធីបណ្តុះកុមារថែរក្សាបរិស្ថាន សុទ្ធសឹងមានបទពិសោធន៍ច្រើននាយៈពេលប៉ុន្មានឆ្នាំមកនេះ ហើយស្ថាប័នលោកចង់ឱ្យខ្មែរធ្វើការងារនេះដើម្បីខ្មែរដោយខ្លួនឯង ដូចការលើកឡើងរបស់ **លោកសាស្ត្រាចារ្យ យ៉ូស៊ីអាគី អ៊ីស៊ីសាវ៉ា** នៃសាកលវិទ្យាល័យ សូហ្វីយ៉ា ដែលមានប្រសាសន៍ថា «អប់រំកូនខ្មែរ ដោយដៃខ្មែរដើម្បីខ្មែរ»។

ក្នុងរយៈពេលចុងក្រោយដែល **លោក SATORU KISHINO** មកកម្ពុជា លោកសង្កេតឃើញថា បញ្ហាបរិស្ថានក្នុងតំបន់អង្គរមានភាពល្អប្រសើរ ទាំងការគ្រប់គ្រងសំរាមក៏ល្អជាងមុន ហើយការគ្រប់គ្រងភ្ញៀវទេសចរក៏ល្អប្រសើរផងដែរ។ ទាក់ទងនឹងកុមារវិញ លោកសង្កេតឃើញថា ពួកគេមានការយកចិត្តទុកដាក់ ចង់ចេះ ចង់ដឹង តាមរយៈក្រសែភ្នែករបស់ពួកគេ ហើយនេះជាលទ្ធផលល្អក្នុងការអប់រំកុមារនៅតំបន់អង្គរ៕






អាយស៊ី-ស៊ីអន្តរៈ ការខាវថែរក្សានិងអភិវឌ្ឍន៍មណីយដ្ឋានអង្គរកាន់តែចម្រុលចានដោតជ័យ

ផ្សាយនៅថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ២០១៨

អស់រយៈពេល២៥ឆ្នាំមកហើយ ដែលរមណីយដ្ឋានអង្គរត្រូវបានចុះក្នុងបញ្ជីសម្បត្តិបេតិកភណ្ឌពិភពលោករបស់អង្គការយូណេស្កូ។ ក្នុងរយៈពេល២៥ឆ្នាំនេះ ពិភពលោកទាំងមូលមានភាពរំដើបរំជួលចំពោះសំណង់ស្ថាបត្យកម្មនៃប្រាសាទអង្គរវត្ត ហើយពីមួយឆ្នាំទៅមួយឆ្នាំភ្ញៀវទេសចរកាន់តែច្រើនបានមកទស្សនារមណីយដ្ឋានអង្គរ។

ថ្លែងក្នុងកិច្ចប្រជុំបច្ចេកទេសលើកទី៣០ នាទីស្នាក់ការអាជ្ញាធរជាតិអប្សរា ថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០១៨ ដោយមានការចូលរួមពី **លោកជំទាវ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាប្រធានអាជ្ញាធរជាតិអប្សរា តំណាងស្ថានទូត ក្រុមអ្នកជំនាញការជាតិ និងអន្តរជាតិនានា សហប្រធានបារាំងនៃកិច្ចប្រជុំអាយស៊ីស៊ី-អង្គរ **លោក Guillaun NARJOLLET** បានបង្ហាញពីភាពរីករាយចំពោះការខិតខំប្រឹងប្រែងរបស់អ្នកជំនាញការជាតិ និងអន្តរជាតិ ដែលធ្វើឱ្យរមណីយដ្ឋានអង្គរមានភាពលេចធ្លោមកដល់សព្វថ្ងៃ។ ទន្ទឹមនឹងការអបអរសាទរ **លោក Guillaun NARJOLLET** ក៏បានរំលឹកដែរថា ការរីករាយជាមួយនឹងភាពជោគជ័យ នឹងអាចនាំឱ្យយើងបរាជ័យដែរ បើយើងធ្វេសប្រហែលនៅ ចំណុចណាមួយនៅក្នុងតំបន់អង្គរ។

សហប្រធានបារាំងរូបនេះ បានពន្យល់ថា អាយស៊ីស៊ី-អង្គរទទួលបានជោគជ័យយ៉ាងខ្លាំងជាបន្តបន្ទាប់នៅក្នុងរមណីយដ្ឋានអង្គរតាំងពីឆ្នាំ១៩៩៣មក ធ្វើឱ្យរមណីយដ្ឋានអង្គរប្រែក្លាយពីសម្បត្តិបេតិកភណ្ឌប្រឈមនឹងគ្រោះថ្នាក់ក្លាយជាសម្បត្តិបេតិកភណ្ឌមួយដ៏ពេញលេញ និងជាគោលដៅទេសចរណ៍ដ៏លេចធ្លោក្នុងពិភពលោក ហើយភ្ញៀវទេសចរមានការកើនឡើងជារៀងរាល់ឆ្នាំ។ ប៉ុន្តែកំណើននេះក៏ជាការគំរាមកំហែងដល់អង្គរដែរ ដូច្នេះយើងមិនត្រូវរីករាយជាមួយនឹងភាពជោគជ័យនេះទេ។ យើងត្រូវផ្តោតសំខាន់នូវការរៀបចំគោលនយោបាយនិងអនុវត្តនូវវិធានការផ្សេងៗដែលអាចឲ្យយើងធានាបាននូវតុល្យភាពរវាងកំណើនវិស័យទេសចរណ៍និងកិច្ចការអភិរក្ស។

ដូចគ្នាដែរ **លោកស្រី Ann LEMEISTRS** តំណាងអង្គការយូណេស្កូប្រចាំកម្ពុជា ក៏បានបង្ហាញការពេញចិត្តជាខ្លាំងពេលឃើញរមណីយដ្ឋានអង្គរមានការអភិវឌ្ឍ ហើយអាជ្ញាធរជាតិអប្សរាបានគិតគូរហ្មត់ចត់ជាមុនពីផលលំបាកនិងចំណុចប្រឈមនានាដែលអាចនឹងកើតឡើងក្នុងរមណីយដ្ឋានអង្គរផងដែរ។ លោកស្រីក៏បានអរគុណដល់អ្នកចូលរួមទាំងអស់ក្នុងរយៈពេល២៥ឆ្នាំមកនេះ ដែលបានធ្វើឱ្យរមណីយដ្ឋានអង្គរមានភាពលេចធ្លោរហូតមកដល់សព្វថ្ងៃ ហើយសង្ឃឹមថា អ្នកទាំងនោះនឹងបន្តការងារដើម្បីបុព្វហេតុរមណីយដ្ឋានអង្គរបន្តទៀត។

លើសពីនេះទៀត គណៈកម្មការអាយស៊ីស៊ីអង្គរក៏បានបង្ហាញនូវសេចក្តីពេញចិត្តជាខ្លាំងចំពោះការរីកចម្រើននូវសមត្ថភាពរបស់អ្នកជំនាញអាជ្ញាធរជាតិអប្សរា ជាពិសេសភាពម្ចាស់ការក្នុងការដឹកនាំអនុវត្តនូវគម្រោងជាច្រើនក្នុងរមណីយដ្ឋានទាំងការងារស្រាវជ្រាវ ការងារអភិរក្សជួសជុល និងការងារអភិវឌ្ឍន៍ប្រកបដោយចីរភាពតំបន់រមណីយដ្ឋានអង្គរ។

គួរបញ្ជាក់ថា គណៈកម្មាធិការអន្តរជាតិដើម្បីសម្របសម្រួលកិច្ចគាំពារ និងអភិវឌ្ឍន៍រមណីយដ្ឋានអង្គរ ហៅកាត់ថា អាយស៊ីស៊ី-អង្គរ បានបើកកិច្ចប្រជុំបច្ចេកទេសលើកទី៣០របស់ខ្លួន នៅថ្ងៃទី៥ និងទី៦ មិថុនា ឆ្នាំ២០១៨ នៅស្នាក់ការអាជ្ញាធរជាតិអប្សរា៕









កិច្ចប្រជុំបច្ចេកទេសលើកទី៣០នៃគណៈកម្មការអាយស៊ីស៊ី-អង្គរបញ្ចប់ដោយលើកពីឧឡារភាពនៃការចារនិងជនជាតមនុស្សរបស់អ្នកជំនាញខ្មែរលើកិច្ចការជួសជុលនិងអភិរក្សសម្បត្តិបេតិកភណ្ឌពិភពលោកក្នុងតំបន់អង្គរ

ផ្សាយនៅថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ២០១៨

កិច្ចប្រជុំបច្ចេកទេសលើកទី៣០នៃគណៈកម្មាធិការអន្តរជាតិដើម្បីសម្របសម្រួលកិច្ចគាំពារ និងអភិវឌ្ឍន៍រមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ ហៅកាត់ថា អាយស៊ីស៊ី-អង្គរ (International Coordinating Committee for the Safeguarding and Development of Historic Site of Angkor : ICC-Angkor) បានបញ្ចប់ដោយជោគជ័យនៅរសៀលថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៨ នាសាលសន្និសីទអង្គរនៃមជ្ឈមណ្ឌលអាជ្ញាធរជាតិអប្សរា។

កិច្ចប្រជុំនេះបានបង្ហាញ ពីរបាយការណ៍ការងារដោយអ្នកជំនាញ ជាតិនិងអន្តរជាតិជាច្រើនដែលក្នុងនោះមានដូចជា វឌ្ឍនភាពនៃការឆ្លាក់កម្រាលពិដានឈើនៅរោងទងកូរសមុទ្រទឹកដោះ ការជួសជុលប្រាសាទភ្នំបាខែង ការជួសជុល ស្ពានហាលប្រាសាទអង្គរវត្ត ការសិក្សាស្រាវជ្រាវបុរាណវិទ្យានៅប្រាសាទបេងមាលា-ភ្នំគូលែន និងការជួសជុល ប្រាសាទតាព្រហ្ម។ល។ រីឯកិច្ចការអភិវឌ្ឍន៍មានដូចជា ការកែលម្អផ្លូវថ្នល់ក្នុងឧទ្យានអង្គរ ការរៀបចំចំណតរថយន្តការរៀបចំនិងបង្កើតរង់ទស្សនាសម្រាប់ភ្ញៀវទេសចរ ការរៀបចំបរិស្ថាន ការទប់ស្កាត់សំណង់ខុសច្បាប់ ។ល។

ក្រៅពីស្តាប់របាយការណ៍និងការវិភាគវែកញែករបស់អ្នកជំនាញ កិច្ចប្រជុំបានសម្តែងនូវសេចក្តីពេញចិត្តជាខ្លាំងចំពោះភាពជោគជ័យដែលក្រុមការងារនៃអាជ្ញាធរជាតិអប្សរានិងក្រុមការងារអន្តរជាតិបានពួតដៃគ្នាយ៉ាងមាំលើវិថីអភិរក្សនិងអភិវឌ្ឍន៍

ប្រកបដោយចីរភាពនៅក្នុងតំបន់អង្គរក្នុងរយៈពេល២៥ឆ្នាំនេះ។ ភាពជោគជ័យនេះ មិនត្រឹមតែជាមោទនភាពរបស់ជាតិប៉ុណ្ណោះទេ ប៉ុន្តែក៏ជាមោទនភាពរបស់អង្គការយូណេស្កូផងដែរព្រោះទម្រង់នៃកិច្ចសហប្រតិបត្តិការអន្តរជាតិទៅលើការអភិរក្សជួសជុលនិងអភិរក្សបេតិកភណ្ឌពិភពលោកដែលមាននៅអង្គរត្រូវចាត់ទុកជាគំរូ និងយកទៅអនុវត្តនៅបណ្តាប្រទេសដទៃទៀតផងដែរ។

ជាពិសេសទៀតនោះគណៈកម្មការអោយស៊ីស៊ី-អង្គរក៏បានសម្តែងនូវការកោតសរសើ និងអបអរសាទរយ៉ាងជ្រាលជ្រៅដល់គោលនយោបាយអភិរក្សវប្បធម៌របស់រាជរដ្ឋាភិបាលកម្ពុជា ជាពិសេសសុឆន្ទៈរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការបញ្ចៀសឱ្យផុតនូវផលប៉ះពាល់អវិជ្ជមាននានាពីកំណើនវិស័យទេសចរណ៍ដល់បេតិកភណ្ឌ។

ស្របនឹងគោលនយោបាយនៃរាជរដ្ឋាភិបាលកម្ពុជា **ឯកឧត្តម ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងជាប្រធានអាជ្ញាធរជាតិអប្សរា បានលើកឡើងនូវកត្តាសំខាន់ៗចំនួន៤ក្នុងការរក្សាបាននូវតុល្យភាពនៃការអភិរក្សនិងការអភិវឌ្ឍដោយចីរភាពនៅតំបន់អង្គរដូចជា ១. កិច្ចសហប្រតិបត្តិការអន្តជាតិដ៏ល្អ ព្រោះកាលពី២៥ឆ្នាំមុន អ្នកជំនាញខ្មែរមិនទាន់មានកម្រិតអាចគ្រប់គ្រងនិងជំនាញអាចជួសជុល អភិរក្សប្រាសាទបានពេញលេញដូចសព្វថ្ងៃនេះ ដូច្នេះមានតែអ្នកជំនាញបរទេសនេះហើយ ដែលបានជួយអង្គរទាំងអ្នកជំនាញ បច្ចេកទេស និងថវិកា ២. កត្តាអ្នកជំនាញជាតិនិងកិច្ចសហប្រតិបត្តិការជាតិ គឺអាជ្ញាធរជាតិអប្សរា បានខិតខំបណ្តុះបណ្តាលធនធានមនុស្សគ្រប់ផ្នែកទាំងក្នុងស្រុកនិងក្រៅស្រុករហូតអ្នកជំនាញខ្មែរ អាចដឹកនាំនិងជួសជុលប្រាសាទបានដោយខ្លួនឯង និងមានការកោតសរសើខ្ពស់ពីអ្នកជំនាញបរទេសផងដែរ។

លើសពីនោះ ក៏មានការរួមចំណែកដ៏ល្អពីស្ថាប័នជាតិនានា ដើម្បីធានាបាននូវភាពទាក់ទាញទេសចរ ការថែរក្សាបានយ៉ាងប្រសើរ ទើបធ្វើឱ្យអង្គរទទួលបានជោគជ័យជាគោលដៅទេសចរណ៍លេខមួយជាច្រើនឆ្នាំ ៣. ការអភិវឌ្ឍជាក់ស្តែងនៅនឹងកន្លែងរបស់សហគមន៍ប្រជាពលរដ្ឋ ក្នុងតំបន់រមណីយដ្ឋានអង្គរ ជាពិសេសការលើកកម្ពស់ជីវភាព របស់ប្រជាពលរដ្ឋតាមរយៈកំណើនទេសចរណ៍ ៤. ចុងក្រោយ គឺកត្តាសុខសន្តិភាពនៃគោលនយោបាយឈ្នះៗរបស់រាជរដ្ឋាភិបាលកម្ពុជានយោបាយបើកចំហជើងមេឃដែលទាក់ទាញបាននូវអ្នកជំនាញការបរទេស ភ្ញៀវទេសចរ និងអ្នកវិនិយោគទុនយ៉ាងច្រើនរួមគ្នាមកអភិរក្សនិងអភិវឌ្ឍន៍តំបន់អង្គរប្រកបដោយចីរភាព៕









អ្នកជំនាញបន្ថាញពីរចនាសម្ព័ន្ធស្រះខាងជើងមុខអង្គរវត្តដែលបានពីលទ្ធផលកំណាយស្រាវជ្រាវ

ផ្សាយនៅថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ២០១៨

មន្ត្រីជំនាញនៃអាជ្ញាធរជាតិអប្សរាបានបង្ហាញថា ការងារកំណាយស្រាវជ្រាវនៅស្រះខាងជើងមុខអង្គរវត្ត ទទួលបានលទ្ធផលខ្លះហើយមកដល់ពេលនេះ។ ជាលទ្ធផលបឋមក្រុមការងារបានរកឃើញរចនាសម្ព័ន្ធស្រះដែលមានកាំជណ្តើរធ្វើអំពីថ្មបាយក្រៀមនៅតួស្រះនិងថ្មកក់នៅមាត់ស្រះ ក្រៅពីនោះមានការចាក់បង្គរដីជាស្រទាប់ៗខុសៗគ្នាដើម្បីរក្សាស្ថេរភាពផ្ទៃស្រះទាំងមូល។

នៅក្នុងកិច្ចប្រជុំបច្ចេកទេសលើកទី៣០ របស់គណៈកម្មាធិការអន្តរជាតិដើម្បីសម្របសម្រួលកិច្ចការគាំពារនិងអភិវឌ្ឍន៍រមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ ហៅកាត់ថា អាយស៊ីស៊ី-អង្គរ កាលពីព្រឹកថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៨ **អ្នកស្រី នេត សុីមន** បុរាណវិទូនៃនាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរនិងបុរាណវិទ្យាបង្គារនៃអាជ្ញាធរជាតិអប្សរា មានប្រសាសន៍ថា ការធ្វើកំណាយនេះមានចំនួន២ទីតាំង។ ទីតាំងទី១ដែលកំពុងកំណាយមាន៣រណ្តៅជាប់គ្នា ហើយលទ្ធផលបឋមបានបង្ហាញអំពីការរៀបចំគ្រឹះ មាត់ស្រះនិងជណ្តើរ៣កាំចុះក្រោមសាងអំពីថ្មកក់ និងកាំជណ្តើរក្រោមៗទៀតធ្វើអំពីថ្មបាយក្រៀមកប់ដីដែលមានសភាពទ្រុឌទ្រោមខូចខាតរូបរាងក្នុងទម្រង់មិនច្បាស់លាស់ ពិបាកសន្និដ្ឋានថាជាកាំជណ្តើរឬជាដីបុកបង្គាប់ធ្វើជាបាតស្រះ។ អ្នកស្រីបានបញ្ជាក់ទៀតថា តាមរយៈការសិក្សាស្រទាប់ដីនេះ បានបង្ហាញទម្រង់ពិសេសៗ៣ចំណុចសំខាន់ៗ។ ទី១. ការចាក់បង្គរដីយ៉ាងធំនៅផ្ទៃខាងក្រៅស្រះដែលបានបុកបង្គាប់ឆ្លាស់គ្នា ដោយមានស្រទាប់ថ្មបាយក្រៀមលាយដីឥដ្ឋ លាយថ្មភ្នំ ស្របតាមបណ្តោយមាត់ស្រះ រីឯផ្ទៃខាងក្រោម មានការបុកបង្គាប់ជាមួយដីខ្សាច់លាយដីឥដ្ឋ លាយថ្មបាយក្រៀម។ ទី២. រចនាសម្ព័ន្ធស្រះទាំងមូលបានរៀបកាំជណ្តើរថ្មកក់នៅមាត់ស្រះ ព្រមទាំងរៀបថ្មបាយក្រៀមផ្នែកខាងក្រៅនៅបាតស្រះមានការបុកបង្គាប់ដី មានខ្សាច់លាយថ្មភ្នំ នៅស្រទាប់នេះ ដែលពិបាកកំណត់តួនាទីនៃការប្រើប្រាស់ ដោយសារថ្មភ្នំនិងថ្មបាយក្រៀមមានការពុកផុយជាអន្លើៗ។ ទី៣. ការចាក់បង្គរសម័យថ្មី រកឃើញកំណាត់ឈើ បន្ទះក្តារប្រើប្រាស់សម័យមុននិងលាយឡំដោយសម្ភារៈសម័យថ្មី។ បន្ទាប់ពីបញ្ចប់គម្រោងកំណាយរណ្តៅទីមួយនេះ ក្រុមការងារនឹងបន្តកំណាយនៅស្រះផ្នែកខាងកើតឆៀងខាងត្បូងដែលជារណ្តៅទី២។

សូមបញ្ជាក់ដែរថា ការធ្វើកំណាយនេះមានគោលបំណងលើកតម្លៃស្រះ ដែលជាផ្នែកមួយនៃស្តាបត្យកម្មប្រាសាទអង្គរ ទម្រង់ស្តាបត្យកម្មប្រាសាទសម្រាប់ការពង្រឹងជួសជុលលើសោកណ្តាភាពស្រះ និងទម្រង់ទស្សនីយភាពទេសចរ។ គួរឲ្យកត់ដែរថា កន្លងមកស្រះខាងជើងនិងខាងត្បូងមុខអង្គរវត្តត្រូវបានបំផ្លាញដោយធម្មជាតិ នៅក្នុងឆ្នាំ១៩២០-២១សាលាបារាំងចុងបូព៌ា មាន **លោក HENRI Machal (ហង់រី ម៉ាហ្សាល់)** បានធ្វើកំណាយ និងជួសជុលឡើងវិញ។ នៅឆ្នាំ២០០៥-

២០០៧ ក្រុមការងារបុរាណវិទ្យាក៏បានសិក្សារចនាសម្ពន្ធស្រះខាងត្បូងរកឃើញជណ្តើរចំនួន៦កាំដែលមានស្ថានភាពល្អ និងជណ្តើរថ្មបាយក្រៀមពុកផុយនិងបាតគ្រឹះមានសភាពនៅល្អនៅឡើយ។









អាជ្ញាធរជាតិអប្សរានឹងចាត់ទិដានការយ៉ាងតឹងរឹងចំពោះការបង្ហោះ Drone នៅក្នុងតំបន់រមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ២០១៨

ដើម្បីទប់ស្កាត់ការបង្ហោះយន្តហោះខ្នាតតូច (Drone) ក្នុងតំបន់អង្គរឲ្យកាន់តែមានប្រសិទ្ធភាពជាងមុន នារសៀលថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៨ អាជ្ញាធរជាតិអប្សរា បានបើកកិច្ចប្រជុំពិភាក្សាជាមួយស្ថាប័នជំនាញ និងសមត្ថកិច្ចពាក់ព័ន្ធផ្សេងៗដូចជា តំណាងរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលកម្ពុជា តំណាងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា តំណាងសាលាខេត្តសៀមរាប តំណាងស្នងការនគរបាលខេត្តសៀមរាប តំណាងមេបញ្ជាការកងរាជអាវុធហត្ថខេត្តសៀមរាប ប្រធាននាយកដ្ឋាននគរបាលទេសចរណ៍ តំណាងនាយកដ្ឋាននគរការពារបេតិកភណ្ឌ តំណាងគ្រឹះស្ថានអង្គរ ប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តសៀមរាប តំណាងមន្ទីរទេសចរណ៍ខេត្តសៀមរាប តំណាងមន្ទីរព័ត៌មានខេត្តសៀមរាប សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ទាំង៦នៅខេត្តសៀមរាប តំណាងសមាគមទីភ្នាក់ងារទេសចរណ៍នៅខេត្តសៀមរាប និងមេធាវីរបស់អាជ្ញាធរជាតិអប្សរាជាដើម ដើម្បីរិះរកវិធានការស្របច្បាប់ និងអាចអនុវត្តបានប្រកបដោយប្រសិទ្ធភាព។

ការរៀបចំកិច្ចប្រជុំនេះឡើង ស្របពេលដែលការលួចបង្ហោះ Drone ក្នុងរមណីយដ្ឋានអង្គរមានការកើនឡើងយ៉ាងគំហុក ក្នុងរយៈពេល២ឆ្នាំចុងក្រោយនេះ ពោលគឺត្រីមាសទី១ ឆ្នាំ២០១៧ មានចំនួន៥៨ គ្រឿង និងត្រីមាសទី១ឆ្នាំ២០១៨ មានរហូតដល់ចំនួន ១៥៨ គ្រឿង បើទោះជាអាជ្ញាធរជាតិអប្សរាធ្លាប់បានផ្សព្វផ្សាយជាសាធារណៈតាមរយៈសេចក្តីជូនដំណឹងលេខ៦៧៧/១៦រប.សជណ ហើយក្រុមការងារបានព្យាយាមទប់ស្កាត់យ៉ាងណាក្តី។ ការរៀបចំកិច្ចប្រជុំនេះ គឺក្នុងគោលដៅពិភាក្សា រកវិធីសាស្ត្រផ្សព្វផ្សាយឱ្យកាន់តែទូលំទូលាយទៅកាន់អ្នកប្រើប្រាស់Drone និងរិះរកវិធានការពិន័យតឹងរឹងបន្ថែមទៀត។

ឯកឧត្តម សុខ សង្ហារ អគ្គនាយករងនៃអាជ្ញាធរជាតិអប្សរា មានប្រសាសន៍ថា កំណើននៃDroneក្នុងតំបន់អង្គរនេះ វាជាហានិភ័យដល់ប្រាង្គប្រាសាទនានា បង្កការរំខាន និងអាចប៉ះពាល់ដល់សុវត្ថិភាពរបស់ប្រជាពលរដ្ឋក្នុងរមណីយដ្ឋានអង្គរ និងភ្ញៀវទេសចរថែមទៀត។ ម្យ៉ាងវិញទៀត Drone ជាបច្ចេកវិជ្ជាដ៏ទំនើប ដែលអាចបង្កភាពងាយស្រួលដល់ក្រុមភេរវកម្មក្នុងការបំផ្លាញដល់រមណីដ្ឋានបេតិកភណ្ឌពិភពលោកផងដែរ។

លោក ក្រូច វ៉ាន់ឌី អនុប្រធាននាយកដ្ឋានអាកាសចរណ៍ស៊ីវិល បញ្ជាក់ថា ជាគោលការណ៍កន្លងមកលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលបានកំណត់មិនឲ្យមានប្រើប្រាស់Droneជាលក្ខណៈបុគ្គលឡើយ។ អាចអនុញ្ញាតបានតែក្នុងករណីក្រុមហ៊ុនមានចុះបញ្ជីត្រឹមត្រូវ និងអាចអនុញ្ញាតឲ្យបង្ហោះក្នុងរយៈចម្ងាយ១៥គម ពីតំបន់ហាមឃាត់ និងមិនឲ្យហួសពីកម្ពស់១៥០ម៉ែត្រពីដី។

ជាលទ្ធផល កិច្ចប្រជុំនេះបានព្រមព្រៀងគ្នាដើម្បីបង្កើតក្រុមការងារចម្រុះមួយដែលនឹងពិភាក្សាទៅលើអង្គច្បាប់ ដើម្បីចាត់វិធានការតឹងរឹងបន្ថែមទៀត។ ចំណែកវិធានការជាបណ្តោះអាសន្ន គឺត្រូវចាប់Droneក្សាទុកមួយរយៈជាបណ្តោះអាសន្ន និងតម្រូវឲ្យម្ចាស់បំពេញបែបបទស្នើសុំតាមក្រោយ។

ជាមួយគ្នានេះ អាជ្ញាធរជាតិអប្សរានិងស្ថាប័នពាក់ព័ន្ធផ្សេងទៀត នឹងរៀបចំការផ្សព្វផ្សាយឲ្យកាន់តែទូលំទូលាយថែមទៀតនូវបម្រាមប្រើប្រាស់Droneក្នុងតំបន់អង្គរ ដូចជា ការបោះពុម្ពផ្ទាំងប៉ាណូធំៗ ការដាក់សញ្ញាហាមឃាត់នៅលើបណ្តាទស្សនាដ្ឋាន និងការផ្សព្វផ្សាយនៅលើគេហទំព័រទេសចរណ៍ជាដើម៕









កម្រោងជួសជុលប្រាសាទមេបុណ្យខាងលិចនឹងត្រូវជួសជុលដោយអាជ្ញាធរជាតិអប្សរាបន្តពីភាគីចារ៉ន

ផ្សាយនៅថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ២០១៨

ប្រាសាទមេបុណ្យខាងលិចត្រូវបានអភិរក្ស ជួសជុល និងស្តារឡើងវិញដោយគម្រោងសហការរវាងអាជ្ញាធរជាតិអប្សរានិងរដ្ឋាភិបាលបារាំង តាមរយៈសាលាបារាំងចុងបូព៌ា ដែលចាប់ផ្តើមពីឆ្នាំ២០១២មក និងគ្រោងបញ្ចប់នៅឆ្នាំ២០១៩។ ប៉ុន្តែដោយមានកង្វះខាតផ្នែកថវិកានិងតាមការពិភាក្សាយ៉ាងហ្មត់ចត់រវាងស្ថាប័នពាក់ពន្ធ័ គម្រោងជួសជុលនឹងត្រូវប្រគល់មកអាជ្ញាធរជាតិអប្សរាជាអ្នកទទួលវ៉ាប់រងជួសជុលវិញ។

ជាក់ស្តែង នៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៨ **ឯកឧត្តម ហង់ ពៅ** អគ្គនាយករងអាជ្ញាធរជាតិអប្សរា នាពេលដឹកនាំក្រុមអ្នកជំនាញជាតិលើផ្នែកជួសជុលនិងអភិរក្សប្រាសាទទៅប្រាសាទមេបុណ្យខាងលិច បានឱ្យដឹងថា នាពេលអនាគតយ៉ាងខ្លីការដ្ឋានជួសជុលប្រាសាទមេបុណ្យខាងលិច ដែលទទួលខុសត្រូវដោយជំនួយឧបត្ថម្ភរបស់រដ្ឋាភិបាលបារាំងនឹងត្រូវបានបញ្ចប់ទាំងស្រុងមុនកំណត់ ប៉ុន្តែការជួសជុលបន្តនឹងត្រូវប្រគល់ជូនអាជ្ញាធរជាតិអប្សរាគ្រប់គ្រងនិងទទួលខុសត្រូវវិញម្តង។

ឯកឧត្តមបន្តថា បើទោះបីជាមិនគ្រប់គ្រងការជួសជុលពេញដៃពេញជើងដូចមុន ក៏ភាគីបារាំងនៅតែបន្តគាំទ្រនិងជួយផ្តល់យោបល់ប្រឹក្សាបច្ចេកទេសដល់អ្នកជំនាញជាន់ខ្ពស់ខ្មែរគ្រប់ពេល។ មិនតែប៉ុណ្ណោះ ភាគីបារាំងក៏បានផ្តល់ព័ត៌មានលម្អិតអំពីវិធីសាស្ត្រនៃការជួសជុលកន្លងមកដល់អ្នកជំនាញជាតិដើម្បីស្វែងយល់ពីការងារឱ្យបានច្បាស់មុននឹងចាប់ផ្តើមការងារបន្ត។

តាមការពិនិត្យជាក់ស្តែង លទ្ធផលជួសជុលនៅប្រាសាទមេបុណ្យខាងលិចមានដូចជា ជួសជុលជញ្ជាំងផ្នែកខាងកើតនិងប៉មចំនួន២បានរួចរាល់ហើយ រីឯប៉ែកខាងលិច ខាងជើង និងខាងត្បូង បានរៀបចំពង្រឹងគ្រឹះដល់កាំទី៥ និងកាំទី៦។

សូមបញ្ជាក់ដែរថា ប្រាសាទមេបុណ្យខាងលិចជាប្រាសាទបុរាណខ្មែរ មានទីតាំងស្ថិតនៅលើដីទួលមួយកន្លែង ចំកណ្តាលបារាយណ៍ខាងលិច។ ប្រាសាទនេះត្រូវបានស្ថាបនាឡើងនៅអំឡុងពាក់កណ្តាលសតវត្សរ៍ទី១១នៃគ្រិស្តសករាជក្នុងរាជ្យព្រះបាទឧទយាទិត្យវរ្ម័នទី២ ឧទ្ទិសចំពោះព្រហ្មញ្ញសាសនាដែលមានលក្ខណៈប្លែកពិសេស ដោយហេតុថា សំណង់ប្រាសាទផ្សំឡើងដោយកំពែងមួយជាន់ធ្វើអំពីថ្មកក់ ហ៊ុមព័ទ្ធស្រះទឹកធំមួយដែលគេជីកនៅលើដីទួលនោះ។ តាមរយៈការធ្វើកំណាយនៅឆ្នាំ១៩៣៩ គេបានរកឃើញរូបបដិមាជាព្រះវិស្ណុក្នុងឥរិយាបថផ្ទំមួយអង្គដែលសព្វថ្ងៃតម្កល់ទុកនៅសារមន្ទីរជាតិភ្នំពេញ៕





ប្រាសាទមេបុណ្យខាងលិច
មុនពេលជួសជុល



ប្រាសាទមេបុណ្យខាងលិច
កំពុងជួសជុល





សកម្មភាពដឹកជញ្ជូនថ្មទៅការដ្ឋាន





សកម្មភាពបង្គាប់ទំនប់កំពែង

អាជ្ញាធរជាតិអប្សរាចុះ អនុស្សារណៈយោគយល់ជាមួយអាជ្ញាធរDASTAរបស់ប្រទេសថៃ ស្តីពីការអភិវឌ្ឍទេសចរណ៍ប្រកបដោយចីរភាព

ផ្សាយនៅថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ២០១៨

នៅទីក្រុងបាងកកនៃប្រទេសថៃ នាព្រឹកថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៨នេះ អាជ្ញាធរជាតិអប្សរា និងអាជ្ញាធរ DASTA (Designated Area for Sustainable Tourism Administration) របស់ប្រទេសថៃ បានចុះអនុស្សារណៈយោគយល់គ្នាជាផ្លូវការក្រោយបានជួបពិភាក្សានិងសិក្សាពីគ្នាអស់រយៈពេលជាងមួយឆ្នាំមក។

សារៈសំខាន់នៃពិធីចុះអនុស្សារណៈគឺ ដើម្បីបង្កើតកិច្ចសហការសម្រាប់ផ្លាស់ប្តូរបទពិសោធន៍ និងជំនាញនៃការគ្រប់គ្រងទេសចរណ៍ប្រកបដោយចីរភាព ដោយផ្តោតទៅលើកិច្ចការសំខាន់ៗមួយចំនួនដូចជា ការស្រាវជ្រាវទេសចរណ៍ ការផ្លាស់ប្តូរអ្នកជំនាញទេសចរណ៍ និងចែករំលែកបទពិសោធន៍ និងចំណេះដឹងនានាពាក់ព័ន្ធនឹងការគ្រប់គ្រងទេសចរណ៍ ការធ្វើទស្សនកិច្ចចុះសង្កេតដើម្បីស្វែងយល់ និងដកពិសោធន៍ការងារ ការបណ្តុះបណ្តាលអំពីគំរូនៃការអភិវឌ្ឍសហគមន៍ទេសចរណ៍និងការបណ្តុះបណ្តាលវគ្គជំនាញទេសចរណ៍ផ្សេងៗជាដើម។

ឯកឧត្តម សុខ សង្ហារ តំណាងឯកឧត្តមអគ្គនាយកអាជ្ញាជាតិអប្សរា បានបញ្ជាក់ថា ការសម្រេចចិត្តចុះអនុស្សារណៈយោគយល់ជាមួយអាជ្ញាធរ DASTA គឺក្នុងគោលដៅពង្រឹងទំនាក់ទំនងលើវិស័យគ្រប់គ្រងទេសចរណ៍ ដោយហេតុថា កិច្ចការចម្បងរបស់អាជ្ញាធរនេះគឺផ្តោតសំខាន់ទៅលើចីរភាពទេសចរណ៍នៅតំបន់ទាំង៥គឺ Koh Chang Islands, Pataya City, Sukhothai-Kamphaengphet Historic Parks, Leoi Province និង U-Thong ដែលបានកំណត់ដោយព្រះរាជក្រឹត្យ។

ឯកឧត្តម Nalikathibhag Sangsnit បញ្ជាក់ថា ភាពជោគជ័យនៃការគ្រប់គ្រងរមណីយដ្ឋានអង្គរ គឺជាចំណុចដែលធ្វើឲ្យក្រុមការងាររបស់លោកកោតសរសើរយ៉ាងខ្លាំង។ ឯកឧត្តមជឿជាក់ថា តាមរយៈទំនាក់ទំនងនេះ ក្រុមការងារលោកនឹងទទួលបានបទពិសោធន៍ល្អៗបន្ថែមទៀត ក្នុងការរៀបចំតំបន់ទេសចរណ៍ DASTA។ ជាមួយគ្នានេះដែរ ឯកឧត្តមក៏បាន

អញ្ជើញមន្ត្រីជំនាញនៃអាជ្ញាធរជាតិអប្សរាដើម្បីចូលរួមប្រជុំអំពីការគ្រប់គ្រងតំបន់បេតិកភណ្ឌពិភពលោកក្នុងតំបន់អាស៊ាន ដែលគ្រោងនឹងរៀបចំនៅប្រទេសថៃក្នុងខែសីហាខាងមុខនេះ។

ជាការចាប់ផ្តើមនៃការអនុវត្តលើអនុស្សារណៈយោគយល់គ្នានេះ អាជ្ញាធរ DASTA បានរៀបចំដំណើរទស្សនកិច្ចសិក្សាជូនមន្ត្រីជំនាញរបស់អាជ្ញាធរជាតិអប្សរា ទៅកាន់រមណីយដ្ឋានសុខោទ័យ ដែលជាបេតិកភណ្ឌពិភពលោកមួយ ដើម្បីដកស្រង់បទពិសោធន៍ពីការងារគ្រប់គ្រងទេសចរណ៍នៅទីនោះ៕






សារលិខិតថ្វាយព្រះពរសម្តេចព្រះមហាក្សត្រក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ

ផ្សាយនៅថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ២០១៨

ទូលព្រះបង្គំខ្ញុំម្ចាស់ **ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងជាប្រធានអាជ្ញាធរជាតិអប្សរា រួមទាំងមន្ត្រីបុគ្គលិកក្រោមបង្គាប់ទាំងអស់ ចូលរួមថ្វាយព្រះពរសព្វសាធុការ ដល់អង្គ **ព្រះមហាក្សត្រក្សត្រី នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត នាឱកាសដ៏សែននក្ខត្តឫក្សនៃព្រះរាជពិធីចម្រើនព្រះជន្មាយុ គម្រប់៨២ព្រះវស្សា ឡើង៨៣ព្រះវស្សា ដែលនឹងប្រព្រឹត្តិទៅនៅថ្ងៃចន្ទ ៦កើត ខែបឋមសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៨ខាងមុខនេះ។

តាងនាមថ្នាក់ដឹកនាំ មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងស្ថាប័នអាជ្ញាធរជាតិអប្សរា និងក្នុងនាមទូលព្រះបង្គំខ្ញុំម្ចាស់ផ្ទាល់ ទូលព្រះបង្គំខ្ញុំម្ចាស់ សូមព្រះបរមរាជានុញ្ញាតដ៏ខ្ពង់ខ្ពស់ ក្រាបបង្គំទូលថ្វាយនូវព្រះរាជសព្វសាធុការពរជ័យ សិរីវឌ្ឍនា វិបុលសុខមហាប្រសើរគ្រប់ប្រការ និងសូមលើកហត្ថប្រណម្យបួងសួងដល់គុណបុណ្យ

ព្រះរតនត្រ័យកែវទាំងបីនិងវត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក ឫទ្ធីបារមីទេវតាថែរក្សាព្រះមហាស្វេតឆត្រ បុណ្យបារមីនៃដួងព្រះក្ខន្ធអតីតព្រះមហាក្សត្រ ព្រះមហាក្សត្រិយានីខ្មែរគ្រប់ព្រះអង្គ ជាពិសេសព្រះករុណាព្រះមហាវីរក្សត្រ ព្រះវររាជបិតាព្រះបរមរតនកោដ្ឋ សូមយាងតាមជួយគាំពារ បីបាច់ថែរក្សា សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ សូមមានព្រះរាជសុខភាពល្អបរិបូណ៌ព្រះកាយពលរឹងមាំ ព្រះបញ្ញាញាណភ្លឺថ្លា និងព្រះជន្មាយុយឺនយូរជាងរយព្រះវស្សា ដើម្បីព្រះអង្គបានថាប់ជាម្លប់ដ៏ត្រជាក់ដល់ប្រជារាស្ត្រខ្មែរជាយូរអង្វែងតរៀងទៅ។



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

សូមក្រាបបង្គំទូលថ្វាយ
សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ

ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត!

ក្នុងឱកាសដ៏សែនមហានក្ខត្តឫក្សនៃព្រះរាជពិធីចម្រើនព្រះជន្មាយុ គម្រប់៨២ព្រះវស្សា យាងចូល៨៣ព្រះវស្សា របស់ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៨ ខាងមុខនេះ តាងនាមថ្នាក់ដឹកនាំ មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងក្នុងនាមទូលព្រះបង្គំខ្ញុំម្ចាស់ផ្ទាល់ ទូលព្រះបង្គំខ្ញុំម្ចាស់សូមព្រះបរមាជានុញ្ញាតដ៏ខ្ពង់ខ្ពស់ ក្រាបបង្គំទូលថ្វាយនូវព្រះពរជ័យសព្វសាធុការពរជ័យ សិរីវឌ្ឍនា វិបុលសុខមហាប្រសើរគ្រប់ប្រការ និងសូមលើកហត្ថប្រណម្យបួងសួងដល់គុណបុណ្យព្រះរតនត្រ័យកែវទាំងបី និងវត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក ឫទ្ធិបារមីទេវតាថែរក្សាព្រះមហាស្វេតឆត្រ បុណ្យបារមីនៃដួងព្រះវិញ្ញាណក្ខន្ធអតីតព្រះមហាក្សត្រ ព្រះមហាក្សត្រិយានីខ្មែរគ្រប់អង្គ ជាពិសេសបុណ្យបារមីព្រះករុណាព្រះមហាវីរក្សត្រ ព្រះវររាជបិតា ព្រះបរមរតនកោដ្ឋ សូមយាងតាមជួយគាំពារ បីបាច់ថែរក្សា **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** សូមមានព្រះរាជសុខភាពល្អបរិបូណ៌ ព្រះកាយពលរឹងមាំ ព្រះបញ្ញាញាណភ្លឺថ្លា និងព្រះជន្មាយុយឺនយូរជាងរយព្រះវស្សា ដើម្បីព្រះអង្គបានប្រថាប់ជាម្លប់ដ៏ត្រជាក់ដល់ប្រជារាស្ត្រខ្មែរជាយូរអង្វែងតរៀងទៅ។

ជាថ្មីម្តងទៀត ទូលព្រះបង្គំខ្ញុំម្ចាស់ សូមអភិវន្ទលំអោនកាយវាចាចិត្ត សម្តែងនូវកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅដែលពុំអាចបំភ្លេចបាននូវព្រះឧបការគុណ និងព្រះមហាករុណាទិគុណ ដ៏ថ្លៃថ្លាបំផុតរបស់ **សម្តេច ព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ដែលតែងតែយកព្រះរាជហឫទ័យទុកដាក់ពុំចេះនឿយណាយព្រះកាយពល ចំពោះសេចក្តីសុខទុក្ខរបស់ប្រជារាស្ត្រទូទាំងព្រះរាជាណាចក្រកម្ពុជា។

សូម **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ទ្រង់ព្រះមេត្តាទទួលនូវគោរកក្តីដ៏ស្មោះស្ម័គ្រ និងអភិវន្ទនាការដ៏ខ្ពង់ខ្ពស់បំផុតអំពីទូលព្រះបង្គំខ្ញុំម្ចាស់។

សេចក្តីគួរពុំគួរ សូម **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ទ្រង់ព្រះមេត្តាប្រោសព្រះរាជទានទោស។

ថ្ងៃសុក្រ ៣កើត ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
ក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៨

រដ្ឋមន្ត្រី

ភឿង - សកុណា

ទូរស័ព្ទ / ទូរសារ : 023 218 148 , E-mail : info@mcfa.gov.kh, www.mcfa.gov.kh, ប្រអប់សំបុត្រ 72
មហាវិថីព្រះនរោត្តម លេខ២២៧ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

ជំឡូងដៃខ្លា ជាជំណាំប្រពៃណីដែលបានលើកកម្ពស់ជីវភាពរបស់អ្នកភូមិពាមបានយ៉ាងប្រសើរ

ផ្សាយនៅថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ២០១៨

ជំឡូងដៃខ្លា ជាប្រភេទរុក្ខជាតិវល្លិ៍ ស្លឹកមានសណ្ឋានដូចស្លឹកម្លូរ និងមានមើមតូចធំទៅតាមប្រភេទពូជ។ ប្រភេទជំឡូងនេះ ជាជំណាំប្រពៃណីរបស់អ្នកភូមិពាម ឃុំដូនកែវ ស្រុកពួក ខេត្តសៀមរាប ដែលដាំតកូនតចៅច្រើនតំណមកហើយ ជាលក្ខណៈគ្រួសារផងនិងសម្រាប់លក់ដូរផង។ បច្ចុប្បន្នប្រជាជនមួយចំនួនធំក្នុងភូមិបានពង្រីកការដាំដុះច្រើនជាងមុន ព្រោះលក់បានតម្លៃខ្ពស់នៅលើទីផ្សារហើយងាយស្រួលថែទាំទៀត។

ទាក់ទងនឹងការដាំដុះ ពីដើមឡើយរហូតមកដល់ពេលនេះ អ្នកភូមិភាគច្រើននៅតែបន្តធ្វើតាមទម្លាប់ពីបរមបុរាណ។ ដោយស្របនឹងគោលការណ៍អភិរក្សវប្បធម៌ប្រពៃណីក្នុងការរស់នៅ ការលើកស្ទួយកម្រិតជីវភាព និងចង់ឱ្យប្រជាជនក្នុងតំបន់អង្គររក្សានូវដំណាំមរតករបស់ខ្លួន អាជ្ញាធរជាតិអប្សរាតាមរយៈគម្រោង ACHA បានសហការជាមួយអង្គការ IDE (In Partnership Promoting Agribusiness) កំពុងយកចិត្តទុកដាក់បង្រៀននិងឱ្យអ្នកភូមិសាកល្បងដាំតាមបច្ចេកទេសថ្មីដែលងាយស្រួល ចំណាយកម្លាំង ទុន និងសម្ភារៈតិចជាងមុន តែទទួលបានទិន្នផលច្រើនជាងដាំតាមទម្លាប់បុរាណ។

អ្នកមីង ផាត គន់ កសិករគំរូនៅភូមិពាម មានប្រសាសន៍ថា គាត់ដាំដំឡូងដៃខ្លាតាមទម្លាប់បុរាណជាង២០ឆ្នាំមកហើយ ពោលគឺតពីម្តាយឪពុករបស់គាត់។ ដំឡូងនេះមួយរដូវដាំបានតែម្តងទេ គឺចាប់ពីក្រោយចូលឆ្នាំហើយ (ខែពិសាខឬខែជេស្ឋ)។ ម៉ាងទៀតជំណាំដំឡូងនេះ ងាយស្រួលដាំដុះ មិនត្រូវការទឹកច្រើន មិនចំណាយទុនច្រើន ឆាប់បានផល វាមិនទាមទារកម្លាំងច្រើនក្នុងការថែទាំ ស្រីៗក៏អាចធ្វើបាននិងងាយស្រួលលក់លើទីផ្សារ។ ចំពោះមើមឆៅលក់ចេញ ៣៥០០រៀល/គីឡូ ចំណែកឆ្អិនបាន៥០០០រៀល/គីឡូ ហើយពេលខ្លះវាអាចថ្លៃជាងនេះក៏មាន។ រីឯនៅឆ្នាំនេះអ្នកមីងបានដាំដំឡូងដៃខ្លានេះតាមទម្លាប់និងតាមបច្ចេកទេសថ្មី ដែលអង្គការ IDE បង្រៀន។

អ្នកមីងបានរៀបរាប់បន្តថា ការដាំតាមទម្លាប់ពីដូនតា គឺគ្រាន់តែជីករណ្តៅជម្រៅ៣តឹកទៅក្រោម ហើយដុតសំរាមទ្រាប់បាត រួចជ្រួយដីបាតឱ្យស្អាត បន្ទាប់មកដាក់ពូជមើមដំឡូងកប់ដី ស្រោចទឹកជាការស្រេច។ បន្ទាប់ពីដំឡូងដុះ លូតលាស់បោះដៃបានសមល្មម ត្រូវយកកូនឈើមាំល្មមមកធ្វើទ្រើងដើម្បីឱ្យដំឡូងវារតោងឡើង លុះរយៈពេលចំនួន៦ខែ អាចប្រមូលផលបានហើយ។ ចំពោះការថែទាំក្នុងពេលកំពុងលូតលាស់ យើងគ្រាន់តែបោចស្មៅកុំឱ្យវាឡើងគ្របលើគល់ ហើយស្រោចទឹក៤ឬ៥ដងក្នុងមួយខែ ប្រសិនបើគ្មានភ្លៀងធ្លាក់ និងជ្រួយដីពូនគល់វាឱ្យខ្ពស់។ ដំឡូងនេះមិនរើសដីទេវាទទួលបានផលទៅតាមរបបទឹកភ្លៀង កាលណាបើភ្លៀងធ្លាក់ច្រើនបណ្តាលឱ្យដីហាប់ មើមចុះតិច និងមិនសូវធំ តែបើភ្លៀងធ្លាក់សមល្មម ដីផុសល្អ នឹងទទួលបានផលច្រើន។ កសិករខ្លួនឯងអាចមើលដឹងថាដំឡូងនឹងទទួលបានទិន្និផលតិចឬច្រើនដោយសង្កេតទៅលើស្លឹក បើស្លឹកដំឡូងធំបញ្ជាក់ថាដំឡូងមើមល្អ តែបើស្លឹកល្អិតៗនោះដំឡូងមើមតូចៗ។ ក្នុងការដាំ ផលលំបាកគឺកាប់ដីធ្វើរោងដាំ ហើយចំណាយតែលុយទិញទ្រើងប៉ុណ្ណោះ តែងាយស្រួលថែនិងមិនសូវមានជំងឺឡើយ។ បើទោះបីមិនទាន់ ដឹងថាទិន្នផលដាំតាមបែបបច្ចេកទេសខុសប្លែក ពីការដាំតាមទម្លាប់យ៉ាងណាតែ **អ្នកមីង ផាត គន់** ឱ្យ ដឹងថា ការដាំតាមបច្ចេកទេស គឺងាយស្រួលជាង ចំណាយកម្លាំងតិច កាត់បន្ថយបង្គោលឈើបានច្រើន ចំណាយការទិញសម្ភារៈតិច ហើយសម្ភារៈមួយចំនួនក៏មានការជួយឧបត្ថម្ភពីអង្គការនិងអាជ្ញាធរជាតិអប្សរាផងដែរ ដូចជាទ្រើងសំណាញ់ស្បៃ និងជី ហើយរបៀបដាំងាយៗ។ អ្នកមីងបញ្ជាក់ថាការនៅបន្តដាំដំណាំនេះដល់សព្វថ្ងៃ ព្រោះផលដំឡូងមានទីផ្សារ អាចលក់ដូរ និងបានលើកស្ទួយជីវភាពគ្រួសារកាន់តែល្អប្រសើរជាងមុន និងមិនបាច់នឿយហត់ក្នុងការដាំដុះ ហើយចង់រក្សាដំណាំពីម្តាយនេះឱ្យគង់វង្សផងដែរ។

លោក ឡាច វីយ៉ា បុគ្គលិកបច្ចេកទេសនៃគម្រោង ACHA ឱ្យដឹងថា នៅឃុំដូនកែវ ដំឡូងដៃខ្លាត្រូវបានប្រជាជនដាំតាំងពីដូនតាមកហើយ។ ដូច្នេះ ដើម្បីលើកទឹកចិត្តដល់អ្នកភូមិឱ្យរក្សានូវដំណាំនេះបន្តនិងក្នុងន័យអភិវឌ្ឍន៍សេដ្ឋកិច្ចគ្រួសារ ហើយស្របតាមគោលការណ៍របស់អាជ្ញាធរជាតិអប្សរាផងនោះ យើងបានផ្តល់បច្ចេកទេសបន្ថែមក្នុងការដាំដំឡូងដល់អ្នកភូមិដើម្បីឱ្យទិន្នផលបានប្រសើរជាងមុន។

លោកបន្តថា ការដាំតាមបច្ចេកទេស គឺងាយស្រួលជាង ចំណាយកម្លាំង និងថវិកាទិញសម្ភារៈតិចជាងដាំតាមទម្លាប់ ដោយគ្រាន់តែជុតសំរាមឬអង្កាមដាក់នៅកន្លែងរោងមុនដាំ រួចហើយកប់ដី ស្រោចទុកជាការស្រេច។ គួរបញ្ជាក់ដែរថា ដំឡូងនេះត្រូវការជាតិអំបិលច្រើន ដូច្នេះការជុតអង្កាម ហើយដាក់ជីកំបោរកសិកម្ម គឺល្អបំផុត ព្រោះវាជួយសម្លាប់មេរោគនិងដីមានជីវជាតិ ធ្វើឱ្យមើមចុះធំ។ លុះពេលវាធំល្មម ចាប់ផ្តើមពូនដីឱ្យខ្ពស់ពីរបីដង រហូតដល់៦ខែប្រមូលផលបាន៕






អាជ្ញាធរជាតិអប្សរាបើកវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រី និងបុគ្គលិកលើដំណាំផលិតទឹកដោះអូ និងបទយកការណ៍

ផ្សាយនៅថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ២០១៨

នៅព្រឹកថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៨ នាស្នាក់ការអាជ្ញាធរជាតិអប្សរា វគ្គបណ្តុះបណ្តាលពីដំនាំផលិតវីដេអូ និងបទយកការណ៍ដល់មន្ត្រី និងបុគ្គលិកនៅនាយកដ្ឋានផ្សព្វផ្សាយត្រូវបានចាប់ផ្តើម។ វគ្គបណ្តុះបណ្តាលមានរយៈពេល៣ថ្ងៃ គឺថ្ងៃទី១៩-២១ ខែមិថុនា ឆ្នាំ២០១៨ រៀបចំឡើងក្នុងបំណងដើម្បីពង្រឹងការផលិតវីដេអូ និងបទយកការណ៍ បម្រើដល់ប្រយោជន៍ក្នុងការផ្សាយចេញនូវសមិទ្ធិផលនានាអាជ្ញាធរជាតិអប្សរាឲ្យកាន់តែទូលំទូលាយ។ សិក្ខាកាមដែលចូលរួមវគ្គបណ្តុះបណ្តាលនេះ គឺជាមន្ត្រី និងបុគ្គលិកនាយកដ្ឋានផ្សព្វផ្សាយចំនួន១៣នាក់ និងមន្ត្រីសាលាខេត្តកំពង់ធំចំនួន០៤នាក់ សរុបមានចំនួន១៧នាក់។

គ្រូបង្គោលនៃវគ្គបណ្តុះបណ្តាលនេះ គឺ **លោក ជា ជានិត** មន្ត្រីព័ត៌មាននៃក្រសួងព័ត៌មាន និងជាអ្នកជំនាញផ្នែកផលិតវីដេអូ និងបទយកការណ៍យ៉ាងប៉ិនប្រសព្វ។ ក្រៅតែពីការយល់ដឹងទ្រឹស្តី សិក្ខាកាម នឹងជ្រើសរើសយកប្រធានបទមួយចំនួនដើម្បីអនុវត្តន៍ជាក់ស្តែង។

លោក ឡុង កុសល ប្រធាននាយកដ្ឋានផ្សព្វផ្សាយ បានថ្លែងក្នុងពិធីបើកវគ្គបណ្តុះបណ្តាលថា ការផ្តល់ចំណេះដឹងនិងបទពិសោធន៍បន្ថែមដល់សិក្ខាកាមទាំងអស់គឺជាសកម្មភាពក្នុងការលើកកម្ពស់ចំណេះដឹងបច្ចេកទេសជំនាញ ដែលចំណេះដឹងទាំងនេះជាធនធានដ៏សំខាន់ក្នុងការជ្រើសយកប្រធានបទសំខាន់ៗនៃការងារជាច្រើនរបស់ស្ថាប័ន ហើយរំលេចខ្លឹមសារទាំងនោះដើម្បីផ្សព្វផ្សាយឲ្យបានស៊ីជម្រៅនិងទាន់ពេលវេលា។ បន្ថែមពីនេះ លោករំពឹងថាមន្ត្រី និងបុគ្គលិកដែលទទួលបន្ទុកផ្នែកព័ត៌មាន វីដេអូ និងបទយកការណ៍ កាន់តែមានលទ្ធភាពអាចផលិតព័ត៌មានគ្រប់ទម្រង់ សំដៅធ្វើយ៉ាងណាពាំនាំព័ត៌មាន ព្រឹត្តិការណ៍សំខាន់ៗរបស់អាជ្ញាធរជាតិអប្សរា ផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់សាធារណជនបានដឹង៕









អាជ្ញាធរជាតិអប្សរាទទួលថវិកាស្តីពីការប្រើប្រាស់រូបភាពប្រាសាទអង្គរវត្តពីក្រុមហ៊ុនសាមសុង

ផ្សាយនៅថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ២០១៨

នារសៀលថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៨នេះ អាជ្ញាធរជាតិអប្សរាបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងទទួលថវិកាចំនួន២៤៧,០៨០,០០០រៀល ពីក្រុមហ៊ុនថៃសាមសុងអេឡិចត្រូនិក ដែលបានប្រើប្រាស់រូបភាពនៃប្រាសាទអង្គរវត្តនៅលើប្រអប់ (box) និងនៅលើផ្ទាំងមុខ (theme) នៃទូរស័ព្ទដៃម៉ាក Samsung Galaxy «J» ស៊េរី២០១៦ តាមរយៈយុទ្ធនាការ «មោទនភាពជាតិក្នុងដៃអ្នក» ក្នុងចេតនាបំផុសទឹកចិត្តស្រលាញ់ និងមោទនភាពចំពោះប្រាសាទអង្គរវត្ត។

លោក Seungho Choi អគ្គនាយកសាខាក្រុមហ៊ុនថៃសាមសុង អេឡិចត្រូនិក ប្រចាំប្រទេសកម្ពុជាបញ្ជាក់ថា រូបភាពអង្គរវត្តដែលបានបង្ហាញនៅលើប្រអប់ (box) និងលើផ្ទាំងមុខ (theme) នៃទូរស័ព្ទដៃម៉ាក Samsung Galaxy «J» សើរី (J3 J5 និង J7) គឺបានបង្ហាញពីចេតនារបស់ក្រុមហ៊ុន ដែលចង់ចូលរួមជាមួយប្រជាជនកម្ពុជា ក្នុងការបំផុសទឹកចិត្តស្រលាញ់ អភិរក្ស និងថែរក្សាសម្បត្តិវប្បធម៌ ដ៏ល្អមួយនេះផងដែរ។ ជាមួយគ្នានេះ លោកក៏បានថ្លែងអំណរគុណចំពោះអាជ្ញាធរជាតិអប្សរា ដែលបានព្រមព្រៀងអនុញ្ញាតឲ្យក្រុមហ៊ុនរបស់លោកប្រើប្រាស់នូវរូបភាពនៃប្រាសាទដ៏ល្អឯកនេះ។

ឯកឧត្តម សុខ សង្ហារ អគ្គនាយករង និងជាតំណាងឯកឧត្តមអគ្គនាយកអាជ្ញាធរជាតិអប្សរា ដែលបានអញ្ជើញចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះបានបញ្ជាក់ថា អាជ្ញាធរជាតិអប្សរា ពិតជាអរគុណ និងកោតសរសើរចំពោះក្រុមហ៊ុនសាមសុង ដែលបានបំពេញតួនាទីជាគំរូយ៉ាងល្អ តាមកិច្ចព្រមព្រៀងក្នុងការប្រើប្រាស់រូបភាពប្រាសាទអង្គរវត្តលើផលិតផលរបស់ខ្លួន។ អាជ្ញាធរជាតិអប្សរា នឹងទទួលយកកញ្ចប់ថវិកានេះ ដើម្បីប្រើប្រាស់សម្រាប់បម្រើការងារអភិរក្សនិងអភិវឌ្ឍន៍រមណីយដ្ឋានអង្គរឲ្យបានល្អប្រសើរថែមទៀត៕





ពិធីចុះហត្ថលេខានេះ ត្រូវបានអញ្ជើញជាអធិបតីដោយ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងលោកជំទាវ Gao Yan អនុរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មចិន

ផ្សាយនៅថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ២០១៨

ថ្ងៃអង្គារ ៧កើត ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ២០១៨នេះ នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ **ឯកឧត្តមបណ្ឌិត ស៊ុំ ម៉ាប់** អគ្គនាយកអាជ្ញាធរជាតិអប្សរា និង **លោក លី អាន** ប្រធានការិយាល័យប្រឹក្សាផ្នែកសេដ្ឋកិច្ច និងពាណិជ្ជកម្ម នៃស្ថានទូតសាធារណៈរដ្ឋប្រជាមានិតចិនប្រចាំនៅ ព្រះរាជាណាចក្រកម្ពុជា បានចុះហត្ថលេខាស្តីពីកិច្ចព្រមព្រៀងសម្រាប់ការអនុវត្តគម្រោង ជួសជុលព្រះបរមរាជវាំង នៅអង្គរ-ខេត្តសៀមរាប។



អាជ្ញាធរជាតិអប្សរាបំភ្លឺនៅបណ្តាញសង្គមអំពីអក្សរបរទេសនៅលើថ្មប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ២០១៨

ថ្មីៗនេះ គេហទំព័រមួយឈ្មោះសារព័ត៌មានក្រមា បានចុះផ្សាយថា «អ្នកលេងហ្វេសបុកវិះគន់អាជ្ញាធរអប្សរា ដែលមិនមើលជនជាតិចិនសរសេរអក្សរចិននៅក្នុងបរិវេណប្រាសាទអង្គរវត្ត» កាលពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៨។

អត្ថបទនេះបានលើកយកមតិរបស់អ្នកប្រើប្រាស់បណ្តាញសង្គមមួយចំនួនបានប្រើនូវពាក្យអសុរោះ ប្រមាថមើលងាយ និងផ្តល់ភាពអយុត្តិធម៌ហាក់គ្មានការយល់ដឹងច្បាស់លាស់ពីអ្វីដែលកើតឡើងពីមុនមក ជាពិសេសលើកិច្ចខិតខំប្រឹងប្រែងរបស់សមត្ថកិច្ចគ្រប់ជំនាញក្នុងការថែរក្សាបេតិកភណ្ឌក្នុងតំបន់អង្គរ។

ទាក់ទងនឹងការលើកឡើងខាងលើនេះ វាមិនមែនជារឿងថ្មីទេ ព្រោះអាជ្ញាធរជាតិអប្សរាធ្លាប់បានធ្វើលិខិតបំភ្លឺម្តងរួចមកហើយ ដែលចុះផ្សាយកាលពីថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៤ បានគូសបញ្ជាក់ថា៖ អក្សរបរទេសដែលមានចារលើថ្មជញ្ជាំងឬសរសេរនៅអង្គរវត្តនោះ ត្រូវបានក្រុមសិក្សាស្រាវជ្រាវសិលាចារឹកនៃអាជ្ញាធរជាតិអប្សរា ចុះបញ្ជីនិងសិក្សាតាំងពីឆ្នាំ២០០២មកម្ល៉េះ។ ភាសាបរទេសដែលបានសរសេរនិងចារលើថ្មប្រាសាទអង្គរវត្ត មានដូចជា ជប៉ុន ចិន ភូមា សៀម បារាំង និងវៀតណាមជាដើម។ អក្សរប្រភេទនេះអ្នកស្រាវជ្រាវចាត់ទុថាជា Graffiti តាមនិយាមអន្តរជាតិ ដែលមិនមែនជាប្រភេទសិលាចារឹកគំនូរឬចម្លាក់ទេ។

តាមការសិក្សារបស់ក្រុមសិលាចារឹកបានផ្តល់ព័ត៌មានថា ក្នុងចំណោមអក្សរជាភាសាបរទេសទាំងអស់បានសរសេរលើថ្មប្រាសាទ គឺភាសាជប៉ុនមានអាយុកាលចាស់ជាងគេ សរសេរនៅដើមសតវត្សទី១៧។ រីឯភាសាផ្សេងៗទៀត សរសេរនៅចុងសតវត្សទី១៩ដើមសតវត្សទី២០ និងមុនឆ្នាំ១៩៤៩។

ភាសាវៀតណាម ដែលប្រទះនៅទីនេះមានពីរសម័យកាលគឺនៅដើមសតវត្សទី២០និងនៅមុនឆ្នាំ១៩៤៩។ បើយើងសរុបន័យសេចក្តីចំណារនិងការសរសេរលើថ្មដូចពោលមកពីខាងលើនោះ ក៏មាននិយាយអំពីអ្នកស្វែងបុណ្យមកពីជប៉ុន ភូមា សៀម និងវៀតណាមមកសំពះបូជនីយដ្ឋានអង្គរវត្ត ជាទឹកដីរបស់ព្រះដែលគេឯងតែងមកគោរពបូជា។

អង្គរវត្តកសាងឡើងកាលពីដើមសតវត្សទី១២ឧទ្ទិសដល់ព្រហ្មញ្ញសាសនានិកាយព្រះនារាយណ៍។ តែចាប់ពីក្រោយសម័យអង្គរមក អង្គរវត្តបានក្លាយជាបូជនីយដ្ឋានព្រះពុទ្ធសាសនា មិនត្រឹមតែចំពោះខ្មែរប៉ុណ្ណោះទេ តែចំពោះពុទ្ធសាសនិកជនទូទាំងអាស៊ីភាគអាគ្នេយ៍ទាំងមូល ដែលមានកស្តុតាងជាសំណេរនិងចំណារលើថ្មនៃជនជាតិទាំងនោះស្រាប់។

ទន្ទឹមនឹងនេះក៏មានជាឈ្មោះមនុស្សនៃជនជាតិនានាច្រើនជាតិសាសន៍មកទស្សនាមុនទសវត្ស១៩៩០ បានសរសេរឬចារទុកសម្គាល់ថា ខ្លួនបានមកដល់អង្គរវត្តទីឋានដ៏ខ្ពង់ខ្ពស់លើលោក។ ក្រោយមកគឺគ្មានចំណារលើសាច់ថ្មដូចមុនទៀតទេ តែអាចមានសំណេរលួចលាក់ដែលសរសេរដោយធ្យូង ដីស ទឹកថ្នាំលុប ពណ៌សឬពណ៌ផ្សេងៗមួយចំនួនតូចនៅតាមកន្លែងស្ងាត់ផុតពីភ្នែកឆ្មាំប្រាសាទ។ បច្ចុប្បន្ននេះ ដោយយោងតាមច្បាប់ស្តីពីការការពារបេតិកភណ្ឌ អាជ្ញាធរជាតិអប្សរាមិនអនុញ្ញាតឱ្យមានការសរសេរឬចារលើសាច់ថ្មនៅតាមជញ្ជាំងឬសសរប្រាសាទទៀតឡើយ។

នៅដើមទសវត្ស១៩៩០ឆ្នាំប្រាសាទនៃអភិរក្សដ្ឋានអង្គរបានព្យាយាមកោសលុបអក្សរចំណារទាំងនោះខ្លះដែរ។ ប៉ុន្តែការប្រឹងនេះមិនសូវបានផល ហើយបានធ្វើឱ្យបាត់ជានប្រវត្តិសាស្ត្ររបស់អង្គរ។ អ្នកស្រាវជ្រាវបរទេសមួយចំនួនដែល

ស្រាវជ្រាវពីអង្គរ តែងតែនិយាយក្នុងសៀវភៅផ្សព្វផ្សាយរបស់ខ្លួនថា អង្គរត្រូវបានគេបោះបង់ចោលក្លាយជាព្រៃស្មសាន ព្រៃស្វា ខ្លាដំរី ទើបតែស្រាវជ្រាវឃើញដោយជនបរទេសទាំងនោះ នាចុងសតវត្សទី១៩។

ដូច្នេះអ្វីដែលបាននិយាយខាងលើ គឺជាភស្តុតាងប្រាកដប្រជាបង្ហាញឱ្យឃើញថាគ្មានពេលណាមួយដែលអង្គរក្លាយជាព្រៃស្មសាន ព្រៃខ្លាដំរី ពោលគឺមានមនុស្សរស់នៅថែទាំរៀងរហូត គ្រាន់តែថយចំនួនដោយសារការប្តូររាជធានីទៅកាន់ទីតាំងផ្សេង៕



សេចក្តីជូនដំណឹង
ចំពោះ
អក្សរអនុសាសន៍នៅលើផ្ទាំងប្រាសាទអង្គរវត្ត

ថ្មីៗនេះ នៅតាមបណ្តាញសង្គមមួយចំនួន បានលេចឡើងនូវការលើកអក្សរបរទេសចារលើផ្ទាំងប្រាសាទអង្គរវត្ត ដោយយោងប្រកាន់អាជ្ញាធរអប្សរា មិនយកចិត្តទុកដាក់ហាមឃាត់។ ចំពោះការលើកឡើងនេះ អាជ្ញាធរអប្សរាមានសេចក្តីរីករាយ សូមធ្វើការបំភ្លឺជូនសាធារណជនទូទៅ ក្បៀរទេសចរជាតិ និងអន្តរជាតិឲ្យបានជ្រាបថា អក្សរបរទេស ដែលមានចារនៅលើផ្ទាំងប្រាសាទអង្គរវត្តនោះ ត្រូវបានក្រុមសិក្សាស្រាវជ្រាវសិលាចារឹកនៃអាជ្ញាធរអប្សរា ចុះបញ្ជី និងសិក្សាកាំងពីឆ្នាំ២០០៦ មកម្ល៉េះ។ ភាសាបរទេសដែលបានសរសេរ និងចារនៅលើផ្ទាំងប្រាសាទអង្គរវត្តមានដូចជា ៖ ជប៉ុន ចិន ភូមា ស្បៀម បាលី និងអ៊ីតណាមជាដើម។ អក្សរប្រភេទនេះ អ្នកស្រាវជ្រាវចាត់ទុកថាជា Graffiti តាមនិយមអន្តរជាតិ ដែលមិនមែនជាប្រភេទសិលាចារឹក តំនូរ ឬចម្លាក់ទេ។

តាមការសិក្សារបស់ក្រុមសិលាចារឹក បានផ្តល់ព័ត៌មានថា ក្នុងចំណោមអក្សរជាភាសាបរទេសទាំងអស់ បានសរសេរលើផ្ទាំងប្រាសាទ គឺភាសាជប៉ុនមានអាយុកាលចាស់ជាងគេ សរសេរនៅដើមសតវត្សទី១៧។ ចំពោះភាសាឆ្លងៗម៉ៀក សរសេរនៅចុងសតវត្សទី១៨ ដើមសតវត្សទី២០ និងមុនឆ្នាំ១៩៨៩។ ភាសាជៀតណាមដែលប្រទះឃើញនៅទីនេះ មានពីសម័យកាល គឺនៅដើមសតវត្សទី២០ និងនៅមុនឆ្នាំ១៩៨៩។

លើសពីនេះទៅទៀត ការសិក្សាស្រាវជ្រាវនៅតែបន្តទៀត ដើម្បីធ្វើការសង្កេតឲ្យកាន់តែច្បាស់លាស់ និងបានលម្អិតបន្ថែមទៀត។ ការសិក្សាស្រាវជ្រាវនេះ ធ្វើឡើងដោយក្រុមការងារជាតិ និងអន្តរជាតិ ដែលមានបទពិសោធន៍ខ្ពស់ក្នុងការសិក្សាស្រាវជ្រាវលើផ្ទាំងប្រាសាទអង្គរវត្ត។ ការសិក្សាស្រាវជ្រាវនេះ ធ្វើឡើងក្រោមការដឹកនាំរបស់ឯកឧត្តម ង៉ែត ភិរុណ រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាប្រធានក្រុមការងារជាតិ ដើម្បីការពារ អភិរក្ស និងអភិវឌ្ឍតំបន់អង្គរ។

ជាចុងក្រោយ អាជ្ញាធរអប្សរា សូមអំពាវនាវដល់ភ្ញៀវទេសចរជាតិ និងអន្តរជាតិ សូមកុំប៉ះពាល់ ឬធ្វើការខូចខាតដល់ផ្ទាំងប្រាសាទអង្គរវត្ត ដែលជាបេតិកភណ្ឌពិភពលោកដ៏ធំធេងនេះ ដោយសារតែវាជាកេរ្តិ៍ដំណែលដ៏ថ្លៃថ្លារបស់ជាតិយើង ដែលត្រូវការពារ និងថែរក្សាដោយក្តីស្រឡាញ់ និងការគោរពបូជា។

ទន្ទឹមនឹងនេះ កំមានជាឈ្មោះមនុស្សនៃជនជាតិនានាច្រើនជាតិសាសន៍ មកទស្សនាមុនទស វត្សទី១៩០ បានសរសេរ ឬចារទុកសម្គាល់ថាខ្លួនបានមកដល់អង្គរវត្ត ទីហានជំនួសលើលោក។ ក្រោយមក គឺគ្មានចំការលើសាច់ថ្មដូចមុនឡើតទេ តែអាចមានសំណេរលួចលាក់ដែលសរសេរដោយធ្យូង ដីស ទឹកថ្នាំលុបឆ្នាំស ឬពណ៌ផ្សេងៗមួយចំនួនតូច នៅតាមតន្លែងស្ងាតឆ្ងាត់ភ្នែកឆ្នាំប្រាសាទ។ បច្ចុប្បន្ននេះ ដោយយោងតាមច្បាប់ស្តីពីការការពារបេតិកភណ្ឌ អាជ្ញាធរអប្សរាមិនអនុញ្ញាតឲ្យមានការសរសេរ ឬចារលើសាច់ថ្មនៅតាមដំណាំង ឬសសរប្រាសាទទៀតឡើយ។

នៅដើមទសវត្សទី៩៩០ ឆ្នាំប្រាសាទនៃអភិរក្សដ្ឋានអង្គរ បានព្យាយាមកោសលុបអក្សរចំណារទាំងនោះខ្លះ។ ប៉ុន្តែការប្រើរនេះមិនសូវបានផល ហើយបានធ្វើឲ្យបាត់ដានប្រវត្តិសាស្ត្ររបស់អង្គរវត្តផង ពីព្រោះភ័ស្តុតាងទាំងនេះ គឺជាទិន្នន័យសំខាន់សម្រាប់ស្វែងយល់ពីប្រវត្តិសាស្ត្ររបស់អង្គរ។ អ្នកស្រាវជ្រាវបរទេសមួយចំនួន ដែលស្រាវជ្រាវអំពីអង្គរ តែងតែនិយាយក្នុងសៀវភៅផ្សាយរបស់ខ្លួនថា អង្គរត្រូវគេបោះបង់ចោលក្លាយជាព្រៃស្មសាន ព្រៃស្វា ខ្លា ដំរី ទើបតែស្រាវជ្រាវឃើញដោយជនបរទេសទាំងនោះ នាចុងសតវត្សទី១៩។

ដូច្នេះ អ្វីដែលបាននិយាយខាងលើ គឺជាភស្តុតាងប្រាកដប្រជា បង្ហាញឲ្យឃើញថា គ្មានពេលណាមួយ ដែលអង្គរក្លាយជាព្រៃស្មសាន ព្រៃខ្លាដំរីទេ ពោលគឺមានមនុស្សរស់នៅថែទាំជារៀងរហូត គ្រាន់តែថយចំនួន ដោយសារការប្តូររាជធានីទៅកាន់ទីតាំងផ្សេង។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន ក្បៀរទេសចរជាតិ និងអន្តរជាតិណែនាំជ្រាបតាមការគួរ។ អាជ្ញាធរអប្សរា សូមថ្លែងអំណរគុណ ចំពោះការយកចិត្តទុកដាក់របស់បងប្អូនទាំងអស់គ្នា ហើយសូមឲ្យស្ថាវតីស្រឡាញ់លើតិកណ្តាជាតិ នៅតែមានក្នុងស្មារតីខ្ពង់ខ្ពស់ជាដរាប និងសូមចូលរួមជួយថែរក្សាកុំឲ្យមានអ្នកសរសេរ តូចារ ឬចារលើផ្ទាំងប្រាសាទជាបន្តទៅទៀត។

បើសោកអ្នកមានចម្ងល់ផ្សេងៗ សូមទាក់ទងសួរនាំព័ត៌មាន តាមរយៈអ្នកនាំពាក្យអាជ្ញាធរអប្សរា តាមទូរស័ព្ទលេខ ០១៧ ៦៦៩ ០០១។

ស្បៀមរាប, ថ្ងៃទី២៧ ខែ កញ្ញា ឆ្នាំ២០១៨

សេចក្តីជូនដំណឹង ការបង្ហោះ និងដាក់ដំណើរការទម្រង់ថ្មីនៃគេហទំព័រទេសចរណ៍ www.angkor.com.kh

ផ្សាយនៅថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ២០១៨

អាជ្ញាធរជាតិអប្សរា មានកិត្តិយសសូមជំរាបជូន ដំណឹងដល់គ្រប់ក្រសួង មន្ទីរ ស្ថាប័នជាតិ-អន្តរជាតិ និងសាធារណជនទាំងអស់អោយបានជ្រាបថា៖ ក្នុងគោលដៅពង្រឹង ក៏ដូចជាអភិវឌ្ឍសេវាកម្មទេសចរណ៍នៃរមណីយដ្ឋានអង្គរ អាជ្ញាធរជាតិអប្សរាបានសិក្សាបង្កើត និងដាក់ឲ្យដំណើរការសោកល្បងគេហទំព័រទេចរណ៍ www.angkor.com.kh នាអំឡុងខែកុម្ភៈ ឆ្នាំ២០១៧។ តាមរយៈគេហទំព័រនេះ ភ្ញៀវជាតិ និងអន្តរជាតិបានស្វែងយល់ពីរមណីយដ្ឋានអង្គរ បានស៊ីជម្រៅ ទាំងព័ត៌មាន ប្រវត្តិសាស្ត្រ សង្គម និតិវិធីនានា ដែលត្រូវអនុវត្តមុន និងអំឡុងពេលទស្សនា រួមទាំងព័ត៌មានសំខាន់ សំរាប់ទេសចរ ក្នុងការរៀបចំកញ្ចប់ទស្សនកិច្ចមកកាន់អង្គរ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA
លេខ ៥១៤ / ណ.ជ.ស.ស
១៨

សេចក្តីជូនដំណឹង
ស្តីពី
ការបង្ហោះ និងដាក់ដំណើរការចម្រង់ថ្មីនៃគេហទំព័រទេសចរណ៍ www.angkor.com.kh
ចាប់ពីថ្ងៃសុក្រ ២រោច ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
ត្រូវនឹងថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៨

អាជ្ញាធរជាតិអប្សរា មានកិត្តិយសសូមជម្រាបជូនដំណឹងដល់គ្រប់ក្រសួង មន្ទីរ ស្ថាប័នជាតិ-អន្តរជាតិ និងសាធារណជនទាំងអស់ឲ្យបានជ្រាបថា៖ ក្នុងគោលដៅពង្រឹង ក៏ដូចជាអភិវឌ្ឍសេវាកម្មទេសចរណ៍នៃរមណីយដ្ឋានអង្គរ អាជ្ញាធរជាតិអប្សរាបានសិក្សាបង្កើត និងដាក់ឲ្យដំណើរការសាកល្បងគេហទំព័រទេសចរណ៍ **www.angkor.com.kh** នាអំឡុងខែកុម្ភៈ ឆ្នាំ២០១៧។ តាមរយៈគេហទំព័រនេះ ភ្ញៀវទេសចរជាតិ និងអន្តរជាតិបានស្វែងយល់ពីរមណីយដ្ឋានអង្គរបានស៊ីជម្រៅ ទាំងព័ត៌មាន ប្រវត្តិសាស្ត្រ សង្គម នីតិវិធីនានា ដែលត្រូវអនុវត្តមុន និងអំឡុងពេលទស្សនា រួមទាំងព័ត៌មានសំខាន់ៗ សំរាប់ទេសចរ ក្នុងការរៀបចំកញ្ចប់ទស្សនកិច្ចមកកាន់អង្គរ។

យោងលើការតាមដានជាប្រចាំលើប្រសិទ្ធភាព ព្រមទាំងបានប្រមូលផ្តុំ វាយតម្លៃលើមតិយោបល់នានារបស់អ្នកប្រើប្រាស់គ្រប់មជ្ឈដ្ឋានទាំងក្នុង និងក្រៅប្រទេស ក្រុមការងារអាជ្ញាធរជាតិអប្សរាបានធ្វើបច្ចុប្បន្នភាពគេហទំព័រនេះរួចរាល់ហើយ ដើម្បីអភិវឌ្ឍខ្លួនឲ្យស្របតាមតម្រូវការអ្នកប្រើប្រាស់ និងវឌ្ឍនភាពនៃបច្ចេកវិទ្យានាពេលបច្ចុប្បន្ន។ ដូចនេះអាជ្ញាធរជាតិអប្សរានឹងធ្វើការបង្ហោះ ក៏ដូចជាដាក់ឲ្យប្រើប្រាស់ជាផ្លូវការនូវទម្រង់ថ្មីនៃគេហទំព័រទេសចរណ៍នេះ ចាប់ពីថ្ងៃសុក្រ ២រោច ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៨ តទៅ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី គ្រប់ក្រសួង មន្ទីរ ស្ថាប័នជាតិ-អន្តរជាតិ និងសាធារណជនទាំងអស់ មេត្តាជ្រាប និងចូលរួមគាំទ្រអនុវត្តឲ្យបានគ្រប់ៗគ្នា។

ថ្ងៃព្រហស្បតិ៍ ទី៧ ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
សៀមរាប ថ្ងៃទី ២១ ខែមិថុនា ឆ្នាំ២០១៨
អគ្គនាយក

ស៊ុំ ម៉ាច់

ចម្លងជូន៖
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងទេសចរណ៍
- សាលាខេត្តសៀមរាប
- សាលាក្រុងសៀមរាប
- គ្រប់មន្ទីរជុំវិញខេត្ត
- គ្រឹះស្ថានអង្គរ
- សួងការិយាធិបតេយ្យខេត្តសៀមរាប
- អង្គភាពនគរបាលជាតិភស្តុភារ ប្រចាំខេត្តសៀមរាប
- អង្គភាពនគរបាលទេសចរណ៍ ប្រចាំខេត្តសៀមរាប
- សមាគមទីភ្នាក់ងារទេសចរណ៍-សមាគមសណ្ឋាគារ
- សមាគមមគ្គុទ្ទេសក៍ទេសចរណ៍
- សមាគមអ្នកបើកបរយានយន្តដឹកជញ្ជូនភ្ញៀវទេសចរ
- គ្រប់នាយកដ្ឋានចំណុះអាជ្ញាធរជាតិអប្សរា "ដើម្បីជូនជ្រាប"
- ឯកសារ-កាលប្បវត្តិ

ភ្នំពេញ:
ផ្ទះលេខ៥១ សង្កាត់ទឹកថ្លា ខណ្ឌដូនពេញ
ទូរស័ព្ទ/ទូរសារ: ០២៣ ២១៥ ៨៨១/០២៣ ២១៥ ៨៨៦

អាជ្ញាធរជាតិអប្សរាសាលាដំបូងខាងលិចបង្គោលទឹកបីបង្គោលសួរ
Email: info@apsaraauthority.gov.kh
Website: http://www.apsaraauthority.gov.kh

សៀមរាប:
ភូមិបន្ទាយ ឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប
ទូរស័ព្ទ/ទូរសារ: ០៦៣ ៦៣៤ ៨៨៨/០៦៣ ៦១៤ ៨៨៥

សេចក្តីជូនដំណឹងស្តីពី ការបង្វែរទិសចរាចរណ៍ នៅមុខអង្គរវត្ត ក្នុងពីធីលែងកូនត្រី នៃទិវាមច្ឆាជាតិនៅថ្ងៃទី ០១ ខែកក្កដា ឆ្នាំ២០១៨

ផ្សាយនៅថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ២០១៨

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA

លេខ.៥៣៦/០៨.សជណ
/១៨

សេចក្តីជូនដំណឹង
ស្តីពី
ការបង្វែរទិសចរាចរណ៍ នៅមុខប្រាសាទអង្គរវត្ត ក្នុងពិធីលែងកូនត្រី នៃទិវាមច្ឆាជាតិនៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៨

អាជ្ញាធរជាតិអប្សរា មានកិត្តិយសសូមជម្រាបជូនដំណឹងដល់គ្រប់ក្រសួង អាជ្ញាធរដែនដី ស្ថាប័នជាតិ-អន្តរជាតិ អាជ្ញាធរដែនដី មន្ទីរ-អង្គភាព សមាគមទីភ្នាក់ងារទេសចរណ៍ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ មគ្គុទ្ទេសក៍ទេសចរណ៍ ក្រុមហ៊ុនទេសចរណ៍ សមាគមដឹកជញ្ជូនភ្ញៀវទេសចរ អ្នកដឹកជញ្ជូនភ្ញៀវទេសចរ ភ្ញៀវទេសចរជាតិ-អន្តរជាតិ បងប្អូនអាជីវករ និងសាធារណជនទាំងអស់បានជ្រាបថា៖ ដើម្បីសម្រួលចរាចរណ៍ រក្សាសណ្តាប់ធ្នាប់ និងរបៀបរៀបរយនៅក្នុងពិធីលែងកូនត្រីនៃទិវាមច្ឆាជាតិនៅមុខប្រាសាទអង្គរវត្ត ក្រោមវត្តមានដ៏ខ្ពង់ខ្ពស់ សម្តេចពិជ័យសេនា **ឡេ ឌ្វាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ នាថ្ងៃអាទិត្យ ៤រោច ខែបឋមាសាធ ឆ្នាំច ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី០១ ខែកក្កដា ឆ្នាំ ២០១៨ខាងមុខនេះ អាជ្ញាធរជាតិអប្សរាសូមធ្វើការជូនដំណឹងដូចខាងក្រោម៖

- យានជំនិះដឹកជញ្ជូនភ្ញៀវទេសចរគ្រប់ប្រភេទ សូមដាក់ភ្ញៀវដែលចូលទស្សនាប្រាសាទអង្គរវត្ត នៅទីតាំងបណ្តោះអាសន្នខាងជើងអង្គភាពនគរបាលការពារបេតិកភណ្ឌ(Drop off) រួចបន្តយកយានជំនិះទៅចតនៅចំណតខាងលិចផ្នែកខាងត្បូង ដោយរក្សាទុកចំណតផ្នែកខាងជើងត្រៀមទុកជូនភ្ញៀវដែលមកចូលរួមក្នុងកម្មវិធីលែងកូនត្រីនៃទិវាមច្ឆាជាតិ
- យានជំនិះគ្រប់ប្រភេទដែលមានបំណងទៅកាន់គោលដៅផ្សេងក្រៅពីប្រាសាទអង្គរវត្ត សូមប្រើប្រាស់ផ្លូវ៦០ម រួចបន្តដំណើរទៅគោលដៅរបស់ខ្លួនតាមផ្លូវវង់តូច ឬវង់ធំ
- ចំពោះបងប្អូនអាជីវករលក់ដូរនៅមុខប្រាសាទអង្គរវត្តទាំងអស់ សូមផ្អាកសកម្មភាពលក់ដូរ និងយកសម្ភារៈលក់ដូររបស់ខ្លួនចេញ ចាប់ពីថ្ងៃទី៣០ ខែមិថុនា រហូតដល់ថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៨

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមគ្រប់ក្រសួង ស្ថាប័នជាតិ-អន្តរជាតិ អាជ្ញាធរដែនដី មន្ទីរ-អង្គភាព សមាគមទីភ្នាក់ងារទេសចរណ៍ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ មគ្គុទ្ទេសក៍ទេសចរណ៍ ក្រុមហ៊ុនទេសចរណ៍ សមាគមដឹកជញ្ជូនភ្ញៀវទេសចរ អ្នកដឹកជញ្ជូនភ្ញៀវទេសចរ ភ្ញៀវទេសចរជាតិ អន្តរជាតិ បងប្អូនអាជីវករ និងសាធារណជនទាំងអស់មេត្តាជ្រាប និងចូលរួមសហការអនុវត្តឲ្យបានល្អប្រសើរនៃសេចក្តីជូនដំណឹងនេះ។

បម្លងជូន:
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងទេសចរណ៍
- សាលាខេត្តសៀមរាប
- គ្រប់មន្ទីរជុំវិញខេត្ត
- សាលាក្រុងសៀមរាប
- គ្រប់នាយកដ្ឋាន
- អង្គភាពនគរបាលការពារបេតិកភណ្ឌប្រចាំខេត្តសៀមរាប
- អង្គភាពនគរបាលទេសចរណ៍ប្រចាំខេត្តសៀមរាប
- សមាគមទីភ្នាក់ងារទេសចរណ៍-សមាគមសណ្ឌាគារ
- សមាគមមគ្គុទ្ទេសក៍ទេសចរណ៍
- សមាគមអ្នកបើកបររថយន្តដឹកជញ្ជូនភ្ញៀវទេសចរ
- ឯកសារ-កាលប្បវត្តិ

ថ្ងៃ ពុធ ១៥ កើត ខែបឋមាសាធ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
សៀមរាប ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១៨
អគ្គនាយក

ស៊ុ ម៉ាប់

ភ្ជុំពេញ:
មហាវិថីសហព័ន្ធរុស្ស៊ី លេខ៤១ សង្កាត់ចំត្តភាព ខណ្ឌឈមការ
ទូរសព្ទ/ទូរសារ៖ ០៦៣ ៣១៥ ៥៧៦/០៦៣ ៣១៥ ៥៧៦

អាជ្ញាធរជីម្មីការពាររមណីយដ្ឋានទិងប្រៀបធំតំបន់អង្គរ
Email: info@apsaraauthority.gov.kh
Website: http//www.apsaraauthority.gov.kh

សៀមរាប:
ភូមិបន្ទាង ឃុំអំពិល ស្រុកក្រាសាទបាគង ខេត្តសៀមរាប
ទូរសព្ទ/ទូរសារ៖ ០៦៣ ៧៦៥ ៥៧៧/០៦៣ ៧៦៥ ៥៧៦

សេចក្តីជូនដំណឹងស្តីពី ការកាត់ដកហូតដើមឈើ និងកាត់ក្រឹមកឈើដែលបង្កហានិភ័យខ្ពស់ ស្ថិតនៅក្នុងបរិវេណប្រាសាទបន្ទាយស្រី

ផ្សាយនៅថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ២០១៨



ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA

ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

អាជ្ញាធរអប្សរា
APSARA
N°.ថ៤២០/.នជ.សផគ
១៨

សេចក្តីជូនដំណឹង
ស្តីពី
ការកាត់ដកហូតដើមឈើ និងកាត់ក្រឹមកឈើ
ដែលមានហានិភ័យខ្ពស់ស្ថិតនៅក្នុងបរិវេណប្រាសាទបន្ទាយស្រី

អាជ្ញាធរជាតិអប្សរា សូមជូនដំណឹងដល់ស្ថាប័ន សមត្ថកិច្ចពាក់ព័ន្ធ ភ្ញៀវជាតិ-អន្តរជាតិ មគ្គុទ្ទេសក៍ទេសចរណ៍ ព្រមទាំងសាធារណជនទាំងអស់មេត្តាជ្រាបថា ដើម្បីធានាដល់សុវត្ថិភាពភ្ញៀវទេសចរ សាធារណជន ក៏ដូចជាដើម្បីលើកកម្ពស់សោភ័ណភាពនៅតាមដងផ្លូវ និងនៅតាមបរិវេណប្រាសាទ ក្នុងតំបន់រមណីយដ្ឋានអង្គរ និងតំបន់ដែលគ្រប់គ្រងដោយអាជ្ញាធរជាតិអប្សរា នាំយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាន នៃអាជ្ញាធរជាតិអប្សរា នឹងកាត់ដកហូតដើមឈើ និងកាត់ក្រឹមកឈើចំនួន **០៩ដើម** ដែលមានហានិភ័យខ្ពស់ ស្ថិតនៅក្នុងបរិវេណប្រាសាទបន្ទាយស្រី។

ការងារនេះ នឹងចាប់ផ្តើមអនុវត្តចាប់ពីថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ២០១៨ រហូតដល់បញ្ចប់ការងារ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមស្ថាប័ន សមត្ថកិច្ចពាក់ព័ន្ធ ភ្ញៀវជាតិ-អន្តរជាតិ មគ្គុទ្ទេសក៍ទេសចរណ៍ ព្រមទាំងសាធារណជនទាំងអស់ មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃចន្ទ ១កាត់ខែបឋមគតឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
សៀមរាប, ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ២០១៨
អគ្គនាយក

ចម្លងជូន៖
-សាលាខេត្តសៀមរាប
-មន្ទីរបរិស្ថានខេត្តសៀមរាប
-មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តសៀមរាប
-អង្គភាពនគរបាលការពារបេតិកភណ្ឌប្រចាំខេត្តសៀមរាប
-ស្នាក់ការតំបន់ការពារទេសភាពអង្គរ
-សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ទាំងអស់ប្រចាំខេត្តសៀមរាប
។ដើម្បីជូនជ្រាប និងសហការ។
-ប៉ូលិសទេសចរណ៍
-គ្រប់នាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធរបស់អាជ្ញាធរអប្សរា
។ដើម្បីមុខការ និងសហការ។
-ឯកសារ-កាលប្បវត្តិ

លេខទូរស័ព្ទទំនាក់ទំនង:លោក តង់ សុវណ្ណារិទ្ធ 012-354-630, លោក ខៀន សុធី 010-304-089,088-9522-5059,លោក ហែ ឋាវ 086 600 740

PHNOM PENH :
#41, Russian Blvd.,Sangkat Meatapheap,Khan 7Makara
Tel : (855-23) 215 771
Fax : (855-23) 215 776

អាជ្ញាធរដើម្បីការពារការគ្រប់គ្រងរមណីយដ្ឋានអង្គរ និងតំបន់អនុវត្ត
AUTHORITY FOR THE PROTECTION AND MANAGEMENT OF ANGKOR AND THE REGION OF SIEMREAP
Website : http://www.apsaraauthority.gov.kh
E-mail : info@apsaraauthority.gov.kh

SIEM REAP :
Bang Kong Village, Ampil Commune, Prasat Bakong District, Siem Reap Province
Tel: (855-63) 76 55 77 or (855-63) 76 66 76
Fax: (855-63) 76 55 76

រមណីយដ្ឋានអង្គរនឹងបង្កើនបណ្តាញប្រព័ន្ធទូរសព្ទកាន់តែទូលំទូលាយ

ផ្សាយនៅថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ២០១៨

ជាយូរមកហើយដែលតំបន់អង្គរពុំសូវមានសេវាទូរសព្ទគ្រប់គ្រាន់ ដោយសារតំបន់នេះគ្របដណ្តប់ដោយប្រាសាទ និងព្រៃឈើជាច្រើន។ ក្រុមហ៊ុនទូរសព្ទជាច្រើនធ្លាប់បានស្នើមកអាជ្ញាធរជាតិអប្សរា សុំលើកបង្គោលអង់តែន ក្នុងតំបន់អង្គរ ដើម្បីបង្កើនប្រព័ន្ធសេវារបស់ខ្លួន។

ដោយតម្រូវការបច្ចុប្បន្នលើការប្រើប្រាស់ប្រព័ន្ធអ៊ិនធើណិតកាន់តែខ្លាំង ជាពិសេស ដើម្បីសម្រួលដល់ការទំនាក់ទំនងរបស់ប្រជាពលរដ្ឋ និងភ្ញៀវទេសចរដែលមកទស្សនាតំបន់អង្គរ អាជ្ញាធរជាតិអប្សរា តាមរយៈការពិភាក្សាជាមួយអ្នកជំនាញជាតិ និងអន្តរជាតិ ជាពិសេស ក្រោយឆ្លងយោបល់ជាមួយគណៈកម្មាធិការ ICC-Angkor រួចមក បានអនុញ្ញាតឲ្យមានការសាងសង់បង្គោលសិប្បនិមិត្ត ដែលអាចអនុញ្ញាតឲ្យក្រុមហ៊ុនទូរសព្ទផ្សេងៗ អាចបំពាក់ប្រព័ន្ធសេវាទូរសព្ទរបស់ខ្លួនបាន។

កាលពីឆ្នាំ២០១៦ បង្គោលសិប្បនិមិត្តនេះត្រូវសាងសង់ឡើងចំនួន៦ទីតាំងសំខាន់ៗនៅក្នុងតំបន់អង្គរ និងមានក្រុមហ៊ុនទូរសព្ទចំនួន៤ក្នុងប្រទេសកម្ពុជាបានជួលបំពាក់សេវា។ ប៉ុន្តែ ចំនួនបង្គោលនេះ នៅតែមិនអាចផ្តល់សេវាគ្របដណ្តប់ក្នុងតំបន់អង្គរបានគ្រប់គ្រាន់នៅឡើយ។ នៅក្នុងកិច្ចប្រជុំបច្ចេកទេស ICC-Angkor នាដើមខែមិថុនា ឆ្នាំ២០១៨ កន្លងទៅថ្មីៗនេះ អាជ្ញាធរអប្សរាបានស្នើយោបល់ជូនគណៈកម្មាធិការនេះ ដើម្បីសាងសង់បង្គោលសិប្បនិមិត្តចំនួន១២ទីតាំងបន្ថែមទៀត។

ឯកឧត្តម សុខ សង្ហារ អគ្គនាយករង និងប្រធានក្រុមការងារអន្តរក្រសួងទាក់ទងការរៀបចំដំឡើងអង់តែនក្នុងតំបន់អង្គរ មានប្រសាសន៍ថា ទោះបីជាការងារនេះមានភាពស្មុគស្មាញ ដោយអាជ្ញាធរជាតិអប្សរា ត្រូវធ្វើការជាមួយដៃគូជាតិ និងអន្តរជាតិអស់រយៈពេលយូរក៏ដោយ តែយើងបាន ស្វែងរកឃើញនូវចំណុចរួមគ្នាពាក់ព័ន្ធនឹងបច្ចេកទេស សម្ភារៈ និងមធ្យោបាយជាដើម ដើម្បីរក្សានូវទេសភាពវប្បធម៌នៃតំបន់អង្គរ និងតម្រូវការជាក់ស្តែងនៃការអភិវឌ្ឍដោយចីរភាព។

ឯកឧត្តមបន្ថែមថា នេះជាការងារសំខាន់សម្រាប់អង្គរ ដើម្បីបម្រើការងារអាជ្ញាធរពាក់ព័ន្ធ និងប្រជាពលរដ្ឋក្នុងតំបន់អង្គរ ព្រមទាំងភ្ញៀវទេសចរគ្រប់ជាតិសាសន៍ដែលមកទស្សនាអង្គរ។ ការងារនេះនឹងជួយដល់កិច្ចការប្រចាំថ្ងៃក្នុងការទំនាក់ទំនង និងជួយសម្រួលដល់បញ្ហាសន្តិសុខក្នុងតំបន់អង្គរផងដែរ។

ឆ្លងតាមកិច្ចពិភាក្សាយ៉ាងល្អិតល្អន់រួចមក គណៈកម្មាធិការ ICC-Angkor បានអនុញ្ញាតលើគម្រោងសាងសង់បង្គោលថ្មីនេះ ជាមួយនឹងអនុសាសន៍ណែនាំឲ្យអាជ្ញាធរជាតិអប្សរា ធ្វើកំណាយស្រាវជ្រាវផ្នែកបុរាណវិទ្យា ជាមុននៅគ្រប់ទីតាំងដែលគ្រោងនឹងសាងសង់ ដើម្បីបញ្ចៀសផលប៉ះពាល់ដល់ផ្នែកបុរាណវិទ្យា និងតម្រូវឲ្យចនាបង្គោលនិងពណ៌ ស៊ីគ្នានឹងស្ថានភាពជាក់ស្តែងនៃដើមឈើធម្មជាតិដែលមាននៅទីនោះ ក្នុងន័យថែរក្សានូវទេសភាពវប្បធម៌ដែលមានស្រាប់។

ចំពោះទីតាំងដែលត្រូវដំឡើងអង់តែនដើមឈើសិប្បនិមិត្តទាំង១២កន្លែងស្ថិតនៅទីតាំងនៃតំបន់ការពារទី១ និងតំបន់ការពារទី២នៃរមណីយដ្ឋានអង្គរ ដូចជា នៅភូមិស្រះស្រង់ ភូមិប្រដាក ភូមិគោកស្នួល ជិតចំណតភ្នំបាខែង ភូមិលាងដៃ ភូមិមណ្ឌល៣ ជិតព្រះលានដល់ដំរី ក្បែរព្រលានយន្តហោះ ជិតចំណតនាគព័ន្ធ តាមបណ្តោយផ្លូវជាតិលេខ៦A ភូមិទឹកវិល និងក្បែរប្រាសាទបាយ័ន។ បង្គោលទាំងនេះមានកម្ពស់ចន្លោះពី១៨ម ទៅ៤០ តាមស្ថានភាពជាក់ស្តែង និងមានទ្រង់ទ្រាយដូចដើមឈើនៅក្បែរៗនោះស្រាប់។

បច្ចុប្បន្ន ក្រុមការងារកំពុងពិភាក្សាលម្អិតជាមួយក្រុមហ៊ុនដំឡើងបង្គោល ដើម្បីឈានដល់ការចុះកិច្ចព្រមព្រៀងមួយ ហើយអាចនឹងដំណើរការក្នុងពេលឆាប់ៗខាងមុខនេះ។ ដូច្នេះ មិនយូរទៀតទេ ភ្ញៀវទេសចរនិងប្រជាពលរដ្ឋក្នុងតំបន់អង្គរ នឹងទទួលបានសេវាអ៊ិនធើណិតគ្រប់គ្រាន់ សម្រាប់ប្រើប្រាស់លើប្រព័ន្ធទូរសព្ទ និងតម្រូវការផ្សេងៗទៀត។ នេះជាផ្នែកមួយនៃការអភិវឌ្ឍរមណីយដ្ឋានអង្គរ ដែលផ្តោតលើការផ្តល់ជូននូវសុខដុមភាពដល់ប្រជាពលរដ្ឋនិងភ្ញៀវទេសចរ គ្រប់ជាតិសាសន៍ហើយរក្សាបាននូវតម្លៃអង្គរដោយចីរភាព៕









ពិធីបិទគម្រោងអប់រំបេតិកភណ្ឌសម្រាប់កុមារប្រចាំឆ្នាំ២០១៨នៅបន្ទាយឆ្មារ

ផ្សាយនៅថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០១៨

គម្រោងអប់រំបេតិកភណ្ឌកុមារប្រចាំឆ្នាំ២០១៨ នៅបន្ទាយឆ្មារ បានបិទបញ្ចប់កាលពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៨ ក្រោមអធិបតីភាព **លោកជំទាវ ប៉ុក ណាឌី** អភិបាលរង តំណាងឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ និង **លោក យឹម សារាវិទ្ធិ** អគ្គនាយករងបេតិកភណ្ឌ តំណាងលោកជំទាវរដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ តំណាងអាជ្ញាធរជាតិអប្សរា រួមទាំងមន្ទីរ ស្ថាប័នពាក់ព័ន្ធ លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស សរុបចំនួន២៦០នាក់។

លោក អ៊ុន មុណីនីតា នាយកប្រតិបត្តិនៃអង្គការគាំពារកេរមរតក បានជម្រាបថា៖ ឆ្នាំ២០១៨ គឺជាឆ្នាំទី៤នៃកម្មវិធីអប់រំបេតិកភណ្ឌសម្រាប់កុមារ ដែលមានកុមារចូលរួមសរុបចំនួន១៧០នាក់ ចាប់ពីថ្នាក់ទី៥និងថ្នាក់ទី៦ មានអាយុចន្លោះ

ពី១០ទៅ១៥ឆ្នាំ ហើយកុមារម្នាក់ៗអាចទទួលបានការបណ្តុះបណ្តាលក្នុងកម្មវិធីអប់រំនេះចំនួន២ឆ្នាំ មុននឹងបន្តទៅសិក្សាថ្នាក់អនុវិទ្យាល័យ។ សរុប៤ឆ្នាំមកនេះ កម្មវិធីបានបណ្តុះចំណេះដឹងនិងបណ្តុះគំនិតដល់កុមារបានចំនួន៣៦៥នាក់ឱ្យចេះស្រឡាញ់បេតិកភណ្ឌនិងចូលរួមថែរក្សាមរតកវប្បធម៌ដូនតារបស់ខ្លួនបានយ៉ាងល្អ។

លោក អ៊ឹម សុខរិទ្ធី សមាជិកក្រុមប្រឹក្សាភិបាលអង្គការគាំពារកេរមរតកនិងជាអនុប្រធានក្រុមការងារអប់រំបេតិកភណ្ឌនៅអង្គរនៃអាជ្ញាធរជាតិអប្សរា បានឱ្យដឹងពីគោលបំណងនៃគម្រោង គឺដើម្បីឱ្យកុមារដែលកើតនិងរស់នៅក្នុងតំបន់រមណីយដ្ឋានវប្បធម៌-ប្រវត្តិសាស្ត្រ បានយល់ដឹងនូវកេរមរតកវប្បធ៌មរបស់ខ្លួន ព្រមទាំងបណ្តុះគំនិតកុមារឱ្យជ្រួតជ្រាបពីតម្លៃមរតកវប្បធម៌ឱ្យចេះស្រឡាញ់ ចេះថែរក្សាការពារ។ ជាពិសេស កុមារទាំងនេះអាចធ្វើជាអ្នកស្នងតំណរនៅសហគមន៍របស់ខ្លួនលើវិស័យថែរក្សាការពារនិងគ្រប់គ្រងកេរមរតកវប្បធ៌មនាពេលអនាគត។

លោកបន្តថា មេរៀននិងសកម្មភាពសិក្សា រៀបចំដោយក្រុមគ្រូបង្រៀនដែលបង្រៀននៅមហាវិទ្យាល័យជិត២០ឆ្នាំមកហើយ និងអ្នកស្រាវជ្រាវផ្នែកសង្គមវប្បធម៌ នរវិទ្យា និងបុរាណវិទ្យា។ ការបង្រៀនម្តងៗ ក៏មានអញ្ជើញលោកគ្រូ អ្នកគ្រូចូលរួមស្តាប់ឱ្យបានជ្រួតជ្រាបអំពីមូលដ្ឋានគ្រឹះនៃបេតិកភណ្ឌវប្បធម៌ និងការចូលរួមរបស់សហគមន៍ចំពោះការថែរក្សាការពារបេតិកភណ្ឌវប្បធម៌ជាមុនសិន ដើម្បីឱ្យងាយស្រួលក្នុងការជួយជំរុញកុមារសិក្សាតាមគោលការណ៍ណែនាំ និងតម្រូវការនៃកម្មវិធីនេះ។

ចំពោះការអប់រំបេតិកភណ្ឌ គឺមានទាំងក្នុងថ្នាក់ ទាំងក្រៅថ្នាក់ ដោយបញ្ជូនកុមារឱ្យចុះសិក្សាតាមរមណីយដ្ឋាននានាក្នុងតំបន់ និងនៅសារមន្ទីរខេត្តបន្ទាយមានជ័យ ព្រមទាំងឱ្យកុមាររៀនអានសៀវភៅនិទានសម្រាប់កុមារដូចជា៖ រឿង "មនុស្ស និងផ្នូរបុរាណ" និងរឿង "រាចាថ្ម" ដែលជាប្រភេទរឿងនិទានទាក់ទងការរួមគ្នារបស់សហគមន៍ជួយគ្នាថែរក្សាការពារ ទប់ស្កាត់ការបំផ្លិចបំផ្លាញ ការជីកកកាយ និងការជួញដូរវត្ថុបុរាណ ព្រមទាំងឱ្យកុមារចេះគូរគំនូរ និងផាត់ពណ៌ជាដើម។

ការអប់រំនេះ ក៏ជំរុញឱ្យកុមារយល់ពីទម្រង់ផ្សេងៗគ្នានៃបេតិកភណ្ឌទាំងមរតករូបី និងមរតកអរូបី យល់ពីតម្លៃ និងសារៈសំខាន់ៗនៃបេតិកភណ្ឌវប្បធម៌ ឱ្យកុមារចេះពិចារណាលើបញ្ហាទាក់ទងនឹងការជីកកកាយ ការលួចវត្ថុបុរាណ ការបំផ្លិចបំផ្លាញទីតាំងបុរាណដ្ឋាន ឬការឈូសឆាយទីទួលបុរាណធ្វើស្រែចំការ ឬភាពមិនអើពើរបស់សហគមន៍ចំពោះស្ថានីយ៏វប្បធ៌ម-ប្រវត្តិសាស្ត្រ ព្រមទាំងឱ្យកុមារចេះលើកឡើងនូវការថែរក្សាការពារដើម្បីទុកជាផលប្រយោជន៍រួមក្នុងសហគមន៍និងអាចទទួលបានចំណូលជាប្រចាំតាមរយៈវិស័យទេសចរណ៍វប្បធម៌នាពេលអនាគត។

សូមបញ្ជាក់ថា កម្មវិធីនេះកើតឡើងបានដោយមានការអនុញ្ញាតនិងការជួយជ្រោមជ្រែងគាំទ្រយ៉ាងសកម្មពីសាលាខេត្តបន្ទាយមានជ័យ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ មន្ទីរអប់រំខេត្ត គម្រោងអប់រំបេតិកភណ្ឌសម្រាប់កុមារដែលផ្ទួចផ្តើមឡើងដោយអង្គការគាំពារកេរមរតក (Heritage Watch) និងក្រុមស្រាវជ្រាវផ្លូវបុរាណរបស់អាជ្ញាធរជាតិអប្សរា បានចាប់ផ្តើមអនុវត្តគម្រោង នៅសាលាបឋមសិក្សាបន្ទាយឆ្មារ ឃុំបន្ទាយឆ្មារ ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ចាប់ពីឆ្នាំ២០១៥។

ពិសេសជាងឆ្នាំមុន ឆ្នាំនេះក៏មានសប្បុរសជនខ្មែរនៃក្រុមយុវជននៅសៀមរាប (ភ្នាក់ងារឯកជន) មានៈ ជាងបាក់វណ្ណហុងថេមផលគ្រុប ម៉ែម៉រនិងស្ប៉ា បានជួយឧបត្ថម្ភជាជំនួយសម្ភារៈសិក្សា រៀបចំអាហារទទួលសម្រាប់កម្មវិធីបិទនេះ ផ្តល់កាបូបស្ពាយចំនួន២០ដល់សិស្សវិទ្យាល័យ និងកង់ចំនួន១០ដល់សិស្សបឋមសិក្សាដែលខ្វះខាតនិងរៀនពូកែ។ នេះជាសញ្ញាវិជ្ជមានខ្លាំង ដែលខ្មែរចាប់ផ្តើមជួយខ្មែរលើវិស័យអប់រំនិងការពារបេតិកភណ្ឌ ហើយជាទីគួរឱ្យមានមោទនៈខ្លាំងដែលក្រុមយុវជននេះក៏បាននិងកំពុងរួមចំណែកដល់ការងារអប់រំបេតិកភណ្ឌនៅអង្គរផងដែរ។






ឆមាសទី១នៃឆ្នាំ២០១៨ អាជ្ញាធរជាតិអប្សរាចានអនុញ្ញាតការជួសជុលសំណង់ស្រាលចំនួន៦២៤ ករណី

ផ្សាយនៅថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០១៨

ក្រុមការងារសហគមន៍របស់អាជ្ញាធរជាតិអប្សរាបានប្រជុំបូកសរុបរបាយការណ៍ក្នុងឆមាសទី១ នៃឆ្នាំ២០១៨ ដោយមានការអនុញ្ញាតសំណង់ស្រាលចំនួន៦២៤ករណី ជូនប្រជាសហគមន៍ក្នុងតំបន់រមណីយដ្ឋានអង្គរ ក្រោមអធិបតីភាព **ឯកឧត្តម ស៊ុំ ម៉ាប់** អគ្គនាយកអាជ្ញាធរជាតិអប្សរា នៅសាលបេងមាលា នៃអាជ្ញាធរជាតុអប្សរា នៅព្រឹកថ្ងៃអង្គារ៍ ទី២៥ ខែ មិថុនាឆ្នាំ២០១៨កន្លងទៅនេះ។

យោងតាមរបាយការណ៍របស់ក្រុមការងារសហគមន៍បានលើកឡើងថា ក្រុមការងារសហគមន៍ទាំង៥ ក្រុង/ស្រុក ក្នុងនោះមានក្រុងសៀមរាប ស្រុកបន្ទាយស្រី ស្រុកប្រាសាទបាគង ស្រុកពួក ស្រុកអង្គរធំ បានចុះទៅដល់ខ្នងផ្ទះរបស់ប្រជាពលរដ្ឋ ព្រមទាំងបានអនុញ្ញាតប្រភេទសំណង់ស្រាល តាមការស្នើសុំរបស់ពួកគាត់មកអាជ្ញាធរជាតិអប្សរា ដែលប្រភេទសំណង់ទាំងនោះគឺមាន តង់ប៉ាប ដូរសសរផ្ទះ ដូរដេញ្ជាំងផ្ទះ ដូរដំបូលផ្ទះ ធ្វើបង្គន់ ធ្វើរបងផ្ទះ។ល។

ឯកឧត្តម ស៊ុំ ម៉ាប់ អគ្គនាយកបានលើកឡើងថា ការងារសហគមន៍ជារឿងចាំបាច់ដែលអាជ្ញាធរជាតិអប្សរាត្រូវតែធ្វើ និងចុះជួបប្រជាពលរដ្ឋតាមខ្នងផ្ទះ និងតាមគោលដៅរៀងៗខ្លួន ដើម្បីបង្កើនការយកចិត្តទុកដាក់ខ្ពស់ក្នុងការដោះស្រាយ និងសម្របសម្រួលជូនប្រជាពលរដ្ឋនៅក្នុងតំបន់រមណីយដ្ឋានអង្គរ ព្រោះវាទាក់ទងនឹងជីវភាព ជាពិសេសគឺសុខទុក្ខរបស់ពួកគាត់ជាចាំបាច់។

ឯកឧត្តមអគ្គនាយក បានបន្តថា ដើម្បីឱ្យការងារសហគមន៍ កាន់តែមានប្រសិទ្ធភាពខ្ពស់ សូមក្រុមការងារសហគមន៍នីមួយៗ បង្កើនការយកចិត្តទុកដាក់បន្ថែមទៀត ក្នុងការងារចុះតាមមូលដ្ឋាន ដើម្បីជួបប្រជាពលរដ្ឋបន្តដោះស្រាយបញ្ហាប្រឈមរបស់ពួកគាត់ដែលនូវសេសសល់ឱ្យដាច់ស្រេច៕






ចាប់ពីឆ្នាំ២០០០មក ការចារជួសជុលប្រាសាទក្នុងតំបន់រលួសមានការខិតក្តីម្ល៉ះ?

ផ្សាយនៅថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ២០១៨

តំបន់រលួសត្រូវបានគេស្គាល់ថា ជាអតីតរាជធានីដើមសម័យអង្គរ។ តំបន់នេះមានប្រាសាទចម្បងៗមួយចំនួន ដូចជា ប្រាសាទលលៃ ប្រាសាទព្រះគោ និងប្រាសាទបាគង។ មិនខុសពីប្រាសាទដ៏ទៃប្រាសាទក្នុងតំបន់នេះរងការខូចខាតជាច្រើនដែលទាមទារឱ្យមានការជួសជុលឱ្យបានទាន់ពេលវេលា។

លោក តាន់ សុផលអនុប្រធាននាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យាន និងបុរាណវិទ្យាបង្ការ នៃអាជ្ញាធរជាតិអប្សរា និងជាអ្នកជំនាញជាតិមួយរូប ដែលបានចូលរួមជួសជុលប្រាសាទក្នុងតំបន់រលួសចាប់ពីឆ្នាំ២០០០មកទល់នឹងបច្ចុប្បន្ន បានរៀបរាប់នៅក្នុងកិច្ចប្រជុំបច្ចេកទេសលើកទី៣០ អាយស៊ីស៊ី-អង្គរ កាលពីដើមខែ មិថុនា ឆ្នាំ២០១៨ថា៖ ប្រាសាទក្នុងតំបន់រលួសដែលទទួលបានការជួសជុលមានដូចជា ប្រាសាទលលៃ ប្រាសាទព្រះគោ និងប្រាសាទបាគង។ លោកបន្ថែមថា ការជួសជុលទាំងនោះភាគច្រើនជាការជួសជុលប្រាសាទឥដ្ឋ ដោយមានទាំងការទល់ទ្រ និងការជួសជុលផ្នែករចនាសម្ព័ន្ធ ក្នុងគោលបំណងដើម្បីទប់ស្កាត់ការខូតខាតតទៅមុខទៀត។

១.ការជួសជុលប្រាសាទលលៃ

ការជួសជុលប្រាសាទលលៃគឺចាប់ពីឆ្នាំ២០០០មក ដោយផ្តើមពីកាងារតូច រហូតដល់ការងារធំ។ នៅទីនោះអ្នកជំនាញការខ្មែរបានរៀបចំទល់ទ្រ និងជួសជុលរចនាសម្ពន្ធប្រាសាទឥដ្ឋ។ តួប្រាង្គចំនួន២ ដែលទទួលបានការជួសជុលបាន ជាង ៥០ភាគរយ ដូចជាប្រាង្គនៅជ្រុងពាយ័ព្យមួយ និងនៅជ្រុងឦសានមួយ ហើយក្រុមការងាររំពឹងថា គម្រោងនេះនឹងអាចបញ្ចប់នៅក្នុងឆ្នាំ២០១៨នេះ។

២.ការជួសជុលប្រាសាទព្រះគោ

ការជួសជុលប្រាសាទព្រះគោ ចាប់ផ្តើមពីឆ្នាំ២០០១មក ដោយបានជួសជុលតួប្រាង្គកណ្តាល ដែលជាប្រាង្គធំជាងគេ រួចរាល់ជាស្ថាពរនៅឆ្នាំ២០០៩។ ចំណែកប្រាង្គនៅជុំវិញទាំង៥ទៀត ក៏ទទួលបានការជួសជុលផ្នែកខ្លះដែរ ដូចជាសសរពេជ្រ និងសសរផ្តោប ហើយនៅឆ្នាំ២០១៦-២០១៧ ការជួសជុលបណ្ណាល័យនៅប្រាសាទព្រះគោ ក៏ត្រូវបានរួចរាល់ជាស្ថាពរ។

៣.ការជួសជុលប្រាសាទបាគង

ប្រាសាទបាគងដូចទៅនឹងប្រាសាទផ្សេងទៀតដែរក្នុងតំបន់រលួស គឺប្រាសាទភាគច្រើនសង់ពីដីឥដ្ឋ។ ការងារជួសជុលនៅប្រាសាទនេះ គឺបានជួសជុលប្រាង្គធំនៅជ្រុងពាយ័ព្យ ដែលជាកិច្ចសហការរវាងអាជ្ញាធរជាតិអប្សរា និងអង្គការអាឡឺម៉ង់ GACP ដែលបានបញ្ចប់នៅដើមឆ្នាំ២០១៨។ បច្ចុប្បន្ន គម្រោងកំពុងបន្តជួសជុលប្រាង្គលេខ៨ ដែលជាប្រាសាទឥដ្ឋ ហើយនេះជាការងារមួយដ៏ធំសម្រាប់អាជ្ញាធរជាតិអប្សរា ដែលត្រូវការទាំងពេលវេលា និងថវិកា ដោយសារនៅទីតាំងនោះមានផ្តៃធំមួយបានធ្លាក់នៅឆ្នាំ២០១០។ បច្ចុប្បន្នផ្តៃនោះបានជួសជុលរួចរាល់ ហើយយើងនឹងរៀបចំឱ្យមានឡើងវិញ។

បើតាមអ្នកជំនាញការងារជួសជុលប្រាសាទ **លោក តាន់ សុផល** ការជួសជុលប្រាសាទក្នុងតំបន់រលួស មានជួបបញ្ហាមួយចំនួនផងដែរ។ លោកបញ្ជាក់ថា អ្នកបច្ចេកទេស ត្រូវគិតគូរឱ្យបានល្អិតល្អន់លើផ្នែកអ្វីមួយ ដូចជារចនាសម្ពន្ធ គឺការជួសជុលត្រូវគោរពទៅតាមទម្រង់ដើម ទាំងសោភណ្ឌភាព និងភាពរឹងមាំ គឺត្រូវបញ្ចូលធាតុផ្សំទាំងនេះតែមួយ ទើបការងារជួសជុលទទួលបានជោគជ័យនិងមានភាពយូរអង្វែង៕









សេចក្តីប្រកាសព័ត៌មានស្តីពីការធប់ស្តាត់សំណង់ខុសច្បាប់ក្នុងមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ២០១៨

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរអប្សរា
APSARA
លេខ.៥៤៤/ប.ស.ហ
២៨

សេចក្តីប្រកាសព័ត៌មាន
ស្តីពីការធប់ស្តាត់សំណង់ខុសច្បាប់ក្នុងមណីយដ្ឋានអង្គរ

ស្របតាមជំពូក១ មាត្រា៤ នៃព្រះរាជក្រឹត្យលេខ ០០១ន.ស ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៤ ស្តីពីការកំណត់និងការចាត់ចែងគ្រប់គ្រងតំបន់សៀមរាប-អង្គរ ប្រការ១ និងប្រការ២ នៃសេចក្តីសម្រេចលេខ៧០ សសរ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០៤ ស្តីពីការកំណត់បទដ្ឋាននៃការប្រើប្រាស់ដីធ្លីនៅតំបន់១និងតំបន់២ ក្នុងតំបន់មណីយដ្ឋានសៀមរាបអង្គរ ហាមឃាត់លើសកម្មភាពទិញ-លក់ដីរបស់ឈ្មួញក្នុងគោលដៅធ្វើអាជីវកម្ម យកចំណេញសម្រាប់ក្រុមហ៊ុន ឬបុគ្គល ឬការទិញ-លក់សម្រាប់យកទៅសាងសង់សណ្ឋាគារ ភោជនីយដ្ឋាន ខាវ៉ាអូខេជាដើម។ល។ អាជ្ញាធរជាតិអប្សរា មានកិត្តិយសសូមជម្រាបព័ត៌មានដល់សាធារណជនទាំងអស់ឱ្យ បានជ្រាបដូចខាងក្រោម៖

១. ពុំមានការអនុញ្ញាតឲ្យមានការសាងសង់ដោយសេរីនៅក្នុងតំបន់ការពារបេតិកភណ្ឌនោះទេ។ រាល់សំណង់ខុសច្បាប់ ការលួចសាងសង់គ្មានការអនុញ្ញាតនឹងត្រូវបានរុះរើចេញដោយគ្មានលក្ខខណ្ឌ។
២. បុគ្គលទាំងឡាយណាដែលឃោសនា និងប្រព្រឹត្តអំពើបោកប្រាស់ តាមរយៈការធានាឲ្យមានការសាងសង់ខុសច្បាប់ និងការទទួលយកប្រាក់កាស ដើម្បីជាថ្នូរនឹងការសាងសង់ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន។
៣. សូមសាធារណជនចូលរួមសហការតាមរយៈការផ្តល់ ឬសាកសួរព័ត៌មានផ្សេងៗទាក់ទងរាល់ការសាងសង់នានាក្នុងតំបន់ការពារមណីយដ្ឋានអង្គរ មកកាន់លេខទូរស័ព្ទ ០៩២ ៨៩ ៩៩ ៦៦/ ០១២ ៨៥ ០២ ២៦/ ០១២ ៣២ ៥៤ ១៩ ឬលេខទូរស័ព្ទថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរាដែលបានប្រកាសតាមគេហទំព័រផ្លូវការរបស់អាជ្ញាធរជាតិអប្សរា *www.apsaraauthority.gov.kh* ឬទំព័រ Facebook *អាជ្ញាធរជាតិអប្សរា Apsara Authority*។

អាជ្ញាធរជាតិអប្សរាសង្ឃឹមយ៉ាងមុតមាំនិងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះការចូលរួមចំណែករបស់សាធារណជនទាំងអស់ក្នុងកិច្ចការអភិរក្ស និងការពារតម្លៃដ៏ថ្លៃថ្លានៃមណីយដ្ឋានអង្គរដែលជាបេតិកភណ្ឌពិភពលោក និងជាអត្តសញ្ញាណជាតិ។

ថ្ងៃព្រហស្បតិ៍ ១៤រោច ខែបំបមាសាស ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២
សៀមរាប ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ២០១៨

ទូរស្ព្ទ
ទូរសារ ៦៦៣ ៧៦៥ ៧៧៧/៦៦៣ ៦៦៥ ៧៧៦

Email: info@apsaraauthority.gov.kh
Website: http://www.apsaraauthority.gov.kh

ព្រឹត្តិការណ៍ព័ត៌មាន
ប្រចាំខែកក្កដា

ផ្នែកទី ៧
ប្រចាំខែកក្កដា

អាជ្ញាធរជាតិអប្សរាបើកវគ្គបណ្តុះបណ្តាលស្តីពី កិច្ចការពារ និងគ្រប់គ្រងរមណីយដ្ឋានអង្គរ បេតិកភណ្ឌពិភពលោកដល់មន្ត្រី-បុគ្គលិកចំនួន១០០នាក់

ផ្សាយនៅថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ២០១៨

នៅព្រឹកថ្ងៃទី២ ខែកក្កដា ឆ្នាំ២០១៨ នាសាលសន្និសីទ អង្គរ នៃអាជ្ញាធរជាតិអប្សរា បានបើកវគ្គបណ្តុះបណ្តាលពី កិច្ចការពារ និងគ្រប់គ្រងរមណីយដ្ឋានអង្គរ បេតិកភណ្ឌពិភពលោក។ វគ្គបណ្តុះបណ្តាលនេះមានរយៈពេល៥ថ្ងៃ ចាប់ពី ថ្ងៃទី២-៦ ខែកក្កដា ឆ្នាំ២០១៨ រៀបចំឡើងក្នុងគោលបំណងបង្កើនចំណេះដឹងបន្ថែមនិងឱ្យមន្ត្រីបុគ្គលិកពាក់ព័ន្ធយល់ដឹង កាន់តែស៊ីជម្រៅអំពីការងារអភិរក្ស និងអភិវឌ្ឍន៍ ក្នុងតំបន់ការពារបេតិកភណ្ឌ«អង្គរ» ឱ្យកាន់តែទូលំទូលាយបន្ថែមទៀត។

វាគ្មិននៃវគ្គបណ្តុះបណ្តាលខាងលើមាន **លោកបណ្ឌិតអ៊ា ជារិទ្ធ លោក អ៊ឹម សុខរិទ្ធី** អនុប្រធានមជ្ឈមណ្ឌលអន្តរជាតិ ស្រាវជ្រាវ និងតម្កល់ឯកសារអង្គរ បានធ្វើបទបង្ហាញដល់សិក្ខាកាមនូវអារ្យធម៌បុរេប្រវត្តិសាស្ត្រ ប្រវត្តិសាស្ត្រពិភពលោក ទូទៅ និងសង្ខេបប្រវត្តិសាស្ត្រខ្មែរ តាំងពីសម័យបុរេប្រវត្តិសាស្ត្រ សម័យមុនអង្គរ សម័យអង្គរ ដែលជាអតីតរាជធានី និងជា អាណាចក្រខ្មែរ នាសម័យអង្គរ។

វគ្គបណ្តុះបណ្តាលនេះផ្តោតសំខាន់ទៅលើប្រវត្តិសាស្ត្រ អារ្យធម៌ និងបេតិកភណ្ឌ។ លើសពីនេះគឺគោលការណ៍អភិរក្ស តំបន់រមណីយដ្ឋានអង្គរបេតិកភណ្ឌពិភពលោក ការគ្រប់គ្រងបេតិកភណ្ឌវប្បធម៌ និងអនុសញ្ញាបេតិកភណ្ឌពិភពលោក បង្ហាញដល់សិក្ខាកាមផងដែរ មុននឹងលើកឡើងអំពីអាជ្ញាធរជាតិអប្សរា និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ទាក់ទងអំពី ការគ្រប់គ្រងមន្ត្រី-បុគ្គលិក។

ម្យ៉ាងទៀតខិតខំធ្វើយ៉ាងណាគ្រប់គ្រងប្រព័ន្ធផ្លូវទឹកបុរាណក្នុងឧទ្យានអង្គរ ការគ្រប់គ្រងនិងអភិវឌ្ឍន៍ទេសចរណ៍ ប្រកបដោយចីរភាព។ ការគ្រប់គ្រងសំណង់លំនៅដ្ឋានខ្មែរក្នុងតំបន់អង្គរ និងគ្រប់គ្រងលំនៅដ្ឋានខ្មែរ ដែលជាកិច្ចការដ៏មាន សារៈសំខាន់ រួមនិងការអភិរក្ស និងអភិវឌ្ឍន៍បេតិកភណ្ឌក្រុងសៀមរាប អង្គរ និងការអភិវឌ្ឍន៍សហគមន៍ក្នុងតំបន់អង្គរ។

គួរបញ្ជាក់ថា សិក្ខាកាមដែលចូលរួមវគ្គបណ្តុះបណ្តាលនេះ គឺជាមន្ត្រី បុគ្គលិកមកពីនាយកដ្ឋានផ្សេងៗរួមមាន នាយកដ្ឋានផ្សព្វផ្សាយ៦នាក់ នាយកដ្ឋានអភិវឌ្ឍន៍វប្បធម៌ សារមន្ទីរ និងបទដ្ឋានបេតិកភណ្ឌ ៧នាក់ នាយកដ្ឋានអភិវឌ្ឍន៍ ទេសចរណ៍អង្គរ ១២នាក់ នាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាន ៥នាក់ នាយកដ្ឋានសណ្តាប់ធ្នាប់ និងសហប្រតិបត្តិការ ១០នាក់ មជ្ឈមណ្ឌលអន្តរជាតិស្រាវជ្រាវ និងតម្កល់ឯកសារអង្គរ ៥នាក់ លេខាធិការដ្ឋានសហគមន៍ ៥នាក់ មជ្ឈមណ្ឌលបណ្តុះបណ្តាលអង្គរ ២នាក់ គម្រោងអភិវឌ្ឍន៍ភូមិធម្មជាតិរុនតាឯក ៣នាក់ នាយកដ្ឋានអភិវឌ្ឍន៍ បេតិកភណ្ឌក្នុងក្រុងតំបន់សៀមរាប៣នាក់ នាយកដ្ឋានគណៈកម្មការអន្តរក្រសួងបន្តដោះស្រាយគោលនយោបាយដីធ្លីបុរី វប្បធម៌ ទេសចរណ៍២នាក់ នាយកដ្ឋានទ្រទ្រង់បច្ចេកទេស និងគម្រោងអន្តរវិស័យ៣នាក់ នាយកដ្ឋានរៀបចំដែនដី និង គ្រប់គ្រងលំនៅដ្ឋានក្នុងឧទ្យានអង្គរ១០នាក់ នាយកដ្ឋានអភិវឌ្ឍន៍កសិកម្ម និងសហគមន៍៤នាក់ នាយកដ្ឋានគ្រប់គ្រង់ទឹក ៥នាក់ នាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យាន និងបុរាណវិទ្យាបង្គារ៥នាក់ នាយកដ្ឋានអភិរក្សប្រាសាទក្រៅឧទ្យានអង្គរ ៦នាក់ នាយកដ្ឋានរដ្ឋបាល បុគ្គលិក និងសម្ភារៈ៣នាក់ អង្គភាពគ្រប់គ្រង់បរិស្ថាន "EMS"២នាក់ និងក្រុមការងារអធិការ កិច្ច២នាក់ សរុបចំនួន១០០នាក់៕






ក្រុមការងារសហគមន៍ប្រចាំស្រុកអង្គរជំជួយសង់ផ្ទះ និងបុកអណ្តូង២ជល់ពលរដ្ឋក្រីក្រ

ផ្សាយនៅថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ២០១៨

ក្រុមលេខាធិការដ្ឋានសហគមន៍ប្រចាំស្រុកអង្គរធំ ដែលដឹកនាំដោយអគ្គនាយករងអាជ្ញាធរជាតិអប្សរា **ឯកឧត្តម ហង់ ពៅ** កាលពីសប្តាហ៍កន្លងទៅ បានចុះជួយធ្វើផ្ទះរបស់ប្រជាពលរដ្ឋមួយខ្នង និងបានបុកអណ្តូងទឹកចំនួន២ ដល់ពលរដ្ឋដែលមានជីវភាពខ្វះខាត។

ក្នុងអំឡុងពេលចុះសួរសុខទុក្ខប្រជាពលរដ្ឋក្នុងឃុំពាក់ស្នែង ស្រុកអង្គរធំ ឯកឧត្តមអគ្គនាយករង បានជួបប្រជាពលរដ្ឋដែលមានជីវភាពខ្វះខាត ហើយបានជួយជាសម្ភារមួយចំនួនដល់ពួកគេក្នុងការសង់ផ្ទះ ដូចជាសសរ ដែកគោល រួមនិងថវិកាមួយចំនួន។ ក្រៅពីនេះ តបតាមសំណូមពររបស់ប្រជាពលរដ្ឋចំនួន២គ្រួសារ ក្នុងឃុំគោលដៅខាងលើ ឯកឧត្តមប្រធានក្រុមការងារសហគមន៍ ក៏បានជួយបុកអណ្តូងទឹកចំនួន២ផងដែរ សម្រាប់ការប្រើប្រាស់ប្រចាំថ្ងៃ។

គួររឲ្យកថា ក្នុងខែ មិថុនា ឆ្នាំ២០១៨នេះ ក្រុមលេខាធិការដ្ឋានសហគមន៍របស់អាជ្ញាធរជាតិអប្សរា បានចុះពិនិត្យ អនុញ្ញាតសាងសង់ និងជួសជុលតូចតាចចំនួន ២៤៣ករណី ក្នុងនោះបានអនុញ្ញាតចំនួន ១៣៥ករណី។ ក្នុងចំណោម ១៣៥ ករណីនោះ រួមមាន ស្រុកប្រាសាទបាគង ១៥ករណី ស្រុកអង្គរធំ ៨ករណី ស្រុកពួក ១៨ករណី ក្រុងសៀមរាប ៩០ករណី និងស្រុកបន្ទាយស្រី ៨ករណី។






អ្នកឃុំដូនកែវនឹងទទួលបានស្ពានបេតុងថ្មីជាចំណងដៃពីអាជ្ញាធរជាតិអប្សរា

ផ្សាយនៅថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ២០១៨

ដោយមើលឃើញពីទុក្ខលំបាកក្នុងការធ្វើដំណើររបស់ប្រជាជនក្នុងឃុំដូនកែវ ស្រុកពួក ដែលត្រូវធ្វើដំណើរកាត់ស្ពានចាស់ទ្រុឌទ្រោម ឆ្លងមកក្រុងសៀមរាប អាជ្ញាធរជាតិអប្សរា បានស្ថាបនាស្ពានបេតុងថ្មី ដើម្បីជាប្រយោជន៍ដល់អ្នកឃុំដូនកែវទាំងមូល។ ស្ពានបេតុងថ្មីនេះ នឹងសម្រួលដល់ការធ្វើដំណើររបស់ប្រជាពលរដ្ឋក្នុងឃុំដូនកែវ ទាំងរដូវប្រាំង និងវស្សា។

អស់ជាច្រើនឆ្នាំមកហើយ ដែលអ្នកឃុំដូនកែវ បានប្រើប្រាស់ស្ពានឈើមួយកន្លែង ដែលឆ្លងកាត់អូរដំរីស្លាប់ កាត់តាមផ្លូវលើខ្នងបារាយណ៍ខាងលិច មកកាន់ក្រុងសៀមរាប។ ស្ពានឈើមានសភាពទ្រុឌទ្រោម ហើយការធ្វើដំណើរមិនអំណោយផលទេក្នុងរដូវវស្សា ដោយសារទឹកជន់លិចខ្លាំង និងពេលខ្លះលិចភូមិដែលនៅជាប់នោះផង។

លោក រ៉ែម វិចិត្រ បុគ្គលិកបច្ចេកទេសនាយកដ្ឋានគ្រប់គ្រងទឹកនៃអាជ្ញាធរជាតិអប្សរា បានឱ្យដឹងថា ស្ពានបេតុងថ្មីនេះ គឺភ្ជាប់ពីឃុំដូនកែវ ទៅក្រុងសៀមរាប។ លោកបន្ថែមថា ស្ពានចាស់មានទំហំតូច ហើយការធ្វើដំណើរក្នុងរដូវវស្សាមានភាពលំបាក និងអាចគ្រោះថ្នាក់បើនៅបន្តប្រើប្រាស់ជាបន្តទៀត។

ក្នុងពេលចុះពិនិត្យការដ្ឋានសាងសង់នៅថ្ងៃទី១៣ ខែកក្កដា **លោក វិចិត្រ** ពន្យល់ថា ស្ពានបេតុងថ្មីនេះគឺឆ្លងកាត់ប្រឡាយរំដោះទឹកជំនន់ពីក្រុងអង្គរ ក្រុងសៀមរាប ទៅស្ទឹងពួក និងស្ទឹងព្រះស្រុក។ ដោយសារស្ពានតូច ធ្វើឱ្យមាត់ប្រឡាយរួមតូចដូច្នេះពេលភ្លៀងខ្លាំងមានជំនន់ទឹកភ្លៀង តែងជន់លិចភូមិក្បែរៗនោះជានិច្ច។ ការស្ថាបនាស្ពានថ្មីនេះ អាជ្ញាធរជាតិអប្សរាបានស្ពារ និងពង្រីកមាត់ប្រឡាយ ដើម្បីសម្រួលចរន្តទឹក និងអាចរំដោះទឹកបានលឿនជាងពេលមុនៗ។

ស្ពានបេតុងថ្មីខាងលើចាប់ផ្តើមសាងសង់នៅចុងខែ មិថុនា ឆ្នាំ២០១៨ ដោយគ្រោងនឹងបញ្ចប់នៅរយៈពេល៣ខែបន្ទាប់។ ស្ពាននេះមានប្រវែង ២៤ម៉ែត្រ និងទទឹង ៣,៥ម៉ែត្រ៕









សេចក្តីជូនដំណឹងស្តីពីការរៀបចំចរាចរឯកទិសនៅផ្លូវខាងក្រោយប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ២០១៨

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
A P S A R A
លេខ.ឃ.ត.ជ/អប-សជណ
១៨

សេចក្តីជូនដំណឹង
ស្តីពី
ការរៀបចំចរាចរឯកទិសនៅផ្លូវខាងក្រោយប្រាសាទអង្គរវត្ត

អាជ្ញាធរជាតិអប្សរាមានកិត្តិយស សូមជូនដំណឹងដល់អ្នកបើកបរយានយន្តគ្រប់ប្រភេទ សមត្ថកិច្ចពាក់ព័ន្ធ និងសាធារណជនទាំងអស់មេត្តាជ្រាបថា រយៈកាលកន្លងមក ការធ្វើចរាចរនៅតាមផ្លូវខាងក្រោយប្រាសាទអង្គរវត្តមានការកកស្ទះខ្លាំង ដែលនាំឲ្យប៉ះពាល់សណ្តាប់ធ្នាប់ សុវត្ថិភាព និងប៉ះពាល់ដល់ការទស្សនារបស់ភ្ញៀវទេសចរជាតិ និងអន្តរជាតិ ដែលមកទស្សនាតំបន់អង្គរជារៀងរាល់ថ្ងៃ។

ដើម្បីដោះស្រាយបញ្ហានេះ អាជ្ញាធរជាតិអប្សរា បានសហការជាមួយនគរបាលចរាចរណ៍ និងសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីរៀបចំចរាចរតាមផ្លូវក្រោយប្រាសាទអង្គរវត្ត ដោយលើកស្លាកសញ្ញាចរាចរកំណត់ជាផ្លូវឯកទិសដូចខាងក្រោម ៖

១. ផ្លូវខាងត្បូងស្របនឹងកសិន្ទុអង្គរវត្ត ត្រូវប្រើប្រាស់សម្រាប់តែការបើកបរចូល
២. ផ្លូវខាងកើតកែងនឹងកសិន្ទុអង្គរវត្ត ត្រូវប្រើប្រាស់សម្រាប់តែការបើកបរចេញ
(សូមមើលគំនូសផែនទីដែលមានភ្ជាប់មកជាមួយ)។
ការរៀបចំចរាចរនេះនឹងចាប់អនុវត្តពីថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៨តទៅ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមអ្នកបើកបរយានយន្តគ្រប់ប្រភេទ សមត្ថកិច្ចពាក់ព័ន្ធ និងសាធារណជនទាំងអស់មេត្តាជ្រាប និងចូលរួមសហការអនុវត្តតាមស្លាកសញ្ញាចរាចរឲ្យបានល្អប្រសើរ។

ថ្ងៃ ក្រ ១កើត ខែ ជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២
សៀមរាម, ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ២០១៨
អគ្គនាយក

ហាច់ ពៅ

ចម្លងជូន:
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងទេសចរណ៍
- សាលាខេត្តសៀមរាប
- គ្រប់មន្ទីរជុំវិញខេត្ត
- គ្រឹះស្ថានអង្គរ
- ស្នងការដ្ឋាននគរបាលខេត្តសៀមរាប
- អង្គភាពនគរបាលការពារបេតិកភណ្ឌ ប្រចាំខេត្តសៀមរាប
- អង្គភាពនគរបាលទេសចរណ៍ ប្រចាំខេត្តសៀមរាប
- សមាគមទីភ្នាក់ងារទេសចរណ៍
- សមាគមសណ្ឋាគារ
- សមាគមមគ្គុទ្ទេសក៍ទេសចរណ៍
- សមាគមអ្នកបើកបរថយន្តដឹកជញ្ជូនភ្ញៀវទេសចរ
- គ្រប់នាយកដ្ឋានចំណុះអាជ្ញាធរអប្សរា
- ដើម្បីជូនជ្រាប -
- ឯកសារ-កាលប្បវត្តិ

ភ្នំពេញ: អាជ្ញាធរជាតិអប្សរាសម្រាប់ការងារសម្រួលនិងរៀបចំតំបន់អង្គរ សៀមរាប:
មហាវិថីសហព័ន្ធរុស្សី លេខ៤១ សង្កាត់មិត្តភាព ខណ្ឌឫស្សីកែវ Email: info@apsaraauthority.gov.kh ភូមិបងគួង ឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប
ទូរស័ព្ទ/ទូរសារ: ០២៣ ២១៥ ៧៨១/០២៣ ២១៥ ៧៨៦ Website: http://www.apsaraauthority.gov.kh ទូរស័ព្ទ/ទូរសារ: ០៦៣ ៧៦៥ ៤៧៧/០៦៣ ៧៦៥ ៤៧៦

អាជ្ញាធរជាតិអប្សរានិងទីស័យឯកជនរួមក្តាំកូនឈើជាង២០០០ដើមនៅបរិវេណ ខាងកើតខ្លោងទ្វារប្រាសាទតាព្រហ្ម

ផ្សាយនៅថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ២០១៨

អាជ្ញាធរជាតិអប្សរាសហការជាមួយសមាគមធនធានមនុស្សខេត្តសៀមរាប និងសមាគមទេសចរណ៍ខេត្តសៀមរាប បានបង្កើតកម្មវិធីដាំដើមឈើប្រភេទកម្រចំនួនជាង២០០០ដើម នៅតំបន់បរិវេណខ្លោងទ្វារខាងកើតប្រាសាទតាព្រហ្ម កាលពីថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៨ ដែលមានសមាជិកជាង៥០សណ្ឋាគារ និងក្រុមហ៊ុនបម្រើឱ្យវិស័យទេសចរណ៍ចូលរួម។ រីឯចំនួនអ្នកចូលរួមដាំមានប្រមាណជាង២០០០នាក់ ថែមទាំងមានអ្នកផ្តល់ឧបត្ថមកម្មវិធី ៧ក្រុមហ៊ុនផងដែរ។

លោក យិត សូរ៉ាត ប្រធានគ្រប់គ្រងផ្នែកកាត់ក្រឹឈើរបស់នាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាននៃអាជ្ញាធរជាតិអប្សរា បានឱ្យដឹងថា កូនឈើដែលយកមកដាំសរុបទាំងអស់ចំនួន២១៧០ដើម មាន៖ នាងនួន១៥០៤ដើម បេង២៧៥ដើម និងក្រញូង៣៩១ ជាប្រភេទកម្រនិងមិនសូវសម្បូរក្នុងតំបន់អង្គរ។ កូនឈើទាំងអស់នឹងរស់គ្រប់ដើម ព្រោះមជ្ឈដ្ឋានជុំវិញមិនមានការបំផ្លាញ ហើយប្រហែលជា៧ទៅ១០ឆ្នាំ ព្រៃពូជនេះនឹងលូតលាស់ល្អបំផុត ក្រោមការថែទាំពីបុគ្គលិកព្រៃឈើក្នុងឧទ្យានអង្គរពេលដាំរួច។ ដូច្នេះហើយ ក្រុមការងារព្រៃឈើក្រៅពីមានតួនាទីទ្រទ្រង់ប្រាសាទហើយ គឺយកចិត្តទុកដាក់ខ្លាំងលើការការពារបរិស្ថានជុំវិញប្រាសាទ។

លោក ហ្វីលិព កៅ ប្រធានក្លឹបប្រតិបត្តិករទេសចរណ៍សៀមរាប)STC) បានលើកឡើងថា នេះជាលើកទី១ដែល STC បានប្រមូលប្រតិបត្តិករទេសចរណ៍ជាង៣០ស្ថាប័នដោយមានអ្នកចូលរួមជាង២០០០នាក់ ចូលរួមដាំកូនឈើនាងនួននិងកូនឈើដទៃទៀតដើម្បីផ្សព្វផ្សាយទីក្រុងសៀមរាបឱ្យក្លាយជាតំបន់ទេសចរណ៍ប្រកបដោយនិរន្តរ៍ភាព ដើម្បីរួមចំណែកទាំងថែរក្សាបរិស្ថាន ការទ្រទ្រង់ប្រាសាទ ទាក់ទាញទេសចរ ដែលប្រតិបត្តិករទេសចរណ៍ទាំងអស់គួរធ្វើដើម្បីសងទៅអង្គរវិញ។

លោក អ៊ឹម សុខវិទ្ធី អនុប្រធានមជ្ឈមណ្ឌលអន្តរជាតិស្រាវជ្រាវនិងតម្កល់ឯកសារអង្គរបានឱ្យដឹងពីគោលបំណងនៃការរៀបចំកម្មវិធីដាំកូនឈើនេះថា អាជ្ញាធរជាតិអប្សរាតែប្រារព្ធពិធីដាំដើមឈើជារៀងរាល់ឆ្នាំ តែនេះជាករណីពិសេសដែលអាជ្ញាធរជាតិអប្សរា សហការជាមួយភ្នាក់ងារឯកជនជាច្រើន រួមទាំងយុវជនឱ្យចូលរួមចំណែកថែរក្សាបរិស្ថាន អភិរក្សពូជឈើដែលជិតផុតពូជ ដើម្បីតបស្នងទៅអង្គរវិញ ព្រោះពួកគាត់អាស្រ័យផលនឹងអង្គរ។ លើសពីនោះទៀត កម្មវិធីនេះជាការចំណែកមួយនៃការបម្រើឱ្យការអប់រំបេតិកភណ្ឌតាមរយៈការបណ្តុះបណ្តាលសិស្សនៅវិទ្យាល័យនៅស្រុះស្រួងឱ្យពួកគេចេះស្រឡាញ់ ថែរក្សា ស្រាវជ្រាវមរតកបេតិកភណ្ឌក្នុងតំបន់ឱ្យបានប្រសើរបន្តពីមនុស្សចាស់។

លោក ខាន់ សារ៉ែន តំណាងសណ្ឋាគារឡាក់គីអង្គរ ដែលបានចូលរួមក្នុងទិវាដាំកូនឈើនេះ បានសម្តែងនូវការចាប់អារម្មណ៍ថា វាការសង្គមដែលយើងត្រូវចូលរួមទាំងអស់គ្នាដាំដើមឈើ ព្រោះវាបានទាំងការពារបរិស្ថានផង ជាការចែករំលែកគំរូល្អដល់សង្គមផង និងជួយលើកតម្លៃទេសចរណ៍ផង៕


អាជ្ញាធរជាតិអប្សរា
www.apsaraauthority.gov.kh


អាជ្ញាធរជាតិអប្សរា
www.apsaraauthority.gov.kh


អាជ្ញាធរជាតិអប្សរា
www.apsaraauthority.gov.kh



សេចក្តីជូនដំណឹងស្តីពីការកាត់ដកហូតដើមឈើ និងកាត់ក្រឹមកឈើ ដែលមានហានិភ័យខ្ពស់ នៅតាមបរិវេណប្រាសាទ ក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ២០១៨

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA
លេខ ៦០១/រប.អជណ
១៨

សេចក្តីជូនដំណឹង
ស្តីពី
ការកាត់ដកហូតដើមឈើ និងកាត់ក្រឹមកឈើ
ដែលមានហានិភ័យខ្ពស់នៅតាមបរិវេណប្រាសាទ ក្នុងរមណីយដ្ឋានអង្គរ

អាជ្ញាធរជាតិអប្សរា សូមជូនដំណឹងដល់ស្ថាប័ន សមត្ថកិច្ចពាក់ព័ន្ធ ភ្ញៀវជាតិ-អន្តរជាតិ មគ្គុទ្ទេសក៍ទេសចរណ៍ ព្រមទាំងសាធារណជនទាំងអស់មេត្តាជ្រាបថា ដើម្បីធានាដល់សុវត្ថិភាពភ្ញៀវទេសចរ សាធារណជន ក៏ដូចជាដើម្បីលើកកម្ពស់សោភ័ណភាពនៅតាមដងផ្លូវ និងនៅតាមបរិវេណប្រាសាទ ក្នុងតំបន់រមណីយដ្ឋានអង្គរ និងតំបន់ដែលគ្រប់គ្រងដោយអាជ្ញាធរជាតិអប្សរា នាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាន នៃអាជ្ញាធរជាតិអប្សរា នឹងកាត់ដកហូតដើមឈើ និងកាត់ក្រឹមកឈើ តាមទីតាំងនានាដូចខាងក្រោម៖

-កាត់ដកហូតដើមចំបក់០១ដើម ដែលមានហានិភ័យខ្ពស់ ស្ថិតនៅត្រង់ចំណុចផ្លូវឡើងទៅសំណង់ទ្វារទឹកចេញនៃបារាយ៍ខាងលិច។

-កាត់ដកហូត និងកាត់ក្រឹមកឈើចំនួន ១៣ដើម ដែលមានហានិភ័យខ្ពស់ ស្ថិតនៅបរិវេណព្រះវិហារ ៧ល្វែង។

-កាត់ដកហូត និងកាត់ក្រឹមកឈើចំនួន ០៥ដើម ដែលមានហានិភ័យខ្ពស់ ស្ថិតនៅក្នុងបរិវេណសាលាអនុវិទ្យាល័យបាគងម៉ូតវ៉ានី។

ការងារនេះ នឹងចាប់ផ្តើមអនុវត្តចាប់ពីថ្ងៃទី ១១ ខែកក្កដា ឆ្នាំ២០១៨ រហូតដល់បញ្ចប់ការងារ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមស្ថាប័ន សមត្ថកិច្ចពាក់ព័ន្ធ ភ្ញៀវជាតិ-អន្តរជាតិ មគ្គុទ្ទេសក៍ទេសចរណ៍ ព្រមទាំងសាធារណជនទាំងអស់ មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃ សៅរ៍ ៨ កើត ខែបុស្សសាស្ត្រ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
សៀមរាប, ថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ២០១៨
អគ្គនាយក

ស៊ឹ ម៉ាប់

ចម្លងជូន៖
-សាលាខេត្តសៀមរាប
-មន្ទីរបរិស្ថានខេត្តសៀមរាប
-មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តសៀមរាប
-អង្គភាពនគរបាលការពារបេតិកភណ្ឌប្រចាំខេត្តសៀមរាប
-ស្នាក់ការតំបន់ការពារទេសភាពអង្គរ
-សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ទាំងអស់ប្រចាំខេត្តសៀមរាប
។ដើម្បីជូនជ្រាប និងសហការ។
-ប៉ូលីសទេសចរណ៍
-គ្រប់នាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធរបស់អាជ្ញាធរអប្សរា
។ដើម្បីមុខការ និងសហការ។
-ឯកសារ-កាលប្បវត្តិ

លេខទូរស័ព្ទមន្ត្រីទំនាក់ទំនង៖លោក គង់ សុវណ្ណារិទ្ធ 012-354-630, លោក ឌៀន សុធី 010-304-089,088-9522-5059,លោក ហែ ហ៊ីត 086 600 740

ភ្នំពេញ៖ មហាវិថីសហព័ន្ធរុស្ស៊ី លេខ៤១ សង្កាត់មិត្តភាព ខណ្ឌឫស្សីកែវ ទូរស័ព្ទ/ទូរសារ៖ ០២៣ ២១៥ ៧៧១/០២៣ ២១៥ ៧៧៦
អាជ្ញាធរជាតិអប្សរាសម្រាប់ការពារ គ្រប់គ្រង និងអភិវឌ្ឍតំបន់អង្គរ Email: info@apsaraauthority.gov.kh Website: http//www.apsaraauthority.gov.kh
សៀមរាប៖ ភូមិបង្គួរ ឃុំស្វាយដង្គំ ស្រុកប្រាសាទបាគង ខេត្តសៀមរាប ទូរស័ព្ទ/ទូរសារ៖ ០៦៣ ៦៦៥ ៤៧៧/០៦៣ ៦៦៥ ៤៧៦

អាជ្ញាធរជាតិអប្សរាអនុញ្ញាតឆ្លាប់ជួសជុលសំណង់ប្រភេទស្រាលចំនួន ១០៦១ ករណីក្នុងតំបន់រមណីយដ្ឋានអង្គរ ឆ្នាំ២០១៧ និងឆមាសទី១នៃឆ្នាំ២០១៨

ផ្សាយនៅថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ២០១៨

ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាបាន និងកំពុងបំពេញការងារយ៉ាងសស្រាក់សស្រាំក្នុងការចុះផ្សព្វផ្សាយអំពីគោលការណ៍ថែរក្សាបេតិកភណ្ឌ បទដ្ឋានគតិយុត្តិផ្សេងៗស្តីពីការសាងសង់ ការប្រើប្រាស់ដីធ្លីក្នុងតំបន់រមណីយដ្ឋានអង្គរ និងដោះស្រាយរាល់ទុក្ខលំបាករបស់ប្រជាពលរដ្ឋដែលរស់នៅក្នុងរមណីយដ្ឋានអង្គរ។

យោងតាមរបាយការណ៍របស់ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាបានលើកថា ឆ្នាំ២០១៧ ប្រភេទសំណង់ដែលត្រូវបានអនុញ្ញាតរួមមានការតសំយោបផ្ទះ ការជួសជុលជញ្ជាំង ជណ្តើរ ដំបូលផ្ទះ ការប្តូរសសរ ការសង់ទ្រុងមាន់ ទា ជ្រូក គ្រោលគោ ជង្រុកស្រូវ បង្គន់អនាម័យ ចំនួន ៤៧៥ ករណី និងឆមាសទី១ នៃឆ្នាំ២០១៨ បានចំនួន៥៨៦ ករណី។

ទន្ទឹមគ្នានឹងការអនុញ្ញាតការជួសជុលសំណង់ប្រភេទស្រាល ក្នុងឆ្នាំ២០១៧ ក្រុមការងារសហគមន៍ក៏បាននាំយកនូវកញ្ចប់ទ្រទ្រង់សុខុមាលភាពម្តាយ និងទារក (ឃីត) ចែកជូនបងប្អូនស្ត្រីអ្នកស្រុកអង្គរ ដែលទើបតែសម្រាលកូនរួចថ្មីៗ ចំនួន៦០៥កញ្ចប់ ក្នុងក្រុង/ស្រុកចំនួន ៥ គឺក្រុងសៀមរាបចំនួន ៩១ កញ្ចប់ ស្រុកប្រាសាទបាគងចំនួន ៩៦ កញ្ចប់ ស្រុកអង្គរធំចំនួន ៦៩ កញ្ចប់ ស្រុកបន្ទាយស្រីចំនួន១៤០កញ្ចប់ផងដែរ។

ក្នុងនោះដែរ ដើម្បីចូលរួមលើកកម្ពស់ជីវភាពអ្នកស្រុកអង្គរ អាជ្ញាធរជាតិអប្សរាបានកសាងហេដ្ឋារចនាម្ព័ន្ធរូបវន្តជាច្រើនតាមមូលដ្ឋានដូចជា ផ្លូវថ្នល់ ការស្ថាបប្រព័ន្ធធារាសាស្ត្រសម្រាប់ការបង្កបង្កើនផលកសិកម្ម ផ្តល់ពូជកសិកម្ម វប្បកម្ម សិប្បកម្ម ផ្តល់បច្ចេកទេសកសិកម្ម ឧបត្ថម្ភថវិកាមនុស្សធម៌ដល់គ្រួសារជួបទុក្ខលំបាកព្រោះគ្រោះទុរភិក្ស ខ្សល់កន្ត្រាក់ ភ្លើងឆេះផ្ទះ ឧបត្ថម្ភគាំទ្រវិស័យសាសនា ឧបត្ថម្ភសំលៀកបំពាក់ឯកសណ្ឋានប្រជាការពារភូមិ ថែរក្សាបរិស្ថាន ដាំដើមឈើ ដើម្បីជាការលើកកម្ពស់ទេសភាពវប្បធម៌ និងការជួសជុលថែរក្សាអភិរក្សប្រាសាទនានានៅក្នុងតំបន់រមណីយដ្ឋានអង្គរ ។









ឯកឧត្តម ហាច់ ពៅ ចុះសួរសុខទុក្ខដឹងគ្រឹះរំឭកមន្ត្រី-បុគ្គលិកក្រៅឧទ្យានអង្គរឱ្យបំពេញកាតព្វកិច្ចជាពលរដ្ឋឱ្យបានគ្រប់ក្លាណៅថ្ងៃចោះឆ្លោតខាងមុខ!

ផ្សាយនៅថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ២០១៨

រយៈពេល៤ថ្ងៃ ចាប់ពីថ្ងៃទី១៧ ដល់ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៨ **ឯកឧត្តម ហាច់ ពៅ** អគ្គនាយករងទទួលបន្ទុកនាយកដ្ឋានអភិរក្សប្រាសាទក្រៅឧទ្យានអង្គរនៃអាជ្ញាធរជាតិអប្សរា បានចុះជួបសំណេះសំណាលនិងទទួលទានអាហារសាមគ្គីជាមួយមន្ត្រី-បុគ្គលិក ភ្នាក់ងារអភិរក្សប្រាសាទនិងពលករក្រៅឧទ្យានអង្គរចំនួន១៥៥នាក់ ដែលមកពីទីតាំងផ្សេងៗគ្នាដូចជា នៅអភិរក្សដ្ឋានភ្នំគូលែន ចំនួន៥៤នាក់ នៅប្រាសាទបេងមាលា ស្ពានទ័ពជ័យ និងស្ពានព្រះទិស សរុបចំនួន៥១នាក់ ប្រាសាទចៅស្រីវិបុល វត្តចេតិយ បន្ទាយអំពិល ក្បាលស្ពាន និងបន្ទាយខ្យង សរុបចំនួន៥០នាក់។

ឯកឧត្តមបានលើកឡើងថា បងប្អូនដែលឈរជើងនៅតាមទីតាំងក្រៅឧទ្យានអង្គរ គឺមានតួនាទីសំខាន់ណាស់ក្នុងការមើលការខុសត្រូវដោយផ្ទាល់នៅតាមគោលដៅរៀងៗខ្លួន បញ្ចៀសបានយ៉ាងល្អនូវរាល់ការអន្តរាយផ្សេងៗដែលកើតឡើងដោយថាហេតុបណ្តាលឱ្យប៉ះពាល់ដល់ប្រាសាទ និងសោភណ្ឌភាពនៃប្រាសាទជាដើម។

ឯកឧត្តមបានថ្លែងអំណរគុណដល់មន្ត្រី-បុគ្គលិក ភ្នាក់ងារ និងពលករទាំងអស់ដែលបានខិតខំបំពេញការងារយ៉ាងល្អ និងសូមកោតសរសើររាល់ស្នាដៃថៃរក្សា ធ្វើយ៉ាងណាឱ្យកិច្ចការអភិរក្សមណីយដ្ឋានអង្គរមានចីរភាព និងកាន់តែលេចធ្លោជាសាកល សក្តិសមជារមណីយដ្ឋានប្រវត្តិសាស្ត្រដែលមានឈ្មោះល្បីល្បាញ។

ក្នុងឱកាសនោះដែរ ឯកឧត្តមក៏មិនភ្លេចរំឭកដល់មន្ត្រី-បុគ្គលិក ភ្នាក់ងារអភិរក្សប្រាសាទ និងពលករទាំងអស់ដែលមានឈ្មោះបោះឆ្នោត ត្រូវត្រៀមខ្លួនទៅបោះឆ្នោតឱ្យបានគ្រប់គ្នាដើម្បីបំពេញកាតព្វកិច្ចជាពលរដ្ឋដែលមានសិទ្ធិជ្រើសរើសថ្នាក់ដឹកនាំដែលខ្លួនពេញចិត្តនៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៨ កុំបីខកខាន៕









សេចក្តីជូនដំណឹងស្តីពីការកាត់ជកហូតដើមឈើ និងកាត់ក្រឹមែកឈើដែលមានហានិភ័យខ្ពស់នៅតាមបរិវេណប្រាសាទ ក្នុងមណីដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ២០១៨



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA
លេខ.. ៦៣៥ ..ប.ស.ណ
/ ១៨

សេចក្តីជូនដំណឹង
ស្តីពី
ការកាត់ជកហូតដើមឈើ និងកាត់ក្រឹមែកឈើ
ដែលមានហានិភ័យខ្ពស់នៅតាមបរិវេណប្រាសាទ ក្នុងមណីយដ្ឋានអង្គរ

អាជ្ញាធរជាតិអប្សរា សូមជូនដំណឹងដល់ស្ថាប័ន សមត្ថកិច្ចពាក់ព័ន្ធ ភ្ញៀវជាតិ-អន្តរជាតិ មត្តុទ្ទេសក៍ទេសចរណ៍ ព្រមទាំងសាធារណជនទាំងអស់មេត្តាជ្រាបថា ដើម្បីធានាដល់សុវត្ថិភាពភ្ញៀវទេសចរ សាធារណជនក៏ដូចជាដើម្បីលើកកម្ពស់សោភ័ណភាពនៅតាមដងផ្លូវ និងនៅតាមបរិវេណប្រាសាទ ក្នុងតំបន់រមណីយដ្ឋានអង្គរ និងតំបន់ដែលគ្រប់គ្រងដោយអាជ្ញាធរជាតិអប្សរា នាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាន នៃអាជ្ញាធរជាតិអប្សរា នឹងកាត់ជកហូតដើមឈើ និងកាត់ក្រឹមែកឈើ តាមទីតាំងនានាដូចខាងក្រោម៖

-កាត់ជកហូតដើមឈើយកចេញចំនួន ០៤ដើម ស្ថិតនៅក្នុងបរិវេណប្រាសាទអង្គរវត្ត។

-កាត់ក្រឹមែកឈើអំពិល០១ដើម មានហានិភ័យ ស្ថិតនៅក្នុងភូមិវាល សង្កាត់គោកចក ក្រុងសៀមរាប នៅចំណុចខាងលិចចំណតរថយន្តមុខអង្គរវត្ត។

ការងារនេះ នឹងចាប់ផ្តើមអនុវត្តចាប់ពីថ្ងៃទី ២៤ ខែកក្កដា ឆ្នាំ២០១៨ រហូតដល់បញ្ចប់ការងារ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមស្ថាប័ន សមត្ថកិច្ចពាក់ព័ន្ធ ភ្ញៀវជាតិ-អន្តរជាតិ មត្តុទ្ទេសក៍ទេសចរណ៍ ព្រមទាំងសាធារណជនទាំងអស់ មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃ ចន្ទ ១១ កើត ខែ ទុតិយាសាឡ ឆ្នាំច សំរឹទ្ធស័ក ព.ស ២៥៦២
សៀមរាប ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ២០១៨
អគ្គនាយក

ស៊ុ ម៉ាប់

ចម្លងជូន៖
-សាណាខេត្តសៀមរាប
-មន្ទីរបរ៉ស្ថានខេត្តសៀមរាប
-មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តសៀមរាប
-អង្គភាពនគរបាលការពារបេតិកភណ្ឌប្រចាំខេត្តសៀមរាប
-ស្នាក់ការតំបន់ការពារទេសភាពអង្គរ
-សមាគមមត្តុទ្ទេសក៍ទេសចរណ៍ទាំងអស់ប្រចាំខេត្តសៀមរាប
"ដើម្បីជូនជ្រាប និងសហការ"
-ប៉ូលីសទេសចរណ៍
-គ្រប់នាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធរបស់អាជ្ញាធរអប្សរា
"ដើម្បីមុខការ និងសហការ"
-ឯកសារ-កាលប្បវត្តិ

លេខទូរស័ព្ទទំនាក់ទំនង: លោក ផង់ សុវណ្ណារ៉ិទ្ធ 012-354-630, លោក ទៀន សុធី 010-304-089,088-9522-5059,លោក ហ៊ែ ហ៊ីត 086 600 740

ភ្ជាប់ឌ្រាយ:
មហាវិទីសហាព័ទ្ធរស្មី លេខ៥៦ សង្កាត់មិត្តភាព ខណ្ឌឫទ្ធាគ
ទូរសព្ទ/ទូរសារ៖ ០២៣ ២១៥ ៥៥៦/០២៣ ២១៥ ៥៥៦

អាជ្ញាធរជើម្បីការពារមណីយដ្ឋាននឹងជ្រាបចំកំបន់អង្គរ
Email: info@apsaraauthority.gov.kh
Website: http//www.apsaraauthority.gov.kh

សៀមរាប:
ភូមិបង្គោង ឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប
ទូរសព្ទ/ទូរសារ៖ ០៦៣ ៥៦៥ ៥៥៥/០៦៣ ៥៦៥ ៥៥៦

អាជ្ញាធរជាតិអប្សរាសាងសង់ទ្វារទឹកសម្រាប់ផ្គត់ផ្គង់ស្រែជិត១០០ហិកតាជូនអ្នកភូមិនគរក្រៅ សង្កាត់គោកចក ក្រុងសៀមរាប

ផ្សាយនៅថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ២០១៨

ឆ្លើយតបទៅនឹងសំណូមពរនិងតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋនៅភូមិនគរក្រៅ សង្កាត់គោកចក ក្រុងសៀមរាប អាជ្ញាធរជាតិអប្សរា កំពុងសាងសង់ទ្វារទឹកមួយកន្លែងដើម្បីគ្រប់គ្រងនិងស្តុកទឹកទុកប្រើប្រាស់ក្នុងរដូវប្រាំង។ អ្នកជំនាញពន្យល់ថា ទ្វារទឹកថ្មីនេះមានទីតាំងក្នុងអូរខ្លូត នៅលើទំនប់ចាស់ដែលអ្នកភូមិហៅថាទំនប់លោកតាស៊ត់ នឹងអាចគ្រប់គ្រងទឹកសម្រាប់ស្រោចស្រពស្រែចម្ការនិងដំណាំផ្សេងៗរបស់ពលរដ្ឋជិត១០០ ហិកតា។

អនុប្រធាននាយកដ្ឋានគ្រប់គ្រងទឹក នៃអាជ្ញាធរជាតិអប្សរា **លោក ភឿន សុឃីម** បានឱ្យដឹងថា ទ្វារទឹកដែលសង់ថ្មីនេះ គឺធ្វើតាមសំណូមពររបស់ប្រជាពលរដ្ឋដែលត្រូវការស្តុកទឹកប្រើប្រាស់ពេលគ្មានទឹកភ្លៀង ឬក្នុងរដូវប្រាំង។ មួយវិញទៀត លោក សុឃីម បានបន្ថែមថា នេះជាគម្រោងរបស់នាយកដ្ឋានគ្រប់គ្រងទឹកផងដែរ ដើម្បីរំដោះជំនន់ទឹកភ្លៀងក្នុងក្រុងអង្គរ និងក្រុងសៀមរាប ព្រមទាំងដើម្បីរក្សាទឹកក្រោមដីក្នុងតំបន់អង្គរ។

ទ្វារទឹកនេះមានបណ្តោយជាង ២០ម៉ែត្រ និងទទឹងប្រមាណ ១៨ម៉ែត្រ ហូរកាត់អូរខ្លូត ដែលរំដោះទឹកភ្លៀងទៅស្ទឹងពួក និងស្ទឹងព្រះស្រុក។ កន្លងមកអ្នកភូមិមានទំនប់មួយឈ្មោះ ទំនប់ **លោកតា ស៊ត់** ដែលគ្មានបច្ចេកទេសទ្វារទឹកត្រឹមត្រូវ ហើយអាចត្រឹមតែទប់ទឹក តែមិនមានប្រព័ន្ធបង្ហូរចេញឡើយ ដូច្នេះពេលខ្លះធ្វើឱ្យជន់លិចភូមិក្បែរ ពេលទឹកជន់ឡើងខ្លាំង។

ទ្វារទឹកដែលកំពុងសាងសង់នេះ ត្រូវបានដាក់ឈ្មោះថា ទ្វារទឹក **លោកតា ស៊ត់** សាងសង់ចាប់ពីថ្ងៃទី១៩ ខែមិថុនា ឆ្នាំ ២០១៨ ដោយគ្រោងនឹងបញ្ចប់នៅរយៈពេល៣ខែបន្ទាប់ និងមានប្រជាពលរដ្ឋចំនួន ជាង៥០០គ្រួសារ ទទួលផលប្រើប្រាស់ទឹកពីសំណង់ទ្វារទឹកនេះ។

គួរបញ្ជាក់ថា តាមការលើកឡើងរបស់ **លោក សុឃីម** ទឹកភ្លៀងនៅឆ្នាំនេះក្នុងតំបន់អង្គរ មានភាពយឺតយ៉ាវជាងឆ្នាំមុនបន្តិច ប៉ុន្តែការគ្រប់គ្រងទឹកគ្មានបញ្ហាចោទឡើយ។ ក្នុងនោះដែរអ្នកជំនាញទឹកបញ្ជាក់ថា ក្រោយមានការស្ថាប្រព័ន្ធបង្ហូរនានាចាប់ពីឆ្នាំ២០១២មក ក្រុងអង្គរ និងក្រុងសៀមរាប មិនមានជំនន់ទឹកភ្លៀងកើតឡើងឡើយ គឺជន់នៅតំបន់ជាយក្រុង ឬនៅផ្នែកខាងក្រោមបន្តិចបន្តួចតែប៉ុណ្ណោះ៕









អាជ្ញាធរជាតិអប្សរាសម្រេចជួសជុលផ្លូវភូមិមួយខ្សែជូនប្រជាពលរដ្ឋភូមិលៃលៃឃុំបាគង

ផ្សាយនៅថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ២០១៨

ស្របតាមសំណូមពរ និងតម្រូវការជាក់ស្តែងនៃប្រជាពលរដ្ឋភូមិលៃលៃ ឃុំបាគង ស្រុកប្រាសាទបាគង ខេត្តសៀមរាប ដែលស្ថិតនៅក្នុងរមណីយដ្ឋានអង្គរ អាជ្ញាធរជាតិអប្សរាបានសម្រេច ជួសជុលផ្លូវលំមួយខ្សែដែលមានប្រវែង២៨០០ម៉ែត្រ ដែលបម្រើដល់សេចក្តីត្រូវការប្រើប្រាស់ប្រចាំថ្ងៃរបស់អ្នកភូមិ។

ក្នុងពិធីបើកការដ្ឋានជួសជុលផ្លូវ នារសៀលថ្ងៃទី២៥ ខែកក្កដានេះ **លោក លុយ ឆន** មេឃុំឃុំបាគង បានបញ្ជាក់ថា ផ្លូវលំមួយខ្សែនេះជាផ្លូវបុរាណដែលប្រជាពលរដ្ឋក្នុងភូមិលៃលៃអាស្រ័យប្រើប្រាស់ជាប្រចាំ។ ប៉ុន្តែ ផ្លូវនេះបានរងការខូចខាតដោយអន្លើ ដោយកន្លែងខ្លះបានបាក់ដី កើតជាដងុកតូចធំ និងកន្លែងខ្លះទៀតតូចចង្អៀត ដែលនាំឲ្យប្រជាពលរដ្ឋជួបការលំបាកច្រើនក្នុងការធ្វើដំណើរ។

លោក ធិននី រិទ្ធ អភិបាលរងស្រុកប្រាសាទបាគងបានលើកឡើងក្នុងពិធីបើកការដ្ឋាននេះថា ក្នុងនាមអាជ្ញាធរស្រុក ក៏ដូចជាអាជ្ញាធរមូលដ្ឋាន លោកពិតជារីករាយ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអាជ្ញាធរជាតិអប្សរា ដែលបានសម្រេចជួសជុលផ្លូវមួយខ្សែនេះជូនប្រជាពលរដ្ឋ ជាពិសេស **ឯកឧត្តម សុខ សង្ហារ** អគ្គនាយករងនៃអាជ្ញាធរជាតិអប្សរា ដែលបានជួយសម្របសម្រួល និងចំណាយថវិកាផ្ទាល់ខ្លួនក្នុងការងារជួសជុលនេះ។

ឯកឧត្តម សុខ សង្ហារ ដែលបានអញ្ជើញជាអធិបតីក្នុងពិធីបើកការដ្ឋាននេះមានប្រសាសន៍ថា ផ្លូវភូមិមួយខ្សែនេះស្ថិតនៅលើខ្នងបារាយណ៍បុរាណ ប៉ុន្តែ ជាតម្រូវការចាំបាច់របស់ប្រជាពលរដ្ឋក្នុងការធ្វើដំណើរប្រចាំថ្ងៃ ទើបអាជ្ញាធរជាតិអប្សរាក្រោយទទួលបានសំណើសុំជួសជុលពីប្រជាពលរដ្ឋ សម្រេចបញ្ជូនមន្ត្រីជំនាញ ដើម្បីសិក្សាអំពីលទ្ធភាពនៃការជួសជុលក្នុងកម្រិតមួយ ដែលមិនប៉ះពាល់ដល់បុរាណដ្ឋាន។

ក្រោយការសិក្សារបស់មន្ត្រីជំនាញឃើញថា ការជួសជុលផ្លូវនេះគឺត្រូវធ្វើឡើងដោយគ្រាន់តែអាចបំពេញដី ត្រង់ដងុកតូចធំ ឈូសពង្រាបទីទួល និងសម្អាតមែកឈើខ្លះៗដែលទេរមកលើផ្លូវប៉ុណ្ណោះ មិនអាចឈូសឆាយទ្រង់ ទ្រាយធំ ឬពង្រីកបន្ថែមលើសពីផ្លូវបច្ចុប្បន្ននេះឡើយ។ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនានាក្នុងរមណីយដ្ឋានអង្គរ គឺត្រូវគិតគូរខ្លាំង ដៀសវាងការអភិវឌ្ឍដែលនាំឲ្យប៉ះពាល់ដល់បុរាណដ្ឋាន ឬទីតាំងប្រវត្តិសាស្ត្រ របស់អង្គរ។

ឯកឧត្តមបន្ថែមថា ទោះជាយ៉ាងនេះក្តី ឯកឧត្តមពិតជារីករាយដែលបានរួមចំណែកជួយដោះស្រាយទុក្ខលំបាករបស់បងប្អូនប្រជាពលរដ្ឋ។ ជាមួយគ្នានេះ ឯកឧត្តមក៏បានសំណូមពរដល់ប្រជាពលរដ្ឋឲ្យជួយថែទាំសមិទ្ធផលដែលសម្រេចបាននេះឲ្យបានល្អ និងប្រើប្រាស់បានយូរតទៅទៀត។ ជាពិសេស ត្រូវរួមគ្នាថែរក្សានូវបេតិកភណ្ឌអង្គរ ដោយមិនធ្វើអ្វីដែលនាំឲ្យប៉ះពាល់ដល់ប្រាង្គប្រាសាទ ឬបុរាណដ្ឋាននានា និងរួមគ្នាគោរពច្បាប់ និងគោលការណ៍នានា ដែលពាក់ព័ន្ធនឹងការអភិរក្សបេតិកភណ្ឌជាដើម៕






អាជ្ញាធរជាតិអប្សរាកំពុងដំណើរការជួសជុលកំណាត់ផ្លូវមិត្តភាពកម្ពុជា-កូរ៉េ ដែលមានប្រវែងជាង ៧០០ម៉ែត្រ

ផ្សាយនៅថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ២០១៨

ដោយចរាចរណ៍ ការដឹកជញ្ជូនធំៗលើកំណាត់ផ្លូវមិត្តភាពកម្ពុជា-កូរ៉េ (ផ្លូវស្វាយធំ) ធ្វើឱ្យផ្លូវនេះរងការខូចខាតមួយចំនួនធំ។ ដោយមើលឃើញពីការលំបាករបស់ប្រជាពលរដ្ឋយ៉ាងដូច្នេះ អាជ្ញាធរជាតិអប្សរា បាននិងកំពុងផ្តើមការជួសជុលឡើងវិញ ដើម្បីសម្រួលចរាចរណ៍ដល់ការធ្វើដំណើររបស់ប្រជាពលរដ្ឋមូលដ្ឋាន។

បច្ចុប្បន្នអាជ្ញាធរជាតិអប្សរាកំពុងដំណើរការជួសជុលទ្រង់ទ្រាយធំលើកំណាត់ផ្លូវមិត្តភាពកម្ពុជា-កូរ៉េ ដែលមានទីតាំងផ្លូវបំបែកផ្លូវជាតិលេខ៦ ពីចំណុចផ្សារស្វាយធំខាងកើត កាត់តាមរង្វង់មូលព្រៃគុយទៅដល់ផ្សារព្រះដាក់ដែលមានប្រវែង

សរុប៧៥០ម៉ែត្រ ក្រោមថវិកាមូលនិធិប្រចាំឆ្នាំ២០១៨។ គម្រោងជួសជុលនេះ នឹងត្រូវជួសជុលចាក់គ្រឹះឡើងវិញត្រង់ចំណុចដែលខូចខាតខ្លាំង ហើយចាក់បំពេញចំណុចដែលមានក្រហូងតូចធំ ធ្វើយ៉ាងណាឱ្យកំណាត់ផ្លូវជាតិនេះមានសភាពល្អប្រសើរឡើងវិញ។

លោក ហេង គឹមឡេង ប្រធាននាយកដ្ឋានទ្រទ្រង់បច្ចេកទេស និងគម្រោងអន្តរវិស័យនៃអគ្គនាយកដ្ឋានអាជ្ញាធរជាតិអប្សរា បានឱ្យដឹងថា ក្រុមការងារនឹងត្រូវចំនាយពេលវេលាអនុវត្តគម្រោងនេះរយៈពេលចំនួន១ខែ។ រីឯការជួសជុលកែលម្អផ្លូវនេះគឺធ្វើឡើងជាអន្លើៗទៅតាមស្ថានភាពផ្លូវដែលខូចខាតជាក់ស្តែង។ ម្យ៉ាងទៀតដោយសារសងខាងផ្លូវ ប្រព័ន្ធបង្ហូរទឹកត្រូវបានកកស្ទះដោយសារការចាក់ដីលុប និងខ្ពស់ជាងផ្លូវនៅតាមមុខផ្ទះរបស់ប្រជាជនមួយចំនួន បណ្តាលឱ្យផ្លូវរងការខូចខាតមួយកម្រិតថែមទៀត ដូច្នេះជាជំហានបន្ទាប់ក្រុមការងារក៏មានគម្រោងស្តារប្រព័ន្ធបង្ហូរឡើងវិញដើម្បីរំដោះទឹក និងរក្សាគុណភាពផ្លូវ។

លោកបានបញ្ជាក់ថានៅពេលខាងមុខអាជ្ញាធរជាតិអប្សរានឹងមាន វិធានការស្តារប្រព័ន្ធបង្ហូរទឹកទាំងអស់នៅតាមផ្លូវដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា ក្រោយពីបញ្ចប់ការជួសជុលលើកំណាត់ផ្លូវនេះ។ លោកក៏បានសំណូមពរដល់ប្រជាពលរដ្ឋដែលនៅសងខាងផ្លូវទាំងអស់មានការយោគយល់ និងចូលរួមសហការដើម្បីថែរក្សាផ្លូវឱ្យស្ថិតនៅគង់វង្សយូរអង្វែង។

គួររំឭកដែរថា ផ្លូវមួយខ្សែរនេះដើមឡើយ គឺជាផ្លូវដី និងបានកែប្រែជាផ្លូវគ្រួសក្រហមតាមរយៈគម្រោង ទីភ្នាក់ងារអភិវឌ្ឍន៍ និងសហប្រតិបត្តិការកូរ៉េ ហៅកាត់ថា KOICA។ នៅឆ្នាំ២០០៩ ក្រោមជំនួយឥតសំណងរបស់សាធារណរដ្ឋកូរ៉េ តាមរយៈ KOICA ដដែល បានកែប្រែផ្លូវនេះមកជាផ្លូវក្រាលកៅស៊ូវិញ ដើម្បីងាយស្រួលដល់ប្រជាជនធ្វើដំណើរឆ្លងកាត់បានប្រសើជាងមុន៕









ឯកឧត្តម សុខ សន្ធារ រំព្រកភ្លាក់ចារប្រាសាទ និងបុគ្គលិកសាមន្ទីរទៅបោះឆ្នោតដើម្បី បំពេញកាតព្វកិច្ចជាពលរដ្ឋល្អ

ផ្សាយនៅថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ២០១៨

នាព្រឹកថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៨នេះ **ឯកឧត្តម សុខ សន្ធារ** អគ្គនាយករងនៃអាជ្ញាធរជាតិអប្សរា ទទួលបន្ទុកនាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍អង្គរ និងនាយកដ្ឋានអភិវឌ្ឍន៍វប្បធម៌ សារមន្ទីរ និងបទដ្ឋានបេតិកភណ្ឌ បានជួបជុំសំណេះសំណាលជាមួយភ្នាក់ងារប្រាសាទ និងបុគ្គលិកសារមន្ទីរដែលស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា សរុបជាង៥០០នាក់។

ក្នុងពិធីជួបក្រុមការងារដ៏ធំនេះ **ឯកឧត្តម សុខ សន្ធារ** បានកោតសរសើរចំពោះក្រុមការងារទាំងអស់ ដែលបានខិតខំបំពេញការងារ ដោយឆន្ទៈមុតមាំ និងមានការទទួលខុសត្រូវខ្ពស់ចំពោះមុខនាទីរបស់ខ្លួន ធ្វើឲ្យការងារគ្រប់គ្រងអង្គរទទួលបាននូវភាពជោគជ័យជាបន្តបន្ទាប់លើឆាកអន្តរជាតិ។

ឯកឧត្តមបញ្ជាក់ថា ភាពជោគជ័យនៃការងារគ្រប់គ្រងរមណីយដ្ឋានអង្គរ គឺជាមោទនភាពរបស់យើងទាំងអស់គ្នា ដែលបានដើរតាមគោលនយោបាយ ដ៏ត្រឹមត្រូវរបស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ដែលមានចក្ខុវិស័យវែងឆ្ងាយ និងមានគោលនយោបាយច្បាស់លាស់ក្នុងការងារគ្រប់គ្រងរមណីយដ្ឋានអង្គរ។

ទោះជាយ៉ាងនេះក្តី ឯកឧត្តមក៏បានក្រើនរំព្រកឲ្យក្រុមការងារបន្តយកចិត្តទុកដាក់បន្ថែមទៀត ជាពិសេស គឺការអត់ធ្មត់នឹងភាពឆ្គាំឆ្គងរបស់ភ្ងៀវទេសចរមួយចំនួន ដោយការណែនាំ ឬហាមឃាត់ដោយពាក្យសម្តី និងកាយវិការសមរម្យ ថ្លៃថ្នូរ ក្នុងនាមជាម្ចាស់អង្គរ ដែលមានអារ្យធម៌ដ៏រុងរឿង។

ឆ្លៀតក្នុងឱកាសសំណេះសំណាលនេះដែរ ឯកឧត្តមក៏បានអំពាវនាវឲ្យភ្នាក់ងារប្រាសាទ និងបុគ្គលិកសារមន្ទីរទាំងអស់នាំគ្នាទៅបោះឆ្នោតឲ្យបានគ្រប់គ្នា ក្នុងនាមប្រជាពលរដ្ឋខ្មែរ ដែលត្រូវទទួលខុសត្រូវ ចំពោះជោគវាសនាអនាគតរបស់ប្រទេសខ្លួន ដោយមិនត្រូវចាញ់បោកការយោសនា ឬការញុះញង់ពីក្រុមមនុស្សដែលរារាំងមិនឲ្យទៅបោះឆ្នោតណាមួយឡើយ។

ទន្ទឹមនឹងនេះ ឯកឧត្តមក៏បានបញ្ជាក់ផងដែរ នូវគណបក្សនយោបាយដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ ក្នុងការដឹកនាំប្រទេសជាតិ នោះគឺគណបក្សដែលមានសមត្ថភាពរក្សានូវសន្តិភាព និងមានធនធានមនុស្សគ្រប់គ្រាន់ក្នុងការអភិវឌ្ឍជាតិគ្រប់វិស័យទាំងអស់។

ជាចុងក្រោយ ឯកឧត្តមបានក្រើនរំព្រកបុគ្គលិកទាំងអស់ឲ្យត្រៀមឯកសារពាក់ព័ន្ធនឹងការបោះឆ្នោត និងទៅបោះឆ្នោតឲ្យបានគ្រប់គ្នា ជាពិសេស គឺទៅបោះឆ្នោតជូនគណបក្សដែលមានសមត្ថភាព ហ៊ានថា ហ៊ានធ្វើ ដើម្បីបុព្វហេតុនៃការរក្សាសន្តិភាព និងការអភិវឌ្ឍជាតិពិតប្រាកដ។









សារអំលែកទុក្ខរបស់លោកជំទាវ ភឿង សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាប្រធានអាជ្ញាធរជាតិអប្សរា ជូនចំពោះលោកស្រី Lablaude ព្រមទាំងក្រុមគ្រួសារ

ផ្សាយនៅថ្ងៃទី ៣០ខែ កក្កដា ឆ្នាំ២០១៨



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៨

សារអំលែកទុក្ខរបស់លោកជំទាវ ភឿង សកុណា
រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាប្រធានអាជ្ញាធរជាតិអប្សរា

លោកស្រី Lablaude ជាទីគោរព!

យើងខ្ញុំទទួលបានដំណឹងដ៏មហាក្រៀមក្រំក្រៃលែង ស្តីពីមរណភាពរបស់លោកសាស្ត្រាចារ្យ Pierre-André Lablaude អ្នកជំនាញការ adhoc ផ្នែកអភិរក្ស ដែលបានណែនាំទីនេះចាប់ពីវិនាទីដំបូង ដែលមណ្ឌលអង្គរត្រូវបានដាក់បញ្ចូលទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក គោលពាក្យដ៏ឆ្នាំ១៩៩២មក។

ខ្ញុំទើបតែស្គាល់លោកសាស្ត្រាចារ្យ Lablaude ថ្មីៗនេះប៉ុណ្ណោះ ប៉ុន្តែភាពប៉ិនប្រសប់ប្រកបដោយសមត្ថភាពវិជ្ជាជីវៈរបស់លោកសាស្ត្រាចារ្យ បានបង្ហាញយ៉ាងជាក់ស្តែងតាមរយៈសកម្មភាពរបស់គាត់នៅតាមទីតាំងផ្ទាល់ និងនៅក្នុងអនុសាសន៍បច្ចេកទេសនានា។

ជាពិសេស ខ្ញុំបានចងចាំយ៉ាងជាក់ច្បាស់ពីបទពិសោធន៍ដ៏ក្តុកក្តន់សម្ងាល់នានារបស់លោកសាស្ត្រាចារ្យក្នុងដំណើរការកិច្ចប្រជុំនានារបស់គណៈកម្មាធិការអន្តរជាតិដើម្បីសម្របសម្រួលកិច្ចការពារ និងអភិវឌ្ឍន៍រមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ ហៅកាត់ថា សេអ៊ីសេ "CIC" ។ ការលះបង់របស់គាត់ គឺជាតំណែលដ៏ល្អ ហើយគុណសម្បត្តិមនុស្សជាតិ និងសមត្ថភាពផ្ទាល់ជីវៈនានារបស់គាត់នឹងធ្វើឱ្យយើងទាំងអស់គ្នាចងចាំមិនអាចបំភ្លេចបាន។

លោកសាស្ត្រាចារ្យ Pierre-André Lablaude គឺជាសសរស្តម្ភមួយចាប់តាំងពីការបង្កើតសេអ៊ីសេអង្គរ ហើយការបាត់បង់លោកសាស្ត្រាចារ្យ គឺប្រៀបផ្ទុំជាការចាកចេញពីយើងនូវទំព័រប្រវត្តិសាស្ត្រអង្គរដ៏ធំមួយ។ ទោះជាយ៉ាងណាក៏ដោយ តាមរយៈស្នាដៃការងារនានា លោកសាស្ត្រាចារ្យ Pierre-André Lablaude នៅតែបន្សល់ទុកនូវមរតកដ៏ណែលមួយ មិនអាចកាត់ថ្លៃបាន ហើយនឹងក្លាយជាប្រយោជន៍ដ៏ធំសំខាន់សម្រាប់អ្នកស្រាវជ្រាវជំនាន់ក្រោយរបស់កម្ពុជា និងអន្តរជាតិជាច្រើននាក់ទៀតនាពេលអនាគត។

ព្រះរាជាណាចក្រកម្ពុជានឹងបន្តនូវការដឹងគុណជានិច្ចនិរន្ត សម្រាប់ការប្តេជ្ញាចិត្តដ៏ខ្លាំងក្លារបស់លោកសាស្ត្រាចារ្យ ដើម្បីបុព្វហេតុនៃចំណេះដឹង នៃការពារ និងការពារមរតកវប្បធម៌។

យើងខ្ញុំតិតដល់ជាពិសេសចំពោះលោកស្រី និងបុត្រនារីកាសដ៏មហាក្រៀមក្រំនេះ ហើយក្នុងនាមមន្ត្រីទាំងអស់នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក៏ដូចជាក្នុងនាមអាជ្ញាធរជាតិអប្សរា និងក្នុងនាមខ្ញុំផ្ទាល់ សូមមេត្តាអនុញ្ញាតឱ្យយើងខ្ញុំ ចូលរួមរំលែកទុក្ខដ៏ស្មោះអស់ពីដួងចិត្ត ជាមួយនឹងក្រុមគ្រួសារលោកស្រី និងសាច់ញាតិទាំងអស់របស់លោកសាស្ត្រាចារ្យ។

ហត្ថលេខា និងត្រា
ភឿង សកុណា
រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
និងជាប្រធានអាជ្ញាធរជាតិអប្សរា



ROYAUME DU CAMBODGE
NATION RELIGION ROI

MINISTERE DE LA CULUTRE ET DES BEAUX-ARTS

APSARA

N°

Phnom Penh, le 28 juillet 2018

MESSAGE DE CONDOLÉANCES DE SON EXCELLENCE DR. PHOEURNG SACKONA

Ministre de la Culture et des Beaux-Arts du Cambodge

Présidente de l'Autorité nationale APSARA

Chère Madame Lablaude,

Nous avons appris, avec une très grande tristesse le décès du Prof Pierre-André Lablaude, expert ad hoc en conservation, dès les premières heures de l'inscription d'Angkor sur la Liste du Patrimoine mondial, depuis 1992.

Je ne connaissais que récemment Prof Lablaude, mais il brillait par ses actions sur le terrain et dans ses recommandations techniques.

J'ai surtout retenu ses remarquables interventions au cours des débats pendant les sessions du Comité International de Coordination pour la sauvegarde et le développement du site historique d'Angkor (CIC). Son dévouement est exemplaire et ses qualités humaines et professionnelles nous manqueront longtemps.

Prof Pierre-André Lablaude était le pilier depuis la création du CIC-d'Angkor et avec sa disparition, c'est une grande page de l'histoire d'Angkor qui nous quitte. Cependant, par ses travaux Prof Pierre-André Lablaude laisse un héritage inestimable et bénéfique à de nombreuses nouvelles générations de chercheurs cambodgiens et internationaux.

Le Cambodge lui sera éternellement reconnaissant pour son profond engagement en faveur de la connaissance, de la sauvegarde et de la protection du Patrimoine angkorien.

Nous pensons surtout à vous et à votre fils en ces douloureuses circonstances, et je souhaite Chère Madame au nom du Ministère de la Culture et des Beaux-Arts, de l'Autorité nationale APSARA, et en mon nom, présenter à votre famille et à ces proches mes condoléances les plus sincères.

Dr PHOEURNG Sackona
Ministre
Présidente Autorité nationale APSARA

Adresse: #227, Preah Norodom Blvd., Khan Chamcar Mon, Phnom Penh, Royaume du Cambodge
Tel: (855) 23 217 647, Fax: (855) 23 218 146, Email: info@mcfa.gov.kh, Website: www.mcfa.gov.kh





ព្រឹត្តិការណ៍ព័ត៌មាន
ប្រចាំខែសីហា

ផ្នែកទី ៨
ប្រចាំខែសីហា

អាជ្ញាធរជាតិអប្សរាកំពុងជួសជុលផ្លូវ៦០ម៉ែត្រដែលរងនូវការខូចខាត

ផ្សាយនៅថ្ងៃទី ០២ ខែ សីហា ឆ្នាំ២០១៨

កំណាត់ផ្លូវ៦០ម៉ែត្រ ចាប់ពីស្ពាននាគរហូតដល់រង្វង់មូលអាជ្ញាធរជាតិអប្សរា បានរងនូវការខូចខាតដោយអន្លើដែលបណ្តាលមកពីទឹកភ្លៀង និងកំណើនចរាចរណ៍ខ្លាំងបង្កឲ្យមានការលំបាកក្នុងការ ធ្វើដំណើររបស់ប្រជាជននិងភ្ញៀវទេសចរ។

ដោយពិនិត្យមើលឃើញស្ថានភាពលំបាកនេះ អាជ្ញាធរជាតិអប្សរា នៅថ្ងៃទី១ ខែសីហា ឆ្នាំ២០១៨ បានកំពុងធ្វើការជួសជុលកន្លែងខូចខាតទាំងនេះយ៉ាងសស្រាក់សស្រាំឱ្យបានទាន់ពេលវេលាមុនភ្លៀងធ្លាក់មកទៀត។ អាជ្ញាធរជាតិអប្សរាក៏សូមការយោគយល់អធ្យាស្រ័យពីអ្នកធ្វើដំណើរទាំងអស់ចំពោះ បញ្ហាយឺតយ៉ាវក៏ព្រោះនេះជារដូវវស្សា ហើយមានភ្លៀងធ្លាក់ជាច្រើនថ្ងៃដែលមិនអនុគ្រោះដល់ការជួសជុល ទើបបណ្តាលឱ្យមានការពន្យារពេលរហូតដល់ថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៨ នេះ៕






អាជ្ញាធរជាតិអប្សរាយកចាច់ផ្កាចូលរួមបុណ្យសពលោកសាស្ត្រាចារ្យ Lablaude នោធីក្រុងចារីស

ផ្សាយនៅថ្ងៃទី ០២ ខែ សីហា ឆ្នាំ២០១៨

អាជ្ញាធរជាតិអប្សរា បានសម្តែងអារម្មណ៍ក្រៀមក្រំក្រៃលែង ចំពោះមរណភាពរបស់ **លោកសាស្ត្រាចារ្យ Pierre-André Lablaude** អ្នកជំនាញការ adhoc ផ្នែកអភិរក្សនៃគណៈកម្មការអាយស៊ីស៊ី-អង្គរ ហើយលោកសាស្ត្រចារ្យបានបំពេញតួនាទីនេះចាប់ពីវិនាទីដំបូង ដែលរមណីយដ្ឋានអង្គរត្រូវបានដាក់បញ្ចូលទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ពោលតាំងពីដើមទស្សវត្តឆ្នាំ១៩៩០មកម្លេះ។

រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាប្រធានអាជ្ញាធរជាតិអប្សរា **លោកជំទាវ ភឿង សកុណា** បានផ្ញើសាររំលែកទុក្ខចំពោះការបាត់បង់របស់ **លោកសាស្ត្រាចារ្យ Lablaude** និងបានរំលឹកនូវការងារជាច្រើនរបស់លោកក្នុងការជួយរមណីយដ្ឋានអង្គររហូតមកដល់បច្ចុប្បន្ន។

ជាមួយគ្នានេះ លោកជំទាវប្រធានអាជ្ញាធរជាតិអប្សរា តាមរយៈតំណាងស្ថានទូតកម្ពុជា និងតំណាងអចិន្ត្រៃយ៍កម្ពុជាប្រចាំអង្គការយូណេស្កូនៅទីក្រុងបារីស បានយកបាច់ផ្កាចូលរួមក្នុងពិធីបុណ្យសពរបស់ **លោកសាស្ត្រាចារ្យ Lablaude** ដើម្បីចូលរួមគោរពវិញ្ញាក្ខន្ធរបស់លោកផងដែរ។





ព្រះមហាក្សត្រកម្ពុជាផ្ញើសារវំលែកទុក្ខដល់ត្រួសារសពលោកសាស្ត្រាចារ្យ Pierre-André Lablaude

ផ្សាយនៅថ្ងៃទី ០២ ខែ សីហា ឆ្នាំ២១៨

ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ ព្រះនរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា បានផ្ញើព្រះរាជសារវំលែកទុក្ខដល់ត្រួសារសព **លោកសាស្ត្រាចារ្យ Pierre-André Lablaude** អ្នកជំនាញការអាដហុក (Ad hoc) ផ្នែកអភិរក្ស នៃគណៈកម្មការអាយស៊ីស៊ី-អង្គរ ដែលបានទទួលមរណភាពនៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៨ នាទីក្រុងប៉ារីស ដោយជំងឺគាំងបេះដូង។ ក្នុងព្រះរាជសារដែលបានផ្ញើទៅ **លោកជំទាវ គឿន សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាប្រធានអាជ្ញាធរជាតិអប្សរា ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា បានសម្តែងនូវការសោកស្តាយ ចំពោះការបាត់បង់លោកសាស្ត្រាចារ្យ ដែលបានបំពេញបេសកកម្មអន្តរជាតិដ៏វិសេសវិសាល ចាប់តាំងពីរមណីយដ្ឋានអង្គរត្រូវបានដាក់បញ្ចូលក្នុងបញ្ជីបេតិកភណ្ឌពិភពលោកនៅឆ្នាំ ១៩៩២។

ជាមួយគ្នានេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់បានប្រោសប្រទាននូវមេដាយសហមេត្រី ថ្នាក់មហាសេរីវឌ្ឍដល់សពរបស់ **លោកសាស្ត្រាចារ្យ Pierre-André Lablaude** ដើម្បីឱ្យស័ក្តិសមចំពោះការលះបង់របស់លោកសាស្ត្រាចារ្យ ក្នុងការងារជាច្រើនដើម្បីបុព្វហេតុរមណីយដ្ឋានអង្គរ។



ព្រះកឡោព្រះបាទសម្តេចព្រះបមេនាថ
នរោត្តម សីហមុនី
ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា

ជូន លោកជំទាវ **គឿន សកុណា**
រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
និងជាប្រធានគណៈកម្មការជាតិយូណេស្សូកម្ពុជា

លោកជំទាវ ជាទីរាប់អានជំនួង់ខ្ពស់

ខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅ ចំពោះលោកជំទាវ ដែលបានផ្ទាយនូវលិខិតលេខ ៤៥ របក ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៨ ស្តីអំពីដំណឹងមរណភាពរបស់លោកសាស្ត្រាចារ្យ Pierre-André Lablaude អ្នកជំនាញការ Ad hoc នៃ CIC-Angkor ផ្នែកអភិរក្ស។

ខ្ញុំសូមចូលរួមវំលែកមរណទុក្ខដ៏មហាក្រៀមក្រំក្រៃលែងជាមួយគ្នាសារ របស់លោកសាស្ត្រាចារ្យ Pierre-André Lablaude ដែលបានទទួលមរណភាព កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៨ កន្លងទៅនេះ។

ខ្ញុំសូមសម្តែងនូវការសោកស្តាយ ចំពោះការបាត់បង់លោកសាស្ត្រាចារ្យ Pierre-André Lablaude ដែលបានបំពេញបេសកកម្មអន្តរជាតិដ៏វិសេសវិសាល ចាប់តាំងពីរមណីយដ្ឋានអង្គរត្រូវបានដាក់បញ្ចូលទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោកនៅឆ្នាំ១៩៩២។

ការចំណាយពេលវេលាអស់ជិតពាទសវត្សរ៍ របស់លោកសាស្ត្រាចារ្យ ចំពោះដំណើរការអភិរក្ស និងអភិវឌ្ឍរមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ បានបន្សល់ទុកនូវស្នាដៃជាច្រើនដល់ប្រជាជនកម្ពុជា និងដល់អ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយទាំងជាតិ និងអន្តរជាតិ ដែលជាកេរដំណែលដ៏ខត្តុង្គខត្តមប្រកបដោយវិជ្ជាជីវៈ និងសមត្ថភាពដ៏ខ្លាំងក្លា ជាគំរូដ៏ល្អមានគុណប្រយោជន៍សប្រាប់ប្រជាជនកម្ពុជា និងអន្តរជាតិ។ ប្រជាជនកម្ពុជាចងចាំជានិច្ចនូវគុណបំណាច់ និងស្នាដៃមិនអាចកាត់ថ្លៃបានរបស់លោកសាស្ត្រាចារ្យ ជារៀងរហូត។

សូម លោកជំទាវ ទទួលនូវសេចក្តីរាប់អានជ៏ខ្ពង់ខ្ពស់ អំពីខ្ញុំ។

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ០១ ខែសីហា ឆ្នាំ២០១៨



KRET

ច្បាប់ចម្លង

NS / KRT / 0818 / 805

Nous
Preah Karuna Preah Bat Samdech
Preah Boromneath Norodom Sihamoni
Roi du Cambodge

DECERNONS
à titre posthume

Monsieur le Professeur Pierre-André Lablaude,
la Grand'Croix de l'Ordre Royal du Sahamétrei,
en témoignage de Notre plus haute considération.

Norodom Sihamoni

ពាក្យ-១៥០៥-៥២០
ចាងប្រជាប់ព្រះរាជលាក្សកវេយ

Fait au Palais Royal, le 1 Août 2018



កម្មវិធីអប់រំបេតិកភណ្ឌក្នុងតំបន់អង្គរបង្កើនការយល់ដឹងនិងក្តីស្រឡាញ់របស់យុវជន ចំពោះមរតកវប្បធម៌ជាតិកាន់តែខ្លាំង!

ផ្សាយនៅថ្ងៃទី ០៦ ខែ សីហា ឆ្នាំ២០១៨

ក្នុងដំណើរការអស់រយៈពេល៣ខែកន្លងមកនេះ កម្មវិធីអប់រំយុវជនបេតិកភណ្ឌអង្គរ ក្រោមកិច្ចសហការរវាងអាជ្ញាធរជាតិអប្សរា ជាមួយនឹងអង្គការគាំពារកេរ្តិ៍មរតក មជ្ឈមណ្ឌលយុវជនជាតិកម្ពុជា និងវិស័យឯកជន បានផ្លាស់ប្តូរឥរិយាបថផ្នត់គំនិត ក្តីស្រឡាញ់ដល់យុវជនស្មគ្រចិត្តក្នុងវិស័យនេះគួរឱ្យកត់សម្គាល់។

ក្នុងដំណើរទស្សនកិច្ចទៅកាន់ប្រាសាទបាតជុំ នាថ្ងៃទី០៦ សីហា ២០១៨ ដើម្បីរៀនអំពីការចុះបញ្ជីសារពើភណ្ឌវត្ថុបុរាណ និងរបៀបនៃការគូសប្តង់បាតប្រាសាទ **លោក អ៊ុក សុធា** នាយកមជ្ឈមណ្ឌលយុវជនជាតិកម្ពុជារបស់ក្រសួងអប់រំ យុជន និងកីឡា បានលើកឡើងថា ការងារអប់រំបេតិកភណ្ឌជាផ្នែកមួយដែលក្រសួងបានយកចិត្តទុកដាក់ដល់ក្មេងៗ ពិសេសនៅខេត្តសៀមរាបដែលជាតំបន់ទេសចរណ៍សម្បូរប្រាង្គប្រាសាទ។ គោលដៅគឺដើម្បីតម្រង់ទិសសិក្សានិងផ្តល់ចំណេះដឹងបេតិកភណ្ឌវប្បធម៌ដល់ពួកគេ ឱ្យយល់ដឹងពីសម្បត្តិបេតិកភណ្ឌជាតិ ឱ្យចូលរួម និងយកចំណេះដឹងទៅបម្រើសេដ្ឋកិច្ចគ្រួសាររបស់ពួកគេនាអនាគត។ តាមការសង្កេតរបស់លោកកន្លងមក ការអប់រំនេះបានផ្លាស់ប្តូរឥរិយាបទរបស់ក្មេងៗពីការមិនដឹងអ្វីទាំងអស់ មកជាដឹង ហើយស្រឡាញ់ ចូលចិត្ត និងលះបង់ពេលវេលាដើម្បីចូលរួម ទោះបីជិតឆ្ងាយ និងមានការជំរុញពីមាតាបិតាពួកគេជាខ្លាំងផងដែរ។

លោក ខៀវ ច័ន្ទ គ្រូឧទ្ទេសនៃគម្រោងអប់រំបេតិកភណ្ឌរបស់អាជ្ញាធរជាតិអប្សរា បានឱ្យដឹងថា នៅក្នុងខែទី៣នេះ យើងបានបង្រៀនយុវសិស្សស្មគ្រចិត្តអំពីទ្រឹស្តីនិងការអនុវត្តជាក់ស្តែងលើការចុះបញ្ជីសារពើភណ្ឌវត្ថុបុរាណនិងរបៀបនៃការគូសប្តង់បាតប្រាសាទ។ កិច្ចការនេះ ធ្វើឡើងដើម្បីបង្កើនចំណេះដឹងក្នុងការសង្កេត ការគូសប្តង់ កត់ត្រារបាយការណ៍យ៉ាងលម្អិតទៅលើអ្វីដែលពួកគេបានឃើញ និងចេះពីរបៀបវាស់វែងប្រាសាទឱ្យបានច្បាស់លាស់ ជាជំនួយក្នុងការសិក្សាស្រាវជ្រាវបានល្អប្រសើរ។

យុវជន ម៉ម ម៉ាច ជាសិស្សថ្នាក់ទី១១A នៃវិទ្យាល័យនគរធំ បានចាប់អារម្មណ៍ថា ក្រោយចូលជាយុវជនបេតិកភណ្ឌ គឺខ្លួនបានយល់ដឹងច្រើនមរតកវប្បធម៌ជាតិ ពិសេសការស្រាវជ្រាវដោយផ្ទាល់នៅតាមភូមិសាស្ត្រ មានប្រាសាទបន្ទាយក្តីនិងឡតានី។ ក្រៅពីនោះក៏ចេះពីរបៀបសាកសួរព័ត៌មានក្នុងពិធីបុណ្យផ្សេងៗ ការចងក្រងព័ត៌មាន និងបានយល់ដឹងច្បាស់ពីពិធីបុណ្យនិងប្រវត្តិសាស្ត្រនៃប្រាសាទដែលធ្លាប់ដឹងពីមុនមិនសូវច្បាស់។

យុវតី គីម នឹង មកពីវិទ្យាល័យនគរធំដែរនោះ បានឱ្យដឹងថា មូលហេតុដែលចូលជាយុវជនបេតិកភណ្ឌ គឺព្រោះចង់យល់ដឹងពីសម្បត្តិដូនតានិងពិធីផ្សេងៗដែលនៅសេសសល់ក្នុងតំបន់អង្គរ ហើយក៏ចង់ចេះចង់ដឹងខ្លួនឯងផង។ ក្នុងការសិក្សានេះ គឺមានការលំបាកបន្តិចពេលរៀនទ្រឹស្តី វាស្មុគ្រស្មាញ តែពេលអនុវត្តមិនជាលំបាកទេ។ បើប្រៀបធៀបកាលពីមុននិងក្រោយពេលចូលជាយុវជនបេតិកភណ្ឌ គឺប្លែកជាខ្លាំងសម្រាប់ប្អូន ព្រោះកាលពីមុនពេលចូលប្រាសាទ គឺមិនដឹងមើលអ្វីឡើយ ហើយក៏មិនស្គាល់ថាវត្ថុនៅក្នុងប្រាសាទគេធ្វើតំណាងឱ្យអ្វី ហើយពេលក្នុងភូមិស្រុកធ្វើពិធីបុណ្យអ្វីមួយក៏សូវចាប់អារម្មណ៍ដែរ តែពេលនេះទាំងពេលចូលប្រាសាទនិងមានពិធីបុណ្យក្នុងភូមិ គឺតែងតែចាប់អារម្មណ៍ថាមានអ្វីដែលសំខាន់គេធ្វើដើម្បីអ្វី មានតាំងពីពេលណា វាសំខាន់បែបម៉េចក្នុងការរស់នៅនិងមនុស្សជាតិ៕






កម្មវិធីអប់រំបេតិកភណ្ឌកុមារ បង្កើនអាំពីការយល់ដឹង ការចូលរួម និងការស្រឡាញ់មរតកវប្បធម៌

ផ្សាយនៅថ្ងៃទី ០៧ ខែ សីហា ឆ្នាំ២០១៨

អាជ្ញាធរជាតិអប្សរាបានសហការជាមួយអង្គការគាំពារកេរមរតក មជ្ឈមណ្ឌលជាតិយុវជនកម្ពុជា និងសប្បុរសជននៅក្នុងខេត្តសៀមរាប បើកវគ្គបណ្តុះបណ្តាលស្តីអំពីកម្មវិធីអប់រំបេតិកភណ្ឌដល់កុមារនៅសាលាសិក្សាស្រះស្រង់ចាប់ពីថ្នាក់ទី៥ ដល់ទី៦។ កម្មវិធីបណ្តុះបណ្តាលនេះ ក្រៅពីបង្រៀនទ្រឹស្តីនៅក្នុងថ្នាក់ ក៏មានកម្មសិក្សានៅតាមរមណីយដ្ឋានផ្ទាល់ដូចជាប្រាសាទ សារមន្ទីរ ពិធីផ្សេងៗនៅក្នុងភូមិ និងផ្តល់ចំណេះដឹងតាមរយៈការផាត់ពណ៌ផងដែរ។

លោក ខៀវ ច័ន្ទ គ្រូឧទ្ទេសនៃគម្រោងកុមារបេតិកភណ្ឌពិភពលោកនិងជាអ្នកជំនាញបុរាណវិទ្យានៃអាជ្ញាធរជាតិអប្សរាបានឱ្យដឹងនៅក្នុងកម្មសិក្សានៅប្រាសាទបន្ទាយក្តីកាលពីថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៨ ថា ការចុះសិក្សាដល់ទីតាំងគឺមានគោលបំណងបង្រៀនសិស្សឱ្យស្គាល់ពីរចនាសម្ព័ន្ធប្រាសាទងាយៗ យល់អំពីមូលដ្ឋានគ្រឹះនៃកេរ្តិ៍មរតក យល់ពីអរិយធម៌

ខ្មែរនៅសម័យអង្គរតាមប្រាសាទនីមួយៗ ស្គាល់ទីតាំងភូមិសាស្ត្រច្បាស់ បណ្តុះគំនិតស្រឡាញ់ និងបណ្តុះចិត្តឱ្យពួកគេចូលរួមការការពារឱ្យបានគង់វង្ស។

លោកបន្ថែមថា ពេលនាំពួកគាត់មកប្រាសាទពេលនេះមិនរំពឹងថាពួកគាត់ទទួលបានចំណេះដឹងទាំងស្រុងនោះទេ ដូច្នេះត្រូវសម្រួលពាក្យខ្លះៗមកជាពាក្យងាយៗ ដើម្បីឱ្យស្តាប់បានដោយមិនបានពន្យល់ លម្អិតទៅលើប្រវត្តិសិល្បៈវែងឆ្ងាយ គ្រាន់តែពន្យល់ប្រវត្តិភូមិសាស្ត្រ ប្រវត្តិសាស្ត្រ បកស្រាយឈ្មោះប្រាសាទ សម័យកាល និងឈ្មោះស្តេច និងរចនាសម្ពន្ធរបស់ប្រាសាទរួមមាន កំពែង ខ្លោងទ្វារ កសិន្ទ សរសរ សរសរពេជ្រ សរសរផ្គោប ផ្តែរ ព្រះពន្លាជាដើម ដែលធ្វើឱ្យពួកគេឆាប់យល់ ចេះចាំបាន។

កុមារី ជា គុណហ៊ីង រៀនថ្នាក់ទី៥ ជាកុមារបេតិកភណ្ឌ បានឱ្យដឹងថា ក្រោយពីបានចូលរួមសិក្សាវគ្គបណ្តុះបណ្តាលនេះ បានយល់ដឹងច្រើនពីសាសនា និងវប្បធម៌ ជាពិសេសកម្មវិធីបុណ្យប្រពៃណីក្នុងស្រុកភូមិផ្ទាល់ និងមានការផ្លាស់ប្តូរឥរិយាបថ ពេលមកដល់ប្រាសាទ មិនស្រែកឡូឡា មិនប្រឡែងគ្នា មិនចោលសំរាមផ្តេសផ្តាស មិនអង្គុយលើថ្ម លើបង្គាន់ដៃ មិនគូសលើថ្ម មិនយកដៃទៅប៉ះពាល់លើចម្លាក់ ឬបដិមាឡើយ។

កុមារ ធី ជាវ រៀនថ្នាក់ទី៥ ជាកុមារបេតិកភណ្ឌបានឱ្យដឹងថា ប្អូនមានចិត្តស្រលាញ់ប្រាង្គប្រាសាទរបស់ដូនតា និងមានបំណងចូលរួមថែរក្សាឱ្យស្ថិតនៅឱ្យបានគង់វង្ស។ កុមារ ជាវ បានបញ្ជាក់ថា ក្រោយពេលលោកគ្រូបានធ្វើបទបង្ហាញប្រាប់ដល់កុមារទាំងអស់ ខ្លួនទទួលបានចំណេះដឹងថ្មីៗដែលមិនធ្លាប់ដឹងពីមុន ដូចជាប្រវត្តិប្រាសាទ រឿងព្រេងទាក់ទងនឹងប្រាសាទជាដើម ជាពិសេសការហៅឈ្មោះរចនាសម្ពន្ធរបស់ប្រាសាទតាំងពីផ្លូវចូលប្រាសាទរហូតដល់ក្នុងប្រាសាទ។ ចំពោះការលំបាកកន្លងមកមានការជួបការលំបាកខ្លះៗ ដូចជាការប្រើប្រាស់ពាក្យដែលជាពាក្យបច្ចេកទេសជាដើម៕





សេចក្តីជូនដំណឹងស្តីពី ការកាត់សម្អាតដើមឈើងាប់ដែលចាក់ជូលរលំ និងកាត់ក្រឹមែកឈើ ដែលមានហានិភ័យខ្ពស់នៅតាមបរិវេណប្រាសាទ ក្នុងមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី ០៨ ខែ សីហា ឆ្នាំ២០១៨



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA
លេខ.ឯ.ជ.ណ/ប.សជណ
១៨

សេចក្តីជូនដំណឹង
ស្តីពី
ការកាត់សម្អាតដើមឈើងាប់ដែលចាក់ជូលរលំ និងកាត់ក្រឹមែកឈើ
ដែលមានហានិភ័យខ្ពស់នៅតាមបរិវេណប្រាសាទ ក្នុងមណីយដ្ឋានអង្គរ

អាជ្ញាធរជាតិអប្សរា សូមជូនដំណឹងដល់ស្ថាប័ន សមត្ថកិច្ចពាក់ព័ន្ធ ភ្ញៀវជាតិ-អន្តរជាតិ មគ្គទ្ទេសក៍ទេសចរណ៍ ព្រមទាំងសាធារណជនទាំងអស់មេត្តាជ្រាបថា ដើម្បីធានាដល់សុវត្ថិភាពភ្ញៀវទេសចរ សាធារណជនក៏ដូចជាដើម្បីលើកកម្ពស់សោភ័ណភាពនៅតាមដងផ្លូវ និងនៅតាមបរិវេណប្រាសាទ ក្នុងតំបន់រមណីយដ្ឋានអង្គរ និងតំបន់ដែលគ្រប់គ្រងដោយអាជ្ញាធរជាតិអប្សរា នាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាន នៃអាជ្ញាធរជាតិអប្សរា នឹងកាត់សម្អាតដើមឈើងាប់ដែលបាក់ដូលរលំ និងកាត់ក្រឹមែកឈើ តាមទីតាំងនានាដូចខាងក្រោម៖

-កាត់សម្អាតដើមឈើងាប់ និងដូលនៅក្នុងកសិណទឹកប្រាសាទព្រះខ័ន។
-កាត់ក្រឹមែកឈើចំនួន **១០ដើម** ដែលមានហានិភ័យខ្ពស់ ស្ថិតនៅក្នុងបរិវេណប្រាសាទព្រះខ័ន។

ការងារនេះ នឹងចាប់ផ្តើមអនុវត្តចាប់ពីថ្ងៃទី ០២ ខែ សីហា ឆ្នាំ២០១៨ រហូតដល់បញ្ចប់ការងារ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមស្ថាប័ន សមត្ថកិច្ចពាក់ព័ន្ធ ភ្ញៀវជាតិ-អន្តរជាតិ មគ្គទ្ទេសក៍ទេសចរណ៍ ព្រមទាំងសាធារណជនទាំងអស់ មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃពុធ ១២ កាត ខែ ឧត្តិយាកាត ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
សៀមរាប ថ្ងៃទី ០៨ ខែ សីហា ឆ្នាំ២០១៨
អគ្គនាយក ជ.ណ.

ស៊ុ ម៉ាប់

ចម្លងជូន៖
-សាលាខេត្តសៀមរាប
-មន្ទីរបរិស្ថានខេត្តសៀមរាប
-មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តសៀមរាប
-អង្គភាពនគរបាលការពារបេកិកភណ្ឌប្រចាំខេត្តសៀមរាប
-ស្នាក់ការតំបន់ការពារទេសភាពអង្គរ
-សមាគមមគ្គទ្ទេសក៍ទេសចរណ៍ទាំងអស់ប្រចាំខេត្តសៀមរាប
"ដើម្បីជូនជ្រាប និងសហការ"
-ប៉ូលីសទេសចរណ៍
-គ្រប់នាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធរបស់អាជ្ញាធរអប្សរា
"ដើម្បីមុខការ និងសហការ"
-ឯកសារ-កាលប្បវត្តិ

លេខទូរស័ព្ទទំនាក់ទំនង:លោក គង់ សុវណ្ណារិទ្ធ 012-354-630, លោក ទៀន សុធី 010-304-089,088-9522-5059,លោក ហ៊ា ហ៊ាត 086 600 740

ភ្ជាប់ៈ
មហាវិទ្យាបាត់ឌ្ធរស្ថ្ថ លេខ៤១ សង្កាត់មិត្តភាព ខណ្ឌដមកា
ទូរសព្ទ/ទូរសារ៖ ០២៣ ២១៥ ៥៥១/០២៣ ២១៥ ៥៥១

អាជ្ញាធរជើម្បីការពារមណីយដ្ឋាននិងរៀបចំតំបន់អង្គរ
Email: info@apsaraauthority.gov.kh
Website: http//www.apsaraauthority.gov.kh

សៀមរាប:
ភូមិបង្កោង ឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប
ទូរសព្ទ/ទូរសារ៖ ០៦៣ ៧៦៥ ៥៧៧/០៦៣ ៧៦៥ ៥៧៦

សកម្មភាពជួសជុលប្រចាំថ្ងៃរបស់ក្រុមការងារអក្តីសនីអាជ្ញាធរជាតិអប្សរាកំពុងជួសជុលភ្លើងបំភ្លឺតាម ជងផ្លូវមួយចំនួនផាងនៅក្នុងនិងនៅខាងក្រៅរមណីយដ្ឋានអង្គរជូចជា ផ្លូវ៦០ម៉ែត្រ ផ្លូវកូម៉ែ ផ្លូវបាឡាលជឺប្ពោលផៅចំបក់កំណប់ និងផ្លូវជុំវិញអង្គភាពនគរចាលការពារបេតិកភ័ណ្ឌ

ផ្សាយនៅថ្ងៃទី ០៩ ខែ សីហា ឆ្នាំ២០១៨









អាជ្ញាធរជាតិអប្សរាបើកទគ្គអប់រំយុវជនស្ម័គ្រចិត្តការពារបេតិកភណ្ឌមកពី១០ប្រទេសផ្សេងគ្នា

ផ្សាយនៅថ្ងៃទី ០៩ ខែ សីហា ឆ្នាំ២០១៨

ចំណែកសហការលើការរៀបចំអប់រំបេតិកភណ្ឌនេះ។ លោកបញ្ជាក់ថា យុវជនស្ម័គ្រចិត្តសហភាពសហព័ន្ធយុវជនកម្ពុជា បានរួមចំណែកជំរុញឱ្យយុវជនវ័យក្មេងចូលរួមក្នុងវិធីអប់រំបេតិកភណ្ឌ ជាក់ស្តែងកម្មវិធីអង្គរសង្ក្រានដែលមានការចូលរួមពីយុវជន ដែលបានចូលរួមកម្មវិធីបេតិកភណ្ឌ បង្ហាញបេតិកភណ្ឌ និងចូលរួមថែរក្សាបេតិកភណ្ឌ។

ឯកឧត្តម ហង់ ពៅ អគ្គនាយករង និងជាតំណាង**ឯកឧត្តមបណ្ឌិត ស៊ុំ ម៉ាប់** អគ្គនាយកអាជ្ញាធរជាតិអប្សរា មានប្រសាសន៍ថា សិក្ខាកាមដែលមកសិក្សានៅពេលនេះពិតជាបានស្គាល់ខ្លះៗមិនខាន អំពីវប្បធម៌ និងអារ្យធម៌របស់ខ្មែរ ព្រោះអង្គរគឺជាដែនដីនៃវប្បធម៌។ ឯកឧត្តមសង្ឃឹមថា សិក្ខាកាមទាំងអស់នឹងទទួលបាននូវចំណេះដឹង និងបទពិសោធន៍ល្អៗពីការចែករំលែកនូវទ្រឹស្តី និងមេរៀនស្តីអំពីវប្បធម៌ អារ្យធម៌ខ្មែរ និងការអភិរក្សតំបន់អង្គរ តាមរយៈអ្នកជំនាញរបស់អាជ្ញាធរជាតិអប្សរានៅរយៈពេលប៉ុន្មានថ្ងៃខាងមុខនេះ។

សូមបញ្ជាក់ថាសិក្ខាកាម១៥រូប មកពីប្រទេស Austria, France, Korea, Lebanon, Tunisia, China, Czech Republic, India, Philippines និងមានការចូលរួមពីយុវជនថ្នាក់ជាតិមាន១០រូប ក្នុងនោះ៥រូបមកពីសហភាពសហព័ន្ធយុវជនកម្ពុជា ៣រូបមកពីអាជ្ញាធរជាតិអប្សរា ១រូបមកពីអាជ្ញាធរជាតិព្រះវិហារ និង១រូបមកពីអាជ្ញាធរជាតិសំបូរព្រៃគុក សរុបចំនួន២០នាក់។

នេះជាលើកទីពីរហើយដែលអាជ្ញាធរជាតិអប្សរាបានបើកវគ្គបណ្តុះបណ្តាលដូចគ្នានេះឡើងនៅឆ្នាំ២០១៦ ដើម្បីបង្កើនចំណេះយុវជន និងបណ្តុះគំនិតយុវជនឱ្យមានចិត្តស្រលាញ់បេតិកភណ្ឌ និងចូលរួមថែរក្សានូវតម្លៃបេតិកភណ្ឌពិភពលោក ទោះបីជាជាតិសាសន៍អ្វីក៏ដោយ៕









តំណាង TripAdvisor ថាអង្គរវត្តពិតជាស័ក្តិសមចំពោះពានរង្វាន់សំណង់ប្រវត្តិសាស្ត្រដ៏អស្ចារ្យបំផុតក្នុងឆ្នាំ២០១៨

ផ្សាយនៅថ្ងៃទី ១០ ខែ សីហា ឆ្នាំ២០១៨

នៅមុខប្រាសាទអង្គរវត្តនៅរសៀលថ្ងៃទី៩ ខែសីហា ឆ្នាំ២០១៨ ក្រសួងទេសចរណ៍ សហការជាមួយអាជ្ញាធរជាតិអប្សរា និងរដ្ឋបាលខេត្តសៀមរាប បានរៀបចំពិធីប្រគល់ និងទទួលពានរង្វាន់ពីតំណាងទីភ្នាក់ងារប្រឹក្សាយោបល់លើការធ្វើដំណើរ (TripAdvisor) ដែលប្រាសាទអង្គរវត្តជាប់លេខ១ ជាសំណង់ប្រវត្តិសាស្ត្រដ៏អស្ចារ្យបំផុតក្នុងចំណោមសំណង់ប្រវត្តិសាស្ត្រល្បីៗលើពិភពលោកសម្រាប់ឆ្នាំ២០១៨។ តំណាង TripAdvisor បានលើកឡើងថា ប្រាសាទអង្គរវត្តពិតជាមានតម្លៃដ៏មហាសាល និងមានភាពអស្ចារ្យបំផុត ដែលស័ក្តិសមនឹងទទួលបានពានរង្វាន់នេះ។

ក្នុងពិធីប្រគល់ និងទទួលពានរង្វាន់នៅបរិវេណមុខប្រាសាទអង្គរវត្ត តំណាង TripAdvisor **លោកស្រី សារ៉ា ម៉ាច្យស៍** បានលើកឡើងថា ការផ្តល់ចំណាត់ថ្នាក់លេខ១ដល់ប្រាសាទអង្គរវត្តរបស់កម្ពុជា ជាសំណង់ប្រវត្តិសាស្ត្រដ៏អស្ចារ្យបំផុតសម្រាប់ឆ្នាំ២០១៨នេះ ធ្វើឡើងតាមរយៈការស្រង់មតិរយៈពេល១២ខែ លើចំណាប់អារម្មណ៍ និងទស្សនៈរបស់អ្នកទេសចរជាប់លាននាក់ជុំវិញពិភពលោកកាលពីថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៨។ លោកស្រីបន្ថែមថា ចំណុចពិសេសដែលលោកស្រីចាប់អារម្មណ៍លើប្រាសាទអង្គរវត្តនោះ គឺសំណង់ស្ថាបត្យកម្ម ទិដ្ឋភាពថ្ងៃរះ និងថ្ងៃលិច ដែលមានពណ៌មាសដិះរស្មីភ្លឺចែងចាំងប៉ះសំណង់ប្រាសាទ ដែលធ្វើឱ្យអង្គរវត្តមានភាពអស្ចារ្យក្នុងអារម្មណ៍ភ្ញៀវទេសចរគ្រប់រូប។

ឯកឧត្តម សុខ សង្ហារ អគ្គនាយករងអាជ្ញាធរជាតិអប្សរា ទទួលបន្ទុកនាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍អង្គរ បានបង្ហាញសុទិដ្ឋិនិយមតាមរយៈការទទួលបានពានរង្វាន់នេះ ដែលនឹងធ្វើឱ្យទេសចរកាន់តែច្រើនទៀត ចង់ស្គាល់ និងធ្វើដំណើរមកទស្សនាប្រាសាទអង្គរវត្ត។ ជាមួយគ្នានេះ ឯកឧត្តមក៏បានរម្លឹកពីការងារ និងការខិតខំប្រឹងប្រែងជាច្រើនរបស់អាជ្ញាធរជាតិអប្សរា លើការងារអភិរក្ស និងអភិវឌ្ឍន៍រមណីយដ្ឋានអង្គរតាំងពីពេលបង្កើតស្ថាប័នអាជ្ញាធរជាតិអប្សរា រហូតមកដល់ទល់នឹងបច្ចុប្បន្ន។

រដ្ឋមន្ត្រីក្រសួងទេសចរណ៍ **ឯកឧត្តម ថោង ខុន** មានប្រសាសន៍ថា ការរីកចម្រើននៃវិស័យទេសចរណ៍កម្ពុជា ពិតជាមិនអាចកាត់ផ្តាច់ចេញពីការបង្កើនភាពទាក់ទាញរបស់កម្ពុជា ជាគោលដៅទេសចរណ៍ដ៏ទាក់ទាញប្រកបដោយគុណភាពទាំងកម្រិតតំបន់ និងពិភពលោក ព្រមជាមួយការដឹកនាំប្រកបដោយភាពវៃឆ្លាត។ ឯកឧត្តមបន្ថែមថា ក្រសួងទេសចរណ៍

ប្តេជ្ញាចិត្តបន្តដឹកនាំវិស័យទេសចរណ៍កម្ពុជាឱ្យកាន់តែរីកចម្រើន ប្រកបដោយនិរន្តរភាព និងការទទួលខុសត្រូវខ្ពស់ ហើយអំពាវនាវដល់ភាគីពាក់ព័ន្ធ ចូលរួមដើម្បីជំរុញការផ្សព្វផ្សាយវិស័យទេសចរណ៍កម្ពុជា ឱ្យកាន់តែខ្លាំងក្លាបន្ថែមទៀត។









អាជ្ញាធរជាតិអប្សរាក្រោធនឹងស្ថាបនាកំណាត់ផ្លូវអន្តរយ្យុងយូឱ្យរួចរាល់នៅក្នុងឆ្នាំ២០១៨

ផ្សាយនៅថ្ងៃទី ១០ ខែ សីហា ឆ្នាំ២០១៨

ផ្លូវអង្គរយ្យុងយូឬផ្លូវ៦០ម៉ែត្រ បានស្ថាបនាឡើងកាលពីឆ្នាំ២០០២ ក្រោមជំនួយឧបត្ថម្ភរបស់ទីភ្នាក់ងារបារាំង (ADF) ហើយនៅឆ្នាំ២០០៦ អាជ្ញាធរជាតិអប្សរាក៏បានចំណាយថវិកាមួយចំនួនដើម្បីធ្វើផ្លូវគ្រួសក្រហមសងខាងផ្លូវ និងបន្តសង់ផ្លូវមកខាងកើតហួសរង្វង់មូលចំនួន៤គីឡូម៉ែត្របន្ថែមទៀត ដើម្បីអបអរសាទរព្រឹត្តិការណ៍វប្បធម៌អង្គរយ្យុងយូ ដែលជាកិច្ចសហប្រតិបត្តិការរវាងតំបន់បេតិកភណ្ឌចំនួន២ គឺអង្គរនិងយ្យុងយូ។ ក្រោយមកនៅឆ្នាំ២០១០ អាជ្ញាធរជាតិអប្សរាក៏បានស្ថាបនាផ្លូវ៦០ម៉ែត្រចំនួន៩.៦៧៩ម៉ែត្រ ចាប់ពីផ្លូវបំបែកត្រាំនាគ រហូតដល់បុរីរដ្ឋបាលខេត្តសៀមរាប បច្ចុប្បន្នជាទីស្នាក់ការអាជ្ញាធរជាតិអប្សរា។

បើគិតមកដល់ពេលនេះ រយៈពេល១៦ឆ្នាំហើយដែលផ្លូវ៦០ម៉ែត្របានបម្រើផលប្រយោជន៍ដល់ប្រជាជននិងទេសចរទាំងឆ្លងកាត់និងដឹកជញ្ជូនទំនិញ។ ១៦ឆ្នាំនេះ ក៏បានធ្វើឱ្យផ្លូវខូចទ្រង់ទ្រាយ ទ្រុឌទ្រោមដោយចៀសមិនផុត តែអាជ្ញាធរជាតិអប្សរាក៏តែងយកចិត្តទុកដាក់ជួសជុល ថែទាំជាប្រចាំផងដែរ។ **លោក ហេង គឹមឡេង** ប្រធាននាយកដ្ឋានទ្រទ្រង់បច្ចេកទេសនិងអន្តរវិស័យនៃអាជ្ញាធរជាតិអប្សរា ក៏បានឱ្យដឹងថា៖ សម្រាប់ឆ្នាំ២០១៨ អាជ្ញាធរជាតិអប្សរាគ្រោងនឹងស្ថាបនានិងពង្រីកកំណាត់ផ្លូវនេះឱ្យរួចរាល់ទាំងស្រុងចំនួន៨៦០ម៉ែត្រ ពីស្ពាននាគ រហូតដល់រង្វង់មូល ដោយចាប់ដំណើរការនៅខែសីហានេះហើយ។

លោក គឹមឡេង បន្តថា ក្រុមការងារនឹងពង្រីកទំហំទទឹងផ្លូវរហូតដល់១០ម៉ែត្រ (ផ្លូវចាស់៨ម៉ែត្រ) ដោយអ៊ុតកៅស៊ូ ហើយគូសគំនូសបែងចែកផ្លូវសងខាងចំនួន១.៥០ម៉ែត្រ សម្រាប់ម៉ូតូកង់ និង៧ម៉ែត្រសម្រាប់រថយន្តទៅមក។ ផ្លូវនេះជាច្រកធ្វើដំណើរយ៉ាងសំខាន់ក្នុងការចេញចូលក្រុងសៀមរាប សារមន្ទីរ ផ្សារកណ្តាល កន្លែងលក់សំបុត្រទស្សនាអង្គរ និងតំបន់ទេសចរណ៍ផងដែរ ហើយអាជ្ញាធរជាតិអប្សរាក៏សូមអភ័យទោសដល់សាធារណជន ដែលមានការយឺតយ៉ាវក្នុងការជួសជុលផ្លូវនេះឱ្យបានល្អប្រសើរទាន់ពេលវេលា។

សូមបញ្ជាក់ដែរថា គម្រោងជួសជុលផ្លូវក្នុងឧទ្យានអង្គរនាឆ្នាំ២០១៨ ក្រៅពីផ្លូវ៦០ម៉ែត្រ ក៏មានការជួសជុលផ្លូវមិត្តភាពកម្ពុជាកូរ៉េពីស្វាយធំមកផ្សារព្រះដាក់ចំនួន៧៥០ម៉ែត្រ និងផ្លូវពីព្រលានយន្តហោះដល់មុខប្រាសាទអង្គរវត្តផងដែរ។ ចំពោះគម្រោងឆ្នាំ២០១៩ នឹងបញ្ចប់ការជួសជុលផ្លូវនៅវង់ធំទាំងអស់។ លើសពីនោះ ចាប់ពីឆ្នាំ២០២០ទៅ អាជ្ញាធរជាតិអប្សរានឹងបង្វែរការជួសជុលកែលម្អផ្លូវមួយចំនួននៅក្នុងសហគមន៍តំបន់អង្គរថែមទៀត។ បើគិតមកដល់ពេលនេះ ផ្លូវក្នុងឧទ្យានអង្គរ ជួសជុលនិងសាងសង់បានចំនួន២០០គីឡូម៉ែត្រហើយ ទាំងក្រាលកៅស៊ូ ក្រាលគ្រួសក្រហម និងផ្លូវលំ ក្រោមថវិកាជាតិនិងជំនួយបរទេស៕









អាជ្ញាធរអប្សរាឃាត់ដើមក្រញូងដែលចោរលួចកាប់ទៅរក្សាទុកនៅកន្លែងមានសុវត្ថិភាព

ផ្សាយនៅថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០១៨

ហេតុការណ៍មួយបានកើតឡើង ដោយជនមិនស្គាល់មុខបានលួចកាប់ដើមគ្រញូងមួយដើម ស្ថិតក្នុងរមណីយដ្ឋានអង្គរ។ ភ្លាមៗ ក្រោយទទួលបានដំណឹងពីអាជ្ញាធរមូលដ្ឋាន អាជ្ញាធរជាតិអប្សរា បានធ្វើការយ៉ាងជិតស្និទ្ធជាមួយមន្ទីរបរិស្ថានខេត្តសៀមរាប និងបានសម្រេចដកហូត ដឹកជញ្ជូនឈើដែលចោរកាប់ផ្តួលនោះ មករក្សាទុកនៅទីមានសុវត្ថិភាព។

កូនឈើគ្រញូងមួយដើម ត្រូវបានជនមិនស្គាល់មុខ បានលួចកាប់នៅយប់ថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៨ ស្ថិតក្នុងភូមិសាស្ត្រភូមិគោកតាចាន់ សង្កាត់គោកចក ក្រុងសៀមរាប។ ប្រជាពលរដ្ឋដែលបានដឹងហេតុការណ៍នេះ បានផ្តល់ដំណឹងភ្លាមៗទៅអាជ្ញាធរជាតិអប្សរាដើម្បីអន្តរាគមន៍ និងទប់ស្កាត់មិនឱ្យមានការដឹកជញ្ជូនចេញ។

បុគ្គលិកនាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាន នៃអាជ្ញាធរជាតិអប្សរា **លោក ស៊ិន ពិសី** បានឱ្យដឹងថា បន្ទាប់ពីមានការសម្របសម្រួលពីភាគីពាក់ព័ន្ធ គ្រញូងដែលគេលួចកាប់នោះ បានយកទៅរក្សាទុកនៅស្នាក់ការតំបន់ការពារឧទ្យានអង្គររបស់មន្ទីរបរិស្ថានខេត្តសៀមរាប នៅថ្ងៃទី១០ ខែសីហា។ លោករម្លឹកថា ក្រោយដឹងហេតុការណ៍នៅយប់ថ្ងៃទី៨មកនោះ ភាគីពាក់ព័ន្ធបានសហការយ៉ាងយកចិត្តទុកដាក់ ដោយបានប្រើកម្លាំងយាមល្បាតជាប់រហូត ព្រោះបារម្ភខ្លាចក្រុមជនខិលខូចចូលមកដឹកជញ្ជូនឈើដែលកាប់រួច។

បើតាមការបញ្ជាក់របស់ **លោក ស៊ិន ពិសី** ដដែល គ្រញូងដែលត្រូវគេលួចកាប់នោះមានទំហំមិនធំប៉ុន្មានទេ គឺមានមុខកាត់ជិត ៤តឹក ឯបណ្តោយជាង ២ម៉ែត្រប៉ុណ្ណោះ (កន្លែងដែលមានតម្លៃ)។ លោកបន្ថែមថា ភូមិសាស្ត្រដែលជនមិនស្គាល់មុខលួចកាប់នោះ គឺចុះពីផ្លូវកៅស៊ូប្រមាណ ១០ម៉ែត្រប៉ុណ្ណោះ តែវានៅជាប់ឆ្ងាយពីផ្ទះអ្នកភូមិបន្តិច ណាមួយយប់ដែលកាប់នោះ មានភ្លៀងធ្លាក់ពេញមួយយប់ផងដែរ ដែលជាឱកាសសម្រាប់ក្រុមអ្នករកស៊ីគ្រញូង៕






សហគមន៍ទេសចរណ៍បន្ទាយស្រី មានទាំងទេសភាពស្អាត និងការក្សាបាននូវការអភិរក្សរមណីយដ្ឋានបុរាណ

ផ្សាយនៅថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០១៨

សហគមន៍ទេសចរណ៍បន្ទាយស្រី ជារមណីយដ្ឋានធម្មជាតិមានទីតាំងនៅខាងជើងជាប់ប្រាសាទបន្ទាយស្រី។ នៅទីនេះទេសចរភាគច្រើន ច្រើនរំលងបើមិនមានពេលវេលាគ្រប់គ្រាន់ ឯទេសចរជាតិក៏ដូចគ្នាដែរ ព្រោះមិនសូវមានអ្នកដឹង។

អាជ្ញាធរជាតិអប្សរាសហការជាមួយគម្រោង ACHA របស់ប្រទេសញូវហ្សីឡែនបានអភិរក្ស និងកែច្នៃត្រពាំងបុរាណ ឈ្មោះ «ស្រែព្រៃ» ឱ្យក្លាយជាសហគមន៍ទេសចរណ៍ដែលមានឈូករីករហង់ មានទេសភាពធម្មជាតិដ៏ស្រស់បំព្រងលម្អដោយទឹកត្រពាំងថ្លាយង់ និងភ្នំដីខៀវស្រងាត់នាទិសខាងកើត។ ទីនេះស័ក្តិសមបំផុតសម្រាប់អ្នកស្រឡាញ់ធម្មជាតិ មានខ្យល់អាកាសបរិសុទ្ធ មានភាពស្ងប់ស្ងាត់ក្នុងការផ្ទង់អារម្មណ៍ មានម្ហូបអាហាររបៀបអ្នកស្រុក និងសកម្មភាពប្រពៃណីផ្សេងៗទៀត។

លោក សំ កុសល មន្ត្រីនាយកដ្ឋានរៀបចំដែនដីនិងគ្រប់គ្រងលំនៅដ្ឋានក្នុងឧទ្យានអង្គរ បានឱ្យដឹងថា សហគមន៍បន្ទាយស្រីបង្កើតឡើងនៅឆ្នាំ២០១៣ មានសមាជិកសហគមន៍៣៥រូប គឺគណៈកម្មការចំនួន៦រូប និងសមាជិក២៩រូប ឆ្លងកាត់តាមរយៈការបោះឆ្នោតជ្រើសតាំង។ ពួកគាត់ជាអ្នកភូមិ មកពីភូមិបន្ទាយស្រីនិងភូមិទួលក្រឡាញ់។

លោក កុសល បន្តថា គម្រោងនេះបង្កើតឡើង ដើម្បីបង្កើនចំណូលបន្ថែមលើមុខរបរប្រចាំថ្ងៃរបស់ប្រជាជនក្នុងតំបន់ ហើយចង់ឃើញប្រជាជនទាំងពីរភូមិមានការរីកចម្រើនតាមរយៈសហគមន៍នេះ ដែលស្របតាមគោលការណ៍របស់អាជ្ញាធរជាតិអប្សរាក្នុងការលើកស្ទួយកម្រិតជីវភាពប្រជាជនឱ្យល្អប្រសើរ។ បន្ថែមពីនោះ ក្រៅពីទាញប្រយោជន៍ពីសហគមន៍នេះ អាជ្ញាធរជាតិអប្សរានិងសហគមន៍ ក៏បានរួមគ្នាអភិរក្ស ថែរក្សាជីវចម្រុះ មានត្រី សត្វស្លាប សត្វក្នុងទឹក រុក្ខជាតិ នៅក្នុងត្រពាំងបុរាណនេះមិនឱ្យមានការបាត់បង់ឬទទួលរងនូវការបំផ្លាញឡើយ។ មិនតែប៉ុណ្ណោះ ក្រៅពីសមាជិក ទាំង៣៥នាក់ប្រជាជនចំនួនពីរភូមិនេះ ក៏ទទួលបានផលពីសហគមន៍ដោយប្រយោលផងដែរ តាមរយៈការផលិត សិប្បកម្មលក់ និងដាំដុះបន្លែបង្គារសម្រាប់ផ្គត់ផ្គង់សហគមន៍និងលក់ជូនទេសចរ។

លោក ស៊ាម សារឿន ប្រធានសហគមន៍បន្ទាយស្រីបានឱ្យដឹងថា នៅទីនេះមានសេវាកម្មជិះទូកដែលពេញនិយមជាងគេ ជិះរទេះគោ ស្ទូចត្រី ស្ទូងនាក់។ ទេសចរអោចមក១០០ច្រូតស្រូវ និងការរៀបចំអាហារសាមគ្គីរបៀបអ្នកស្រុកបានចំនួន/បអ្នកស្រុកម្សាន្តទីនេះជាលក្ខណៈឯកជន គ្រួសារ និងជាក្រុមក៏បាន ដើម្បីស្វែងយល់ពីការរស់នៅរបៀក ជិះទូកលម្ហែកាយក្នុងត្រពាំង ថតរូបភាពស្អាតៗតាមចំណូលចិត្ត និងពិសាអាហារឆ្ងាញ់ៗ មានតម្លៃសេវាកម្មសមរម្យ។ សហគមន៍ទទួលបានការគាំទ្រច្រើនពីសំណាក់ភ្ញៀវអឺរ៉ុប ចំណែកភ្ញៀវអាស៊ី ពួកគាត់មកត្រឹមថតរូបប៉ុណ្ណោះ។

លោកបន្តទៀតថា តាំងពីចាប់ផ្តើមការងារបញ្ហាលំបាកខ្លះៗដែលជួបប្រទះ គឺនៅរដូវប្រាំង ព្រោះគ្មានទឹក ទេសភាពមិនស្អាត ចំណែកខែវស្សាមិនជាមានបញ្ហាទេ។ ដូច្នេះពួកយើងបានបង្កើនការផ្សព្វផ្សាយតាមមគ្គុទ្ទេសក៍ទេសចរណ៍ សណ្ឋាគារ និងតាមរយៈភ្ញៀវដោយផ្ទាល់ និងការពង្រីកទីតាំង បង្កើនការអភិរក្សសត្វបន្ថែមទៀតដើម្បីទាក់ទាញទេសចរ។ លោកបានសំណូមពរឱ្យមគ្គុទ្ទេសក៍ទេសចរណ៍ សូមជួយណែនាំភ្ញៀវមកកាន់ទីនេះ ពិសេសភ្ញៀវជាតិសូមជួយគាំទ្រទេសចរណ៍សហគមន៍ ព្រោះវានឹងជួយកាត់បន្ថយភាពក្រីក្រដល់ប្រជាជនក្នុងតំបន់ និងរួមចំណែកក្នុងការអភិរក្សរមណីយដ្ឋានបុរាណផងដែរ។

លោក ជានិត ជាអ្នកភូមិបន្ទាយស្រី បានចូលធ្វើការក្នុងសហគមន៍នេះរយៈពេល៤ឆ្នាំមកហើយ ដែលគាត់ជាអ្នកចែវទូក និងមានប្រពន្ធជាអ្នកធ្វើម្ហូបអាហារសម្រាប់ភ្ញៀវ។ លោកលើកឡើងថា «តាមរយៈទេសចរណ៍សហគមន៍ បានធ្វើឱ្យជីវភាពគ្រួសារខ្ញុំធូរធារជាងពីមុន មានលុយកាក់ផ្គង់ផ្គង់គ្រួសារសមរម្យ កូនចៅបានសិក្សារៀនសូត្រ និងមានការងារធ្វើបន្ថែមលើមុខរបរស្រែចម្ការ»។









អ្នកជំនាញកសិកម្មចិនបង្ហាញប្រជាជនភូមិជម្មជាតិរុនតាឯកពីបច្ចេកទេសធ្វើស្រែ ឱ្យទទួលបានផលច្រើន ប្រើពូជតិច និងចំណេញពេលវេលា

ផ្សាយនៅថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០១៩

អ្នកជំនាញកសិកម្មជនជាតិចិននៃគម្រោង Caproc របស់ក្រុមហ៊ុន FORWORD សហការជាមួយអាជ្ញាធរជាតិអប្សរា បានបង្ហាញពីរបៀបធ្វើស្រែឱ្យទទួលបានទិន្នផលខ្ពស់ ចំណេញពេល ប្រើពូជតិច និងកម្លាំងតិច ដល់ប្រជាជនភូមិធម្មជាតិរុនតាឯក កាលពីថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៨។

លោក XIE ZHI GAN អ្នកជំនាញដំណាំស្រូវបាននិយាយថា ការយកបច្ចេកទេសដាំស្រូវមកបង្ហាញ ព្រោះស្រូវជាដំណាំដ៏ធំនៅកម្ពុជា ហើយប្រជាជនភាគច្រើនធ្វើតាមទម្លាប់ បុរាណ ប្រើកម្លាំងមនុស្សនិងពូជច្រើន ហើយបានទិន្នផលតិច។ ដូច្នេះទើបក្រុមការងារមកចែករំលែកអំពីបទពិសោធន៍ក្នុងការធ្វើស្រែដោយចំណាយពូជតិច ចំណេញពេល និងបានទិន្នផលខ្ពស់។

លោក XIE ZHI GAN បន្តទៀតថា វគ្គសិក្សានេះបង្រៀនប្រជាជនអំពីការគ្រវែងសំណាប ការប្រើគ្រឿងយន្ត វិធីថែទាំ និងការការពារដំណាំស្រូវ ដើម្បីទទួលបានទិន្នផលខ្ពស់ ហើយចំណេញពេល និងថវិកាថែមទៀត។ ចំពោះការគ្រវែងសំណាបវាពិតជាថ្មីសម្រាប់ប្រជាជនខ្មែរ តែវាងាយស្រួល លឿន និងបានផលបំផុត។

អ្នកស្រី សួត សាលី កសិករភូមិធម្មជាតិរុនតាឯក ដែលបានរៀនវគ្គបណ្តុះបណ្តាលអំពីដំណាំស្រូវបានលើកឡើងថា វគ្គសិក្សានេះថ្មី ប្លែកជាងអ្វីដែលអ្នកស្រីទៀតធ្លាប់ធ្វើកន្លងមកដោយប្រើកម្លាំងច្រើន ប្រើន័ង្គល ដែលចំណាយពេលច្រើន។ តែវគ្គនេះបង្រៀនដោយគ្រវែងសំណាបនិងប្រើម៉ាស៊ីន វាងាយស្រួល ចំណេញពេល និងគួរឱ្យចាប់អារម្មណ៍ចង់សាកល្បង។ ក្រៅពីនោះ អ្នកស្រីក៏ចេះពីវិធីការពារនិងថែរក្សាស្រូវឱ្យបានល្អ ដឹងពីសត្វល្អិតណាមានប្រយោជន៍និងជាសត្វបំផ្លាញ ហើយត្រូវកម្ចាត់ដោយរបៀបណា។

លោក អ៊ឹង តុងអៀង អនុប្រធានគម្រោងអភិវឌ្ឍន៍ភូមិធម្មជាតិរុនតាឯក បានឱ្យដឹងថា ដំណាំស្រូវជាវគ្គសិក្សាលើកទី១ សម្រាប់កសិកររនៅភូមិធម្មជាតិរុនតាឯក។ តាមរយៈវគ្គសិក្សានេះ នឹងធ្វើឱ្យកសិករយល់ដឹងពីរបៀបដាំដុះ ការថែទាំ ការកម្ចាត់សត្វល្អិតចង្រៃ ការជ្រើសរើសពូជ និងមានជម្រើសក្នុងការសាកល្បងពីវិធីណាមួយដែលគាត់ចង់ធ្វើសម្រាប់ ដំណាំស្រូវរបស់គាត់ឱ្យទទួលបានផលល្អ។ អាជ្ញាធរជាតិអប្សរាតែងតែស្វែងរកដៃគូសហការផ្សេងៗ អ្នកជំនាញកសិកម្មជាតិអន្តរជាតិ ដើម្បីមកផ្តល់ចំណេះដឹងដល់អ្នកភូមិ ធ្វើយ៉ាងណាឱ្យអ្នកភូមិមានជីវភាពល្អប្រសើរតាមរយៈការធ្វើកសិកម្ម និងលក់ដូរផលិតផលរបស់ខ្លួន៕






យុវជនស្ម័គ្រចិត្តបេតិកភណ្ឌពិភពលោក២៤រូប ចានបញ្ចប់កម្មសិក្សារបស់ខ្លួនចានយ៉ាងជោគជ័យ

ផ្សាយនៅថ្ងៃទី ២០ ខែ សីហា ឆ្នាំ២០១៨

សិក្ខាកាមចំនួន២៥រូប ១០រូបមកពីអាជ្ញាធរជាតិអប្សរា អាជ្ញាធរជាតិព្រះវិហារ អាជ្ញាធរជាតិសម្បូរព្រៃគុគ សហភាពសហព័ន្ធយុវជនកម្ពុជា និង១៥រូបទៀតមកពី៩ប្រទេសជុំវិញពិភពលោក បានទទួលវិញ្ញាបនបត្របញ្ជាក់ការសិក្សា បន្ទាប់ពីបានបញ្ចប់វគ្គបណ្តុះបណ្តាលស្តីពីអប់រំយុវជនស្ម័គ្រចិត្ត បេតិកភណ្ឌពិភពលោកដោយជោគជ័យកាលពីព្រឹកថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៨។ កម្មវិធីនេះរៀបចំឡើងនៅសាលសន្និសិទ្ធិអង្គរនៃអាជ្ញាធរជាតិអប្សរា ក្រោមអធិបតីភាព **ឯកឧត្តម ហង់ ពៅ** អគ្គនាយករង តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិត ស៊ុំ ម៉ាប់** អគ្គនាយកអាជ្ញាធរជាតិអប្សរា **លោក ជា សថានី** សមាជិកអចិន្ត្រៃយ៍ ស.ស.យ.ក ខេត្តសៀមរាប និង **លោកស្រី** Sin Boram នាយិកាវិទ្យាស្ថានបេតិកភណ្ឌវប្បធម៌កូរ៉េ។

ក្នុងឱកាសបិទកម្មវិធី **ឯកឧត្តម ហង់ ពៅ** មានប្រសាសន៍ថ្លែងអំណរគុណដល់ស្ថាប័នពាក់ព័ន្ធដែលបានរៀបចំកម្មវិធីនេះឡើង ក៏ដូចជាសិក្ខាកាមទាំងអស់ដែលបានចំណាយពេលសិក្សារៀនសូត្រក្នុងរយៈពេល១០ថ្ងៃកន្លងនេះ។ ឯកឧត្តមសង្ឃឹមថាតាមរយៈវគ្គបណ្តុះបណ្តាលនេះសិក្ខាកាមយល់ដឹងច្រើនពីវប្បធម៌ អរិយធម៌អង្គរ នឹងការអភិរក្ស សហគមន៍ និងក្រមប្រតិបត្តិអង្គរ។

យ៉ាងណាក៏ដោយ ឯកឧត្តមបន្តថារយៈពេល១០ថ្ងៃរបស់សិក្ខាកាមមិនអាចគ្រប់គ្រាន់សម្រាប់សិក្សាស្វែងយល់បានឡើយ រមណីយដ្ឋានអង្គរទាំងមូលក្រៅពីប្រាង្គប្រាសាទ គឺមានបេតិកភណ្ឌអរូបីជាទនៀមទម្លាប់របស់អ្នកស្រុក ប៉ុន្តែសិក្ខាកាមពិតជាបានស្គាល់ និងបានដឹងនូវការប្រារព្ធពិធីខ្លះៗរបស់អ្នកស្រុកអំឡុងថ្ងៃចុះសិក្សា ដែលតំបន់អង្គរបានរក្សាទេសភាពវប្បធម៌បានយ៉ាងល្អប្រសើរ។ ចុងក្រោយឯកឧត្តមសង្ឃឹមថា សិក្ខាកាមដែលមកពី៨ប្រទេសអាចមកកម្ពុជាម្តងទៀត ដើម្បីសិក្សាឱ្យបានលម្អិតពីការងារ ការអភិរក្ស ការអភិវឌ្ឍន៍ ពិសេសនាំក្រុមគ្រួសារ មិត្តភក្តិមកសិក្សាស្វែងយល់ និងទស្សនារមណីយដ្ឋានអង្គរដែលជាចក្រភពនៃវប្បធម៌នៅអាស៊ី។

លោកស្រី Sin Boram នាយិកាវិទ្យាស្ថានបេតិកភណ្ឌវប្បធម៌កូរ៉េ និងជាអ្នករៀបចំកម្មវិធីនេះមានប្រសាសន៍ថានេះជាលើកទី២ដែលបើកវគ្គបណ្តុះបណ្តាលនៅតំបន់អង្គរ សហការរវាងអង្គការយូណេស្កូ អាជ្ញាធរជាតិអប្សរា សហភាពសហព័ន្ធយុវជនកម្ពុជា និងវិទ្យាស្ថានកូរ៉េ-អង្គរដើម្បីបេតិកភណ្ឌ គោលបំណងបណ្តុះបណ្តាលយុវជនអំពីបេតិកភណ្ឌវប្បធម៌។ លោកស្រីសង្ឃឹមថាវគ្គបណ្តុះបណ្តាលនេះនឹងមាននៅឆ្នាំខាងមុខជាបន្តបន្ទាប់សម្រាប់យុវជនកម្ពុជា និងយុវជននៅជុំវិញពិភពលោកដើម្បីយល់កាន់តែច្បាស់អំពីការអភិរក្ស និងការអភិវឌ្ឍន៍រមណីយដ្ឋានអង្គរ។ ចុងបញ្ចប់លោកស្រីបញ្ជាក់ថា នាពេលអនាគត វគ្គបណ្តុះបណ្តាលនេះមិនត្រឹមតែធ្វើនៅក្នុងតំបន់អង្គរប៉ុណ្ណោះទេ គឺនឹងធ្វើនៅខេត្តព្រះវិហារ និង សំបូរព្រៃគុក និងសូមឱ្យយុវជនទាំងអស់ចូលរួមឱ្យបានច្រើនផងដែរ។

លោក សុខ ទីយាវុឌ្ឍ ជាយុវជនស្ម័គ្រចិត្តកម្ពុជាបានបង្ហាញចំណាប់អារម្មណ៍ទៅលើការអភិរក្ស ក្រមប្រតិបត្តិអង្គរ និងភូមិធម្មជាតិរុនតាឯក។ លោកបានទទួលចំណេះដឹងច្រើនដូចជាអភិរក្សថ្ម ឥដ្ឋ កុលាលជន៍ សហគមន៍ជុំវិញ ការគ្រប់គ្រងទេសចរ ជាពិសេសក្រមប្រតិបត្តិអង្គរ ដែលភ្ញៀវទេសចរត្រូវយល់ដឹងពេលចូលមកទស្សនារមណីដ្ឋានអង្គរ។ លោកក៏បានសំណូមពរឱ្យមានកម្មវិធីនេះនៅពេលខាងមុខបន្តទៀត ព្រោះផ្តល់ឱ្យយុវជនយល់ដឹងពីតម្លៃវប្បធម៌ ការរស់នៅរបស់សហគមន៍ និងចូលរួមថែរក្សារាល់សម្បត្តិបេតិកភណ្ឌជាតិ។

កញ្ញា MICHELLE ALMAGRO ជាយុវជនស្ម័គ្រចិត្តកីលីពីន បានឱ្យដឹងថា ពិតជារីករាយណាស់បានក្លាយជាយុវជនស្ម័គ្រចិត្តបេតិកភណ្ឌពិភពលោក និងបានចូលរួមវគ្គបណ្តុះបណ្តាលនេះជាមួយយុវជនមកពីប្រទេសផ្សេងទៀតនៅរមណីយដ្ឋានអង្គរ។ កញ្ញា រំឭកថា កាលពីប៉ុន្មានឆ្នាំមុនបានមកលេងតំបន់អង្គរតាមរយៈក្រុមហ៊ុនទេសចរណ៍មួយ បើប្រៀបធៀបពេលនោះអ្នកស្រីមិនបានស្វែងយល់អ្វីទាល់តែសោះ ពិសេសផ្នែកក្រមប្រតិបត្តិអង្គរ ការងារជួសជុល ការអភិរក្ស និងការអភិវឌ្ឍន៍សហគមន៍។ កញ្ញាមានចំណាប់អារម្មណ៍ទៅលើការអភិរក្សប្រាសាទខ្មែរដែលខុសគ្នានៅ ភីលីពីន និងសំណូមពរឱ្យកម្មវិធីនេះលើកក្រោយមានរយៈពេលវែងសម្រាប់ការចុះសិក្សាដល់ទីតាំងតែម្តង៕









សេចក្តីជូនដំណឹងស្តីពីធ្វើការដាំកូនឈើបន្តវេនស្ថិតនៅតាមមាត់កសិណមុខប្រាសាទអង្គរខាងលិច និងដាំកូនរំលួស

ផ្សាយនៅថ្ងៃទី ២១ ខែ សីហា ឆ្នាំ២០១៨



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA
លេខ.ណជ/រប.សជ/ ...

សេចក្តីជូនដំណឹង
ស្តីពី
ធ្វើការដាំកូនឈើបន្តវេន
ស្ថិតនៅតាមមាត់កសិណមុខប្រាសាទអង្គរវត្តខាងលិច និងដាំកូនរំលួស

អាជ្ញាធរអប្សរា សូមជូនដំណឹងដល់ស្ថាប័ន សមត្ថកិច្ចពាក់ព័ន្ធ ភ្ញៀវជាតិ-អន្តរជាតិ មគ្គុទ្ទេសក៍ទេសចរណ៍ ព្រមទាំងសាធារណជនទាំងអស់មេត្តាជ្រាបថា ដើម្បីលើកកម្ពស់សោភ័ណភាពស្រស់ស្អាតនៅតាមដងផ្លូវ និងនៅតាមបរិវេណប្រាសាទ ក្នុងតំបន់រមណីយដ្ឋានអង្គរ និងតំបន់ដែលគ្រប់គ្រងដោយអាជ្ញាធរអប្សរា នាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពប្បធម៌ និងបរិស្ថាន នៃអាជ្ញាធរអប្សរា នឹងធ្វើការដាំកូនឈើបន្តវេនចំនួន ៣៨ដើម ស្ថិតនៅតាមមាត់កសិណមុខប្រាសាទអង្គរវត្តខាងលិច និងដាំកូនរំលួសចំនួន ៤០ដើម បន្តពីចំបក់កំណាប់តាមមាត់កសិណប្រាសាទអង្គរវត្តខាងត្បូងទៅទិសខាងលិច។

ការងារនេះ នឹងចាប់ផ្តើមអនុវត្តចាប់ពីថ្ងៃទី ២០ ខែ សីហា ឆ្នាំ២០១៨។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមស្ថាប័ន សមត្ថកិច្ចពាក់ព័ន្ធ ភ្ញៀវជាតិ-អន្តរជាតិ មគ្គុទ្ទេសក៍ទេសចរណ៍ ព្រមទាំងសាធារណជនទាំងអស់ មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃ...ខែ... ឆ្នាំច សំរឹទ្ធស័កព.ស២៥៦២
សៀមរាប, ថ្ងៃទី...ខែ សីហា ឆ្នាំ២០១៨
ដឹកនាំដោយ

ស៊ុំ ម៉ាប់

ចម្លងជូន៖
-សាលាខេត្តសៀមរាប
-មន្ទីរបរិស្ថានខេត្តសៀមរាប
-មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តសៀមរាប
-អង្គភាពនគរបាលការពារបរិវេណប្រចាំខេត្តសៀមរាប
-ស្នាក់ការគ្រប់គ្រងការពារមេសកាពអង្គរ
-សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ទាំងអស់ប្រចាំខេត្តសៀមរាប
-អង្គភាពនគរបាលទេសចរណ៍ប្រចាំខេត្តសៀមរាប
-ដើម្បីជូនជ្រាប និងសហការ-
-គ្រប់នាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធរបស់អាជ្ញាធរអប្សរា
-ដើម្បីអនុវត្ត និងសហការ-
-ឯកសារ-កាលប្បវត្តិ

លេខទូរស័ព្ទចំនាក់ទំនង៖ឈោក ឆង់ សុវណ្ណារិទ្ធ 012-354-630, ឈោក រឿន សុធី 010-304-089,088-9522-5059,ឈោក ឃៀ ប៊ីតេ 086 600 740

Email: info@apsaraauthority.gov.kh
Website: http://www.apsaraauthority.gov.kh

ឯកសារបេតិកភណ្ឌប្រចាំតំបន់ដីឥដ្ឋចចក្រចនិងរក្សាទុកដោយក្រុមយុវជនបេតិកភណ្ឌស្ម័គ្រចិត្តក្នុងតំបន់អង្គរដោយខ្លួនឯង

ផ្សាយនៅថ្ងៃទី ២៤ ខែ សីហា ឆ្នាំ២០១៨

បន្ទាប់ពីបើកវគ្គសិក្សាអស់រយៈពេល៤ខែកន្លងមក កម្មវិធីអប់រំកុមារបេតិកភណ្ឌនៅសាលាបឋមសិក្សាស្រះស្រង់ បានបញ្ចប់វគ្គទី១ដោយជោគជ័យកាលពីព្រឹកថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៨ ក្រោមវត្តមានថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា អង្គការគាំពារពពែរកេរមរតក មន្ទីរអប់រំ យុវជន និងកីឡា មន្ទីរវប្បធម៌ខេត្តសៀមរាប មជ្ឈមណ្ឌលយុវជនជាតិកម្ពុជាខេត្តសៀមរាប សម្បុរសជនគាំទ្រគម្រោង មាតាបិតាសិស្ស រួមនឹងអាជ្ញាធរមូលដ្ឋានប្រហែលជាង២០០នាក់។

កម្មវិធីនេះ បានបង្កើតឡើងនៅសាលាគោលដៅចំនួន២ គឺសាលាបឋមសិក្សាស្រះស្រង់និងវិទ្យាល័យនគរធំ ក្នុងគោលបំណងបណ្តុះគំនិតឱ្យសិស្សានុសិស្សចេះស្រឡាញ់ ស្វែងយល់ពីបេតិកភណ្ឌក្នុងតំបន់ដែលខ្លួនកំពុងរស់នៅឱ្យកាន់តែច្បាស់ ចេះស្រាវជ្រាវ ចេះចងក្រងឯកសាររក្សាទុកសម្រាប់ក្មេងជំនាន់ក្រោយ។ អប់រំផ្ទាល់លើសិស្សអំពីអ្វីដែលអ្នកស្រាវជ្រាវបានឃើញ ដើម្បីឱ្យសិស្សតាមទាន់សភាពការណ៍នៃការស្រាវជ្រាវ ផ្តល់ព័ត៌មានថ្មី និងបច្ចុប្បន្នភាពដល់សិស្សានុសិស្ស និងបន្តវិធីសាស្ត្រនៃការស្រាវជ្រាវបែបវិទ្យាសាស្ត្រជាមូលដ្ឋានបណ្តុះបណ្តាលដល់សិស្សបន្តិចម្តងៗ ហើយសិស្សអាចសិក្សាស្វែងយល់ដោយខ្លួនឯង ដើម្បីបន្ថយគម្លាតនៃការយល់ដឹងពីសហគមន៍ ព្រោះខ្លួនកំពុងរស់នៅក្នុងតំបន់បេតិកភណ្ឌ។

លោកស្រី Joyce Hanan Clark ប្រធានអង្គការគាំពារកេរមរតកប្រចាំសហរដ្ឋអាមេរិកមានប្រសាសន៍ថា យើងមិនអាចធ្វើការមួយថ្ងៃ ដើម្បីឱ្យអនាគតល្អប្រសើរទេ គឺយើងមានដំណើរការវែងឆ្ងាយបន្តទៀតជាមួយកិច្ចការអប់រំបេតិកភណ្ឌ។ កម្មវិធីអប់រំនេះមិនបានផ្តោតតែលើប្រាសាទទេ គឺរាប់បញ្ចូលទាំងបរិស្ថាន បេតិកភណ្ឌក្រោមដី ក្នុងទឹក រូបី និងអរូបីផង ដើម្បីឱ្យក្មេងៗដឹងថាមានអ្វីខ្លះជាបេតិកភណ្ឌក្នុងតំបន់ខ្លួន? វាមានប្រយោជន៍ដូចម្តេច? ហើយត្រូវការពារយ៉ាងណា? ដូច្នេះហើយទាមទារឱ្យយើងត្រូវបណ្តុះដល់ក្មេងៗជំនាន់ក្រោយ ធ្វើការងារនេះជាប្រចាំនិងយូរអង្វែងក្នុងការថែរក្សា ព្រោះមិនមែនដើម្បីតែមួយគ្រួសារទេ គឺបេតិកភណ្ឌដើម្បីជាតិទាំងមូល។

វាជាការសំខាន់ណាស់ ដែលយើងបានកើត រស់នៅ រកស៊ីជាមួយបេតិកភណ្ឌ ត្រូវតែសិក្សា ស្វែងយល់ ការពារ ថែរក្សាបេតិកភណ្ឌ។ បើទោះបីជាម៉ោងសិក្សាមានរយៈពេលខ្លី តែសិស្សានុសិស្សពិតជាបានដឹងច្រើនអំពីប្រវត្តិសាស្ត្រ ការស្រាវជ្រាវ ទំនៀមទម្លាប់ តួនាទីប្រាសាទ បរិស្ថាន ក្រមសីលធម៌ពេលចូលប្រាសាទ និងប្រវត្តិសិល្បៈ។ នេះជាការកែប្រែទម្លាប់ដ៏ប្រសើរ ដែលអ្នកជំនាន់មុន ត្រូវបន្តវេនដល់អ្នកជំនាន់ក្រោយ។

លោក អ៊ឹម សុខរិទ្ធ ប្រធានគម្រោងនិងជាតំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមបណ្ឌិត ស៊ុំ ម៉ាប់** អគ្គនាយកអាជ្ញាធរជាតិអប្សរា បានរំឭកថា គម្រោងនេះបង្កើតឡើងតាំងពីឆ្នាំ២០០៧ ដោយមានកិច្ចសហការជាមួយប្រទេសថៃ ហើយទទួលជោគជ័យបំផុតនៅវិទ្យាល័យបន្ទាយឆ្មារ តែនេះជាវគ្គសិក្សាទី១នៅក្នុងតំបន់រមណីយដ្ឋានអង្គរ។

លោកក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ក្រុមការងារដែលបានចូលរួមសហការទាំងអស់ ពិសេសអ្នកឧបត្ថម្ភកម្មវិធី ដែលបានជ្រោមជ្រែងឱ្យការអប់រំដ៏មានតម្លៃនេះដំណើរការយ៉ាងរលូន ជាប្រយោជន៍សម្រាប់មនុស្សជាតិទាំងមូល។ យើងនឹងពង្រីកវិសាលភាពទៅសាលាផ្សេងទៀតនៅតំបន់អង្គរមាន សាលាបាគងជាដើម ដែលនៅពេលអនាគត កុមារនិងយុវជនស្ម័គ្រចិត្តនឹងបានផ្លាស់ប្តូរបទពិសោធន៍គ្នាទៅវិញទៅមក ចងក្រងឯកសារប្រចាំតំបន់របស់ខ្លួនដោយខ្លួនឯង ហើយរក្សាទុកនៅទីតាំងផ្ទាល់សម្រាប់សហគមន៍។ លើសពីនោះ យើងក៏នឹងបង្កើតឱ្យមានការចុះកម្មសិក្សាទៅក្រៅតំបន់ដូចជាសំបូរព្រៃគុក និងបន្ទាយឆ្មារជាដើម ដើម្បីស្វែងយល់បន្ថែមពីបេតិកភណ្ឌក្រៅស្រុក៕









ឥណ្ឌូនេស៊ីស្វែងរកកិច្ចសហការជាមួយអាជ្ញាធរជាតិអប្សរាដើម្បីចុះអនុស្សារណៈរវាងរមណីយដ្ឋានអង្គរ និងរមណីយដ្ឋាន Borobudur

ផ្សាយនៅថ្ងៃទី ២៤ ខែ សីហា ឆ្នាំ២០១៨

ព្រឹកថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៨ នៅស្នាក់ការអាជ្ញាធរជាតិអប្សរា **ឯកឧត្តម ហង់ ពៅ** អគ្គនាយករងតំណាង **ឯកឧត្តម ស៊ុំ ម៉ាប់** អគ្គនាយកអាជ្ញាធរជាតិអប្សរា អនុញ្ញាតឲ្យ **លោក Ricky SP Siahaan** ប្រធានផ្នែកទីផ្សារនិងសេវាកម្មនៃ PT Taman Wisata Candi ដែលគ្រប់គ្រងរមណីយដ្ឋាន Borobudur ប្រទេសឥណ្ឌូនេស៊ី ចូលជួបសំណេះសំណាលផ្លាស់ប្តូរយោបល់គ្នាទៅវិញទៅមកដើម្បីពង្រីកកិច្ចសហប្រតិបត្តិការទៅវិញទៅមករវាងតំបន់បេតិកភណ្ឌពិភពលោករបស់ប្រទេសទាំងពីរ គឺរមណីយដ្ឋានអង្គរ និងរមណីយដ្ឋាន Borobudur។

លោក Ricky SP Siahaan មានប្រសាសន៍ថា លោកពិតជាមានក្តីរំភើបដែលបានមកកាន់ទីនេះ ស្របពេលពេលថ្មីៗនេះ ប្រាសាទអង្គរវត្តរបស់កម្ពុជា ជាប់ចំណាត់ថ្នាក់ជាសំណង់ប្រវត្តិសាស្ត្រដ៏អស្ចារ្យបំផុត ធ្វើឡើងតាមរយៈការស្រង់មតិ លើចំណាប់អារម្មណ៍ និងទស្សនៈរបស់អ្នកទេសចរជាប់លាននាក់ជុំវិញពិភពលោក ជាចំណុចដែលប្រទេសឥណ្ឌូនេស៊ីចាប់អារម្មណ៍ មានបំណងចង់ធ្វើកិច្ចសហប្រតិបត្តិការណ៍រវាងរមណីយដ្ឋានអង្គរ របស់កម្ពុជានិងរមណីយដ្ឋាន Borobudur របស់ឥណ្ឌូនេស៊ី ដើម្បីផ្លាស់ប្តូរបទពិសោធន៍ ចំណេះដឹងល្អៗ ដូចជាការអភិរក្សការគ្រប់គ្រង ការអភិវឌ្ឍន៍សេវាកម្មផ្សេងៗ។ ក្នុងនោះ តាមរយៈកម្មវិធី Twin World Heritage Program ខាងភាគីឥណ្ឌូនេស៊ីមានបំណងបង្កើតកិច្ចព្រមព្រៀងរវាងស្ថាប័នទាំងពីរដើម្បីជម្រុញការផ្សព្វផ្សាយអំពីគ្នាទៅវិញទៅមក និងទាក់ទាញភ្ញៀវទេសចរឱ្យកាន់តែច្រើន។

ថ្លែងក្នុងជំនួបនោះ **ឯកឧត្តម ហង់ ពៅ** បានសម្តែងនូវអំណរសាទរយ៉ាងជ្រាលជ្រៅចំពោះគណៈប្រតិភូឥណ្ឌនេស៊ីថា នេះមិនមែនជាលើកទីមួយទេដែលអាជ្ញាធរជាតិអប្សរាចែករំលែកបទពិសោធន៍ល្អៗ លើការអភិរក្ស ការជួសជុល ការគ្រប់គ្រងរមណីយដ្ឋានអង្គរដល់បណ្តាប្រទេសផ្សេងៗដែលមានបំណងស្វែងយល់ អំពីបទពិសោធន៍ក្នុងការគ្រប់គ្រងអភិរក្ស និងអភិវឌ្ឍន៍ដោយចីរភាពនៃរមណីយដ្ឋានអង្គរ។

ឯកឧត្តមសង្កត់ធ្ងន់ថា អាជ្ញាធរជាតិអប្សរាពេញចិត្តនឹងស្វាគមន៍រាល់កិច្ចសហប្រតិបត្តិការដែលបម្រើដល់ប្រយោជន៍បេតិកភណ្ឌទាំងមូល។ ម្យ៉ាងទៀតទស្សនៈវិស័យក្នុងការអភិរក្ស និងការអភិវឌ្ឍបេតិកភណ្ឌពិភពលោករវាងប្រទេសទាំងពីរ គឺមានទស្សនវិស័យប្រហាក់ប្រហែលគ្នា ងាយសហការគ្នារីកចម្រើនទៅមុខ និងមានចំណុចពិសេសសម្រាប់ការផ្លាស់ប្តូរបទពិសោធន៍រវាងកម្ពុជា និងឥណ្ឌូនេស៊ីក្នុងការអភិរក្សប្រាសាទ ការអភិវឌ្ឍវិស័យទេសចរណ៍។

ឯកឧត្តមបន្ថែមថាជោគជ័យរមណីយដ្ឋានអង្គរមកដល់ពេលនេះ គឺដោយមានការខិតខំ និងសហការណ៍ពីស្ថាប័នជាតិ និងអន្តរជាតិផ្សេងៗដែលធ្វើការពាក់ព័ន្ធនឹងវិស័យបេតិកណ្ឌ៕









សេចក្តីជូនដំណឹង

ផ្សាយនៅថ្ងៃទី ២៩ ខែ សីហា ឆ្នាំ២០១៨

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA

លេខ ៨៦៨ /រប.សដលា
/ ១៨

សេចក្តីជូនជំណឹង

អាជ្ញាធរជាតិអប្សរា មានកិត្តិយសសូមជម្រាបជូនជំណឹងដល់ភ្ញៀវទេសចរជាតិ-អន្តរជាតិ ព្រមទាំងសាធារណជនទាំងអស់ជ្រាបថា លោកជំទាវ ស៊ុសម៉ា ស្វារ៉ាច (Sushma Swaraj) រដ្ឋមន្ត្រីក្រសួងការបរទេសឥណ្ឌា នឹងដឹកនាំគណៈប្រតិភូអញ្ជើញមកបំពេញទស្សនកិច្ចផ្លូវការ និងមិត្តភាពនៅព្រះរាជាណាចក្រកម្ពុជា ចាប់ពីថ្ងៃទី២៨ រហូតដល់ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៨។ ឆ្លៀតក្នុងឱកាសនៃការបំពេញទស្សនកិច្ចផ្លូវការនេះ គណៈប្រតិភូនឹងមកធ្វើទស្សនកិច្ចនៅតំបន់រមណីយដ្ឋានអង្គរ នាថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៨ ខាងមុខនេះ។ ប៉ុន្តែទន្ទឹមនឹងនោះ ដោយសារលោកជំទាវរដ្ឋមន្ត្រីមានបញ្ហាសុខភាពពិបាកក្នុងការធ្វើដំណើរចូលទស្សនាប្រាសាទអង្គរវត្ត អាជ្ញាធរជាតិអប្សរា បានអនុញ្ញាតឱ្យយករថយន្ត Golf cart ជូនដំណើរលោកជំទាវរដ្ឋមន្ត្រី និងគណៈប្រតិភូចូលទស្សនាប្រាសាទអង្គរវត្ត តាមច្រកចូលខាងកើត និងរង់ចាំទទួលគណៈប្រតិភូនៅផ្នែកខាងត្បូងនៃប្រាសាទអង្គរវត្ត។

អាស្រ័យដូចបានជម្រាបជូនខាងលើនេះ សូមភ្ញៀវទេសចរជាតិ-អន្តរជាតិ និងសាធារណជនទាំងអស់មេត្តាជ្រាបជាព័ត៌មានតាមការគួរ។

ថ្ងៃ ពុធ ៣៣៣ ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
ស្រៀមរាប ថ្ងៃទី ២៦ ខែសីហា ឆ្នាំ២០១៨

អគ្គនាយក

ស៊ុ ម៉ាប់

ចម្លងជូន:
- សាលាខេត្តសៀមរាប
- ស្នងការដ្ឋាននគរបាលខេត្តសៀមរាប
- បញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តសៀមរាប
- សាលាក្រុងសៀមរាប
- អង្គភាពនគរបាលការពារបេតិកភណ្ឌប្រចាំខេត្តសៀមរាប
- អង្គភាពនគរបាលទេសចរណ៍ប្រចាំខេត្តសៀមរាប
- មន្ទីរអង្គភាពជុំវិញខេត្ត
- ត្រឹះស្ថានអង្គរ
  "ដើម្បីជូនជ្រាប និងជួយផ្សព្វផ្សាយ"
- ឯកសារ-កាលប្បវត្តិ

ភ្ជាធ្វេ:
ទីបាវីធីសហព័ន្ធរុស្ស៊ី លេខ៤១ សង្កាត់ទីក្លាភាព ខណ្ឌដាមកា
ទូរសព្ទ/ទូរសារ៖ ០៦៣ ៧១៤ ៨៨១/០៦៣ ៧១៤ ៨៨៦

អាជ្ញាធរជាតិអ្នកសាធារណៈបាតិយជ្ជានិងដាច្រាត់ចំនង្គម
Email: info@apsaraauthority.gov.kh
Website: http//www.apsaraauthority.gov.kh

ឆ្លៀមរាប:
ភូមិកន្តាង ប៉ុន់ធំលាស ស្រុកប្រាសាទបាគង ខេត្តសៀមរាប
ទូរសព្ទ/ទូរសារ៖ ០៦៣ ៨៦៤ ៤៨៨/០៦៣ ៨៦៤ ៤៨៦

វិទ្យាស្ថានជាតិស្រាវជ្រាវណាក៉ាប្រគល់វត្ថុបុរាណដែលបានពីកំណាយស្រាវជ្រាវនិងជួសជុលនៅតំបន់អង្គរជូនអាជ្ញាធរជាតិអប្សរា

ផ្សាយនៅថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០១៨

នារសៀលថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៨ **លោក Hiroshi SUGIYAMA** ប្រធានគម្រោងវិទ្យាស្ថានជាតិស្រាវជ្រាវណាក៉ារបស់ប្រទេសជប៉ុន បាននាំយកវត្ថុបុរាណដែលបានពីការធ្វើកំណាយស្រាវជ្រាវនៅឡតានីនិងការជួសជុលប្រាសាទតុបខាងលិច មកប្រគល់ជូនអាជ្ញាធរជាតិអប្សរាដើម្បីរក្សាទុក។

វត្ថុបុរាណទាំងនេះមានបំណែកកុលាលភាជន៍ ដែលបានពីកំណាយស្រាវជ្រាវនៅឡតានី និងបំណែកតូចល្អិតធ្វើពីលោហធាតុ ដែលសង្ស័យថាជារបស់ដែលគេយកមកធ្វើពិធីបូជាអ្វីមួយនៅប្រាសាទតុបខាងលិច។ វិទ្យាស្ថានស្រាវជ្រាវជាតិណាក៉ា មានសេចក្តីរីករាយក្នុងការគោរពទៅតាមច្បាប់បេតិកភណ្ឌនៃប្រទេសកម្ពុជា និងមានមោទកភាពណាស់ ដែលបានចូលរួមចំណែកក្នុងថែរក្សា ការពារ ជួសជុល និងអភិរក្សនូវសំណង់បុរាណក្នុងតំបន់អង្គរ ព្រមទាំងការស្រាវជ្រាវនៅទីនេះផង។

ឯកឧត្តម ហង់ ពៅ អគ្គនាយករងនៃអាជ្ញាធរជាតិអប្សរា ក្នុងពិធីទទួលនូវវត្ថុទាំងនោះបានកត់សម្គាល់ថា វិទ្យាស្ថានជាតិស្រាវជ្រាវណាក៉ារបស់ប្រទេសជប៉ុន គឺជាស្ថាប័នអន្តរជាតិទី១ដែលបានប្រគល់នូវបុរាណវត្ថុដល់អាជ្ញាធរជាតិអប្សរាក្រោយធ្វើការស្រាវជ្រាវរួចរាល់។ ការប្រគល់វត្ថុបុរាណទាំងនោះមកអាជ្ញាធរជាតិអប្សរានាពេលនេះ គឺតបតាមការអំពាវនាវរបស់**លោកជំទាវ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងជាប្រធានអាជ្ញាធរជាតិអប្សរា ដែលលោកជំទាវបានអំពាវនាវនាឱកាសជួបប្រជុំជាមួយស្ថាប័នអន្តរជាតិ បំពេញការកិច្ចក្នុងរមណីយដ្ឋានអង្គរឱ្យបញ្ជូនវត្ថុបុរាណនានាដែលប្រទះឃើញក្នុងពេលធ្វើកំណាយស្រាវជ្រាវឬជួសជុល មកអាជ្ញាធរជាតិអប្សរាដើម្បីចុះបញ្ជីសារពើ កណ្ឌក្នុងក្របខណ្ឌជាតិនៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។

ឯកឧត្តម ហង់ ពៅ បន្តទៀតថា វត្ថុទាំងនេះនឹងត្រូវរក្សាទុកនៅអាជ្ញាធរជាតិអប្សរា ដើម្បីសិក្សាអំពីប្រវត្តិ ចុះបញ្ជីសារពើកណ្ឌ និងធ្វើការជួសជុលអភិរក្សនូវបុរាណវត្ថុសិល្បៈទាំងនេះឱ្យបានល្អប្រសើរ។ ឯកឧត្តមក៏បានថ្លែងអំណរគុណដ៏ជ្រាលជ្រៅ ចំពោះវិទ្យាស្ថានជាតិស្រាវជ្រាវណាក៉ា ដែលមានកិច្ចសហការដ៏ល្អជាមួយអាជ្ញាធរជាតិអប្សរាជាច្រើនឆ្នាំលើកិច្ចការអភិរក្សនិងជួសជុលប្រាសាទក្នុងតំបន់អង្គរ ការស្រាវជ្រាវ ការបណ្តុះបណ្តាលធនមនុស្ស និងការផ្តល់ការងារដល់អ្នកជំនាញខ្មែរផងដែរ៕









លោកជំទាវ ភឿង សកុណា ជួបសំណេះសំណាលជាមួយបុគ្គលិកអចិន្ត្រៃយ៍និងជំនាញរបស់អាជ្ញាធរជាតិអប្សរាដែលត្រូវធ្វើសមាហរណកម្មជាមន្ត្រីរាជការនៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

ផ្សាយនៅថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០១៨

នាព្រឹកថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៨ **លោកជំទាវ ភឿង សកុណា** រដ្ឋមន្ត្រីនៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងជាប្រធានអាជ្ញាធរជាតិអប្សរា បានជួបសំណេះសំណាលជាមួយបុគ្គលិកជំនាញនិងអចិន្ត្រៃយ៍ចំនួន៣៥៥នាក់ ដែលត្រូវធ្វើសមាហរណកម្មជាមន្ត្រីរាជការនៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។ ពិធីនេះរៀបចំឡើងនៅសាលសន្និសីទអង្គរនៃមជ្ឈមណ្ឌលអាជ្ញាធរជាតិអប្សរា ក្នុងបំណងផ្តល់ដំណឹងអំពីលក្ខខណ្ឌមួយចំនួនដែលត្រូវអនុវត្ត និងការទទួលបាននូវផលប្រយោជន៍សាធារណៈជាច្រើនផ្សេងទៀតស្របតាមគោលការណ៍របស់រាជរដ្ឋាភិបាល រាប់បញ្ចូលទាំងឱកាសនៃបង្កើតអាជីពវិជ្ជាជីវៈ ការទទួលបានការផ្តល់សេចក្តីទុកចិត្តតែងតាំងឱ្យទទួលភារកិច្ចថ្មីៗ និងការដំឡើងប្រាក់បៀវត្សរ៍នៅពេលក្លាយខ្លួនជាមន្ត្រីរាជការ។

បន្ថែមពីនោះ លោកជំទាវក៏ក្រើនរំឭកដល់បុគ្គលិកទាំងអស់ថា ក្នុងនាមជាមន្ត្រីអាជ្ញាធរជាតិអប្សរាដែលបំពេញការងារអភិរក្សលើកស្ទួយតម្លៃមរតកវប្បធម៌ជាតិ គឺជាភ័ព្វសំណាងមួយដែលមនុស្សជាច្រើនប៉ងប្រាថ្នា។ ដូច្នេះ សូមឱ្យមន្ត្រីទាំងអស់ត្រូវបំពេញការងារដោយយកចិត្តទុកដាក់ មានវិន័យត្រឹមត្រូវខ្ជាប់ខ្ជួន ផ្ចិតផ្ចង់ក្នុងការងារ និងរៀនសូត្រដកស្រង់យកបទពិសោធន៍ការងារឱ្យបានកាន់តែច្រើនដើម្បីភាពរីកចម្រើននៃសមត្ថភាពរបស់ខ្លួន និងប្រសិទ្ធភាពការងារ ព្រោះថាមន្ត្រីទាំងនេះគឺជាសសរទ្រូងយ៉ាងរឹងមាំក្នុងកិច្ចការអភិរក្ស អភិវឌ្ឍន៍ប្រកបដោយចីរភាពរមណីយដ្ឋានអង្គរ និងអាចក្លាយជាថ្នាក់ដឹកនាំស្ថាប័នអាជ្ញាធរជាតិអប្សរានាពេលអនាគត៕









លោកជំទាវ ភឿង សកុណា ស្វាគមន៍ដំណើរទស្សនកិច្ចផ្លូវការរបស់រដ្ឋមន្ត្រីក្រសួងការបរទេសឥណ្ឌា ក្នុងខេត្តសៀមរាប

ផ្សាយនៅថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០១៨

លោកជំទាវ ស៊ុសម៉ា ស្វារ៉ាច (Sushma Swaraj) រដ្ឋមន្ត្រីក្រសួងការបរទេសឥណ្ឌា បានមកបំពេញទស្សនកិច្ចផ្លូវការនៅព្រះរាជាណាចក្រកម្ពុជារយៈពេល២ថ្ងៃ គឺចាប់ពីថ្ងៃទី២៩ ដល់ថ្ងៃទី៣០ ខែ សីហា ឆ្នាំ២០១៨។ ក្នុងដំណើរទស្សនកិច្ចមកកាន់ខេត្ត សៀមរាប នៅព្រឹកថ្ងៃទី៣០ ខែសីហា លោកជំទាវរដ្ឋមន្ត្រី បានធ្វើទស្សនកិច្ចរមណីយដ្ឋានអង្គរ និងសារមន្ទីរវាយនកណ្ដាប្រពៃណីអាស៊ី អិម ជី ស៊ី ដែលជាគម្រោងកិច្ចសហប្រតិបត្តិការរវាងអាជ្ញាធរជាតិអប្សរា និង រដ្ឋាភិបាលសាធារណរដ្ឋឥណ្ឌា។

ក្នុងពិធីស្វាគមន៍ដំណើរទស្សនកិច្ចរបស់ **លោកជំទាវ ស៊ុសម៉ា ស្វារ៉ាច** រដ្ឋមន្ត្រីការបរទេសឥណ្ឌា នាសារមន្ទីរវាយនកណ្ដាប្រពៃណីអាស៊ី អិម ជី ស៊ី **លោកជំទាវ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាប្រធានអាជ្ញាធរជាតិអប្សរា បានសម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅបំផុតជូនចំពោះលោកជំទាវរដ្ឋមន្ត្រីក្រសួងការបរទេសឥណ្ឌា និងបានថ្លែងអំណរគុណដល់ភាគីឥណ្ឌា ដែលបានខិតខំជ្រោមជ្រែងចូលរួមក្នុងការថែរក្សា អភិរក្សរមណីយដ្ឋានអង្គរនាពេលកន្លងមក តាមរយៈគម្រោងជួសជុលនៅប្រាសាទអង្គរ និងតាព្រហ្ម៕









លោកជំទាវ ភឿង សកុណា បើកកិច្ចប្រជុំពិភាក្សាត្រៀមរៀបចំកិច្ចប្រជុំគណៈកម្មាធិការអាយស៊ីស៊ី-អង្គរ និងខួប២៥ឆ្នាំនៃការបង្កើតគណៈកម្មាធិការអាយស៊ីស៊ី-អង្គរ

ផ្សាយនៅថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០១៨

រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាប្រធានអាជ្ញាធរជាតិអប្សរា **លោកជំទាវ ភឿង សកុណា** នៅព្រឹកថ្ងៃទី ៣១ ខែសីហា បានបើកកិច្ចប្រជុំផ្ទៃក្នុងមួយ ដើម្បីត្រៀមរៀបចំកិច្ចប្រជុំគណៈកម្មាធិការអន្តរជាតិសម្របសម្រួលគាំពារ និងអភិវឌ្ឍន៍តំបន់ប្រវត្តិសាស្ត្រអង្គរ ហៅកាត់ថា អាយស៊ីស៊ី-អង្គរ និងរៀបចំខួបលើកទី២៥ឆ្នាំនៃការបង្កើតគណៈកម្មាធិការអាយស៊ីស៊ី-អង្គរ។

តាមប្រសាសន៍របស់ **លោកជំទាវ ភឿង សកុណា** ខួបលើកទី២៥ឆ្នាំ នៃកិច្ចប្រជុំគណៈកម្មាធិការអន្តរជាតិអាយស៊ីស៊ី-អង្គរ នឹងមានការបើកក្រោមអធិបតីភាព **សម្តេចអគ្គមហាសេនាបតី តេជោ ហ៊ុន សែន** ប្រមុខរាជរដ្ឋាភិបាលកម្ពុជា និងកម្មវិធីបិទ ក្រោមព្រះវត្តមានដ៏ខ្ពង់ខ្ពស់របស់ **ព្រះករុណាព្រះបាទព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា**៕






ឆាយកដ្ឋានផ្សព្វផ្សាយ
www.apsaraauthority.gov.kh


ឆាយកដ្ឋានផ្សព្វផ្សាយ
www.apsaraauthority.gov.kh

ព្រឹត្តិការណ៍ព័ត៌មាន
ប្រចាំខែកញ្ញា

ផ្នែកទី ៩
ប្រចាំខែកញ្ញា

ការចូលរួមដាំដើមឈើក្នុងតំបន់អង្គរ ជាការកិច្ចដែលអ្នកអាស្រ័យផលត្រូវចូលរួមទាំងអស់គ្នា

ផ្សាយនៅថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០១៨

មនុស្សប្រមាណជាង៤០០នាក់ មកពីវិស័យឯកជនតាមរយៈសមាគមធនធានមនុស្សនិងសមាគមទេសចរណ៍ខេត្តសៀមរាប សហការជាមួយអាជ្ញាធរជាតិអប្សរានៃគម្រោងអប់រំបេតិកភណ្ឌបានជួបជុំគ្នាដាំដើមឈើជាង២០០០ដើមនៅខាងត្បូងបរិវេណប្រាសាទបន្ទាយក្តី កាលពីព្រឹកថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១៨កន្លងទៅនេះ។

ដើមឈើទាំងនោះមាន៣ប្រភេទគឺ ដើមគគីរ ដើមឈើទាល ដើមកកោះ ជាប្រភេទឈើធំ ស្រូបទឹកបានច្រើន មាំទាំអាចទប់ខ្យល់បានល្អ។ បើគិតមកដល់ពេលនេះ អាជ្ញាធរជាតិអប្សរាដាំកូនឈើបានជាង១ម៉ឺនដើមហើយក្នុងតំបន់អង្គរ ដោយមានការថែទាំយ៉ាងល្អ។

លោក អ៊ឹម សុខរិទ្ធ អនុប្រធានមជ្ឈមណ្ឌលអន្តរជាតិស្រាវជ្រាវនិងតម្កល់ឯកសារអង្គរ បានលើកឡើងថា នេះជាលើកទី២ហើយដែលវិស័យឯកជនបានចូលរួមដាំដើមឈើ ហើយគម្រោងនេះនៅតែមានបន្តទៀត ដើម្បីថែរក្សាទេសភាពតំបន់អង្គរដែលត្រូវការកម្លាំងដាំឡើងវិញ។

លោកបន្តទៀតថា នៅឆ្នាំ២០១៨នេះដែរ ក៏ជាឱកាសបង្កើតស្ពានមេត្រីរវាងវិស័យឯកជន អាជ្ញាធរដែនដី និងអាជ្ញាធរជាតិអប្សរា ដែលជាអ្នកប្រាស្រ័យ អ្នកទទួលកេរមរតក អ្នកទទួលផល និងធ្វើការដើម្បីបេតិកភណ្ឌ រួមគ្នាបម្រើអង្គរ។ ដូច្នេះការចូលរួមដាំដើមឈើ ជាការចូលរួមរួមកិច្ចការសង្គមនិងការអភិរក្សដែលជាកាតព្វកិច្ចមនុស្សទូទៅត្រូវចូលរួមឱ្យបានទាំងអស់គ្នាសម្រាប់លម្អក្រុងអង្គរ បង្កើនភាពបៃតងដល់បរិស្ថាន និងធ្វើជាគំរូសម្រាប់មនុស្សជំនាន់ក្រោយ។

លោកស្រី ប្លង សុភាព មកពី Artisans Angkor តំណាងឱ្យសមាគមនធនធានមនុស្សខេត្តសៀមរាបបានលើកឡើងថា មានវិស័យឯកជនជាង៨០ស្ថាប័នដែលបានចូលរួម សកម្មភាពដាំកូនឈើ ដើម្បីជាចំណែកថែរក្សានិងការអភិរក្ស ក៏ដូចជាបង្ហាញដល់សាធារណៈជន យុវជន ក្មេងៗជំនាន់ក្រោយឱ្យចេះស្រឡាញ់បរិស្ថាននិងចូលរួមថែរក្សាកេរមរតកដូនតាខ្មែរ ព្រោះនៅក្នុងខេត្តសៀមរាប ក្រៅពីប្រាសាទ សក្តានុពលធម្មជាតិបានទាញទាញភ្ញៀវទេសចរាប់លាននាក់ក្នុងមួយឆ្នាំៗ។ លោកស្រីក៏សូមឱ្យអ្នកចូលរួមបន្តគាំទ្រនិងចូលរួមឱ្យបានផុសផុល ទោះបីមិនបានចំណាយថវិកាចូលរួម ក៏ចូលរួមដាសកម្មភាព ជាកម្លាំង និងផ្សព្វផ្សាយ។ លោកស្រីក៏បានថ្លែងអំណរគុណដល់អាជ្ញាធរជាតិអប្សរាដែលបានបើកទូលាយដល់សាធារណៈជនបានចូលរួមដើម្បីប្រយោជន៍សង្គមនិងបេតិកភណ្ឌ៕









អាជ្ញាធរជាតិអប្សរាបញ្ចប់ការជួសជុលច្រាំងកសិន្ទអង្គរវត្តជ្រុងខាងលិចស្ពាបខាងជើងប្រវែង៤០ម៉ែត្រ និងបន្តធ្វើ២០ម៉ែត្រទៀត

ផ្សាយនៅថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០១៨

ច្រាំងកសិន្ទអង្គរវត្តជ្រុងខាងលិច ស្ពាបខាងជើងប្រវែង៤០ម៉ែត្រ ត្រូវបានជួសជុលដោយអ្នកជំនាញអាជ្ញាធរជាតិអប្សរា រួចរាល់ជាស្ថាពរកាលពីចុងឆ្នាំ២០១៧ និងកំពុងបន្តជួសជុលប្រវែង២០ម៉ែត្របន្ថែមទៀត នៅក្នុងឆ្នាំ២០១៨។

លោកស្រី នង ប៉ារី បុរាណវិទូនៃនាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរនិងបុរាណវិទ្យាបង្គារបស់អាជ្ញាធរជាតិអប្សរា បានឱ្យដឹងថា ច្រាំងកសិន្ទប្រវែង៤០ម៉ែត្រដែលជួសជុលរួច គឺចំណាយរយៈពេល៤ឆ្នាំ ដោយចាប់ផ្តើមពីឆ្នាំ២០១៣ដល់ ២០១៧។ ក្នុងចំណោម៤០ម៉ែត្រនេះដែរ គឺមានប្រវែង២០ម៉ែត្រដំបូងឆ្លាប់បានជួសជុលម្តងហើយដោយបារាំងនាទសវត្សទី៦០ ដែលដឹងបានតាមរយៈការមើលឃើញដោយផ្ទាល់ និងកាន់តែច្បាស់ពេលបើករណ្តៅកំណាយស្រាវជ្រាវមុនធ្វើការជួសជុល។ ក្រោយការបញ្ចប់គម្រោង៤០ម៉ែត្រដោយជោគជ័យ ក្រុមការងារក៏បានបន្តគម្រោងជួសជុល២០ម៉ែត្របន្ថែមនៅឆ្នាំ២០១៨។

លោកស្រីបន្តទៀតថា ចំពោះបច្ចេកទេសជួសជុល បន្ទាប់ពីកំណាយស្រាវជ្រាវយើងដឹងថា ចាស់បុរាណកសាងច្រាំងកសិន្ទដោយដីបុកបង្គាប់បាតគ្រឹះក្រោម ដូច្នេះដើម្បីរក្សាតម្លៃនៃបេតិកភណ្ឌវប្បធម៌ អាជ្ញាធរជាតិអប្សរាបានជ្រើសយកបច្ចេកទេសបុរាណមកអនុវត្ត ដោយកាយយកដីចាស់ ដីស្អុយចេញ ហើយជំនួសដោយដីថ្មី ហើយបុកបង្គាប់គ្រឹះក្រោមឱ្យមាំជាមួយថ្មភ្នំ ថ្មក្រលៀន ដីខ្សាច់ និងល្បាយដីដែលបានពីកម្ទេចថ្មបាយក្រៀម ដីឥដ្ឋ កំបោរស។ ចំពោះគ្រឹះ យើងពង្រីក

ទំហំគ្រឹះចាស់៨០សង់ទីម៉ែត្រទៅ១២០សង់ទីម៉ែត្រ ហើយជម្រៅគ្រឹះទៅក្រោម៣០សង់ទីម៉ែត្រទៅ៨០សង់ទីម៉ែត្រ ធ្វើយ៉ាងណាឱ្យកាំកសិន្ទុរឹងមាំបានល្អ។

ក្រៅពីពង្រឹងគ្រឹះហើយ យើងក៏ពង្រឹងរចនាសម្ពន្ធច្រាំងកសិន្ទុដោយប្រើថ្មបាយក្រៀមចាស់ដែលមានស្រាប់និងថ្មបាយក្រៀមថ្មីជំនួសថ្មដែលពុកផុយមករៀបជាជណ្តើរចំនួន៨កាំ ដោយដាក់ឆ្លាស់គ្នា និងដាប់ចុះក្រោម១សង់ទីម៉ែត្រសម្រាប់ប្រទាក់គ្នាពីមួយទៅមួយក្នុងការរក្សាលំនឹងឱ្យបានល្អមិនឱ្យថ្មរអិល ហើយបិទភ្ជាប់ថ្មពីមួយទៅមួយដោយបាយអរារ៉ៅ ដើម្បីការពារដម្រាបទឹកចូលក្នុងថ្ម ធ្វើឱ្យថ្មឆាប់ពុកផុយ។ រីឯថ្មកក់ដែលរៀបនៅផ្នែកខាងលើថ្មបាយក្រៀមក៏រៀបទៅតាមលំនាំដើម ដោយប្រើថ្មដែលមានស្រាប់និងថ្មីជំនួសថ្មីដែលមិនអាចទ្រទម្ងន់បានទៀត ហើយបិទភ្ជាប់ថ្មដោយបាយអរម្សៅ ដើម្បីធ្វើតស្នាមមិនឱ្យទឹកចូលក្នុងថ្ម ធ្វើឱ្យថ្មឆាប់ខូច។

លោកស្រី ប៉ូរ៉ាវី ក៏បានបញ្ជាក់ដែរពីមូលហេតុសំខាន់ៗដែលធ្វើឱ្យរចនាសម្ពន្ធសំណង់កសិន្ទុអង្គរវត្តផ្នែកខាងលិចស្លាបខាងជើងរងនូវការខូចខាតយ៉ាងខ្លាំង គឺដោយសារអាយុកាលនៃសំណង់ កង្វះការថែទាំជាប្រចាំ ការឡើងចុះនៃកម្ពស់ទឹកមិនទៀងទាត់បានបំផ្លាញគ្រឹះក្រោម រួមទាំងការពុកផុយនៃស្រទាប់ថ្មបាយក្រៀមខាងក្រោម ដើមឈើធំៗដុះក្បែរច្រាំងបានចាក់ឫសជ្រែកទៅក្នុងថ្ម ធ្វើឱ្យថ្មរំកិលពីទីតាំងដើម នាំឱ្យច្រាំងកសិន្ទុរលំ។

បច្ចុប្បន្នអាជ្ញាធរជាតិអប្សរាបានយកចិត្តទុកដាក់យ៉ាងខ្លាំងលើការអភិរក្សនិងជួសជុលទាំងប្រាសាទនិងកសិន្ទុ ដើម្បីអភិរក្សសំណង់បុរាណដែលជានិមិត្តរូបនៃជាតិខ្មែរឱ្យរឹងមាំយូរអង្វែង និងលើកតម្លៃសោភ័ណភាពសំណង់បេតិកភណ្ឌឱ្យមានភាពស្រស់ស្អាតជាទីទាក់ទាញទេសចរ។ បន្ថែមពីនោះ ការបណ្តុះធនធានមនុស្ស ក៏ជាផ្នែកសំខាន់ដែលអាជ្ញាធរជាតិអប្សរាគិតគូរយ៉ាងខ្លាំង ដើម្បីបង្កើនស្នាដៃក្នុងនាមជារបស់ខ្លួន ដោយមិនពឹងលើកិច្ចសហប្រតិបត្តិការអន្តរជាតិច្រើនដូចមុន៕









អាជ្ញាធរជាតិអប្សរាអបអរសាទរជូនចំពោះលោកជំទាវ ភឿង សកុណា

ក្នុងតំណែងជា រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ នៃរាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៦

ផ្សាយនៅថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១៨

យើងខ្ញុំទាំងអស់គ្នាជាថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិក នៃអាជ្ញាធរជាតិអប្សរាសូមអបអរសាទរយ៉ាងស្មគ្រស្មោះជូនចំពោះ **លោកជំទាវ ភឿង សកុណា** ក្នុងតំណែងជារដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ នៃរាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៦ ក្នុងឱកាសដ៏វិសេសថ្លៃថ្លានេះ យើងខ្ញុំសូមគោរពជូនពរលោកជំទាវរដ្ឋមន្ត្រី ទទួលបាននូវសុខភាពល្អ កម្លាំងមាំមួន បញ្ញាវាងវៃ ដើម្បីបន្តបំពេញបេសកកម្មក្នុងបុព្វហេតុ វប្បធម៌ បេតិកភណ្ឌ និងវិចិត្រសិល្បៈបន្តទៀត។



សកម្មភាពក្នាក់ទាក់ទងទេសចរណ៍នៃអាជ្ញាធរជាតិអប្សរាចានជួយសង្គ្រោះភ្ញៀវ និងប្រគល់របស់ជូនភ្ញៀវទេសចរ

ផ្សាយនៅថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១៨

ក្នាក់ងារទេសចរណ៍ មានតួនាទីសំខាន់ក្នុងការផ្តល់នូវព័ត៌មានអំពីសេវាកម្មទេសចរណ៍ដល់ភ្ញៀវ មើលសកម្មភាពនានានៅក្នុងរមណីយដ្ឋានអង្គរ និងពន្យល់ណែនាំឱ្យភ្ញៀវគោរពតាមក្រមប្រតិបត្តិអង្គរ ជួយសង្គ្រោះភ្ញៀវ ជួយស្វែងរកនិងប្រគល់របស់ជូនភ្ញៀវ ជាពិសេសដោះស្រាយនូវបញ្ហាផ្សេងៗដែលបានកើតឡើងចំពោះភ្ញៀវដោយថាហេតុក្នុងដំណើរទស្សនាតំបន់អង្គរ។

របាយការណ៍សកម្មភាពការងាររបស់នាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍អង្គរនៃអាជ្ញាធរជាតិអប្សរាប្រចាំខែសីហា ឆ្នាំ២០១៨ បង្ហាញថា ក្រុមការងារជួយសង្គ្រោះភ្ញៀវទេសចរដែលរងរបួសដោយ រអិលឬជំពប់ជើង ដួល គ្រិច ថ្លោះដៃ ជើង ខ្យល់គរលើមុខ ចុកពោះ សត្វស្វាខាំ និងពុលអាហារជាដើមបាន១៩ករណី។ បញ្ហាទាំងនេះកើតឡើងដោយសារភ្ញៀវខ្លះមានការធ្វេសប្រហែស និងមិនគោរពតាមការណែនាំ ឬផ្លាកសញ្ញាហាមឃាត់ និងបញ្ហាសុខភាពផ្ទាល់ខ្លួន។

បញ្ហាទាំងនេះត្រូវបានក្នាក់ងារទេសចរណ៍ដែលមានជំនាញសង្គ្រោះបឋម និងមានបរិក្ខារសង្គ្រោះបឋមនៅជាប់ខ្លួនជួយសង្គ្រោះបឋមទាន់ពេលវេលានៅកន្លែងកើតហេតុក្នុងករណីស្រាលៗនិងសហការជាមួយនគរបាលទេសចរ និងនគរបាលការពារបេតិកភណ្ឌ បញ្ជូនទៅមន្ទីរពេទ្យក្នុងរកណីរបួសធ្ងន់ធ្ងរ។

ក្រុមក្នាក់ងារទេសចរណ៍ក៏បានរើសរបស់របរភ្ញៀវដែលភ្លេចឬជ្រុះនៅតាមប្រាសាទចំនួន៣៤ករណី និងបានរកឃើញ៣១ករណីរួមមាន៖ ទូរសព្ទដៃ អាយផេត កាបូបស្ពាយ កាបូបយួរដៃ កាបូបលុយ កាតវីសា និងម៉ាស៊ីនថតជាដើម ហើយបានរកឃើញនិងប្រគល់ជូនម្ចាស់វិញ។ ឯរបស់ខ្លះទៀត ដែលភ្ញៀវមិនបានមករកភ្លាមៗ ក្រុមការងារបានប្រគល់ឱ្យនគរបាលទេសចរណ៍រក្សាទុក រងចាំម្ចាស់ដើមមកទាក់ទងយក។ គួរបញ្ជាក់ថាសកម្មភាពទាំងអស់នេះទទួលបាននូវការថ្លែងអំណរគុណនិងការកោតសរសើរយ៉ាងកក់ក្តៅពីសំណាក់ភ្ញៀវទេសចរជាតិនិងអន្តរជាតិ ព្រមទាំងបានបង្ហាញនូវក្តីស្រលាញ់និងទំនុកចិត្តខ្ពស់មកលើក្នាក់ងារទេសចរណ៍។

ក្រៅពីសកម្មភាពសង្គ្រោះនិងការរើស ប្រគល់វត្ថុដែលភ្ញៀវបាត់ឬភ្លេច ក្រុមក្នាក់ងារទេសចរណ៍ក៏បានហាមឃាត់ភ្ញៀវដែលប្រព្រឹត្តិមិនសមរម្យបានចំនួន៦២ករណីរួមមាន៖ ការបង្ហោះត្រួន (Drone) ការបន្ទោបង់ក្នុងបរិវេណប្រាសាទ ជនបរទេសថតរូបអាពាហ៍ពិពាហ៍ដោយគ្មានការអនុញ្ញាត ការថតរូបបញ្ចេញកាយវិការមិនសមរម្យ (ថតបង្ហាញម៉ូត ថតរូបភាពមិនសមរម្យ) ស្លៀកពាក់មិនសមរម្យ សម្តែងសៀកនៅក្នុងប្រាសាទ រៀបចំពិធីទទួលទានអាហារនៅក្នុងប្រាសាទ ប្រើប្រាស់ម៉ាស៊ីនថតខ្នាតធំ ធ្វើពិធីសាសនាដោយគ្មានការអនុញ្ញាត ថតរូបផ្សព្វផ្សាយពាណិជ្ជកម្មនិង គូរគំនូរលក្ខណៈទ្រង់ទ្រាយធំដោយមិនមានការអនុញ្ញាត។ល។ ក្រោយពីហាមឃាត់ ក្រុមក្នាក់ងារទេសចរបានណែនាំតាមគោលការណ៍ដែលមានជាធរមាន និងពន្យល់ណែនាំដល់បុគ្គលទាំងនោះ ត្រូវដាក់សំណើសុំច្បាប់អនុញ្ញាតពីអាជ្ញាធរជាតិអប្សរាជាមុនសិន ក្នុងករណីណាមួយដែលត្រូវឆ្លងកាត់អាជ្ញាធរជាតិអប្សរា៕






អាជ្ញាធរជាតិអប្សរានិងមូលនិធិបេតិកភណ្ឌវប្បធម៌កូរ៉េ
នឹងបន្តកិច្ចសហការលើការអភិរក្សជួសជុលក្រុមប្រាសាទព្រះពិឃ្នេរ

ផ្សាយនៅថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៨

នៅព្រឹកថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៨ គណៈប្រតិភូកូរ៉េដឹកនាំដោយ**លោក** Kwon Sagju នាយកផ្នែកផែនការនៃមូលនិធិបេតិកភណ្ឌវប្បធម៌កូរ៉េ (KOCHEF) ចូលជួបសម្តែងការគួរសមជាមួយ **ឯកឧត្តម ហង់ ពៅ** អគ្គនាយករងអាជ្ញាធរជាតិអប្សរា ដើម្បីពិភាក្សាការងារបន្តលើគម្រោងអភិរក្សជួសជុលក្រុមប្រាសាទពិឃ្នេរ ដែលនឹងត្រូវបញ្ចប់ដំហានទី១នៅចុងឆ្នាំ ២០១៨ និងពិភាក្សាអំពីការអនុវត្តបន្តសម្រាប់ដំហានទី២ នៅឆ្នាំ២០១៩។

នៅក្នុងជំនួបពិភាក្សានេះ ភាគីទាំងពីរសន្យាពង្រឹងទំនាក់ទំនងល្អរវាងស្ថាប័នKOCHEFនិងអាជ្ញាធរជាតិអប្សរាឱ្យកាន់តែរឹងមាំ។ ជាពិសេសភាគីកូរ៉េ បានថ្លែងអំណរគុណដល់អាជ្ញាធរជាតិអប្សរា ដែលអនុញ្ញាតឱ្យអ្នកជំនាញកូរ៉េបានចូលរួមក្នុងកិច្ចការអភិរក្ស និងជួសជុលប្រាសាទបុរាណខ្មែរក្នុងតំបន់អង្គរ និងបានរៀនសូត្របន្ថែមពីអាជ្ញាធរជាតិអប្សរា។

អាជ្ញាធរជាតិអប្សរាក៏សូមថ្លែងអំណរគុណដល់មូលនិធិបេតិកភណ្ឌវប្បធម៌កូរ៉េដែលបានផ្តល់កិច្ចសហប្រតិបត្តិការល្អ និងបានបណ្តុះបណ្តាលជំនាញផ្សេងៗដល់អ្នកជំនាញខ្មែរទាំងក្នុងនិងក្រៅប្រទេសនាពេលកន្លងមក។ ដោយឡែក ដើម្បីចែករំលែកនូវបទពិសោធន៍ល្អៗទាំងលើកិច្ចការអភិរក្សនិងការគ្រប់គ្រងរមណីយដ្ឋានបេតិកភណ្ឌពិភពលោក ភាគីទាំងពីរបាន

ឯកភាពទៅលើកម្មវិធីបណ្តុះបណ្តាលនាពេលអនាគតដោយផ្តោតលើប្រធានបទសំខាន់ៗដូចជា ជំនាញវិទ្យាសាស្ត្រអំពីការអភិរក្សនិងជួសជុលបេតិកភណ្ឌ និងការគ្រប់គ្រងទូទៅក្នុងតំបន់បេតិកភណ្ឌពិភពលោក។

គួររំឭកដែរថា គម្រោងជួសជុលអភិរក្សក្រុមប្រាសាទព្រះពិធូរបានចាប់ផ្តើមឡើងតាំងពីឆ្នាំ២០១៥ ហើយនឹងបញ្ចប់ដំហានដំបូងនៅចុងឆ្នាំ២០១៨៕






សិក្ខាកាម១២នាក់នៃអាជ្ញាធរជាតិអប្សរាបញ្ចប់វគ្គសិក្សាការពិសោធបែបវិទ្យាសាស្ត្រសម្រាប់កិច្ចការអភិរក្ស

ផ្សាយនៅថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៨

វគ្គសិក្សាស្តីពីការពិសោធបែបវិទ្យាសាស្ត្រសម្រាប់កិច្ចអភិរក្ស ដែលបង្រៀនដោយអ្នកជំនាញអន្តរជាតិផ្នែកអភិរក្សបេតិកភណ្ឌនៃស្ថាប័នGIZ **លោកស្រីបណ្ឌិត** Federica Grifi ដល់សិក្ខាកាមចំនួន១២នាក់ មកពីក្រុមអភិរក្សថ្ម (SCU/GIZ) និងនាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរនិងបុរាណវិទ្យាបង្គារ បានបញ្ចប់នាព្រឹកថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៨។

លោកស្រីបណ្ឌិត Federica Grifi មានប្រសាសន៍ថា វគ្គសិក្សានេះបានចាប់ផ្តើមកាលពីថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៨ មានរយៈពេល១៦០ម៉ោង។ គោលបំណងដើម្បីបំពេញបន្ថែមនូវចំណុចខ្វះខាតដែលមានលើបទពិសោធន៍ការងារកន្លងមក និងចង់ឱ្យអ្នកជំនាញចេះស្រាវជ្រាវ ស្វែងយល់បានច្បាស់អំពីដំណើរការនៃការប្រើប្រាស់ឧបករណ៍ពិសោធន៍ និងការអនុវត្តផ្ទាល់រកលទ្ធផលមុននឹងយកវាទៅធ្វើលើវត្ថុពិត។ បន្ថែមពីនោះក៏ដើម្បីឱ្យអ្នកសិក្សាចេះស្វែងយល់បន្ថែមអំពីដំណើរការទំនាក់ទំនងនៃការងារអភិរក្សថ្មនៅតាមប្រាសាទនានា។

លោក ឡុង ណារី មន្ត្រីជំនាញអភិរក្សថ្មនៃនាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរនិងបុរាណវិទ្យាបង្គារ ដែលបានសិក្សាវគ្គនេះអស់រយៈពេល៦ខែមកហើយ បានចាប់អារម្មណ៍ថា វគ្គបណ្តុះបណ្តាលនេះហាក់ខ្លីបន្តិចចំពោះពេលវេលារៀនសូត្រ ព្រោះមួយអាទិត្យយើងរៀនតែមួយថ្ងៃ ទើបតម្រូវឱ្យពួកយើងធ្វើការស្រាវជ្រាវឯកសារដោយខ្លួនឯងច្រើន។ លោកក៏រំពឹងថា ថ្ងៃអនាគតបើមានឱកាស ពួកយើងចង់ចូលរៀនវគ្គបណ្តុះបណ្តាលបែបនេះទៀតជាមួយអ្នកជំនាញ ពិសេសពួកយើងចង់រៀនពីការងារនៅក្នុងបន្ទប់ពិសោធន៏ឱ្យបានច្រើនជាងនេះ។

តំណាងឱ្យអគ្គនាយកអាជ្ញាធរជាតិអប្សរានៅក្នុងពិធីបិទវគ្គ **លោក អ៊ឹម សុខរិទ្ធី** អនុប្រធានមជ្ឈមណ្ឌលស្រាវជ្រាវអន្តរជាតិនិងតម្កល់ឯកសារអង្គរបានលើកឡើងថា នេះជាឱកាសល្អសម្រាប់អ្នកជំនាញអាជ្ញាធរជាតិអប្សរាអភិវឌ្ឍសមត្ថភាពខ្លួនលើការងារប្រចាំថ្ងៃនិងមានគោលដៅវែងឆ្ងាយលើវិស័យបេតិកភណ្ឌ។ ការសិក្សានៅទីនេះ អាចនឹងល្អជាងបរទេសមួយចំនួនព្រោះមានទាំងមន្ទីរពិសោធន៏និងការអនុវត្តនៅលើទីតាំងផ្ទាល់ រួមទាំងមានអ្នកជំនាញអន្តរជាតិជាច្រើនមកចែករំលែកចំណេះដឹងបន្ថែមជាញឹកញាប់។ លោកក៏សូមអរគុណដល់អ្នកស្រីបណ្ឌិតដែលបានចែករំលែកចំណេះដឹងដល់អ្នកជំនាញអាជ្ញាធរជាតិអប្សរាក្នុងការអភិវឌ្ឍសមត្ថភាពចំណេះដឹងបន្ថែមពីអ្វីដែលធ្លាប់មានទាំងទ្រឹស្តីនិងការអនុវត្តការពិសោធបែបវិទ្យាសាស្ត្រសម្រាប់កិច្ចការអភិរក្សកាន់តែច្បាស់លាស់៕









អាជ្ញាធរជាតិអប្សរាប្រជុំផ្ទៃក្នុងកណ្តាលកម្មការប្រព័ន្ធគ្រប់គ្រងបរិស្ថាន-អង្គរ ISO 14001:2015

ផ្សាយនៅថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៨

នៅព្រឹកថ្ងៃទី១៧ កញ្ញា ឆ្នាំ២០១៨ អង្គភាពគ្រប់គ្រងបរិស្ថានអង្គរនៃអាជ្ញាធរជាតិអប្សរា បានរៀបចំបើកសវនកម្មផ្ទៃក្នុងលើប្រព័ន្ធគ្រប់គ្រងបរិស្ថាន-អង្គរ ស្របតាមស្តង់ដារអន្តរជាតិ ISO14001 គ្រប់នាយកដ្ឋាន និងអង្គភាពចំណុះនៃអាជ្ញាធរជាតិអប្សរា។

កិច្ចប្រជុំប្រព្រឹត្តទៅក្រោមអធិបតីភាព **ឯកឧត្តម ហង់ ពៅ** អគ្គនាយករងជាតំណាង **ឯកឧត្តមបណ្ឌិត ស៊ុំ ម៉ាប់** អគ្គនាយកអាជ្ញាធរជាតិអប្សរា ថ្នាក់ដឹកនាំនាយកដ្ឋាន និងអ្នកជំរុញការងារបរិស្ថានគ្រប់នាយកដ្ឋានពាក់ព័ន្ធទាំងអស់។

ការបើកសវនកម្មផ្ទៃក្នុងលើប្រព័ន្ធគ្រប់គ្រងបរិស្ថាន-អង្គរនេះ ធ្វើឡើងដើម្បីពិភាក្សា ដោះស្រាយបញ្ហាបរិស្ថាន ចង្អុលទិសដៅអំពីគោលបំណងបរិស្ថានរបស់អាជ្ញាធរជាតិអប្សរាទាំងមូល និងសម្របសម្រួលរាល់សកម្មភាពការងារបរិស្ថានក្នុងតំបន់អង្គរដោយអនុលោមតាមស្តង់ដារ ISO14001 ដែលអាជ្ញាធរជាតិអប្សរាទទួលបានពីស្ថាប័នធានាគុណភាពជប៉ុន Japan Quality Assurance (JQA)។

លោក ភោគ បញ្ញា អនុប្រធានស្តីទីអង្គភាពប្រព័ន្ធគ្រប់គ្រងបរិស្ថាន បានលើកឡើងថា ចំពោះលទ្ធផលការធ្វើសវនកម្មផ្ទៃក្នុងឆ្នាំ២០១៨ គឺនាយកដ្ឋាននិងអង្គភាពចំនួន១៦នៃស្ថាប័នអាជ្ញាធរជាតិអប្សរា នៅតែបន្តភាពវិជ្ជមាន ដោយមិនមានភាពមិនអនុលោមណាមួយឡើយ ដែលខុសពីស្តង់ដា SIO 14001។ ប៉ុន្តែមានចំណុចតាមសង្កេតចំនួន៣ចំណុច ដែលស្ថិតនៅលើគោលបំណងនៃកម្មវិធី ដែលសវនករបានផ្តល់ជាអនុសាសន៍គ្រប់នាយកដ្ឋានបានកំណត់ បង្កើតកម្មវិធីអនុវត្ត និងទទួលលទ្ធផលតាមផែនការច្បាប់ ប៉ុន្តែការកំណត់គោលដៅក្នុងផែនការអនុវត្តនេះរក្សានៅដដែលដូចឆ្នាំ២០១៧និង ២០១៨ ដោយកំណត់ទិសដៅបរិស្ថានឱ្យលើសពីឆ្នាំចាស់។

ថ្លែងក្នុងអង្គប្រជុំ **ឯកឧត្តម ហង់ ពៅ** បានរំឭកថា ការបង្កើតប្រព័ន្ធការពារបរិស្ថាន សំខាន់ជាងគេគឺយល់ពីការគ្រប់គ្រងរួម ហើយមានទំនាក់ទំនងគ្នាទៅវិញទៅមក ទោះបីជានាយកដ្ឋានផ្សេងៗ ឬជំនាញផ្សេងៗ គឺត្រូវតែមានការពាក់ព័ន្ធគ្នាគ្រប់នាយកដ្ឋាន។ ដូច្នេះក្រុមបរិស្ថានជាអ្នកសម្របសម្រួល ធ្វើយ៉ាងណាឱ្យត្រូវតាមចំណុចទាមទាររបស់ស្តង់ដារ ISO 14001 ហើយម្ចាស់សាមីនាយកដ្ឋានឬអង្គភាពនីមួយៗ ត្រូវចូលរួមអនុវត្តឲ្យបានខ្ជាប់ខ្ជួន។ ឯកឧត្តមបន្តថា កិច្ចការនេះគឺជាការងារយើងទាំងអស់គ្នាដោយមិនផ្តោតតែទៅលើនរណាម្នាក់ឡើយ ទើបអាចបង្ហាញពីប្រសិទ្ធិភាពនៃការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរាលើប្រព័ន្ធបរិស្ថានបានជោគជ័យ។

គួររំឭកថា អាជ្ញាធរជាតិអប្សរាបានចុះឈ្មោះ ដើម្បីទទួលបានការវាយតម្លៃលើប្រព័ន្ធគ្រប់គ្រងបរិស្ថាន ពីស្ថាប័នធានាគុណភាពជប៉ុន JQA តាំងពីឆ្នាំ២០០៣មក ហើយក៏ធ្លាប់បានទទួលវិញ្ញាបនបត្រ ISO14001 លើការងារគ្រប់គ្រងប្រព័ន្ធបរិស្ថានពីស្ថាប័នអន្តរជាតិមួយនេះ ចំនួន៥លើករួចមកហើយដែរ៕









ព្រឹត្តិការណ៍សមរាត្រីឆ្នាំ២០១៨មកដល់ខៀតហើយ

ផ្សាយនៅថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៨

តាមការសិក្សារបស់អ្នកស្រាវជ្រាវរបស់មជ្ឈមណ្ឌលស្រាវជ្រាវនិងតម្កល់ឯកសារអង្គរនៃអាជ្ញាធរជាតិអប្សរា សមរាត្រីនារដូវស្សាឆ្នាំ២០១៨នេះ នឹងត្រូវចំថ្ងៃអាទិត្យ ១៤កើត ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ពុទ្ធសករាជ២៥៦២ ត្រូវនឹងថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៨។

ជារៀងរាល់ឆ្នាំ សមរាត្រី (Equinox) តែងតែកើតមាន២ដង គឺនៅរដូវប្រាំង (Vernal Equinox) កើតឡើងនៅខែមីនា និងសមរាត្រីរដូវស្សា (Autumnal Equinox) កើតឡើងនៅខែកញ្ញា។
សមរាត្រីជាវេលាដែលថ្ងៃនិងយប់មានរយៈពេលស្មើគ្នាតែស្មើគ្នា។ ក្រៅពីនេះ ខែខ្លះថ្ងៃមានរយៈពេលវែងជាងយប់ ហើយខ្លះទៀត យប់មានរយៈពេលវែងជាងថ្ងៃវិញ។

ជាករណីពិសេសនៅអង្គរវត្ត វេលាថ្ងៃនិងយប់មានរយៈពេលស្មើគ្នានេះ ព្រះអាទិត្យតែងតែរះឡើងចំកំពូលកណ្តាលនៃអង្គរវត្តនាព្រឹកព្រលឹមស្រាងៗ។ ចំពោះសមរាត្រីរដូវស្សានៅថ្ងៃទី២៣ ខែកញ្ញានេះ ព្រះអាទិត្យនឹងរះឡើងចំកំពូលកណ្តាលដែលយើងអាចមើលឃើញពីស្ពោងទ្វារកណ្តាលនៃគុកតារាជ (ស្ពោងទ្វារធំខាងលិច) ចាប់ម៉ោង៥និង៥០នាទីដល់ម៉ោងប្រហែល៧ព្រឹក។ សង្ឃឹមថា អាកាសធាតុនឹងអំណោយផលសម្រាប់ការផ្តិតយករូបភាពរបស់ថ្ងៃរះជាមួយប្រាសាទអង្គរវត្តដ៏ស្អាតអស្ចារ្យ៕





កិច្ចប្រជុំបច្ចេកទេសលើកទី៤ ចាននឹកសម័យប្រជុំរបស់ខ្លួនលើយនៅព្រឹកថ្ងៃទី២០នេះ

ផ្សាយនៅថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១៨

នៅព្រឹកថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៨ **លោកជំទាវ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាប្រធានអាជ្ញាធរជាតិអប្សរា បានដឹកនាំគណៈប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ចូលរួមកិច្ចប្រជុំបច្ចេកទេសលើកទី៤ របស់គណៈកម្មាធិការសម្របសម្រួលអន្តរជាតិសម្រាប់ការអភិរក្ស និងការលើកតម្លៃថព្រះវិហារ ហៅកាត់ថា អាយស៊ីស៊ី-ព្រះវិហារ (ICC- Preah Vihear) នៅសាលសន្និសីទអង្គរនៃអាជ្ញាធរជាតិអប្សរា។

កិច្ចប្រជុំគណៈកម្មាធិការ អាយស៊ីស៊ី-ព្រះវិហារ ដឹកនាំដោយសហប្រធាននៃប្រទេសចិន និងប្រទេសឥណ្ឌា និងប្រទេសជាសមាជិកចំនួន ៦ទៀត រួមមាន ប្រទេសបែកហ្សិក បារាំង ជប៉ុន សាធារណរដ្ឋកូរ៉ែ ថៃឡង់ដ៍ និងសហរដ្ឋអាមេរិក ព្រមទាំងមានការចូលរួមពីអ្នកជំនាញជាតិ និងអន្តរជាតិ ដើម្បីពិភាក្សាគ្នាអំពីយន្តការនៃការអភិរក្ស និងអភិវឌ្ឍរមណីយដ្ឋានប្រាសាទព្រះវិហារ និងរមណីយដ្ឋានប្រាសាទកោះកែរ។

កិច្ចប្រជុំបច្ចេកទេសលើកទី៤ របស់គណៈកម្មាធិការ ICC-Preah Vihear នៅឆ្នាំនេះផ្តោតការពិភាក្សាអំពីការងារកំណាយបុរាណប្រព័ន្ធបង្ហូរទឹកប្រាសាទព្រះវិហារ ការរៀបចំទីតាំងបដិសណ្ឋារកិច្ចលើភ្នំប្រាសាទព្រះវិហារ ការរៀបចំផែនការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍ និងការរៀបចំកម្មវិធីអភិវឌ្ឍសហគមន៍នៅរមណីយដ្ឋានប្រាសាទព្រះវិហារ និងប្រាសាទកោះកែរ និងការងារចាំបាច់មួយចំនួនផ្សេងៗទៀត។

គួរបញ្ជាក់ថា អាជ្ញាធរជាតិព្រះវិហារ និងលេខាធិការដ្ឋានអចិន្ត្រៃយ៍ ICC-Preah Vihear តែងតែរៀបចំកិច្ចប្រជុំនេះ២ដងក្នុងមួយឆ្នាំ ដែលរួមមានកិច្ចប្រជុំពេញអង្គរៀបចំនៅរៀងរាល់ខែ មីនា និងកិច្ចប្រជុំបច្ចេកទេស តែងរៀបចំនៅរាល់ខែ កញ្ញា៕









អាជ្ញាធរអប្សរាសូមជូនដំណឹងដល់បេក្ខជនទាំងអស់ដែលបានដាក់ពាក្យចូលបម្រើការងារជាភ្នាក់ងារទេសចរ បានជ្រាបថាអាជ្ញាធរអប្សរា នឹងធ្វើការប្រលងជ្រើសពីសនៅថ្ងៃព្រហស្បតិ៍ ទី២៧ ខែកញ្ញា ឆ្នាំ ២០១៨

ផ្សាយនៅថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១៨



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA
លេខ.៥៤៦/សៈ.សឌណ
១៨

ថ្ងៃ សុក្រ ១២កើត ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២
សៀមរាប ថ្ងៃទី ២១ ខែកញ្ញា ឆ្នាំ២០១៨

សេចក្តីជូនដំណឹង

អាជ្ញាធរអប្សរា "អាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ" (www.apsaraauthority.gov.kh) សូមជូនដំណឹងដល់បេក្ខជនទាំងអស់ដែលបានដាក់ពាក្យចូលបម្រើការងារជាភ្នាក់ងារទេសចរ បានជ្រាបថា អាជ្ញាធរអប្សរា នឹងធ្វើការប្រលងជ្រើសរើស តាមកាលបរិច្ឆេទ ដូចខាងក្រោម ៖

កាលបរិច្ឆេទ ៖ ថ្ងៃព្រហស្បតិ៍ ទី២៧ ខែកញ្ញា ឆ្នាំ២០១៨

ក្រុមទី១ បេក្ខជនដែលមានលេខរៀងក្នុងបង្ហាន់ដៃទទួលពាក្យ ពីលេខរៀងទី០១ រហូត ដល់លេខរៀងទី២៥០ ប្រលងម៉ោង ៨៖៣០ នាទី ព្រឹក

ក្រុមទី២ បេក្ខជនដែលមានលេខរៀងក្នុងបង្ហាន់ដៃទទួលពាក្យ ពីលេខរៀងទី២៥១ រហូត ដល់លេខរៀងទី៨៥១ ប្រលងម៉ោង ៩៖៣០ នាទី ព្រឹក

មណ្ឌលប្រលង ៖ សាលសន្និសីទអង្គរ

អាស្រ័យដូចបានជម្រាបខាងលើ សូមបេក្ខជនទាំងអស់ជ្រាបជាព័ត៌មាន។

ក្នុងនាម:
មហាឥសាបាតិត្ថូរាជ្ឌ លោងឯ សង្ឋាន់ឌិត្ថូកាន មណ្ឌលបាន
ទូរស្ទូ/ទូរសារ ៦៥៣ ៣៤៥ ៣៤៥/៦៥៣ ៣៤៥ ៣៤៥

អាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ
Email: info@apsaraauthority.gov.kh
Website: http//www.apsaraauthority.gov.kh

អរិយាធរ:
ភូមិបន្ទាន ឃុំតាឯ ឃុរាជ្ជាសាទបាទ បាត្ថាស្ថិមាន
ទូរស្ទូ/ទូរសារ ៦៥៣ ៣៤៥ ៣៤៥/៦៥៣ ៣៤៥ ៣៤៥

អាជ្ញាធរជាតិអប្សរានិងភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉ៃ KOICA នឹងចុះអនុស្សារណៈយោគយល់ព្រៅ នៅចុងឆ្នាំ២០១៨ដើម្បីបន្តជួសជុលក្រុមប្រាសាទព្រះពិធូរដំហានទី២ និងព្រះលានដល់ដំរី

ផ្សាយនៅថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១៨

នៅព្រឹកថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ គណៈប្រតិភូកូរ៉េដឹកនាំដោយ **លោកស្រី Weon Jihye** អនុប្រធានភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA) បានចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារមួយចំនួននៅតំបន់អង្គរជាមួយ **ឯកឧត្តម ហង់ ពៅ** អគ្គនាយករងអាជ្ញាធរជាតិអប្សរាតំណាង**ឯកឧត្តមបណ្ឌិត ស៊ុំ ម៉ាប់** អគ្គនាយកអាជ្ញាធរជាតិអប្សរា។

ក្នុងជំនួបពិភាក្សានេះបានផ្តោតសំខាន់ទៅលើការចុះអនុស្សារណៈយោគយល់គ្នា ដើម្បីបន្តគម្រោងអភិរក្សជួសជុលក្រុមប្រាសាទពិធូរដំណាក់កាលទី២ និងការជួសជុលព្រះលានដល់ដំរី។ ការជួសជុលក្រុមប្រាសាទព្រះពិធូរដំហានទី១បានបញ្ចប់ប្រកបដោយជោគជ័យ ហើយថែមទាំងបានបណ្តុះបណ្តាលធនធានមនុស្សរបស់អាជ្ញាធរជាតិអប្សរាទាំងក្នុងស្រុកនិងក្រៅស្រុកបានយ៉ាងច្រើននិងពេញដោយសមត្ថភាពការងារ ។

គួរឲ្យកត់ដែរថា ភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ KOICAបានចាប់ផ្តើមគម្រោងជួសជុលអភិរក្សក្រុមប្រាសាទព្រះពិធូរកាលពីឆ្នាំ២០១៥ និងបញ្ចប់ដំហានដំបូងនៅចុងឆ្នាំ២០១៨ និងបានបណ្តុះបណ្តាលជំនាញផ្សេងៗដល់អ្នកជំនាញខ្មែរទាំងក្នុងនិងក្រៅប្រទេសនាពេលកន្លងមកដើម្បីចែករំលែកនូវបទពិសោធន៍ល្អៗទាំងលើកិច្ចការអភិរក្សនិងការគ្រប់គ្រងរមណីយដ្ឋានបេតិកភណ្ឌពិភពលោក៕









អាជ្ញាធរជាតិអប្សរារៀបចំការប្រឡងជ្រើសរើសភ្នាក់ងារទេសចរណ៍លើកទី២

ផ្សាយនៅថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៨

នៅព្រឹកថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៨ អាជ្ញាធរជាតិអប្សរា បានរៀបចំការប្រឡងជ្រើសរើសភ្នាក់ងារទេសចរណ៍សម្រាប់ឆ្នាំ ២០១៨។ ការប្រឡងនេះ ត្រូវបានរៀបចំឡើងនៅសាលសន្និសីទអង្គរ នៃអាជ្ញាធរជាតិអប្សរា។

ចំពោះបេក្ខជនដែលបានដាក់ពាក្យប្រឡងសរុបមានចំនួនជិត ៥០០នាក់។ ការប្រឡងលើកទី២នេះ គឺដើម្បីជ្រើសរើសបុគ្គលិកបម្រើការងារនៅតាមប្រាសាទនានាក្នុងរមណីយដ្ឋានអង្គរ ដែលលើកទី១ ធ្វើឡើងកាលពីឆ្នាំ២០១៦។ ការប្រឡងនេះនឹងជ្រើសរើសបេក្ខជនចំនួន ៣៤នាក់តែប៉ុណ្ណោះ ដែលជាតម្រូវការជាក់ស្តែងរបស់នាយកដ្ឋាននាពេលបច្ចុប្បន្ន៕









ព្រឹត្តិការណ៍ព័ត៌មាន
ប្រចាំខែតុលា

ផ្នែកទី ១០
ប្រចាំខែតុលា

សេចក្តីជូនដំណឹងស្តីពី ការកាត់ដកហូតដើមឈើ និងកាត់ក្រឹមែកឈើដែលមានហានិភ័យខ្ពស់នៅតាមបរិវេណប្រាសាទ ក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០១៨



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA
លេខ.១៧៤/ប្រ.សផ
១៨

សេចក្តីជូនដំណឹង
ស្តីពី
ការកាត់ដកហូតដើមឈើ និងកាត់ក្រឹមែកឈើ
ដែលមានហានិភ័យខ្ពស់នៅតាមបរិវេណប្រាសាទ ក្នុងរមណីយដ្ឋានអង្គរ

អាជ្ញាធរជាតិអប្សរា សូមជូនដំណឹងដល់ស្ថាប័ន សមត្ថកិច្ចពាក់ព័ន្ធ ភ្ញៀវជាតិ-អន្តរជាតិ មគ្គុទ្ទេសក៍ទេសចរណ៍ ព្រមទាំងសាធារណជនទាំងអស់មេត្តាជ្រាបថា ដើម្បីធានាដល់សុវត្ថិភាពភ្ញៀវទេសចរ សាធារណជន ក៏ដូចជាដើម្បីលើកកម្ពស់សោភ័ណភាពនៅតាមដងផ្លូវ និងនៅតាមបរិវេណប្រាសាទ ក្នុងតំបន់រមណីយដ្ឋានអង្គរ និងតំបន់ដែលគ្រប់គ្រងដោយអាជ្ញាធរជាតិអប្សរា នាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាន នៃអាជ្ញាធរជាតិអប្សរា នឹងកាត់ដកហូតដើមឈើ និងកាត់ក្រឹមែកឈើ តាមទីតាំងនានាដូចខាងក្រោម៖

-កាត់ដកហូត និងកាត់ក្រឹមែកឈើចំនួន ០៧ដើម នៅបរិវេណប្រាសាទបាគង។
-កាត់ដកហូត និងកាត់ក្រឹមែកឈើចំនួន ០៩ដើម នៅក្នុងបរិវេណប្រាសាទភិមានអាកាស។
-កាត់ដកហូត និងកាត់ក្រឹមែកឈើចំនួន ១១ដើម នៅបរិវេណប្រាសាទព្រះពិឋារ។
-កាត់ដកហូត និងកាត់ក្រឹមែកឈើចំនួន ៣៣ដើម នៅក្នុងបរិវេណមុខប្រាសាទអង្គរវត្តទិសខាងលិច។
-កាត់ដកហូត និងកាត់ក្រឹមែកឈើចំនួន ៧៦ដើម នៅបរិវេណប្រាសាទនាគព័ន្ធ។
-កាត់ដកហូតដើមឈើចំនួន ០៣ដើម នៅក្នុងបរិវេណប្រាសាទអង្គរវត្តទិសខាងត្បូង។
-កាត់ដកហូត និងកាត់ក្រឹមែកឈើចំនួន ០៩ដើម ស្ថិតនៅតាមដងផ្លូវឡើងភ្នំបាខែង និងកាត់លះមែកឈើចំនួន០២ទីតាំង។

ការងារនេះ នឹងចាប់ផ្តើមអនុវត្តចាប់ពីថ្ងៃទី ០២ ខែ តុលា ឆ្នាំ២០១៨ រហូតដល់បញ្ចប់ការងារ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមស្ថាប័ន សមត្ថកិច្ចពាក់ព័ន្ធ ភ្ញៀវជាតិ-អន្តរជាតិ មគ្គុទ្ទេសក៍ទេសចរណ៍ ព្រមទាំងសាធារណជនទាំងអស់ មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃពុធ ទី៣ ខែ កញ្ញា ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២
សៀមរាប ថ្ងៃទី០៣ ខែ តុលា ឆ្នាំ២០១៨
អគ្គនាយក

ហង់ ពៅ

ចម្លងជូន៖
-សាលាខេត្តសៀមរាប
-មន្ទីរបរិស្ថានខេត្តសៀមរាប
-មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តសៀមរាប
-អង្គភាពនរបាលការពារបេតិកភណ្ឌប្រចាំខេត្តសៀមរាប
-ស្នាក់ការតំបន់ការពារទេសភាពអង្គរ
-សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ទាំងអស់ប្រចាំខេត្តសៀមរាប
-ដើម្បីជ្រាប និងសហការ-
-ប៉ូលីសទេសចរណ៍
-គ្រប់នាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធរបស់អាជ្ញាធរអប្សរា
-ដើម្បីសុខការ និងសហការ-
-ឯកសារ-កាលប្បវត្តិ

លេខទូរស័ព្ទទំនាក់ទំនង៖លោក ឆង់ សុវណ្ណារិទ្ធ 012-354-630, លោក ខៀន សុធី 010-304-089,088-9522-5059,លោក ហែ ហ៊ីត 086 600 740

ចំណេះដឹង
មហាវិទ្យាល័យសុខុម លេខ៥១ សង្កាត់ចិន្តាមន ខណ្ឌដង្កោ
ទូរស័ព្ទ/ទូរសារ ០២៦ ៦១៥ ៧៧១/០២៣ ៦១៥ ៧៧៦

អាជ្ញាធរជាតិអប្សរា
Email: info@apsaraauthority.gov.kh
Website: http://www.apsaraauthority.gov.kh

សៀមរាប៖
ភូមិបង្គោល ឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប
ទូរស័ព្ទ/ទូរសារ ០៦៣ ៦៦៥ ៥៧៧/០៦៣ ៧៦៥ ៥៧៦

រមណីយដ្ឋានអង្គរចាប់ផ្តើមចងមិត្តភាពជាមួយឧទ្យានណាយហ្គាវ៉ានៃប្រទេសកាណាដើម្បីពង្រឹងការងារគ្រប់គ្រង និងអភិវឌ្ឍន៍ទិស័យទេសចរណ៍

ផ្សាយនៅថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៨

ដើម្បីពង្រីកវិសាលភាពនៃរមណីយដ្ឋានអង្គរលើឆាកអន្តរជាតិ តាមរយៈការចងសម្ពន្ធភាពជាមួយរមណីយដ្ឋានផ្សេងៗ លើសកលលោក នាថ្ងៃទី៤ ខែតុលា ឆ្នាំ២០១៨នេះ អាជ្ញាធរអប្សរាបានសម្រេចុះអនុស្សារណៈនៃការយោគយល់គ្នាមួយជាមួយឧទ្យានណាយហ្គាវ៉ា នៃប្រទេសកាណាដា។ អនុស្សារណៈនេះធ្វើឡើងស្របគ្នានឹងពិធីប្រកាសសម្ពោធស្ថានកុងស៊ុលកិត្តិយសនៃព្រះរាជាណាចក្រកម្ពុជាប្រចាំទីក្រុងតូរ៉ុនតូនៃប្រទេសកាណាដា ក្នុងន័យរឹតចំណងភាពជាបងប្អូននៃរមណីយដ្ឋានពិភពលោកទាំងពីរគឺ រមណីយដ្ឋានអង្គរ និងឧទ្យានណាយហ្គាវ៉ា ដើម្បីស្វែងរកកិច្ចសហការរួមគ្នា លើការងារគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍នៃរមណីយដ្ឋានទាំងពីរ។

ពិធីចុះអនុស្សារណៈនេះធ្វើឡើងដោយភាគីអាជ្ញាធរអប្សរា តំណាងដោយ **ឯកឧត្តម សុខ សង្ហារ** អគ្គនាយករងនៃអាជ្ញាធរអប្សរា និងលោកស្រី Janice Thomson ប្រធានគណៈកម្មាធិការឧទ្យានណាយហ្គាវ៉ានៃប្រទេសកាណាដា ដោយមានការអញ្ជើញចូលរួមពីសំណាក់ **ឯកឧត្តម ឆាត ឈួ** កុងស៊ុលកិត្តិយសនៃព្រះរាជាណាចក្រកម្ពុជា និងអគ្គកុងស៊ុលនៃបណ្តាប្រទេស១៥ផ្សេងទៀត ដូចជា ប្រទេសចិន អាហ្រ្វិកខាងត្បូង រុស្ស៊ី ហ្គាណា ប៉េរូ កូរ៉េខាងត្បូង អារ៉ាប់រួម និងប្រ៊ុយណេដារ៉ូសាឡឹម ព្រមទាំងប្រជាពលរដ្ឋខ្មែរដែលកំពុងរស់នៅប្រទេសកាណាដាផងដែរ។

លោកស្រី Janice Thomson បានបង្ហាញនូវសេចក្តីរីករាយដែលរមណីយដ្ឋានពិភពលោកទាំងពីរ បានភ្ជាប់សាច់ឈាមជាបងប្អូននឹងគ្នា។ លោកស្រីជឿជាក់ថា តាមរយៈចំណងមិត្តភាពនេះ រមណីយដ្ឋានទាំងពីរនឹងអាចផ្លាស់ប្តូរបទពិសោធន៍ការងារគ្នាល្អ។ ពាក់ព័ន្ធនឹងការងារគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍ រវាងរមណីយដ្ឋានអង្គរដែលជាបេតិកភណ្ឌវប្បធម៌ និងឧទ្យានណាយហ្គាវ៉ា ដែលជាបេតិកភណ្ឌធម្មជាតិ។

ឯកឧត្តម សុខ សង្ហារ ក៏បានថ្លែងអំណរគុណរាជរដ្ឋាភិបាលកម្ពុជា និងគណៈកម្មាធិការនៃឧទ្យានណាយហ្គាវ៉ា ព្រមទាំងតំណាងស្ថានកុលស៊ុលទាំងអស់ ដែលបានអញ្ជើញចូលរួមជាសាក្សីដ៏សំខាន់នៃពិធីចុះអនុស្សារណៈនេះ។ ឯកឧត្តមសង្ឃឹមថា ចំណងមិត្តភាពនេះនឹងជំរុញឲ្យមានភ្ញៀវទេសចរកាន់តែច្រើនក្នុងប្រទេសទាំងពីរ តាមរយៈកិច្ចសហការការជំរុញផ្សព្វផ្សាយនូវរមណីយដ្ឋានទាំងពីរ ជាពិសេស គឺការចែករំលែកបទពិសោធន៍គ្រប់គ្រងវិស័យទេសចរណ៍រវាងមន្ត្រីនៃរមណីយដ្ឋានអង្គរ និងឧទ្យានណាយហ្គាវ៉ា៕









លោកបណ្ឌិត អ៊ា ជារិទ្ធ អ្នកជំនាញអាជ្ញាធរជាតិអប្សរា ត្រូវចានអញ្ជើញទៅបង្រៀននៅសាកលវិទ្យាល័យ CORNELL នៃសហរដ្ឋអាមេរិកអំពីកិច្ចការស្រាវជ្រាវកុលាលភាជន៍ខ្មែរ

ផ្សាយនៅថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៨

ឆ្លងកាត់ជីវិតសិក្សា បទពិសោធន៍ការងារផ្នែកបុរាណវិទ្យា និងការស្រាវជ្រាវជាង២០ឆ្នាំជាមួយស្ថាប័នជាតិ-អន្តរជាតិ **លោកបណ្ឌិត អ៊ា ជារិទ្ធ** អនុប្រធានមជ្ឈមណ្ឌលអន្តរជាតិស្រាវជ្រាវនិងតម្កល់ឯកសារអង្គរនៃអាជ្ញាធរជាតិអប្សរា ត្រូវបានសកលវិទ្យាល័យ CORNELL សហរដ្ឋអាមេរិក អញ្ជើញឱ្យទៅសហការបង្រៀនជាមួយសាស្ត្រាចារ្យ Kaja McGowan រយៈពេល១ ឆមាស ចាប់ពីថ្ងៃទី១ សីហា ដល់២៤ ធ្នូ ឆ្នាំ២០១៨។

មុខវិជ្ជាដែលបង្រៀននៅទីនោះគឺ "ទឹកៈ សិល្បៈនិងនយោបាយនៅតំបន់អាស៊ីខាងត្បូងនិងអាស៊ីអគ្នេយ៍"។ ខ្លឹមសារសំខាន់នៃមេរៀននោះគឺបង្ហាញនយោបាយគ្រប់គ្រងទឹកនៃអរិយធម៌អង្គរ និងសារៈសំខាន់នៃទឹកក្នុងជំនឿសាសនា ពិសេសទឹកអម្រិតនៅក្នុងទេវកថាកូរសមុទ្រទឹកដោះ។

លើសពីនោះ **លោកបណ្ឌិត ជារិទ្ធ** ក៏បានបង្រៀនប្រវត្តិសាស្ត្រខ្មែរសង្ខេបពីសម័យហ្វូណនរហូតដល់សម័យបច្ចុប្បន្ន កុលាលភាជន៍ខ្មែរ ការចុះបញ្ជីបេតិកភណ្ឌពិភពលោកអង្គរ និងការគ្រប់គ្រងបេតិកភណ្ឌអង្គរដោយអាជ្ញាធរជាតិអប្សរា។ មិនតែប៉ុណ្ណោះ លោកក៏បានចូលរួមផ្សព្វផ្សាយអំពីការរៀនភាសាខ្មែរ និងអំពាវនាវឱ្យនិស្សិតអន្តរជាតិចាប់អារម្មណ៍ពីប្រទេសខ្មែរទាំងផ្នែកបុរាណដ្ឋាននិងប្រវត្តិសាស្ត្រផងដែរ។

ក្រៅពីបង្រៀន **លោកបណ្ឌិត អ៊ា ដារិទ្ធ** ក៏បានសិក្សាអំពីរបៀបចុះបញ្ជីវត្ថុបុរាណ ការតាំងពិពណ៌វត្ថុសិល្បៈ ស្តាប់បទបង្ហាញផ្សេងៗ ស្រាវជ្រាវឯកសារផ្សេងៗនៅបណ្ណាល័យ និងធ្វើបទបង្ហាញសាធារណៈនៅ សាកលវិទ្យាល័យ Wisconsin, Northern Illinois University, និង Yale University។

អស់រយៈពេលជិត២០ឆ្នាំក្នុងនាមជាមន្ត្រីអាជ្ញាធរជាតិអប្សរា **លោកបណ្ឌិត អ៊ា ដារិទ្ធ** មានប្រសាសន៍ថា នេះជាលើកទី១ ហើយដែលអាជ្ញាធរជាតិអប្សរាបានបញ្ជូនមន្ត្រីជំនាញឱ្យចេញទៅបង្រៀននិស្សិតអន្តរជាតិនៅបរទេសរយៈពេលវែង។
លោកបណ្ឌិតបន្តថា នេះជាមោទកភាពណាស់សម្រាប់រូបលោក ក៏ដូចជាស្ថាប័នអាជ្ញាធរជាតិអប្សរា ដែលបានចែករំលែកបទពិសោធន៍ការងារគ្រប់គ្រងបេតិកភណ្ឌអង្គរ រយៈពេល២៥ ឆ្នាំដល់និស្សិតអន្តរជាតិនៅសហរដ្ឋអាមេរិក។ ជាពិសេសលោកសប្បាយរីករាយដែលបានផ្សព្វផ្សាយវប្បធម៌អរិយធម៌ខ្មែរដល់និស្សិតនៅសកលវិទ្យាល័យ CORNELL ហើយសង្ឃឹមថានឹងមានមន្ត្រីអាជ្ញាធរជាតិអប្សរាផ្សេងៗទៀត ទៅចែករំលែកចំណេះដឹងដល់និស្សិតអន្តរជាតិកាន់តែច្រើននាអនាគត។
ទាក់ទងនឹងការសិក្សា **លោកបណ្ឌិត អ៊ា ដារិទ្ធ** បានបញ្ចប់ថ្នាក់បរិញ្ញាបត្របុរាណវិទ្យានៅសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈនាឆ្នាំ១៩៩៥ ថ្នាក់អនុបណ្ឌិតនៅសកលវិទ្យាល័យ Kyoto នៅឆ្នាំ២០០០ និងថ្នាក់បណ្ឌិតនៅសកលវិទ្យាល័យ Osaka Ohtani នៃប្រទេសជប៉ុន នាឆ្នាំ២០១០។

លោកបានបំពេញការងារនៅស្ថាប័នអាជ្ញាធរជាតិអប្សរាចាប់ពីឆ្នាំ២០០០មក ហើយជាសាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ មហាវិទ្យាល័យបុរាណវិទ្យាលើមុខវិជ្ជាប្រវត្តិកុលាលភាជន៍ខ្មែរ។ បន្ថែមពីនោះ លោកក៏ជាសាស្ត្រាចារ្យបង្រៀនពីប្រវត្តិសាស្ត្រខ្មែរ និងអរិយធម៌ពិភពលោកនៅសលវិទ្យាល័យបញ្ញាស្ត្រក្នុងខេត្តសៀមរាប។
នៅឆ្នាំ២០០៤ លោកបានទទួលអាហារូបករណ៍ពី Asian Cultural Council, USA ដើម្បីសិក្សាអំពីរបៀបគ្រប់គ្រងវត្ថុបុរាណដែលបានពីកំណាយរហូតដល់អភិរក្សនៅ Arizona State University, Freer/Sackler Galleries (Smithsonian) និង University of Pennsylvania Museum of Archaeology and Anthropology។

ក្នុងនាមជាអ្នកជំនាញលើផ្នែកស្រាវជ្រាវកុលាលភាជន៍ខ្មែរសម័យអង្គរ **លោក ដារិទ្ធ** ក៏ធ្លាប់បានវិទ្យាស្ថាន Nalanda Sriwijaya នៃប្រទេសសិង្ហបុរី អញ្ជើញឱ្យទៅស្រាវជ្រាវនិងសរសេរសៀវភៅអំពីប្រាសាទអង្គរវត្ត កាលពីឆ្នាំ២០១៤និង២០១៥។ មិនតែប៉ុណ្ណោះ លោកក៏ជាសហប្រធាននៃគម្រោងស្រាវជ្រាវ Field school សហការជាមួយសិង្ហបុរីនៅកោះកេរ និងនៅតំបន់អង្គរជាច្រើនលើកផងដែរ៕









អាជ្ញាធរជាតិអប្សរាចូលរួមការពព្រះបរមនិញ្ញាណក្ខន្ធព្រះករុណា ព្រះបរមរតនកោដ្ឋ

ផ្សាយនៅថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៨

នាព្រឹកថ្ងៃចន្ទ ៦កើត ខែអស្សុជ ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២ ត្រូវនឹងថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៨ **លោក ឡុង កុសល** ប្រធាននាយកដ្ឋានផ្សព្វផ្សាយ ក្នុងនាមថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា ចូលរួមព្រះរាជពិធីគោរព **ព្រះបរមនិញ្ញាណក្ខន្ធ អតីតព្រះមហាវីរៈក្សត្រ ព្រះបរមរតនកោដ្ឋ** ចំពោះការយាងចូលទីវង្គត់គម្រប់៦ព្រះវស្សា នៅព្រះរាជដំណាក់ខេត្តសៀមរាប។

ក្នុងនាមទូលព្រះបង្គំយើងខ្ញុំព្រះករុណាជាថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិកគ្រប់ជាន់ថ្នាក់នៃអាជ្ញាធរជាតិអប្សរា សូមសម្តែងនូវមហាទុក្ខសោកចំពោះការបាត់បង់អង្គព្រះមហាវីរៈក្សត្រដ៏ឆ្នើមនៃកម្ពុជា និងសូមថ្វាយមហាព្រះរាជកុសល ព្រះបរមវិញ្ញាណក្ខន្ធ ព្រះករុណា ព្រះបរមរតនកោដ្ឋ ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ស្តេចយាងសោយសុខក្នុងឋានព្រះបរមសុខ កុំបីឃ្លៀងឃ្លាតឡើយ។

បើទោះបីព្រះកាយនៃអង្គព្រះករុណា ព្រះបរមរតនកោដ្ឋ បានយាងសោយព្រះទីវង្គត់ក្តីក៏ពិតមែន ក៏យើងខ្ញុំព្រះករុណា ជាកូន ចៅ ចៅទួតរបស់ព្រះអង្គ ចងចាំមិនភ្លេចឡើយនូវព្រះគុណូបការៈមហាថ្លៃថ្លារបស់ព្រះបិតាជាតិខ្មែរក្នុងការស្វែងរកសុខសន្តិភាពជូនជាតិ ធ្វើឲ្យព្រះរាជាណាចក្រកម្ពុជា ក្រោមព្រះរាជដឹកនាំរបស់ព្រះអង្គបានស្គាល់នូវការរីកចម្រើនគ្រប់វិស័យនិងរស់នៅក្រោមម្លប់សុខក្សេមក្សាន្ត។

ក្រៅពីការស្វែងរកសុខសន្តិភាព ការពារបូរណភាពទឹកដី បង្រួបបង្រួមជាតិហើយ ព្រះអង្គបានលះបង់ព្រះកាយពល ព្រះបញ្ញាញាណរបស់ព្រះអង្គចំពោះវិស័យវប្បធម៌ក្នុងនាមជាព្រះប្រធានកិត្តិយស នៃគណៈកម្មាធិការអន្តរជាតិដើម្បីសម្របសម្រួលកិច្ចគាំពារនិងអភិវឌ្ឍន៍រមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ (អាយស៊ីស៊ី-អង្គរ) និងការការពារប្រាសាទព្រះវិហារពីពួកបរទេសឈ្លានពានផងដែរ។

អាជ្ញាធរជាតិអប្សរា ប្តេជ្ញាថែរក្សា ការពារ និងដើរតាមមាគ៌ានៃអង្គព្រះមហាវីរៈក្សត្រ ព្រះបរមរតនកោដ្ឋ យ៉ាងមុតមាំ ក្នុងការលើកស្ទួយអភិរក្សរមណីយដ្ឋានអង្គរឲ្យបានកាន់តែល្អប្រសើរគ្រប់កាលវេលាតទៅ៕











ស្ពានឈើប្រវែង១៨៣ម៉ែត្រនៅក្នុងបរិវេណប្រាសាទបេងមាលាកំពុងសាងសង់ឡើងវិញ

ផ្សាយនៅថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១៨

ប្រាសាទបេងមាលា បើទោះបីស្ថិតនៅឆ្ងាយពីតំបន់អង្គរ ហើយមានការបែកបាក់ច្រើន ក៏ប៉ុន្តែនូវទទួលបានការចាប់អារម្មណ៍យ៉ាងខ្លាំងពីសំណាក់ភ្ញៀវទេសចរជាតិនិងអន្តរជាតិលើស្ថាបត្យកម្មសំណង់ ទេសភាព ពិសេសស្ពានឈើសម្រាប់ដើរទស្សនាប្រាសាទ។

ប៉ុន្តែដោយសារកត្តាអាយុកាល អាកាសធាតុ បានធ្វើឱ្យស្ពានឈើដែលសង់ឡើងកាលពីឆ្នាំ២០០២ រងនូវការពុកផុយដោយអន្លើរអាចបង្កឱ្យគ្រោះថ្នាក់ ហើយស្ពានភាពស្ពានតូចចង្អៀត ពិបាកទេសចរធ្វើដំណើរនិងដើរជៀសគ្នាផងនោះ អាជ្ញាធរជាតិអប្សរាសហការជាមួយក្រុមហ៊ុន ខាំ សាមេត បានរុះស្ពានចាស់ធ្វើស្ពានថ្មីទាំងស្រុង មានទទឹងមួយម៉ែត្រកន្លះ ប្រវែង១៨៣ម៉ែត្រ ក្នុងប្រវែងស្ពានសរុប២៦៣ម៉ែត្រ។

លោកបណ្ឌិត ឈាន រដ្ឋា ប្រធានស្តីទីនាយកដ្ឋានអភិរក្សប្រាសាទក្រៅឧទ្យានអង្គរនៃអាជ្ញាធរជាតិអប្សរា បានឱ្យដឹងថា ដំណើរការសាងសង់ស្ពានឈើបានចាប់ផ្តើមកាលពីថ្ងៃទី១០ ខែកញ្ញា ហើយគ្រោងនឹងបញ្ចប់នៅចុងខែវិច្ឆិកា ឆ្នាំ២០១៨

ដោយអាជ្ញាធរជាតិអប្សរាជាអ្នកទទួលខុសត្រូវលើបច្ចេកទេសសាងសង់ រីឯក្រុមហ៊ុន ខាំ សាមេត ជាអ្នកផ្តល់ថវិកាក្នុងការសាងសង់។ សំណង់ស្ពានថ្មីនេះប្រើឈើអស់ចំនួនជាង៨០ម៉ែត្រគូប មានឈើបីប្រភេទ គឺធ្នឹក គគីរ និងរាំង ដែលធន់នឹងអាកាសធាតុ ហើយជានាគុណភាពបានយូរឆ្នាំ។

លោកបណ្ឌិត រដ្ឋា បន្តទៀតថា ការសង់ស្ពានថ្មីនេះធ្វើឡើងក្នុងបំណងការពារសុវត្ថិភាពអ្នកទស្សនាដែលកើនឡើងជាលំដាប់ ការពារមិនឱ្យទេសចរចុះជាន់លើថ្មនាំឱ្យរអិលឬធ្លាក់នាំគ្រោះថ្នាក់ដល់ខ្លួន ហើយប៉ះពាល់ដល់ថ្មប្រាសាទ និងសម្រួលដល់ការធ្វើដំណើរដៀសគ្នាថែមទៀត។ ចំពោះការសាងសង់វិញ ក្រុមការងារបុរាណវិទូនិងស្ថាបត្យកររនៃអាជ្ញាធរជាតិអប្សរាបានយកចិត្តទុកដាក់ខ្ពស់និងសិក្សាយ៉ាងល្អិតល្អន់ ទាំងប្លង់ រួមទាំងបញ្ជៀសហានិភ័យផ្សេងៗដល់ថ្មប្រាសាទដោយការមិនដឹកដីដាំសសរ បើកន្លែងប៉ះថ្ម គឺប្រើសំបកកង់ឡានទ្រាប់ពីលើដៀសវាងការកកិត។ ដោយឡែក សម្រាប់ស្ពានចាស់ ដែលមានទំហំសមល្មម និងមានភាពមាំទាំនៅឡើយ ក៏ក្រុមការងារបន្តការយកចិត្តទុកដាក់ថែទាំពង្រឹងបន្ថែមទៀតដែរ។

សូមបញ្ជាក់ថា ស្ពានឈើដែលជាសោភ័ណភាពមួយនៃប្រាសាទបេងមាលានេះ កើតឡើងនៅឆ្នាំ២០០២ ដោយក្រុមហ៊ុនភាពយន្តហូលីវូដបានសុំការអនុញ្ញាតពីអាជ្ញាធរជាតិអប្សរាដើម្បីធ្វើស្ពានឈើចូលទៅក្នុងប្រាសាទសម្រាប់ដញ្ជូនសម្ភារៈក្នុងការថតភាពយន្តនិងជួយផ្សព្វផ្សាយដល់ទេសចរឱ្យស្គាល់ពីប្រាសាទបេងមាលាផង។ ក្រោយមកដោយកំណើនភ្ញៀវទេសចរកាន់តែកើនឡើង ធ្វើឱ្យភ្ញៀវខ្លះជាន់ថ្មប្រាសាទពេលដើរទស្សនា ហើយមើលឃើញពីប្រយោជន៍នៃស្ពានឈើនេះអាចសង្គ្រោះដល់ប្រាសាទផងនោះ អាជ្ញាធរជាតិអប្សរាក៏បានបន្តពង្រីកធ្វើស្ពានឈើនេះជាបន្តក្បាច់ជាមួយស្ពានចាស់រហូតមកសព្វថ្ងៃ៕









ក្រុមប្រឹក្សានិស្សិតអាស៊ានមកពីប្រទេសជប៉ុនជាង៣០០នាក់ ចាន់ដាំកូនឈើនៅមុខប្រាសាទបន្ទាយក្តី ក្រោមការសម្របសម្រួលពីអាជ្ញាធរជាតិអប្សរា និងក្រសួងបរិស្ថាន

ផ្សាយនៅថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១៨

នៅថ្ងៃទី ២១ ខែតុលា ឆ្នាំ២០១៨ ក្រុមប្រឹក្សានិស្សិតអាស៊ានមកពីប្រទេសជប៉ុន ហៅកាត់ថា ASCOJA ចំនួន៣៥០នាក់ បាននាំគ្នាដាំកូនឈើជាង៣០០ដើមនៅមុខប្រាសាទបន្ទាយក្តី ក្រោមការសម្របសម្រួលពីអាជ្ញាធរជាតិអប្សរា និងក្រសួងបរិស្ថាន ដើម្បីជាសួនអនុស្សាវរីយ៍ក្នុងឱកាសនៃសន្និបាតលើកទី២៤ នៃ ASCOJAនៅខេត្តសៀមរាប។

លោក រ៉ូ មុនីវ័ណ្ណ ប្រធានសមាគមអតីតនិស្សិតខ្មែរមកពីប្រទេសជប៉ុន (JAC) បានថ្លែងថា ព្រឹត្តិការណ៍ដាំដើមឈើនៅក្នុងតំបន់អង្គរនេះ នឹងជួយពង្រឹងថែមទៀតនូវកិច្ចសហប្រតិបត្តិការ និងមិត្តភាពរវាងបណ្តាប្រទេសអាស៊ាន និងជប៉ុន ក៏ដូចជាបានជួយផ្តល់ភាពបៃតងដល់ភពផែនដីថែមទៀត។

ឯកឧត្តម សុខ សង្ហារ អគ្គនាយករងនៃអាជ្ញាធរជាតិអប្សរា បានបញ្ជាក់ក្នុងឱកាសនៃពិធីដាំកូនឈើនេះថា ក្នុងនាមស្ថាប័នគ្រប់គ្រងរមណីយដ្ឋានអង្គរ អាជ្ញាធរជាតិអប្សរាពិតជាស្វាគមន៍យ៉ាងកក់ក្តៅបំផុតសម្រាប់ដំណើរស្វែងយល់ពីអារ្យធម៌អង្គររបស់ក្រុមប្រឹក្សានិស្សិតអាស៊ានមកពីប្រទេសជប៉ុន ជាពិសេស គឺការចូលរួមដាំកូនឈើ ដែលជាការរួម ចំណែកលើកតម្លៃទេសភាពវប្បធម៌អង្គរ ក៏ដូចជា ភាពបៃតងនៃភពផែនដីនៅលើទឹកដីអង្គរ។

ឯកឧត្តមបញ្ជាក់ថា ជារៀងរាល់ឆ្នាំអាជ្ញាធរជាតិអប្សរាបានដាំកូនឈើរាប់ម៉ឺនដើមបន្ថែម និងថែរក្សាព្យាបាលដើមឈើធំៗដែលមានអាយុកាលរាប់រយឆ្នាំជាប្រចាំ។ ក្រៅពីនេះ អាជ្ញាធរជាតិអប្សរាក៏បានចែកចាយកូនឈើរាប់ម៉ឺនដើមទៅស្ថាប័នរដ្ឋ និងស្ថាប័នឯកជន វត្តអារាមជារៀងរាល់ឆ្នាំ ជាដើម ដើម្បីរួមចំណែកក្នុងការការពារបរិស្ថាន។

ឯកឧត្តម សាយ សំអាល់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន ដែលបានអញ្ជើញជាអធិបតីក្នុងពិធីដាំនេះបានបញ្ជាក់ថា កម្មវិធីដាំដើមឈើនៅថ្ងៃនេះ ជាការល្អប្រសើរបំផុត បង្ហាញពីការខិតខំប្រឹងប្រែង រឹតចំណងសាមគ្គីភាពជាមួយគ្នារវាងកម្ពុជា និងជប៉ុន ក៏ដូចជាអាស៊ាននិងជប៉ុន ហើយបានស្វែងយល់ពីតំបន់ធម្មជាតិប្រវត្តិសាស្ត្រ សម្បត្តិបេតកណ្ឌរបស់ពិភពលោកផងដែរ។

ឯកឧត្តមរដ្ឋមន្ត្រីបានរំឭកពីកិច្ចការអភិរក្សតំបន់រមណីដ្ឋានធម្មជាតិប្រវត្តិសាស្ត្រអង្គរ ដែលរាជរដ្ឋាភិបាលកំពុងយកចិត្តទុកដាក់ខ្ពស់នេះ។ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីបាននាំយកនូវសុខសន្តិភាពជូនប្រទេស ហើយបង្កើតឱ្យមានឱកាសក្នុងការអភិរក្ស និងថែរក្សាសម្បត្តិបេតិកភណ្ឌពិភពលោកមួយនេះ តាមរយៈគណៈកម្មាធិការអន្តរជាតិ សម្របសម្រួលកិច្ចគាំពារ និងអភិវឌ្ឍន៍តំបន់អង្គរ (ICC-Angkor) និងការរីកចម្រើននៃវិស័យទេសចរណ៍។

ជាមួយគ្នានេះ ឯកឧត្តមរដ្ឋមន្ត្រីបានលើកឡើងពីការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ក្រសួងបរិស្ថានក្នុងកិច្ចគាំពារបរិស្ថាន ការគ្រប់គ្រងសំណល់រឹងរាវ សំរាម និងអភិរក្សធនធានធម្មជាតិ និងជីវៈចម្រុះឱ្យបានគង់វង្ស ការទប់ស្កាត់និងបង្ក្រាបបទល្មើសធនធានធម្មជាតិផ្សេងៗ និងទប់ស្កាត់បង្ក្រាបការបរបាញ់ ការជួញដូរសត្វ និងសាច់សត្វដោយខុសច្បាប់៕









អាជ្ញាធរជាតិអប្សរាជួសជុលពង្រីកទំនប់បារាយណ៍ទឹកថ្លាជ្រុងខាងលិច ផ្នែកខាងត្បូង ប្រវែង១,៦៤០ម៉ែត្រ

ផ្សាយនៅថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៨

អាជ្ញាធរជាតិអប្សរាបានសហការជាមួយក្រុមហ៊ុនរាជសីហ៍ ធ្វើការជួសជុលតួទំនប់បារាយណ៍ទឹកថ្លាជ្រុងខាងលិច ផ្នែកខាងត្បូង ស្ថិតនៅភូមិប្រឡាយ ឃុំខ្នាត ស្រុកពួក មានប្រវែង១៦៤០ម៉ែត្រ ដែលរងការខូចខាតដោយសារអាយុកាល ទឹករលក និងការហូរច្រោះដោយទឹកភ្លៀងជាដើម។

តាមការបញ្ជាក់របស់**លោក មាន់ ជានិត** មន្ត្រីបច្ចេកទេសរបស់នាយកដ្ឋានគ្រប់គ្រងទឹកនៃអាជ្ញាធរជាតិអប្សរាបានឱ្យដឹងថា ការងារនេះអនុវត្តដោយក្រុមហ៊ុនរាជសីហ៍ដែលស្ថិតនៅក្រោមការពិនិត្យជាប្រចាំដោយក្រុមការងារបច្ចេកទេសរបស់អជ្ញាធរជាតិអប្សរា ក្នុងបំណងអភិរក្សនិងថែរក្សាបារាយណ៍ទឹកថ្លាឱ្យមាំទាំជាងមុននិងស្ថិតនៅគង់វង្សយូរអង្វែង។

លោក ជានិត បន្តថា ចំពោះគម្រោងនៃការជួសជុលមានរយៈពេល៦ខែ គិតចាប់ពីថ្ងៃ២៦ ខែកក្កដា ឆ្នាំ២០១៨ រហូតដល់ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៩។ ចំពោះការអនុម័តយល់ព្រមឱ្យប្រើប្រាស់គ្រឿងចក្រក្នុងការជួសជុលពង្រឹងទំនប់បុរាណនេះ ក្រុមអ្នកបុរាណវិទ្យានៃអាជ្ញាធរជាតិអប្សរា ក៏បានធ្វើកំណាយដើម្បីសិក្សាបន្ថែមអំពីវិធីសាស្ត្របង្ហាប់ដីបុរាណ រចនាសម្ព័ន្ធ និងប្រភេទដីទំនប់ដើម្បីធានាថា ការជួសជុលនេះមិនប៉ះពាល់ដល់បុរាណដ្ឋាន និងធានាគុណភាពយូរអង្វែង។

សូមបញ្ជាក់ថា បារាយណ៍ទឹកថ្លាមានទំហំធំជាងគេក្នុងចំណោមបារាយណ៍ទាំងបួននៅក្នុងតំបន់សៀមរាប-អង្គរ ដែលស្ថិតនៅខាងលិចក្រុងអង្គរធំ មានទទឹងប្រវែង២២០០ម៉ែត្រនិងបណ្តោយប្រវែង៨០០០ម៉ែត្រ អាចរក្សាទឹករហូតដល់៥៦លានម៉ែត្រគូប។ កន្លងមកអាជ្ញាធរជាតិអប្សរាបានយកចិត្តទុកដាក់អភិរក្សនិងជួសជុលតួទំនប់បារាយណ៍ទឹកថ្លាជាច្រើនដំណាក់កាលមកហើយ។

លើសពីនោះ បារាយណ៍ទឹកថ្លានេះមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ផ្គត់ផ្គង់ទឹកស្រោចស្រពស្រែនិងដំណាំផ្សេងៗជាងមួយម៉ឺនហិកតា បញ្ចៀសបញ្ហាទឹកជំនន់ក្នុងតំបន់សៀមរាប-អង្គរ ទាក់ទាញភ្ញៀវទេសចរណ៍ បង្កើនការងារដល់ប្រជាជនតាមរយៈការលក់វត្ថុអនុស្សាវរីយ៍ អ្នកបម្រើអាហារ សេវាជិះទូកកម្សាន្ត ផ្គត់ផ្គង់ទឹកសម្រាប់ផលិតទឹកស្អាត ក្នុងក្រុងសៀមរាប (១៨០០០ម៉ែត្រគូបក្នុងមួយថ្ងៃ) ជាពិសេសទឹកបារាយណ៍បានចូលទៅបំពេញទឹកក្រោមដីឱ្យរក្សាបាននូវតុល្យភាពនិងរក្សាលំនឹងគ្រឹះប្រាសាទឱ្យមានភាពរឹងមាំ ពិសេសជាកន្លែងរក្សាពូជត្រីបានយ៉ាងល្អ ហើយផ្តល់ផលត្រីយ៉ាងច្រើនជូនប្រជាជនដែលរស់នៅជុំវិញផងដែរ៕









ផ្លូវ៦០ម៉ែត្រក្នុងក្រុងសៀមរាប ត្រូវបានប្រកាស់ប្រសិទ្ធិនាមជា «វិថីសម្តេចវិបុលបញ្ញា សុខ អាន™

ផ្សាយនៅថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៨

ផ្លូវ ៦០ម៉ែត្រក្នុងក្រុងសៀមរាប ចាប់ពីចំណុចកែងមុខមន្ទីរពេទ្យគន្ធបុប្ផា ដល់ទីស្នាក់ការអាជ្ញាធរជាតិអប្សរា ចាប់ពីពេលនេះតទៅ នឹងត្រូវបានប្រសិទ្ធិនាមជា «**វិថីសម្តេចវិបុលបញ្ញា សុខ អាន**»។ ផ្លូវនេះត្រូវបានសម្រេចប្រសិទ្ធិនាមយ៉ាងដូច្នេះបន្ទាប់អាជ្ញាធរជាតិអប្សរាបានស្នើសុំទៅរដ្ឋបាលខេត្តសៀមរាប។ យោងតាមសេចក្តីសម្រេចរបស់រដ្ឋបាលខេត្តសៀមរាប មូលហេតុនៃការប្រសិទ្ធិនាមឈ្មោះនេះ គឺដើម្បីតបស្នងសងគុណដ៏ថ្លៃថ្លារបស់ **សម្តេចវិបុលបញ្ញា សុខ អាន** ក្នុងបុព្វហេតុលើវិស័យបេតិកភណ្ឌ។

វិថីសម្តេចវិបុលបញ្ញា សុខ អាន កន្លងមកពលរដ្ឋទូទៅក្នុងក្រុងសៀមរាបនិយមហៅថា ផ្លូវ៦០ម៉ែត្រ ព្រោះយោងតាមទំហំផ្លូវដែលមានទទឹងប្រវែង ៦០ម៉ែត្រ ប៉ុន្តែពុំដែលបានកំណត់ជាផ្លូវការនៅឡើយទេ។ ទើបតែថ្មីៗនេះអាជ្ញាធរជាតិអប្សរាក៏បានដាក់សំណើរទៅរដ្ឋបាលខេត្តសៀមរាប ដោយប្រសិទ្ធិនាមផ្លូវនេះជា **វិថីសម្តេចវិបុលបញ្ញា សុខ អាន** ។

គួររម្លឹកថា **វិថីសម្តេចវិបុលបញ្ញា សុខ អាន** ត្រូវបានស្ថាបនាឡើងកាលពីឆ្នាំ២០០២ ក្រោមជំនួយឧបត្ថម្ភរបស់ទីភ្នាក់ងារបារាំង (ADF)។ នៅឆ្នាំ២០០៦ អាជ្ញាធរជាតិអប្សរាបានចំណាយថវិកាមួយចំនួនដើម្បីធ្វើផ្លូវគ្រួសក្រហមសងខាងផ្លូវ និងបន្តសង់ផ្លូវមកខាងកើតហួសរង្វង់មូលចំនួន៤គីឡូម៉ែត្របន្ថែមទៀត ដើម្បីអបអរសាទរព្រឹត្តិការណ៍វប្បធម៌អង្គរយ៉ុងយូ ដែលជាកិច្ចសហប្រតិបត្តិការរវាងតំបន់បេតិកភណ្ឌចំនួន២ គឺអង្គរនិងយ៉ុងយូ។ ក្រោយមកនៅឆ្នាំ២០១០ អាជ្ញាធរជាតិអប្សរាក៏បានស្ថាបនានេះ ចំនួន៩.៦៧៩ម៉ែត្រ ចាប់ពីផ្លូវបំបែកត្រាំនាគ រហូតដល់បុរីរដ្ឋបាលខេត្តសៀមរាបបច្ចុប្បន្នជាទីស្នាក់ការអាជ្ញាធរជាតិអប្សរា។ បើគិតមកដល់ពេលនេះ **វិថីសម្តេចវិបុលបញ្ញា សុខ អាន** បានបម្រើផលប្រយោជន៍ដល់ប្រជាជននិងទេសចរទាំងឆ្លងកាត់និងដឹកជញ្ជូនទំនិញអស់រយៈពេល១៦ឆ្នាំមកហើយ៕









សេចក្តីជូនដំណឹងស្តីពី ការកាត់ជកហូតដើមឈើ និងកាត់ក្រឹមែកឈើដែលមានហានិភ័យខ្ពស់នៅតាមបរិវេណប្រាសាទ ក្នុងមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១៨



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA
លេខ ១០៩៦/ឆ.សអ៉ណ
៦៤

សេចក្តីជូនដំណឹង
ស្តីពី
ការកាត់ជកហូតដើមឈើ និងកាត់ក្រឹមែកឈើ
ដែលមានហានិភ័យខ្ពស់នៅតាមបរិវេណប្រាសាទ ក្នុងតំបន់មណីយដ្ឋានអង្គរ

អាជ្ញាធរជាតិអប្សរា សូមជូនដំណឹងដល់ស្ថាប័ន សមត្ថកិច្ចពាក់ព័ន្ធ ភ្ជៀវជាតិ-អន្តរជាតិ មត្តុទ្ទេសក៍ ទេសចរណ៍ ព្រមទាំងសាធារណជនទាំងអស់មេត្តាជ្រាបថា ដើម្បីធានាដល់សុវត្ថិភាពភ្ជៀវទេសចរ សាធារណជន ក៏ដូចជាដើម្បីលើកកម្ពស់សោភ័ណភាពនៅតាមដងផ្លូវ និងនៅតាមបរិវណប្រាសាទ ក្នុងតំបន់រមណីយដ្ឋានអង្គរ និងតំបន់ដែលគ្រប់គ្រងដោយអាជ្ញាធរជាតិអប្សរា នាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាន នៃអាជ្ញាធរជាតិអប្សរា នឹងកាត់ជកហូតដើមឈើ និងកាត់ក្រឹមែកឈើ តាមទីតាំងនានាដូចខាងក្រោម៖

-កាត់ជកហូត និងកាត់ក្រឹមែកឈើចំនួន ០៤ដើម នៅជាប់ព្រះវិហារវត្តគោកធ្លក ខាងលិចប្រាសាទបាយ័ន។

-កាត់ជកហូត និងកាត់ក្រឹមែកឈើចំនួន ១៥០ដើម នៅតាមផ្លូវវង់តូច-វង់ធំ ក្នុងតំបន់ឧទ្យានអង្គរ។

-កាត់ជកហូត និងកាត់ក្រឹមែកឈើចំនួន ០៣ដើម នៅតាមដងផ្លូវ ភូមិកោះជ្រុំ ឃុំឧារសណ្តាយ ស្រុកបន្ទាយស្រី។

-កាត់ជកហូតដើមក្រឡាញ់ ០១ដើម នៅតាមដងផ្លូវជាតិលេខ៦A ពីមុខដេប៉ូប្រេងតេឡា ភូមិលលៃឃុំបាគង។

-កាត់ជកហូតដើមឈើទាល០១ដើម នៅបរិវេណសាលារៀនបាគង ក្នុងភូមិថ្នល់ ឃុំបាគង ខេត្តសៀមរាប។

ការងារនេះ នឹងចាប់ផ្តើមអនុវត្តចាប់ពីថ្ងៃទី ៣០ ខែ តុលា ឆ្នាំ២០១៨ រហូតដល់បញ្ចប់ការងារ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមស្ថាប័ន សមត្ថកិច្ចពាក់ព័ន្ធ ភ្ជៀវជាតិ-អន្តរជាតិ មត្តុទ្ទេសក៍ ទេសចរណ៍ ព្រមទាំងសាធារណជនទាំងអស់ មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃ ពុធ ១៥ រោត ខែ ឆ្នាំច សំរឹទ្ធិស័ក.ព.ស២៥៦២
សៀមរាប ថ្ងៃទី ខែ តុលា ឆ្នាំ២០១៨
អគ្គនាយក

ឆ្នុ ម៉ាប់

ចម្លងជូន៖
-សាណាខេត្តសៀមរាប
-មន្ទីរបរិស្ថានខេត្តសៀមរាប
-មន្ទីរកសិកម្ម ក្នុប្រមាញ់ និងនេសាទខេត្តសៀមរាប
-អង្គភាពនគរបាលការពារបេតិកភណ្ឌប្រចាំខេត្តសៀមរាប
-ស្នាក់ការតំបន់ការពារទេសភាពអង្គរ
-សមាគមមត្តុទ្ទេសក៍ទេសចរណ៍ទាំងអស់ប្រចាំខេត្តសៀមរាប
"ដើម្បីជូនជ្រាប និងសហការ"
-ប៉ូលីសទេសចរណ៍
-គ្រប់នាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធរបស់អាជ្ញាធរអប្សរា
"ដើម្បីមុនការ និងសហការ"
-ឯកសារ-កាលប្បវត្តិ

លេខទូរស័ព្ទទំនាក់ទំនង:លោក ឆង់ សុវណ្ណារិទ្ធ 012-354-630, លោក ទៀន សុធី 010-304-089,088-9522-5059,លោក ហែ ហ៊ត 086 600 740

ទ្វាលេខ្យ:
ចបាវិធីសាកល្លុងស្តី លេខ៦ សង្ឋាក់មិត្តភាព ឧស្ថាផមកា
ទូរសន្ទូទូរសារ ០២៦ ៨៨៨ ៨៨៨/០២៦ ៨៨៨ ៨៨៨

អាជ្ញាធរដើម្បីការពារបេណីយដ្ឋានវិងប្រាចាំតំបន់អង្គរ
Email: info@apsaraauthority.gov.kh
Website: http://www.apsaraauthority.gov.kh

សៀមរាប:
ភូមិបន្ទាង ឃុំរំដិល ស្រុកប្រាសាទជាតន ខេត្តសៀមរាប
ទូរសន្ទូទូរសារ ០៦៣ ៨៦៨ ៨៨៨/០៦៣ ៨៦៨ ៨៨៨

លោកជំទាវ ភឿង សកុណា ចូលរួមសិក្ខាសាលាស្តីពីលទ្ធផលកម្រោងអភិរក្ស និងជួសជុលប្រាសាទព្រះពិជូរនៅទីក្រុងសេអ៊ូល សាធារណរដ្ឋកូរ៉េ

ផ្សាយនៅថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១៨

គណៈប្រតិភូក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដឹកនាំដោយ **លោកជំទាវ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងជាប្រធានអាជ្ញាធរជាតិអប្សរា រួមដំណើរដោយថ្នាក់ដឹកនាំនៃអាជ្ញាធរជាតិអប្សរា អញ្ជើញចូលរួមក្នុងសិក្ខាស្តីពីលទ្ធផលគម្រោងអភិរក្ស និងជួសជុលប្រាសាទព្រះពិជូរ នៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៨ នាទីក្រុងសេអ៊ូល សាធារណរដ្ឋកូរ៉េ។ សិក្ខាសាលានេះរៀបចំឡើងដោយមូលនិធិបេតិកភណ្ឌវប្បធម៌កូរ៉េ Korea Cultural Heritage Foundation និងមានការអញ្ជើញចូលរួមជាកិត្តិយសដោយ **ឯកឧត្តម ង្វុង ឌីម៉ង់** ឯកអគ្គរាជទូតព្រះរាជាណាចក្រកម្ពុជាប្រចាំសាធារណរដ្ឋកូរ៉េ តំណាងទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិកូរ៉េ KOICA និងរដ្ឋបាលគ្រប់គ្រងបេតិកភណ្ឌវប្បធម៌កូរ៉េ។

ថ្លែងក្នុងពិធីបើកសិក្ខាសាលាខាងលើ **លោក Jin OK-Sub** ប្រធានមូលនិធិបេតិកភណ្ឌវប្បធម៌កូរ៉េ បានសម្តែងនូវអារម្មណ៍សប្បាយរីករាយក្រៃលែង និងស្វាគមន៍យ៉ាងកក់ក្តៅចំពោះគណៈប្រតិភូកម្ពុជាទាំងអស់ដែលបានចំណាយពេលចូលរួមក្នុងសិក្ខាសាលាដ៏មានសារសំខាន់នេះ។ ការចូលរួមនេះគឺបង្ហាញពីការយកចិត្តទុកដាក់នៃស្ថាប័នជំនាញពាក់ព័ន្ធក្នុងកិច្ចការងារបេតិកភណ្ឌ លើកិច្ចសហប្រតិបត្តិការរវាងកម្ពុជា និងកូរ៉េ។

ទាក់ទងនឹងការងារអភិរក្ស និងជួសជុលប្រាសាទនេះដែរ ប្រធានមូលនិធិបេតិកភណ្ឌវប្បធម៌កូរ៉េ បានឱ្យដឹងទៀតថា អ្វីដែលជាមោទនភាពបំផុតរបស់កូរ៉េ គឺបានចូលរួមជួយស្តារឡើងវិញនៃភាពល្បីល្បាញរបស់បេតិកភណ្ឌកម្ពុជា ដែលជាបេតិកភណ្ឌមនុស្សជាតិ និងជួយជំរុញការផ្សព្វផ្សាយការយល់ដឹងលើការងារនេះដល់ប្រជាជនកូរ៉េផងដែរ។

ថ្លែងក្នុងពិធីនោះដែរ **លោកជំទាវ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាប្រធានអាជ្ញាធរជាតិអប្សរា បានសម្តែងនូវការអរគុណដល់ស្ថាប័នសំខាន់ៗមួយចំនួនដូចជា មូលនិធិបេតិកភណ្ឌវប្បធម៌កូរ៉េ ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិកូរ៉េ KOICA រដ្ឋបាលគ្រប់គ្រងបេតិកភណ្ឌវប្បធម៌កូរ៉េ ដែលបានផ្តល់កិច្ចសហប្រតិបត្តិការទាំងផ្នែកបច្ចេកទេស និងថវិកា ក្នុងកិច្ចសហប្រតិបត្តិការអភិរក្ស និងជួសជុលប្រាសាទព្រះពិជូរនាពេលកន្លងមក។ ជាពិសេសទៅទៀតនោះ កិច្ចសហប្រតិបត្តិការរវាងមូលនិធិបេតិកភណ្ឌវប្បធម៌កូរ៉េនិងអាជ្ញាធរជាតិអប្សរាបានបង្កើតនូវសមិទ្ធផលយ៉ាងល្អប្រសើរ ហើយតែងតែទទួលបានការគាំទ្រនិងកោតសរសើរពីសំណាក់គណៈកម្មាធិការអាយស៊ីស៊ី-អង្គរ។ ដូច្នេះរាល់សមិទ្ធផលទាំងនេះគឺជាការលើកទឹកចិត្តដ៏ខ្លាំងក្លាដល់គ្រប់ផ្នែកពាក់ព័ន្ធទាំងអស់។

ជាការចែករំលែកចំណេះដឹង អង្គសិក្ខាសាលាក៏មានការធ្វើបទបង្ហាញគន្លឹះចំនួនពីរដោយថ្នាក់ដឹកនាំនៃអាជ្ញាធរជាតិអប្សរាលើប្រធានបទលើការគ្រប់គ្រងទឹក និងការអភិវឌ្ឍវិស័យទេសចរណ៍នៅរមណីយដ្ឋានអង្គរ។ ក្នុងនោះដែរ អ្នកជំនាញអន្តរជាតិដែលបានចូលរួមធ្វើការស្រាវជ្រាវនៅក្រុមប្រាសាទព្រះពិជូរក៏បានធ្វើបង្ហាញលើប្រធានបទសំខាន់ៗដូចជា បុរាណវិទ្យា ស្ថាបត្យកម្ម ប្រវត្តិសិល្បៈ និងការអភិរក្ស។ល។

គួរឲ្យកត់ដែរថា មូលនិធិបេតិកភណ្ឌវប្បធម៌កូរ៉េ បានចាប់ផ្តើមគម្រោងជួសជុលអភិរក្សក្រុមប្រាសាទព្រះពិជូរ កាលពីឆ្នាំ ២០១៥ និងបញ្ចប់ជំហានដំបូងនៅចុងឆ្នាំ២០១៨ និងបានបណ្តុះបណ្តាលជំនាញផ្សេងៗដល់អ្នកជំនាញខ្មែរទាំងក្នុងនិងក្រៅប្រទេសនាពេលកន្លងមកដើម្បីចែករំលែកនូវបទពិសោធន៍ល្អៗទាំងលើកិច្ចការអភិរក្សនិងការគ្រប់គ្រងរមណីយដ្ឋានបេតិកភណ្ឌពិភពលោក៕









ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរាចូលរួមកោរពវិញ្ញាណក្ខន្ធសពឧត្តមសេនីយ៍ឯក ជា ម៉ន

ផ្សាយនៅថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១៨

នៅរសៀលថ្ងៃទី២៦ ខែតុលា ឆ្នាំ ២០១៨ ប្រតិភូអាជ្ញាធរជាតិអប្សរា ដឹកនាំដោយ**លោក ជុំ សុកមករា** អគ្គនាយករងអាជ្ញាធរជាតិអប្សរា ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីមួយចំនួន បានអញ្ជើញគោរពវិញ្ញាណក្ខន្ធសព **ឯកឧត្តមឧត្តមសេនីយ៍ឯក ជា ម៉ន** នៅគេហដ្ឋានឯកឧត្តម ស្ថិតនៅភូមិត្រពាំងសេះ សង្កាត់គោកចក ក្រុងសៀមរាប។

ឯកឧត្តមឧត្តមសេនីយ៍ឯក ជា ម៉ន មេបញ្ជាការរងកងទ័ពជើងគោក និងជាមេបញ្ជាការយោធភូមិភាគទី៤ បានទទួលមរណភាពនៅថ្ងៃទី២៣ ខែតុលា ឆ្នាំ ២០១៨ វេលាម៉ោង ៩ និង១៥នាទីយប់ ក្នុងជន្មាយុ ៦៦ឆ្នាំ ដោយរោគាពាធ។





ព្រឹត្តិការណ៍ព័ត៌មាន
ប្រចាំខែវិច្ឆិកា

ផ្នែកទី ១១
ប្រចាំខែវិច្ឆិកា

សេចក្តីជូនដំណឹងស្តីពី ការបើកឲ្យចូលទស្សនាសារមន្ទីរព្រះនរោត្តមសីហនុអន្តរ ដោយមិនគិតថ្លៃចំនួន០៣ថ្ងៃ

ផ្សាយនៅថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១៨



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA
លេខ.១១៦៤.អប.សដណ
១៨

សេចក្តីជូនដំណឹង
ស្តីពី
ការបើកឲ្យចូលទស្សនាសារមន្ទីរព្រះនរោត្តមសីហនុ-អន្តរ
ដោយមិនគិតថ្លៃចំនួន០៣ថ្ងៃ

អគ្គនាយកដ្ឋាននៃអាជ្ញាធរអប្សរា មានកិត្តិយសសូមជម្រាបជូនដំណឹងដល់គ្រប់ក្រសួង មន្ទីរ ស្ថាប័នជាតិ-អន្តរជាតិ អង្គភាព សមាគមទីភ្នាក់ងារទេសចរណ៍ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ មគ្គុទ្ទេសក៍ទេសចរណ៍ ក្រុមហ៊ុនទេសចរណ៍ សមាគមដឹកជញ្ជូនភ្ញៀវទេសចរ អ្នកដឹកជញ្ជូនភ្ញៀវទេសចរ ភ្ញៀវទេសចរជាតិ-អន្តរជាតិ ព្រមទាំងសាធារណជនទាំងអស់ មេត្តាជ្រាបថា៖ ដើម្បីចូលរួមអបអរសាទរពិធីខួបគម្រប់១០ឆ្នាំ នៃដំណើរការបើកទទួលភ្ញៀវរបស់សារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ និងពិធីសម្ពោធព្រះពុទ្ធអង្គធំដែលតម្កល់ក្នុងសួនខាងមុខសារមន្ទីរផង សារមន្ទីរនឹងបើកឲ្យសាធារណជនទាំងភ្ញៀវជាតិ-អន្តរជាតិចូលទស្សនាដោយមិនគិតថ្លៃរយៈពេល០៣ថ្ងៃ ចាប់ពីថ្ងៃអង្គារទី០៤ ដល់ថ្ងៃព្រហស្បតិ៍ទី០៦ ខែធ្នូ ឆ្នាំ២០១៨ ក្នុងម៉ោងធ្វើការ ចាប់ពីម៉ោង៨:៣០នាទីព្រឹក ដល់ម៉ោង៤:៣០នាទីល្ងាច។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមគ្រប់ក្រសួង មន្ទីរ ស្ថាប័នជាតិ-អន្តរជាតិ អង្គភាព សមាគមទីភ្នាក់ងារទេសចរណ៍ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ មគ្គុទ្ទេសក៍ទេសចរណ៍ ក្រុមហ៊ុនទេសចរណ៍ សមាគមដឹកជញ្ជូនភ្ញៀវទេសចរ អ្នកដឹកជញ្ជូនភ្ញៀវទេសចរ ភ្ញៀវទេសចរជាតិ-អន្តរជាតិ និងសាធារណជនទាំងអស់ មេត្តាជ្រាបជាព័ត៌មាន និងអញ្ជើញចូលទស្សនាសារមន្ទីរឲ្យបានច្រើនកុះករ។

ថ្ងៃ ៣ ខែ សល្វែង ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
សៀមរាប ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ២០១៨

អគ្គនាយក

ស៊ឹ ម៉ាប់

ចម្លងជូន៖
-ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
-ក្រសួងទេសចរណ៍
-សាលាខេត្តសៀមរាប
-គ្រប់មន្ទីរជុំវិញខេត្ត
-សាលាក្រុងសៀមរាប
-គ្រប់នាយកដ្ឋាន
-អង្គភាពនគរបាលការពារបេតិកភណ្ឌប្រចាំខេត្តសៀមរាប
-អង្គភាពនគរបាលទេសចរណ៍ប្រចាំខេត្តសៀមរាប
-សមាគមទីភ្នាក់ងារទេសចរណ៍-សមាគមសណ្ឋាគារ
-សមាគមមគ្គុទ្ទេសក៍ទេសចរណ៍
-សមាគមអ្នកបើកបរយន្តដឹកជញ្ជូនភ្ញៀវទេសចរ
-ឯកសារ-កាលប្បវត្តិ

ភ្នំពេញ:
មហាវិថីសហព័ន្ធរុស្ស៊ី លេខ៤១ សង្កាត់មិត្តភាព ខណ្ឌឫស្សីកែវ
ទូរសព្ទ/ទូរសារ៖ ០២៣ ២១៤ ៧៨១/០២៣ ២១៤ ៧៨៦

អាជ្ញាធរជាតិអប្សរា
Email: info@apsaraauthority.gov.kh
Website: http//www.apsaraauthority.gov.kh

សៀមរាប:
ភូមិបង្គួរ ឃុំសំពៅលិច ស្រុកប្រាសាទជាន ខេត្តសៀមរាប
ទូរសព្ទ/ទូរសារ៖ ០៦៣ ៧៦៤ ៥៧៧/០៦៣ ៧៦៤ ៥៧៦

បុគ្គលិកថ្មីបម្រើការងារថ្មីប្រមាណ១០០នាក់ទទួលបានការបណ្តុះបណ្តាលលើកិច្ចការពារ និងគ្រប់គ្រងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១៨

នៅព្រឹកថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ នាសាលសន្និសីទអង្គរ នៃអាជ្ញាធរជាតិអប្សរា បានបើកវគ្គបណ្តុះបណ្តាលពីកិច្ចការពារ និងគ្រប់គ្រងរមណីយដ្ឋានអង្គរ បេតិកភណ្ឌពិភពលោក។ វគ្គបណ្តុះបណ្តាលនេះមានរយៈពេល៣ថ្ងៃ ចាប់ពីថ្ងៃទី ៣១ តុលា ដល់ថ្ងៃទី២ វិច្ឆិកា ឆ្នាំ២០១៨ រៀបចំឡើងក្នុងគោលបំណងបំពេញចំណេះដឹងបន្ថែមដល់បុគ្គលិកផ្នែកសណ្តាប់ធ្នាប់ចំនួន ៣៦នាក់ និងផ្នែកទេសចរណ៍ចំនួន ៦៤នាក់ដែលទើបចូលបម្រើការងារនៅអាជ្ញាធរជាតិអប្សរាឱ្យយល់ដឹងកាន់តែស៊ីជម្រៅ និងទូលំទូលាយបន្ថែមទៀតអំពីតម្លៃប្រវត្តិសាស្ត្រខ្មែរ ការងារអភិរក្ស និងអភិវឌ្ឍន៍ ក្នុងតំបន់ការពារបេតិកភណ្ឌ«អង្គរ»ទាំងមូល។

លោក អ៊ឹម សុខរិទ្ធ អនុប្រធានមជ្ឈមណ្ឌលអន្តរជាតិស្រាវជ្រាវ និងតម្កល់ឯកសារអង្គរ តំណាងឱ្យ **ឯកឧត្តម ស៊ុំ ម៉ាប់** អគ្គនាយកអាជ្ញាធរជាតិអប្សរាបានឱ្យដឹងថា កម្មវិធីបណ្តុះបណ្តាលនេះមានសារៈសំខាន់ណាស់ ដែលអាចផ្តល់ចំណេះដឹងជាមូលដ្ឋានដល់បុគ្គលិកដែលបម្រើការងារនៅតាមប្រាសាទ ដែលស្ថិតនៅជួរមុខ ប្រៀបបានជាខ្សែត្រៀម ស្ថិតនៅជាប់ជាមួយប្រាសាទ ប្រតិបត្តិការណ៍ផ្ទាល់ជាពិសេសជាមួយភ្ញៀវទេសចរ។ លោកបានបន្តថាយើងមានគោលការណ៍សិក្សារៀនសូត្របន្តិចម្តងៗជាបន្តបន្ទាប់ និងមានភាពសាមគ្គីគ្នាផ្តល់ព័ត៌មានឱ្យគ្នាទៅវិញទៅមក ហើយអាចយកចំណេះដឹងផ្ទាល់ខ្លួននេះទៅអប់រំ ផ្សព្វផ្សាយបន្តដល់សហគមន៍ ដៀសវាងការទទួលយកព័ត៌មានមិនពិត។

លោក ស្វាយ ពិសិដ្ឋ តំណាងឱ្យនាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍អង្គរ បានលើកឡើងក្នុងឱកាសនោះដែរថា សិក្ខាកាមដែលមានវត្តមាននៅទីនេះពិតជាបានខិតខំប្រឹងប្រែង តស៊ូ អត់ធ្មត់ដោយឆ្លងកាត់ការធ្វើតេស្តសមត្ថភាពដោយសរសេរនិងផ្ទាល់មាត់បានយ៉ាងជោគជ័យ។ លោកបានបន្តទៀតថា ក្នុងនាមជាអ្នកធ្វើការបម្រើបេតិកភណ្ឌ ត្រូវស្វែងយល់ពីបេតិកភណ្ឌ និងចូលរួមថែរក្សាទាំងអស់គ្នា។

គួរបញ្ជាក់ថា វគ្គបណ្តុះបណ្តាលនេះផ្តោតសំខាន់ទៅលើប្រវត្តិសាស្ត្រ អារ្យធម៌ និងបេតិកភណ្ឌ។ លើសពីនេះគឺគោលការណ៍អភិរក្សតំបន់រមណីយដ្ឋានអង្គរបេតិកភណ្ឌពិភពលោក ការគ្រប់គ្រងបេតិកភណ្ឌវប្បធម៌ និងអនុសញ្ញាបេតិកភណ្ឌពិភពលោកបង្ហាញដល់សិក្ខាកាមផងដែរ មុននឹងលើកឡើងអំពីអាជ្ញាធរជាតិអប្សរា និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធទាក់ទងអំពីការគ្រប់គ្រងមន្ត្រី-បុគ្គលិក។ ម្យ៉ាងទៀតខិតខំធ្វើយ៉ាងណាគ្រប់គ្រងប្រព័ន្ធផ្លូវទឹកបុរាណក្នុងឧទ្យានអង្គរ ការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍ប្រកបដោយចីរភាព។ ការគ្រប់គ្រងសំណង់លំនៅដ្ឋានខ្មែរក្នុងតំបន់អង្គរ និងគ្រប់គ្រងលំនៅដ្ឋានខ្មែរ ដែលជាកិច្ចការដ៏មានសារៈសំខាន់ រួមនិងការអភិរក្ស និងអភិវឌ្ឍន៍បេតិកភណ្ឌក្រុងសៀមរាប អង្គរ និងការអភិវឌ្ឍន៍សហគមន៍ក្នុងតំបន់អង្គរ៕









ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរាចូលរួមកោរពវិញ្ញាណក្ខន្ធសពឯកឧត្តមឧត្តមសេនីយ៍ឯក ព្រហ្ម ពុធ

ផ្សាយនៅថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០១៨

នៅព្រឹកថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ ២០១៨ ប្រតិភូអាជ្ញាធរជាតិអប្សរា ដឹកនាំដោយ **ឯកឧត្តម ខួយ គឹមឆួ** ទីប្រឹក្សាអាជ្ញាធរជាតិអប្សរាព្រមទាំងថ្នាក់ដឹកនាំនិងមន្ត្រីមួយចំនួនបានអញ្ជើញគោរពវិញ្ញាណក្ខន្ធសព **ឯកឧត្តមឧត្តមសេនីយ៍ឯក ព្រហ្ម ពុធ** នៅគេហដ្ឋានឯកឧត្តម ស្ថិតនៅភូមិទ្រាំង សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប។

ឯកឧត្តមឧត្តមសេនីយ៍ឯក ព្រហ្ម ពុធ មេបញ្ជាការរងកងពលធំអន្តរាគមន៍លេខ២ បានទទួលមរណភាពនៅថ្ងៃទី៣១ ខែតុលា ឆ្នាំ ២០១៨ ក្នុងជន្មាយុ ៦២ឆ្នាំ ដោយរោគាពាធ។

សូមវិញ្ញាណក្ខន្ធឯកឧត្តមឧត្តមសេនីយ៍ឯក បានទៅកាន់សុគតិភព កុំបីឃ្លៀងឃ្លាតឡើយ។









ផ្លូវជួលដែលស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា នឹងចាប់ផ្តើមជួសជុលឡើងវិញទាំងអស់នៅចុងឆ្នាំ២០១៨នេះតទៅ

ផ្សាយនៅថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០១៨

រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាប្រធានអាជ្ញាធរជាតិអប្សរា **លោកជំទាវ ភឿង សកុណា** មានប្រសាសន៍ថា ផ្លូវថ្នល់ដែលស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា នឹងត្រូវធ្វើការជួសជុលឡើងវិញទៅអស់នៅចុងឆ្នាំ ២០១៨ខាងមុននេះតទៅ។ ការថ្លែងបែបនេះរបស់លោកជំទាវ គឺនៅក្នុងកិច្ចប្រជុំលើកដំបូងនៃគណៈកម្មការអន្តរក្រសួង ដើម្បីសិក្សារៀបចំផែនការមេសម្រាប់ការអភិវឌ្ឍវិស័យទេសចរណ៍ខេត្តសៀមរាប ដែលធ្វើឡើងនៅរដ្ឋបាលខេត្តសៀមរាប នារសៀលថ្ងៃទី ៣០ តុលាកន្លងទៅ។

ការលើកឡើងរបស់លោកជំទាវរដ្ឋមន្ត្រី គោលបំណងសំខាន់នៃការរៀបចំជួសជុលផ្លូវទាំងអស់របស់អាជ្ញាធរជាតិអប្សរាឡើងវិញ គឺដើម្បីសម្រួលដល់ការធ្វើដំណើររបស់ប្រជាពលរដ្ឋ ក៏ដូចជាភ្ញៀវទេសចរដែលមានការកើនឡើងយ៉ាងឆាប់រហ័សមកកាន់ខេត្តសៀមរាប។

គួរឱ្យកត់ថា ផ្លូវប្រៀបដូចសរសៃឈាមរបស់ប្រទេសជាតិ។ នារយៈពេលចុងក្រោយនេះ អាជ្ញាធរជាតិអប្សរាបានធ្វើការជួសជុល និងកែលម្អប្រព័ន្ធផ្លូវថ្នល់មួយចំនួនក្នុងរមណីយដ្ឋានអង្គរ បំណងដើម្បីលើកសោភ័ណភាព និងការសម្រួលដល់ការធ្វើដំណើរដល់សាធារណជនទូទៅ គួរយ៉ាងដូចផ្លូវក្នុងវង់តូច និងវង់ធំ។ យ៉ាងណាមិញ ដ្បិតបានអភិវឌ្ឍបានច្រើនយ៉ាងណាក្តី ក៏នៅមានផ្លូវខ្លះមានការខូចខាតផងដែរ មូលហេតុទាំងនោះដោយសារការដឹកជញ្ជូនធ្ងន់ៗ និងចរាចរណ៍មានភាពមមាញឹកជាងពេលមុនៗជាដើម។ល។









អាជ្ញាធរជាតិអប្សរាចុះអនុស្សរណៈជាមួយវិទ្យាស្ថាន KICT ដើម្បីសិក្សាលើការរៀបចំលំហូរចរាចរក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១៨

ស្របពេលដែលរមណីយដ្ឋានអង្គរកំពុងតែទទួលបាននូវកំណើនទេសចរជារៀងរាល់ឆ្នាំ អាជ្ញាធរជាតិអប្សរាក៏បានគិតគូរដល់ការរៀបចំហេដ្ឋារចនាសម្ព័ន្ធ និងគ្រប់គ្រងលំហូរចរាចរឲ្យបានល្អប្រសើរ ដើម្បីលើកកម្ពស់បទពិសោធន៍ទស្សនារបស់ភ្ញៀវទេសចរ ការពារនូវតម្លៃលេចធ្លោរបស់រមណីយដ្ឋានអង្គរ ព្រមទាំងសម្រួលដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្នុងតំបន់អង្គរ។

ក្នុងន័យនេះ អាជ្ញាធរជាតិអប្សរាបានសម្រេចចុះអនុស្សរណៈយោគយល់គ្នាជាមួយវិទ្យាស្ថានកូរ៉េសម្រាប់វិស្វកម្មសំណង់ និងបច្ចេកវិទ្យា KICT (Korea Institute of Civil Engineering and Building Technology) នារសៀលថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៨ ក្រោមអធិបតីភាព **ឯកឧត្តម សុខ សន្ធារ** អគ្គនាយករងនៃអាជ្ញាធរជាតិអប្សរា និង **បណ្ឌិត** Junhwa Jung អនុប្រធាននៃវិទ្យាស្ថានKICT។

ពិធីចុះហត្ថលេខានេះ ធ្វើឡើងបន្ទាប់ពីដំណើរទស្សនកិច្ចជាផ្លូវការរបស់ **លោកជំទាវ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាប្រធានអាជ្ញាធរជាតិអប្សរា ទៅកាន់សាធារណរដ្ឋកូរ៉េកាលពីចុងខែតុលាកន្លងទៅថ្មីៗនេះ។ គោលបំណងចម្បងនៃអនុស្សរណៈនេះ គឺដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការ និងសិក្សារួមគ្នាអំពី ការរៀបចំហេដ្ឋារចនាសម្ព័ន្ធ និងការគ្រប់គ្រងចរាចរក្នុងរមណីយដ្ឋានអង្គរឲ្យបានល្អប្រសើរ ក្នុងន័យត្រៀមខ្លួនសម្រាប់កំណើនទេសចរជារៀងរាល់ឆ្នាំ។

លោក Junhwa Jung បានបង្ហាញអារម្មណ៍សប្បាយរីករាយ ដែលបានចូលរួមសហការជាមួយអាជ្ញាធរជាតិអប្សរា លើការងាររៀបចំចរាចរក្នុងតំបន់បេតិកភណ្ឌពិភពលោកអង្គរ។ KICT ធ្លាប់បានរៀបចំដោយជោគជ័យនូវការរៀបចំហេដ្ឋារចនាសម្ព័ន្ធ និងលំហូរចរាចរក្នុងប្រទេសកូរ៉េក៏ដូចជា បណ្តាប្រទេសផ្សេងៗមួយចំនួនទៀត។ យើងសង្ឃឹមថា កិច្ចសហការនេះនឹងចូលរួមលើកស្ទួយតម្លៃបេតិកភណ្ឌពិភពលោក ក៏ដូចជា រួមចំណែកជាមួយពលរដ្ឋខ្មែរក្នុងកិច្ចការពាររមណីយដ្ឋានអង្គរ។ មានប្រសាសន៍ក្នុងពិធីចុះហត្ថលេខានេះ **ឯកឧត្តម សុខ សន្ធារ** បានថ្លែងអំណរគុណចំពោះវិទ្យាស្ថាន KICT ដែលបានគាំទ្រចំពោះកិច្ចការអភិរក្ស និងអភិវឌ្ឍក្នុងរមណីយដ្ឋានអង្គរ តាមរយៈកិច្ចសហការដែលឈានមកដល់ការចុះអនុស្សរណៈយោគយល់គ្នានៅថ្ងៃនេះ។ ឯកឧត្តម បញ្ជាក់ថា អនុស្សរណៈនេះគឺជាលទ្ធផលមួយយ៉ាងល្អ ក្រោយពីក្រុមទាំងពីរបានធ្វើការជាមួយគ្នាអស់រយៈពេលជាងមួយឆ្នាំកន្លងមក។

ឯកឧត្តម សង្ឃឹមថា កិច្ចសហការរវាងស្ថាប័នទាំងពីរនឹងកាន់តែរឹងមាំថែមទៀត និងសម្រេចបាននូវលទ្ធផលយ៉ាងល្អប្រសើរនាពេលឆាប់ៗខាងមុខនេះ ជាពិសេស គឺការរៀបចំលំហូរចរាចរក្នុងតំបន់អង្គរបានល្អប្រសើរ ដែលអាចកាត់បន្ថយនូវផលប៉ះពាល់ទាំងផ្នែកបរិស្ថាន និងបេតិកភណ្ឌក្នុងតំបន់អង្គរ៕






អ្នកភូមិនគរក្រៅអរគុណដល់អាជ្ញាធរជាតិអប្សរាចំពោះទ្វារទឹកថ្មីដែលជួយឱ្យដំណាំកសិកម្មពួកគាត់មានផលល្អឡើងវិញ

ផ្សាយនៅថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១៨

អ្នកភូមិនគរក្រៅ សង្កាត់គោកចក ក្រុងសៀមរាប បានសម្តែងការសោទរចំពោះសំណង់ទ្វារទឹកថ្មីនៅមូលដ្ឋានពួកគេ ដែលសង់ឡើងដោយអាជ្ញាធរជាតិអប្សរា។ ទ្វារទឹកនេះអាចផ្គត់ផ្គង់ទឹកសម្រាប់ស្រែចម្ការពេលរដូវជាង ៥០០គ្រួសារ លើផ្ទៃដីជិត ១០០ហិកតា។

ទ្វារទឹកលោកតា ស៊ត់ ទើបនឹងសង់រួចរាល់នៅអំឡុងខែតុលា ក្រោយដំណើរការសាងសង់ចាប់ពីខែមិថុនាមក។ ទ្វារទឹកនេះសង់ឡើងដោយបច្ចេកទេសត្រឹមត្រូវ ដោយមានប្រព័ន្ធបិទទ្វារទឹកដើម្បីស្ទាក់ទឹកទុកប្រើនារដូវប្រាំងផងដែរ។

ពលរដ្ឋមួយរូប**លោក ឃឿន ម៉ាប់** បានឱ្យដឹងថា ស្រែរបស់លោកនៅឆ្នាំនេះទទួលបានផលល្អណាស់ ដោយសារមានទឹកស្រោចស្រពគ្រប់គ្រាន់។ តាមការបញ្ជាក់របស់**លោក ម៉ាប់** ក្រោយទំនប់ទឹកចាស់បានបាក់មក អ្នកភូមិនគរក្រៅ មិនដែលធ្វើស្រែបានផលល្អឡើយ ដោយសារគ្មានទឹកផ្គត់ផ្គង់គ្រប់គ្រាន់ ពិសេសពេលរដូវប្រាំងមកដល់។ ទើបតែឆ្នាំនេះទេ ដែល

លោក ម៉ាប់ ធ្វើស្រែបានល្អ ហើយលោករំពឹងថា ផលដំណាំស្រូវលោកអាចនឹងទទួលបានផលច្រើននៅលើផ្ទៃដីជាង ២ហិកតា ដែលរាល់ឆ្នាំ អត់ទឹក ធ្វើឱ្យស្រូវស្កក ហើយទទួលផលតែ២ទៅ៣ការ៉ុងប៉ុណ្ណោះក្នុងមួយឆ្នាំៗ។

ចំណែក**អ្នកស្រី ឡាយ ខុំ** នោះវិញ អ្នកស្រីកំពុងមមាញឹកនឹងដំណាំត្រសក់ទឹក ដែលកំពុងឡើងទ្រើងបណ្តើរៗហើយនោះ។ អ្នកស្រីថា តាំងពីមានទឹកដែលបង្ហូរពីទ្វារទឹកថ្មីដែលសង់ដោយអាជ្ញាធរជាតិអប្សរាមក ធ្វើឱ្យអ្នកស្រីមានភាពងាយស្រួលក្នុងការទាញទឹកមកស្រោចស្រពដំណាំ ដែលពេលមុនការប្រើប្រាស់ត្រូវបុកអណ្តូង ហើយត្រូវចំណាយធនធានច្រើន។ ពេលនេះ **អ្នកស្រី ខុំ** អាចបូមទឹកមកស្រោចស្រពដំណាំបានយ៉ាងងាយ ដោយគ្រាន់តែដាក់ម៉ាស៊ីនបូមចេញពីប្រឡាយតែប៉ុណ្ណោះ។

លោក ភឿន សុយឹម អនុប្រធាននាយកដ្ឋានគ្រប់គ្រងនៃអាជ្ញាធរជាតិអប្សរា បានឱ្យដឹងថា ទ្វារទឹកលោកតា ស៊ត់ ក្រៅពីបម្រើដល់ផលកសិកម្មដល់ប្រជាពលរដ្ឋហើយនោះ ទ្វារទឹកនេះសង់ឡើងដើម្បីគ្រប់គ្រង និងស្តុកទឹករក្សាលំនឹងប្រាសាទផងដែរ ព្រោះទឹកមានទំនាក់ទំនងយ៉ាងជិតស្និទទៅនឹងគ្រឹះប្រាសាទក្នុងរមណីយដ្ឋានអង្គរ។ តាមលោក សុយឹម ទ្វារទឹកនេះអាចស្តាក់ទឹកបម្រើដល់ប្រយោជន៍ប្រជាពលរដ្ឋជាង ៥០០គ្រួសារ លើផ្ទៃដីកសិកម្មជិត ១០០ ហិកតា។ ក្រៅពីនេះ ទ្វារទឹកនេះដើរតួយ៉ាងសំខាន់សម្រាប់រំដោះជំនន់ទឹកភ្លៀងក្នុងក្រុងអង្គរ និងក្រុងសៀមរាប ព្រមទាំងដើម្បីរក្សាទឹកក្រោមដីក្នុងតំបន់អង្គរផងដែរ។

គួរបញ្ជាក់ថា ទ្វារទឹកលោកតា ស៊ត់ មានបណ្តោយជាង ២០ម៉ែត្រ និងទទឹងប្រមាណ ១៨ម៉ែត្រ ហូរកាត់អូរខ្លូត ដែលរំដោះទឹកភ្លៀងហូរចាក់ទៅស្ទឹងពួក និងស្ទឹងព្រះស្រុក៕









តំណាងផ្នែកវប្បធម៌ និងសារមន្ទីរប្រទេសអាស៊ានចុះសិក្សាស្វែងយល់ពីការងារគ្រប់គ្រងរមណីយដ្ឋានអង្គរបស់អាជ្ញាធរជាតិអប្សរា

ផ្សាយនៅថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១៨

នៅព្រឹកថ្ងៃទី៥ វិច្ឆិកា ឆ្នាំ២០១៨ សិក្ខកាមតំណាងស្ថាប័នផ្នែកវប្បធម៌ និងសារមន្ទីរនៃប្រទេសអាស៊ាន បានចូលជួបសម្តែងការគួរសមជាមួយថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា ក៏ដូចជាសិក្សាស្វែងយល់ពីការងារគ្រប់គ្រងរមណីដ្ឋានអង្គរ ដែលគ្រប់គ្រងដោយអាជ្ញាធរជាតិអប្សរា។

លោកបណ្ឌិត យូ យ៉ុនហាន់ មន្ត្រីផ្នែកវប្បធម៌ និងកិច្ចការសាសនានៃប្រទេសភូមា និងតំណាងលោកសាស្ត្រាចារ្យ យូស៊ីអាគី អ៊ីស៊ីសាវ៉ា ប្រធានសាកលវិទ្យាល័យស៊ូហ្វីយ៉ា បានលើកឡើងថា សាកលវិទ្យាល័យស៊ូហ្វីយ៉ា បានរៀបចំសិក្ខាសាលារយៈពេល៧ថ្ងៃ ដោយពិភាក្សាពីតួនាទីរបស់សារមន្ទីរនៅក្នុងតំបន់អាស៊ាន។ នេះជាឆ្នាំទី២ហើយដែលសិក្ខាសាលានេះត្រូវបានរៀបចំឡើង ហើយប្រធានបទសម្រាប់ឆ្នាំនេះ គឺការទុកដាក់វត្ថុបុរាណដែលរកឃើញនៅក្នុងតំបន់ការពារ ការចុះបញ្ជើសារពើភ័ណ្ឌ ការតាំងបង្ហាញ និងការផ្តល់ព័ត៌មានដល់ប្រជាជនក្នុងតំបន់ឱ្យស្គាល់ពីស្ថាប័នគ្រប់គ្រងដោយរបៀបណា។ល។
លោកបណ្ឌិត ឡៅ គឹមលាង អ្នកដឹកនាំកម្មវិធីសិក្ខាសាលាអន្តរជាតិសារមន្ទីរ និងវត្ថុបុរាណ អាស៊ានឆ្នាំ ២០១៨ បានឱ្យដឹងថា បណ្តាប្រទេសអាស៊ានមានបញ្ហាទាក់ទងនឹងការងារសារមន្ទីរ និងវត្ថុបុរាណ ប្រហាក់ប្រហែល ដូច្នេះសិក្ខាសាលានេះគឺចង់ធ្វើយ៉ាងណាឱ្យបណ្តាប្រទេសទាំងនោះមានយន្តការតែមួយ បែបបទតែមួយ ដើម្បីដោះស្រាយបញ្ហារួមគ្នា។ តាមការបញ្ជាក់របស់លោក ឡៅ គឹមលាង គម្រោងរបស់សាកលវិទ្យាល័យស៊ូហ្វីយ៉ា គ្រោងនឹងរៀបចំសិក្ខាសាលានេះរយៈពេល ៣ឆ្នាំ ដោយឆ្នាំទី១ ធ្វើឡើងកាលពីឆ្នាំទៅ ផ្តោតលើប្រធានបទ ការគ្រប់គ្រងសារមន្ទីរនៅតាមជនបទ ឬតាមបណ្តាខេត្ត។

មានប្រសាសន៍ស្វាគមន៍ដល់សិក្ខាកាមប្រទេសអាស៊ាន **ឯកឧត្តម ហង់ ពៅ** អគ្គនាយករង និងជាតំណាងឯកឧត្តមអគ្គនាយកអាជ្ញាធរជាតិអប្សរា បានអរគុណដល់កិច្ចសហប្រតិបត្តិការនានារបស់ប្រទេសអាស៊ាន ក៏ដូចជាការជ្រើសរើសរមណីយដ្ឋានអង្គរជាគោលដៅសម្រាប់សិក្សាស្វែងយល់នានា រួមទាំងសិក្ខាសាលានៅពេលនេះជាដើម។ ឯកឧត្តម ក៏បានធ្វើបទបង្ហាញខ្លីទាក់ទងនឹងការងារគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍រមណីយដ្ឋានអង្គរជូនដល់អ្នកចូលរួមឱ្យយល់ផងដែរ។ ឯកឧត្តមបន្ថែមថា អាជ្ញាធរជាតិអប្សរារីករាយជានិច្ចក្នុងការចែករំលែកបទពិសោធន៍ការងារគ្រប់គ្រងរមណីយដ្ឋានអង្គរដល់ប្រទេសនានាដែលចង់រៀនសូត្រ។

គួរបញ្ជាក់ថា សិក្ខាសាលាអន្តរជាតិសារមន្ទីរ និងវត្ថុបុរាណ អាស៊ានឆ្នាំ ២០១៨ ធ្វើឡើងរយៈពេល៧ថ្ងៃ គឺចាប់ពីថ្ងៃទី២ ដល់ទី៨ ខែវិច្ឆិកា ដោយកម្មវិធីនេះធ្វើនៅរាជធានីភ្នំពេញ និងខេត្តសៀមរាប។ នៅខេត្តសៀមរាប សិក្ខាកាមនឹងចុះសិក្សាស្វែងយល់នៅសារមន្ទីរព្រះនរោត្តម សីហនុ-អង្គរ អភិរក្សដ្ឋានអង្គរ ការដ្ឋានជួសជុលប្រាសាទ និងទស្សនាប្រាសាទមួយចំនួនទៀត។ល។






អាជ្ញាធរជាតិអប្សរាចាប់ផ្តើមអ៊ុតកៅស៊ូលើផ្លូវសម្តេចតិបុលបញ្ញា សុខ អាន ដែលជាផ្លូវសំខាន់មួយក្នុងក្រុងសៀមរាប

ផ្សាយនៅថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១៨

អនុលោមតាមប្រសាសន៍របស់**លោកជំទាវ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រ និងជាប្រធានអាជ្ញាធរជាតិអប្សរា ក្នុងកិច្ចប្រជុំលើកដំបូងនៃគណៈកម្មការអន្តរក្រសួង ដើម្បីសិក្សារៀបចំផែនការមេសម្រាប់ការអភិវឌ្ឍវិស័យទេសចរណ៍ខេត្តសៀមរាប កាលពីថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨ អាជ្ញាធរជាតិអប្សរា បានចាប់ផ្តើមអ៊ុតក្រាលកៅស៊ូនៅតាមបណ្តោយផ្លូវ**សម្តេចតិបុលបញ្ញា សុខ អាន** ហើយនៅថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០១៨។

គួរបញ្ជាក់ថា ការស្តាបនា ជួសជុល និងកែលម្អផ្លូវនានាក្នុងរមណីយដ្ឋានអង្គរ គឺធ្វើឡើងក្នុងបំណងដើម្បីសម្រួលការធ្វើដំណើរដល់សាធារណជន ក៏ដូចជាភ្ញៀវទេសចរដែលធ្វើដំណើរមកកម្សាន្តខេត្តសៀមរាប ដែលមានការកើនឡើងជារៀងរាល់ថ្ងៃ។






សិក្ខាកាម៤០នាក់ នឹងក្លាយជាអ្នកជំនាញនិងពេញសិទ្ធិក្នុងការបម្រើការងារនៅអាជ្ញាធរជាតិអប្សរា ក្រោយបញ្ចប់វគ្គបណ្តុះបណ្តាលស្តីអំពីកិច្ចការពារ និងគ្រប់គ្រងរមណីយដ្ឋានអង្គរបេតិកភណ្ឌពិភពលោក

ផ្សាយនៅថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨

នាថ្ងៃបញ្ចប់វគ្គបណ្តុះបណ្តាលស្តីអំពីកិច្ចការពារ និងគ្រប់គ្រងរមណីយដ្ឋានអង្គរបេតិកភណ្ឌពិភពលោកដល់បុគ្គលិកថ្មីជាភ្នាក់ងារសណ្តាប់ធ្នាប់ និងភ្នាក់ងារទេសចរណ៍កាលពីរសៀលថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៨ ក្រោមអធិបតីភាព **ឯកឧត្តម សុខ សន្ធារ** អគ្គនាយករង តំណាង **ឯកឧត្តមបណ្ឌិត ស៊ុំ ម៉ាប់** អគ្គនាយកអាជ្ញាធរជាតិអប្សរា ជ្រើសបានបុគ្គលិកពេញសិទ្ធិចំនួន៤០នាក់ ក្នុងចំណោម១០០នាក់។

លោក អ៊ឹម សុខរីទ្ធី អនុប្រធានមជ្ឈមណ្ឌលអន្តរជាតិស្រាវជ្រាវ និងតម្កល់ឯកសារអង្គរ បានលើកឡើងថា ក្រោយបញ្ចប់វគ្គបណ្តុះបណ្តាលនេះ សិក្ខាកាមនឹងបានយល់ដឹងកាន់តែច្រើននិងច្បាស់លាស់ពីកិច្ចការអភិរក្ស ការគ្រប់គ្រងតំបន់អង្គរមានសំណង់ប្រាសាទ បរិស្ថាន ហេដ្ឋារចនាសម្ព័ន្ធ សហគមន៍ ច្បាប់ការពារបេតិកភណ្ឌ រួមទាំងមរតកវប្បធម៌ទាំងរូបីនិងអរូបី ពីសំណាក់វាគ្មិនជំនាញៗរបស់អាជ្ញាធរជាតិអប្សរា។

លោកសង្ឃឹមថា សិក្ខាកាមពេញសិទ្ធិជាបុគ្គលិកអាជ្ញាធរជាតិអប្សរាទាំង៤០នាក់ នឹងយកចំណេះដឹងទាំងនេះទៅអនុវត្តលើការងារជាក់ស្តែងប្រកបដោយប្រសិទ្ធិភាពតាមមុខការរបស់ខ្លួន សមជាអ្នកការពាររមណីយដ្ឋានអង្គរបេតិកភណ្ឌពិភពលោក។ ពិសេសសូមអរគុណដល់បុគ្គលិកបម្រុងទាំងអស់ដែលចំណាយពេលវេលាមករៀនសូត្រដើម្បីស្វែងយល់ពីកិច្ចការនៅតំបន់អង្គររបស់អាជ្ញាធរជាតិអប្សរាទុកជាបទពិសោធន៍និងអភិវឌ្ឍន៍ចំណេះដឹងរបស់ខ្លួន ដែលអាចនឹងមានប្រយោជន៍នៅថ្ងៃណាមួយមិនខាន។

ថ្លែងក្នុងឱកាសបិទកម្មវិធី **ឯកឧត្តម សុខ សង្ហារ** អគ្គនាយករងទទួលបន្ទុកនាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍អង្គរបានមានប្រសាសន៍ស្វាគមន៍បុគ្គលិកថ្មីចូលមកកាន់គ្រួសារអប្សរា ដែលឆ្លងកាត់ការប្រឡងជ្រើសរើសប្រកបដោយសមត្ថភាព ពិត សុក្រឹតភាព តម្លាភាព យុត្តិធម៌ និងក្រមសីលធម៌ គ្មានការសូកប៉ាន់អ្វីទាំងអស់។

ឯកឧត្តមក៏បានកថ្លែងអំណរគុណដល់សិក្ខាកាមទាំងអស់ដែលបានចាប់អារម្មណ៍លើការងារជាអ្នកបម្រើវិស័យបេតិកភណ្ឌ និងការយកចិត្តទុកដាក់រៀនសូត្រស្វែងយល់ពីតំបន់រមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ ព្រោះយុវជនជាសសរទ្រូងដ៏សំខាន់ក្នុងការទ្រទ្រង់ប្រទេសជាតិនិងខឿនវប្បធម៌ជាតិឲ្យរុងរឿងបន្តពីមនុស្សជំនាន់មុន។

បន្ថែមពីនោះ ឯកឧត្តមក៏បានចែករំលែកបទពិសោធន៍ខ្លះៗដល់សិក្ខាកាមស្តីអំពីការអភិរក្សនិងការអភិវឌ្ឍន៍តំបន់អង្គរកន្លងមក ព្រមទាំងក្រើនរំឭកដល់សិក្ខាកាមដែលនឹងចូលបម្រើការថ្មី ត្រូវយកចិត្តទុកដាក់ ផ្តល់សេវាល្អ ប្រកបដោយគុណភាព សន្តិសុខ ជូនចំពោះភ្ញៀវជាតិ និងអន្តរជាតិ ហើយមើលការខុសត្រូវភ្ញៀវឱ្យគោរពក្រមប្រតិបត្តិអង្គរឲ្យបានច្បាប់ខ្ជួននៅពេលមកទស្សនារមណីយដ្ឋានអង្គរ៕









សេចក្តីជូនដំណឹងស្តីពី ការកាត់ដកហូតដើមឈើ និងកាត់ក្រឹមកឈើដែលមានហានិភ័យខ្ពស់នៅតាមបរិវេណប្រាសាទ ក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA
លេខ ១១៦៤/២៤ អប. សជណ

សេចក្តីជូនដំណឹង
ស្តីពី
ការកាត់ដកហូតដើមឈើ និងកាត់ក្រឹមកឈើ
ដែលមានហានិភ័យខ្ពស់នៅតាមបរិវេណប្រាសាទ ក្នុងរមណីយដ្ឋានអង្គរ

អាជ្ញាធរជាតិអប្សរា សូមជូនដំណឹងដល់ស្ថាប័ន សមត្ថកិច្ចពាក់ព័ន្ធ ភ្ញៀវជាតិ-អន្តរជាតិ មគ្គុទ្ទេសក៍ទេសចរណ៍ ព្រមទាំងសាធារណជនទាំងអស់មេត្តាជ្រាបថា ដើម្បីធានាដល់សុវត្ថិភាពភ្ញៀវទេសចរ សាធារណជន ក៏ដូចជាដើម្បីលើកកម្ពស់សោភ័ណភាពនៅតាមដងផ្លូវ និងនៅតាមបរិវេណប្រាសាទ ក្នុងតំបន់រមណីយដ្ឋានអង្គរ និងតំបន់ដែលគ្រប់គ្រងដោយអាជ្ញាធរជាតិអប្សរា នាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាន នៃអាជ្ញាធរជាតិអប្សរា នឹងកាត់ដកហូតដើមឈើ និងកាត់ក្រឹមកឈើ តាមទីតាំងនានាដូចខាងក្រោម៖

-កាត់ក្រឹមកឈើចំនួន ០៨ដើម នៅបរិវេណប្រាសាទបន្ទាយក្តី។

-កាត់ក្រឹមកឈើចំនួន ១៧ដើម នៅក្នុងបរិវេណបង្គន់អនាម័យរបស់គ្រឹៈស្ថានអង្គរចំនួន ០៤ទីតាំង មានបរិវេណបង្គន់អនាម័យមុខភ្នំបាខែង បង្គន់អនាម័យតាំងតុ បង្គន់អនាម័យមុខប្រាសាទតាព្រហ្មទិសខាងលិច និងបង្គន់អនាម័យស្រះស្រង់។

-កាត់ដកហូតដើមឈើ និងកាត់ក្រឹមកឈើចំនួន ០៩ដើម នៅបរិវេណប្រាសាទព្រះខ័ន។

-កាត់ដកហូតដើមឈើ និងកាត់ក្រឹមកឈើចំនួន ១០ដើម នៅបរិវេណប៉ុស្តិ៍នគរបាលការពារបេតិកភ័ណ្ឌខ្លោងទ្វារទន្លេអុំ និងនៅតាមជើងកំពែងអង្គរធំទិសខាងត្បូង។

-កាត់ដកហូតដើមឈើ និងកាត់ក្រឹមកឈើចំនួន០៧ដើម នៅក្នុងបរិវេណខ្លោងទ្វារជីស្នាំង។

-កាត់ដកហូតដើមឈើ និងកាត់ក្រឹមកឈើចំនួន ២១ដើម នៅបរិវេណមុខប្រាសាទអង្គរវត្តទិសខាងលិចឆៀងខាងត្បូង។

ការងារនេះ នឹងចាប់ផ្តើមអនុវត្តចាប់ពីថ្ងៃទី០៧ ខែ វិច្ឆិកា ឆ្នាំ២០១៨ រហូតដល់បញ្ចប់ការងារ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមស្ថាប័ន សមត្ថកិច្ចពាក់ព័ន្ធ ភ្ញៀវជាតិ-អន្តរជាតិ មគ្គុទ្ទេសក៍ទេសចរណ៍ ព្រមទាំងសាធារណជនទាំងអស់ មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃ ៤ ក្រ ០៥ ខែ អាស្វុជ ឆ្នាំច សំរឹទ្ធិស័កព.ស២៥៦២
សៀមរាប ថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ២០១៨
អគ្គនាយក

ហង់ ពៅ

ចម្លងជូន៖
-សាលាខេត្តសៀមរាប
-មន្ទីរបរិស្ថានខេត្តសៀមរាប
-មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តសៀមរាប
-អង្គភាពនគរបាលការពារបេតិកភណ្ឌប្រចាំខេត្តសៀមរាប
-ស្នាក់ការតំបន់ការពារទេសភាពអង្គរ
-សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ទាំងអស់ប្រចាំខេត្តសៀមរាប
-ដើម្បីជូនជ្រាប និងសហការ-
-ប៉ូលីសទេសចរណ៍
-គ្រប់នាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធរបស់អាជ្ញាធរអប្សរា
-ដើម្បីមុខការ និងសហការ-
-ឯកសារ-កាលប្បវត្តិ

លេខទូរស័ព្ទទំនាក់ទំនង៖លោក ឆង់ សុវណ្ណារិទ្ធ 012-354-630, លោក ទៀន សុធី 010-304-089,088-9522-5059,លោក ឃែ ហ៊ីត 086 600 740

ភ្នំពេញ៖ មហាវិថីសហព័ន្ធរុស្សី លេខ៨១ សង្កាត់ទឹកថ្លា ខណ្ឌឫស្សីកែវ ទូរសព្ទ/ទូរសារ ០២៣ ២១៥ ៧៧១/០២៣ ២១៥ ៧៧៦
អាជ្ញាធរដើម្បីការពារអចលនវត្ថុនិងរៀបចំតំបន់អង្គរ Email: info@apsaraauthority.gov.kh Website: http//www.apsaraauthority.gov.kh
សៀមរាប៖ ភូមិបន្ទាយ ឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប ទូរសព្ទ/ទូរសារ ០៦៣ ៧៦៥ ៥៧៧/០៦៣ ៧៦៥ ៥៧៦

អាជ្ញាធរជាតិអប្សរាលើកកម្ពស់តម្លៃបេតិកភណ្ឌនិងដំរុញការអានជំរុញការអានជំរុញការអានជ

សេចក្តីជូនដំណឹងស្តីពី ការរៀបចំទិវាជំងឺទឹកនោមផ្អែមពិភពលោកឆ្នាំ២០១៨ នៅបរិវេណទីលាន Parvis ប្រាសាទបន្ទាយស្រី

ផ្សាយនៅថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០១៨



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA
លេខ.២០៥/បេ.សជ/១៨

សេចក្តីជូនដំណឹង
ស្តីពី
ការរៀបចំទិវាជំងឺទឹកនោមផ្អែមពិភពលោកឆ្នាំ២០១៨
នៅបរិវេណទីលាន Parvis ប្រាសាទបន្ទាយស្រី

អាជ្ញាធរជាតិអប្សរាមានកិត្តិយសសូមជម្រាបជូនដំណឹងដល់គ្រប់ក្រសួង មន្ទីរ-អង្គភាព ស្ថាប័នជាតិ-អន្តរជាតិ សមាគមទីភ្នាក់ងារទេសចរណ៍ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ មគ្គុទ្ទេសក៍ទេសចរណ៍ ក្រុមហ៊ុនទេសចរណ៍ ភ្ញៀវទេសចរជាតិ-អន្តរជាតិ និងសាធារណជនទាំងអស់ឱ្យបានជ្រាបថា អាជ្ញាធរជាតិអប្សរាបានឯកភាព និងអនុញ្ញាតជូនសមាគមជំងឺទឹកនោមផ្អែមកម្ពុជា សាខាខេត្តសៀមរាប រៀបចំទិវាជំងឺទឹកនោមផ្អែមពិភពលោកឆ្នាំ២០១៨ នៅបរិវេណទីលាន Parvis ប្រាសាទបន្ទាយស្រី នៅថ្ងៃអាទិត្យ ៨កើត ខែកត្តិក ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២ ត្រូវនឹងថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ចាប់ពីម៉ោង ០៧ ៖ ៣០នាទីព្រឹក ដល់ម៉ោង ០៣ ៖ ៣០នាទីរសៀល។

អាស្រ័យហេតុនេះ សូមឯកឧត្តម លោកជំទាវ អស់លោក លោកស្រី គ្រប់ក្រសួង មន្ទីរ-អង្គភាព ស្ថាប័នជាតិ-អន្តរជាតិ សមាគមទីភ្នាក់ងារទេសចរណ៍ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ មគ្គុទ្ទេសក៍ទេសចរណ៍ ក្រុមហ៊ុនទេសចរណ៍ ភ្ញៀវទេសចរជាតិ-អន្តរជាតិ និងសាធារណជនទាំងអស់ មេត្តាជ្រាប និងជួយផ្សព្វផ្សាយ។

ថ្ងៃ ទួ ១២ ៗ ៣៤ ខែ មិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
សៀមរាប ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១៨

អគ្គនាយក

ហាច់ ពៅ

ចម្លងជូន:
-សាលាខេត្តសៀមរាប
-ស្នងការដ្ឋាននគរបាលខេត្តសៀមរាប
-គ្រប់មន្ទីរជុំវិញខេត្តសៀមរាប
-អង្គភាពនគរបាលការពារបេតិកភណ្ឌ ប្រចាំខេត្តសៀមរាប
-អង្គភាពនគរបាលទេសចរណ៍ ប្រចាំខេត្តសៀមរាប
-សមាគមទីភ្នាក់ងារទេសចរណ៍-សមាគមសណ្ឋាគារ
-សមាគមមគ្គុទ្ទេសក៍ទេសចរណ៍-មគ្គុទ្ទេសក៍ទេសចរណ៍
-សមាគមអ្នកបើកបររថយន្តដឹកជញ្ជូនភ្ញៀវទេសចរ
-ក្រុមហ៊ុនសុខា អូតែល
-ផ់សមាគមជំងឺទឹកនោមផ្អែមកម្ពុជា
-ឯកសារ-កាលប្បវត្តិ

ទំនាក់ទំនង: ... Email: info@apsaraauthority.gov Website: http//www.apsaraauthority.gov.kh ... សៀមរាប ...

អាជ្ញាធរជាតិអប្សរាដាំកូនឈើជំនួសដើមចាស់ដើម្បីរក្សាទេសភាពវប្បធម៌ក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០១៨

នៅព្រឹកថ្ងៃទី៦ វិច្ឆិកា ឆ្នាំ ២០១៨ អាជ្ញាធរជាតិអប្សរាតាមរយៈនាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាន បានធ្វើការដាំកូនឈើនៅមុខប្រាសាទអង្គរវត្ត ដើម្បីជំនួសដើមឈើចាស់ដែលបានដួលរំលំកាលពីខែតុលា កន្លងទៅ។ គោលបំណងនៃការដាំនេះ គឺដើម្បីថែរក្សាទេសភាពវប្បធម៌ក្នុងរមណីដ្ឋានអង្គរ កុំឱ្យបាត់បង់។

អគ្គនាយករងអាជ្ញាធរជាតិអប្សរា **ឯកឧត្តម ហង់ ពៅ** ដែលបានចូលរួមដាំកូនឈើជំនួសនៅពេលនោះបានឱ្យដឹងថា ជាគោលការណ៍របស់អាជ្ញាធរជាតិអប្សរា គឺថែរក្សាទេសភាពវប្បធម៌នៅតំបន់អង្គរធ្វើយ៉ាងណាឱ្យនៅដដែលដូចពេលកន្លងមក។ ឯកឧត្តមបន្តថា កន្លងមកអាជ្ញាធរជាតិអប្សរាបានធ្វើការងារជាច្រើនទាក់ទងនឹងបញ្ហានេះ ដូចជាការព្យាបាលដើមឈើដែលមានវ័យចំណាស់ បំណងចង់ឱ្យដើមឈើទាំងនោះមានអាយុរស់នៅតទៅមុខទៀត ដើម្បីរក្សាទេសភាពវប្បធម៌នៅតំបន់នោះ។

សម្រាប់ដើមឈើដែលដាំជំនួសនៅជ្រុងខាងជើងនៃកសិន្ទុអង្គរវត្តនៅពេលនេះ គឺជាប្រភេទឈើយាង ជំនួសឈើយាងចាស់ ដែលបានដួលរំលំក្នុងអំឡុងខែតុលាកន្លងទៅ។ ហើយឈើដែលដាំនេះ ជាដើមឈើធំមានអាយុខ្ពង់ ១៥ឆ្នាំហើយ។ ត្រង់ចំណុចនេះ **ឯកឧត្តម ហង់ ពៅ** ពន្យល់ថា គេចាំបាច់យកដើមឈើដែលធំស្រាប់មកដាំ ដើម្បីឱ្យប្រហាក់ប្រហែលទៅនឹងដើមឈើមុនដែលបានបាត់បង់ទៅ។

តាមការពន្យល់របស់ **ឯកឧត្តម ហង់ ពៅ** ទេសភាពវប្បធម៌ក្នុងរមណីយដ្ឋានអង្គរ គឺទាក់ទងនឹងកត្តាពីរ គឺដើមឈើនិងទឹក។ ក្នុងការងារនេះអាជ្ញាធរជាតិអប្សរា បានធ្វើការងាររាប់ដូចជាការធ្វើឱ្យទឹកច្រើនឡើងវិញនៅតាមកសិន្ទុ ការរក្សាដើមឈើចាស់ និងដាំឡើងវិញក្នុងរមណីយដ្ឋានអង្គរ។ ក្នុងនោះដែរ តាមការបញ្ជាក់របស់**ឯកឧត្តម ហង់ ពៅ** ព្រៃឈើរមណីយដ្ឋានអង្គរមានឈើសរុបចំនួន ១៨៣ប្រភេទ ហើយប្រភេទឈើទាំងនោះត្រូវបានអាជ្ញាធរជាតិអប្សរា ធ្វើការបណ្តុះ និងចែកចាយដល់ពលរដ្ឋទាំងក្នុង និងក្រៅខេត្ត យកទៅដាំផងដែរ៕









អាជ្ញាធរជាតិអប្សរាបើកវគ្គបណ្តុះបណ្តាលពីការប្រើប្រាស់គេហទំព័រអាយស៊ីស៊ី-អង្គរ

ផ្សាយនៅថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០១៨

អាជ្ញាធរជាតិអប្សរា សហការជាមួយអង្គការយូណេស្កូ បើកវគ្គបណ្តុះបណ្តាលស្តីពីការប្រើប្រាស់គេហទំព័រ អាយស៊ីស៊ី-អង្គរ (ICC-Angkor) កាលពីថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ដោយមានការចូលរួមពីមន្ត្រីគ្រប់នាយកដ្ឋាននៃអាជ្ញាធរជាតិអប្សរា អង្គការយូណេស្កូ អាជ្ញាធរព្រះវិហារ និងអាជ្ញាធរសំបូរព្រៃគុក ប្រមាណជា៤០នាក់។

វគ្គបណ្តុះបណ្តាលនេះបង្រៀនដោយអ្នកជំនាញមកពីអង្គការយូណេស្កូ និងអ្នកជំនាញនៃអាជ្ញាធរជាតិអប្សរា ក្នុងបំណងឱ្យមន្ត្រីបុគ្គលិកនៃស្ថាប័នទាំងអស់ អាចស្វែងរកព័ត៌មានលម្អិតប្រកបដោយប្រសិទ្ធិភាពអំពីកិច្ចការអភិរក្ស ការជួសជុលប្រាសាទនៅក្នុងតំបន់រមណីយដ្ឋានអង្គរ ដោយស្ថាប័នជាតិ និងអន្តរជាតិ រួមទាំងរបាយការណ៍ទាំងស្រុងនៃកិច្ចប្រជុំអាយស៊ីស៊ី-អង្គរ គ្រប់ឆ្នាំទាំងអស់។

វគ្គសិក្សានេះ ក៏នឹងផ្តល់ជាគំនិតមួយធំសម្រាប់អាជ្ញាធរជាតិព្រះវិហារនិងសំបូរព្រៃគុកដែរ ក្នុងការរៀបចំគេហទំព័រផ្តល់ព័ត៌មានពីសកម្មភាពនៃកិច្ចការអភិរក្ស ការជួសជុលនៅក្នុងតំបន់របស់ខ្លួន៕









ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរាចូលរួមកោរពវិញ្ញាណក្ខន្ធវីរៈយុទ្ធជន និងរំលឹកខួបអនុស្សាវរីយ៍លើកទី៦៥ ទិវាបុណ្យឯករាជ្យជាតិ

ផ្សាយនៅថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១៨

នៅព្រឹកថ្ងៃទី៩ វិច្ឆិកា នេះ ថ្នាក់ដឹកនាំនៃអាជ្ញាធរជាតិអប្សរា បានចូលរួមក្នុងពិធីគោរពវិញ្ញាណក្ខន្ធវីរៈយុទ្ធជន និងរំលឹកខួបអនុស្សាវរីយ៍លើកទី៦៥ ទិវាបុណ្យឯករាជ្យជាតិ និងថ្ងៃបង្កើតកងយោធពលខេមរភូមិន្ទ ៩ វិច្ឆិកា ១៩៥៣ - ៩ វិច្ឆិកា ២០១៨ ដែលពិធីនេះធ្វើឡើងនៅវិមានរំលឹកគុណ អតីតវីរៈយុទ្ធជន ខេត្តសៀមរាប។

ពិធីនេះមានការចូលរួមពីមន្ត្រីរាជការ កងកម្លាំងគ្រប់លំដាប់ថ្នាក់ ក៏ដូចជាសិស្សានុសិស្ស ដើម្បីដាក់កម្រងផ្កាគោរពវិញ្ញាណក្ខន្ធយុទ្ធជន យុទ្ធនារី និងវីរបុរសអ្នកស្នេហាជាតិដែលបានពលីជីវិតដ៏ថ្លៃថ្លាសម្រាប់បុព្វហេតុមាតុភូមិ និងប្រជាជន។ ជាមួយគ្នានេះដែរ ទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា គឺជាការរំលឹកដល់ពលរដ្ឋកម្ពុជា ជាពិសេសយុវជនយុវនារីជំនាន់ក្រោយ ឱ្យបានយល់ដឹងអំពីព្រះរាជបេសកកម្មដើម្បីជាតិមាតុភូមិ និងប្រជារាស្ត្រខ្មែររបស់ព្រះករុណាព្រះបាទសម្តេច ព្រះនរោត្តម សីហនុ ព្រះបិតាឯករាជ្យជាតិ ព្រះបរមរតនកោដ្ឋ ដែលព្រះអង្គបានលះបង់ព្រះកាយពល និងព្រះបញ្ញាញាណយ៉ាងក្លៀវក្លាបំផុត តស៊ូរំដោះជាតិទាមទារឯករាជ្យពីនឹមអាណានិគមនិយមបារាំង ដោយជោគជ័យទាំងស្រុង នៅថ្ងៃទី ៩ វិច្ឆិកា ឆ្នាំ ១៩៥៣៕









អាជ្ញាធរជាតិអប្សរាបណ្តុះកំដិតឱ្យកុមារស្វែងយល់ពីប្រវត្តិនិងការអភិរក្សបុរាណដ្ឋាន ដើម្បីឱ្យពួកគេចេះស្រឡាញ់និងចូលរួមការពារ

ផ្សាយនៅថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១៨

សាលាបឋមសិក្សាបន្ទាយសំរែ ជាសាលាគោលដៅទី២នៃកម្មវិធីអប់រំបេតិកភណ្ឌក្នុងតំបន់អង្គរ ដែលរៀបចំឡើងនាថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ២០១៨ ដោយអាជ្ញាធរជាតិអប្សរា ក្នុងបំណងចូលរួមចំណែកជាមួយវិស័យអប់រំបញ្ចៀបចំណេះដឹងផ្នែកបេតិកភណ្ឌ បរិស្ថាន និងបំនិននៃការអានដល់កុមារដែលរស់នៅក្នុងតំបន់អង្គរ។

កម្មវិធីនេះចែករំលែកចំណេះដឹងដោយអ្នកជំនាញបុរាណវិទ្យានៃអាជ្ញាធរជាតិអប្សរាទាំងផ្នែកប្រវត្តិសាស្ត្រ វប្បធម៌ប្រពៃណីជំនឿ សាសនា បរិស្ថាន និងតួនាទីរបស់កុមារក្នុងការរួមចំណែកថែរក្សានិងស្គាល់ពីកេរតំណែលដែលមានក្នុងតំបន់ខ្លួនរស់នៅ។

លោក ខៀវ ច័ន្ទ មន្ត្រីជំនាញបុរាណវិទ្យានៃមជ្ឈមណ្ឌលអន្តរជាតិស្រាវជ្រាវនិងតម្កល់ឯកសារអង្គរ និង;វាគ្មិននៃកម្មវិធី បានឱ្យដឹងថា មនុស្សគ្រប់ជាតិសាសន៍ត្រូវស្គាល់ពីមរតករបស់ប្រទេសខ្លួន ថាមានកេរអាករអ្វីខ្លះ មានបេតិកភណ្ឌអ្វីខ្លះជារបស់ផ្ទាល់ខ្លួននិងសម្រាប់ជាតិខ្លួន។ ដូច្នេះ ការបណ្តុះឱ្យកុមារស្គាល់ពីប្រវត្តិសាស្ត្រ ពីមរតកដែលខ្លួនមាន ធ្វើឱ្យពួកគេចេះស្រឡាញ់ យល់ពីតម្លៃ និងចូលរួមការពារ។ ជាក់ស្តែងនៅតាមបណ្តាប្រទេសជិតខាងនិងប្រទេសជឿនលឿន ក្នុងប្រព័ន្ធអប់រំគេបានបញ្ចូលមេរៀននេះឱ្យកុមារស្គាល់ពីតូចៗ ហើយគេធ្វើយូរហើយដែរ តែប្រទេសយើងមិនទាន់បានធ្វើពេញដៃជើងនៅឡើយ។

លោកបន្តថា ពេលអង្គរចូលជាបេតិកភណ្ឌពិភពលោក អង្គការយូណេស្កូក៏បានជំរុញឱ្យអាជ្ញាធរជាតិអប្សរាគិតគូរពីរឿងអប់រំបេតិកភណ្ឌដល់សិស្សក្នុងតំបន់ឱ្យស្គាល់ពីមរតកដែលខ្លួនមានផងដែរ។ ដូច្នេះហើយ ជាជំហានដំបូងនាឆ្នាំ២០០៩ អាជ្ញាធរជាតិអប្សរាបានចាប់ផ្តើមបោះពុម្ពសៀវភៅគំនូរអំពីចម្លាក់បេតិកភណ្ឌ សហការជាមួយមន្ទីរអប់រំយុវជនកីឡាខេត្តសៀមរាបនិងអង្គការសហព័ន្ធជាតិយូណេស្កូប្រទេសជប៉ុនបាន២ភាគ ព្រមទាំងចុះបង្រៀនដល់ក្មេងៗឱ្យស្គាល់ពីបេតិកភណ្ឌដោយមានគម្រោងសហការជាមួយប្រទេសញូវហ្សេឡែន និងសហគមន៍ខ្មែរនៅកាណាដា។ បច្ចុប្បន្នអាជ្ញាធរជាតិអប្សរា ក៏កំពុងធ្វើសៀវភៅបេតិកភណ្ឌភាគទី៣ ដែលមានកម្រិតខ្ពស់ជាងមុនឱ្យសិស្សស្គាល់ពីអ្វីទៅជាអង្គរ និងអនុវត្តកម្មវិធីអប់រំបេតិកភណ្ឌសហការជាមួយអង្គការគាំពារកេរមរតកដល់សិស្សនៅអនុវិទ្យាល័យស្រះស្រង់ ដើម្បីបង្ហិតសិស្សកម្ពុជាកុំឱ្យមានគំលាត អំពីការយល់ដឹងពីបេតិកភណ្ឌខ្លួនឆ្ងាយពីបរទេសពេក។

លោក រីក រេត មន្ត្រីជំនាញអភិរក្សនៃនាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរនិងបុរាណវិទ្យាបង្គារ បានលើកឡើងថា ការបញ្ចៀបចំណេះដឹងផ្នែកអភិរក្សបុរាណដ្ឋានដល់កុមារ ជាគោលបំណងរបស់អ្នកអភិរក្ស ដែលចង់ឱ្យក្មេងៗបានយល់ដឹងពីរបៀបថែទាំ បច្ចេកទេសជួសជុល ស្គាល់សម្ភារៈត្រូវប្រើ និងការការពារកេរមរតកដូនតាទាំងនោះឱ្យបានគង់វង្សតពីមនុស្សចាស់នាថ្ងៃអនាគត។ លោកចង់ឱ្យខ្មែរគ្រប់រូបចូលរួមថែរក្សាទាំងអស់គ្នាមិនថាកុមារ យុវវ័យ មនុស្សចាស់ រួមទាំងអ្នកអាស្រ័យផលក្នុងតំបន់អង្គរផងដែរ។

អ្នកស្រី កាន កែម នាយិការងនៃសាលាបឋមសិក្សាបន្ទាយសំរែ បានថ្លែងអំណរគុណដល់អាជ្ញាធរជាតិអប្សរដែលបានបង្កើតកម្មវិធីនេះឡើង ដែលជាប្រយោជន៍ដល់សិស្សានុសិស្ស ឱ្យពួកគេបានដឹងនិងស្គាល់ពីបេតិកភណ្ឌនៅកន្លែងដែលពួកគេរស់នៅ។ ពិសេសអាចប្រតិបត្តិខ្លួនបានល្អក្នុងការរួមចំណែកថែរក្សា ការពារពេលពួកគេទៅលេងតាមប្រាសាទផង។ កន្លងមកកម្មវិធីបែបនេះមិនមានទេ តែសាលាធ្លាប់ធ្វើម្តងកាលពេលលោកគ្រូអ្នកគ្រូធ្វើតែងសេចក្តីអំពីប្រាសាទ ហើយនាំសិស្សទៅសង្កេតដល់បុរាណដ្ឋានផ្ទាល់។ បើមានកម្មវិធីបែបនេះច្រើន សិស្សានុសិស្សនឹងបានស្វែងយល់ដឹងច្រើនពីតំបន់បេតិកភណ្ឌដែលខ្លួនរស់នៅ៕









អាជ្ញាធរជាតិអប្សរាបើកកិច្ចប្រជុំសវនកម្មផ្ទៃក្នុងប្រព័ន្ធគ្រប់គ្រងបរិស្ថាន-អង្គរ ISO-14001:2015

ផ្សាយនៅថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១៨

នៅព្រឹកថ្ងៃទី១២ វិច្ឆិកា ឆ្នាំ២០១៨ អង្គភាពប្រព័ន្ធគ្រប់គ្រងបរិស្ថាន-អង្គរនៃអាជ្ញាធរជាតិអប្សរា បានបើកកិច្ចប្រជុំសវនកម្មផ្ទៃក្នុងគ្រប់នាយកដ្ឋាន និងអង្គភាពចំណុះ ដើម្បីគូសបញ្ជាក់អំពីបញ្ហា រួមទាំងចំណុចគួរកែតម្រូវទាំងឡាយលើបញ្ហាដែលមាន ឱ្យសម្រេចជោគជ័យក្នុងការធ្វើសវនកម្មទទួលវិញ្ញាបនបត្រ ISO-14001:2015។

កិច្ចប្រជុំនេះប្រព្រឹត្តទៅក្រោមអធិបតីភាព **ឯកឧត្តម សុខ លក្ខិណា** ទីប្រឹក្សាអាជ្ញាធរជាតិអប្សរានិងជាប្រធានអង្គភាពប្រព័ន្ធគ្រប់គ្រងប្រព័ន្ធបរិស្ថាន-អង្គរ តំណាង **ឯកឧត្តមបណ្ឌិត ស៊ុំ ម៉ាប់** អគ្គនាយកអាជ្ញាធរជាតិអប្សរា រួមទាំងថ្នាក់ដឹកនាំគ្រប់នាយកដ្ឋាន និងអ្នកជំនាញការងារបរិស្ថានគ្រប់នាយកដ្ឋានពាក់ព័ន្ធនានាចូលរួម។

សវនកម្មផ្ទៃក្នុងលើប្រព័ន្ធគ្រប់គ្រងបរិស្ថាន-អង្គរ ធ្វើឡើងដើម្បីប្រសិទ្ធភាព ផ្តោតលើលទ្ធផលសម្រេចបានតាមគោលនយោបាយ និងគោលបំណងបរិស្ថាន។ ស្ថានភាពនៃការគោរពច្បាប់បញ្ញត្តិទាក់ទងបរិស្ថាន ឆ្លើយតបទៅនឹងការប្រាស្រ័យទាក់ទងជាមួយភាគីផ្ទៃក្រៅ ស្ថានភាពនៃការកែតម្រូវ និងការបង្ការភាពមិនអនុលោម កែលម្អការសម្តែងបរិស្ថានទាំងមូល។ **លោក អ៊ុន មុន្នីនីតា** ប្រធានសវនករនៃអង្គភាពប្រព័ន្ធគ្រប់គ្រងបរិស្ថាន-អង្គរ បានលើកឡើងថា ការវាយតម្លៃតាមរយៈសវនកម្ម គឺធ្វើឡើង១ឆ្នាំម្តង ដោយអនុលោមតាមស្តង់ដារ ISO-14001 ដែលអាជ្ញាធរជាតិអប្សរាទទួលបានតាមរយៈស្ថាប័នធានាគុណភាពជប៉ុន Japan Quality Assurance (JQA)។ លោកបន្តថា បើកសវនកម្មនៅពេលនេះដើម្បីសិក្សាចំណុចជោគជ័យ និងចំណុចខ្វះខាត ដើម្បីបំពេញចន្លោះខ្វះខាតទាំងនោះទៅឆ្នាំក្រោយ។

ថ្លែងបើកក្នុងអង្គប្រជុំ **ឯកឧត្តម សុខ លក្ខិណា** មានប្រសាសន៍ថា ការប្រជុំសវនកម្មលើកនេះខុសប្លែកពីរាល់ដងដែលស្ថាប័ន JQA បានផ្តល់មួយទៀត គឺចំណុចប្រសើរ បន្ថែមលើភាពមិនអនុលោម និងចំណុចតាមអង្កេត។ ឯកឧត្តមបន្តថា ការជោគជ័យដ៏ធំធេងមួយទៀតពីការវាតតម្លៃដែលបានបង្ហាញថា តំបន់អង្គរជារមណីយដ្ឋានមានបរិស្ថានល្អ និងជាគោលដៅទេសចរណ៍ទី១លើពិភពលោក។









លោកជំទាវ ភឿង សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងជាប្រធានអាជ្ញាធរជាតិអប្សរា អញ្ជើញទស្សនកិច្ចផ្លាស់ប្តូរបទពិសោធន៍ការគ្រប់គ្រងរមណីយដ្ឋាន Paestum នៅប្រទេសអ៊ីតាលី

ផ្សាយនៅថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨

ក្នុងដំណើរទស្សនកិច្ចផ្លូវការចូលរួមកិច្ចប្រជុំផ្លាស់ប្តូរបទពិសោធន៍អំពីបេតិកភណ្ឌនិងទេសចរណ៍នៃតំបន់មេឌីទែរ៉ាណេនិងអឺរ៉ុប នាប្រទេសអ៊ីតាលី នៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៨ **លោកជំទាវ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងជាប្រធានអាជ្ញាធរជាតិអប្សរា បានអញ្ជើញទៅទស្សនកិច្ចផ្លាស់ប្តូរបទពិសោធន៍ការគ្រប់គ្រងរមណីយដ្ឋាន Paestum ជាតំបន់ទេសចរណ៍ដ៏ល្បីល្បាញផ្នែកបេតិកភណ្ឌវប្បធម៌នៅប្រទេសអ៊ីតាលី។ ការចែករំលែកបទពិសោធន៍លើការគ្រប់គ្រង ការរក្សាបាននូវតុល្យភាពរវាងកិច្ចការអភិរក្សនិងអភិវឌ្ឍន៍ដោយចីរភាព គឺជាប្រធានបទសំខាន់ៗក្នុងការផ្លាស់ប្តូរយោបល់រវាងប្រតិភូដែលដឹកនាំដោយ **លោកជំទាវ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងជាប្រធានអាជ្ញាធរជាតិអប្សរា និងថ្នាក់ដឹកនាំនៃរមណីយដ្ឋាន Paestum។

សូមបញ្ជាក់ថា រមណីយដ្ឋាន Paestum បញ្ចូលជាក្នុងបេតិកភណ្ឌពិភពលោកនាឆ្នាំ១៩៩៨ បានកសាងភាពល្បីល្បាញនិងទាក់ទាញភ្ញៀវទេសចរដោយផ្អែកទៅលើការងារអភិរក្សនិងការថែរក្សាទេសភាពវប្បធម៌យ៉ាងខ្ជាប់ខ្ជួនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ បច្ចុប្បន្នភ្ញៀវទេសចរប្រម៉ាណជាង៤លាននាក់បានទៅទស្សនានៅទីនោះ និងថែមទាំងបានចូលរួមអភិវឌ្ឍន៍សេដ្ឋកិច្ចក្នុងតំបន់យ៉ាងសកម្ម។

បន្ទាប់ពីនេះ ប្រតិភូក៏បានអញ្ជើញទៅទស្សនាសារមន្ទីនិងកន្លែងសិប្បកម្មប្រពៃណី។ នៅក្នុងសារមន្ទីមានតាំងបង្ហាញនូវវត្ថុសិល្បៈបុរាណដែលរកឃើញតាមរយៈកំណាយបុរាណវិទ្យាក្នុងរមណីយដ្ឋាន Paestum ដែលរំលេចអំពីប្រវត្តិសាស្ត្រនិងតម្លៃរបស់រមណីយដ្ឋាននេះ។ រីឯនៅកន្លែងសិប្បកម្មប្រពៃណីមានតាំងបង្ហាញវត្ថុសិប្បកម្មជាច្រើន ជាពិសេសបង្ហាញពីការផលិតភាជន៍ ការកាត់ដេរសម្លៀកបំពាក់និងស្បែកជើង ការឆ្លាក់ពណ៌លើឥដ្ឋការ៉ូ ការផលិតអាវុធនិងឧបករណ៍ការពារខ្លួននាសម័យបុរាណជាច្រើន ដែលរំលេចអំពីការថែរក្សាទំនៀមទម្លាប់ប្រពៃណីនិងអត្តសញ្ញាណតំបន់នេះពីបុរាណរហូតមកដល់បច្ចុប្បន្ន៕






លោកជំទាវ ភឿង សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងជាប្រធានអាជ្ញាធរជាតិអប្សរា ចូលរួមជាភ្ញៀវកិត្តិយសក្នុងកិច្ចប្រជុំផ្លាស់ប្តូរបទពិសោធន៍អំពីបេតិកភណ្ឌ និងទេសចរណ៍នៃតំបន់មេឌីទែរ៉ាណេនិងអឺរ៉ុប

ផ្សាយនៅថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨

លោកជំទាវ ភឿង សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាប្រធានអាជ្ញាធរជាតិអប្សរា បានដឹកនាំប្រតិភូចូលរួមជាភ្ញៀវកិត្តិយសក្នុងកិច្ចប្រជុំផ្លាស់ប្តូរបទពិសោធន៍អំពីបេតិកភណ្ឌ និងទេសចរណ៍នៃតំបន់មេឌីទែរ៉ាណេនិងអឺរ៉ុប នាប្រទេសអ៊ីតាលីចាប់ពីថ្ងៃទី១៥ រហូតដល់ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៨។ ដើម្បីអបអរសាទរឆ្នាំ២០១៨ អឺរ៉ុបដើម្បីវប្បធម៌ និងឆ្នាំ២០១៨ជាឆ្នាំម្ហូបអាហារអឺតាលី កម្មវិធីនេះជាកិច្ចប្រជុំលក្ខណៈអន្តរជាតិដើម្បីផ្លាស់ប្តូរបទពិសោធន៍រវាងប្រទេសក្នុងតំបន់មេឌីទែរ៉ាណេ ប្រទេសក្នុងតំបន់អឺរ៉ុប និងបណ្តាប្រទេសផ្សេងទៀតសរុបចំនួន៤៨ប្រទេស ដែលរួមមានការជួបប្រជុំពិភាក្សារវាងអ្នកជំនាញដោយផ្តោតលើការរៀបចំឯកសារបេតិកភណ្ឌ ការផ្លាស់ប្តូរបទពិសោធន៍ផ្នែកបុរាណវិទ្យា ការផ្សព្វផ្សាយអំពីបច្ចេកទេសនិងបច្ចេកវិទ្យាថ្មីៗដោយសាកលវិទ្យាល័យ អ្នកប្រតិបត្តិករផ្នែកបេតិកភណ្ឌ និងទេសចរណ៍ពីបណ្តាប្រទេសចំនួន៣០ប្រទេស និងអ្នកចូលទស្សនាប្រមាណ១ម៉ឺននាក់ ។

ក្នុងនាមជាភ្ញៀវកិត្តិយស **លោកជំទាវ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាប្រធានអាជ្ញាធរជាតិអប្សរា បានជួបពិភាក្សាការងារជាមួយអ្នករៀបចំកម្មវិធី និងប្រតិភូនៃបណ្តាប្រទេសផ្សេងៗ ឥស្សរជនសំខាន់ៗមួយចំនួនជាមិត្តរបស់កម្ពុជាគឺ**លោកសាស្ត្រាចារ្យ** Mounir Bouchenaki និង**លោកសាស្ត្រាចារ្យ** Azedine Beschaouch។

ទន្ទឹមនេះដែរ ព្រះរាជាណាចក្រកម្ពុជាក្នុងនាមជាប្រទេសភ្ញៀវកិត្តយសត្រូវបាន អញ្ជើញធ្វើការរៀបចំស្តង់ពិព័រណ៌បង្ហាញដល់អន្តរជាតិ ដើម្បីតាំងបង្ហាញផ្សព្វផ្សាយអំពីរមណីយដ្ឋានបេតិកភណ្ឌពិភពលោកទាំង៣របស់កម្ពុជាគឺ រមណីយដ្ឋានអង្គរ រមណីយដ្ឋានសម្បូរព្រៃគុក និងរមណីយដ្ឋានប្រាសាទព្រះវិហារ។

សូមបញ្ជាក់ថា គោលបំណងនៃកម្មវិធីគឺដើម្បីបង្ហាញអំពីសារៈសំខាន់នៃបេតិកភណ្ឌវប្បធម៌ដែលជាកត្តាជម្រុញដ៏ចម្បងក្នុងការបង្កើតទំនាក់ទំនងរវាងគ្នាទៅវិញទៅមកនៃវប្បធម៌ចម្រុះជាតិសាសន៍ ការច្របាច់រួមបញ្ចូលគ្នាក្នុងសង្គម និងការអភិវឌ្ឍសេដ្ឋកិច្ច ជាពិសេសលើកកម្ពស់កិច្ចសហប្រតិបត្តិការរវាងមនុស្សនិងមនុស្សតាមរយៈការចូលរួម ការផ្លាស់ប្តូរបទពិសោធន៍ និងការផ្សព្វផ្សាយផ្ទាល់ដោយមន្ត្រីនៃប្រទេសកិត្តិយសមួយចំនួនដែលក្នុងនោះ**ឯកឧត្តម ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងជាប្រធានអាជ្ញាធរជាតិអប្សរា បានចូលរួមតំណាងរាជរដ្ឋាភិបាលកម្ពុជា៕









លោកជំទាវ ភឿង សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងជាប្រធានអាជ្ញាធរជាតិអប្សរា ទទួលពានរង្វាន់បុរាណវិទ្យាប៉ាស្ទូមឆ្នាំ២០១៨ (PAESTUM ARCHEOLOGIA) នៅប្រទេសអ៊ីតាលី

ផ្សាយនៅថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១៨

ពានរង្វាន់បុរាណវិទ្យាប៉ាស្ទូមឆ្នាំ២០១៨ (PAESTUM ARCHEOLOGIA) នៃវេទិកាកិច្ចប្រជុំលើកទី២១ដើម្បីផ្លាស់ប្តូរបទពិសោធន៍អំពីបេតិកភណ្ឌនិងទេសចរណ៍នៃតំបន់មេឌីទែរ៉ាណេនិងតំបន់អឺរ៉ុប ត្រូវបានប្រគល់ជូន **លោកជំទាវ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងជាប្រធានអាជ្ញាធរជាតិអប្សរា នៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៨ នាមណីយដ្ឋានពិភពលោកប៉ាស្ទូម (Paestum) ប្រទេសអ៊ីតាលី។

ស្ថិតក្នុងវេទិកាពិសេសនៃកិច្ចប្រជុំលើកទី២១ខាងលើ **លោកសាស្ត្រាចារ្យ** Azedine Beschaouch បុរាណវិទូនិងជាសមាជិកបណ្ឌិតសភាបារាំងខាងសិលាចារឹកនិងអក្សរផ្នែង់ និងជាអតីតប្រធានគណៈកម្មាធិការបេតិកភណ្ឌពិភពលោកចំនួនពីរដង បានធ្វើបទបង្ហាញស្តីពីលក្ខណៈពិសេសនៃមណីយដ្ឋានបេតិកភណ្ឌពិភពលោក ជាពិសេសភាពអស្ចារ្យនិងអច្ឆរិយៈនៃប្រាសាទអង្គរវត្ត និងតំណាងពីស្ថាប័នគ្រប់គ្រងកីឡដ្ឋានColosseumនៃប្រទេសអ៊ីតាលីក៏បានធ្វើបទបង្ហាញស្តីពីប្រវត្តិសាស្ត្រនៃកីឡដ្ឋាននេះផងដែរ។ ជាមួយគ្នានឹងបទបង្ហាញ **លោកជំទាវ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងជាប្រធានអាជ្ញាធរជាតិអប្សរា ក៏បានចូលរួមជាវាគ្មិនគន្លឹះក្នុងការជជែកពិភាក្សា ប្រៀបធៀបជាលក្ខណៈប្រវត្តិសាស្ត្រនិងវិទ្យាសាស្ត្រអំពីរមណីយដ្ឋានពិភពលោកទាំងពីរ។

ជាកិច្ចបន្ត **លោកបណ្ឌិត** Ugo Picarelli ប្រធាននៃវេទិកាកិច្ចប្រជុំលើកទី២១ដើម្បីផ្លាស់ប្តូរបទពិសោធន៍អំពីបេតិកភណ្ឌនិងទេសចរណ៍នៃតំបន់មេឌីទែរ៉ាណេនិងតំបន់អឺរ៉ុប បានប្រគល់ពានរង្វាន់បុរាណវិទ្យាប៉ាស្ទូមឆ្នាំ២០១៨ ជូនដល់ជ័យលាភី **លោកជំទាវ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងជាប្រធានអាជ្ញាធរជាតិអប្សរា។ ជ័យលាភីក្នុងឆ្នាំ២០១៨ មានចំនួន៤រូបក្នុងនោះ២រូបមកពីផ្នែកវប្បធម៌រួមមាន **លោកជំទាវ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងជាប្រធានអាជ្ញាធរជាតិអប្សរា និង **លោកជំទាវ** Irina Bokova អតីតអគ្គនាយិកាអង្គការយូណេស្កូ។ ចំពោះពានរង្វាន់ប្រចាំឆ្នាំនៃវេទិកាកិច្ចប្រជុំដើម្បីផ្លាស់ប្តូរបទពិសោធន៍អំពីបេតិកភណ្ឌនិងទេសចរណ៍នៃតំបន់មេឌីទែរ៉ាណេនិងតំបន់អឺរ៉ុបតែងតែប្រារព្ធឡើងជារៀងរាល់ឆ្នាំចាប់ពីឆ្នាំ២០០៥រហូតដល់បច្ចុប្បន្ន។

ការប្រគល់ពានរង្វាន់នេះគឺជាមហាកិត្តិយសដ៏ឧត្តុងឧត្តមដល់ព្រះរាណាចក្រកម្ពុជា ជាពិសេសការទទួលស្គាល់ជាអន្តរជាតិអំពីភាពអស្ចារ្យនៃរមណីយដ្ឋានអង្គរជាសារមន្ទីរមានជីវិតដែលពោរពេញទៅដោយប្រវត្តិសាស្ត្រ សិល្បៈ និងបុរាណវិទ្យា និងការខិតខំរបស់លោកជំទាវ ភឿង សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងជាប្រធានអាជ្ញាធរជាតិអប្សរា ក្នុងការការពារ ថែរក្សា លើកតម្លៃបេតិកភណ្ឌវប្បធម៌នៃព្រះរាជាណាចក្រកម្ពុជាដូចជា រមណីយដ្ឋានអង្គរ រមណីយដ្ឋានប្រាសាទសំបូរព្រៃគុក និងរមណីយដ្ឋានប្រាសាទព្រះវិហារ៕





កណៈកម្មការចម្រុះដឹកនាំដោយអាជ្ញាធរជាតិអប្សរាប្រជុំពិភាក្សា រកដំណោះស្រាយនៃការរៀបចំសណ្តាប់ធ្នាប់តូបលក់ដូរនៅមុខក្រុមប្រាសាទព្រះពិធូរ

ផ្សាយនៅថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១៨

គណៈកម្មការដឹកនាំ និងសម្របសម្រួលរៀបចំសណ្តាប់ធ្នាប់អ្នកលក់ដូរក្នុងរមណីយដ្ឋានអង្គរ ដែលមានសមាសភាពចម្រុះគ្នារវាងអាជ្ញាធរជាតិអប្សរា សាលាខេត្តសៀមរាប មន្ទីរពាក់ព័ន្ធជុំវិញខេត្ត រួមទាំងអាជ្ញាធរមូលដ្ឋានដែលស្ថិតនៅក្នុងតំបន់រមណីយដ្ឋានអង្គរ បានជួបប្រជុំពិភាក្សាគ្នារកដំណោះស្រាយលើការរៀបចំសណ្តាប់ធ្នាប់តូបលក់ដូរនៅមុខក្រុមប្រាសាទព្រះពិធូរ នាព្រឹកថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ នៅសាលាខេត្តសៀមរាប។

ឯកឧត្តម សុខ សង្ហារ អគ្គនាយករងនៃអាជ្ញាធរជាតិអប្សរា និងជាប្រធានគណៈកម្មការដឹកនាំ និងសម្របសម្រួលរៀបចំសណ្តាប់អ្នកលក់ដូរក្នុងរមណីយដ្ឋានអង្គរបានបញ្ជាក់ក្នុងអង្គប្រជុំថា សណ្តាប់ធ្នាប់នៃតូបលក់ដូរ និងការចតយានជំនិះមុខក្រុមប្រាសាទព្រះពិធូរសព្វថ្ងៃមិនមានសណ្តាប់ធ្នាប់របៀបរៀបរយ ដែលធ្វើឲ្យបិទបាំងប្រាសាទ និងទេសភាពល្អប្រណីតរបស់ប្រាសាទ។ មិនត្រឹមតែប៉ុណ្ណោះ ក្លិនឆ្អេះឆ្អាបនៃការតូបលក់ដូរម្ហូបអាហារ សំឡេងម៉ាស៊ីនភ្លើងជាប្រចាំក៏បានបង្កភាពរំខានដល់ភ្ញៀវទេសចរដែលចូលទៅទស្សនាប្រាសាទផងដែរ។

ឯកឧត្តមបញ្ជាក់ថា ការរៀបចំអង្គប្រជុំនេះឡើង គឺជាការឆ្លើយនឹងអនុសាសន៍ណែនាំរបស់អ្នកជំនាញនៃគណៈកម្មាធិការ ICC-Angkor និងស្ថាប័ន KOICA របស់ប្រទេសកូរ៉េ និងស្ថានទូតកូរ៉េដែលបានទទួលជួយជួសជុលក្រុមប្រាសាទព្រះពិធូរតាមរយៈមូលនិធិបេតិកភណ្ឌវប្បធម៌កូរ៉េ (KCHF) និងបានបញ្ចប់ជំហានរបស់ខ្លួនហើយនៅពេលថ្មីៗនេះ។
ថ្មីៗនេះ អាជ្ញាធរជាតិអប្សរាបានបង្កើតគណៈកម្មការមួយដោយឡែក ដោយផ្តោតសំខាន់លើការសិក្សារកទីតាំងថ្មីសម្រាប់រៀបចំចំណត និងតូបលក់ដូរទាំងនេះ។ ទោះជាយ៉ាងនេះក្តី មន្ត្រីជំនាញនៅតែមិនទាន់សម្រេចបានទីតាំងសមស្របនៅឡើយ ដោយហេតុថា ទីតាំងនៅបរិវេណនោះសុទ្ធតែគ្របដណ្តប់ដោយព្រៃឈើ និងបុរាណដ្ឋានជាច្រើន។ កិច្ចប្រជុំនៅពេលនេះ គឺដើម្បីប្រមូលគំនិតយោបល់បន្ថែមពីគណៈកម្មការ ដើម្បីមន្ត្រីជំនាញបានជាមូលដ្ឋានសម្រាប់យកទៅសិក្សាបន្តទៀត។

លោកឧត្តមសេនីយ៍ទោ ម៉ាន់ ឈឿន អនុប្រធាននាយកដ្ឋានទទួលបន្ទុកអង្គភាពការពារបេតិកភណ្ឌប្រចាំតំបន់អង្គរបញ្ជាក់ថា តូបលក់ដូរក្នុងតំបន់អង្គរពិតជាជួបភាពស្មុគស្មាញខ្លាំងមែន តែក្រុមការងាររៀមខ្លួនជានិច្ច ដើម្បីសហការគ្រប់ពេលវេលា។

គួរឱ្យកថា ព្រះពិធូរ ជាឈ្មោះក្រុមប្រាសាទចំនួន៥ ដែលស្ថិតនៅទល់មុខទីលានស្តេចគម្លង់ក្នុងបរិវេណរាជធានីអង្គរធំគឺ ប្រាសាទកោរសេក់ ប្រាសាទជម ប្រាសាទតាទួត ប្រាសាទដូនមា និងប្រាសាទសណ្តាកយក្ស។ ប៉ុន្តែ មានមនុស្សតិចតួចប៉ុណ្ណោះ ដែលបានស្គាល់ និងបានទៅទស្សនាប្រាសាទទាំងនេះ ដោយសារតែប្រាសាទទាំងនេះបិទបាំងដោយរបាំងព្រៃឈើ និងជាពិសេស គឺតូបលក់ដូរជាច្រើននៅពីមុខផង។






កុមារសាលាបឋមសិក្សាព្រះសាឧចារ្យចាប់អារម្មណ៍ការផ្សព្វផ្សាយការអប់រំបេតិកភណ្ឌក្នុងតំបន់អង្គរ

ផ្សាយនៅថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨

ដើម្បីរួមចំណែកបញ្ជ្រាបចំណេះដឹងអំពីវប្បធម៌ បរិស្ថាន និងការរួមចំណែករបស់កុមារក្នុងការថែរក្សាបុរាណដ្ឋាននៅតំបន់ដែលខ្លួនរស់នៅ អាជ្ញាធរជាតិអប្សរាបានបង្កើតកម្មវិធីអប់រំបេតិកភណ្ឌក្នុងតំបន់អង្គរ ដើម្បីផ្សព្វផ្សាយនៅតាមសាលាមួយចំនួនក្នុងតំបន់អង្គរឱ្យកុមារបានស្គាល់ យល់ដឹង បណ្តុះគំនិតស្រឡាញ់ និងចូលរួមថែរក្សានូវអ្វីដែលមានក្នុងភូមិរបស់ខ្លួនទាំងមរតកវប្បធម៌រូបីនិងអរូបី។

កម្មវិធីនេះមានការចូលរួមពី**លោកឡុង កុសល** ប្រធាននៃនាយកដ្ឋានផ្សព្វផ្សាយ រួមនឹងវាគ្មិន**លោក លឹម ស្រ៊ូ** និង**លោក ខៀវ ច័ន្ទ** អ្នកជំនាញបុរាណវិទ្យានៃអាជ្ញាធរជាតិអប្សរាដើម្បីចែករំលែកចំណេះដឹង ព្រមទាំងយកសៀវភៅពាក់ព័ន្ធនឹងចំណេះដឹងទូទៅ ទំនៀមទម្លាប់ប្រពៃណី ប្រវត្តិសាស្ត្រ បំនិនថ្មីៗរក្សាទុកក្នុងបណ្ណាល័យរបស់សាលា សម្រាប់សិស្សអានបង្កើនចំណេះដឹងនិងកម្សាន្តផង។

ជាក់ស្តែងនៅថ្ងៃទី២០ វិច្ឆិកា ឆ្នាំ២០១៨ ការអនុវត្តកម្មវិធីនៅសាលាបឋមសិក្សាប្រាសាទចារ្យ ដែលស្ថិតនៅភូមិប្រាសាទចារ្យ ឃុំដូនកែវ ស្រុកពួក ខេត្តសៀមរាប សិស្សានុសិស្សបានចាប់អារម្មណ៍យ៉ាងខ្លាំងពីចំណេះដឹងថ្មីមួយនេះ ព្រោះនៅភូមិនេះមាននៅសេសសល់បុរាណដ្ឋាន សំណល់បុរាណវិទ្យា ទំនៀមទម្លាប់ ជំនឿ និងពិធីបុណ្យផ្សេងៗច្រើនជាងបណ្តាភូមិដទៃក្នុងតំបន់អង្គរ។

កុមារី ឃឿត គិន ថ្នាក់ទី៦ក បានឱ្យដឹងថា «ខ្ញុំសប្បាយចិត្តដែលបានចូលរៀនកម្មវិធីនេះ ធ្វើឱ្យខ្ញុំដឹងពីប្រវត្តិភូមិខ្ញុំ និងដឹងថាភូមិខ្ញុំនៅមានមរតកដូនតាសល់ច្រើន។ ពីមុនខ្ញុំមិនដែលបានរៀនពីចំណេះដឹងនេះទេ ក៏មិនដឹងពីប្រវត្តិភូមិ មិនដឹងថានៅភូមិមានអីសំខាន់ តែខ្ញុំធ្លាប់ឃើញប្រាសាទ ធ្លាប់ចូលរួមក្នុងពិធីផ្សេងៗ ថែមទាំងបានរស់នៅជាមួយវា តែខ្ញុំមិនដឹងទេថានោះជាអ្វី មានតម្លៃយ៉ាងណា ហើយគួរថែរក្សាយ៉ាងម៉េច តែក្រោយពេលបានស្តាប់លោកគ្រូហើយ ខ្ញុំដឹងថាប្រាសាទក្នុងភូមិខ្ញុំខ្លះមានអាយុកាលជាង១០០០ឆ្នាំ ខ្លះជាង៩០០ឆ្នាំ ហើយភូមិខ្ញុំក៏កើតយូរមកហើយ ខ្ញុំដឹងពីវិធីងាយៗក្នុងការថែរក្សាមរតកដូនតា។ ខ្ញុំនឹងខំរៀនសូត្រ ដើម្បីឱ្យចេះដឹង ហើយចង់ឱ្យមានកម្មវិធីនេះទៀត»។

កុមារ មួន កាង រៀនថ្នាក់ទី៦កដែរនោះ បានលើកឡើងថា «បន្ទាប់ពីចូលរួមកម្មវិធីអប់រំបេតិកភណ្ឌ ខ្ញុំបានស្គាល់អ្វីទៅមរតករូបីនិងអរូបី ដែលពីមុនធ្លាប់បានឃើញ ចូលរួមផ្ទាល់តែមិនបានយល់ មិនចេះសង្កេត។ នៅភូមិខ្ញុំមានមរតកដូចជាប្រាសាទចារ្យ ប្រាសាទស្រឡៅ ត្រពាំងល្បើក ស្ពានបុរាណដែលសល់ពីដូនតាមក ហើយមានអាយុកាលពាន់ឆ្នាំ។ លើសពីនោះ ខ្ញុំក៏បានចូលរួមពិធីផ្សេងៗដូចជា ឡើងអ្នកតា ឡើងមាយ លៀងមេមត់ កោរជុក បុណ្យភូមិផងដែរ»។ កុមារ កាង បន្តថា ខ្ញុំពិតជារីករាយណាស់ដែលមានកម្មវិធីនេះឡើងនៅសាលារបស់ខ្ញុំ ទោះបីជាមានពេលខ្លីក៏ដោយ តែវាបានផ្តល់ចំណេះដឹងដល់ខ្ញុំនិងសិស្សផ្សេងៗយល់ដឹងពីមរតកដែលពួកខ្ញុំកំពុងរស់នៅជាមួយរាល់ថ្ងៃ៕









សេចក្តីជូនដំណឹងស្តីពី ការកាត់ដកហូតដើមឈើ និងកាត់ក្រឹមកឈើដែលមានហានិភ័យខ្ពស់នៅតាមបរិវេណប្រាសាទ ក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA
លេខ៦២៧/ល.ស.ជ.ស
១៨

សេចក្តីជូនដំណឹង
ស្តីពី
ការកាត់ដកហូតដើមឈើ និងកាត់ក្រឹមកឈើ
ដែលមានហានិភ័យខ្ពស់នៅតាមបរិវេណប្រាសាទ ក្នុងតំបន់រមណីយដ្ឋានអង្គរ

អាជ្ញាធរជាតិអប្សរា សូមជូនដំណឹងដល់ស្ថាប័ន សមត្ថកិច្ចពាក់ព័ន្ធ ភ្ញៀវជាតិ-អន្តរជាតិ មគ្គុទ្ទេសក៍ទេសចរណ៍ ព្រមទាំងសាធារណជនទាំងអស់មេត្តាជ្រាបថា ដើម្បីធានាដល់សុវត្ថិភាពភ្ញៀវទេសចរ សាធារណជន ក៏ដូចជាដើម្បីលើកកម្ពស់សោភ័ណភាពនៅតាមដងផ្លូវ និងនៅតាមបរិវេណប្រាសាទ ក្នុងតំបន់រមណីយដ្ឋានអង្គរ និងតំបន់ដែលគ្រប់គ្រងដោយអាជ្ញាធរជាតិអប្សរា នាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាន នៃអាជ្ញាធរជាតិអប្សរា នឹងកាត់ដកហូតដើមឈើ និងកាត់ក្រឹមកឈើ តាមទីតាំងនានាដូចខាងក្រោម៖

-កាត់ដកហូត និងកាត់ក្រឹមកឈើចំនួន ១៥ដើម នៅក្នុងបរិវេណប្រាសាទបាភួន។
-កាត់ដកហូត និងកាត់ក្រឹមកឈើចំនួន ១៨ដើម នៅក្នុងភូមិនគរក្រៅ។
-កាត់ក្រឹមកដើមផ្លៀក០១ដើម នៅមុខស្នាក់ការតំបន់ការពារទេសភាពអង្គរ។

ការងារនេះ នឹងចាប់ផ្តើមអនុវត្តចាប់ពីថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ២០១៨ រហូតដល់បញ្ចប់ការងារ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមស្ថាប័ន សមត្ថកិច្ចពាក់ព័ន្ធ ភ្ញៀវជាតិ-អន្តរជាតិ មគ្គុទ្ទេសក៍ទេសចរណ៍ ព្រមទាំងសាធារណជនទាំងអស់ មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃ សុក្រ ៩ កើត ខែ កត្តិក ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
សៀមរាប, ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ២០១៨
អគ្គនាយក

ចម្លងជូន៖
-សាលាខេត្តសៀមរាប
-មន្ទីរបរិស្ថានខេត្តសៀមរាប
-មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តសៀមរាប
-អង្គភាពនគរបាលការពារបតិកភណ្ឌប្រចាំខេត្តសៀមរាប
-ស្នាក់ការតំបន់ការពារទេសភាពអង្គរ
-សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ទាំងអស់ប្រចាំខេត្តសៀមរាប
-ដើម្បីជូនជ្រាប និងសហការ-
-ប៉ុស្តិ៍សាទេសចរណ៍
-គ្រប់នាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធរបស់អាជ្ញាធរអប្សរា
-ដើម្បីមូលការ និងសហការ-
-ឯកសារ-កាលប្បវត្តិ

លេខទូរស័ព្ទទំនាក់ទំនង៖លោក គង់ សុវណ្ណារិទ្ធ 012-354-630, លោក ម៉ៀន សុធី 010-304-089,088-9522-5059,លោក ណៃ ហ៊ីត 086 600 740

ភ្ជុំពេញ៖ អាជ្ញាធរជាតិអប្សរា Email: info@apsaraauthority.gov.kh Website: http://www.apsaraauthority.gov.kh
សៀមរាប៖ ភូមិបន្ទាយ ឃុំសំរិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប

សេចក្តីប្រកាសព័ត៌មានស្តីពីការប្រារព្ធពធីខួប២៥ឆ្នាំនៃការបង្កើតគណៈកម្មាធិការអន្តរជាតិដើម្បីសម្របសម្រួលកិច្ចគាំពារ និងអភិវឌ្ឍន៍តំបន់រមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ(អាយស៊ីស៊ី-អង្គរ)

ផ្សាយនៅថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៨



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ជាធរអប្សរា
APSARA

លេខ ១៣២០/ លេ-សបក/២៨

សេចក្តីប្រកាសព័ត៌មាន
ស្តីពី
ការប្រារព្ធពិធីខួប២៥ឆ្នាំនៃការបង្កើតគណៈកម្មាធិការអន្តរជាតិដើម្បីសម្របសម្រួលកិច្ចគាំពារ និងអភិវឌ្ឍន៍តំបន់រមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ (អាយស៊ីស៊ី-អង្គរ)

អាជ្ជាធរជាតិអប្សរា មានកិត្តិយសសូមជម្រាបជូនសាធារណជន ព្រមទាំងអ្នកសារព័ត៌មានជាតិនិងអន្តរជាតិទាំងអស់មេត្តាជ្រាបថា៖ គណៈកម្មាធិការអន្តរជាតិដើម្បីសម្របសម្រួលកិច្ចគាំពារនិងអភិវឌ្ឍន៍តំបន់រមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ (អាយស៊ីស៊ី-អង្គរ) នឹងរៀបចំកិច្ចប្រជុំបច្ចេកទេសលើកទី៣១ និងកិច្ចប្រជុំពេញអង្គលើកទី២៥ នៃអាយស៊ីស៊ី-អង្គរ ព្រមទាំងប្រារព្ធពិធីអបអរសាទរខួប២៥ឆ្នាំ នៃការបង្កើត អាយស៊ីស៊ី-អង្គរ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃអង្គារ-ពុធ ១២-១៣រោច ខែកត្តិក ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី ៤-៥ ខែធ្នូ ឆ្នាំ២០១៨ ។ កិច្ចប្រជុំនឹងបើកជាផ្លូវការក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងបិទជាផ្លូវការក្រោមព្រះរាជាធិបតីភាពដ៏ថ្លៃថ្លាបំផុតរបស់ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។

ដើម្បីអបអរសាទរខួប២៥ឆ្នាំនៃការបង្កើត អាយស៊ីស៊ី-អង្គរ និងផ្សព្វផ្សាយពីសកម្មភាព និងសមិទ្ធផលសំខាន់ៗរបស់អាយស៊ីស៊ី-អង្គរ រយៈពេល២៥ឆ្នាំកន្លងមកនេះ អាជ្ជាធរជាតិអប្សរានឹងរៀបចំការតាំងពិព័រណ៍ជាសាធារណៈ នៅខាងមុខសួនមហាសណ្ឋាគារអង្គរ ចាប់ពីថ្ងៃទី២៨ ខែវិច្ឆិកា ដល់ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៨។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន ព្រមទាំងអ្នកសារព័ត៌មានជាតិ និងអន្តរជាតិទាំងអស់មេត្តាជ្រាបជាព័ត៌មាន និងអញ្ជើញចូលរួមការតាំងពិព័រណ៍ឲ្យបានច្រើនកុះការ។ សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង លោក ឡុង កុសល អ្នកនាំពាក្យអាជ្ជាធរជាតិអប្សរាតាមរយៈលេខទូរស័ព្ទ ០៩២ ៨៩៩ ៩៦៦ ឬលោកជំទាវ ចៅស៊ុន កិរិយា ទីប្រឹក្សាអាជ្ជាធរជាតិអប្សរា និងជាអ្នកសម្របសម្រួលកម្មវិធី តាមរយៈលេខទូរស័ព្ទ ០១៧ ៥៦៩ ០០១។

ថ្ងៃពុធ ៦ ពាល ខែកត្តិក ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
សៀមរាប ថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០១៨
អាជ្ជាធរជាតិអប្សរា

ស៊ុំ ម៉ាប់

ចម្លងជូន៖
- ក្រសួងរៀបចំ និងវិចិត្រសិល្បៈ
- ក្រសួងទេសចរណ៍
- សាលាខេត្តសៀមរាប
- ត្រប់មន្ទីរជុំវិញខេត្ត
- សាលាក្រុងសៀមរាប
- ត្រប់នាយកដ្ឋាន
- អង្គភាពនគរបាលការពារបេតិកភណ្ឌប្រចាំខេត្តសៀមរាប
- អង្គភាពនគរបាលទេសចរណ៍ប្រចាំខេត្តសៀមរាប
- សមាគមទីភ្នាក់ងារទេសចរណ៍-សមាគមសណ្ឋាគារ
- សមាគមមគ្គុទ្ទេសក៍ទេសចរណ៍
- សមាគមម្ចាបើកបររថយន្តដឹកជញ្ជូនភ្ជៀវទេសចរ
- ឯកសារ-កាលប្បវត្តិ

ផ្ទំពេញ:
មហាវិថីសហព័ន្ធស្សឹ លេខ៥១ សង្ឋាត់មិត្តភាព ខណ្ឌឈមកក
ទូរសព្ទ/ទូរសារ៖ ០២៣ ២១៥ ៧៧១/០២៣ ២១៥ ៧៧៦

អាជ្ជាធរធើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ
Email: info@apsaraauthority.gov.kh
Website: http://www.apsaraauthority.gov.kh

សៀមរាប:
ភូមិបង្កោង ឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប
ទូរសព្ទ/ទូរសារ៖ ០៦៣ ៧៦៥ ៥៧៧/០៦៣ ៧៦៥ ៥៧៦

អាជ្ញាធរជាតិអប្សរាតាំងបង្ហាញជាសាធារណៈដើម្បីត្រៀមសម្ពោធការតាំងពិព័រណ៍ផ្លូវការអំពីសកម្មភាពការងារ និងសមិទ្ធផលនានារបស់គណៈកម្មាធិការអន្តរជាតិសម្របសម្រួលការគាំពារ និងអភិវឌ្ឍន៍តំបន់រមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ ហៅកាត់ថា អាយស៊ីស៊ី-អង្គរ

ផ្សាយនៅថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១៨

អាជ្ញាធរជាតិអប្សរា រួមនិងស្ថាប័នដៃគូពាក់ព័ន្ធ បានរៀបចំការតាំងបង្ហាញជាសាធារណៈដើម្បីត្រៀមសម្ពោធការតាំងពិព័រណ៍ផ្លូវការអំពីសកម្មភាពការងារ និងសមិទ្ធផលនានារបស់គណៈកម្មាធិការអន្តរជាតិសម្របសម្រួលការគាំពារ និងអភិវឌ្ឍន៍តំបន់រមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ ហៅកាត់ថា អាយស៊ីស៊ី-អង្គរ។ ការតាំងបង្ហាញនេះធ្វើឡើងរយៈពេល ១៥ ថ្ងៃ គឺចាប់ពីថ្ងៃទី២៨ វិច្ឆិកា ដល់ថ្ងៃទី ១២ ធ្នូ ឆ្នាំ២០១៨ នៅបរិវេណសួនច្បារមហាសណ្ឋាគារអង្គរ ឬក្រោយទីសក្ការៈព្រះអង្គចេក ព្រះអង្គចម។

គោលបំណងនៃការតាំងបង្ហាញនេះ គឺដើម្បីបង្កើនការផ្សព្វផ្សាយនិងយល់ដឹងជាសាធារណៈអំពីសកម្មភាពនិងសមិទ្ធផលសំខាន់ៗរបស់គណៈកម្មាធិការអាយស៊ីស៊ី-អង្គរ លើគម្រោងអភិរក្ស និងអភិវឌ្ឍន៍រមណីយដ្ឋានអង្គរយៈពេល២៥ឆ្នាំកន្លងមកដល់សិស្សានុសិស្ស និសិត្ស សាធារណជន និងភ្ញៀវទេសចរគ្រប់ប្រភេទ។

សូមបញ្ជាក់ថា ការសម្ពោធពិព័រណ៍ផ្លូវការអំពីសកម្មភាពនិងសមិទ្ធផលសំខាន់ៗ២៥ឆ្នាំរបស់គណៈកម្មាធិការអាយស៊ីស៊ី-អង្គរ លើការងារអភិរក្ស និងអភិវឌ្ឍន៍រមណីយដ្ឋានអង្គរនឹងប្រព្រឹត្តទៅក្រោមអធិបតីភាព **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជានាថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៨ នៅសាលសន្និសីទសុខាសៀមរាប៕









ភូមិជម្មជាតិរុនតាឯកចាត់ទទួលពានរង្វាន់សហគមន៍ទេសចរណ៍កំរូ

ផ្សាយនៅថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៨

កាលពីថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ **ឯកឧត្តម ម៉ី ម៉ារ៉ាឌី** ប្រធានគម្រោងអភិវឌ្ឍន៍ភូមិធម្មជាតិរុនតាឯក ត្រូវបានអញ្ជើញឱ្យចូលរួមទទួលពានរង្វាន់ «សហគមន៍ទេសចរណ៍គំរូភូមិធម្មជាតិរុនតាឯក» ដែលជាពានរង្វាន់ថ្មី រៀបចំឡើងដោយក្រសួងទេចរណ៍នៃព្រះរាជាណាចក្រកម្ពុជា។

ការប្រគល់ជូនពានរង្វាន់នេះ ត្រូវបានធ្វើឡើងក្នុងសិក្ខាសាលាបូកសរុប «ការប្រឡងប្រណាំងរមណីយដ្ឋានទេសចរណ៍គំរូលើកទី២» និង «ការប្រឡងប្រណាំងសហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍គំរូលើកទី១» ឆ្នាំ២០១៨ នៅសណ្ឋាគារភ្នំពេញ ក្រោមអធិបតីភាព **ឯកឧត្តម ថោង ខុន** រដ្ឋមន្ត្រីទទួលបន្ទុកក្រសួងទេសចរណ៍។

តាមការបញ្ជាក់ពី **ឯកឧត្តម ម៉ី ម៉ារ៉ាឌី** បានឱ្យដឹងថា «កម្មវិធីប្រកួតប្រជែងនេះ ធ្វើឡើងដើម្បីបង្កើតស្តង់ដារសហគមន៍ទេសចរណ៍កម្ពុជា ដោយផ្អែកលើគោលបំណងបួនសំខាន់គឺ៖ ១. តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអភិវឌ្ឍសហគមន៍ទេសចរណ៍កម្ពុជា។ ២. ពង្រឹងការគ្រប់គ្រងសហគមន៍ទេសចរណ៍ប្រកបដោយនិរន្តរភាព គុណភាព ប្រសិទ្ធភាព និងការទទួលខុសត្រូវ។ ៣. ជំរុញនិងលើកទឹកចិត្តឱ្យមានការចូលរួមពីប្រជាពលរដ្ឋសហគមន៍មូលដ្ឋាន។ ៤. ពង្រឹងនិងពង្រីកការជឿទុកចិត្តទៅលើសហគមន៍ទេសចរណ៍ពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់។

ឯកឧត្តមក៏បានបញ្ជាក់ពីដំណើរការមុននឹងទទួលបានពានរង្វាន់នេះដែរ គឺក្រុមការងារដឹកនាំគម្រោងអភិវឌ្ឍន៍ភូមិធម្មជាតរុនតាឯក បានទទួលដំណឹងអំពីការប្រកួតប្រជែងនេះ និងដោយពិនិត្យឃើញកត្តាសមស្របរបស់ភូមិធម្មជាតិរុនតាឯកនោះ ក្រុមការងារក៏បានដាក់ពាក្យទៅក្រសួងទេសចរណ៍ដើម្បីចូលរួម។ ក្រោយមានការត្រួតពិនិត្យបច្ចេកទេសរួចមក មន្ទីរទេសចរណ៍ខេត្តសៀមរាប បានចុះមកធ្វើការត្រួតពិនិត្យ និងវាយតម្លៃជំហានដំបូង។

បន្ទាប់មក ភូមិធម្មជាតិរុនតាឯកក៏បានទទួលការចុះមកត្រួតពិនិត្យ និងវាយតម្លៃពីតំណាងក្រសួងទេសចរណ៍ដោយផ្ទាល់។ ការវាយតម្លៃនោះឃើញថា ភូមិធម្មជាតិរុនតាឯក ពិតជាមានបរិស្ថានល្អ ស្អាត អនាម័យខ្ពស់ មានផ្ទះស្នាក់ មានអាហារដ្ឋាន សៀវភៅមុខម្ហូបពុំមានប្រភេទគ្រឿងស្រវឹង និងបារី ថែមទាំងសកម្មភាពកសិកម្មពុំមានវត្តមានសារជាតិគីមី ហើយភូមិធម្មជាតិរុនតាឯកក៏មានការគាំទ្រពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ អាជ្ញាធរជាតិអប្សរា អាជ្ញាធរភូមិ ឃុំ/ស្រុកបន្ទាយស្រី និងអង្គការ GIZ ដែលគាំទ្រលើការបណ្តុះបណ្តាល និងបច្ចេកទេសផ្សេងៗ ក៏ដូចជាអង្គការ EDOTA ដែលធ្វើការលើការលើកស្ទួយផ្សព្វផ្សាយវិស័យទេសចរណ៍ប្រចាំស្រុកបន្ទាយស្រីផងដែរ។

សូមបញ្ជាក់ដែរថា កន្លងមកភូមិធម្មជាតិរុនតាឯកក៏ធ្លាប់បានទទួលពានរង្វាន់ចំនួន០៤មកហើយនាឆ្នាំ២០១៥-២០១៧ ដូចជា «ពានរង្វាន់សុខុមាលភាពសង្គមនិងបេតិកភណ្ឌវប្បធម៌» «ពានរង្វាន់អនាម័យ និងបរិស្ថាន» «ពានរង្វាន់ពិសេសរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា» និង «ពានរង្វាន់ ASEAN Homestay Standard (2017-2019)»៕






អ្នកជំនាញអាជ្ញាធរជាតិអប្សរាបង្រៀនអំពីការអភិរក្សចម្លាក់ថ្មប្រាសាទដល់សិស្សានុសិស្សនៃសាលាបឋមសិក្សាប្រាសាទបន្ទាយសំរ៉ែ

ផ្សាយនៅថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៨

កាលពីព្រឹកថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៨ នាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរ និងបុរាណវិទ្យាបង្គារនៃអាជ្ញាធរអប្សរា បានសហការជាមួយអង្គការ GIZ នៃប្រទេសអាល្លឺម៉ង់រៀបចំកម្មវិធីអប់រំបែតិកកណ្ឌមួយសម្រាប់សិស្សានុសិស្សនៃសាលាបឋមសិក្សាប្រាសាទបន្ទាយសំរ៉ែនៅក្នុងឧទ្យានអង្គរ ក្នុងឱកាសខួបទី១០ឆ្នាំនៃការបង្កើតកម្មវិធីបណ្តុះបណ្តាលអ្នកជំនាញខ្មែរខាងវិស័យអភិរក្សនិងជួសជុលចម្លាក់ថ្មរបស់អង្គការ GIZ នៅតំបន់អង្គរ។

កម្មវិធីនេះចូលរួមក្រោមវត្តមាន**លោកបណ្ឌិត លី វណ្ណា** ប្រធាននាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរ និងបុរាណវិទ្យាបង្គារ ក្រុមអ្នកជំនាញអភិរក្សថ្មនៃអាជ្ញាធរជាតិអប្សរា ព្រមទាំងអ្នកសម្របសម្រួលបច្ចេកទេសបរទេស២រូប គ្រូបង្វឹក៣រូប សិស្សានុសិស្សនៃសាលាបឋមសិក្សាប្រាសាទបន្ទាយសំរ៉ែចំនួន៥០នាក់ និងលោកគ្រូអ្នកគ្រូ៥រូប។

កម្មវិធីនេះរៀបចំឡើងនៅប្រាសាទបន្ទាយសំរ៉ែ ក្នុងបំណងផ្តល់សញ្ញាណខ្លះៗអំពីកិច្ចការអភិរក្សចម្លាក់ថ្មប្រាសាទតាមរយៈការបង្ហាញផ្ទាល់នៅប្រាសាទបន្ទាយសំរ៉ែ និងណែនាំអំពីរបៀបថែទាំងចម្លាក់ដោយប្រើសម្ភារៈ និងឧបករណ៍សម្អាត ជួសជុល។ល។ ក្រៅពីនេះ អ្វីដែលសំខាន់នោះសម្រាប់កម្មវិធីនេះ គឺបណ្តុះគំនិតស្រឡាញ់និងចូលរួមថែរក្សាមរតកដូនតាខ្មែរដល់ប្អូនៗសិស្សានុសិស្សដែលរស់នៅក្បែរប្រាសាទបុរាណ។

ទាក់ទងនឹងចំណុចបណ្តុះស្មារតីស្រឡាញ់ និងចូលរួមថែរក្សាប្រាសាទក្នុងតំបន់អង្គរ លោកប្រធាននាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរនិងបុរាណវិទ្យាបង្ការបានពន្យល់ដល់ប្អូនៗសិស្សានុសិស្សថា ហេតុអ្វីបានជាយើងត្រូវការថែរក្សាការពារមរតកដូនតារបស់យើង ជាពិសេសប្រាសាទនិងរូបចម្លាក់នៅតាមប្រាសាទ? ព្រោះថា មនុស្សរស់ត្រូវការរបស់ពីរសំខាន់ៗ ទី១ មធ្យោបាយដើម្បីរស់ ដូចជាអាហារ ថ្នាំសង្កូវ សម្លៀកបំពាក់ និងជម្រកៗល។ ទី២ គឺវប្បធម៌។ បើមនុស្សរស់គ្មានវប្បធម៌ មនុស្សនឹងមិនដឹងពូជពង្ស មិនដឹងដូនតានៅឯណាមកពីណា ដូនតាបានធ្វើអ្វីខ្លះៗល។

លោកបណ្ឌិតបន្តទៀតថា ដូនតាខ្មែរបានសង់ប្រាសាទជាមរតកវប្បធម៌ដើម្បីសម្គាល់ថា យើងជាខ្មែរ យើងមានពូជពង្សវង្សត្រកូលជាអ្នកសង់ប្រាសាទ មានអារ្យធម៌ខ្ពង់ខ្ពស់។ ចុះបើយើងមិនស្រឡាញ់ មិនចូលរួមថែរក្សាការពារ ថ្ងៃអនាគត មរតកដូនតាយើងកាន់តែខូចខាត និងឈានទៅរកការបាត់បង់។ ពេលនោះហើយកូនចៅយើងជំនាន់ក្រោយៗមកទៀតនឹងមិនដឹងថាដូនតាយើងជាអ្នកណា បានសាងអ្វីខ្លះ មានអារ្យធម៌ដូចម្តេច?

បន្ថែមពីនោះ **លោកបណ្ឌិត លី វណ្ណា** ក៏បានរំឭកដែរថា នៅសម័យអង្គរ ដូនតាយើងតែងតែក្រើនរំឭកទូន្មានដល់កូនចៅឱ្យស្រឡាញ់ ថែរក្សាប្រាសាទ និងមរតកបុរាណដទៃទៀត តាមរយៈសិលាចារឹកនៅលើថ្មប្រាសាទជាមួយនឹងបំរាម ក៏ដូចជាការដាក់បណ្តាសាដល់អ្នកដែលបំផ្លាញប្រាសាទ ឬប្រព្រឹត្តអំពើមិនគាប្បីចំពោះប្រាសាទនឹងត្រូវចុះហានរករហូតដល់ព្រះច័ន្ទ ព្រះអាទិត្យលែងរះ ....។





សេចក្តីជូនដំណឹងស្តីពី ការបិទបរិវេណលានដល់ដំរី

ផ្សាយនៅថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៨



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរអប្សរា
APSARA
លេខ ...../អ.ស.ស

សេចក្តីជូនដំណឹង
ស្តីពី
ការបិទបរិវេណលានដល់ដំរី

អាជ្ញាធរជាតិអប្សរា មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ក្រសួង មន្ទីរ អង្គភាព ស្ថាប័នជាតិ-អន្តរជាតិ សមាគមទីភ្នាក់ងារទេសចរណ៍ សមាគមន៍មគ្គុទ្ទេសក៍ទេសចរណ៍ មគ្គុទ្ទេសក៍ទេសចរណ៍ ក្រុមហ៊ុនទេសចរណ៍ និងសាធារណជនទាំងអស់មេត្តាជ្រាបថា៖ អាជ្ញាធរជាតិអប្សរានឹងធ្វើការបិទបរិវេណលានដល់ដំរី **នៅថ្ងៃពុធ ១៣រោច ខែកត្តិក ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៨ ចាប់ពីម៉ោង១២:០០ថ្ងៃត្រង់** ដើម្បីប្រារព្ធពិធីបិទខួប២៥ឆ្នាំនៃការបង្កើតគណៈកម្មាធិការអន្តរជាតិដើម្បីសម្របសម្រួលកិច្ចគាំពារ និងអភិវឌ្ឍន៍តំបន់មណ្ឌិយដ្ឋានប្រវត្តិសាស្ត្រអង្គរ (អាយស៊ីស៊ី-អង្គរ) ក្រោមព្រះរាជាធិបតីភាពដ៏ថ្លៃថ្លាបំផុតរបស់ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។

អាជ្ញាធរជាតិអប្សរាសង្ឃឹមយ៉ាងមុតមាំថា គ្រប់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព ស្ថាប័នជាតិ-អន្តរជាតិ សមាគមទីភ្នាក់ងារទេសចរណ៍ សមាគមន៍មគ្គុទ្ទេសក៍ទេសចរណ៍ មគ្គុទ្ទេសក៍ទេសចរណ៍ ក្រុមហ៊ុនទេសចរណ៍ សមាគមអ្នកបើកបរដឹកជញ្ជូនភ្ញៀវទេសចរ អ្នកបើកបរដឹកជញ្ជូនភ្ញៀវទេសចរ ភ្ញៀវទេសចរជាតិ និងអន្តរជាតិ ព្រមទាំងសាធារណជនទាំងអស់ជ្រាបជាព័ត៌មាន។

ថ្ងៃព្រហស្បតិ៍ ៧រោច ខែ កត្តិក ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
សៀមរាប ថ្ងៃទី ...... ខែ វិច្ឆិកា ឆ្នាំ២០១៨
អគ្គនាយក

ស៊ុំ ម៉ាត់

ចម្លងជូន៖
-ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
-ក្រសួងទេសចរណ៍
-សាលាខេត្តសៀមរាប
-ក្រុមប្រឹក្សាខេត្ត
-សាលាក្រុងសៀមរាប
-គ្រប់ទាយកជ្ជា
-អង្គភាពនានាជាសមាសភាពគណៈកម្មការគ្រប់គ្រងខេត្តសៀមរាប
-អង្គភាពនានាជាសមាសភាពសាលាក្រុងសៀមរាប
-សមាគមទីភ្នាក់ងារទេសចរណ៍-សមាគមន៍មគ្គុទ្ទេសក៍
-សមាគមមគ្គុទ្ទេសក៍ទេសចរណ៍
-សមាគមអ្នកបើកបរដឹកជញ្ជូនភ្ញៀវទេសចរ
ឯកសារ,កាលប្បវត្តិ

ស្នាក់ការ:
អាជ្ញាធរជើម្បីការពារ...
Email: info@apsaraauthority.gov.kh
Website: http://www.apsaraauthority.gov.kh
សៀមរាប:
ទូរស័ព្ទ/ទូរសារ: ...

ព្រឹត្តិការណ៍ព័ត៌មាន
ប្រចាំខែមិថុនា

ផ្នែកទី ១២
ប្រចាំខែធ្នូ

អភិបាលក្រុង Fontainebleau នៃប្រទេសបារាំងស្វែងរកកិច្ចសហការជាមួយអាជ្ញាធរជាតិអប្សរា ដើម្បីចងសម្ពន្ធមេត្រីភាពរវាងរមណីយដ្ឋានអង្គរ និងរមណីយដ្ឋាន Fontainebleau

ផ្សាយនៅថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៨

នាព្រឹកថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៨ នៅស្នាក់ការអាជ្ញាធរជាតិអប្សរា **ឯកឧត្តម ហង់ ពៅ** អគ្គនាយករងតំណាង **ឯកឧត្តមបណ្ឌិត ស៊ុំ ម៉ាម៉ ** អគ្គនាយកអាជ្ញាធរជាតិអប្សរា អនុញ្ញាតឱ្យ **លោក** Frédéric VALLETOUX អភិបាលក្រុង Fontainebleau និងប្រតិភូចូលជួបសំណេះសំណាល ផ្លាស់ប្តូរយោបល់គ្នា ចែករំលែកបទពិសោធន៍រវាងបេតិកភណ្ឌពិភពលោកនៃប្រទេសទាំងពីរ គឺតំបន់រមណីយដ្ឋានអង្គរ និងរមណីយដ្ឋាន Fontainebleau។

ក្នុងជំនួបពិភាក្សានេះ ធ្វើឡើងដើម្បីផ្លាស់ប្តូរបទពិសោធន៍ជាពិសេសក្នុងស្ថានភាពដែលរមណីយដ្ឋានទាំងពីរកំពុងតែទទួលបាននូវកំណើនភ្ញៀវទេសចរគួរឲ្យកត់សម្គាល់ជារៀងរាល់ឆ្នាំ និងស្វែងរកការសហការណ៍ផ្សេងៗនាពេលអនាគតរវាងរមណីយដ្ឋានអង្គរ និងរមណីយដ្ឋាន Fontainebleau។

ម្យ៉ាងទៀតដើម្បីស្វែងយល់អំពីផលប៉ះពាល់ទៅលើបេតិកភណ្ឌ ដែលភ្ញៀវទេសចរមកទស្សនាក្នុងតំបន់រមណីយដ្ឋានអង្គរ ការអភិរក្សប្រាសាទ និងការគ្រប់គ្រងធនធានធម្មជាតិដូចជា ទឹក ព្រៃឈើ ព្រមទាំងពិនិត្យលទ្ធភាពនៃការចងសម្ពន្ធមេត្រីភាព ដើម្បីផ្លាស់ប្តូរបច្ចេកទេសរវាងរមណីយដ្ឋានបេតិកភណ្ឌទាំងពីរ ទាក់ទងនឹងប្រាសាទ ការអភិរក្ស ធនធានធម្មជាតិមានទឹក ព្រៃឈើ និងទេសភាពវប្បធម៌ជាដើម៕









សោម៉ាគ្រុបផ្តល់កង់៩២គ្រឿង និងសម្ភារសិក្សាជាច្រើនជូនសិស្សានុសិស្សនៅភូមិជម្មជាតិរុនតាឯក

ផ្សាយនៅថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១៨

ដើម្បីរួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងការលើកកម្ពស់ជីវភាពរបស់ប្រជាពលរដ្ឋ ដែលកំពុងរស់នៅភូមិជម្មជាតិរុនតាឯក នាព្រឹកថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០១៨នេះ សោម៉ាគ្រុប បាននាំយកកង់ និងសម្ភារសិក្សាជាច្រើនសម្រាប់ផ្តល់ជូនដល់សិស្សានុ-សិស្ស ដែលកំពុងសិក្សានៅសាលាបឋមសិក្សាជាលាធំក្នុងគម្រោងអភិវឌ្ឍន៍ភូមិជម្មជាតិរុនតាឯក។
សម្ភារសិក្សាដែលប្រគល់ជូននេះនៅពេលនេះមានដូចជា កង់៩២គ្រឿង កាបូបស្ពាយ៨៧ សម្ភារសិក្សាផ្សេងៗ៨៧ សម្រាប់ ឯកសណ្ឋានសិស្ស៨៧កំប្លេ ម៉ាស៊ីនបូមទឹក២គ្រឿង ពងមាន់៦០០គ្រាប់ ដួងក្រអូប១៤០ផ្លែ ខ្នុរ១៤ផ្លែ និងកេសជ្ជៈ Aloe Vera ៣០កេស ព្រមទាំងសម្ភារមួយចំនួនទៀត។

ឯកឧត្តម ម៉ី ម៉ារ៉ាឌី ទីប្រឹក្សានៃអាជ្ញាធរជាតិអប្សរា និងជាប្រធានគម្រោងអភិវឌ្ឍន៍ភូមិជម្មជាតិរុនតាឯកបានសម្តែងនូវការស្វាគមន៍ និងថ្លែងអំណរគុណចំពោះសោម៉ាគ្រុប ដែលតែងតែរួមចំណែកជួយដល់គម្រោងអភិវឌ្ឍន៍នេះ។ ឯកឧត្តមក៏បានបញ្ជាក់ផងដែរអំពីមូលហេតុចម្បង ដែលនាំឲ្យបង្កើតគម្រោងអភិវឌ្ឍន៍នេះឡើង ព្រមទាំងជំណើរការរីកចម្រើនរបស់គម្រោង។ ជាមួយគ្នានេះឯកឧត្តមក៏បានរំឭកដល់គុណូបការៈរបស់**សម្តេចតិបុលបញ្ញា សុខ អាន** ដែលជាអ្នកផ្តួចផ្តើមគម្រោងនេះឡើងក្នុងបុព្វហេតុការពារនូវរមណីយដ្ឋានអង្គរ។

ឯកឧត្តម សុខ សុភេន តំណាងសោម៉ាគ្រុប បញ្ជាក់ថា ការផ្តល់ជូនសម្ភារសិក្សាដល់សិស្សានុសិស្សនេះ ធ្វើឡើងក្នុងនាមគ្រួសារសោម៉ាគ្រុបដើម្បីរួមចំណែកការងារមនុស្សធម៌ ជាពិសេស គឺដើម្បីរួមចំណែកក្នុងការងារអភិរក្សបេតិកភណ្ឌ។ សកម្មភាពនេះនឹងជំរុញឲ្យបុគ្គលិកគ្រប់ផ្នែករបស់សោម៉ាគ្រុបបានរួមចំណែកក្នុងកិច្ចការប្បុរធម៌ដែលជាកេរមរតករបស់ដូនតា។
ឯកឧត្តម សុខ សង្វារ អគ្គនាយករង និងជាតំណាង**ឯកឧត្តមបណ្ឌិត ស៊ុំ ម៉ាប់** អគ្គនាយកអាជ្ញាធរជាតិអប្សរា បានថ្លែងអំណរគុណចំពោះសោម៉ាគ្រុបសម្រាប់សកម្មភាពរួមចំណែកជាមួយអាជ្ញាធរជាតិអប្សរានៅពេលនេះ។ ឯកឧត្តមក៏បានបញ្ជាក់ថា អាជ្ញាធរជាតិអប្សរាដែលជាស្ថាប័នទទួលបន្ទុកអភិវឌ្ឍគម្រោងនេះតែងយកចិត្តទុកដាក់ជាមួយប្រជាពលរដ្ឋតាមរយៈការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដល់ពួកគាត់ កសាងហេដ្ឋារចនាសម្ព័ន្ធ និងសហការជាមួយដៃគូពាក់ព័ន្ធផ្សេងៗដើម្បីបង្កើតមុខរបរជូនពួកគាត់។ ក្រៅពីនេះ អាជ្ញាធរជាតិអប្សរា ក៏តែងសហការជាមួយសប្បុរសជននានាដើម្បីផ្តល់ជូននូវសម្ភារបរិក្ខារដល់អ្នកភូមិដូចជា អណ្តូងទឹក សាលារៀន និងសម្ភារសិក្សាដល់សិស្សានុសិស្សជាដើម ដើម្បីជួយសម្រួលដល់ជីវភាពរបស់ពួកគាត់៕









អ្នកជំនាញអាជ្ញាកុះពិនិត្យការដ្ឋានតោរមណីយដ្ឋានអង្គរមុនកិច្ចប្រជុំអាយស៊ីស៊ី-អង្គរ

ផ្សាយនៅថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១៨

នៅព្រឹកថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៨ អ្នកជំនាញការអាជ្ញាកុះរបស់គណៈកម្មាធិការអន្តរជាតិសម្របសម្រួលការគាំពារ និងអភិវឌ្ឍន៍តំបន់ប្រវត្តិសាស្ត្រអង្គរ ហៅកាត់ថា អាស៊ីស៊ី-អង្គរ បានចុះទៅពិនិត្យការដ្ឋានមួយចំនួនក្នុងរមណីយដ្ឋានអង្គរ។ កម្មវិធីនេះ តែងធ្វើជាទៀងទាត់នៅមុនកិច្ចប្រជុំអាយស៊ីស៊ី-អង្គរ ហើយកិច្ចប្រជុំនៅលើកនេះ នឹងប្រារព្ធធ្វើនៅថ្ងៃទី៤-៥ ខែធ្នូ អមនឹងការប្រារព្ធខួប ២៥ឆ្នាំនៃការបង្កើតគណៈកម្មាធិការអន្តរជាតិនេះផងដែរ។

ឯកឧត្តម ហង់ ពៅ អគ្គនាយករងអាជ្ញាធរជាតិអប្សរា ដែលអមដំណើរជាមួយគណៈប្រតិភូអ្នកជំនាញការអាជ្ញាកុះមានប្រសាសន៍ថា កម្មវិធីនៅឆ្នាំនេះដូចរាល់ឆ្នាំដែរ គឺតែងមានអ្នកជំនាញការធំៗរបស់យូណេស្កូ ចុះមើលការដ្ឋានជាតិ និងអន្តរជាតិនៅតំបន់រមណីយដ្ឋានអង្គរ ដើម្បីលើកជាយោបល់ដល់ក្រុមការងារទាំងអស់ឱ្យធ្វើ និងអនុវត្តន៍តាម ពិសេសគឺត្រួតពិនិត្យការងារកន្លងមក ថាតើធ្វើតាមការណែនាំរបស់អ្នកជំនាញការទាំងនោះដែរឬទេ។

គួរបញ្ជាក់ថា គណៈប្រតិភូជំនាញការអាជ្ញាកុះ បាននិងកំពុងចុះទៅការដ្ឋានមួយចំនួន រួមមាន ស្ពានហាល និងគម្រោងរៀបចំកន្លែងបដិសណ្ឋារកិច្ចអង្គរវត្ត ប្រាសាទបាយ័ន ប្រាសាទព្រះពិឃុរ ប្រាសាទតាព្រហ្ម ប្រាសាទមេបុណ្យខាងលិច ប្រាសាទតាកែវ រួមនិងគម្រោងការដ្ឋានធ្វើផ្លូវនៅភ្នំគូលែន។ល។






លោកជំទាវ ភឿង សកុណា ចូលរួមក្នុងពិធីខួប១០ឆ្នាំរបស់សារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ និងពិធីពុទ្ធាភិសេកព្រះពុទ្ធអង្គធំ

ផ្សាយនៅថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១៨

នៅព្រឹកថ្ងៃទី២ ខែធ្នូ ឆ្នាំ ២០១៨ **លោកជំទាវ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាប្រធានអាជ្ញាធរជាតិអប្សរា ចូលរួមក្នុងពិធីអបអរខួប១០ ឆ្នាំរបស់សារមន្ទីរព្រះនរោត្តម សីហនុ-អង្គរ និងពិធីពុទ្ធាភិសេកព្រះពុទ្ធអង្គធំ ដែលធ្វើឡើងក្រោមវត្តមានចូលរួមពីមន្ត្រីរាជការ អ្នកជំនាញការជាតិ-អន្តរជាតិ និងភ្ញៀវអន្តរជាតិប្រមាណ១០០នាក់។ ក្នុងពិធីពុទ្ធាភិសេកព្រះពុទ្ធអង្គធំ ក៏មានការនិមន្តព្រះសង្ឃ ដើម្បីរៀបចំទៅតាមពិធីសាសនា។ ក្នុងពិធីនេះដែរ **លោកជំទាវ ភឿង សកុណា** បានឧបត្ថម្ភដល់វត្តរាជបូព៌ជាថវិកាចំនួន ២លានរៀលផងដែរ។

ដើមហេតុនៃការបង្កើតសារមន្ទីរនេះ គឺនៅឆ្នាំ២០០១ សាកលវិទ្យាល័យសូហ្វីយ៉ា និងបុរាណវិទូខ្មែរ បានធ្វើកំណាយសិក្សាស្រាវជ្រាវនៅប្រាសាទបន្ទាយក្តី ហើយប្រទះរូបចម្លាក់ចំនួន ២៧៤ បំណែក ដែលស្ថិតនៅក្នុងរណ្តៅកំណាយនៅពេលនោះ។ ក្លាមៗ បំណែករូបចម្លាក់ទាំងអស់ ត្រូវបាននាំយកទៅរក្សាទុកបណ្តោះអាសន្ននៅសាកលវិទ្យាល័យសូហ្វីយ៉ា។ នៅឆ្នាំ ២០០៣ **លោក តាគីយ៉ា អូកាដា** ប្រធានកិត្តិយសនៃក្រុមហ៊ុន អ៊ីអុង ជប៉ុន បានទស្សនាមជ្ឈមណ្ឌលសូហ្វីយ៉ា នៅសៀមរាប ហើយក៏មានបំណងបង្កើតសារមន្ទីរមួយដើម្បីតម្កល់ និងថែរក្សារូបចម្លាក់ទាំងនោះ។ សារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ ត្រូវបានដាក់សម្ពោធជាផ្លូវការនៅថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០០៧។ សារមន្ទីរនេះសាងសង់ឡើងដោយមានការឧបត្ថម្ភពីក្រុមហ៊ុនអ៊ីអុង (AEON) របស់ជប៉ុន តាមរយៈមូលនិធិ ១% ហើយត្រូវបានប្រសិទ្ធនាមថា «សារមន្ទីរព្រះនរោត្តម សីហនុ-អង្គរ»។

សារមន្ទីរព្រះនរោត្តម សីហនុ-អង្គរ ដើរតួយ៉ាងសំខាន់ក្នុងការរួមចំណែកផ្តល់ចំណេះដឹងដល់ម្ចាស់ស្រុក អ្នកស្រាវជ្រាវ ជាពិសេសសិស្សនិស្សិត អំពីតម្លៃដ៏អស្ចារ្យនៃវប្បធម៌ អរិយធម៌ ប្រវត្តិសាស្ត្រ និងសាសនារបស់ខ្មែរ ហើយក៏ជាកន្លែងតម្កល់ ថែរក្សា ជួសជុល នូវរូបចម្លាក់ និងវត្ថុបុរាណដែលបានស្រាវជ្រាវរកឃើញនៅរមណីដ្ឋានអង្គរ ក៏ដូចជាតាមបុរាណដ្ឋាននានាមកបង្ហាញសាធារណជន។

ទាក់ទងនឹងព្រះពុទ្ធអង្គធំ ដែលមានកម្ពស់ ៦ម៉ែត្រ ដែលតម្កល់នៅមុខសារមន្ទីរ គឺសាងសង់ឡើងដោយ**លោកស្រី** Sulata Mitra Sarkar ដែលជាជនជាតិឥណ្ឌា ហើយកសាងរួចរាល់នៅឆ្នាំ ២០១១មកម្លេះ។ គោលបំណងនៃការសាងសង់នេះ ដើម្បីសុំសេចក្តីសុខសន្តិភាព និងភាពសុខដុមរមនា ក៏ដូចជាទីសក្ការៈដល់ប្រជាជនខ្មែរទូទៅ។ អាជ្ញាធរជាតិអប្សរា ក៏បានចូលរួមជួយឧបត្ថម្ភក្នុងការសាងសង់ផងដែរ ដូចជាការផ្តល់ដីសាងសង់ សំណង់ដំបូល គ្រឹះតម្កល់បដិមា និងស្រះឈូក។

គួរបញ្ជាក់ថា ដើម្បីអបអរពិធីខាងលើនេះ សារមន្ទីរព្រះនរោត្តម សីហនុ-អង្គរ ក៏បានរៀបចំពិព័រណ៍ខ្នាតតូចមួយបន្ថែមស្តីពីព្រះពុទ្ធជាគ្រូថ្នាំ និងការបើកឱ្យទស្សនាដោយឥតគិតថ្លៃចំនួន ៣ថ្ងៃ គឺចាប់ពីថ្ងៃទី៤-៦ ខែធ្នូ៕









អ្នកជំនាញការអាជហុកចុះពិនិត្យការដ្ឋានសាងសង់ផ្លូវលើភ្នំគូលែនមុននឹងបើកកិច្ចប្រជុំអាយស៊ីស៊ី-អង្គរ

ផ្សាយនៅថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១៨

កាលពីព្រឹកថ្ងៃទី០២ខែធ្នូ ឆ្នាំ២០១៨ ក្រុមអ្នកជំនាញការអាជហុកនៃអង្គការយូណេស្កូចំនួន៤រូប មន្ត្រីអាជ្ញាធរជាតិអប្សរា រួមទាំងមន្ត្រីបរិស្ថាន និងភាគីក្រុមហ៊ុនសាងសង់ផ្លូវ បានចុះពិនិត្យមើលការសាង់សង់ផ្លូវថ្មីលើភ្នំគូលែន ដើម្បីត្រៀមទទួលយោបល់កែលម្អនៅក្នុងកិច្ចប្រជុំបច្ចេកទេសអាយស៊ីស៊ី-អង្គរលើកទី៣១ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី៤-៥ ខែធ្នូ ឆ្នាំ ២០១៨ ខាងមុខនេះ។

លោកបណ្ឌិត ឈាន រដ្ឋា ប្រធានស្តីទីនៃនាយកដ្ឋានអភិរក្សប្រាសាទក្រៅឧទ្យានអង្គរ បានឱ្យដឹងថា ក្នុងដំណើរចុះពិនិត្យរបស់ក្រុមអ្នកជំនាញការអាជហុក គឺក្នុងគោលបំណងពិនិត្យមើលនិងតាមដានការងារធ្វើផ្លូវនេះ ថាតើបានអនុវត្តន៍ត្រឹមត្រូវស្របតាមអនុសាសន៍កន្លងមកដែរឬទេ ដើម្បីចៀសវាងផលប៉ះពាល់ធ្ងន់ធ្ងរដល់ព្រៃឈើនិងទីតាំងបុរាណដ្ឋានមួយចំនួនត្រូវការពារ។ បន្ថែមពីនោះ អ្នកជំនាញបានចុះពិនិត្យមើលរណ្តៅកំណាយចំនួន០៩កន្លែងដែលក្រុមការងាររបស់អាជ្ញាធរជាតិអប្សរាបាននិងកំពុងធ្វើកំណាយ ដើម្បីឱ្យដឹងថា តើនៅក្រោមដីដែលត្រូវធ្វើផ្លូវពីលើនិងនៅសងខាងផ្លូវដែលត្រូវធ្វើផ្លូវនោះ មានបុរាណដ្ឋានឬរចនាសម្ពន្ធអ្វីដែលគួរចៀសវាងឬអត់។

លោកបណ្ឌិត រដ្ឋា បន្តទៀតថា រណ្តៅចំនួន០៩កន្លែងនៅភូមិអន្លង់ធំនោះ ក្រុមការងារបានប្រទះឃើញមានបំណែកកុលាលភាជន៍តិចតួច និងបានប្រទះឃើញរចនាសម្ពន្ធធ្វើអំពីឥដ្ឋចំនួនមួយរណ្តៅ តែមិនទាន់អាចសន្និដ្ឋានបានថាជាអ្វីឱ្យប្រាកដនៅឡើយទេ គឺត្រូវការពេលវេលាដើម្បីសិក្សាបន្ថែម។ ចំណែកយោបល់លើការធ្វើផ្លូវ ភាគច្រើនគឺគោរពតាមអនុសាសន៍កន្លងមក និងមានកន្លែងតិចតួចប៉ុណ្ណោះដែលត្រូវពង្រីកធំ ដោយយោងទៅលើស្ថានភាពផ្លូវកោង ហើយយោបល់កែតម្រូវយ៉ាងណានោះ នឹងដឹងពិស្តារនៅក្នុងអង្គប្រជុំអាយស៊ីស៊ី-អង្គរ នាពេលខាងមុខនេះ។

សូមបញ្ជាក់ដែរថា ដំណើរចុះពិនិត្យទីតាំង សមិទ្ធផលការងារ ការដ្ឋានសាង់សង់ ហេដ្ឋារចនាសម្ពន្ធសំណង់ បរិស្ថានផ្សេងៗរបស់អ្នកជំនាញការអាជហុកនៃអង្គការយូណេស្កូ គឺតែងធ្វើឡើងជាប្រចាំមុនបើកកិច្ចប្រជុំអាយស៊ីស៊ី-អង្គរ ដើម្បីតាមដានរាល់សកម្មភាព ការងារ ថាដំណើរទៅតាមអនុសាសន៍ និងគោរពច្បាប់បេតិកភណ្ឌពិភពលោកឬអត់។









កម្មវិធីអបអរខួប ២៥ឆ្នាំ នៃការបង្កើតអាយស៊ីស៊ី-អង្គរ ក្រោមវត្តមាន សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

ផ្សាយនៅថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១៨

នៅព្រឹកថ្ងៃទី៤ ខែធ្នូ ឆ្នាំ ២០១៨ នេះ កម្មវិធីអបអរខួប ២៥ឆ្នាំ នៃការបង្កើតគណៈកម្មាធិការអន្តរជាតិសម្របសម្រួលការគាំពារ និងអភិវឌ្ឍន៍តំបន់រមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ ហៅកាត់ថា អាយស៊ីស៊ី-អង្គរ បានចាប់ផ្តើមជាផ្លូវការ ក្រោមវត្តមានដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង **លោកជំទាវ** Audrey AZOULAY អគ្គនាយិកាយូណេស្កូ។

ក្នុងពិធីនេះដែរ ក៏មានការចូលរួមពីឥស្សរជនជាន់ខ្ពស់ តំណាងក្រសួងការបរទេសជប៉ុន និងតំណាងក្រសួងវប្បធម៌បារាំង ព្រមទាំងថ្នាក់ដឹកនាំក្នុងជួររាជរដ្ឋាភិបាលកម្ពុជា មន្ត្រីរាជការ អ្នកជំនាញជាតិជាតិ-អន្តរជាតិ និងអ្នកសារព័ត៌មានប្រមាណជាង ៦០០នាក់។

មុនចាប់ផ្តើមកម្មវិធី ប្រមុខរាជរដ្ឋាភិបាលកម្ពុជា បានទទួលជួបសវនាការជាមួយ **លោកជំទាវ** Audrey AZOULAY អគ្គនាយិកាយូណេស្កូ **ឯកឧត្តម** Manabu MIYAGAWA អនុរដ្ឋមន្ត្រី និងជាអគ្គនាយកទទួលបន្ទុកកិច្ចការវប្បធម៌ នៃក្រសួងការបរទេសជប៉ុន **លោកជំទាវ** Eva NGUYEN BINH ឯកអគ្គរដ្ឋទូតបារាំង តំណាងក្រសួងវប្បធម៌បារាំង **ឯកឧត្តម** Hidehisa Horinouchi ឯកអគ្គរដ្ឋទូតជប៉ុន សហប្រធាននៃ អាយស៊ីស៊ី-អង្គរ និងគណៈប្រតិភូមួយចំនួនទៀត។

ការចូលរួមរបស់គណៈប្រតិភូទាំងអស់ បង្ហាញឱ្យឃើញពីការគាំទ្រយ៉ាងរឹងមាំ ក៏ដូចជាការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល ចំពោះកិច្ចការពារ និងលើកតម្លៃបេតិកភណ្ឌវប្បធម៌ជាតិ និងបេតិកភណ្ឌពិភពលោក។ គណៈកម្មាធិការអន្តរជាតិ អាយស៊ីស៊ី-អង្គរ គឺជាយន្តការអន្តរជាតិដើម្បីគៀងគរធនធានថវិកា ជំនាញបច្ចេកទេស និងធនធានមនុស្ស ពីសហគមន៍អន្តរជាតិ ដើម្បីធ្វើការជួសជុល អភិរក្ស និងលើកតម្លៃប្រាសាទនានា ក៏ដូចជាការអភិវឌ្ឍរមណីយដ្ឋានបេតិកភណ្ឌពិភពលោកអង្គរ ដែលមានភាពធំធេង និងត្រូវការធនធានច្រើនដើម្បីអនុវត្តភារកិច្ចនេះ។ ក្នុងដំណើរការរបស់ខ្លួន គណៈកម្មាធិការ អាយស៊ីស៊ី-អង្គរ បានរៀបចំកិច្ចប្រជុំបច្ចេកទេសចំនួន ៣១ដង និងកិច្ចប្រជុំពេញអង្គចំនួន ២៥ដងរួចមកហើយ ហើយដែលថវិការាប់រយលានដុល្លារត្រូវបានប្រើប្រាស់ និងអ្នកជំនាញបច្ចេកទេសជាតិរាប់រយនាក់ បានទទួលការបណ្តុះបណ្តាល និងបន្តវេនយ៉ាងរឹងមាំ ដើម្បីធានានូវការអភិរក្សប្រកបដោយចីរភាពនៃតំបន់អង្គរ។

ជាសក្សីភាពនៃការជោគជ័យរបស់រាជរដ្ឋាភិបាលក្នុងវិស័យបេតិកភណ្ឌវប្បធម៌ **លោកជំទាវ** Audrey AZOULAY អគ្គនាយិកាយូណេស្កូ បានប្រគល់វិញ្ញាបនបត្រការចុះបញ្ជីល្ខោនខោល វត្តស្វាយអណ្តែត ជាតំណាងល្ខោនខោលនៃកម្ពុជាចូលជាសម្បត្តិបេតិកភណ្ឌអរូបីមនុស្សជាតិកាលពីថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០១៨ នាទីក្រុងព័រល្វី នៃសាធារណរដ្ឋ ម៉ូរីសដល់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ដែលនេះជាមោទនភាពដ៏ឧត្តុងឧត្តមរបស់កម្ពុជាទាំងមូល។ ជាមួយគ្នានេះដែរ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** បានធ្វើការបំពាក់មេដាយនិមិត្តរូបជូនឥស្សរជនអន្តរជាតិដែលបានលះបង់កម្លាំងកាយកចិត្តក្នុងបុព្វហេតុអភិរក្ស និងអភិវឌ្ឍន៍រមណីយដ្ឋានអង្គរ។

ជាមួយនឹងទស្សនទាន និងការចែករំលែកបទពិសោធន៍ជាច្រើន ដែលកម្ពុជាឆ្លងកាត់នាអតីតកាល **សម្តេចអគ្គមហាសេនាបតីតេជោ** ក៏បានបង្ហាញអំពីការតាំងចិត្ត និងសុឆន្ទៈដ៏មោះមុត និងត្រៀមខ្លួនចូលរួមជានិច្ចជាមួយរាល់ដៃគូសហប្រតិបត្តិការអន្តរជាតិទាំងអស់ ក្នុងការថែរក្សាមរតកជូនតាដែលជាមរតកមនុស្សជាតិ។ ក្នុងការងារនេះដែរ **សម្តេចអគ្គមហាសេនាបតីតេជោ** ក៏បានរម្លឹកដល់ប្រជាពលរដ្ឋខ្មែរគ្រប់រូប ចូលរួមធ្វើយ៉ាងណាលើកតម្លៃបេតិកភណ្ឌជាតិឱ្យបានគង់វង្ស និងស្ថិតស្ថេរជានិរន្ត។

ចុងបញ្ចប់នៃកម្មវិធី គណៈប្រតិភូក៏អញ្ជើញទស្សនាស្តង់ពិព័រណ៍រូបភាពជុំវិញសមិទ្ធផល២៥ឆ្នាំ របស់គណៈកម្មាធិការអាយស៊ីស៊ី-អង្គរ ដែលបានរៀបចំនៅមុខបន្ទប់ប្រជុំផងដែរ៕









សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន អំពាវនាវដល់បណ្តាប្រទេសជាមិត្ត និងដៃគូសហប្រតិបត្តិការអន្តរជាតិបន្តជួយរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១៨

ថ្លែងក្នុងពិធីបើកកិច្ចប្រជុំបច្ចេកទេសលើកទី៣១ និងកិច្ចប្រជុំពេញអង្គលើកទី២៥នៃអាយស៊ីស៊ី-អង្គរនាព្រឹកថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៨ នៅសណ្ឋាគារសុខាសៀមរាប **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានអំពាវនាវដល់បណ្តាប្រទេសជាមិត្តនិងដៃគូសហប្រតិបត្តិការអន្តរជាតិបន្តជួយគាំទ្រទាំងផ្នែកហិរញ្ញវត្ថុនិងធនធានមនុស្សបន្តទៀត។ រីឯក្រសួងស្ថាប័នជាតិដែលពាក់ព័ន្ធ រួមទាំងប្រជាជនកម្ពុជាទាំងអស់ ត្រូវតែចូលរួមសហការគ្នាឱ្យបានល្អក្នុងការការពារបេតិកភណ្ឌមនុស្សជាតិនិងរមណីយដ្ឋានអង្គរ ពោលគឺដើម្បីអង្គរទាំងអស់គ្នា។

សម្តេចក៏បានសង្កត់ធ្ងន់ផងថា នាសតវត្សទី១៩៨០ កម្ពុជាអភ័ព្វណាស់ តាមរយៈការគាំទ្រអាសនៈរបស់ខ្មែរក្រហមនៅអង្គការសហប្រជាជាតិ កត្តាសង្គ្រាម និងកត្តានយោបាយ កម្ពុជាបានទទួលរងនូវទណ្ឌកម្មទាំងផ្នែកនយោបាយនិងសេដ្ឋកិច្ច ធ្វើឲ្យប្រទេសរងនូវការបំផ្លាញគ្រប់បែបយ៉ាង សូម្បីតែប្រាសាទអង្គរវត្តនិងប្រាសាទព្រះវិហារ ដែលចំណុចនេះសម្តេចស្នើដល់ពិភពលោកគួរធ្វើការដកពិសោធន៍ ហើយមិនគួរទុកឱ្យបេតិកភណ្ឌប្រវត្តិសាស្ត្ររបស់មនុស្សជាតិទាំងនៅកម្ពុជានិងនៅបណ្តាប្រទេសនានានៅឡូកឡំដោយទណ្ឌកម្មនយោបាយឡើយ។

អំពីការថែរក្សានិងគ្រប់គ្រងរមណីយដ្ឋានអង្គរ សម្តេចបានថ្លែងថា វាមិនមែនជារឿងងាយស្រួលនោះទេសម្រាប់អាជ្ញាធរជាតិអប្សរា ដូច្នេះសូមអ្នកនយោបាយកុំធ្វើការញុះញង់ដោយប្រការណាមួយក្នុងន័យជំរុញប្រជាពលរដ្ឋឲ្យចូលទៅកាន់កាប់ឬរស់នៅដោយគ្មានការអនុញ្ញាតក្នុងតំបន់បេតិកភណ្ឌនារដូវបោះឆ្នោតដោយរួមទាំងតំបន់បេតិកភណ្ឌដែលចុះបញ្ជីនិងមិនទាន់បានចុះបញ្ជីជាសម្បត្តិបេតិកភណ្ឌពិភពលោក ព្រោះការថែរក្សាតំបន់បេតិកភណ្ឌជាភារកិច្ចរបស់ខ្មែរគ្រប់រូប គ្រប់ជាន់ថ្នាក់។ លើសពីនេះ សម្តេចបានប្រដូចអង្គរដោមេមាន់ ដែលមិនត្រូវសម្លាប់មាន់ដើម្បីធ្វាញ់តែមួយពេលទេ គឺត្រូវចិញ្ចឹមយកស៊ុតនិងកូន ទើបបានប្រយោជន៍យូរអង្វែងសម្រាប់អនាគតរបស់មនុស្សជំនាន់ក្រោយ។

ទន្ទឹមគ្នានេះ សម្តេចក៏បានរំឭកពីកិច្ចខិតខំប្រឹងប្រែងក្នុងការពារនិងបញ្ចៀសបញ្ហាផ្សេងៗដែលនាំឱ្យប៉ះពាល់ដល់បុរាណដ្ឋានក្នុងប្រទេសជាមួយអង្គព្រះមហាក្សត្រ ព្រះបរមតនកោដ្ឋ ពិសេសតំបន់អង្គរ ទាំងការបង្កើតច្បាប់ការពារបេតិកភណ្ឌ ការដោះដូរដីធ្លី និងផ្លាស់ប្តូរទីលំនៅរបស់បងប្អូនប្រជាពលរដ្ឋចេញពីតំបន់មុខប្រាសាទអង្គរវត្តនាដើមទសវត្សទី១៩៩០។ សម្តេចនាយករដ្ឋមន្ត្រីក៏បានសម្តែងការគាំទ្រយ៉ាងពេញទំហឹងចំពោះការបង្កើតឱ្យមានកិច្ចប្រជុំអាយស៊ីស៊ី-អង្គរ ពិសេសថ្លែងអំណរគុណដល់កិច្ចខិតខំប្រឹងប្រែងរបស់អង្គការយូណេស្កូ បណ្តាដៃគូសហប្រតិបត្តិការអន្តរជាតិផ្នែកអភិរក្ស អាជ្ញាធរជាតិអប្សរា ស្ថាប័នពាក់ព័ន្ធដែលបានធ្វើឱ្យអាយស៊ីស៊ី-អង្គរក្លាយជាស្ថាប័នគំរូសម្រាប់ជាតិនិងអន្តរជាតិ ជួយអភិរក្សប្រាសាទក្នុងរមណីយដ្ឋានអង្គរ និងបណ្តុះបណ្តាលធនធានមនុស្សបានយ៉ាងច្រើនក្នុងការថែរក្សាអង្គរ៕









ជូនដំណឹងអាជ្ញាធរជាតិអប្សរា និង អាយស៊ីស៊ី-អង្គរ អញ្ជើញការពិញ្ញាណក្ខន្ធលោកសាស្ត្រាចារ្យ Pierre Andre Lablaude អតីតអ្នកជំនាញ Adhoc របស់អាយស៊ីស៊ី-អង្គរ

ផ្សាយនៅថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១៨

នាឱកាសពិធីបើកកិច្ចប្រជុំបច្ចេកទេសលើកទី៣១ និងកិច្ចប្រជុំពេញអង្គលើកទី២៥ នៃគណៈកម្មាធិការអាយស៊ីស៊ី-អង្គរ នាថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៨ នៅសាលសន្និសិទសុខាសៀមរាប លោកជំទាវ កឿង សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាប្រធានអាជ្ញាធរជាតិអប្សរា **ឯកឧត្តម** Manabu Miyagawa អនុរដ្ឋមន្ត្រី និងជាអគ្គនាយកទទួលបន្ទុកកិច្ចការវប្បធម៌ នៃក្រសួងការបរទេសជប៉ុន លោកជំទាវ ឯកឧត្តម ជាសហប្រធានអាយស៊ីស៊ី-អង្គរ និងអ្នកជំនាញជាតិ-អន្តរជាតិជាច្រើន បានអញ្ជើញចូលរួមគោរពវិញ្ញាណក្ខន្ធ**លោកសាស្ត្រាចារ្យ** Pierre Andre Lablaude ដែលបានខិតខំ និងលះបង់កម្លាំងកាយ កម្លាំងចិត្ត ចូលរួមចំណែកយ៉ាងខ្លាំងក្លាក្នុងកិច្ចការ ថែរក្សា និងអភិវឌ្ឍន៍ប្រកបដោយចីរភាពរមណីយដ្ឋានអង្គរ។

សូមបញ្ជាក់ថា **លោកសាស្ត្រាចារ្យ** Pierre Andre Lablaude បានទទួលអនិច្ចកម្មនាខែកក្កដា ឆ្នាំ២០១៧ នៅទីក្រុងប៉ារីស ដោយជំងឺ៕









សេចក្តីជូនដំណឹងស្តីពី ការរៀបចំកម្មវិធីសម្តែងសិល្បៈស្បែកជំ និងរាំកូរ៉ែនៅទីតាំងប្រាសាទព្រះពិហារនិងនៅដីប៉ឺរ៉ែនសង្កាត់-ខប្បងមីខាងក្បែងសាលាខេត្តសៀមរាប

ផ្សាយនៅថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១៨



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លេខ ១២៤៧/ស.ល.ជ.ស
/១៤

សេចក្តីជូនដំណឹង
ស្តីពី
ការរៀបចំកម្មវិធីសម្តែងសិល្បៈស្បែកជំ និងរាំកូរ៉ែ នៅទីតាំងប្រៃប្រាសាទព្រះពិហារ និងនៅដីប៉ឺរ៉ែនសង្កាត់-ខប្បងមីខាងក្បែងសាលាខេត្តសៀមរាប

អាជ្ញាធរជាតិអប្សរាមានកិត្តិយសសូមជម្រាបជូនដំណឹងដល់ត្រប់ក្រសួង មន្ទីរ-អង្គភាព ស្ថាប័នជាតិ-អន្តរជាតិ សមាគមទីភ្នាក់ងារទេសចរណ៍ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ មគ្គុទ្ទេសក៍ទេសចរណ៍ ក្រុមហ៊ុនទេសចរណ៍ ភ្ញៀវទេសចរជាតិ និងសាធារណជនទាំងអស់ឱ្យបានជ្រាបថា អាជ្ញាធរជាតិអប្សរាបានឯកភាព និងអនុញ្ញាតជូនស្ថាប័ន Korea Cultural Heritage Foundation (KCHF) ក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការគម្រោងជួសជុលប្រាសាទព្រះពិហារ ជាមួយអាជ្ញាធរជាតិអប្សរាដើម្បីសម្តែងសិល្បៈស្បែកជំ និងរាំកូរ៉ែ (Arirang) ដែលជាបេតិកភណ្ឌអរូបីរបស់អង្គការយូណេស្កូ នៅតាមទីកន្លែងកាលបរិច្ឆេទដូចខាងក្រោម៖

១-នៅថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៨ ចាប់ពីម៉ោង ០៦:៣០នាទី ដល់ម៉ោង ០៨:៣០នាទីយប់ ដើម្បីសម្តែងសិល្បៈស្បែកជំ និងរាំកូរ៉ែ នៅទីតាំងក្បែរសាលាតំណាងគម្រោងជួសជុលប្រាសាទព្រះពិហារ។

២-នៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៨ ចាប់ពីម៉ោង ០៦:៣០នាទី ដល់ម៉ោង ០៨:៣០នាទីយប់ ដើម្បីសម្តែងសិល្បៈស្បែកជំ និងរាំកូរ៉ែ នៅដីប៉ឺរ៉ែនសង្កាត់-ឃុំខប្បងមីខាងក្បែងសាលាខេត្តសៀមរាប។

ដោយហេតុនេះ សូមអញ្ជើញលោកជំទាវ អស់លោក លោកស្រី ត្រប់ក្រសួង មន្ទីរ-អង្គភាព ស្ថាប័នជាតិ-អន្តរជាតិ សមាគមទីភ្នាក់ងារទេសចរណ៍ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ មគ្គុទ្ទេសក៍ទេសចរណ៍ ក្រុមហ៊ុនទេសចរណ៍ ភ្ញៀវទេសចរជាតិ-អន្តរជាតិ និងសាធារណជនទាំងអស់ មេត្តាជ្រាប និងចូលរួមឲ្យបានច្រើនកុះករ។

ថ្ងៃសុក្រ ១១ កើត ខែកត្តិក ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
សៀមរាប ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១៨
អគ្គនាយក

ចម្លងជូន:
- សាលាខេត្តសៀមរាប
- ស្នងការដ្ឋាននគរបាលខេត្តសៀមរាប
- ក្រប់ទីរ៉ឺស៊ីញ៉ូរខេត្តសៀមរាប
- ក្រប់ជាយការដ្ឋាននគរជាតិអប្សរា
- អគ្គភាពនគរបាលសហការនិងកណ្តាប ប្រចាំខេត្តសៀមរាប
- អគ្គភាពនគរបាលរដ្ឋបាលខេត្តសៀមរាប
- សមាគមទីភ្នាក់ងារទេសចរណ៍-សមាគមទេសណ៍
- សមាគមមគ្គុទ្ទេសក៍ទេសចរណ៍-មគ្គុទ្ទេសក៍ទេសចរណ៍
- សមាគមស្ត្រីអាជីពបរទេសក្នុងប្រទេសកម្ពុជា
- ឯកសារ-កាលប្បវត្តិ

រមណីយដ្ឋានអង្គរលែងប្រឈមនឹងបញ្ហាអសន្តិសុខ ប្រាសាទជួលរលំ និងការលួចឥតុបុរាណទៀតហើយ!

ផ្សាយនៅថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១៨

ថ្លែងក្នុងសន្ទរកថានៃកិច្ចប្រជុំបច្ចេកទេសលើកទី៣១ និងពេញអង្គលើកទី២៥នៃការបង្កើតគណៈកម្មាធិការអន្តរជាតិសម្របសម្រួលកិច្ចគាំពារនិងអភិវឌ្ឍន៍តំបន់អង្គរ ហៅកាត់ថាអាយស៊ីស៊ី-អង្គរ (ICC-Angkor) **លោកជំទាវ ភឿង សកុណា** រដ្ឋមន្ត្រី ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងជាប្រធានអាជ្ញាធរជាតិអប្សរា បានបង្ហាញពីគោលបំណងនៃការប្រារព្ធខួបលើកទី២៥ឆ្នាំ គឺដើម្បីរំឭកឡើងវិញនូវការប្តេជ្ញាចិត្តរបស់យើងទាំងអស់គ្នាកាលពី២៥ឆ្នាំមុន ក៏ដូចជាបង្ហាញពីភាពជោគជ័យដែលរាជរដ្ឋាភិបាលកម្ពុជានិងសហគមន៍អន្តរជាតិទទួលបាន ដោយជម្នះនូវបញ្ហាប្រឈមនានាដែលជួបប្រទះកន្លងមក ហើយដែលនឹងកំពុងដោះស្រាយជាមួយគ្នាទៅតាមមាគ៌ាដែលបានត្រួសត្រាយឱ្យបានសម្រេចតាមគោលដៅនាពេលខាងមុខ។

លោកជំទាវរដ្ឋមន្ត្រីបន្តទៀតថា បច្ចុប្បន្នរមណីយដ្ឋានបេតិកភណ្ឌពិភពលោក-អង្គរ លែងប្រឈមនឹងបញ្ហាអសន្តិសុខ ប្រាង្គប្រាសាទដួលរលំ ឬការលួចវត្ថុបុរាណទៀតហើយ។ ក៏ប៉ុន្តែយើងក៏ជួបប្រទះនឹងបញ្ហាប្រឈមមួយចំនួនផ្សេងទៀត ដូចជា ការប្រែប្រួលអាកាសធាតុ ការបំពុលបរិស្ថាន ការគ្រប់គ្រងការតាំងទីលំនៅថ្មីនៅក្នុងតំបន់ការពារនៃរមណីយដ្ឋានអង្គរ ការគ្រប់គ្រងលំហូរភ្ញៀវទេសចរ។ល។ ដែលចាំបាច់ត្រូវរកដំណោះស្រាយនិងវិធីសាស្ត្រទប់ទល់ឱ្យបានសមស្របនិងមានប្រសិទ្ធិភាពទាំងក្នុងបច្ចុប្បន្ននិងអនាគត។

តែក៏ជាសំណាងល្អដែលយើងមានក្រមប្រតិបត្តិអង្គរសម្រាប់ឱ្យភ្ញៀវទេសចរគ្រប់ជាតិសាសន៍គោរពតាម និងមានអង្គការធានាគុណភាពជប៉ុន (JQA) ដែលតែងធ្វើសវនកម្មផ្ទៃក្នុង/ក្រៅលើផ្នែកគ្រប់គ្រងប្រព័ន្ធបរិស្ថាននៅតំបន់អង្គរ រហូតទទួលបានវិញ្ញាបនបត្រធានាគុណភាពជប៉ុនដល់ទៅ៥លើកសម្រាប់អាជ្ញធរជាតិអប្សរា។ ប៉ុន្តែទោះជាយ៉ាងណាក៏យើងនៅតែបារម្ភនិងបន្តការខិតខំរកដំណោះស្រាយបន្តទៅទៀតលើបញ្ហាទាំងនេះបន្តផងដែរ។

ទាក់ទងនឹងការលើកឡើងពីបញ្ហាប្រាសាទលែងប្រឈមនឹងបញ្ហាគ្រោះថ្នាក់នោះ លោកជំទាវ ក៏បានឱ្យដឹង វាជាការផ្តើមចេញដ៏ល្អពីកិច្ចសហប្រតិបត្តិការជាតិនិងអន្តរជាតិ ចេញពីឫសគល់នៃក្តីស្រឡាញ់ និងស្មារតីនៃការថែរក្សាតំបន់អង្គរ ដែលគ្រប់គ្នាចាត់ទុកថាជាសម្បត្តិបេតិកភណ្ឌពិភពលោក ដែលមនុស្សជាតិទាំងអស់ត្រូវនាំគ្នាថែរក្សា។

ជាពិសេស គឺបានមកពីគណៈកម្មាធិការអាយស៊ីស៊ី-អង្គរ ដែលជាយន្តការអន្តរជាតិដើម្បីកៀងគរធនធានថវិកា ជំនាញបច្ចេកទេស និងធនធានមនុស្សពីសហគមន៍អន្តរជាតិដើម្បីធ្វើការជួសជុល អភិរក្ស និងលើកតម្លៃប្រាសាទនានា ក៏ដូចជាការអភិវឌ្ឍរមណីយដ្ឋានបេតិកភណ្ឌពិភពលោក-អង្គរដ៏ធំធេងនិងត្រូវការធនធានច្រើនក្នុងការអនុវត្តកិច្ចការនេះ។

ក្នុងបេសកម្មរបស់ដៃគូសហប្រតិបត្តិការអន្តរជាតិលើការអភិរក្សប្រាសាទក្នុងតំបន់អង្គរ ក៏បានផ្តល់នូវការរីកចម្រើនផ្នែកធនធានមនុស្សរបស់អាជ្ញាធរជាតិអប្សរាយ៉ាងច្រើន ដែលមកដល់ពេលនេះ ក៏មានប្រាសាទមួយចំនួនជួសជុលដោយអ្នកជំនាញខ្មែរផ្ទាល់តែម្តង។

នេះជាឱកាសដ៏ពិសេសដែលអាជ្ញាធរជាតិអប្សរាបានពង្រឹងសមត្ថភាពខ្លួនជាមួយនឹងដៃគូអន្តរជាតិ ក្នុងការស្រោចស្រង់ប្រាសាទក្នុងតំបន់អង្គរឱ្យរួចផុតពីគ្រោះថ្នាក់បាន៕






អគ្គនាយិកាអង្គការយូណេស្កូ អញ្ជើញទស្សនកិច្ចរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១៨

ឆ្លៀតក្នុងឱកាសអញ្ជើញទស្សនកិច្ចនៅខេត្តសៀមរាបរយៈពេល២ថ្ងៃ ពីថ្ងៃទី៤-៥ ខែធ្នូ ឆ្នាំ២០១៨ ដើម្បីចូលរួមជាអធិបតីក្នុងពិធីបើកជាផ្លូវការខួបលើកទី ២៥ឆ្នាំ នៃការបង្កើតគណៈកម្មាធិការអន្តរជាតិ អាយស៊ីស៊ី-អង្គរ និងកិច្ចប្រជុំបច្ចេកទេសលើកទី៣១ កិច្ចប្រជុំពេញអង្គលើកទី២៥ នៃអាយស៊ីស៊ី-អង្គរ **លោកជំទាវ** Audrey AZOULAY អគ្គនាយិកាយូណេស្កូ បានធ្វើទស្សនកិច្ចតាមការដ្ឋានជួសជុលតាមប្រាសាទមួយចំនួនក្នុងរមណីយដ្ឋានអង្គរ ដោយមានការអមដំណើរដោយ **ឯកឧត្តម ហង់ ពៅ** អគ្គនាយករងនៃអាជ្ញាធរជាតិអប្សរា និងមន្ត្រីមួយចំនួននៃអង្គការយូណេស្កូ។

នារសៀលថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៨ លោកជំទាវ បានអញ្ជើញស្វែងយល់ពីការជួសជុលនៅការដ្ឋានមួយចំនួនក្នុងប្រាសាទអង្គរវត្តដូចជា ការដ្ឋានសាកលវិទ្យាល័យសូហ្វីយ៉ា របស់ប្រទេសជប៉ុន និងការដ្ឋានគម្រោងអភិរក្សអាល្លឺម៉ង់-អប្សរា (GACP) ប្រទេសអាល្លឺម៉ង់ ពិសេសគម្រោងអភិរក្ស ជួសជុលរបស់អាជ្ញាធរជាតិអប្សរានៅអង្គរវត្ត។ ដោយឡែក នៅព្រឹកថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១៨ លោកជំទាវ បានអញ្ជើញពិនិត្យការដ្ឋានជប៉ុន-អប្សរា (JASA) នៅប្រាសាទបាយ័ន្ត ការដ្ឋានរបស់ប្រទេសឥណ្ឌា (ASI) នៅប្រាសាទតាព្រហ្ម និងចុះពិនិត្យការងារគ្រប់គ្រងទឹករបស់អាជ្ញាធរជាតិអប្សរានៅប្រាសាទនាគព័ន្ធ។

ក្រៅពីការទស្សនានៅតាមប្រាង្គប្រាសាទហើយនោះ លោកជំទាវអគ្គនាយិកា និងថ្នាក់ដឹកនាំនៃអាជ្ញាធរជាតិអប្សរាក៏បានពិភាក្សា ពន្យល់ ទៅលើការងារគ្រប់គ្រង ការអភិរក្សទូទៅ និងការបណ្តុះបណ្តាលធនធានមនុស្ស។

លើសពីនោះទៀត លោកជំទាវក៏មានចំណាប់អារម្មណ៍ចំពោះភ្ញៀវទេសចរដែលមកទស្សនាតំបន់អង្គរ ពិសេសគឺមកតែវប្បធម៌អូបី ដោយបានស្វែងយល់ពីប្រពៃណី ទំនៀមទម្លាប់ ប្រាសាទការធ្វើបុណ្យ ការគោរពបូជាព្រះ ការដោះស្បែកជើងពេលដើរលើប្រាសាទ ដោយសង្កត់ធ្ងន់ថា ចំពោះភ្ញៀវទេសចរខ្មែរមិនមែនមកទស្សនាតែប្រាសាទទេ គឺមកដើម្បីបានគោរពបូជាព្រះ។ ដូច្នេះអង្គរមិនស្លាប់ទេ គឺនៅតែមានការគោរពបូជាយ៉ាងខ្ជាប់ខ្ជួនពីប្រជាជនខ្មែរ៕









អាជ្ញាធរជាតិអប្សរានិងភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA) ចុះអនុស្សារណៈយោគយល់ក្នុងបន្តជួសជុលក្រុមប្រាសាទព្រះពិធូរ និងលានដល់ជំរឹ

ផ្សាយនៅថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១៨

នាព្រឹកថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៨ នៅក្នុងកិច្ចប្រជុំពេញអង្គលើកទី២៥ របស់អាយស៊ីស៊ី-អង្គរ នាសាលសន្និសីទសុខាសៀមរាប បានប្រារព្ធពិធីចុះអនុស្សារណៈយោគយល់គ្នា ដើម្បីបន្តជួសជុល អភិរក្សក្រុមប្រាសាទព្រះពិធូរ និងលានដល់ជំរឹនៅក្នុងទីក្រុងអង្គរធំ ក្រោមអធិបតីភាព **ឯកឧត្តមបណ្ឌិត ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងជាប្រធានអាជ្ញាធរជាតិអប្សរា សហប្រធានអាយស៊ីស៊ី-អង្គរ រួមទាំងអ្នកជំនាញជាតិនិងអន្តរជាតិជាច្រើនទៀត។

ពិធីនេះត្រូវបានចុះហត្ថលេខាដោយ **ឯកឧត្តមបណ្ឌិត ស៊ុំ ម៉ាប់** អគ្គនាយកអាជ្ញាធរជាតិអប្សរា និង **ឯកឧត្តម** Jeong Yungil នាយកប្រតិបត្តិភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA) តំណាងឱ្យភាគីកូរ៉េ។ តាមខ្លឹមសារនៃអនុស្សារណៈ គម្រោងជួសជុលក្រុមប្រាសាទព្រះពិធូរ និងលានដល់ជំរឹមានរយៈពេល៥ឆ្នាំ ដោយអនុវត្តការងារពីឆ្នាំ២០១៩ ដល់ ២០២៣ ដែលប្រើប្រាស់ថវិកាសរុប៧លានដុល្លារ។

សូមបញ្ជាក់ថា ការជួសជុលក្រុមប្រាសាទព្រះពិធូរដំហានទី១បានបញ្ចប់ដោយជោគជ័យនៅចុងឆ្នាំ២០១៨ ហើយនៅថ្ងៃទី ១៦-២១ កញ្ញា ២០១៨ អ្នកជំនាញរបស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ KOICA បានចុះមកពិនិត្យមើលការងារបច្ចេកទេស លទ្ធភាពក្នុងការជួសជុល និងប្រមូលផ្តុំព័ត៌មានផ្សេងៗ មុននឹងសម្រេចបន្តកិច្ចសហប្រតិបត្តិការនេះឡើង។

ការកិច្ចសំខាន់ៗក្នុងកិច្ចសហប្រតិបត្តិការនេះ គឺអភិរក្សជួសជុលប្រាសាទជាំ សិក្សាពីចំណុចហានិភ័យខ្ពស់នៅតាមប្រាសាទក្នុងក្រុមប្រាសាទព្រះពិធូ ជួសជុលផ្នែកខ្លះនៃលានដល់ដំរី រួមទាំងផ្តល់សម្ភារៈក្នុងដំណើរការជួសជុលក្នុងគម្រោង ព្រមទាំងបណ្តុះបណ្តាលធនធានមនុស្សលើផ្នែកអភិរក្សបេតិកភណ្ឌវប្បធម៌ដល់អ្នកជំនាញអាជ្ញាធរជាតិអប្សរា៕









សេចក្តីប្រកាសព័ត៌មានលទ្ធផលកិច្ចប្រជុំបច្ចេកទេសលើកទី៣១ និងពេញអង្គលើកទី២៤ នៃគណៈកម្មាធិការអន្តរជាតិសម្របសម្រួលកិច្ចគាំពារនិងអភិវឌ្ឍន៍រមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ

ផ្សាយនៅថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១៨

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរអប្សរា
APSARA
លេខ ១៣៩៤/១៨ រប.សម៣

សេចក្តីប្រកាសព័ត៌មាន

លទ្ធផលកិច្ចប្រជុំបច្ចេកទេសលើកទី៣១ និងពេញអង្គលើកទី២៥ នៃគណៈកម្មាធិការអន្តរជាតិ
សម្របសម្រួលកិច្ចគាំពារនិងអភិវឌ្ឍន៍រមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ (អាយស៊ីស៊ី-អង្គរ)
ថ្ងៃអង្គារ-ពុធ ១២-១៣រោច ខែកត្តិក ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
ត្រូវនឹងថ្ងៃទី៤-៥ ខែធ្នូ ឆ្នាំ២០១៨

កិច្ចប្រជុំបច្ចេកទេសលើកទី៣១ និងកិច្ចប្រជុំពេញអង្គលើកទី២៥ នៃគណៈកម្មាធិការអន្តរជាតិដើម្បីសម្របសម្រួលកិច្ចគាំពារនិងអភិវឌ្ឍន៍តំបន់រមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ (អាយស៊ីស៊ី-អង្គរ) ប្រព្រឹត្តទៅនៅថ្ងៃអង្គារ-ពុធ ១២-១៣រោច ខែកត្តិក ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី៤-៥ ខែធ្នូ ឆ្នាំ២០១៨ ក្រោមពិធីបើកជាផ្លូវការដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង បិទជាផ្លូវការក្រោមព្រះរាជាធិបតីភាពដ៏ថ្លៃថ្លាបំផុតរបស់ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថនរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា នាសាលសន្នីសិទសុខាសៀមរាប ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

១. **លោកជំទាវ** Audrey AZOULAY អគ្គនាយិកាអង្គការយូណេស្កូ បានវាយតម្លៃខ្ពស់ចំពោះជោគជ័យរបស់គណៈកម្មាធិការ អាយស៊ីស៊ី-អង្គរ រយៈពេល២៥ឆ្នាំកន្លងមក ហើយបានចាត់ទុកយន្តការនេះជាយន្តការគំរូសម្រាប់ពិភពលោកទាំងមូលលើកិច្ចការសហប្រតិបត្តិការអន្តរជាតិលើកិច្ចការងារអភិរក្សបេតិកភណ្ឌវប្បធម៌។ **លោកជំទាវ** Audrey AZOULAY ក៏បានប្រគល់វិញ្ញាបនបត្របញ្ជាក់ពីការចុះបញ្ជីល្ខោនខោល(វត្តស្វាយអណ្តែត) ជាបេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិរបស់អង្គការយូណេស្កូ កាលពីថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ នាទីក្រុងព័រល្វី សាធារណរដ្ឋម៉ូរីជូន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

២. **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានអបអរសាទរចំពោះជោគជ័យ និងសម្តែងនូវការវាយតម្លៃខ្ពស់ដល់អាយស៊ីស៊ី-អង្គរ ព្រមទាំងថ្លែងអំណរគុណដល់គ្រប់ដៃគូអន្តរជាតិទាំងអស់ ដែលបានចូលរួមយ៉ាងសកម្មក្នុងកិច្ចការអភិរក្ស និងអភិវឌ្ឍន៍ប្រកបដោយចីរភាពរមណីយដ្ឋានអង្គរ។ **សម្តេច** ក៏បានអំពាវនាវដល់ប្រទេសជាមិត្ត ដៃគូអភិវឌ្ឍន៍ និងអន្តរជាតិ សូមបន្តជួយគាំទ្រទាំងបច្ចេកទេស ហិរញ្ញវត្ថុ និងធនធានមនុស្ស ហើយក្រសួងស្ថាប័នពាក់ព័ន្ធ និងប្រជាជនកម្ពុជាទាំងអស់ ត្រូវចូលរួមសហការគ្នាឱ្យបានល្អ ដើម្បីភាពជោគជ័យក្នុងការការពារ និងអភិរក្សបេតិកភណ្ឌវប្បធម៌មនុស្សជាតិ និងរមណីយដ្ឋានអង្គរ ពោល

ភ្ជំពេញ:
មហាវិថីសហពន្ធរុស្ស៊ី លេខ៥១ សង្កាត់ទ៉ិត្តភាព ខណ្ឌ៧មករា
ទូរសព្ទ/ទូរសារ៖ ០៦៣ ២១៥ ៧៧១/០៦៣ ២១៥ ៧៧៦
អាជ្ញាធរដើម្បីការពាររមណីយដ្ឋាននិងរៀបចំតំបន់អង្គរ
Email: info@apsaraauthority.gov.kh
Website: http://www.apsaraauthority.gov.kh
សៀមរាប:
ភូមិបង្កោង ឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប
ទូរសព្ទ/ទូរសារ៖ ០៦៣ ៧៦៥ ៥៧៧/០៦៣ ៧៦៥ ៥៧៦

គឺធ្វើដើម្បីយើងទាំងអស់គ្នា។ បន្ថែមលើនេះ **សម្តេច** បានផ្តល់សារដល់បណ្តាគណបក្សនយោបាយមួយចំនួននៅកម្ពុជា ក៏ដូចជាបុគ្គលខ្លះៗ កុំឱ្យមានការញុះញង់ប្រជាពលរដ្ឋ ឬធ្លៀតឱកាសទៅកាន់កាប់តំបន់បេតិកភណ្ឌ ដែលមិនគ្រាន់តែតំបន់បេតិកភណ្ឌដែលបានចុះទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោកប៉ុណ្ណោះទេ ប៉ុន្តែក៏មានប្រាង្គប្រាសាទច្រើនទៀតនៅក្នុងប្រទេសកម្ពុជា ដែលត្រៀមបំរុងដាក់បញ្ចូលបណ្តើរៗទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក។

៣. ចុះហត្ថលេខាលើកិច្ចព្រមព្រៀងសហប្រតិបត្តិការរវាងអង្គការយូណេស្កូ និងអង្គការអាយកាប់/ក្រុមប្រឹក្សាវប្បធម៌អាស៊ី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

៤. ចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នារវាងអាជ្ញាធរជាតិអប្សរា ជាមួយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA) អំពីគម្រោងអភិរក្សនិងជួសជុលក្រុមប្រាសាទព្រះពិធូរ និងព្រះលានជល់ជំរី។

៥. អបអរសាទរលទ្ធផលដ៏ត្រចះត្រចង់នៃជំណើរការ២៥ឆ្នាំ របស់គណៈកម្មាធិការអាយស៊ីស៊ី-អង្គរ ដែលបានគៀងគរធនធានថវិកា ជំនាញបច្ចេកទេស និងធនធានមនុស្សពីសហគមន៍អន្តរជាតិ ដើម្បីធ្វើការជួសជុល អភិរក្ស និងលើកតម្លៃរមណីយដ្ឋានអង្គរ (សាកលវិទ្យាល័យសូហ្វីយ៉ា ប្រទេសជប៉ុន ចាប់តាំងពីឆ្នាំ១៩៩៣, JASA ប្រទេសជប៉ុន រយៈពេល២៥ឆ្នាំ, EFEO ប្រទេសបារាំង ២៥ឆ្នាំ, GACP ប្រទេសអាល្លឺម៉ង់ ២៥ឆ្នាំ, WMF សហរដ្ឋអាមេរិច ២៥ឆ្នាំ, CSA ប្រទេសចិន២០ឆ្នាំ, ASI ប្រទេសឥណ្ឌា ១៣ឆ្នាំ ។ល។)

៦. កោតសរសើរ និងវាយតម្លៃខ្ពស់ដល់សមត្ថភាពមន្ត្រីជំនាញកម្ពុជា ដែលទទួលបានការបណ្តុះបណ្តាលនាពេលកន្លងមក ហើយកំពុងតែក្លាយជាអ្នកដឹកនាំគម្រោងជួសជុល និងអភិរក្សផ្សេងៗ ក្នុងតំបន់អង្គរប្រកបដោយប្រសិទ្ធភាពខ្ពស់។

៧. ពង្រីកលទ្ធភាពប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ ក្នុងកិច្ចការអភិរក្ស ស្រាវជ្រាវ និងអភិវឌ្ឍប្រកបដោយចីរភាពក្នុងរមណីយដ្ឋានអង្គរដូចជា LiDAR , ICONEM។

៨. រម្លឹកនូវគុណូបការៈរបស់ឥស្សរជនជាតិ ពិសេស **សម្តេចឫទ្ធិបុលបញ្ញា សុខ អាន ឯកឧត្តម ឫទ្ធិ មូលីឫទ្ធិ** អតីតប្រធានអាជ្ញាធរជាតិអប្សរា និងឥស្សរជនជាតិ-អន្តរជាតិនានាព្រមទាំងសមាជិកអាយស៊ីស៊ី-អង្គរ ទាំងអស់ដែលបានលះបង់កម្លាំងកាយ ប្រាជ្ញា ស្មារតី រហូតដល់ចុងបញ្ចប់នៃអាយុជីវិតរបស់ខ្លួនដើម្បីសេចក្តីស្រឡាញ់ និងកិច្ចការពារបេតិកភណ្ឌវប្បធម៌ពិភពលោកជាពិសេសរមណីយដ្ឋានអង្គរ ដែលជារតនវត្ថុរបស់មនុស្សជាតិទាំងមូល។

ថ្ងៃ ពុធ ១៣រោច ខែ កត្តិក ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
សៀមរាប ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ២០១៨
អាជ្ញាធរជាតិអប្សរា

កិច្ចប្រជុំ អាយស៊ីស៊ី-អង្គរ រយៈពេល២ថ្ងៃទទួលបានលទ្ធផលគួរឱ្យមោទនភាព

ផ្សាយនៅថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១៨

កិច្ចប្រជុំបច្ចេកទេសលើកទី៣១ និងពេញអង្គលើកទី២៥ នៃគណៈកម្មាធិការអន្តរជាតិសម្របសម្រួលការគាំពារ និងអភិវឌ្ឍន៍រមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ ហៅកាត់ថា អាយស៊ីស៊ី-អង្គរ រយៈពេល២ថ្ងៃ គឺចាប់ពីថ្ងៃទី៤-៥ ខែធ្នូ ឆ្នាំ២០១៨ បានបិទបញ្ចប់ជាមួយនឹងលទ្ធផលដ៏គួរឱ្យមោទនភាព។ កិច្ចប្រជុំ ដែលអមជាមួយនឹងការប្រារព្ធខួប ២៥ឆ្នាំ របស់អាយស៊ីស៊ី-អង្គរ ដែលមានការចូលរួមពីព្រះវត្តមានដ៏ថ្លៃថ្លារបស់ **ព្រះករុណាព្រះបាទ សម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានសាទរពីភ្ញៀវជាតិ និងអន្តរជាតិ។

លទ្ធផលដែលទទួលបានពីការប្រារព្ធខួប ២៥ឆ្នាំ នៃការបង្កើតអាយស៊ីស៊ី-អង្គរ កិច្ចប្រជុំបច្ចេកទេសលើកទី៣១ និងពេញអង្គ២៥ រួមមាន **លោកជំទាវ** Audrey AZOULAY អគ្គនាយិកាអង្គការយូណេស្កូ បានវាយតម្លៃខ្ពស់ចំពោះជោគជ័យរបស់គណៈកម្មាធិការ អាយស៊ីស៊ី-អង្គរ រយៈពេល២៥ឆ្នាំកន្លងមក ហើយបានចាត់ទុកយន្តការនេះជាយន្តការគំរូសម្រាប់ពិភពលោកទាំងមូលលើកិច្ចការសហប្រតិបត្តិការអន្តរជាតិលើ កិច្ចការងារអភិរក្សបេតិកភណ្ឌវប្បធម៌។ **លោកជំទាវ** Audrey AZOULAY ក៏បានប្រគល់វិញ្ញាបនបត្របញ្ជាក់ពីការចុះបញ្ជីល្ងោនខោល (វត្តស្វាយអណ្តែត) ជាបេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្ស ជាតិរបស់អង្គការយូណេស្កូ កាលពីថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ នាទីក្រុងព័រល្វី សាធារណរដ្ឋម៉ូរី ជូន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន បានអបអរសាទរចំពោះជោគជ័យ និងវាយតម្លៃខ្ពស់ដល់អាយស៊ីស៊ី-អង្គរ ព្រមទាំងថ្លែងអំណរគុណដល់គ្រប់ដៃគូអន្តរជាតិទាំងអស់ ដែលចូលរួមយ៉ាងសកម្មក្នុងកិច្ចការអភិរក្ស និងអភិវឌ្ឍន៍ប្រកបដោយចីរភាពរមណីយដ្ឋានអង្គរ។ ព្រមជាមួយគ្នានេះ សម្តេចក៏បានអំពាវនាវដល់ប្រទេសជាមិត្ត ដៃគូអភិវឌ្ឍន៍ និងអន្តរជាតិ បន្តជួយគាំទ្រទាំងបច្ចេកទេស ហិរញ្ញវត្ថុ និងធនធានមនុស្ស ហើយស្ថាប័នពាក់ព័ន្ធ និងប្រជាជនកម្ពុជា ត្រូវចូលរួមសហការគ្នាឱ្យបានល្អ ដើម្បីបេតិកភណ្ឌវប្បធម៌ជាតិ។ បន្ថែមពីនេះទៀត ប្រមុខរាជរដ្ឋាភិបាល បានផ្តល់សារដល់បណ្តាគណបក្សនយោបាយមួយចំនួននៅកម្ពុជា ក៏ដូចជាបុគ្គលមួយចំនួន កុំឱ្យញុះញង់ប្រជាពលរដ្ឋ ឬឆ្លៀតឱកាសទៅកាន់កាប់តំបន់បេតិកភណ្ឌ ទាំងតំបន់ដែលបានចុះក្នុងបញ្ជីបេតិកភណ្ឌ និងតំបន់ប្រាសាទដែលបម្រុងចុះបញ្ជីនាពេលអនាគត។

ក្រៅពីនេះ ក៏មានចុះហត្ថលេខាលើកិច្ចព្រមព្រៀងសហប្រតិបត្តិការរវាងអង្គការយូណេស្កូ និងអង្គការអាលកាប់/ក្រុមប្រឹក្សាវប្បធម៌អាស៊ី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**។ កិច្ចប្រជុំនោះដែរ ក៏បានចុះអនុស្សរណៈនៃការយោគយល់គ្នារវាងអាជ្ញាធរជាតិអប្សរា ជាមួយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA) អំពីគម្រោងអភិរក្ស និងជួសជុលក្រុមប្រាសាទព្រះពិធូរ និងព្រះលានដល់ដំរី។

ជាមួយគ្នានោះដែរ កិច្ចប្រជុំបានអបអរសាទរចំពោះលទ្ធផលដ៏ត្រចះត្រចង់នៃដំណើរការ ២៥ឆ្នាំ របស់អាយស៊ីស៊ី-អង្គរ ដែលបានគៀងគរធនធានថវិកា ជំនាញបច្ចេកទេស និងធនធានមនុស្សពីសហគមន៍អន្តរជាតិ ដើម្បីធ្វើការជួសជុល អភិរក្ស និងលើកតម្លៃរមណីយដ្ឋានអង្គរ (សាកលវិទ្យាល័យសូហ្វីយ៉ា ប្រទេសជប៉ុន ចាប់តាំងពីឆ្នាំ១៩៩៣, JASA ប្រទេសជប៉ុន រយៈពេល២៥ឆ្នាំ, EFEO ប្រទេសបារាំង ២៥ឆ្នាំ, GACP ប្រទេសអាល្លឺម៉ង់ ២៥ឆ្នាំ, WMF សហរដ្ឋអាមេរិច ២៥ឆ្នាំ,

CSA ប្រទេសចិន២០ឆ្នាំ, ASI ប្រទេសឥណ្ឌា ១៣ឆ្នាំ ។ល។ កិច្ចប្រជុំបានវាយតម្លៃខ្ពស់ដល់សមត្ថភាពមន្ត្រីជំនាញកម្ពុជា ដែលទទួលបានការបណ្តុះបណ្តាលនាពេលកន្លងមក ហើយកំពុងក្លាយជាអ្នកដឹកនាំគម្រោងជួសជុល និងអភិរក្សផ្សេងៗ ក្នុងតំបន់អង្គរប្រកបដោយប្រសិទ្ធភាពខ្ពស់។ ក្នុងនោះដែរ ក៏មានការឯកភាពគ្នាលើការពង្រីកលទ្ធភាពប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ ក្នុងកិច្ចការអភិរក្ស ស្រាវជ្រាវ និងអភិវឌ្ឍន៍ប្រកបដោយចីរភាពក្នុងរមណីយដ្ឋានអង្គរ ដូចជា LiDAR និង ICONEM។

កិច្ចប្រជុំក៏បានរម្លឹកដល់គុណូបការៈរបស់ឥស្សរជនជាតិ ពិសេស **សម្តេចវិបុលបញ្ញា សុខ អាន ឯកឧត្តម ឥណ្ណ មូលី ឥណ្ណ** អតីតប្រធានអាជ្ញាធរជាតិអប្សរា និងឥស្សរជនជាតិ-អន្តរជាតិនានា ព្រមទាំងសមាជិកអាយស៊ីស៊ី-អង្គរ ដែលបានលះបង់កម្លាំងកាយ ប្រាជ្ញា ស្មារតី រហូតដល់ចុងបញ្ចប់នៃអាយុជីវិតរបស់ខ្លួន ដើម្បីសេចក្តីស្រឡាញ់ និងកិច្ចការពារបេតិកភណ្ឌវប្បធម៌ពិភពលោក ជាពិសេសរមណីយដ្ឋានអង្គរ ដែលជារតនវត្ថុរបស់មនុស្សជាតិទាំងមូល៕









ថ្នាក់ដឹកនាំនៃអាជ្ញាធរជាតិអប្សរាចូលរួមថ្វាយយាងនិវត្តរបស់ព្រះមហាក្សត្រ និងព្រះមហាក្សត្រី

ផ្សាយនៅថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១៨

នៅព្រឹកថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១៨ ថ្នាក់ដឹកនាំនៃអាជ្ញាធរជាតិអប្សរាមានកិត្តិយសដោយបានចូលរួមថ្វាយបដិសណ្ឋារកិច្ច និងថ្វាយដំណើរយាងនិវត្តរបស់ **ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី** និង **សម្តេច មហាក្សត្រី នរោត្តម មុនីនាថ សីហនុ** តាមព្រះទីនាំងពិសេសត្រឡប់ទៅរាជធានីភ្នំពេញវិញបន្ទាប់ពីបំពេញព្រះរាជកិច្ចដ៏ថ្លៃថ្លាមួយចំនួននៅខេត្តសៀមរាប។

យើងខ្ញុំទាំងអស់គ្នា ជាថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិក កម្មករគ្រប់ជាន់ថ្នាក់ សូមថ្លែងអំណរព្រះគុណដ៏ជ្រាលជ្រៅចំពោះព្រះវត្តមានដ៏ខ្ពស់ខ្ពស់របស់ **ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ដែលព្រះអង្គសព្វព្រះរាជហារទ័យ យាងចូលរួមជាអធិបតីភាពក្នុងព្រះរាជពិធីអបអរសាទរខួប ២៥ឆ្នាំ នៃការបង្កើតគណៈកម្មាធិការអន្តរជាតិសម្របសម្រួលការគាំពារ និងអភិវឌ្ឍន៍តំបន់រមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ ហៅកាត់ថា អាយស៊ីស៊ី-អង្គរ និងពិធីលៀងសាយភោជ នៅព្រះលានជល់ដំរី នៅយប់ថ្ងៃទី ៥ ខែធ្នូ ឆ្នាំ២០១៨។ យើងខ្ញុំទាំងអស់គ្នាសូមក្រាបថ្វាយព្រះពរ សូមស្តេចយាងប្រកបដោយព្រះសុវត្តិភាព។









ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហាមុនី សព្វព្រះរាជហប្ញទ័យស្តេចយាងជាព្រះរាជាធិបតីដ៏ខ្ពង់ខ្ពស់បំផុត ក្នុងព្រះរាជពិធីបិទអបអរសាទរខួប២៥ឆ្នាំ អាយស៊ីស៊ី-អង្គរ និងព្រះរាជពិធីលៀងសាយភោជន៍ នាព្រះលានជល់ជ័រ

ផ្សាយនៅថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១៨

នេះជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនារាត្រីថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១៨ ដែលព្រះករុណាជាម្ចាស់ជីវិតតម្កល់លើត្បូង **ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហាមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ព្រះអង្គសព្វព្រះរាជហប្ញទ័យស្តេចយាងជាព្រះរាជាធិបតីដ៏ខ្ពង់ខ្ពស់បំផុត ក្នុងព្រះរាជពិធីបិទអបអរសាទរខួប២៥ឆ្នាំនៃការបង្កើតអាយស៊ីស៊ី-អង្គរ និងព្រះរាជពិធីលៀងសាយភោជន៍ នៅព្រះលានជល់ជ័រ ក្រុងអង្គរធំ ខេត្តសៀមរាប។

ក្នុងព្រះរាជពិធីដ៏ឧត្តុង្គឧត្តមនេះ ក៏មានការអញ្ជើញចូលរួមពីបណ្តាឥស្សរជនជាន់ខ្ពស់នៃរាជរដ្ឋាភិបាលកម្ពុជា អគ្គនាយិកាអង្គការយូនីស្កូ សហប្រធានអាយស៊ីស៊ី-អង្គរ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ អាជ្ញាធរជាតិអប្សរា និងអ្នកជំនាញជាន់ខ្ពស់ជាតិ-អន្តរជាតិជាច្រើនរូប។

មានព្រះរាជបន្ទូលដ៏ថ្លៃថ្លាក្នុងសន្ទរកថានៃព្រះរាជពិធីបិទអបអរសាទរខួប២៥ឆ្នាំនៃអាយស៊ីស៊ី-អង្គរនារាត្រីនោះ **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហាមុនី** បានរំឭកអំពីព្រះរាជកិច្ចរបស់ព្រះបរមរតនកោដ្ឋក្នុងបុព្វហេតុស្វែងរកសន្តិភាពជូនជាតិ និងការអំពាវនាវដល់អង្គការយូណេស្កូ ព្រមទាំងបណ្តាប្រទេសជាមិត្ត ដើម្បីជួយស្រោចស្រង់អង្គរឱ្យរួចផុតពីគ្រោះថ្នាក់។

ព្រះអង្គមានព្រះរាជបន្ទូលថា កិច្ចការអភិរក្សនិងអភិវឌ្ឍន៍បេតិកភណ្ឌ ជាកិច្ចការគ្មានទីបញ្ចប់ ដែលទាមទារឱ្យមានការចូលរួមពីគ្រប់មជ្ឈដ្ឋានជាតិនិងអន្តរជាតិ ជាពិសេសគឺស្រទាប់យុវជនជាអ្នកបន្តវេន។ ជាក់ស្តែង ធនធានមនុស្សក្នុងវិស័យអភិរក្សនិងស្រាវជ្រាវរបស់កម្ពុជាកំពុងឈានមុខ ក្នុងចំណោមបណ្តាប្រទេសអាស៊ីអាគ្នេយ៍ ហើយរមណីយដ្ឋានអង្គរ បានក្លាយជាទីតាំងបុរាណវិទ្យាដ៏ធំជាងគេរបស់យូណេស្កូសម្រាប់កិច្ចការបណ្តុះបណ្តាលធនធានមនុស្សលើវិស័យនេះ។

អង្គព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាក៏បានវាយតម្លៃខ្ពស់ចំពោះអាយស៊ីស៊ី-អង្គរ ដែលបានផ្តល់នូវអនុសាសន៍ដ៏មានសារៈសំខាន់ក្នុងការជំរុញកិច្ចការអភិរក្ស ស្រាវជ្រាវ បណ្តុះបណ្តាល និងអភិវឌ្ឍន៍រមណីយដ្ឋានអង្គរប្រកបដោយចីរភាព តាមរយៈយន្តការដែលបានក្លាយជាគំរូអន្តរជាតិរបស់អង្គការយូណេស្កូនេះ។ អាយស៊ីស៊ី-អង្គរបានគៀងគរការចូលរួមកាន់តែច្រើនឡើងពីគ្រប់អ្នកជំនាញមកពីជុំវិញពិភពលោក ដែលបច្ចុប្បន្នបាននិងកំពុងស្នើសុំកិច្ចសហប្រតិបត្តិការជាបន្តបន្ទាប់ជាមួយអាជ្ញាធរជាតិអប្សរាក្នុងការអភិរក្ស ស្រាវជ្រាវ បណ្តុះបណ្តាល និងអភិវឌ្ឍន៍។

នាឱកាសដ៏ថ្លៃថ្លានោះដែរ ព្រះអង្គក៏បានថ្លែងអំណរគុណនិងកោតសរសើរខ្ពស់ដល់កិច្ចខិតខំប្រឹងប្រែងអស់កម្លាំងកាយចិត្តរបស់ដៃគូអភិវឌ្ឍន៍ជាតិ-អន្តរជាតិ ព្រមទាំងមន្ត្រី-បុគ្គលិកគ្រប់លំដាប់ថ្នាក់នៃអាជ្ញាធរជាតិអប្សរា ដែលលះបង់ពេលវេលាប្រាជ្ញា ស្មារតី ដែលខំពុះពារក្សាតម្លៃលេចធ្លោជាសាកលរបស់រមណីយដ្ឋានអង្គរជាបេតិកភណ្ឌពិភពលោកឱ្យស្ថិតស្ថេរគង់វង្ស និងលើភារកិច្ចដឹកនាំប្រកបដោយការទទួលខុសត្រូវខ្ពស់ ឱ្យរមណីយដ្ឋានអង្គរកាន់តែល្បីល្បាញលើពិភពលោក។ ជោគជ័យកន្លងមកនេះ ក៏បានបង្ហាញពីការអនុវត្តគោលនយោបាយវប្បធម៌ជាតិដ៏ត្រឹមត្រូវរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលជានិច្চকាលតែងយកចិត្តទុកដាក់ខ្ពស់ក្នុងការការពារ អភិរក្ស និងអភិវឌ្ឍន៍មរតកវប្បធម៌ជាតិ។

ពិសេសប្រទេសបារាំងនិងជប៉ុន ដែលក្នុងរយៈពេល២៥ឆ្នាំកន្លងមកនេះ ក្នុងនាមជាសហប្រធាន បានដឹកនាំកិច្ចប្រជុំពេញអង្គនិងកិច្ចប្រជុំបច្ចេកទេសដោយស្មារតីទទួលខុសត្រូវខ្ពស់ រួមចំណែកយ៉ាងធំធេង ដល់ភាពជោគជ័យនៃអាយស៊ីស៊ី-អង្គរ។ អង្គការយូណេស្កូ តាមរយៈស្ថានដំណើររបស់ខ្លួនប្រចាំព្រះរាជាណាចក្រកម្ពុជា បានដឹកនាំសម្របសម្រួលសំដៅធ្វើយ៉ាងណាឱ្យកិច្ចការអភិរក្សនិងការអភិវឌ្ឍន៍រមណីយដ្ឋានអង្គរ អនុលោមទៅតាមក្រមសីលធម៌និងបទដ្ឋានបេតិកភណ្ឌវប្បធម៌ក្នុងរយៈពេល២៥ឆ្នាំកន្លងមកនេះ អង្គការយូណេស្កូក៏នៅតែបន្តគាំទ្រនូវរាល់សកម្មភាពរបស់លេខាធិការដ្ឋានអចិន្ត្រៃយរបស់អាយស៊ីស៊ី-អង្គរផងដែរ។

ជាថ្មីម្តងទៀត ព្រះករុណាព្រះមហាក្សត្រ ក៏សង្ឃឹមថា អាយស៊ីស៊ី-អង្គរនឹងបន្តមានដំណើរការល្អ បំពេញភារកិច្ចរបស់ខ្លួនទទួលបានជោគជ័យដ៏ធំធេងក្នុងការងារអភិរក្សនិងអភិវឌ្ឍន៍រមណីយដ្ឋានអង្គរ ព្រមទាំងបេតិកភណ្ឌវប្បធម៌ និងធម្មជាតិពាក់ព័ន្ធផ្សេងៗទៀត សម្រាប់ជាអភិវឌ្ឍន៍ប្រទេស៕









អាជ្ញាធរជាតិអប្សរានិងភ្ញាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េសម្តែងសិល្បៈទប្បជមី អបអរការបញ្ចប់កម្រោងជួសជុលប្រាសាទព្រះពិធូរជំហានទី១

ផ្សាយនៅថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០១៨

នារាត្រីថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៨ សិល្បៈស្បែកជំនួនិងសិល្បៈ Arirang របស់កូរ៉េ ដែលជាបេតិកភណ្ឌវប្បធម៌អរូបីសម្រាប់មនុស្សជាតិត្រូវបានបង្ហាញរួមគ្នា ដើម្បីអបអរការបញ្ចប់គម្រោងជួសជុលក្រុមប្រាសាទព្រះពិធូរជំហានទី១។

កម្មវិធីនេះអញ្ជើញចូលរួមក្រោមអធិបតីភាព**ឯកឧត្តមបណ្ឌិត ស៊ុំ ម៉ាប់** អគ្គនាយកអាជ្ញាធរជាតិអប្សរា **លោកសាស្ត្រាចារ្យ** Azedine Beschaouch អគ្គលេខាធិការវិទ្យាសាស្ត្រអចិន្ត្រៃយ៍នៃគណៈកម្មាធិការអោយស៊ីស៊ី **លោក** JIN Oksub ប្រធានមូលនិធិបេតិកភណ្ឌវប្បធម៌កូរ៉េ លោក PARK Seunggyoo អគ្គនាយកកុងស៊ុលសាធារណៈកូរ៉េប្រចាំខេត្តសៀមរាប និងសហការី រួមទាំងបុគ្គលិក កម្មករ និងអ្នកភូមិជុំវិញប្រមាណ៣០០នាក់។

លោក JIN Oksub បានថ្លែងថា ការសម្តែងសិល្បៈរួមគ្នានៅឱកាសនេះ ក្នុងបំណងថ្លែងអំណរគុណដល់អ្នកជំនាញខ្មែរ-កូរ៉េ និងកម្មករដែលបានខិតខំបំពេញការងារកន្លងមក បានយ៉ាងល្អប្រសើរ។ ពិសេសដើម្បីបង្ហាញពីកិច្ចសហប្រតិបត្តិការល្អទាំងទំនាក់ទំនងការទូតនិងវិស័យវប្បធម៌រវាងប្រទេសទាំងពីរផង។ លោកសង្កត់ធ្ងន់ថា ចំណុចសំខាន់នៃការបង្ហាញសិល្បៈរួមគ្នាថ្ងៃនេះគឺជាការផ្តល់ទឹកចិត្ត ក្តីស្រលាញ់ និងការចងចាំតាមរយៈការបង្ហាញសិល្បៈប្រពៃណីជាតិខ្មែរនិងរបាំArirang ក្នុងន័យថែរក្សាការពារឱ្យបានគង់វង្សនូវបេតិកភណ្ឌមនុស្សជាតិអរូបីដែលបញ្ជូលជាបេតិកភណ្ឌរបស់អង្គការយូនីស្កូ។ អ្វីដែលសំខាន់មិនត្រឹមតែអភិរក្សតែម្យ៉ាងទេ គឺមនុស្សជាតិផ្ទាល់ជាអ្នកថែរក្សា បើគ្មានអ្នកគ្រប់គ្រងឬអនុវត្តវានឹងក្លាយទៅជាសិល្បៈមួយគ្មានជីវិត។

ឯកឧត្តមបណ្ឌិត ស៊ុំ ម៉ាប់ បានថ្លែងអំណរគុណនិងកោតសរសើរដល់ក្រុមការងារពាក់ព័ន្ធគ្រប់ផ្នែកដែលបានប្រឹងប្រែងបំពេញតួនាទី ភារកិច្ចយ៉ាងយកចិត្តទុកដាក់លើការសិក្សា អនុវត្តគម្រោងឈានដល់ការបញ្ចប់ការជួសជុលដំណាក់កាលទី១នេះ។

ឯកឧត្តមបន្ថែមថា ការប្រកាសបិទគម្រោងជួសជុលដំណាក់កាលទី១នេះបានបង្ហាញឱ្យឃើញកាន់តែច្បាស់ថែមទៀតពីជោគជ័យនៃការអនុវត្តគោលនយោបាយក្រៅប្រទេសរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការពង្រឹងចំណងមិត្តភាពជាមួយបណ្តាប្រទេសនានា អង្គការអន្តរជាតិ ពិសេសជាមួយសាធារណៈរដ្ឋកូរ៉េ ទាំងអភិវឌ្ឍន៍វិស័យទេសចរណ៍តាមរយៈការពង្រឹងការងារអភិរក្ស ជួសជុល សំដៅធ្វើយ៉ាងណារក្សាបាននូវស្មោនភាពដើមនៃប្រាង្គប្រាសាទបុរាណនានា ជាកេរមរតកដ៏ថ្លៃថ្លារបស់ដូនតាខ្មែរដោយគៀងគរធនធានជំនួយពីខាងក្រៅ រួមផ្សំធនធានផ្ទាល់ខ្លួនរបស់កម្ពុជា។ ម្យ៉ាងទៀតការងារអភិរក្សប្រាសាទបុរាណមិនត្រឹមតែដើម្បីការពារថែរក្សាប្រាង្គប្រាសាទ តែថែមទាំងបានបង្កើតការងារជូនប្រជាពលរដ្ឋ ពិសេសលើកកម្ពស់ប្រកួតប្រជែងលើវិស័យទេសចរណ៍កម្ពុជាជាមួយប្រទេសនានាឱ្យមានកម្រិតកាន់តែខ្ពស់ថែមទៀត។

ឯកឧត្តមបញ្ជាក់ថា ជោគជ័យនៃការជួសជុលប្រាសាទព្រះពិធូរមិនមែនជាលទ្ធផលដំបូងនៃជំនួយរាជរដ្ឋាភិបាលសាធារណៈរដ្ឋកូរ៉េប៉ុណ្ណោះទេ កន្លងមកសាធារណៈរដ្ឋកូរ៉េបានផ្តល់គម្រោងជំនួយជាច្រើនសម្រាប់អភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមនៅកម្ពុជា ដូចជាផ្លូវមិត្តភាពកម្ពុជា-កូរ៉េជាដើម និងសង្ឃឹមថា រាជរដ្ឋាភិបាលសាធារណៈរដ្ឋកូរ៉េ និងមូលនិធិបេតិកភណ្ឌវប្បធម៌អន្តរជាតិកូរ៉េ តាមរយៈទីភ្នាក់ងារនៃកិច្ចសហប្រតិបត្តិការអន្តរជាតិកូរ៉េនឹងបន្តពិនិត្យលទ្ធភាពក្នុងការលើកគម្រោងជួសជុលប្រាសាទនានាពេលអនាគត។

គួរបញ្ជាក់ថា គម្រោងសហប្រតិបត្តិការរវាងអាជ្ញាធរជាតិអប្សរានិងមូលនិធិបេតិកភណ្ឌវប្បធម៌អន្តរជាតិកូរ៉េរយៈពេល៣ឆ្នាំកន្លងមកនេះ បានជួសជុលវានហាលប្រាសាទព្រះពិធូរ៖ បើកវគ្គបណ្តុះបណ្តាលនិងផ្លាស់ប្តូរបទពិសោធន៍លើកិច្ចការអភិរក្សនិងជួសជុលបេតិកភណ្ឌនៅប្រទេសកូរ៉េដល់អ្នកជំនាញការខ្មែរមកពីនាយកដ្ឋានពាក់ព័ន្ធ នៃអាជ្ញាធរជាតិអប្សរាបានចំនួន៥២នាក់ វគ្គខ្លីចំនួន២សប្តាហ៍បានចំនួន៤០នាក់ និងវគ្គខ្លី៣ខែបាន១២នាក់ បង្កើតមន្ទីរពិសោធន៍មួយនៅអាជ្ញាធរជាតិអប្សរាសម្រាប់ពិសោធន៍ការងារទាក់ទងនឹងការអភិរក្សប្រាសាទ។

សម្រាប់ដំហានបន្ទាប់ អាជ្ញាធរជាតិអប្សរានិងមូលនិធិបេតិកភណ្ឌវប្បធម៌អន្តរជាតិកូរ៉េ បានចុះអនុស្សារណៈយោគយល់គ្នាដើម្បីបន្តទៅដំណាក់កាលទីដើម្បីបន្តគម្រោងអភិរក្ស ជួសជុលប្រាសាទនៃក្រុមប្រាសាទព្រះពិធូរនិងព្រះលានដល់ដំរីនៅបរិវេណអង្គរធំបន្ត៕









ការអប់រំបេតិកភណ្ឌដល់កុមារជុំញការយល់ដឹងផ្នែកវប្បធម៌ ដែលនាមុងារឱ្យមានការជួយពីអ្នកជំនាញបន្ថែមលើមោទនភាព

ផ្សាយនៅថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១៨

ជាការរួមចំណែកជាមួយវិស័យអប់រំក្នុងការបណ្តុះបណ្តាលកុមារឱ្យស្គាល់ពីប្រាង្គប្រាសាទ ប្រវត្តិភូមិសាស្ត្រ និងវប្បធម៌ប្រពៃណីក្នុងតំបន់ នាយកដ្ឋានផ្សព្វផ្សាយនៃអាជ្ញាធរជាតិអប្សរា បានបណ្តុះបណ្តាលដល់សិស្សានុសិស្សអំពីបេតិកភណ្ឌក្នុងតំបន់អង្គរនៅសាលាបឋមសិក្សា ហ៊ុន សែន ស្វាយចេក ចំនួន២០០នាក់ ឱ្យស្គាល់ ចូលរួម ថែរក្សា ការពារបុរាណដ្ឋានទំនៀមទម្លាប់ ជំនឿសាសនា និងបរិស្ថានក្នុងតំបន់ដែលពួកគេរស់នៅ កាលពីថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៨។

មេរៀនសំខាន់ៗនៅក្នុងកម្មវិធីនិយាយអំពីប្រវត្តិនិងភូមិសាស្ត្រនៃភូមិស្វាយចេក តួនាទីកុមារក្នុងការរួមចំណែកថែរក្សាបុរាណដ្ឋានក្នុងភូមិ និងការអប់រំបរិស្ថាន ដែលបង្រៀនដោយអ្នកជំនាញបុរាណវិទ្យានិងអ្នកជំនាញបរិស្ថាន មានលក្ខណៈសាមញ្ញ ខ្លីៗ ងាយយល់ និងងាយអនុវត្តតាមសមស្របតាមកម្រិតថ្នាក់ រួមទាំងការយល់ដឹងរបស់កុមារ។ លើសពីនេះ ក្រុមការងារក៏បានយកសៀវភៅពាក់ព័ន្ធនឹងចំណេះដឹងទូទៅ ទំនៀមទម្លាប់ប្រពៃណី ប្រវត្តិសាស្ត្រ បំនិនថ្មីៗរក្សាទុកក្នុងបណ្ណាល័យរបស់សាលា សម្រាប់សិស្សអានបង្កើនចំណេះដឹងនិងកម្សាន្តផងដែរ។

ថ្លែងក្នុងកម្មវិធី**លោកស្រី ញ៉ែប សាយឿន** នាយិកាសាលាបឋមសិក្សាស្វាយចេកបានថ្លែងអំណរគុណដល់អាជ្ញាធរជាតិអប្សរាដែលបានបង្កើតកម្មវិធីដ៏មានសារៈសំខាន់នេះឡើង បើទោះបីមានរយៈពេលខ្លី តែបានបន្ថែមចំណេះដឹងផ្នែកប្រវត្តិសាស្ត្រ ភូមិសាស្ត្រ និងជំនឿអ្នកស្រុកដល់កុមារនៅទីនេះបានស្គាល់ ហើយអាចសង្កេតបានពេលគេទៅចូលរួមក្នុងកម្មវិធីទាំងនោះ។

លោកស្រីបន្តថា ការអប់រំបែតិកកណ្ឌដល់កុមារ ជំរុញការយល់ដឹង ការស្រឡាញ់មរតកវប្បធម៌ក្នុងភូមិ ដែលកត្តានេះទាមទារការជួយពីសហគមន៍និងអ្នកជំនាញបុរាណវិទ្យាបន្ថែមលើម៉ោងសិក្សា ព្រោះកម្មវិធីអប់រំអនុវត្តតាមក្រសួងកំណត់មិនសូវមានពេលវេលាច្រើន ចំណែកសមត្ថភាពរបស់លោកគ្រូអ្នកគ្រូក៏នៅមានកម្រិត មិនសូវយល់ច្បាស់ដូចអ្នកជំនាញដែលមានការសិក្សាស្រាវជ្រាវច្បាស់លាស់នោះទេ។ ពិសេស ការនៅបន្តទំនៀមរបស់អ្នកស្រុកក្នុងសហគមន៍ ការណែនាំពីចាស់ព្រឹទ្ធាចារ្យក្នុងភូមិ ការគាំទ្រពីគ្រួសារ ក៏ជាកត្តាសំខាន់ក្នុងការឱ្យកុមារចងចាំ ស្គាល់ បានឃើញ និងបណ្តុះគំនិតពួកគេឱ្យថែរក្សានិងស្រឡាញ់មរតកវប្បធម៌ទាំងនោះដោយឯកឯងដែរ៕









សេចក្តីជូនដំណឹងស្តីពីការដឹកប្រឡាយតាមព្រំផ្ទៃដីព្រៃឈើ ដើម្បីការពារ និងរក្សាព្រៃឈើក្នុងឧទ្យានអង្គរ

ផ្សាយនៅថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១៨



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA
លេខ ៦៣៩/ស.សជណ
២៨

សេចក្តីជូនដំណឹង
ស្តីពី
ការដឹកប្រឡាយតាមព្រំផ្ទៃដីព្រៃឈើ ដើម្បីការពារ និងរក្សាព្រៃឈើក្នុងឧទ្យានអង្គរ

ជាយូរលង់មកហើយ ព្រៃឈើដែលស្ថិតនៅក្នុងតំបន់អង្គរ និងនៅជុំវិញអង្គរជាប្រភេទព្រៃស្រោង ពាក់កណ្តាលស្រោង និងព្រៃល្បោះ មានសត្វស្មើរគ្រប់ប្រភេទរស់នៅជាព្រៃធម្មជាតិមានសម្រស់ស្រស់បំព្រងគួរជាទីគាប់ចិត្ត មិនត្រឹមប៉ុណ្ណោះព្រៃឈើនៅក្នុងតំបន់ឧទ្យានអង្គរ មានផលប្រយោជន៍យ៉ាងសំខាន់ដល់ភាពគង់វង្សនៃប្រាសាទ។ ទោះបីកន្លងមកអាជ្ញាធរជាតិអប្សរាខិតខំបង្ការ និងការពារព្រៃឈើឲ្យប្រសើរឡើងក៏នូវមានជនខិលខូចមួយក្តាប់តូចនៅបន្តកាប់រានដីព្រៃឈើម្តងបន្តិចៗដើម្បីពង្រីកផ្ទៃដី ផ្ទះសម្បែង ស្រែចំការ និងចាប់យកដីព្រៃជាកម្មសិទ្ធិ។ល។ ដើម្បីការពារ និងរក្សាព្រៃឈើនៅក្នុងឧទ្យានអង្គរឲ្យមានភាពគង់វង្សយូរអង្វែង អាជ្ញាធរជាតិអប្សរាសូមជម្រាបជូនដំណឹងដល់សាធារណជនព្រមទាំងគ្រប់មន្ទីរអង្គភាព និងគ្រប់ស្ថាប័នដែលមានការពាក់ព័ន្ធមេត្តាជ្រាបថា៖ នាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាននៃអាជ្ញាធរជាតិអប្សរានឹងធ្វើការដឹកប្រឡាយតាមព្រំផ្ទៃដីព្រៃឈើតាមទីតាំងដូចខាងក្រោម៖

-ភូមិគោកបេង ភូមិគោកតាចាន់ និងភូមិកសិន្ទុអង្គរខាងត្បូង សង្កាត់គោកចក ក្រុងសៀមរាប
-ភូមិមណ្ឌលបី សង្កាត់ស្លក្រាម ក្រុងសៀមរាប
-ភូមិក្រាំន់ និងស្រះស្រង់ត្បូង សង្កាត់នគរធំ ក្រុងសៀមរាប
-ភូមិត្រាចជ្រុំ សង្កាត់អំពិល ក្រុងសៀមរាប
-ភូមិអូរទទឹង ឃុំព្រះដាក់ ស្រុកបន្ទាយស្រី ខេត្តសៀមរាប។

ការងារនេះនឹងចាប់ផ្តើមអនុវត្តចាប់ពីថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៨ រហូតដល់បញ្ចប់ការងារ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមស្ថាប័ន សមត្ថកិច្ចពាក់ព័ន្ធ ភ្ញៀវទេសចរជាតិ និងអន្តរជាតិ ព្រមទាំងសាធារណជនទាំងអស់ មេត្តាជ្រាបជាពត៌មាន។

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២
សៀមរាប,ថ្ងៃទី[illegible] ខែ ធ្នូ ឆ្នាំ២០១៨
អគ្គនាយក

ស៊ុំ ម៉ាប់

ចម្លងជូន៖
-សាលាខេត្តសៀមរាប
-ស្នងការដ្ឋាននគរបាលខេត្តសៀមរាប
-មន្ទីរបរិស្ថានខេត្តសៀមរាប
-មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តសៀមរាប
-អង្គភាពនគរបាលការពារបេតិកភណ្ឌប្រចាំខេត្តសៀមរាប
-អង្គភាពនគរបាលទេសចរប្រចាំខេត្តសៀមរាប
-ស្នាក់ការតំបន់ការពារទេសភាពអង្គរ
-សាលាក្រុងសៀមរាប
-សាលាស្រុកបន្ទាយស្រី
"ដើម្បីជូនជ្រាប និងសហការ"
-គ្រប់នាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធរបស់អាជ្ញាធរអប្សរា
"ដើម្បីមុខការ និងសហការ"
-ឯកសារ-កាលប្បវត្តិ

ភ្នំពេញ:
មហាវិថីសហព័ន្ធរុស្ស៊ី លេខ៤១ សង្កាត់មិត្តភាព ខណ្ឌឫស្សីកែវ
ទូរស័ព្ទ/ទូរសារ: ០២៣ ២១៤ ៨៨៩/០២៣ ២១៤ ៨៨០

អាជ្ញាធរដើម្បីការគ្រប់គ្រងរដ្ឋបាលនិងរៀបចំតំបន់អង្គរ
Email: info@apsaraauthority.gov.kh
Website: http//www.apsaraauthority.gov.kh

សៀមរាប:
ភូមិបង្គួន ឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប
ទូរស័ព្ទ/ទូរសារ: ០៦៣ ៨៦៥ ៥៣៧/០៦៣ ៨៦៥ ៥៣៦

សេចក្តីជូនដំណឹងស្តីពី ការកាត់ជកហូតដើមឈើ និងកាត់ក្រឹមកឈើដែលមានហានិភ័យខ្ពស់នៅតាមបរិវេណប្រាសាទ ក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១៨



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA
លេខ.៧៥៦.អប.សជណ

សេចក្តីជូនដំណឹង
ស្តីពី
ការកាត់ជកហូតដើមឈើ និងកាត់ក្រឹមកឈើ
ដែលមានហានិភ័យខ្ពស់នៅតាមបរិវេណប្រាសាទ ក្នុងរមណីយដ្ឋានអង្គរ

អាជ្ញាធរជាតិអប្សរា សូមជូនដំណឹងដល់ស្ថាប័ន សមត្ថកិច្ចពាក់ព័ន្ធ ភ្ញៀវជាតិ-អន្តរជាតិ មគ្គុទ្ទេសក៍ទេសចរណ៍ ព្រមទាំងសាធារណជនទាំងអស់មេត្តាជ្រាបថា ដើម្បីធានាដល់សុវត្ថិភាពភ្ញៀវទេសចរ សាធារណជន ក៏ដូចជាដើម្បីលើកកម្ពស់សោភ័ណភាពនៅតាមដងផ្លូវ និងនៅតាមបរិវេណប្រាសាទ ក្នុងតំបន់រមណីយដ្ឋានអង្គរ និងតំបន់ដែលគ្រប់គ្រងដោយអាជ្ញាធរជាតិអប្សរា នាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាន នៃអាជ្ញាធរជាតិអប្សរា នឹងកាត់ជកហូតដើមឈើ និងកាត់ក្រឹមកឈើ តាមទីតាំងនានាដូចខាងក្រោម៖

-កាត់ជកហូតដើមឈើ និងកាត់ក្រឹមកឈើចំនួន១២ដើម នៅបរិវេណវត្តតាំងតុ។

-កាត់ជកហូតដើមឈើទាល០១ដើម នៅតាមដងផ្លូវពីខ្លោងទ្វារទន្លេអ៊ុំទៅប្រាសាទបាយ័ន ក្បែរផ្លូវចូលវត្តគងជុំ។

ការងារនេះ នឹងចាប់ផ្តើមអនុវត្តចាប់ពីថ្ងៃទី១២ ខែ ធ្នូ ឆ្នាំ២០១៨ រហូតដល់បញ្ចប់ការងារ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមស្ថាប័ន សមត្ថកិច្ចពាក់ព័ន្ធ ភ្ញៀវជាតិ-អន្តរជាតិ មគ្គុទ្ទេសក៍ទេសចរណ៍ ព្រមទាំងសាធារណជនទាំងអស់ មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំច សំរឹទ្ធិស័កព.ស២៥៦២
សៀមរាប, ថ្ងៃទី ... ខែ ... ឆ្នាំ២០១៨
អគ្គនាយក

សុំ ម៉ាប់

ចម្លងជូន៖
-សាលាខេត្តសៀមរាប
-មន្ទីរបរិស្ថានខេត្តសៀមរាប
-មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តសៀមរាប
-អង្គភាពនគរបាលការពារបតិកភណ្ឌប្រចាំខេត្តសៀមរាប
-ស្នាក់ការតំបន់ការពារទេសភាពអង្គរ
-សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ទាំងអស់ប្រចាំខេត្តសៀមរាប
-ដើម្បីជូនជ្រាប និងសហការ-
-នគរបាលទេសចរណ៍
-គ្រប់នាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធរបស់អាជ្ញាធរអប្សរា
-ដើម្បីមុខការ និងសហការ-
-ឯកសារ-កាលប្បវត្តិ

លេខទូរស័ព្ទទំនាក់ទំនង:លោក គង់ សុវណ្ណារិទ្ធ 012-354-630, លោក ខៀន សុធី 010-304-089,088-9522-5059,លោក ហែ ហ៊ីត 086 600 740

ភ្នំពេញ: មហាវិថីសហព័ន្ធរុស្ស៊ី លេខ៨១ សង្កាត់មិត្តភាព ខណ្ឌឫស្សីកែវ ទូរសព្ទ/ទូរសារ: ០២៣ ២១៥ ៧៧១/០២៣ ២១៥ ៧៧៦
អាជ្ញាធរជាតិដើម្បីការអភិរក្សរមណីយដ្ឋាននិងរៀបចំតំបន់អង្គរ Email: info@apsaraauthority.gov.kh Website: http://www.apsaraauthority.gov.kh
សៀមរាប: ភូមិបង្គោល ឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប ទូរសព្ទ/ទូរសារ: ០៦៣ ៧៦៥ ៥៧៧/០៦៣ ៧៦៥ ៥៧៦

សិប្បកម្មបុរាណផ្ទែកសិល្បៈកាំងលម្អនិងក្តេងខ្មែរនៅសហគមន៍កុដិសូរ ធធូលចានការកាំទ្រច្រើនពីសំណាក់ភ្ញៀវទេសចរ

ផ្សាយនៅថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៨

ជាគោលនយោបាយរបស់អាជ្ញាធរជាតិអប្សរាក្នុងការអភិរក្សតំបន់អង្គរមានទាំង ជំនឿ សាសនា សិល្បៈ ទំនៀមទម្លាប់ របៀបរបបរស់នៅ និងលើកកម្ពស់ជីវភាពប្រជាពលរដ្ឋ អាជ្ញាធរជាតិអប្សរាតែងសហការ ផ្តល់យោបល់ ជួយគាំទ្រសហគមន៍ ដើម្បីឱ្យសហគមន៍មានគំនិតឆ្នៃប្រឌិត និងចូលរួមអភិវឌ្ឍន៍សហគមន៍ខ្លួនដោយខ្លួនឯង។

ជាក់ស្តែងដោយមើលឃើញពីសក្តានុពលសិល្បៈបុរាណក្នុងការទាក់ទាញទេសចរដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ចប្រជាជន អាជ្ញាធរជាតិអប្សរាសហការណ៍ជាមួយប្រទេសញ្ញូវហ្សេឡែនតាមរយៈគម្រោង (ACHA) បង្កើតសហគមន៍កុដិសូរឡើងនៅឆ្នាំ ២០១០ នៅភូមិរហាលនិងស្រះស្រង់ខាងជើង ដើម្បីលើកតម្លៃសិល្បៈខ្មែរផងនិងបង្កើនជីវភាពប្រជាជនក្នុងតំបន់ឱ្យកាន់តែប្រសើរផង ព្រោះអ្នកស្រុកនៅភូមិនេះមានចំណេះជំនាញខាងសិល្បៈសិប្បកម្មយ៉ាងចំណានពីដូនតារហូតមកដល់បច្ចុប្បន្ន។

លោក សំ កុសល មន្ត្រីនាយកដ្ឋានរៀបចំដែនដីនិងគ្រប់គ្រងលំនៅដ្ឋានក្នុងឧទ្យានអង្គរនិងគ្រប់គ្រងគម្រោងបានឱ្យដឹងថាសហគមន៍កុដិសូរមានបម្រើសេវាកម្មពីរ គឺរទេះទេសចរនិងសិប្បកម្ម។ ប៉ុន្តែបច្ចុប្បន្នរទេះគោទេសចរបានធ្លាក់ចុះសល់ត្រឹម ៤រទេះប៉ុណ្ណោះ ដោយសារកត្តាភ្ញៀវ ការផ្សព្វផ្សាយមិនបានទូលំទូលាយ ការងាកទៅប្រើគ្រឿងយន្តក្នុងរបរកសិកម្ម និងទម្លាប់ប្រជាជនលក់គោពេញកម្លាំងចេញពេលដកស្ទូងរួច ទើបមិនមានគោសម្រាប់ដឹកជញ្ជូន។ ដោយឡែក សិប្បកម្មចម្លាក់និងឧបករណ៍ភ្លេងខ្មែររបស់ប្រជាជនទាំង៤៨គ្រួសារ គឺនៅតែទទួលបានការពេញនិយម ហើយមានការគាំទ្រច្រើនពីសំណាក់ភ្ញៀវទេសចរជាតិ អន្តរជាតិ និងឈ្មួញ។

លោក កុសល បន្ថែមថា ដើម្បីអភិវឌ្ឍន៍សមត្ថភាពផ្នែកសិប្បកម្ម ក្រុមការងារក៏បាននាំប្រជាជនទៅទស្សនកិច្ចសិក្សានៅក្រៅស្រុកនិងក្រៅប្រទេសផងដែរ ដើម្បីស្វែងយល់បន្ថែមពីក្បាច់ចម្លាក់ បច្ចេកទេសក្នុងការធ្វើថាមានអ្វីដែលខុសប្លែកពីតំបន់ខ្លួន។ តាមរយៈគម្រោងកុដិសូរ ក៏នាំទីផ្សារដល់ប្រជាជនផងដែរ ដោយការមានសិទ្ធិយកសម្ភារៈទៅលក់នៅពិព៌រណ៍ថ្នាក់ខេត្ត និងអង្គរសង្ក្រានជាដើម។

លោក ឃុំ សឿត បានឱ្យដឹងថា លោកមានជំនាញខាងចម្លាក់ឈើតូចៗនិងរទេះគោ ជាង២០ឆ្នាំមកហើយនៅភូមិរហាល។ កាលមិនទាន់ចូលជាសមាជិកសហគមន៍កុដិសូរ ការលក់ដូរមិនសូវមានទីផ្សារច្រើនទេ តែក្រោយពេលមានសមាគមន៍នេះ អាជ្ញាធរជាតិអប្សរានិងប្រទេសញ្ញូវហ្សេឡែនបានបង្កើនការផ្សព្វផ្សាយ ធ្វើឱ្យភ្ញៀវទេសចរជាតិ-អន្តរជាតិបានស្គាល់ច្រើន ហើយខ្លះបានមកទិញដល់កន្លែង ពេលខ្លះផលិតមិនទាន់តម្រូវការទីផ្សារទេ ហើយយើងមានសិទ្ធិយកទៅលក់នៅក្នុងព្រឹត្តិការណ៍ធំៗក្នុងខេត្តសៀមរាបផង។ លើសពីនេះ គម្រោងក៏បាននាំទៅទស្សនកិច្ចនៅកំពង់ឆ្នាំង កំពង់ស្ពឺ និងប្រទេសវៀតណាម ដើម្បីមើលពីការផលិតសិប្បកម្មរបស់គេ ទុកជាបទពិសោធន៍មកច្នៃប្រឌិតបន្ថែមលើអ្វីដែលខ្លួនមាន។

ជាអ្នកជំនាញធ្វើរទេះគោដែលចេះតគ្នាពីអ្នកភូមិដែរនោះ **លោក វ្ជន ហ៉ាង** បានប្រាប់ថា ការលក់ចម្លាក់ឈើវត្ថុអនុស្សាវរីយ៍នៅទីនេះ ទទួលបានកម្រៃគួរសមតាមខែមានភ្ញៀវតិច-ច្រើន និងលក់ឱ្យឈ្មួញ។ តែអ្វីដែលជួបការលំបាក គឺការរកឈើមកធ្វើចម្លាក់ពិសេសក្នុងរដូវភ្លៀង ណាមួយតម្លៃឈើសព្វថ្ងៃក៏ឡើងថ្លៃ ហើយទិញទុកយូរ វាក៏ខូចទៀត។ **លោក ហ៉ាង** ក៏

សំណូមពរឱ្យអាជ្ញាធរជាតិអប្សរាជួយយកចិត្តទុកដាក់លើផ្នែកបរិស្ថាន និងផ្សព្វផ្សាយពីសហគមន៍កុដិសូរឱ្យបានច្រើន ដើម្បីអភិរក្សរបរសិប្បកម្មសិល្បៈមួយនេះ ហើយលោកក៏មានទទួលបង្រៀនសិស្សដោយមិនគិតថ្លៃផងដែរ។

សម្រាប់គ្រួសារ**អ្នកស្រី ព្រឿង សាអឿម** ដែលជំនាញខាងផលិតឧបករណ៍ភ្លេងខ្មែរតាំងពីឆ្នាំ១៩៩២ មានសាដៀវ ទ្រ ជាដើមនោះ បានលើកឡើងថា របរនេះជួនកាលដាច់ខ្លាំងធ្វើមិនទាន់ ជួនក៏បានតិច តាមក្បៀវកើនឡើងឬធ្លាក់ចុះ ហើយអ្នកទិញយកទៅលក់បន្តមានទាំងខ្មែរនិងថៃ។ តាមរយៈរបរនេះ ធ្វើឱ្យគ្រួសារអ្នកស្រីមានជីវភាពសមរម្យ ហើយមិនបាច់ចំណាកស្រុក កូនចៅក៏បានរៀនសូត្រ និងបន្តផ្ទេរមរតកនៃចំណេះទាំងនេះដល់កូនចៅផងដែរ ដើម្បីកុំឱ្យបាត់បង់៕









សិស្សថ្នាក់ទី៤,៥ និង៦ ទទួលការអប់រំឱ្យចេះកាត់បន្ថយសំរាម

ផ្សាយនៅថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៨

សិស្សានុសិស្សដែលកំពុងរៀនថ្នាក់ទី៤,៥ និងទី៦ នៅក្នុងរមណីយដ្ឋានអង្គរ ទទួលបានការបណ្តុះបណ្តាលក្នុងគម្រោងអប់រំបរិស្ថាន ដែលជាគម្រោងសហការជាមួយអាជ្ញាធរជាតិអប្សរា ស្ថាប័នជានាគុណភាពជប៉ុន (JQA) មន្ទីរអប់រំ យុវជន និងកីឡា និងសាកលវិទ្យាល័យ សូហ្វីយ៉ា។ សិស្សានុសិស្សទាំងនោះ ត្រូវបានអប់រំឱ្យស្គាល់សំរាម ប្រភពដែលបណ្តាលឱ្យមានសំរាម របៀបកាត់បន្ថយសំរាម រួមនិងដំណោះស្រាយជាដើម។ល។

ការអប់រំបរិស្ថានចំពោះកុមារតូចៗ ត្រូវបានមើលឃើញថាមានប្រសិទ្ធភាពខ្ពស់ ព្រោះវាជាគ្រឹះសម្រាប់ការអប់រំនៅពេលពួកគេរៀនថ្នាក់ខ្ពស់ និងក្លាយជាពលរដ្ឋដ៏ល្អមួយរូបនាពេលអនាគត។ សាលាបឋមសិក្សាគំរូ៣ ត្រូវបានគម្រោងជ្រើសរើសដើម្បីអនុវត្តន៍កម្មវិធីអប់រំបរិស្ថាន នៅក្នុងតំបន់រមណីយដ្ឋានអង្គរ។

លោក ឡៅ គីមលាង តំណាងសាកលវិទ្យាល័យ សូហ្វីយ៉ា និងជាគ្រូបង្គោលក្នុងវគ្គបណ្តុះបណ្តាលខាងលើបានឱ្យដឹងថា មេរៀនស្នូលសំខាន់សម្រាប់ការអប់រំកុមារទាក់ទងនឹងបរិស្ថាននេះ ដំបូងឱ្យក្មេងទាំងនោះយល់ដឹងតើអ្វីជាសំរាមជាមុនសិន និងថាតើរាល់ថ្ងៃពីព្រឹកដល់យប់ ពួកគេបានធ្វើអ្វីខ្លះទាក់ទងនឹងបរិស្ថាន ដូចជាការមុជទឹក ដោះធ្មេញ។ល។ លោកបន្ថែមថា នៅពេលពួកគេចាប់ផ្តើមយល់ពីបញ្ហាទាំងអស់ នោះពួកគេនឹងងាយចាប់បាន និងយល់ពីផលប៉ះពាល់បរិស្ថាន។ លោក គីមលាង ពន្យល់ថា ប្លង់មេរៀនដែលដាក់បង្រៀន គឺអនុវត្តន៍តាមកង PDCA គឺPlan (ដាក់គោលដៅ រៀបចំផែនការដើម្បីកាត់បន្ថយសំរាម) Do (ចាប់ធ្វើទៅតាមផែនការដែលបានគិត) Check (តាមដានមើលថា តើបានសម្រេចគោលដៅប៉ុណ្ណា)? និង Act (តើត្រូវធ្វើយ៉ាងណាទើបវិតតែប្រសើរ)?

បើតាមការពន្យល់របស់**លោក ឡៅ គីមលាង** សាលាបឋមសិក្សាចំនួន៣ ដែលត្រូវបានជ្រើសរើសជាសាលាគំរូសម្រាប់អនុវត្តន៍គម្រោងលើកនេះមានសាលាបឋមសិក្សាគោកគ្រើល សាលាបឋមសិក្សាដូនឪ និងសាលាបឋមសិក្សាត្រពាំងស្វាយ។ គម្រោងនេះបានប្រមូលសិស្សទាំង៣ថ្នាក់បញ្ចូលគ្នាមានសិស្សថ្នាក់ទី៤,៥ និងទី៦ ដើម្បីបង្រៀនពីមេរៀនបរិស្ថានផ្សេងៗ ចំនួនមួយព្រឹក ហើយពួកគេនឹងឆ្លងកាត់ការអនុវត្តផ្ទាល់ជាមួយគ្រូបន្ទុកថ្នាក់ចំនួន ៣ខែបន្ថែមទៀត។

ក្នុងគម្រោងអប់រំបរិស្ថាននៅព្រឹកថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៨ ដែលធ្វើនៅសាលាបឋមសិក្សាគោកគ្រើល **លោក សាត្ថ** តំណាងស្ថាប័នជានាគុណភាពជប៉ុន បានឱ្យដឹងថា ការអប់រំនេះពិតជាសំខាន់ណាស់ ដើម្បីឱ្យពួកគេម្នាក់ៗមានទឹកចិត្តចង់ចូលរួមសម្អាតបរិស្ថាន ហើយមិនមែនតែរឿងសំរាមតែមួយមុខទេ បើនិយាយពីសំរាមគឺចាប់ផ្តើមពីការមិនចោលសំរាមពាសវាលពាសកាល ចេះគ្រប់គ្រង ការកាត់បន្ថយ និងការមិនប្រើហួសតម្រូវការជាដើម។ **លោក សាត្ថ** ទទួលស្គាល់ថា ការអប់រំឱ្យមនុស្សចូលរួមសម្អាតបរិស្ថាននេះ គឺត្រូវការប្រើពេលយូរបន្តិច ត្រូវការការចូលរួម ដូច្នេះហើយទើបគម្រោងចាប់យកកូនសិស្សថ្នាក់បឋម ដោយរំពឹងថា ពួកគេនឹងចាប់ផ្តើមយល់ពីបញ្ហានេះតាំងពីពេលនេះទៅ និងរហូតដល់ពួកគេក្លាយជាពលរដ្ឋល្អមួយរូបក្នុងសង្គម។

គួរម្លឹកថា នេះជាលើកទី១១ ហើយ ដែលកម្មវិធីអប់រំបរិស្ថានត្រូវបានរៀបចំនៅតាមសាលាបឋមសិក្សាក្នុងតំបន់រមណីយដ្ឋានអង្គរ ក្រោយគម្រោងនេះចាប់ផ្តើមដំណើរការតាំងពីឆ្នាំ ២០០៤មក។ គម្រោងនេះបានចូលមកក្នុងតំបន់អង្គរ ពីព្រោះស្ថាប័នជានាគុណភាពជប៉ុន បានធ្វើការបញ្ចូលប្រព័ន្ធគ្រប់គ្រងបរិស្ថាន ISO 14001 នៅក្នុងអាជ្ញាធរជាតិអប្សរា ហើយដើម្បីធ្វើសកម្មភាពផ្ទាល់ ស្ថាប័នជានាគុណភាពជប៉ុន ក៏បានដំណើរការគម្រោងរបស់ខ្លួន ដើម្បីជាចំណេះដឹងចំពោះក្មេងៗ ឱ្យមានទម្លាប់ល្អទាក់ទងនឹងបរិស្ថានចាប់ពីតូចៗតទៅ៕









សិស្សថ្នាក់បឋមសិក្សាក្នុងរមណីយដ្ឋានអង្គរជាង ៣០០នាក់ ទទួលបានការអប់រំឱ្យចេះការពារបរិស្ថាន

ផ្សាយនៅថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១៨

សិស្សបឋមសិក្សាចំនួន ៣សាលាដែលសរុបចំនួន ៣៥១នាក់ បានទទួលការអប់រំបរិស្ថាន ដែលកម្មវិធីនេះរៀបចំឡើងដោយស្ថាប័នជានាគុណភាពជប៉ុន Japan Quality Organization ហៅកាត់ថា (JQA) អាជ្ញាធរជាតិអប្សរា សាកលវិទ្យាល័យ សូហ្វីយ៉ា និងមន្ទីរអប់រំ យុវជន និងកីឡាខេត្តសៀមរាប។ សិស្សដែលត្រូវបានបង្រៀនមានថ្នាក់ទី ៤ដល់ទី៦ នៅតាមសាលាចំនួន៣ ក្នុងរមណីយដ្ឋានអង្គរ មានសាលាបឋមសិក្សាគោកគ្រើល សាលាបឋមដូនឪ និងសាលាបឋមសិក្សាត្រពាំងស្វាយ។

លោក ឡៅ គឹមលាង តំណាងសាកលវិទ្យាល័យ សូហ្វីយ៉ា និងជាគ្រូបង្គោលក្នុងកម្មវិធីអប់រំបរិស្ថានខាងលើបានលើកឡើងថា កម្មវិធីអប់រំលើកទី១១នេះ បានបញ្ចប់ដោយជោគជ័យ និងដែលមានសិស្សជាង ៣០០នាក់ចូលរួម។ សម្រាប់លោក គឹមលាង ការអប់រំបរិស្ថានលើកុមារតូចៗពិតជាមានសារសំខាន់ណាស់ ព្រោះវាជាគ្រឹះសម្រាប់កុមារទាំងនោះ នៅពេលពួកគេក្លាយជាពលរដ្ឋដែលយល់ពីបរិស្ថាន និងតម្លៃបេតិកភណ្ឌដែលនៅជុំវិញខ្លួន។

បើតាមការបញ្ជាក់របស់**លោក គឹមលាង** មេរៀនអប់រំបរិស្ថាននៅពេលនេះ ក៏ដូចការបង្រៀនលើកមុនៗដែរ គឺអប់រំកុមារឱ្យយល់ពីបញ្ហាបរិស្ថាន ដូចជាការទុកដាក់សំរាម ប្រភពដែលបណ្តាលឱ្យមានសំរាម និងដំណោះស្រាយដើម្បីឱ្យមានបរិស្ថានស្អាតជាដើម។ លោកបន្ថែមថា នៅពេលពួកគេចាប់ផ្តើមយល់ពីបញ្ហាទាំងអស់ នោះពួកគេនឹងងាយចាប់បាន និងយល់ពីផលប៉ះពាល់បរិស្ថាន។ លោកពន្យល់ថា ប្លង់មេរៀនដែលដាក់បង្រៀន គឺអនុវត្តន៍តាមកង PDCA គឺPlan (ដាក់គោលដៅរៀបចំផែនការដើម្បីកាត់បន្ថយសំរាម) Do (ចាប់ធ្វើទៅតាមផែនការដែលបានគិត) Check (តាមដានមើលថា តើបានសម្រេចគោលដៅប៉ុណ្ណា)? និង Act (តើត្រូវធ្វើយ៉ាងណាទើបរឹតតែប្រសើរ)?

គួរម្លឹកថា ក្នុងគម្រោងអប់រំបរិស្ថាននេះមានរយៈ៤ថ្ងៃ គឺចាប់ពីថ្ងៃទី១៧ ដល់ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨។ ការអប់រំបរិស្ថានសរុបចំនួន ៣៥១នាក់ ក្នុងនោះនៅសាលាបឋមសិក្សាគោកគ្រើលមានចំនួន ៤៨នាក់ សាលាបឋមសិក្សាដូនឪចំនួន ១៨២នាក់ និងសាលាបឋមសិក្សាត្រពាំងស្វាយ ចំនួន ១២១នាក់។ នេះជាលើកទី១១ ហើយ ដែលកម្មវិធីអប់រំបរិស្ថានត្រូវបានរៀបចំនៅតាមសាលាបឋមសិក្សាក្នុងតំបន់រមណីយដ្ឋានអង្គរ ក្រោយគម្រោងនេះចាប់ផ្តើមដំណើរការតាំងពីឆ្នាំ ២០០៤មក។ គម្រោងអប់រំបរិស្ថានបានចូលមកក្នុងតំបន់អង្គរ ក្រោយស្ថាប័នជានាគុណភាពជប៉ុន បានធ្វើការបញ្ចូល

ប្រព័ន្ធគ្រប់គ្រងបរិស្ថាន ISO14001 នៅក្នុងអាជ្ញាធរជាតិអប្សរា ហើយដើម្បីធ្វើសកម្មភាពផ្ទាល់ ស្ថាប័នធានាគុណភាពនេះ ក៏បានដំណើរការគម្រោងរបស់ខ្លួន ដើម្បីជាចំណេះដឹងចំពោះក្មេងៗឱ្យមានទម្លាប់ល្អទាក់ទងនឹងបរិស្ថានចាប់ពីតូចៗនេះតទៅ៕









ឧបសម្ព័ន្ធ

ចំណងជើងព័ត៌មាន **លេខទំព័រ**

ផ្នែកទី ១
សកម្មភាពថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា

- សេចក្តីជូនដំណឹងស្តីពី ការប្រារព្ធពិធីប្រកាសក្រុមប្រឹក្សាវប្បធម៌អាស៊ីជាផ្លូវការនៅទីលានព្រះជល់ដំរី ៣
- ៤០ឆ្នាំនៃការរស់រានសាជាថ្មីនៃប្រទេសកម្ពុជានិងបេតិកភណ្ឌវប្បធម៌ខ្មែរ ៤
- អគ្គនាយិកាអង្គការយូណេស្កូ៖ អង្គរតែងតែស្ថិតនៅក្នុងបេះដូងរបស់ខ្មែរគ្រប់ៗរូប ៥
- ប្រតិភូចម្រុះមកពីប្រទេសកាដាណាស្វែងរកកិច្ចសហប្រតិបត្តិការការងារជាមួយអាជ្ញាធរជាតិអប្សរា ៩
- អាជ្ញាធរជាតិអប្សរាបើកសវនកម្មផ្ទៃក្រៅលើកទី១លើប្រព័ន្ធគ្រប់គ្រងបរិស្ថាន ISO 14001:2015 ..... ១៣
- សវនកម្មផ្ទៃក្រៅលើកទី១លើប្រព័ន្ធគ្រប់គ្រងបរិស្ថាន ISO 14001: 2015 របស់អាជ្ញាធរជាតិអប្សរាទទួលបានលទ្ធផលជាទីមោទន ១៦
- រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងទេសចរណ៍នៃសាធារណរដ្ឋប្រជាមានិតចិនទស្សនកិច្ចរមណីយដ្ឋានអង្គរ ១៩
- អាជ្ញាធរជាតិអប្សរាកំពុងរៀបចំដំឡើងផ្ទាំងឈ្មោះប្រាសាទជាង១០០ផ្ទាំង ជាក់តាមប្រាសាទនានាក្នុងរមណីយដ្ឋានអង្គរ ៣៧
- ពិធីប្រកាសចូលកាន់តំណែងអគ្គនាយកនៃអាជ្ញាធរជាតិអប្សរា ៤៩
- លិខិតជូនដំណឹងស្តីពី ការហាមបរិភោគអាហារនៅក្នុងបរិវេណប្រាសាទ ក្នុងពេលទស្សនាប្រាសាទនៅតំបន់រមណីយដ្ឋានអង្គរ ៥៥
- សេចក្តីប្រកាសព័ត៌មាន៖ ការក្រើនរំឭកឲ្យប្រុងប្រយ័ត្នចំពោះគ្រោះអគ្គីភ័យឆេះព្រៃនារដូវប្រាំងឆ្នាំនេះ ៥៨
- អគ្គនាយកអាជ្ញាធរជាតិអប្សរាដឹកនាំកិច្ចប្រជុំពិភាក្សាអំពីការអនុវត្ត និងតាមដានការងារនៅការដ្ឋាននានាក្នុងរមណីយដ្ឋានអង្គរ ៧២
- ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរាចូលរួមក្នុងពិធីសំណេះសំណាលកុមារគជ្ជង់ និងពិការភ្នែក ក្រោមអធិបតីយភាពសម្តេចពិជ័យសេនា ទៀ បាញ់ ៧៧
- រដ្ឋមន្ត្រីក្រសួងវប្បធម៌ដឹកនាំកិច្ចប្រជុំពេញអង្គលើកទី៥ នៃគណៈកម្មាធិការអោយស៊ីស៊ី-ព្រះវិហារ ៧៩
- អាជ្ញាធរជាតិអប្សរាសហការជាមួយសប្បុរសជនខេត្តសៀមរាបឧបត្ថម្ភសម្ភារៈសិក្សា ដល់សិស្សានុសិស្សសាលាបឋមសិក្សាស្រះស្រង់ ៨០
- អាជ្ញាធរជាតិអប្សរាប្រជុំតាមដានអនុសាសន៍គណៈកម្មាធិការអោយស៊ីស៊ី-អង្គរ (ICC-Agnkor) ៨២
- អាជ្ញាធរជាតិអប្សសារាប្រារព្ធពិធីសូត្រមន្ត បង្សុកូល រាប់បាត្រ ចម្រើនសិរីសួស្តីអបអរឱកាសបុណ្យចូលឆ្នាំថ្មី! ៨៦
- អាជ្ញាធរជាតិអប្សរា និងក្រសួងសាធារណការ និងដឹកជញ្ជូន ប្រជុំពិភាក្សាលើគម្រោងធ្វើផ្លូវវាងសៀមរាបប៉ែកខាងជើង ៩៣
- អាជ្ញាធរជាតិអប្សរានិងគណៈប្រតិភូក្រសួងទេសចរណ៍ចុះសួរសុខទុក្ខនាយទាហាន និងពលទាហាននៃកងយោធភូមិភាគទី៤ ..... ៩៤
- អាជ្ញាធរជាតិអប្សរាសហការជាមួយរដ្ឋបាលខេត្តសៀមរាប សហភាពសហព័ន្ធយុវជនកម្ពុជា ខេត្តសៀមរាប

រៀបចំព្រឹត្តិការណ៍សៀមរាបសង្ក្រាន្តនៅបរិវេណព្រះអង្គចេកព្រះអង្គចម ៩៧

- សកម្មភាពភ្នាក់ងារទេសចរណ៍នៃអាជ្ញាធរជាតិអប្សរាបានជួយសង្គ្រោះភ្ញៀវ
  និងប្រគល់សម្ភារៈជូនភ្ញៀវទេសចរក្នុងត្រីមាសទី១ឆ្នាំ២០១៩ ..... ១០២
- អ្នកជំនាញការអាជីវកម្មនៃគណៈកម្មាធិការអាយស៊ីស៊ី-អង្គរ
  ចុះពិនិត្យតាមការដ្ឋាននៃគម្រោងអភិរក្សនិងអភិវឌ្ឍន៍ដោយយថីរភាពនៃរមណីយដ្ឋានអង្គរមុនកិច្ចប្រជុំ ១៣០
- អាជ្ញាធរជាតិអប្សរាចូលរួមគោរពវិញ្ញាណក្ខន្ធសពឯកឧត្តម ចៅ សែន សមាជិកក្រុមប្រឹក្សាខេត្តសៀមរាប ១៣៧
- មជ្ឈមណ្ឌលបណ្តុះបណ្តាលអង្គរ ចូលរួមទិវាពិព័រណ៌ការងារតម្រង់ទិសអាជីព (Career Fair)
  លើកទី២ ក្នុងឆ្នាំក្នុងឆ្នាំ ២០១៩ ..... ១៤០
- អាជ្ញាធរជាតិអប្សរាប្រជុំត្រួតពិនិត្យវឌ្ឍនភាពផែនការសកម្មភាពការងារឆ្នាំ២០១៩ ..... ១៤៧
- គណៈកម្មាធិការអាយស៊ីស៊ី-អង្គរប្រជុំបច្ចេកទេសលើកទី៣២ នៅទីស្នាក់ការអាជ្ញាធរជាតិអប្សរា ១៤៩
- លោកជំទាវ ភឿង សកុណាៈ គ្មានជោគជ័យពីក្រៅណាមួយកើតឡើង
  ដោយគ្មានជោគជ័យពីផ្ទៃក្នុងខ្លួនឯងនោះឡើយ! ១៥០
- លោកជំទាវ ភឿង សកុណា កោតសរសើរចំពោះលទ្ធផលផ្លូវការនៃកិច្ចប្រជុំអាយស៊ីស៊ី-អង្គរលើកទី៣២ ..... ១៥១
- សារលិខិតថ្វាយព្រះពរ សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ
  ព្រះវររាជមាតាជាតិខ្មែរក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល ១៥៥
- អាជ្ញាធរជាតិអប្សរាបើកកិច្ចប្រជុំក្រុមប្រឹក្សាកិបាលអាណត្តិទី៤ លើកទី៤ ..... ១៦៣
- អាជ្ញាធរជាតិអប្សរាធ្វើការកែសម្រួលភារកិច្ចមន្ត្រីនៅតាមមូលដ្ឋាន ១៧២
- ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរាបើកកិច្ចប្រជុំតាមដានអនុសាសន៍ដែលត្រូវអនុវត្តនៅតាមការដ្ឋានក្នុងតំបន់អង្គរ ១៧៤

ផ្នែកទី ២
កិច្ចសហប្រតិបត្តិការអន្តរជាតិ

- អាជ្ញាធរជាតិអប្សរានិងសាកលវិទ្យាល័យ Cornell បន្តពង្រឹងទំនាក់ទំនង
  ផ្នែកសិល្បៈវប្បធម៌និងបុរាណវិទ្យាដើម្បីឱ្យនិស្សិតបានស្វែងយល់អំពីវប្បធម៌-អរិយធម៌ខ្មែរ ១
- អាជ្ញាធរជាតិអប្សរាទទួលជួបពិភាក្សាការងារជាមួយសាកលវិទ្យាល័យ Fudan
  នៃសាធារណៈរដ្ឋប្រជាមានិតចិន លើវិស័យបណ្តុះបណ្តាលធនធានមនុស្សនិងអភិរក្សបេតិកភណ្ឌ ១២
- ភូមិធម្មជាតិរុនតាឯកទទួលបានអគារសិក្សាថ្មីមួយខ្នងពីអង្គការ
  ARK Beautiful Earth of Children នៃប្រទេសជប៉ុន ១៥
- រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងទេសចរណ៍នៃសាធារណរដ្ឋប្រជាមានិតចិនទស្សនកិច្ចរមណីយដ្ឋានអង្គរ ១៩
- អាជ្ញាធរជាតិអប្សរាសហការជាមួយសាកលវិទ្យាល័យជាតិគួរូនគូ
  ធ្វើកំណាយស្រាវជ្រាវខឿនព្រះវិហារពុទ្ធសាសនានៅអង្គរធំ ២២
- ជនជាតិបារាំងស្ម័គ្រចិត្តប្រគល់ភាជន៍បុរាណចំនួនពីរ
  ឱ្យអាជ្ញាធរជាតិអប្សរាក្រោយរក្សាទុកអស់រយៈពេល១៥ឆ្នាំ ៨៨

- គណៈប្រតិភូអាជ្ញាធរជាតិអប្សរាចូលរួមសិក្ខាសាលាអន្តរជាតិលើគម្រោងជួសជុលស្ពានហាលអង្គរ.....៤៨
- អាជ្ញាធរជាតិអប្សរាទទួលបានពានរង្វាន់បេតិកកណ្ឌអង្គរគ្មានផ្សេងបារី ពីសម្ពន្ធត្រួតពិនិត្យថ្នាំជក់អាស៊ីអាគ្នេយ៍ និងអង្គការសុខភាពពិភពលោកប្រចាំអាស៊ីប៉ាស៊ីហ្វិក ៥២
- អគ្គនាយកអាជ្ញាធរជាតិអប្សរាចូលរួមពិព័រណ៍សប្តាហ៍បារាំង.....៦១
- ពិព័រណ៍សិល្បៈចិនស្នើខ្ចីបដិមាពីប្រាសាទតាកែវនិងប្រាសាទចៅសាយទេវតាយកទៅតាំងពិព័រណ៍នៅប្រទេសចិន.....៦៥
- ចេក ម៉ា មហាសេដ្ឋីស្រុកចិនមកទស្សនាអង្គរទាំងអារម្មណ៍អស្ចារ្យនិងក្តីគោរព.....៦៦
- ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរានិងលេខាធិការវិទ្យាសាស្ត្រអចិន្ត្រៃយ៍នៃគណៈកម្មាធិការអាយស៊ីស៊ី-អង្គរ ចុះពិនិត្យនិងផ្លាស់ប្តូរយោបល់គម្រោងផ្សេងៗក្នុងរមណីយដ្ឋានអង្គរ ៧៣
- ប្រធានាធិបតីសាធារណៈរដ្ឋកូរ៉េមកបំពេញទស្សនកិច្ចនៅតំបន់រមណីដ្ឋានអង្គរ ៧៥
- សាកលវិទ្យាល័យសូហ្វីយ៉ា ប្តេជ្ញាជួយជ្រោមជ្រែងអាជ្ញាធរជាតិអប្សរាក្នុងកិច្ចអភិរក្សប្រាសាទក្នុងតំបន់អង្គរ.....១០១
- លោកជំទាវ អោង សានស៊ូជី (Aung San Suu Kyi) ទីប្រឹក្សារដ្ឋនៃសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា អញ្ជើញទស្សនកិច្ចនៅរមណីយដ្ឋានអង្គរ.....១០៧
- អគ្គនាយកអាជ្ញាធរជាតិអប្សរានិងតំណាងស្ថានទូតបារាំងចុះពិនិត្យការដ្ឋានជួសជុលប្រាសាទមេបុណ្យខាងលិច ១១១
- សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជាស្វែងរកកិច្ចសហប្រតិបត្តិការអំពីការគ្រប់គ្រងសំណល់រឹងនិងទឹកកខ្វក់នៅរមណីយដ្ឋានអង្គរជាមួយអាជ្ញាធរជាតិអប្សរា ១១២
- អគ្គនាយកអាជ្ញាធរជាតិអប្សរាថ្វាយព្រះពរចៅអធិរាជជប៉ុន នៅស្ថានឯកអគ្គកុងស៊ុលជប៉ុនប្រចាំខេត្តសៀមរាប .១១៣
- អាជ្ញាធរជាតិអប្សរានិងស្ថាប័ន Dunhuang Academy ចុះអនុស្សារណៈយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការអន្តរជាតិជាមិត្តភាពនិងផ្សព្វផ្សាយពីរមណីយដ្ឋានប្រវត្តិសាស្ត្រ ១១៥
- ព្រះមហាក្សត្រកម្ពុជាយាងចូលរួមពិធីអបអរសាទរ២៥ឆ្នាំនៃការចូលរួមរបស់កម្ពុជា-បារាំងនិងសហគមន៍អន្តរជាតិលើកិច្ចការអភិរក្សនិងអភិវឌ្ឍន៍រមណីយដ្ឋានអង្គរ ១១៩
- គណៈប្រតិភូក្រសួងវប្បធម៌ និងទេសចរណ៍នៃសាធារណរដ្ឋប្រជាមានិតចិនបំពេញទស្សនកិច្ច នៅតំបន់រមណីយដ្ឋានអង្គរ.....១៣៦
- ឯកអគ្គរដ្ឋទូតញូវហ្សេឡែនអញ្ជើញពិនិត្យលទ្ធផលគម្រោងកិច្ចសហប្រតិបត្តិការរវាងអាជ្ញាធរជាតិអប្សរានិងរដ្ឋាភិបាលញូវហ្សេឡែន ១៤៣
- អង្គការមូលនិធិប្រាសាទពិភពលោកប្រារព្ធខួប៣០ឆ្នាំនៃកិច្ចសហប្រតិបត្តិការជួសជុលប្រាសាទក្នុងរមណីយដ្ឋានអង្គរ ១៤៤
- សិក្ខាកាម៤ប្រទេសក្នុងតំបន់អាស៊ានចូលរួមសិក្ខាសាលាស្តីអំពី«យុវជននិងការគ្រប់គ្រងបេតិកភណ្ឌវប្បធម៌» .. ១៥២
- អគ្គនាយកអាជ្ញាធរជាតិអប្សរាអនុញ្ញាតឱ្យលោក Atsushi Yazaki ប្រធានអង្គការសិល្បៈសហសម័យជប៉ុន ចូលជួបសម្តែងការគួរសម ១៦៩

ផ្នែកទី ៣

ការអភិរក្ស និងជួសជុល

- កុលាលភាជន៍សម័យអង្គរចំនួនមួយត្រូវបានប្រគល់ជូនអាជ្ញាធរជាតិអប្សរារក្សាទុក ២៩
- ប្រាសាទមេបុណ្យខាងលិចកំពុងត្រូវបានបន្តជួសជុលឡើងវិញ ៣៣
- ការចូលរួមរបស់ព្រះសង្ឃវត្តលលៃក្នុងការងារសម្បត្តិបេតិកភណ្ឌ ៣៨
- អាជ្ញាធរជាតិអប្សរាកំពុងជួសជុលច្រាំងកសិន្ទុប្រាសាទអង្គរវត្តក្បាប់ចន្លោះគម្រោងរបស់អ៊ីតាលី និងគម្រោងជំហានដំបូងរបស់អាជ្ញាធរជាតិអប្សរា ៩១
- លោក លឹម គង់៖ មួយជីវិតខ្ញុំគឺដើម្បីការងារអភិរក្សជួសជុល និងសង្គ្រោះប្រាសាទខ្មែរឱ្យល្អដូចពីបុរាណ! ១១៨
- សកម្មភាពសម្អាតស្លែក្នុងកសិន្ទុប្រាសាទអង្គរវត្ត ១២៧
- ប្រវត្តិនៃការជួសជុលតារាជ ១៥៩

ផ្នែកទី ៨
ការគ្រប់គ្រងបរិស្ថាន ទឹក និងព្រៃឈើ

- សេចក្តីជូនដំណឹងស្តីពី ការកាត់ដកហូតដើមឈើ និងកាត់ក្រឹមែកឈើ ដែលមានហានិភ័យខ្ពស់នៅតាមបរិវេណប្រាសាទ ក្នុងរមណីយដ្ឋានអង្គរ ១៨
- សេចក្តីជូនដំណឹងស្តីពី ការកាត់ដកហូតដើមឈើ និង កាត់ក្រឹមែកឈើ ដែលមានហានិភ័យខ្ពស់នៅតាមបរិវេណប្រាសាទ ក្នុងរមណីយដ្ឋានអង្គរ ២៨
- អាជ្ញាធរជាតិអប្សរាកំពុងបូមទឹកបញ្ចូលក្នុងស្រះប្រាសាទអង្គរវត្ត ២៨
- សេចក្តីជូនដំណឹងស្តីពីការកាត់ដកហូតដើមឈើនិងកាត់ក្រឹមែកឈើ ដែលមានហានិភ័យខ្ពស់នៅតាមបរិវេណប្រាសាទ ក្នុងរមណីយដ្ឋានអង្គរ ៤២
- តំបន់អង្គរអាចនឹងប្រឈមបញ្ហាកង្វះទឹកនារដូវប្រាំងឆ្នាំនេះ ៤៣
- កសិន្ទុប្រាសាទអង្គរវត្តកំពុងបញ្ចូលទឹកឱ្យបានច្រើន ៤៦
- សេចក្តីជូនដំណឹងស្តីពីការកាត់ដកហូតដើមឈើនិងកាត់ក្រឹមែកឈើ ដែលមានហានិភ័យខ្ពស់នៅតាមបរិវេណប្រាសាទ ក្នុងរមណីយដ្ឋានអង្គរ ៥៩
- សេចក្តីជូនដំណឹងស្តីពីការកាត់ដកហូតដើមឈើ កាត់ដកហូតដើមឈើពាក់កណ្តាលដើមនិងកាត់ក្រឹមែកឈើ ដែលមានហានិភ័យខ្ពស់នៅតាមបរិវេណប្រាសាទ ក្នុងរមណីយដ្ឋានអង្គរ ៦០
- សេចក្តីជូនដំណឹង ស្តីពីការកាត់ដកហូតដើមឈើ កាត់ដកហូតដើមឈើពាក់កណ្តាលដើមនិងកាត់ក្រឹមែកឈើ ដែលមានហានិភ័យខ្ពស់នៅតាមបរិវេណប្រាសាទ ក្នុងរមណីយដ្ឋានអង្គរ ៦២
- សេចក្តីជូនដំណឹងស្តីពី ការកាត់ដកហូតដើមឈើនិងកាត់ក្រឹមែកឈើ ដែលមានហានិភ័យខ្ពស់នៅតាមបរិវេណប្រាសាទ ក្នុងរមណីយដ្ឋានអង្គរ ៦៣
- សេចក្តីជូនដំណឹងស្តីពី ការកាត់ដកហូតដើមឈើនិង កាត់ក្រឹមែកឈើ ដែលមានហានិភ័យខ្ពស់នៅតាមបរិវេណប្រាសាទ ក្នុងរមណីយដ្ឋានអង្គរ ៦៩
- អាជ្ញាធរជាតិអប្សរាស្តារស្ទឹងព្រះស្រុកឡើងវិញដើម្បីរក្សាកំណើនទឹកនិងបញ្ចៀសទឹកជំនន់ ៧៣
- កសិន្ទុប្រាសាទអង្គរវត្តនៅតែរក្សាបានតុល្យភាពទឹក បើទោះបីជួបប្រទះអាកាសធាតុក្តៅខ្លាំងនារដូវប្រាំង! ៨១

- អ្នកជំនាញស្នើឱ្យមានការចូលរួមពីប្រជាពលរដ្ឋដើម្បីថែរក្សារក្សាព្រៃឈើក្នុងតំបន់រមណីយដ្ឋានអង្គរ ៨៣
- សេចក្តីជូនដំណឹងស្តីពីការកាត់ដកហូតដើមឈើនិងកាត់ក្រឹមែកឈើ ដែលមានហានិភ័យខ្ពស់នៅ តាមបរិវេណប្រាសាទ ក្នុងរមណីយដ្ឋានអង្គរ ៨៩
- អាជ្ញាធរជាតិអប្សរាផ្តល់ទឹកបន្ថែមដល់រដ្ឋាករទឹកស្វយ័តស្រុកពួក ១០៤

- សេចក្តីជូនដំណឹងស្តីពី ការកាត់ដកហូតដើមឈើ កាត់ដកហូតដើមឈើពាក់កណ្តាលដើមនិងកាត់ក្រឹមែកឈើ ដែលមានហានិភ័យខ្ពស់នៅតាមបរិវេណប្រាសាទ ក្នុងរមណីយដ្ឋានអង្គរ ១០៨
- សេចក្តីជូនដំណឹងស្តីពី ការកាត់ដកហូតដើមឈើ កាត់ដកហូតដើមឈើពាក់កណ្តាលដើមនិងកាត់ក្រឹមែកឈើ ដែលមានហានិភ័យខ្ពស់នៅតាមបរិវេណប្រាសាទក្នុងរមណីយដ្ឋានអង្គរ ១១៨
- សកម្មភាពសម្អាតស្មៅ និងរុក្ខជាតិតូចៗនៅតាមប្រាសាទក្នុងតំបន់អង្គរ ១២០
- កូនឈើប្រមាណ៣ម៉ឺនដើមត្រូវបានដាំក្នុងឧទ្យានអង្គរជារៀងរាល់ឆ្នាំ ១២១
- អាជ្ញាធរជាតិអប្សរាអំពាវនាវដល់សាធារណជនចូលរួមក្នុងយុទ្ធនាការដាំដើមឈើក្នុងតំបន់រមណីយដ្ឋានអង្គរ ១៣៨
- ដើមឈើចំនួន ២០០០ដើមត្រូវបានដាំឡើងវិញក្នុងតំបន់រមណីដ្ឋានអង្គរ ១៤៥
- អាជ្ញាធរជាតិអប្សរាស្នើសុំប្រជាជនកុំកាប់ដើមឈើក្នុងតំបន់អង្គរដោយគ្មានការអនុញ្ញាត ១៦១
- សេចក្តីជូនដំណឹងស្តីពី ការកាត់ដកហូតដើមឈើ កាត់ដកហូតដើមឈើពាក់កណ្តាលដើម និងកាត់ក្រឹមែកឈើដែលមានហានិភ័យខ្ពស់នៅ តាមបរិវេណប្រាសាទក្នុងរមណីយដ្ឋានអង្គរ ១៦៨
- អាជ្ញាធរជាតិអប្សរាប្រគល់កូនឈើចំនួន៥០០០ដើមជូនមន្ទីរបរិស្ថានខេត្តសៀមរាប ១៧៥

ផ្នែកទី ៥
ការបណ្តុះបណ្តាល

- អ្នកជំនាញអភិរក្សជាតិ-អន្តរជាតិកំពុងយកចិត្តទុកដាក់ពង្រឹងសមត្ថភាព ក្រុមការងារជួសជុលព្រះពុទ្ធរូបពីរអង្គសម័យក្រោយអង្គរនៅប្រាសាទប្រែរូប ៧
- មជ្ឈមណ្ឌលបណ្តុះបណ្តាលអង្គរចូលរួមតាំងពិព័រណ៍ការងារអប់រំឆ្នាំ២០១៩ ..... ៣២
- សិស្សានុសិស្សនៅឃុំបាគងប្រមាណជិត ១០០នាក់ នឹងទទួលបានការបណ្តុះបណ្តាលពិសេសលើវិស័យអប់រំបេតិកភណ្ឌ ៨៧
- សិស្សសាលាបឋមសិក្សា ហ៊ុន សែន ស្រះស្រង់ ស្វែងយល់ពីប្រវត្តិសមុច្ច័យបុរាណនៅសារមន្ទីរព្រះនរោត្តម សីហនុ-អង្គរ ៥៦
- សិស្សវិទ្យាល័យ ហ៊ុន សែន ប្រាសាទបាគង ចាប់ផ្តើមទទួលចំណេះដឹងពីការអប់រំបេតិកភណ្ឌពីអាជ្ញាធរជាតិអប្សរា ៦៤
- មន្ត្រីបុគ្គលិកអាជ្ញាធរជាតិអប្សរា២០នាក់បានបញ្ចប់វគ្គបណ្តុះបណ្តាល ស្តីការធ្វើអង្កេតសាធារណៈក្នុងរមណីយដ្ឋានអង្គរ ៨៧
- មន្ត្រី-បុគ្គលិកនៃនាយកដ្ឋានផ្សព្វផ្សាយទទួលការបណ្តុះបណ្តាលលើជំនាញថតរូប ៩៥
- អាជ្ញាធរជាតិអប្សរាបិទវគ្គអប់រំបរិស្ថានកុមារក្នុងរមណីយដ្ឋានអង្គរ ១២៦

- មន្ត្រី-បុគ្គលិកជំនាញនៃអាជ្ញាធរជាតិអប្សរា និងអាជ្ញាធរជាតិព្រះវិហារ ធ្វើការផ្លាស់ប្តូរបទពិសោធន៍ការងារទៅវិញទៅមក ១២៩
- មន្ត្រី-បុគ្គលិកជំនាញគ្រប់គ្រងបេតិកកណ្ឌពិភពលោកតំបន់អង្គរ និងព្រះវិហារ បានបញ្ចប់ទស្សនកិច្ចសិក្សាដោយជោគជ័យ ១៣១
- សារមន្ទីរវាយនកណ្ឌប្រពៃណីអាស៊ី បើវគ្គបណ្តុះបណ្តាលស្តីអំពីការអភិរក្សវាយនកណ្ឌ ១៣៣
- មន្ត្រី-បុគ្គលិកនៃអាជ្ញាធរជាតិអប្សរា១០រូប បានបិទវគ្គបណ្តុះបណ្តាល English Fellow Program ដោយជោគជ័យ ១៤៨
- បាឋកថាអំពី «សមុច្ច័យពុម្ពចម្លាក់និងប្រាសាទខ្មែរដែលបានតាំងនៅសារមន្ទីរសិល្បៈអាស៊ី Guimet ៖ មណ្ឌលសម្រាប់ការងារអភិរក្សបេតិកកណ្ឌទៅអនាគត ? » ១៥៣
- សៀវភៅផាត់ពណ៌បេតិកកណ្ឌទី៣នឹងលេចរូបរាងសម្រាប់សិស្សអនុវត្តក្នុងពេលឆាប់ៗនេះ ១៥៨
- សិក្ខាសាលាផ្លាស់ប្តូរបទពិសោធន៍គ្រប់គ្រងបេតិកកណ្ឌរវាងយុវជន៤ប្រទេសបានបិទបញ្ចប់ដោយជោគជ័យ ១៦៥
- អ្នកជំនាញអភិរក្សប្រាសាទបុរាណខ្មែរ ចែករំលែកបទពិសោធន៍និងចំណេះដឹងអំពីការជួសជុល និងអភិរក្សប្រាសាទឥដ្ឋបុរាណដល់អ្នកជំនាញថៃ ១៧០
- បង្គាន់ដៃនាគដែលលម្អដោយអសុរនិងទេវតា នៅក្លោងទ្វារដីឆ្នាំងកំពុងទទួលបានការជួសជុលពីអ្នកជំនាញអាជ្ញាធរជាតិអប្សរា ១៧១

ផ្នែកទី ៦
ការសិក្សាស្រាវជ្រាវ

- សេចក្តីជូនដំណឹងស្តីពីការធ្វើកំណាយបុរាណវិទ្យានៅស្រះខាងជើងប្រាអង្គរវត្ត ៣៩
- អ្នកជំនាញអះអាងថាដើមធ្លកប្រទះឃើញនៅបាតប្រាសាទភិមានអាកាស បញ្ជាក់ថារឿងព្រេងនគរគោកធ្លកមានកំណើតនៅអង្គរ ៧០
- គម្រោងស្រាវជ្រាវនៅប្រាសាទអកយំរកឃើញខឿនប្រាសាទដែលកប់ក្នុងទំនប់ខាងត្បូងបារាយណ៍ខាងលិច ១០០
- បង្ហៈទឹកស្រះខាងជើងប្រាសាទអង្គរវត្តដើម្បីធ្វើកំណាយស្រាវជ្រាវបុរាណវិទ្យា ១០៩

ផ្នែកទី ៧
ការអភិវឌ្ឍទេសចរណ៍

- សេចក្តីជូនដំណឹងស្តីពី ការផ្អាកចរាចរណ៍លើកំណាត់ផ្លូវកូម៉ែ ចាប់ពីចំណុចខាងមុខវត្តទេពពោធិវង្សហៅវត្តថ្មី រហូតដល់បញ្ជរត្រួតពិនិត្យប័ណ្ណចូលទស្សនាតំបន់អង្គរ ផ្នែកខាងត្បូងកសិណអង្គរវត្តជាបណ្តោះអាសន្ន ៨៥
- អាជ្ញាធរជាតិអប្សរាកំពុងដំណើរការជួសជុលផ្លូវស្វាយធំប្រវែងជាង ១៤គីឡូម៉ែត្រ ៥១
- អាជ្ញាធរជាតិអប្សរាកំពុងរៀបចំកែសម្រួលផ្លូវថ្មើរជើងតូចៗក្នុងបរិវេណប្រាសាទអង្គរវត្តឡើងវិញ ៦៧
- ប្រជាពលរដ្ឋសាទរចំពោះសមិទ្ធផលផ្លូវក្រហមដែលអាជ្ញាធរជាតិអប្សរាបានជួសជុលនៅបារាយណ៍ខាងលិច ៨៥
- ផ្លូវស្រះស្រង់ប្រវែងមួយគីឡូម៉ែត្រត្រូវបានអជ្ញាធរជាតិអប្សរាកំពុងជួសជុលកែលម្អ ៩០

- ផ្លូវវង់ធំកាន់តែមានភាពងាយស្រួលក្នុងការធ្វើដំណើរ ៩០
- ផ្ទាំងស្លាកឈ្មោះប្រាសាទចំនួន១១៨ផ្ទាំង កំពុងដំឡើងក្នុងរមណីយដ្ឋានអង្គរ.....៩៦
- ការថែទាំនិងជួសជុលផ្លូវថ្នល់ជាការរួមចំណែកយ៉ាងសំខាន់ក្នុងការលើកតម្លៃរមណីយដ្ឋានអង្គរ ៩៨
- អាជ្ញាធរជាតិអប្សរាជួយសង្គ្រោះភ្ញៀវដួលសន្លប់នៅប្រាសាទអង្គរវត្ត ១១៦

ផ្នែកទី ៨
ការអភិវឌ្ឍសហគមន៍

- អាជ្ញាធរជាតិអប្សរាផ្តល់ថវិកាបដិភាគសង់បង្គន់អនាម័យដល់ប្រជាពលរដ្ឋរស់នៅក្នុងតំបន់រមណីយដ្ឋានអង្គរ ៨
- អាជ្ញាធរជាតិអប្សរាអនុវត្តសាកល្បងគម្រោងចម្រោះទឹកកខ្វក់ ចេញពីបង្គន់តាមផ្ទះប្រជាពលរដ្ឋក្នុងរមណីយដ្ឋានអង្គរ..... ១១
- ឆ្នាំ២០១៨ អាជ្ញាធរជាតិអប្សរាផ្តល់ការអនុញ្ញាតជួសជុលកែលម្អលំនៅដ្ឋាន និងសាងសង់សំណង់ស្រាលតូចតាចដល់អ្នកស្រុកអង្គរចំនួន២១៥៩គ្រួសារ..... ២០
- អាជ្ញាធរជាតិអប្សរាកំពុងមមាញឹកក្នុងការជួសជុលផ្លូវសំខាន់ៗក្នុងតំបន់រមណីយដ្ឋានអង្គរ ២១
- អាជ្ញាធរជាតិអប្សរាបានផ្តល់ការអនុញ្ញាតជួសជុលកែលម្អលំនៅដ្ឋាន ដល់អ្នកស្រុកអង្គរចំនួន៨៥គ្រួសារ នៅខែមេសាឆ្នាំ២០១៩ ..... ១១០
- អាជ្ញាធរជាតិអប្សរាដង្ហែរផ្តើរប្រាក់សាមគ្គីចូលរួមកសាងកុដិនិង សមិទ្ធផលនានាក្នុងវត្តប្រាសាទលលៃ..... ១២៣
- ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាអនុញ្ញាតជួសជុលកែលម្អ និងតសំយ៉ាបមុខផ្ទះចំនួន១៩ករណីដល់ប្រជាជនក្នុងតំបន់អង្គរ..... ១២៤
- រយៈពេល៥ខែដើមឆ្នាំ២០១៩ ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរា បានអនុញ្ញាតការជួសជុលផ្ទះរបស់ប្រជាពលរដ្ឋបានជាង ៦០០ករណី..... ១២៨
- អ្នកជំនាញការអាជ្ញាធរជាតិអប្សរាស៊ីស៊ី-អង្គរ ចាត់ទុកការសម្រេចព្រះទ័យ របស់ព្រះសង្ឃវត្តលលៃជាការចូលរួមចំណែកដ៏គួរឱ្យគោរពនិងយកគំរូតាមក្នុងកិច្ចការបេតិកភណ្ឌ..... ១៣២
- អាជ្ញាធរជាតិអប្សរាផ្តល់ច្បាប់អនុញ្ញាតរុះរើផ្ទះចាស់ សាងសង់ផ្ទះថ្មីចំនួន៣៥ករណី នៅរមណីយដ្ឋានអង្គរ ក្នុងខែឧសភា ឆ្នាំ២០១៩..... ១៣៤
- អាជ្ញាធរជាតិអប្សរានឹងរៀបចំសណ្តាប់ធ្នាប់តូបលក់ដូរនៅមុខប្រាសាទព្រះពិធូរ..... ១៣៦
- អ្នកជំនាញការនៃគណៈកម្មាធិការអាយស៊ីស៊ី-អង្គរចុះពិនិត្យសកម្មភាពកសាងផ្លូវឡើងភ្នំគូលែន..... ១៤២
- អាជ្ញាធរជាតិអប្សរា៖ សូមដាក់ច្បាប់ស្នើសុំដើម្បីកែលម្អផ្ទះ សាងសង់តូចតាច ចាក់ជីរុះរើផ្ទះចាស់សង់ផ្ទះថ្មីក្នុងតំបន់អង្គរ..... ១៦៤
- ស្ពានឈើប្រវែង២១៥ម៉ែត្រនៅប្រាសាទបេងមាលា បានស្ថាបនារួចជាស្ថាពរ!..... ១៦៦

ផ្នែកទី ៩
ទំនៀមទម្លាប់អ្នកស្រុកអង្គរ

- ការបន្តវេនពីដូនតាក្នុងការធ្វើធូបលក់របស់អ្នកស្រុកអង្គរ..... ២៥
- អ្នកភូមិបង្កោងរៀបចំពិធីរកត្រីរួមដើម្បីត្រៀមឡើងមាឃនៅថ្ងៃ៣កើត..... ២៦
- ឡើងមាឃ ឬ ឡើងអ្នកតា ទំនៀមបុរាណដែលបញ្ជាក់ពីការចាប់ផ្តើមវដ្តថ្មីនៃរដូវកសិកម្ម ៤០

ផ្នែកទី ១០
ចំណេះដឹងទូទៅអំពីបេតិកភណ្ឌ

- ការទិញ-លក់ដីធ្លីក្នុងតំបន់រមណីយដ្ឋានអង្គរគឺខុសច្បាប់ ៣០
- អាជ្ញាធរជាតិអប្សរាសហការជាមួយសាលាក្រុង
  បានចុះរុះរើសំណង់របងខុសច្បាប់មួយកន្លែងនៅភូមិសាលាកន្សែង ៣៥
- ឆ្នាំ២០១៨ អាជ្ញាធរជាតិអប្សរាបានរកឃើញនិងប្រគល់សម្ភារៈជូនភ្ញៀវទេសចរវិញចំនួន២៤៥ករណី ៣៦
- ព្រឹត្តិការណ៍សមរាត្រីឆ្នាំ២០១៩មកដល់ទៀតហើយ ៧៦
- ព្រឹត្តិការណ៍ព្រះអាទិត្យរះចំកំពូលប្រាសាទអង្គរវត្តមិនធ្វើឱ្យអ្នកទស្សនាខកបំណង! ៧៨
- កម្រងរូបភាពការប្រារព្ធពិធីបុណ្យវិសាខបូជានៅបរិវេណប្រាសាទអង្គរវត្ត ១២៣
- បុគ្គលដែលប្រកាសលក់ដូរដីធ្លីក្នុងតំបន់រមណីយដ្ឋានអង្គរដែលជាបេតិកភណ្ឌពិភពលោក
  អាចនឹងប្រឈមវិធានការផ្លូវច្បាប់ប្រសិនបើមិនបញ្ឈប់! ១៥៦



ផលិតដោយនាយកដ្ឋានផ្សព្វផ្សាយ
ឆ្នាំ២០១៩

តើប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់អង្គរមានសិទ្ធិអ្វីខ្លះលើដីធ្លីរបស់ខ្លួន?

១ ប្រជាពលរដ្ឋដែលមានលំនៅដ្ឋាន និងរស់នៅយូរលង់មកហើយ អាចបន្តរស់នៅតទៅទៀតបាន ដោយមិនមានការដេញឱ្យចាកចេញពីភូមិដ្ឋានឡើយ ។

២ ប្រជាពលរដ្ឋអាចរុះរើផ្ទះចាស់ទ្រុឌទ្រោម ឬសាងសង់ថ្មីជំនួសផ្ទះចាស់បាន ដោយមានការសុំអនុញ្ញាតពីសមត្ថកិច្ចនៃអាជ្ញាធរជាតិអប្សរា ។

៣ ប្រជាពលរដ្ឋមានសិទ្ធិគ្រប់គ្រង និងចាត់ចែងដីធ្លីតាមរូបភាពដូចជា ផ្ទេរមរតក ទៅឱ្យញាតិសន្តានពីឪពុកម្តាយទៅកូន ក្មួយ ឬលក់ដូរឱ្យអ្នកភូមិផងជាមួយគ្នា ដើម្បីដោះស្រាយជីវភាព ប៉ុន្តែហាមឃាត់លើសកម្មភាពទិញ-លក់ដីរបស់ឈ្មួញក្នុងគោលដៅធ្វើអាជីវកម្មយកចំណេញសម្រាប់ក្រុមហ៊ុន ឬបុគ្គល ឬការទិញ-លក់ដី សម្រាប់យកទៅសាងសង់សណ្ឋាគារ កោជនីដ្ឋាន ខាអ៉ាអូខេ ជាដើម។ល។